មានសេចក្តីខ្មាសបាប បរិបូណ៌ដោយសេចក្តីអាណិតអាសូរ ជាអ្នកអនុគ្រោះដោយប្រយោជន៍ដល់សត្វមានជីវិតទាំងអស់ លះបង់នូវអទិន្នាទាន ជាអ្នកវៀរចាកអទិន្នាទាន កាន់យកតែវត្ថុដែលគេឲ្យ ចង់បានតែវត្ថុដែលគេឲ្យ មិនមែនជាមនុស្សលួច មានខ្លួនដ៏ស្អាត លះបង់អព្រហ្មចរិយៈ ជាអ្នកប្រព្រឹត្តធម៌ដ៏ប្រសើរ ជាអ្នកប្រព្រឹត្តឆ្ងាយ វៀរចាកមេថុនធម្ម ដែលជាធម៌របស់អ្នកស្រុក លះបង់មុសាវាទ ជាអ្នកវៀរចាកមុសាវាទ ជាអ្នកនិយាយតែពាក្យពិត តពាក្យពិត មានសំដីទៀងទាត់ និយាយពាក្យដែលគេគប្បីជឿ មិនបានពោលបំភាន់ដល់សត្វលោក លះបង់បិសុណវាចា ជាអ្នកវៀរចាកបិសុណវាចា ឮអំពីទីនេះ មិនបានយកទៅនិយាយប្រាប់ក្នុងទីឯណោះ ដើម្បីបំបែកជនទាំងឡាយនេះ ឬឮអំពីទីឯណោះ មិនបានយកមកប្រាប់ដល់ជនទាំងឡាយនេះ ដើម្បីបំបែកជនទាំងឡាយឯណោះ ជាអ្នកផ្សះផ្សាពួកជនដែលបែកបាក់គ្នាហើយ ឬឲ្យកម្លាំងថែមដល់ពួកជនដែលបានជានឹងគ្នាហើយ ជាអ្នកពេញចិត្តនឹងការព្រមព្រៀងគ្នា ត្រេកអរនឹងការព្រមព្រៀងគ្នា រីករាយតែក្នុងសេចក្តីព្រមព្រៀងគ្នា ជាអ្នកនិយាយតែពាក្យ ដែលធ្វើឲ្យកើតសេចក្តីព្រមព្រៀងគ្នា

ផរុសំ វាចំ បហាយ ផរុសាយ វាចាយ បដិវិរតោ ហោតិ យា សា វាចា នេលា កណ្ណសុខា បេមនីយា ហទយង្គមា បោរី ពហុជនកន្តា ពហុជនមនាបា តថារូបឹ វាចំ ភាសិតា ហោតិ សម្ផប្បលាបំ បហាយ សម្ផប្បលាបា បដិវិរតោ ហោតិ កាលវាទី ភូតវាទី អត្ថវាទី ធម្មវាទី វិនយវាទី និធានវតឹ វាចំ ភាសិតា កាលេន សាបទេសំ បរិយន្តវតឹ អត្ថសញ្ហិតំ ។ សោ ពីជគាមភូតគាមសមារម្ភា បដិវិរតោ ហោតិ ឯកភត្តិកោ ហោតិ រត្តូបរតោ បដិវិរតោ វិកាលភោជនា នច្ចគីតវាទិតវិសូកទស្សនា បដិវិរតោ ហោតិ មាលាគន្ធវិលេបនធារណមណ្ឌនវិភូសនដ្ឋានា បដិវិរតោ ហោតិ ឧច្ចាសយនមហាសយនា បដិវិរតោ ហោតិ ជាតរូបរជតប្បដិគ្គហណា បដិវិរតោ ហោតិ

លះបង់ផរុសវាចា ជាអ្នកវៀរចាកផរុសវាចា គឺសំដីណាមិនមានទោស នាំមកនូវសេចក្តីសុខដល់ត្រចៀក (នៃអ្នកដទៃ) ជាពាក្យគួរស្រឡាញ់ ជាពាក្យគួរគិតកល់ទុកក្នុងហឫទ័យ ជាសំដីរបស់អ្នកក្រុង ជាពាក្យជាទីត្រេកអរនៃជនច្រើនគ្នា ជាទីពេញចិត្តនៃជនច្រើនគ្នា ជាអ្នកពោលតែសំដីផ្ទោះ លះបង់សម្ផប្បលាបៈ វៀរចាកសម្ផប្បលាបៈ ជាអ្នកនិយាយពាក្យក្នុងកាលគួរ និយាយពាក្យពិត និយាយពាក្យមានប្រយោជន៍ និយាយធម៌ និយាយវិន័យ ជាអ្នកនិយាយសំដីដែលគួរគិតកល់ទុកក្នុងហឫទ័យ ជាពាក្យប្រកបដោយគ្រឿងអាង ជាពាក្យមានកំណត់ ជាពាក្យប្រកបដោយប្រយោជន៍តាមកាលគួរ ។ ភិក្ខុនោះវៀរចាកការធ្វើពីជគាមនិងភូតគាមឲ្យវិនាស ជាអ្នកបរិភោគភត្តតែ ១ ពេល វៀរចាកការបរិភោគក្នុងរាត្រី វៀរចាកបរិភោគក្នុងកាលខុស វៀរចាកការមើលនូវរបាំនិងការស្តាប់នូវចម្រៀងនិងភ្លេងប្រគំ (ជាសត្រូវដល់កុសលធម៌) វៀរចាកការទ្រទ្រង់និងការប្រដាប់ស្អិតស្អាងរាងកាយ ដោយផ្កាកម្រងនិងគ្រឿងប្រអប់និងគ្រឿងលាបផ្សេងៗ ជាអ្នកវៀរចាកទីដេកទីអង្គុយដ៏ខ្ពស់ និងទីដេក ទីអង្គុយដ៏ប្រសើរ ជាអ្នកវៀរចាកការទទួលមាសនិងប្រាក់

អាមកធញ្ញប្បដិគ្គហណា បដិវិរតោ ហោតិ អាម-
កមំសប្បដិគ្គហណា បដិវិរតោ ហោតិ ឥត្ថីកុមារិ-
កាបដិគ្គហណា បដិវិរតោ ហោតិ ទាសីទាសប្ប
ដិគ្គហណា បដិវិរតោ ហោតិ អជេឡកប្បដិគ្គហណា
បដិវិរតោ ហោតិ កុក្កុដសូករប្បដិគ្គហណា បដិវិរតោ
ហោតិ ហត្ថិគវស្សវឡវប្បដិគ្គហណា បដិវិរតោ ហោតិ
ខេត្តវត្ថុប្បដិគ្គហណា បដិវិរតោ ហោតិ ទូតេយ្យប្បហី-
ណគមនានុយោគា បដិវិរតោ ហោតិ កយវិក្កយា
បដិវិរតោ ហោតិ តុលាកូដកំសកូដមានកូដា
បដិវិរតោ ហោតិ ឧក្កោដនវញ្ចននិកតិសាចិយោគា
បដិវិរតោ ហោតិ ឆេទនវធពន្ធនវិបរាមោសអាលោប-
សហសាការា បដិវិរតោ ហោតិ ។ សោ សន្តុដ្ឋោ
ហោតិ កាយបរិហារិកេន ចីវរេន កុច្ឆិបរិហារិ-
កេន បិណ្ឌបាតេន យេន យេនេវ បក្កមតិ
សមាទាយេវ បក្កមតិ សេយ្យថាបិ នាម បក្ខី

ជាអ្នកវៀរចាកការទទួលនូវធញ្ញជាតិឆៅ វៀរចាកការទទួលសាច់ឆៅ វៀរចាកការទទួលស្រីនិងកុមារី វៀរចាកការទទួលខ្ញុំស្រីនិងខ្ញុំប្រុស វៀរចាកការទទួលពពែនិងចៀម វៀរចាកការទទួលមាន់និងជ្រូក វៀរចាកការទទួលដំរី គោ សេះ ឈ្មោល ញី វៀរចាកការទទួលស្រែនិងចំការ វៀរចាកការប្រកបទូតកម្មគឺនាំសំបុត្រ ឬពាក្យបណ្តាំនៃគ្រហស្ថ និងការទៅដោយគេប្រើអំពីផ្ទះមួយទៅផ្ទះមួយ វៀរចាកការទិញនិងការលក់ វៀរចាកការបញ្ឆោតឬបន្លំដោយជញ្ជីង បញ្ឆោតដោយភាជន៍ការឡែមាស (ជាដើម) និងការបញ្ឆោតដោយរង្វាស់រង្វាល់ វៀរចាកការប្រកបអំពើវៀច គឺបង្ខុសបំភាន់និងការបោកប្រាស និងការបន្លំដោយរបស់ក្លែង វៀរចាកការកាត់ (នូវអវយវៈមានដៃជាដើម) និងការសម្លាប់ចងលាក់ខ្លួនពួនចាំធ្វើអំពើអាក្រក់ និងការប្លន់គាំហែងយកទ្រព្យ ។ ភិក្ខុនោះ ជាអ្នកសន្តោសដោយចីវរជាគ្រឿងរក្សាកាយ ដោយបិណ្ឌបាតជាគ្រឿងរក្សាផ្ទៃ កាលបើចេញទៅក្នុងទិសណា ៗ តែងកាន់យក (តែគ្រឿងបរិក្ខារ ៨ ប៉ុណ្ណោះ) ជាប់ជាមួយនឹងខ្លួនចេញទៅ សកុណជាតិ ដែលមានស្លាប

សកុណោ យេន យេនេវ ឌេតិ សបត្តភារោវ ឌេតិ ឯវមេវ ភិក្ខុ សន្តុដ្ឋោ ហោតិ កាយបរិហារិកេន ចីវរេន កុច្ឆិបរិហារិកេន បិណ្ឌបាតេន យេន យេនេវ បក្កមតិ សមាទាយេវ បក្កមតិ ។

(១៧) សោ ឥមិនា អរិយេន សីលក្ខន្ធេន សមន្នាគតោ អជ្ឈត្តំ អនវជ្ជសុខំ បដិសំវេទេតិ ។ សោ ចក្ខុនា រូបំ ទិស្វា ន និមិត្តគ្គាហី ហោតិ នានុព្យញ្ជនគ្គាហី យត្វាធិករណមេនំ ចក្ខុន្ទ្រិយំ អសំវុតំ វិហរន្តំ អភិជ្ឈាទោមនស្សា បាបកា អកុសលា ធម្មា អន្វាស្សវេយ្យុំ តស្ស សំវរាយ បដិបជ្ជតិ រក្ខតិ ចក្ខុន្ទ្រិយំ ចក្ខុន្ទ្រិយេ សំវរំ អាបជ្ជតិ ។ សោ សោតេន សទ្ទំ សុត្វា ... ឃានេន គន្ធំ ឃាយិត្វា ... ជិវ្ហាយ រសំ សាយិត្វា ...

កាលហើរទៅក្នុងទិសណា ៗ រមែងមានតែទម្ងន់ស្លាបរបស់ខ្លួនប៉ុណ្ណោះ ហើរទៅ មានឧបមាដូចម្តេចមិញ មានឧបមេយ្យដូចភិក្ខុជាអ្នកសន្តោស ដោយចីវរជាគ្រឿងរក្សាកាយ ដោយបិណ្ឌបាតជាគ្រឿងរក្សាផ្ទៃ កាលបើចេញទៅ ក្នុងទិសណា ៗ តែងកាន់យក ( តែគ្រឿងបរិក្ខារ ៨ ប៉ុណ្ណោះ) ជាប់ជាមួយនឹងខ្លួនចេញទៅ ដូច្នោះឯង ។

(១៧) ភិក្ខុនោះបរិបូណ៌ដោយសីលក្ខន្ធដ៏ប្រសើរនេះហើយ តែងទទួលនូវសេចក្តីសុខ ដែលមិនមានទោសខាងក្នុងសន្តាន ។ ភិក្ខុនោះបានឃើញរូបដោយភ្នែក មិនកួបកាន់នូវនិមិត្ត មិនកួបកាន់នូវអនុព្យញ្ជនៈ អភិជ្ឈានិងទោមនស្ស ជាអកុសលធម៌ដ៏លាមក តែងគ្របសង្កត់ នូវបុគ្គលដែលមិនសង្រួមនូវចក្ខុន្ទ្រិយ ព្រោះហេតុតែ មិនបានសង្រួមនូវចក្ខុន្ទ្រិយណា ភិក្ខុនោះក៏ប្រតិបត្តិ ដើម្បីសង្រួមនូវចក្ខុន្ទ្រិយនោះ រក្សានូវចក្ខុន្ទ្រិយ ដល់នូវការសង្រួម ក្នុងចក្ខុន្ទ្រិយ ។ បានឮសំឡេងដោយត្រចៀក ... បានធុំក្លិនដោយច្រមុះ ... បានទទួលរសដោយអណ្តាត ...

កាយេន ផោដ្ឋព្វំ ផុសិត្វា... មនសា ធម្មំ វិញ្ញាយ ន និមិត្តគ្គាហី ហោតិ នានុព្យញ្ជនគ្គាហី យត្វាធិករណមេនំ មនិន្ទ្រិយំ អសំវុតំ វិហរន្តំ អភិជ្ឈាទោមនស្សា បាបកា អកុសលា ធម្មា អន្វាស្សវេយ្យុំ តស្ស សំវរាយ បដិបជ្ជតិ រក្ខតិ មនិន្ទ្រិយំ មនិន្ទ្រិយេ សំវរំ អាបជ្ជតិ ។

(១៨) សោ ឥមិនា អរិយេន ឥន្ទ្រិយសំវរេន សមន្នាគតោ អជ្ឈត្តំ អព្យាសេកសុខំ បដិសំវេទេតិ ។ សោ អភិក្កន្តេ បដិក្កន្តេ សម្បជានការី ហោតិ អាលោកិតេ វិលោកិតេ សម្បជានការី ហោតិ សម្មិញ្ជិតេ បសារិតេ សម្បជានការី ហោតិ សង្ឃាដិបត្តចីវរធារណេ សម្បជានការី ហោតិ អសិតេ បីតេ ខាយិតេ សាយិតេ សម្បជានការី ហោតិ ឧច្ចារបស្សាវកម្មេ សម្បជានការី ហោតិ គតេ ឋិតេ និសិន្នេ សុត្តេ ជាគរិតេ ភាសិតេ តុណ្ហីភាវេ សម្បជានការី ហោតិ ។

បានពាល់ត្រូវនូវសម្ផស្ស ដោយកាយ ... បានដឹងច្បាស់នូវធម្មារម្មណ៍ ដោយចិត្ត ក៏មិនក្តោបកាន់នូវនិមិត្ត មិនក្តោបកាន់នូវអនុព្យញ្ជនៈ អភិជ្ឈានិង ទោមនស្ស ជាអកុសលធម៌ដ៏លាមក តែងគ្របសង្កត់នូវបុគ្គលដែល មិនសង្រួមនូវមនិន្ទ្រិយ ព្រោះហេតុតែ មិនបានសង្រួមនូវមនិន្ទ្រិយណា ភិក្ខុនោះ ក៏ប្រតិបត្តិ ដើម្បីសង្រួម នូវមនិន្ទ្រិយនោះ រក្សានូវមនិន្ទ្រិយ ដល់នូវការសង្រួម ក្នុងមនិន្ទ្រិយ ។

(១៨) ភិក្ខុនោះ បរិបូណ៌ដោយឥន្ទ្រិយសំវរៈដ៏ប្រសើរនេះហើយ តែងទទួលនូវសេចក្តីសុខ ដែលមិនច្រឡូកច្រឡំ ដោយកិលេសខាងក្នុងសន្តាន ។ ភិក្ខុនោះ កាលឈានទៅមុខ ឈានថយក្រោយ ក៏ជាអ្នកដឹងខ្លួន កាលក្រឡេកមើលទៅមុខ ក្រឡេកមើលទៅទិសផ្សេង ៗ ក៏ជាអ្នកដឹងខ្លួន កាលបត់លា (ដៃជើង) ក៏ជាអ្នកដឹងខ្លួន កាលប្រើប្រាស់សង្ឃាដី បាត្រ ចីវរ ក៏ជាអ្នកដឹងខ្លួន កាលបរិភោគ ផឹក ទំពា ទទួលរស ក៏ជាអ្នកដឹងខ្លួន កាលបន្ទោឧច្ចារៈ បស្សាវៈ ក៏ជាអ្នកដឹងខ្លួន កាលដើរ ឈរ អង្គុយ ដេកលក់ ភ្ញាក់ពីដេក និយាយ ស្ងៀម ក៏ជាអ្នកដឹងខ្លួន ។

(១៩) សោ ឥមិនា ច អរិយេន សីលក្ខន្ធេន សមន្នាគតោ ឥមិនា ច អរិយេន ឥន្ទ្រិយសំវរេន សមន្នាគតោ ឥមិនា ច អរិយេន សតិសម្បជញ្ញេន សមន្នាគតោ សោ វិវិត្តំ សេនាសនំ ភជតិ អរញ្ញំ រុក្ខមូលំ បព្វតំ កន្ទរំ គិរិគុហំ សុសានំ វនបត្ថំ អព្ភោកាសំ បលាលបុញ្ជំ ។ សោ បច្ឆាភត្តំ បិណ្ឌបាតប្បដិក្កន្តោ និសីទតិ បល្លង្កំ អាភុជិត្វា ឧជុំ កាយំ បណិធាយ បរិមុខំ សតឹ ឧបដ្ឋបេត្វា ។ សោ អភិជ្ឈំ លោកេ បហាយ វិគតាភិជ្ឈេន ចេតសា វិហរតិ អភិជ្ឈាយ ចិត្តំ បរិសោធេតិ ព្យាបាទប្បទោសំ បហាយ អព្យាបន្នចិត្តោ វិហរតិ សព្វបាណភូតហិតានុកម្បី ព្យាបាទប្បទោសា ចិត្តំ បរិសោធេតិ ថីនមិទ្ធំ បហាយ វិគតថីនមិទ្ធោ វិហរតិ អាលោកសញ្ញី សតោ សម្បជានោ ថីនមិទ្ធា ចិត្តំ បរិសោធេតិ ឧទ្ធច្ចកុក្កុច្ចំ បហាយ

(១៩) ភិក្ខុនោះបរិបូណ៌ដោយសីលក្ខន្ធដ៏ប្រសើរនេះផង បរិបូណ៌ដោយឥន្ទ្រិយសំវរៈដ៏ប្រសើរនេះផង បរិបូណ៌ដោយសតិសម្បជញ្ញៈដ៏ប្រសើរនេះផង តែងគប់រកនូវសេនាសនៈដ៏ស្ងាត់ គឺព្រៃ គល់ឈើ ភ្នំ រូងភ្នំ ព្រៃស្មសាន ព្រៃធ្លាយ ទីវាល គំនរចំបើង ។ ភិក្ខុនោះ លុះហួសពេលបិណ្ឌបាត ក្នុងវេលាខាងក្រោយភត្ត ក៏អង្គុយពត់ភ្នែនតម្រង់កាយឲ្យត្រង់ តម្កល់ស្មារតីឲ្យមានមុខឆ្ពោះទៅរកកម្មដ្ឋាន ។ ភិក្ខុនោះក៏លះបង់នូវអភិជ្ឈាក្នុងលោកគឺបញ្ចុបាទានក្ខន្ធ មានចិត្តប្រាសចាកអភិជ្ឈា ធ្វើចិត្តឲ្យស្អាតចាកអភិជ្ឈា លះបង់នូវព្យាបាទនិងសេចក្តីប្រទូស្ត មានចិត្តមិនព្យាបាទ មានសេចក្តីអនុគ្រោះដោយប្រយោជន៍ដល់សត្វមានជីវិតទាំងអស់ ធ្វើចិត្តឲ្យបរិសុទ្ធចាកព្យាបាទនិងសេចក្តីប្រទូស្ត លះបង់ថីន-មិទ្ធៈ ជាអ្នកប្រាសចាកថីនមិទ្ធៈ មានសេចក្តីសំគាល់នូវពន្លឺ ជាអ្នកមានសតិនិងសម្បជញ្ញៈ ធ្វើចិត្តឲ្យស្អាតចាកថីនមិទ្ធៈ លះបង់ឧទ្ធច្ចកុក្កុច្ចៈ

អនុទ្ធតោ វិហរតិ អជ្ឈត្តំ វូបសន្តចិត្តោ ឧទ្ធច្ចកុក្កុច្ចា ចិត្តំ បរិសោធេតិ វិចិកិច្ឆំ បហាយ តិណ្ណវិចិកិច្ឆោ វិហរតិ អកថំកថី កុសលេសុ ធម្មេសុ វិចិកិច្ឆាយ ចិត្តំ បរិសោធេតិ ។

(២០) សោ ឥមេ បញ្ច នីវរណេ បហាយ ចេតសោ ឧបក្កិលេសេ បញ្ញាយ ទុព្ពលីករណេ វិវិច្ចេវ កាមេហិ វិវិច្ច អកុសលេហិ ធម្មេហិ សវិតក្កំ សវិចារំ វិវេកជំ បីតិសុខំ បឋមំ ឈានំ ឧបសម្បជ្ជ វិហរតិ ។ ឯវម្បិ ភិក្ខវេ សផលោ ឧបក្កមោ ហោតិ សផលំ បធានំ ។

(២១) បុន ចបរំ ភិក្ខវេ ភិក្ខុ វិតក្កវិចារានំ វូបសមា អជ្ឈត្តំ សម្បសាទនំ ចេតសោ ឯកោទិភាវំ

ជាអ្នកមានចិត្តមិនរាយមាយ មានចិត្តស្ងប់ស្ងាត់ក្នុងសន្តានរបស់ខ្លួន ធ្វើចិត្តឲ្យស្អាតចាកឧទ្ធច្ចកុក្កុច្ចៈ លះបង់វិចិកិច្ឆា ជាអ្នកឆ្លងផុតចាកវិចិកិច្ឆា ហើយ មិនមានសេចក្តីងឿងឆ្ងល់ ក្នុងកុសលធម៌ទាំងឡាយ ធ្វើចិត្តឲ្យស្អាតចាកវិចិកិច្ឆា ។

(២០) ភិក្ខុនោះលុះលះបង់នូវនីវរណៈទាំង ៥ នេះ ដែលជាឧបក្កិលេសរបស់ចិត្ត ដែលធ្វើប្រាជ្ញាឲ្យមានកម្លាំងថយហើយ ក៏ស្ងាត់ចាកកាមទាំងឡាយ ស្ងាត់ចាកអកុសលធម៌ទាំងឡាយ ហើយចូលកាន់បឋមជ្ឈានដែលប្រកបដោយវិតក្កៈ វិចារៈ មានបីតិនិងសុខៈដែលកើតអំពីសេចក្តីស្ងប់ស្ងាត់ ក៏សម្រាន្តនៅដោយឥរិយាបថ ៤ ។ ម្នាលភិក្ខុទាំងឡាយ សេចក្តីប្រឹងប្រែងមានផល សេចក្តីព្យាយាមមានផល យ៉ាងនេះឯង ។

(២១) ម្នាលភិក្ខុទាំងឡាយ មួយទៀត ភិក្ខុរម្ងាប់នូវវិតក្កៈ និងវិចារៈ ហើយក៏ចូលកាន់ទុតិយជ្ឈាន ជាធម្មជាតកើតមានក្នុងសន្តាននៃខ្លួន ប្រកបដោយសេចក្តីជ្រះថ្លាគឺសទ្ធា មានសភាពជាចិត្តខ្ពស់ឯក

អវិតក្កំ អវិចារំ សមាធិជំ បីតិសុខំ ទុតិយំ ឈានំ ឧបសម្បជ្ជ វិហរតិ ។ ឯវម្បិ ភិក្ខវេ សផលោ ឧបក្កមោ ហោតិ សផលំ បធានំ ។

(២២) បុន ចបរំ ភិក្ខវេ ភិក្ខុ បីតិយា ច វិរាគា ឧបេក្ខកោ ច វិហរតិ សតោ ច សម្បជានោ សុខញ្ច កាយេន បដិសំវេទេតិ យន្តំ អរិយា អាចិក្ខន្តិ ឧបេក្ខកោ សតិមា សុខវិហារីតិ តតិយំ ឈានំ ឧបសម្បជ្ជ វិហរតិ ។ ឯវម្បិ ភិក្ខវេ សផលោ ឧបក្កមោ ហោតិ សផលំ បធានំ ។

(២៣) បុន ចបរំ ភិក្ខវេ ភិក្ខុ សុខស្ស ច បហានា ទុក្ខស្ស ច បហានា បុព្វេវ សោមនស្សទោមនស្សានំ អត្ថង្គមា អទុក្ខមសុខំ ឧបេក្ខាសតិបារិសុទ្ធឹ ចតុត្ថំ ឈានំ ឧបសម្បជ្ជ វិហរតិ ។ ឯវម្បិ ភិក្ខវេ សផលោ ឧបក្កមោ ហោតិ សផលំ បធានំ ។

មិនមានវិតក្កៈ មិនមានវិចារៈ មានតែបីតិនិងសុខៈដែលកើតអំពីសមាធិ គឺបឋមជ្ឈាន ក៏សម្រាន្តនៅដោយឥរិយាបថ ៤ ។ ម្នាលភិក្ខុទាំងឡាយ សេចក្តីប្រឹងប្រែងមានផល សេចក្តីព្យាយាមមានផល យ៉ាងនេះឯង ។

(២២) ម្នាលភិក្ខុទាំងឡាយ មួយទៀត ភិក្ខុនឿយណាយចាកបីតិផង ជាអ្នកប្រកបដោយឧបេក្ខាផង មានសតិសម្បជញ្ញៈទទួលសុខដោយនាមកាយផង ក៏ចូលកាន់តតិយជ្ឈាន ដែលព្រះអរិយៈទាំងឡាយតែងសរសើរថា បុគ្គលដែលបានតតិយជ្ឈាន មានចិត្តប្រកបដោយឧបេក្ខា មានស្មារតីនៅជាសុខដូច្នេះ ក៏សម្រាន្តនៅដោយឥរិយាបថ ៤ ។ ម្នាលភិក្ខុទាំងឡាយ សេចក្តីប្រឹងប្រែងមានផល សេចក្តីព្យាយាមមានផល យ៉ាងនេះឯង ។

(២៣) ម្នាលភិក្ខុទាំងឡាយ មួយវិញទៀត ភិក្ខុលះបង់នូវសុខផង លះបង់នូវទុក្ខផង អស់សោមនស្សនិងទោមនស្ស ក្នុងកាលមុនផង ក៏ចូលកាន់ចតុត្ថជ្ឈាន ជាធម្មជាតមានអារម្មណ៍មិនមែនទុក្ខមិនមែនសុខគឺឧបេក្ខា មានសតិដ៏បរិសុទ្ធដោយឧបេក្ខា ក៏សម្រាន្តនៅដោយឥរិយាបថ ៤ ។ ម្នាលភិក្ខុទាំងឡាយ សេចក្តីប្រឹងប្រែងមានផល សេចក្តីព្យាយាមមានផល យ៉ាងនេះឯង ។

(២៦) សោ ឯវំ សមាហិតេ ចិត្តេ បរិសុទ្ធេ បរិយោទាតេ អនង្គណេ វិគតូបក្កិលេសេ មុទុភូតេ កម្មនិយេ ឋិតេ អានេញ្ជប្បត្តេ បុព្វេនិវាសានុស្ស-តិញ្ញាណាយ ចិត្តំ អភិនិន្នាមេតិ ។ សោ អនេកវិហិតំ បុព្វេនិវាសំ អនុស្សរតិ សេយ្យថីទំ ឯកម្បិ ជាតឹ ទ្វេបិ ជាតិយោ តិស្សោបិ ជាតិយោ ចតស្សោបិ ជាតិយោ បញ្ចបិ ជាតិយោ ទសបិ ជាតិយោ វីសម្បិ ជាតិយោ តឹសម្បិ ជាតិយោ ចត្តាឡីសម្បិ ជាតិយោ បញ្ញាសម្បិ ជាតិយោ ជាតិសតម្បិ ជាតិសហ-ស្សម្បិ ជាតិសតសហស្សម្បិ អនេកេបិ សំវដ្ដ-កប្បេ អនេកេបិ វិវដ្ដកប្បេ អនេកេបិ សំវដ្ដវិវដ្ដ-កប្បេ អមុត្រាសឹ ឯវំនាមោ ឯវំគោត្តោ ឯវំវណ្ណោ ឯវមាហារោ ឯវំសុខទុក្ខប្បដិសំវេទី ឯវមាយុបរិយន្តោ សោ តតោ ចុតោ អមុត្រ ឧទបាទឹ តត្រា-បាសឹ ឯវំនាមោ ឯវំគោត្តោ ឯវំវណ្ណោ ឯវមាហារោ

(៦៦) ភិក្ខុនោះ កាលបើចិត្តតាំងខ្ជាប់ខ្ជួន បរិសុទ្ធ ផូរផង់ មិនមានទីទួលគឺកិលេស ប្រាសចាកឧបក្កិលេស មានសភាពជាចិត្តទន់គួរដល់ការនៃកម្ម ជាចិត្តនឹងធឹង មិនញាប់ញ័រទៅតាមអារម្មណ៍យ៉ាងនេះហើយ ក៏តម្រង់ផ្ចង់បង្អោនចិត្តទៅ ដើម្បីបុព្វេនិវាសានុស្សតិញាណ ។ ភិក្ខុនោះ រលឹកឃើញនូវខន្ធដែលខ្លួនធ្លាប់អាស្រ័យនៅក្នុងកាលមុន ជាច្រើនប្រការ រលឹកឃើញនូវខន្ធនោះតើដូចម្តេចខ្លះ គឺរលឹកឃើញ ១ ជាតិ ២ ជាតិ ៣ ជាតិ ៤ ជាតិ ៥ ជាតិ ១០ ជាតិ ២០ ជាតិ ៣០ ជាតិ ៤០ ជាតិ ៥០ ជាតិ មួយរយជាតិ មួយពាន់ជាតិ មួយសែនជាតិក៏បាន រលឹកឃើញនូវសំវដ្តកប្បជាច្រើនក៏បាន នូវវិវដ្តកប្បជាច្រើនក៏បាន សំវដ្តវិវដ្តកប្ប ជាច្រើនក៏បាន ថា អាត្មាអញបានកើតក្នុងភពឯណោះ មានឈ្មោះយ៉ាងនេះ មានគោត្រយ៉ាងនេះ មានសម្បុរយ៉ាងនេះ មានអាហារយ៉ាងនេះ បានទទួលសុខទុក្ខយ៉ាងនេះ មានកំណត់អាយុត្រឹមប៉ុណ្ណេះ លុះអាត្មាអញច្យុតចាកអត្តភាពនោះហើយ ក៏បានទៅកើតក្នុងភពឯណោះ កាលដែលអាត្មាអញទៅកើតក្នុងភពនោះ មានឈ្មោះយ៉ាងនេះ មានគោត្រយ៉ាងនេះ មានសម្បុរយ៉ាងនេះ មានអាហារយ៉ាងនេះ

ឯវំសុខទុក្ខប្បដិសំវេទី ឯវមាយុបរិយន្តោ សោ តតោ ចុតោ ឥធូបបន្នោតិ ។ ឥតិ សាការំ សឧទ្ទេសំ អនេកវិហិតំ បុព្វេនិវាសំ អនុស្សរតិ ។ ឯវម្បិ ភិក្ខវេ សេដ្ឋោ ឧបក្កមោ ហោតិ សេដ្ឋំ បធានំ ។

(២៨) សោ ឯវំ សមាហិតេ ចិត្តេ បរិសុទ្ធេ បរិយោទាតេ អនង្គណេ វិគតូបក្កិលេសេ មុទុភូតេ កម្មនីយេ ឋិតេ អនេញ្ជប្បត្តេ សត្តានំ ចុតូបបាត-ញាណាយ ចិត្តំ អភិនិន្នាមេតិ ។ សោ ទិព្វេន ចក្ខុនា វិសុទ្ធេន អតិក្កន្តមានុសកេន សត្តេ បស្សតិ ចវមានេ ឧបបជ្ជមានេ ហីនេ បណីតេ សុវណ្ណេ ទុព្វណ្ណេ សុគតេ ទុគ្គតេ យថាកម្មូបគេ សត្តេ បជានាតិ ឥមេ វត ភោន្តោ សត្តា កាយ-ទុច្ចរិតេន សមន្នាគតា វចីទុច្ចរិតេន សមន្នាគតា

បានទទួលសុខនិងទុក្ខយ៉ាងនេះ មានកំណត់អាយុត្រឹមប៉ុណ្ណេះ លុះអាត្មាអញច្យុតចាកអត្តភាពនោះហើយ ក៏បានមកកើតក្នុងភពនេះ ៗ ភិក្ខុនោះរលឹកឃើញនូវខន្ធដែលខ្លួនធ្លាប់អាស្រ័យនៅក្នុងកាលមុន ជាច្រើនប្រការ ព្រមទាំងអាការ គឺសម្បុរនិងអាហារជាដើម ព្រមទាំងឧទ្ទេស គឺឈ្មោះនិងគោត្រ ដោយប្រការដូច្នេះ ៗ ម្នាលភិក្ខុទាំងឡាយ សេចក្ដីប្រឹងប្រែងមានផល សេចក្ដីព្យាយាមមានផល យ៉ាងនេះឯង ៗ

(២៥) ភិក្ខុនោះ កាលបើមានចិត្តខ្ជាប់ខ្ជួន បរិសុទ្ធ ផូរផង់ មិនមានទីទួលគឺកិលេស ប្រាសចាកឧបក្កិលេស មានសភាពជាចិត្តទន់ គួរដល់ការនាកម្ម ជាចិត្តនឹងធឹង មិនញាប់ញ័រទៅតាមអារម្មណ៍យ៉ាងនេះហើយ ក៏តម្រង់ផ្ចង់បង្អោនចិត្តទៅ ដើម្បីចុតូបបាតញ្ញាណ (ការដឹងចុតិបដិសន្ធិ) របស់សត្វទាំងឡាយ ៗ ភិក្ខុនោះមានចក្ខុដូចជាទិព្វ បរិសុទ្ធ កន្លងបង់ចក្ខុជារបស់មនុស្សធម្មតា រមែងឃើញពួកសត្វដែលច្យុតដែលកើត ជាសត្វថោកទាប ខ្ពង់ខ្ពស់ មានសម្បុរល្អ មានសម្បុរអាក្រក់ មានគតិល្អ មានគតិអាក្រក់ ដឹងច្បាស់នូវសត្វដែលប្រព្រឹត្តទៅតាមកម្មរបស់ខ្លួនដូច្នេះថា អើហ្ន៎ សត្វអម្បាលនេះប្រកបដោយកាយទុច្ចរិត ប្រកបដោយវចីទុច្ចរិត

មនោទុច្ចរិតេន សមន្នាគតា អរិយានំ ឧបវាទកា មិច្ឆាទិដ្ឋិកា មិច្ឆាទិដ្ឋិកម្មសមាទានា តេ កាយស្ស ភេទា បរម្មរណា អបាយំ ទុគ្គតឹ វិនិបាតំ និរយំ ឧបបន្នា ឥមេ វា បន ភោន្តោ សត្តា កាយសុចរិតេន សមន្នាគតា វចីសុចរិតេន សមន្នាគតា មនោសុចរិតេន សមន្នាគតា អរិយានំ អនុបវាទកា សម្មាទិដ្ឋិកា សម្មាទិដ្ឋិកម្មសមាទានា តេ កាយស្ស ភេទា បរម្មរណា សុគតឹ សគ្គំ លោកំ ឧបបន្នាតិ ។ ឥតិ ទិព្វេន ចក្ខុនា វិសុទ្ធេន អតិក្កន្តមានុសកេន សត្តេ បស្សតិ ចវមានេ ឧបបជ្ជមានេ ហីនេ បណីតេ សុវណ្ណេ ទុព្វណ្ណេ សុគតេ ទុគ្គតេ យថាកម្មូបគេ សត្តេ បជានាតិ ។ ឯវំ ភិក្ខវេ សផលោ ឧបក្កមោ ហោតិ សផលំ បធានំ ។

(២៦) សោ ឯវំ សមាហិតេ ចិត្តេ បរិសុទ្ធេ បរិយោទាតេ អនង្គណេ វិគតូបក្កិលេសេ មុទុភូតេ កម្មនិយេ ឋិតេ អានេញ្ជប្បត្តេ អាសវានំ ខយញាណាយ ចិត្តំ អភិនិន្នាមេតិ ។ សោ

ប្រកបដោយមនោទុច្ចរិត ជាអ្នកតិះដៀលពួកព្រះអរិយៈ ជាមិច្ឆាទិដ្ឋិ ប្រកាន់អំពើជាមិច្ឆាទិដ្ឋិ សត្វទាំងនោះ លុះបែកធ្លាយរាងកាយស្លាប់ទៅ ក៏ទៅកើតក្នុងអបាយ ទុគ្គតិ វិនិបាត នរក មួយទៀត សត្វអម្បាលនេះ ប្រកបដោយកាយសុចរិត ប្រកបដោយវចីសុចរិត ប្រកបដោយមនោសុចរិត ជាអ្នកមិនតិះដៀលពួកព្រះអរិយៈ ជាសម្មាទិដ្ឋិ ប្រកាន់អំពើជាសម្មាទិដ្ឋិ សត្វទាំងនោះ លុះបែកធ្លាយរាងកាយស្លាប់ទៅ ក៏ទៅកើតក្នុងសុគតិ សួគ៌ ទេវលោក ។ ភិក្ខុនោះមានចក្ខុដូចជាទិព្វ បរិសុទ្ធ កន្លងបង់ចក្ខុជារបស់មនុស្សធម្មតា រមែងឃើញពួកសត្វដែលច្យុត ដែលកើត ជាសត្វថោកទាប ខ្ពង់ខ្ពស់ មានសម្បុរល្អ មានសម្បុរអាក្រក់ មានគតិល្អ មានគតិអាក្រក់ ដឹងច្បាស់នូវពួកសត្វដែលប្រព្រឹត្តទៅតាមកម្មរបស់ខ្លួន ដោយប្រការដូច្នេះ ។ ម្នាលភិក្ខុទាំងឡាយ សេចក្តីប្រឹងប្រែងមានផល សេចក្តីព្យាយាមមានផល យ៉ាងនេះឯង ។

[៨៦] ភិក្ខុនោះ កាលបើមានចិត្តតាំងខ្ជាប់ខ្ជួន បរិសុទ្ធ ផូរផង់ មិនមានទីទួលគឺកិលេស ប្រាសចាកឧបក្កិលេស ជាចិត្តទន់ គួរដល់ភាវនាកម្ម ជាចិត្តនឹងធឹង មិនញាប់ញ័រទៅតាមអារម្មណ៍ យ៉ាងនេះហើយ ក៏តម្រង់ផ្ចង់បង្អោនចិត្តទៅ ដើម្បីអាសវក្ខយញ្ញាណ ។ ភិក្ខុនោះ

ឥទំ ទុក្ខន្តិ យថាភូតំ បជានាតិ អយំ ទុក្ខសមុទ-យោតិ យថាភូតំ បជានាតិ អយំ ទុក្ខនិរោធោតិ យថាភូតំ បជានាតិ អយំ ទុក្ខនិរោធគាមិនី បដិបទាតិ យថាភូតំ បជានាតិ ឥមេ អាសវាតិ យថាភូតំ បជានាតិ អយំ អាសវសមុទយោតិ យថាភូតំ បជានាតិ អយំ អាសវនិរោធោតិ យថាភូតំ បជានាតិ អយំ អាសវនិរោធគាមិនី បដិបទាតិ យថាភូតំ បជានាតិ ។ តស្ស ឯវំ ជានតោ ឯវំ បស្សតោ កាមាសវាបិ ចិត្តំ វិមុច្ចតិ ភវាសវាបិ ចិត្តំ វិមុច្ចតិ អវិជ្ជាសវាបិ ចិត្តំ វិមុច្ចតិ វិមុត្តស្មឹ វិមុត្តមិតិ ញាណំ ហោតិ ខីណា ជាតិ វុសិតំ ព្រហ្មចរិយំ កតំ ករណីយំ នាបរំ ឥត្ថត្តាយាតិ បជានាតិ ។ ឯវំ ខោ ភិក្ខវេ សផលោ ឧបក្កមោ ហោតិ សផលំ បធានំ ។

ដឹងតាមពិតថា នេះជាទុក្ខ ដឹងតាមពិតថា នេះជាហេតុនាំឲ្យកើតទុក្ខ ដឹងតាមពិតថា នេះជាសេចក្ដីរលត់ទុក្ខ ដឹងតាមពិតថា នេះជាបដិបទាឲ្យបានដល់នូវសេចក្ដីរលត់ទុក្ខ ដឹងតាមពិតថា នេះជាអាសវៈ ដឹងតាមពិតថា នេះជាសេចក្ដីរលត់អាសវៈ ដឹងតាមពិតថា នេះជាបដិបទាឲ្យបានដល់នូវសេចក្ដីរលត់អាសវៈ ។ កាលបើភិក្ខុនោះដឹងយ៉ាងនេះឃើញយ៉ាងនេះហើយ ចិត្តក៏រួចស្រឡះចាកកាមាសវៈផង ចិត្តរួចស្រឡះចាកភវាសវៈផង ចិត្តរួចស្រឡះចាកអវិជ្ជាសវៈផង កាលបើចិត្តរួចស្រឡះហើយ ប្រាជ្ញាក៏កើតឡើងថា ចិត្តរួចស្រឡះហើយ ភិក្ខុនោះក៏ដឹងច្បាស់ថា ជាតិអស់ហើយ មគ្គព្រហ្មចរិយៈ អាត្មាអញបានប្រព្រឹត្តគ្រប់គ្រាន់ហើយ សោឡសកិច្ច អាត្មាអញបានធ្វើស្រេចហើយ មគ្គភាវនា–កិច្ចដទៃ ប្រព្រឹត្តទៅ ដើម្បីសោឡសកិច្ចនេះទៀត មិនមានឡើយ ។ ម្នាលភិក្ខុទាំងឡាយ សេចក្ដីប្រឹងប្រែងមានផល សេចក្ដីព្យាយាមមានផល យ៉ាងនេះឯង ។

(២៧) ឯវំវាទី ភិក្ខវេ តថាគតោ ឯវំវាទឹ ភិក្ខវេ តថាគតំ ទស សហធម្មិកា បាសំសដ្ឋានំ អាគច្ឆន្តិ ។ សចេ ភិក្ខវេ សត្តា បុព្វេកតហេតុ សុខទុក្ខំ បដិសំវេទេន្តិ អទ្ធា ភិក្ខវេ តថាគតោ បុព្វេ សុកតកម្មការី យំ ឯតរហិ ឯវរូបា អនាសវា សុខា វេទនា វេទេតិ ។ សចេ ភិក្ខវេ សត្តា ឥស្សរនិម្មានហេតុ សុខទុក្ខំ បដិសំវេទេន្តិ អទ្ធា ភិក្ខវេ តថាគតោ ភទ្ទកេន ឥស្សរេន និម្មិតោ យំ ឯតរហិ ឯវរូបា អនាសវា សុខា វេទនា វេទេតិ ។ សចេ ភិក្ខវេ សត្តា សង្គតិភាវហេតុ សុខទុក្ខំ បដិសំវេទេន្តិ អទ្ធា ភិក្ខវេ តថាគតោ កល្យាណសង្គតិកោ យំ ឯតរហិ ឯវរូបា អនាសវា សុខា វេទនា វេទេតិ ។ សចេ ភិក្ខវេ

(៤៧) ម្នាលភិក្ខុទាំងឡាយ ព្រះតថាគតតែងពោលយ៉ាងនេះ ម្នាលភិក្ខុទាំងឡាយ ពាក្យប្រកបដោយធម៌ ១០ ប្រការ តែងមកកាន់ស្ថានដែលគប្បីសរសើរ ចំពោះព្រះតថាគត ជាអ្នកពោលយ៉ាងនេះ ។ ម្នាលភិក្ខុទាំងឡាយ បើពួកសត្វរងសុខនិងទុក្ខ ព្រោះហេតុតែកម្មដែលខ្លួនបានធ្វើក្នុងកាលមុន ម្នាលភិក្ខុទាំងឡាយ ព្រះតថាគតជាអ្នកធ្វើអំពើល្អក្នុងកាលមុនដោយពិត បានជាក្នុងកាលឥឡូវនេះ ទទួលសុខវេទនា មិនមានអាសវៈ មានសភាពយ៉ាងនេះ ១ ។ ម្នាលភិក្ខុទាំងឡាយ បើពួកសត្វរងសុខនិងទុក្ខ ព្រោះហេតុតែព្រះឥស្សរ កាត់តែងឲ្យ ម្នាលភិក្ខុទាំងឡាយ ព្រះតថាគតគឺព្រះឥស្សរដ៏ប្រសើរកាត់តែងឲ្យដោយពិត បានជាក្នុងកាលឥឡូវនេះ ទទួលសុខវេទនា មិនមានអាសវៈ មានសភាពយ៉ាងនេះ ១ ។ ម្នាលភិក្ខុទាំងឡាយ បើពួកសត្វរងសុខនិងទុក្ខ ព្រោះហេតុតែសង្គតិនិងភាវៈ ម្នាលភិក្ខុទាំងឡាយ ព្រះតថាគតមានសង្គតិល្អដោយពិត្រ បានជាក្នុងកាលឥឡូវនេះ ទទួលសុខវេទនា មិនមានអាសវៈ មានសភាពយ៉ាងនេះ ១ ។ ម្នាលភិក្ខុទាំងឡាយ បើ

សត្តា អភិជាតិហេតុ សុខទុក្ខំ បដិសំវេទេន្តិ អទ្ធា ភិក្ខវេ តថាគតោ កល្យាណាភិជាតិកោ យំ ឯតរហិ ឯវរូបា អនាសវា សុខា វេទនា វេទេតិ ។ សចេ ភិក្ខវេ សត្តា ទិដ្ឋធម្មុបក្កមហេតុ សុខទុក្ខំ បដិសំវេទេន្តិ អទ្ធា ភិក្ខវេ តថាគតោ កល្យាណទិដ្ឋធម្មុបក្កមោ យំ ឯតរហិ ឯវរូបា អនាសវា សុខា វេទនា វេទេតិ ។ សចេ ភិក្ខវេ សត្តា បុព្វេកតហេតុ សុខទុក្ខំ បដិសំវេទេន្តិ បាសំសោ តថាគតោ នោ ចេ សត្តា បុព្វេកតហេតុ សុខទុក្ខំ បដិសំវេទេន្តិ បាសំសោ តថាគតោ ។ សចេ ភិក្ខវេ សត្តា ឥស្សរនិម្មានហេតុ សុខទុក្ខំ បដិសំវេទេន្តិ បាសំសោ តថាគតោ នោ ចេ សត្តា ឥស្សរនិម្មានហេតុ សុខទុក្ខំ បដិសំវេទេន្តិ បាសំសោ តថាគតោ ។ សចេ ភិក្ខវេ សត្តា សង្គតិភាវហេតុ សុខទុក្ខំ បដិសំវេទេន្តិ បាសំសោ តថាគតោ នោ ចេ សត្តា សង្គតិភាវហេតុ សុខទុក្ខំ បដិសំវេទេន្តិ បាសំសោ តថាគតោ ។ សចេ ភិក្ខវេ

ពួកសត្វរងសុខនិងទុក្ខ ព្រោះហេតុតែអភិជាតិ ម្នាលភិក្ខុទាំងឡាយ ព្រះតថាគតមានអភិជាតិល្អដោយពិត បានជាក្នុងកាលឥឡូវនេះ ទទួលសុខ-វេទនា មិនមានអាសវៈ មានសភាពយ៉ាងនេះ ១ ។ ម្នាលភិក្ខុទាំងឡាយ បើពួកសត្វរងសុខនិងទុក្ខ ព្រោះហេតុតែសេចក្តីប្រឹងប្រែងក្នុងបច្ចុប្បន្ននេះ ម្នាលភិក្ខុទាំងឡាយ ព្រះតថាគត មានសេចក្តីប្រឹងប្រែងក្នុងបច្ចុប្បន្ននេះ ល្អដោយពិត បានជាក្នុងកាលឥឡូវនេះ ទទួលសុខវេទនា មិនមានអាសវៈ មានសភាពយ៉ាងនេះ ១ ។ ម្នាលភិក្ខុទាំងឡាយ បើពួកសត្វរងសុខនិងទុក្ខ ព្រោះហេតុតែកម្មដែលខ្លួនធ្វើក្នុងកាលមុន ព្រះតថាគតក៏គួរគេសរសើរបាន បើទុកជាពួកសត្វមិនរងសុខនិងទុក្ខ ព្រោះហេតុតែកម្មដែលខ្លួនធ្វើក្នុងកាលមុនក៏ដោយ ព្រះតថាគតក៏គង់គេសរសើរបាន ១ ។ ម្នាលភិក្ខុទាំងឡាយ បើពួកសត្វរងសុខនិងទុក្ខ ព្រោះហេតុតែព្រះឥសូរតាក់តែងឲ្យ ព្រះតថាគតក៏គួរគេសរសើរបាន បើទុកជាពួកសត្វមិនរងសុខនិងទុក្ខ ព្រោះហេតុតែព្រះឥសូរតាក់តែងឲ្យក៏ដោយ ព្រះតថាគតក៏គង់គេសរសើរបាន ១ ។ ម្នាលភិក្ខុទាំងឡាយ បើពួកសត្វរងសុខនិងទុក្ខ ព្រោះហេតុតែសង្គតិនិងភាវៈ ព្រះតថាគតក៏គួរគេសរសើរបាន បើទុកជាពួកសត្វមិនរងសុខនិងទុក្ខ ព្រោះហេតុតែសង្គតិនិងភាវៈក៏ដោយ ព្រះតថាគត ក៏គង់គេសរសើរបាន ១ ។ ម្នាលភិក្ខុទាំងឡាយ បើ

សត្តា អភិជាតិហេតុ សុខទុក្ខំ បដិសំវេទេន្តិ បាសំសោ តថាគតោ នោ ចេ សត្តា អភិជាតិហេតុ សុខទុក្ខំ បដិសំវេទេន្តិ បាសំសោ តថាគតោ ។ សចេ ភិក្ខវេ សត្តា ទិដ្ឋធម្មូបក្កមហេតុ សុខទុក្ខំ បដិសំវេទេន្តិ បាសំសោ តថាគតោ នោ ចេ សត្តា ទិដ្ឋធម្មូបក្កមហេតុ សុខទុក្ខំ បដិសំវេទេន្តិ បាសំសោ តថាគតោ ។ ឯវំវាទី ភិក្ខវេ តថាគតោ ឯវំវាទឹ ភិក្ខវេ តថាគតំ ឥមេ ទស សហធម្មិកា បាសំសដ្ឋានំ អាគច្ឆន្តិ ។ ឥទមវោច ភគវា អត្តមនា តេ ភិក្ខូ ភគវតោ ភាសិតំ អភិនន្ទុន្តិ ។

ទេវទហសុត្តំ បឋមំ និដ្ឋិតំ ។

ពួកសត្វដែលសុខនិងទុក្ខ ព្រោះហេតុតែអភិជាតិ ព្រះតថាគតក៏គួរគេសរសើរបាន បើទុកជាពួកសត្វមិនដែលសុខនិងទុក្ខ ព្រោះហេតុតែអភិជាតិក៏ដោយ ព្រះតថាគតក៏គង់គេសរសើរបាន ១ ។ ម្នាលភិក្ខុទាំងឡាយ បើពួកសត្វដែលសុខនិងទុក្ខ ព្រោះហេតុតែសេចក្តីប្រឹងប្រែងក្នុងបច្ចុប្បន្ននេះ ព្រះតថាគតក៏គួរគេសរសើរបាន បើទុកជាពួកសត្វមិនដែលសុខនិងទុក្ខ ព្រោះហេតុតែសេចក្តីប្រឹងប្រែង ក្នុងបច្ចុប្បន្ននេះក៏ដោយ ព្រះតថាគតក៏គង់គេសរសើរបាន ១ ។ ម្នាលភិក្ខុទាំងឡាយ ព្រះតថាគតតែងពោលយ៉ាងនេះ ម្នាលភិក្ខុទាំងឡាយ ពាក្យប្រកបដោយហេតុ ១០ ប្រការនេះឯង តែងមកកាន់ស្ថានដែលគេគប្បីសរសើរ ចំពោះព្រះតថាគតជាអ្នកពោលយ៉ាងនេះ ។ លុះព្រះមានបុណ្យបានសំដែងព្រះសូត្រនេះចប់ហើយ ភិក្ខុទាំងនោះ ជាអ្នកមានចិត្តត្រេកអរ រីករាយ ចំពោះភាសិត របស់ព្រះមានបុណ្យ ។

ចប់ ទេវទហសូត្រ ទី ១ ។

---

# ទុតិយំ បញ្ចត្តយសុត្តំ

(២៨) ឯវម្មេ សុតំ ។ ឯកំ សមយំ ភគវា សាវត្ថិយំ វិហរតិ ជេតវនេ អនាថបិណ្ឌិកស្ស អារាមេ ។ តត្រ ខោ ភគវា ភិក្ខូ អាមន្តេសិ ភិក្ខវោតិ ។ ភទន្តេតិ តេ ភិក្ខូ ភគវតោ បច្ចស្សោសុំ ។

(២៩) ភគវា ឯតទវោច សន្តិ ភិក្ខវេ ឯកេ សមណព្រាហ្មណា អបរន្តកប្បិកា អបរន្តានុទិដ្ឋិនោ អបរន្តំ អារព្ភ អនេកវិហិតានិ អធិមុត្តិបទានិ អភិវទន្តិ ។ សញ្ញី អត្តា ហោតិ អរោគោ បរម្មរណាតិ ឥត្ថេកេ អភិវទន្តិ ។ អសញ្ញី អត្តា ហោតិ អរោគោ បរម្មរណាតិ ឥត្ថេកេ អភិវទន្តិ ។

# បញ្ចត្តយសូត្រ ទី ២

(៤៨) ខ្ញុំបានស្តាប់មក យ៉ាងនេះ ។ សម័យមួយ ព្រះមានព្រះភាគទ្រង់គង់នៅក្នុងវត្តជេតពន របស់អនាថបិណ្ឌិកសេដ្ឋី ជិតក្រុងសាវត្ថី ។ កាលព្រះមានព្រះភាគគង់នៅក្នុងវត្តនោះ បានត្រាស់ហៅភិក្ខុទាំងឡាយថា ម្នាលភិក្ខុទាំងឡាយ ។ ភិក្ខុទាំងនោះទទួលតបព្រះពុទ្ធដីកា របស់ព្រះមានព្រះភាគថា ព្រះករុណា ព្រះអង្គ ។

(៤៩) ព្រះមានព្រះភាគទ្រង់ត្រាស់ដូច្នេះថា ម្នាលភិក្ខុទាំង-ឡាយ មានសមណព្រាហ្មណ៍ពួកខ្លះ ជាអ្នកកំណត់នូវខន្ធជាចំណែកខាងមុខ ( ខន្ធក្នុងអនាគត) មានសេចក្តីយល់ឃើញ នូវខន្ធជាចំណែកខាងមុខ ប្រារព្ធខន្ធជាចំណែកខាងមុខ ហើយសំដែងនូវចំណែកនៃទិដ្ឋិច្រើនប្រការ ។ គឺសមណព្រាហ្មណ៍ពួកខ្លះនិយាយយ៉ាងនេះថា អត្តា ( ខ្លួន ) កាលស្លាប់ទៅហើយ ជាសភាវៈមានសញ្ញា ទាំងឥតមានរោគ ១ ។ សមណព្រាហ្មណ៍ពួកខ្លះនិយាយយ៉ាងនេះថា អត្តាកាលស្លាប់ទៅហើយ ជាសភាវៈមិនមានសញ្ញា ទាំងឥតមានរោគ ១ ។

នេវសញ្ញីនាសញ្ញី អត្តា ហោតិ អរោគោ បរម្មរណាតិ ឥធេកេ អភិវទន្តិ ។ សតោ វា បន សត្តស្ស ឧច្ឆេទំ វិនាសំ វិភវំ បញ្ញាបេន្តិ ។ ទិដ្ឋធម្មនិព្វានំ វា បនេកេ អភិវទន្តិ ។ ឥតិ សន្តំ វា អត្តានំ បញ្ញាបេន្តិ អរោគំ បរម្មរណា ។ សតោ វា បន សត្តស្ស ឧច្ឆេទំ វិនាសំ វិភវំ បញ្ញាបេន្តិ ។ ទិដ្ឋធម្មនិព្វានំ វា បនេកេ អភិវទន្តិ ។ ឥតិ ឥមានិ បញ្ច ហុត្វា តីណិ ហោន្តិ តីណិ ហុត្វា បញ្ច ហោន្តិ ។ អយមុទ្ទេសោ បញ្ចត្តយស្ស ។

សមណព្រាហ្មណ៍ពួកខ្លះនិយាយយ៉ាងនេះថា អត្តាកាលស្លាប់ទៅហើយ ជាសភាវៈមានសញ្ញាក៏មិនមែន មិនមានសញ្ញាក៏មិនមែន ទាំងឥតមានរោគ ១ ។ សមណព្រាហ្មណ៍ពួកខ្លះ បញ្ញត្តនូវការដាច់សូន្យ នូវសេចក្តីវិនាស នូវការមិនកើតទៀត របស់សត្វដែលមាននៅ ១ ។ មួយទៀត សមណព្រាហ្មណ៍ពួកខ្លះនិយាយថា ព្រះនិព្វានក្នុងបច្ចុប្បន្ន ១ (រួមជា ៥ ពួក) ។ តែបើបំប្រួញមកវិញ (មានត្រឹម ៣ ពួក) គឺសមណ-ព្រាហ្មណ៍ពួកខ្លះ បញ្ញត្តអត្តាដែលមាននៅ កាលស្លាប់ទៅហើយ មិនមានរោគ[1] ១ ។ សមណព្រាហ្មណ៍ពួកខ្លះ បញ្ញត្តនូវការដាច់សូន្យ នូវសេចក្តីវិនាស នូវការមិនកើតទៀត របស់សត្វ ដែលមាននៅ ១ ។ សមណព្រាហ្មណ៍ពួកខ្លះ និយាយថា ព្រះនិព្វានក្នុងបច្ចុប្បន្ន ១ ។ ទិដ្ឋិទាំងនេះ មាន ៥ ប្រការ រួមមកជា ៣ ប្រការ ឬមាន ៣ ប្រការ ញែកទៅជា ៥ ប្រការវិញ ដោយប្រការដូច្នេះឯង ។ នេះជាឧទ្ទេស នៃប្រជុំទិដ្ឋិ ៥ ប្រការ ឬ ៣ ប្រការ ។

---

១ ទិដ្ឋិ ៣ យ៉ាងខាងដើមគឺ យល់ឃើញថា អត្តាមានសញ្ញា ១ អត្តាមិនមានសញ្ញា ១ អត្តាមានសញ្ញាក៏មិនមែន មិនមានសញ្ញាក៏មិនមែន ១ ទាំង ៣ នេះរាប់ទុកជាតែ ១ វិញ ព្រោះមានសេចក្តីយល់ឃើញត្រូវគ្នា ប្លែកគ្នាខ្លះតែត្រង់សញ្ញាប៉ុណ្ណោះ ។

[៣០] តត្រ ភិក្ខវេ យេ តេ សមណព្រាហ្មណា សញ្ញឹ[១] អត្តានំ បញ្ញាបេន្តិ អរោគំ បរម្មរណា រូបឹ[២] វា តេ ភោន្តោ សមណព្រាហ្មណា សញ្ញឹ អត្តានំ បញ្ញាបេន្តិ អរោគំ បរម្មរណា អរូបឹ វា តេ ភោន្តោ សមណព្រាហ្មណា សញ្ញឹ អត្តានំ បញ្ញាបេន្តិ អរោគំ បរម្មរណា រូបិញ្ច អរូបិញ្ច[៣] វា តេ ភោន្តោ សមណព្រាហ្មណា សញ្ញឹ អត្តានំ បញ្ញាបេន្តិ អរោគំ បរម្មរណា នេវរូបឹ នារូបឹ វា តេ ភោន្តោ សមណព្រាហ្មណា សញ្ញឹ អត្តានំ បញ្ញាបេន្តិ អរោគំ បរម្មរណា ឯកត្តសញ្ញឹ វា តេ ភោន្តោ សមណព្រាហ្មណា សញ្ញឹ អត្តានំ បញ្ញាបេន្តិ អរោគំ បរម្មរណា នានត្តសញ្ញឹ វា តេ ភោន្តោ សមណព្រាហ្មណា សញ្ញឹ អត្តានំ បញ្ញាបេន្តិ

---

១ ម. សព្វត្ថ សញ្ញីតិ ទិស្សតិ ។ ២ ម. សព្វត្ថ រូបីតិ ទិស្សតិ ។ ៣ ម. រូបី ច អរូបី ច ។

(៣០) ម្នាលភិក្ខុទាំងឡាយ បណ្តាពួកសមណព្រាហ្មណ៍ទាំងនោះ ពួកសមណព្រាហ្មណ៍ណា បញ្ញត្តថា អត្តាកាលស្លាប់ទៅហើយ ជាសភាវៈមានសញ្ញា ទាំងឥតមានរោគ សមណព្រាហ្មណ៍ដ៏ចម្រើនទាំងនោះ តែងបញ្ញត្តអត្តា ដែលមានរូបថា កាលស្លាប់ទៅហើយ ជាសភាវៈមានសញ្ញា ទាំងឥតមានរោគខ្លះ សមណព្រាហ្មណ៍ដ៏ចម្រើនទាំងនោះ តែងបញ្ញត្តអត្តាដែលមិនមានរូបថា កាលស្លាប់ទៅហើយ ជាសភាវៈមានសញ្ញា ទាំងឥតមានរោគខ្លះ សមណព្រាហ្មណ៍ដ៏ចម្រើនទាំងនោះ តែងបញ្ញត្តអត្តាដែលមានរូបទាំងមិនមានរូបថា កាលស្លាប់ទៅហើយ ជាសភាវៈមានសញ្ញា ទាំងឥតមានរោគខ្លះ សមណព្រាហ្មណ៍ដ៏ចម្រើនទាំងនោះ តែងបញ្ញត្តអត្តាដែលមានរូបក៏មិនមែន មិនមានរូបក៏មិនមែនថា កាលស្លាប់ទៅហើយ ជាសភាវៈមានសញ្ញា ទាំងឥតមានរោគខ្លះ សមណព្រាហ្មណ៍ដ៏ចម្រើនទាំងនោះ តែងបញ្ញត្តអត្តាដែលមានសញ្ញាដូចគ្នាថា កាលស្លាប់ទៅហើយ ជាសភាវៈមានសញ្ញា ទាំងឥតមានរោគខ្លះ សមណព្រាហ្មណ៍ដ៏ចម្រើនទាំងនោះ តែងបញ្ញត្តអត្តាដែលមានសញ្ញាផ្សេងគ្នាថា កាលស្លាប់ទៅហើយ ជាសភាវៈមានសញ្ញា

អរោគំ បរម្មរណា បរិត្តសញ្ញឹ វា តេ ភោន្តោ សមណព្រាហ្មណា សញ្ញឹ អត្តានំ បញ្ញបេន្តិ អរោគំ បរម្មរណា អប្បមាណសញ្ញឹ វា តេ ភោន្តោ សមណព្រាហ្មណា សញ្ញឹ អត្តានំ បញ្ញបេន្តិ អរោគំ បរម្មរណា ឯតំ វា បនេតេសំ ឧបាតិវត្តតំ វិញ្ញាណកសិណមេកេ អភិវទន្តិ អប្បមាណំ អានេញ្ជំ[១] ។ តយិទំ ភិក្ខវេ តថាគតោ បជានាតិ យេ ខោ តេ ភោន្តោ សមណព្រាហ្មណា សញ្ញឹ អត្តានំ បញ្ញបេន្តិ អរោគំ បរម្មរណា រូបឹ វា តេ ភោន្តោ សមណព្រាហ្មណា សញ្ញឹ អត្តានំ បញ្ញបេន្តិ អរោគំ បរម្មរណា អរូបឹ វា តេ ភោន្តោ សមណព្រាហ្មណា សញ្ញឹ អត្តានំ បញ្ញបេន្តិ អរោគំ បរម្មរណា រូបិញ្ច អរូបិញ្ច វា តេ ភោន្តោ សមណព្រាហ្មណា សញ្ញឹ អត្តានំ បញ្ញបេន្តិ អរោគំ បរម្មរណា

---

១ ឱ. អណេញ្ជំ ។

ទាំងឥតមានរោគខ្លះ សមណព្រាហ្មណ៍ដ៏ចម្រើនទាំងនោះ តែងបញ្ញត្តអត្តាដែលមានសញ្ញាតិចថា កាលស្លាប់ទៅហើយ ជាសភាវៈមានសញ្ញា ទាំងឥតមានរោគខ្លះ សមណព្រាហ្មណ៍ ដ៏ចម្រើនទាំងនោះ តែងបញ្ញត្តអត្តា ដែលមានសញ្ញារកប្រមាណមិនបានថា កាលស្លាប់ទៅហើយ ជាសភាវៈមានសញ្ញា ទាំងឥតមានរោគខ្លះ មួយទៀត សមណព្រាហ្មណ៍ពួកខ្លះ សំដែងនូវវិញ្ញាណកសិណ របស់សមណព្រាហ្មណ៍ទាំងនុ៎ះ ដែលជាអ្នកកន្លងនូវសញ្ញាខាងលើទាំង ៧ នុ៎ះថា មិនមានប្រមាណ មិនញាប់ញ័រខ្លះ ។ ម្នាលភិក្ខុទាំងឡាយ តថាគតស្គាល់ច្បាស់នូវដំណើរនោះថា ពួកសមណព្រាហ្មណ៍ដ៏ចម្រើនណា បញ្ញត្តថា អត្តាកាលស្លាប់ទៅហើយ ជាសភាវៈមានសញ្ញា ទាំងឥតមានរោគខ្លះ សមណព្រាហ្មណ៍ដ៏ចម្រើនទាំងនោះ តែងបញ្ញត្តអត្តា ដែលមានរូបថា កាលស្លាប់ទៅហើយ ជាសភាវៈមានសញ្ញា ទាំងឥតមានរោគខ្លះ សមណព្រាហ្មណ៍ដ៏ចម្រើនទាំងនោះ តែងបញ្ញត្តអត្តាដែលមិនមានរូបថា កាលស្លាប់ទៅហើយ ជាសភាវៈមានសញ្ញា ទាំងឥតមានរោគខ្លះ សមណព្រាហ្មណ៍ដ៏ចម្រើនទាំងនោះ តែងបញ្ញត្តអត្តាដែលមានរូបនឹងមិនមានរូបថា កាលស្លាប់ទៅហើយ ជាសភាវៈមានសញ្ញា ទាំងឥតមានរោគខ្លះ

នេវរូបី នារូបី វា តេ ភោន្តោ សមណព្រាហ្មណា
សញ្ញី អត្តានំ បញ្ញបេន្តិ អរោគំ បរម្មរណា
ឯកត្តសញ្ញី វា តេ ភោន្តោ សមណព្រាហ្មណា
សញ្ញី អត្តានំ បញ្ញបេន្តិ អរោគំ បរម្មរណា
នានត្តសញ្ញី វា តេ ភោន្តោ សមណព្រាហ្មណា
សញ្ញី អត្តានំ បញ្ញបេន្តិ អរោគំ បរម្មរណា
បរិត្តសញ្ញី វា តេ ភោន្តោ សមណព្រាហ្មណា
សញ្ញី អត្តានំ បញ្ញបេន្តិ អរោគំ បរម្មរណា
អប្បមាណសញ្ញី វា តេ ភោន្តោ សមណព្រាហ្មណា
សញ្ញី អត្តានំ បញ្ញបេន្តិ អរោគំ បរម្មរណា
យា វា បនេតាសំ(១) សញ្ញានំ បរិសុទ្ធា បរមា
អគ្គា អនុត្តរិយា អក្ខាយតិ យទិ រូបសញ្ញានំ
យទិ អរូបសញ្ញានំ យទិ ឯកត្តសញ្ញានំ យទិ
នានត្តសញ្ញានំ នត្ថិ កិញ្ចីតិ អាកិញ្ចញ្ញាយតន-
មេកេ អភិវទន្តិ អប្បមាណំ អនេញ្ជំ តយិទំ

---

១ ឱ. បនេសំ ។ ម. បន ឯតាសំ ។

សមណព្រាហ្មណ៍ដ៏ចម្រើនទាំងនោះ តែងបញ្ញត្តអត្តាដែលមានរូបក៏មិនមែន មិនមានរូបក៏មិនមែនថា កាលស្លាប់ទៅហើយ ជាសភាវៈមានសញ្ញា ទាំងឥតមានរោគខ្លះ សមណព្រាហ្មណ៍ដ៏ចម្រើនទាំងនោះ តែងបញ្ញត្តអត្តា ដែលមានសញ្ញាដូចគ្នាថា កាលស្លាប់ទៅហើយ ជាសភាវៈមានសញ្ញា ទាំងឥតមានរោគខ្លះ សមណព្រាហ្មណ៍ដ៏ចម្រើនទាំងនោះ តែងបញ្ញត្តអត្តា ដែលមានសញ្ញាផ្សេងគ្នាថា កាលស្លាប់ទៅហើយ ជាសភាវៈមានសញ្ញា ទាំងឥតមានរោគខ្លះ សមណព្រាហ្មណ៍ដ៏ចម្រើនទាំងនោះ តែងបញ្ញត្តអត្តា ដែលមានសញ្ញាតិចថា កាលស្លាប់ទៅហើយ ជាសភាវៈមានសញ្ញា ទាំងឥតមានរោគខ្លះ សមណព្រាហ្មណ៍ដ៏ចម្រើនទាំងនោះ តែងបញ្ញត្តអត្តា ដែលមានសញ្ញារកប្រមាណមិនបានថា កាលស្លាប់ទៅហើយ ជាសភាវៈមានសញ្ញា ទាំងឥតមានរោគខ្លះ មួយទៀត បណ្ដាសញ្ញាទាំងនោះ ទោះជារូបសញ្ញាក្ដី អរូបសញ្ញាក្ដី សញ្ញាដូចគ្នាក្ដី សញ្ញាផ្សេងគ្នាក្ដី សញ្ញាណា ដែលគេថាបរិសុទ្ធខ្ពង់ខ្ពស់ប្រសើរថ្លៃថ្លា សមណព្រាហ្មណ៍ពួកខ្លះសំដែង (នូវសញ្ញានោះ) គឺអាកិញ្ចញ្ញាយតនសញ្ញា ដែលបរិកម្មថា អ្វីតិចតួចមិនមាន ជាជាសញ្ញាមិនមានប្រមាណ មិនញាប់ញ័រ តែសញ្ញា ( ទាំងអស់ ) នោះ

សង្ខតំ ឱឡារិកំ អត្ថិ ខោ បន សង្ខារានំ និរោធោ អត្ថេតន្តិ ឥតិ វិទិត្វា តស្ស និស្សរណទស្សាវី តថាគតោ តទុបាតិវត្តោ ។

(៣១) តត្រ ភិក្ខវេ យេ តេ សមណព្រាហ្មណា អសញ្ញឹ អត្តានំ បញ្ញបេន្តិ អរោគំ បរម្មរណា រូបឹ វា តេ ភោន្តោ សមណព្រាហ្មណា អសញ្ញឹ អត្តានំ បញ្ញបេន្តិ អរោគំ បរម្មរណា អរូបឹ វា តេ ភោន្តោ សមណព្រាហ្មណា អសញ្ញឹ អត្តានំ បញ្ញបេន្តិ អរោគំ បរម្មរណា រូបិញ្ច អរូបិញ្ច វា តេ ភោន្តោ សមណព្រាហ្មណា អសញ្ញឹ អត្តានំ បញ្ញបេន្តិ អរោគំ បរម្មរណា នេវរូបឹ នារូបឹ វា តេ ភោន្តោ សមណព្រាហ្មណា អសញ្ញឹ អត្តានំ បញ្ញបេន្តិ អរោគំ បរម្មរណា ។ តត្រ ភិក្ខវេ

ជាសង្ខតធម៌ គឺមានបច្ច័យប្រជុំតាក់តែង ជារបស់គ្រោតគ្រាត ចំណែកខាងការរលត់នៃសង្ខារទាំងឡាយមានពិត ព្រះនិព្វានក៏មានពិត លុះព្រះតថាគតបានដឹងច្បាស់ដូច្នេះហើយ ជាអ្នកឃើញនូវការរលាស់ចេញនូវសង្ខតធម៌នោះ កន្លងនូវសង្ខតធម៌នោះ ។

(៣១) ម្នាលភិក្ខុទាំងឡាយ បណ្តាសមណព្រាហ្មណ៍ទាំងនោះ សមណព្រាហ្មណ៍ណា បញ្ញត្តថា អត្តាកាលស្លាប់ទៅហើយ ជាសភាវៈមិនមានសញ្ញា ទាំងឥតមានរោគ សមណព្រាហ្មណ៍ដ៏ចម្រើនទាំងនោះ តែងបញ្ញត្តអត្តា ដែលមានរូបថា កាលស្លាប់ទៅហើយ ជាសភាវៈមិនមានសញ្ញា ទាំងឥតមានរោគខ្លះ សមណព្រាហ្មណ៍ដ៏ចម្រើនទាំងនោះ តែងបញ្ញត្តអត្តា ដែលមិនមានរូបថា កាលស្លាប់ទៅហើយ ជាសភាវៈមិនមានសញ្ញា ទាំងឥតមានរោគខ្លះ សមណ–ព្រាហ្មណ៍ដ៏ចម្រើនទាំងនោះ តែងបញ្ញត្តអត្តា ដែលមានរូបនិងមិនមានរូបថា កាលស្លាប់ទៅហើយ ជាសភាវៈមិនមានសញ្ញា ទាំងឥតមានរោគខ្លះ សមណព្រាហ្មណ៍ដ៏ចម្រើនទាំងនោះ តែងបញ្ញត្ត អត្តាដែលមានរូបក៏មិនមែន មិនមានរូបក៏មិនមែនថា កាលស្លាប់ទៅហើយ ជាសភាវៈមិនមានសញ្ញា ទាំងឥតមានរោគខ្លះ ។ ម្នាលភិក្ខុទាំងឡាយ

យេ តេ សមណព្រាហ្មណា សញ្ញឹ អត្តានំ បញ្ញបេន្តិ អរោគំ បរម្មរណា តេសមេកេ[១] បដិក្កោសន្តិ តំ កិស្ស ហេតុ សញ្ញា រោគោ សញ្ញា គណ្ឌោ សញ្ញា សល្លំ ឯតំ សន្តំ ឯតំ[២] បណីតំ យទិទំ អសញ្ញន្តិ ។ តយិទំ ភិក្ខវេ តថាគតោ បជានាតិ យេ ខោ តេ ភោន្តោ សមណព្រាហ្មណា អសញ្ញឹ អត្តានំ បញ្ញបេន្តិ អរោគំ បរម្មរណា រូបឹ វា តេ ភោន្តោ សមណព្រាហ្មណា អសញ្ញឹ អត្តានំ បញ្ញបេន្តិ អរោគំ បរម្មរណា អរូបឹ វា តេ ភោន្តោ សមណព្រាហ្មណា អសញ្ញឹ អត្តានំ បញ្ញបេន្តិ អរោគំ បរម្មរណា រូបិញ្ច អរូបិញ្ច វា តេ ភោន្តោ សមណព្រាហ្មណា អសញ្ញឹ អត្តានំ បញ្ញបេន្តិ អរោគំ បរម្មរណា

---

១ ឱ. ម. តេសមេកេ ។ ២ ឱ. ឯកត្តំ ន ទិស្សតិ ។

បណ្ដាសមណព្រាហ្មណ៍ទាំងនោះ ពួកសមណព្រាហ្មណ៍ណា បញ្ញត្តថា អត្តាកាលស្លាប់ទៅហើយ ជាសភាវៈមានសញ្ញា ទាំងឥតមានរោគ សមណព្រាហ្មណ៍ពួកនេះបដិសេធ (ពាក្យ) របស់ពួកសមណព្រាហ្មណ៍នោះ ដំណើរនោះតើព្រោះហេតុអ្វី (ព្រោះ) សញ្ញាជារោគ សញ្ញាជាបូស សញ្ញាជាព្រួញ ឯដំណើរដែលមិនមានសញ្ញានុះ ទើបជាធម្មជាតស្ងប់ ជាធម្មជាតថ្លៃថ្លា ៗ ម្នាលភិក្ខុទាំងឡាយ តថាគតដឹងច្បាស់នូវដំណើរនោះថា ពួកសមណព្រាហ្មណ៍ដ៏ចម្រើនណា បញ្ញត្តថា អត្តាកាលស្លាប់ទៅហើយ ជាសភាវៈមិនមានសញ្ញា ទាំងឥតមានរោគ សមណ-ព្រាហ្មណ៍ដ៏ចម្រើនទាំងនោះ តែងបញ្ញត្តអត្តាដែលមានរូបថា កាលស្លាប់ទៅហើយ ជាសភាវៈមិនមានសញ្ញា ទាំងឥតមានរោគខ្លះ សមណ-ព្រាហ្មណ៍ដ៏ចម្រើនទាំងនោះ តែងបញ្ញត្តអត្តាដែលមិនមានរូបថា កាលស្លាប់ទៅហើយ ជាសភាវៈមិនមានសញ្ញា ទាំងឥតមានរោគខ្លះ សមណ-ព្រាហ្មណ៍ដ៏ចម្រើនទាំងនោះ តែងបញ្ញត្តអត្តាដែលមានរូបនិងមិនមានរូបថា កាលស្លាប់ទៅហើយ ជាសភាវៈមិនមានសញ្ញា ទាំងឥតមានរោគខ្លះ

នេវរូបឹ នារូបឹ វា តេ ភោន្តោ សមណព្រាហ្មណា អសញ្ញឹ អត្តានំ បញ្ញាបេន្តិ អរោគំ បរម្មរណា យោ ហិ កោចិ ភិក្ខវេ សមណោ វា ព្រាហ្មណោ វា ឯវំ វទេយ្យ អហមញ្ញត្រ រូបា អញ្ញត្រ វេទនាយ អញ្ញត្រ សញ្ញាយ អញ្ញត្រ សង្ខារេហិ អញ្ញត្រ វិញ្ញាណា(១) អាគតឹ វា គតឹ វា ចុតឹ វា ឧបបត្តឹ វា វុឌ្ឍឹ វា វិរុឡ្ហឹ វា វេបុល្លំ វា បញ្ញាបេស្សាមីតិ នេតំ ឋានំ វិជ្ជតិ តយិទំ សង្ខតំ ឱឡារិកំ អត្ថិ ខោ បន សង្ខារានំ និរោធោ អត្ថេតន្តិ ឥតិ វិទិត្វា តស្ស និស្សរណទស្សាវី តថាគតោ តទុបាតិវត្តោ

---
១ ឱ. វិញ្ញាណស្ស ។ ម. វិញ្ញាណេន ។

សមណព្រាហ្មណ៍ដ៏ចម្រើនទាំងនោះ តែងបញ្ញត្តអត្តា ដែលមានរូបក៏មិនមែន មិនមានរូបក៏មិនមែនថា កាលស្លាប់ទៅហើយជាសភាវៈមិនមានសញ្ញា ទាំងឥតមានរោគខ្វះ ម្នាលភិក្ខុទាំងឡាយ តែបើបុគ្គលណាមួយ ជាសមណៈឬព្រាហ្មណ៍ និយាយយ៉ាងនេះថា អាត្មាអញបើវៀរចាករូប វៀរចាកវេទនា វៀរចាកសញ្ញា វៀរចាកសង្ខារទាំងឡាយ វៀរចាកវិញ្ញាណចេញហើយ នឹងដឹងនូវដំណើរជាទីមក (ចាប់បដិសន្ធិ) ឬដំណើរជាទីទៅ ការច្យុតិឬការកើតឡើងឬការចម្រើនឡើង ការលូតលាស់ឬធំទូលាយបាន ពាក្យដូច្នេះនេះ មិនសមហេតុឡើយ (ព្រោះ) ការដែលមិនមានសញ្ញានោះ ជាសង្ខតធម៌ ជារបស់គ្រោតគ្រាត ចំណែកអាងការរលត់ទៅនៃសង្ខារទាំងឡាយមានពិត ព្រះនិព្វាននុ៎ះក៏មានពិត លុះព្រះតថាគត ដឹងច្បាស់ដូច្នេះហើយ ជាអ្នកឃើញនូវការរលាស់ចេញនូវសង្ខតធម៌នោះ កន្លងនូវសង្ខតធម៌នោះ ៗ

(៣២) តត្រ ភិក្ខវេ យេ តេ សមណព្រាហ្មណា នេវសញ្ញឹ នាសញ្ញឹ អត្តានំ បញ្ញបេន្តិ អរោគំ បរម្មរណា រូបឹ វា តេ ភោន្តោ សមណព្រាហ្មណា នេវសញ្ញឹ នាសញ្ញឹ អត្តានំ បញ្ញបេន្តិ អរោគំ បរម្មរណា អរូបឹ វា តេ ភោន្តោ សមណព្រាហ្មណា នេវសញ្ញឹ នាសញ្ញឹ អត្តានំ បញ្ញបេន្តិ អរោគំ បរម្មរណា រូបិញ្ច អរូបិញ្ច វា តេ ភោន្តោ សមណព្រាហ្មណា នេវសញ្ញឹ នាសញ្ញឹ អត្តានំ បញ្ញបេន្តិ អរោគំ បរម្មរណា នេវរូបឹ នារូបឹ វា តេ ភោន្តោ សមណព្រាហ្មណា នេវសញ្ញឹ នាសញ្ញឹ អត្តានំ បញ្ញបេន្តិ អរោគំ បរម្មរណា ។ តត្រ ភិក្ខវេ យេ តេ សមណព្រាហ្មណា សញ្ញឹ អត្តានំ បញ្ញបេន្តិ អរោគំ បរម្មរណា

(៣៦) ម្នាលភិក្ខុទាំងឡាយ បណ្ដាសមណព្រាហ្មណ៍ទាំងនោះ ពួកសមណព្រាហ្មណ៍ណា បញ្ញត្តថា អត្តាកាលស្លាប់ទៅហើយ ជាសភាវៈមានសញ្ញាក៏មិនមែន មិនមានសញ្ញាក៏មិនមែន ទាំងឥតមានរោគ សមណព្រាហ្មណ៍ដ៏ចម្រើនទាំងនោះ តែងបញ្ញត្តអត្តាដែលមានរូបថា កាលស្លាប់ទៅហើយ ជាសភាវៈមានសញ្ញាក៏មិនមែន មិនមានសញ្ញាក៏មិនមែន ទាំងឥតមានរោគខ្លះ សមណព្រាហ្មណ៍ដ៏ចម្រើនទាំងនោះ តែងបញ្ញត្តអត្តា ដែលមិនមានរូបថា កាលស្លាប់ទៅហើយ ជាសភាវៈមានសញ្ញាក៏មិនមែន មិនមានសញ្ញាក៏មិនមែន ទាំងឥតមានរោគខ្លះ សមណព្រាហ្មណ៍ដ៏ចម្រើនទាំងនោះ តែងបញ្ញត្តអត្តាដែលមានរូបនិងមិនមានរូបថា កាលស្លាប់ទៅហើយ ជាសភាវៈមានសញ្ញាក៏មិនមែន មិនមានសញ្ញាក៏មិនមែន ទាំងឥតមានរោគខ្លះ សមណព្រាហ្មណ៍ដ៏ចម្រើនទាំងនោះ តែងបញ្ញត្តអត្តាដែលមានរូបក៏មិនមែន មិនមានរូបក៏មិនមែនថា កាលស្លាប់ទៅហើយ ជាសភាវៈមានសញ្ញាក៏មិនមែន មិនមានសញ្ញាក៏មិនមែន ទាំងឥតមានរោគខ្លះ ។ ម្នាលភិក្ខុទាំងឡាយ បណ្ដាសមណព្រាហ្មណ៍ទាំងនោះ សមណព្រាហ្មណ៍ណា បញ្ញត្តថា អត្តាកាលស្លាប់ទៅហើយ ជាសភាវៈមានសញ្ញា ទាំងឥតមានរោគ

តេសមេតេ បដិក្កោសន្តិ យេបិ តេ ភោន្តោ សម-
ណព្រាហ្មណា អសញ្ញឹ អត្តានំ បញ្ញបេន្តិ អរោគំ
បរម្មរណា តេសមេតេ បដិក្កោសន្តិ តំ កិស្ស
ហេតុ សញ្ញា រោគោ សញ្ញា គណ្ឌោ សញ្ញា
សល្លំ អសញ្ញា សម្មោហោ ឯតំ សន្តំ ឯតំ
បណីតំ យទិទំ នេវសញ្ញានាសញ្ញន្តិ ។ តយិទំ
ភិក្ខវេ តថាគតោ អភិជានាតិ យេ ខោ
តេ ភោន្តោ សមណព្រាហ្មណា នេវសញ្ញី នា-
សញ្ញឹ អត្តានំ បញ្ញបេន្តិ អរោគំ បរម្មរណា រូបំ
វា តេ ភោន្តោ សមណព្រាហ្មណា នេវសញ្ញី
នាសញ្ញឹ អត្តានំ បញ្ញបេន្តិ អរោគំ បរម្មរណា

សមណព្រាហ្មណ៍ពួកនេះបដិសេធ (ពាក្យ) របស់ពួកសមណព្រាហ្មណ៍ទាំងនោះ ព្រោះបើពួកសមណព្រាហ្មណ៍ដ៏ច្រើនណា បញ្ញត្តថា អត្តាកាលស្លាប់ទៅហើយ ជាសភាវៈមិនមានសញ្ញា ទាំងឥតមានរោគ សមណ-ព្រាហ្មណ៍ពួកនេះ ក៏បដិសេធ (ពាក្យ) របស់ពួកសមណព្រាហ្មណ៍ទាំងនោះដែរ ដំណើរនោះតើព្រោះហេតុអ្វី (ព្រោះ) សញ្ញា ជារោគ សញ្ញាជាបូស សញ្ញាជាព្រួញ ការមិនមានសញ្ញាប្រកបដោយមោហ: ដំណើរដែលមានសញ្ញាក៏មិនមែន មិនមានសញ្ញាក៏មិនមែននុ៎ះ ទើបជាធម្មជាតស្ងប់ ជាធម្មជាតឧត្តម ។ ម្នាលភិក្ខុទាំងឡាយ តថាគតដឹងច្បាស់នូវដំណើរនោះថា សមណព្រាហ្មណ៍ដ៏ច្រើនណា បញ្ញត្តអត្តាថា កាលស្លាប់ទៅហើយ ជាសភាវៈមានសញ្ញាក៏មិនមែន មិនមានសញ្ញាក៏មិនមែន ទាំងឥតមានរោគ សមណព្រាហ្មណ៍ដ៏ច្រើនទាំងនោះ តែងបញ្ញត្តអត្តាដែលមានរូបថា កាលស្លាប់ទៅហើយ ជាសភាវៈមានសញ្ញាក៏មិនមែន មិនមានសញ្ញាក៏មិនមែន ទាំងឥតមានរោគខ្លះ

អរូបី វា តេ ភោន្តោ សមណព្រាហ្មណា នេវសញ្ញី នាសញ្ញី អត្តានំ បញ្ញាបេន្តិ អរោគំ បរម្មរណា រូបិញ្ច អរូបិញ្ច វា តេ ភោន្តោ សមណព្រាហ្មណា នេវសញ្ញី នាសញ្ញី អត្តានំ បញ្ញាបេន្តិ អរោគំ បរម្មរណា នេវរូបី នារូបី វា តេ ភោន្តោ សមណព្រាហ្មណា នេវសញ្ញី នាសញ្ញី អត្តានំ បញ្ញាបេន្តិ អរោគំ បរម្មរណា យេ ហិ កេចិ ភិក្ខវេ សមណា វា ព្រាហ្មណា វា ទិដ្ឋសុតមុតវិញ្ញាតព្វសង្ខារមត្តេន[១] ឯតស្ស អាយតនស្ស ឧបសម្បទំ បញ្ញាបេន្តិ ព្យសនំ ហេតំ ភិក្ខវេ អក្ខាយតិ ឯតស្ស អាយតនស្ស ឧបសម្បទាយ ន ហេតំ ភិក្ខវេ អាយតនំ សង្ខារសមាបត្តិបត្តព្វមក្ខាយតិ

១ ឱ. ម. ទិដ្ឋសុតមុតវិញ្ញាតព្វស្សសង្ខារមត្តេន ។

សមណព្រាហ្មណ៍ដ៏ចម្រើនទាំងនោះ តែងបញ្ញត្តអត្តាដែលមិនមានរូបថា កាលស្លាប់ទៅហើយ ជាសភាវៈមានសញ្ញាក៏មិនមែន មិនមានសញ្ញាក៏មិនមែន ទាំងឥតមានរោគខ្លះ សមណព្រាហ្មណ៍ដ៏ចម្រើនទាំងនោះ តែងបញ្ញត្តអត្តាដែលមានរូបនិងមិនមានរូបថា កាលស្លាប់ទៅហើយ ជាសភាវៈមានសញ្ញាក៏មិនមែន មិនមានសញ្ញាក៏មិនមែន ទាំងឥតមានរោគខ្លះ សមណព្រាហ្មណ៍ដ៏ចម្រើនទាំងនោះ តែងបញ្ញត្តអត្តាដែលមានរូបក៏មិនមែន មិនមានរូបក៏មិនមែនថា កាលស្លាប់ទៅហើយ ជាសភាវៈមានសញ្ញាក៏មិនមែន មិនមានសញ្ញាក៏មិនមែន ទាំងឥតមានរោគខ្លះ ម្នាលភិក្ខុទាំងឡាយ តែបើបុគ្គលណាមួយ ជាសមណៈឬព្រាហ្មណ៍ បញ្ញត្តនូវការបាននូវនេវសញ្ញានាសញ្ញាយតនៈនុ៎ះ ដោយត្រឹមតែសង្ខារដែលបុគ្គលត្រូវដឹង ដោយការឃើញ ការឮ ការប៉ះពាល់ ម្នាលភិក្ខុទាំងឡាយ ការបាននូវនេវសញ្ញានាសញ្ញាយតនៈនោះ ប្រាកដជាវិនាសទៅវិញដោយពិត ម្នាលភិក្ខុទាំងឡាយ ព្រោះថានេវសញ្ញា-នាសញ្ញាយតនៈនោះ មិនប្រាកដថាត្រូវបានដោយសង្ខារសមាបត្តិឡើយ

សង្ខារាវសេសសមាបត្តិបត្តព្ពមេតំ ភិក្ខវេ អាយតនំ-
មក្ខាយតិ ។ តយិទំ សង្ខតំ ឱឡារិកំ អត្ថិ ខោ
បន សង្ខារានំ និរោធោ អត្ថេតន្តិ ឥតិ វិទិត្វា
តស្ស និស្សរណទស្សាវី តថាគតោ តទុបាតិវត្តោ ។

(៣៣) តត្រ ភិក្ខវេ យេ តេ សមណព្រាហ្មណា
សតោ សត្តស្ស ឧច្ឆេទំ វិនាសំ វិភវំ បញ្ញបេន្តិ
តត្រ ភិក្ខវេ យេ តេ សមណព្រាហ្មណា សញ្ញី
អត្តានំ បញ្ញបេន្តិ អរោគំ បរម្មរណា តេសមេតេ
បដិក្កោសន្តិ យេបិ តេ ភោន្តោ សមណព្រាហ្មណា
អសញ្ញី អត្តានំ បញ្ញបេន្តិ អរោគំ បរម្មរណា

ម្នាលភិក្ខុទាំងឡាយ នៅសញ្ញានាសញ្ញាយតនៈនុ៎ះ ប្រាកដជាត្រូវបាន ដោយសង្ខារសេសសមាបត្តិ ។ នៅសញ្ញានាសញ្ញាយតនៈនោះ ជាសង្ខតធម៌ដ៏គ្រោតគ្រាត បំណែកខាងការរលត់ទៅនៃសង្ខារទាំងឡាយ មានពិត ព្រោះនិព្វាននុ៎ះក៏មានពិត លុះព្រះតថាគតបានដឹងច្បាស់ដូច្នេះហើយ ជាអ្នកឃើញនូវការរលាស់ចេញនូវសង្ខតធម៌នោះ កន្លងនូវសង្ខតធម៌នោះ ។

(៣៣) ម្នាលភិក្ខុទាំងឡាយ បណ្តាសមណព្រាហ្មណ៍ទាំងនោះ ពួកសមណព្រាហ្មណ៍ណា បញ្ញត្តនូវការដាច់សូន្យ នូវសេចក្តីវិនាស នូវការមិនកើតទៀត របស់ដែលមាននៅ ម្នាលភិក្ខុទាំងឡាយ បណ្តាសមណព្រាហ្មណ៍ទាំងនោះ ពួកសមណព្រាហ្មណ៍ណា បញ្ញត្តថា អត្តាកាលស្លាប់ទៅហើយ ជាសភាវៈមានសញ្ញា ទាំងឥតមានរោគ សមណព្រាហ្មណ៍ពួកនេះបដិសេធ (ពាក្យ) របស់សមណ–ព្រាហ្មណ៍ទាំងនោះ ពួកសមណព្រាហ្មណ៍ដ៏ចម្រើនណាក្តី បញ្ញត្តថា អត្តាកាលស្លាប់ទៅហើយ ជាសភាវៈមិនមានសញ្ញា ទាំងឥតមានរោគ

តេសមេតេ បដិក្កោសន្តិ យេបិ តេ ភោន្តោ សមណព្រាហ្មណា នេវសញ្ញីនាសញ្ញី អត្តានំ បញ្ញាបេន្តិ អរោគំ បរម្មរណា តេសមេតេ បដិក្កោសន្តិ តំ កិស្ស ហេតុ សព្វេបិមេ ភោន្តោ សមណព្រាហ្មណា ឧទ្ធំ បរាមសន្តិ អាសត្តិំយេវ(១) អភិវទន្តិ ឥតិ បេច្ច ភវិស្សាម ឥតិ បេច្ច ភវិស្សាមាតិ ។ សេយ្យថាបិ នាម វាណិជស្ស វាណិជ្ជាយ គច្ឆតោ ឯវំ ហោតិ ឥតោ មេ ឥទំ ភវិស្សតិ ឥមិនា ឥទំ លច្ឆាមីតិ ឯវមេវ ខោ មេ(២) ភោន្តោ សមណព្រាហ្មណា វាណិជូបមំ មញ្ញេ បដិភន្តិ ឥតិ បេច្ច ភវិស្សាម ឥតិ បេច្ច ភវិស្សាមាតិ ។

---

១ ឱ. សរ អាសត្តិំយេវ ។ ម. បរំ អាសត្តិំយេវ ។ ២ ឱ. ឯវមេវិមេ ។ ម. ឯវមេតេ ។

សមណព្រាហ្មណ៍ពួកនេះបដិសេធ (ពាក្យ) របស់សមណព្រាហ្មណ៍ទាំងនោះ ពួកសមណព្រាហ្មណ៍ ដ៏ចម្រើនណាក៏ បញ្ញត្តថា អត្តាកាលស្លាប់ទៅហើយ ជាសភាវៈមានសញ្ញាក៏មិនមែន មិនមានសញ្ញាក៏មិនមែន ទាំងមិនមានរោគ សមណព្រាហ្មណ៍ពួកនេះបដិសេធ (ពាក្យ) របស់សមណព្រាហ្មណ៍ទាំងនោះ ដំណើរនោះតើព្រោះហេតុអ្វី ព្រោះថា សមណព្រាហ្មណ៍ដ៏ចម្រើន ទាំងអស់នេះ តែងប្រកាន់និយាយថា មានសញ្ញាក្នុងអនាគត តែងពោលនូវការជាប់ចំពាក់ គឺតណ្ហាតែមួយយ៉ាងថា យើងទាំងឡាយ នឹងកើតក្នុងលោកខាងមុខដោយអាការដូច្នេះ យើងទាំងឡាយ នឹងកើតក្នុងលោកខាងមុខដោយអាការដូច្នេះ ៗ ឈ្មួញកាលចេញទៅដើម្បីជួញប្រែ តែងមានសេចក្តីត្រិះរិះយ៉ាងនេះថា វត្ថុនេះនឹងមានដល់អញ ដោយសារហេតុនេះ អញនឹងបានវត្ថុនេះ ដោយសារហេតុនេះ សេចក្តីនេះមានឧបមាយ៉ាងណា សមណព្រាហ្មណ៍ដ៏ចម្រើនទាំងនេះ ប្រហែលគ្នានឹងឈ្មួញ រមែងប៉ុនប៉ងថា យើងទាំងឡាយនឹងកើតក្នុងលោកខាងមុខដោយអាការដូច្នេះ យើងទាំងឡាយ នឹងកើតក្នុងលោកខាងមុខដោយអាការដូច្នេះ ក៏មានឧបមេយ្យយ៉ាងនោះឯង ៗ

តយិទំ ភិក្ខវេ តថាគតោ អភិជានាតិ យេ តេ[១] ភោន្តោ សមណព្រាហ្មណា សតោ សត្តស្ស ឧច្ឆេទំ វិនាសំ វិភវំ បញ្ញាបេន្តិ តេ សក្កាយភយា សក្កាយបរិជេគុច្ឆា សក្កាយញ្ញេវ អនុបរិធាវន្តិ អនុបរិវត្តន្តិ ។ សេយ្យថាបិ នាម សា គទ្ទុលពន្ធោ[២] ទឡ្ហេ ថម្ភេ វា ខីលេ វា ឧបនិពន្ធោ[៣] តមេវ ថម្ភំ វា ខីលំ វា អនុបរិធាវតិ អនុបរិវត្តតិ ឯវមេវិមេ ភោន្តោ សមណព្រាហ្មណា សក្កាយភយា សក្កាយបរិជេគុច្ឆា សក្កាយញ្ញេវ អនុបរិធាវន្តិ អនុបរិវត្តន្តិ ។ តយិទំ សង្ខតំ ឱឡារិកំ អត្ថិ ខោ បន សង្ខារានំ និរោធោ អត្ថេតន្តិ ឥតិ វិទិត្វា តស្ស និស្សរណទស្សាវី តថាគតោ តទុបាតិវត្តោ ។

---

១ ឱ. ម. យេ ខោ តេ ។ ២ ឱ. គទ្ទូលពទ្ធោ ។ ម. គទ្ទុលពទ្ធោ ។ ៣ ឱ. ឧបនិពទ្ធោ ។

ម្នាលភិក្ខុទាំងឡាយ តថាគតដឹងច្បាស់នូវដំណើរនុ៎ះថា ពួកសមណព្រាហ្មណ៍ដ៏ចម្រើនណា បញ្ញត្តនូវសេចក្តីដាច់សូន្យ នូវសេចក្តីវិនាស នូវការមិនកើតឡើងទៀត របស់សត្វដែលមាននៅ សមណព្រាហ្មណ៍ទាំងនោះ ជាអ្នកមានភ័យព្រោះសក្កាយ[1] ខ្ពើមរអើមសក្កាយ តែងស្ទុះត្រឡប់ទៅរកសក្កាយវិញដដែល ៗ សុនខជាប់ចំណងដងដោយ[2] ដែលគេចងភ្ជាប់នឹងសសរ ឬនឹងបង្គោល តែងស្ទុះវិលជុំវិញសសរ ឬបង្គោលនោះឯង សេចក្តីនេះមានឧបមាយ៉ាងណា សមណព្រាហ្មណ៍ដ៏ចម្រើនទាំងនេះ ជាអ្នកមានភ័យព្រោះសក្កាយ ខ្ពើមរអើមសក្កាយ តែងស្ទុះត្រឡប់ទៅរកសក្កាយវិញដដែល ក៏មានឧបមេយ្យយ៉ាងនោះឯង ៗ ទិដ្ឋិនោះជាសង្ខតធម៌ដ៏គ្រោតគ្រាត ចំណែកខាងការរលត់ទៅនៃសង្ខារទាំងឡាយមានពិត ព្រះនិព្វាននុ៎ះក៏មានពិត លុះព្រះតថាគតដឹងច្បាស់ដូច្នេះហើយ ជាអ្នកឃើញនូវការរលាស់ចេញនូវសង្ខតធម៌នោះ កន្លងនូវសង្ខតធម៌នោះ ៗ

---

១ ពាក្យថា សក្កាយ សំដៅយកវដ្តៈប្រព្រឹត្តទៅក្នុងភូមិ ៣ ។ អដ្ឋកថា ។ ២ ចំណងនេះ គេយកឈើឬឬស្សីចងបន្តពីកដែកាបៈទៅភ្ជាប់នឹងបង្គោលឬសសរ កុំឲ្យវាខាំខាប់ អ្នកស្រុកខ្លះហៅនឹងដោយ ខ្លះហៅឈើបង្ខាំង ។

(៣៤) យេ ហិ កេចិ ភិក្ខវេ សមណា វា ព្រាហ្មណា វា អបរន្តកប្បិកា អបរន្តានុទិដ្ឋិនោ អបរន្តំ អារព្ភ អនេកវិហិតានិ អធិមុត្តិបទានិ អភិវទន្តិ សព្វេ តេ ឥមានេវ បញ្ចាយតនានិ អភិវទន្តិ ឯតេសំ វា អញ្ញតរំ ។ សន្តិ ភិក្ខវេ ឯកេ សមណ-ព្រាហ្មណា បុព្វន្តកប្បិកា បុព្វន្តានុទិដ្ឋិនោ បុព្វន្តំ អារព្ភ អនេកវិហិតានិ អធិមុត្តិបទានិ អភិវទន្តិ ។ សស្សតោ អត្តា ច លោកោ ច ឥទមេវ សច្ចំ មោឃមញ្ញន្តិ ឥត្ថេកេ អភិវទន្តិ ។ អសស្សតោ អត្តា ច លោកោ ច ឥទមេវ សច្ចំ មោឃមញ្ញន្តិ ឥត្ថេកេ អភិវទន្តិ ។ សស្សតោ ច អសស្សតោ ច អត្តា ច លោកោ ច ឥទមេវ សច្ចំ

(៣៤) ម្នាលភិក្ខុទាំងឡាយ បុគ្គលណាមួយ ជាសមណៈ ឬព្រាហ្មណ៍ ជាអ្នកកំណត់នូវខន្ធជាចំណែកខាងមុខ មានសេចក្តីយល់ឃើញនូវខន្ធជាចំណែកខាងមុខ ប្រារព្ធនូវខន្ធជាចំណែកខាងមុខ ហើយសំដែងនូវចំណែកនៃទិដ្ឋិច្រើនប្រការ សមណព្រាហ្មណ៍ទាំងអស់នោះ តែងសំដែងនូវហេតុទាំង ៥ យ៉ាងនេះឯង ឬក៏បណ្តាហេតុទាំង ៥ យ៉ាងនោះ ហេតុណាមួយ ៗ ម្នាលភិក្ខុទាំងឡាយ មានសមណព្រាហ្មណ៍ពួកមួយ ជាអ្នកកំណត់នូវខន្ធជាចំណែកខាងដើម (ខន្ធអតីត) មានសេចក្តីយល់ឃើញនូវខន្ធជាចំណែកខាងដើម ប្រារព្ធនូវខន្ធជាចំណែកខាងដើម ហើយសំដែងនូវចំណែកនៃទិដ្ឋិច្រើនប្រការ ៗ គឺសមណព្រាហ្មណ៍ពួកខ្លះនិយាយយ៉ាងនេះថា អត្តាក្តី លោកក្តី ជាសការៈទៀង ការយល់ឃើញនេះឯងត្រូវពិត ការយល់ឃើញដទៃ ជាមោឃៈ ៗ សមណព្រាហ្មណ៍ពួកខ្លះនិយាយយ៉ាងនេះថា អត្តាក្តី លោកក្តី ជាសការៈមិនទៀង ការយល់ឃើញនេះឯងត្រូវពិត ការយល់ឃើញដទៃជាមោឃៈ ៗ សមណព្រាហ្មណ៍ពួកខ្លះ និយាយយ៉ាងនេះថា អត្តាក្តី លោកក្តី ជាសការៈទៀងផង មិនទៀងផង ការយល់ឃើញនេះឯងត្រូវពិត

មោឃមញ្ញន្តិ ឥត្ថេកេ អភិវទន្តិ ។ នេវសស្សតោ នាសស្សតោ អត្តា ច លោកោ ច ឥទមេវ សច្ចំ មោឃមញ្ញន្តិ ឥត្ថេកេ អភិវទន្តិ ។ អន្តវា អត្តា ច លោកោ ច ឥទមេវ សច្ចំ មោឃមញ្ញន្តិ ឥត្ថេកេ អភិវទន្តិ ។ អនន្តវា អត្តា ច លោកោ ច ឥទមេវ សច្ចំ មោឃមញ្ញន្តិ ឥត្ថេកេ អភិវទន្តិ ។ អន្តវា ច អនន្តវា ច អត្តា ច លោកោ ច ឥទមេវ សច្ចំ មោឃមញ្ញន្តិ ឥត្ថេកេ អភិវទន្តិ ។ នេវន្តវា នានន្តវា អត្តា ច លោកោ ច ឥទមេវ សច្ចំ មោឃមញ្ញន្តិ ឥត្ថេកេ អភិវទន្តិ ។ ឯកត្តសញ្ញី អត្តា ច លោកោ ច ឥទមេវ សច្ចំ មោឃមញ្ញន្តិ ឥត្ថេកេ អភិវទន្តិ ។ នានត្តសញ្ញី អត្តា ច លោកោ ច ឥទមេវ សច្ចំ មោឃមញ្ញន្តិ ឥត្ថេកេ អភិវទន្តិ ។

ការយល់ឃើញដទៃ ជាមោឃៈ ៗ សមណព្រាហ្មណ៍ពួកខ្លះនិយាយយ៉ាងនេះថា អត្តាក៏ លោកក៏ ជាសភាវៈទៀងក៏មិនមែន មិនទៀងក៏មិនមែន ការយល់ឃើញនេះឯងត្រូវពិត ការយល់ឃើញដទៃ ជាមោឃៈ ៗ សមណព្រាហ្មណ៍ពួកខ្លះ និយាយយ៉ាងនេះថា អត្តាក៏ លោកក៏ មានទីបំផុត ការយល់ឃើញនេះឯងត្រូវពិត ការយល់ឃើញដទៃ ជាមោឃៈ ៗ សមណព្រាហ្មណ៍ពួកខ្លះ និយាយយ៉ាងនេះថា អត្តាក៏ លោកក៏ មិនមានទីបំផុត ការយល់ឃើញនេះឯងត្រូវពិត ការយល់ឃើញដទៃ ជាមោឃៈ ៗ សមណព្រាហ្មណ៍ពួកខ្លះនិយាយយ៉ាងនេះថា អត្តាក៏ លោកក៏ មានទីបំផុតផង មិនមានទីបំផុតផង ការយល់ឃើញនេះឯងត្រូវពិត ការយល់ឃើញដទៃ ជាមោឃៈ ៗ សមណព្រាហ្មណ៍ពួកខ្លះនិយាយយ៉ាងនេះថា អត្តាក៏ លោកក៏ មានទីបំផុតក៏មិនមែន មិនមានទីបំផុតក៏មិនមែន ការយល់ឃើញនេះឯងត្រូវពិត ការយល់ឃើញដទៃ ជាមោឃៈ ៗ សមណព្រាហ្មណ៍ពួកខ្លះនិយាយយ៉ាងនេះថា អត្តាក៏ លោកក៏ មានសញ្ញាដូចគ្នា ការយល់ឃើញនេះឯងត្រូវពិត ការយល់ឃើញដទៃ ជាមោឃៈ ៗ សមណព្រាហ្មណ៍ពួកខ្លះ និយាយយ៉ាងនេះថា អត្តាក៏ លោកក៏ មានសញ្ញាផ្សេងគ្នា ការយល់ឃើញនេះឯងត្រូវពិត ការយល់ឃើញដទៃ ជាមោឃៈ ៗ

ទេវទហវគ្គស្ស បញ្ចត្តយបុតេ អបរនាទិទិដ្ឋិ

បរិត្តសញ្ញី អត្តា ច លោកោ ច ឥទមេវ សច្ចំ មោឃមញ្ញន្តិ ឥត្ថេកេ អភិវទន្តិ ។ អប្បមាណសញ្ញី អត្តា ច លោកោ ច ឥទមេវ សច្ចំ មោឃមញ្ញន្តិ ឥត្ថេកេ អភិវទន្តិ ។ ឯកន្តសុខី អត្តា ច លោកោ ច ឥទមេវ សច្ចំ មោឃមញ្ញន្តិ ឥត្ថេកេ អភិវទន្តិ ។ ឯកន្តទុក្ខី អត្តា ច លោកោ ច ឥទមេវ សច្ចំ មោឃមញ្ញន្តិ ឥត្ថេកេ អភិវទន្តិ ។ សុខទុក្ខី អត្តា ច លោកោ ច ឥទមេវ សច្ចំ មោឃមញ្ញន្តិ ឥត្ថេកេ អភិវទន្តិ ។ អទុក្ខមសុខី អត្តា ច លោកោ ច ឥទមេវ សច្ចំ មោឃមញ្ញន្តិ ឥត្ថេកេ អភិវទន្តិ ។

សមណព្រាហ្មណ៍ពួកខ្លះ និយាយយ៉ាងនេះថា អត្តាក្តី លោកក្តី មានសញ្ញាតិច ការយល់ឃើញនេះឯងត្រូវពិត ការយល់ឃើញដទៃ ជាមោឃៈ ។ សមណព្រាហ្មណ៍ពួកខ្លះនិយាយយ៉ាងនេះថា អត្តាក្តី លោកក្តី មានសញ្ញាមិនមានប្រមាណ ការយល់ឃើញនេះឯងត្រូវពិត ការយល់ឃើញដទៃ ជាមោឃៈ ។ សមណព្រាហ្មណ៍ពួកខ្លះនិយាយយ៉ាងនេះថា អត្តាក្តី លោកក្តី មានសេចក្តីសុខតែមួយយ៉ាង ការយល់ឃើញនេះឯងត្រូវពិត ការយល់ឃើញដទៃ ជាមោឃៈ ។ សមណ-ព្រាហ្មណ៍ពួកខ្លះនិយាយយ៉ាងនេះថា អត្តាក្តី លោកក្តី មានសេចក្តីទុក្ខតែមួយយ៉ាង ការយល់ឃើញនេះឯងត្រូវពិត ការយល់ឃើញដទៃ ជាមោឃៈ ។ សមណព្រាហ្មណ៍ពួកខ្លះ និយាយយ៉ាងនេះថា អត្តាក្តី លោកក្តី មានសុខនិងទុក្ខ ការយល់ឃើញនេះឯងត្រូវពិត ការយល់ឃើញដទៃ ជាមោឃៈ ។ សមណព្រាហ្មណ៍ពួកខ្លះនិយាយយ៉ាងនេះថា អត្តាក្តី លោកក្តី មានអារម្មណ៍មិនជាទុក្ខមិនជាសុខ ការយល់ឃើញនេះឯងត្រូវពិត ការយល់ឃើញដទៃ ជាមោឃៈ ។

(៣៥) ឥធ ភិក្ខវេ យេ តេ សមណព្រាហ្មណា ឯវំវាទិនោ ឯវំទិដ្ឋិនោ សស្សតោ អត្តា ច លោកោ ច ឥទមេវ សច្ចំ មោឃមញ្ញន្តិ តេសំ វត អញ្ញត្រេវ សទ្ធាយ អញ្ញត្រ រុចិយា អញ្ញត្រ អនុស្សវា អញ្ញត្រ អាការបរិវិតក្កា អញ្ញត្រ ទិដ្ឋិនិជ្ឈានក្ខន្តិយា បច្ចត្តញ្ញេវ[១] ញាណំ ភវិស្សតិ បរិសុទ្ធំ បរិយោទាតន្តិ នេតំ ឋានំ វិជ្ជតិ ។ បច្ចត្តំ ខោ បន ភិក្ខវេ ញាណេ អសតិ បរិសុទ្ធេ បរិយោទាតេ យទបិ តេ ភោន្តោ សមណព្រាហ្មណា តត្ថ ញាណភាគមត្តមេវ បរិយោទបេន្តិ តទបិ តេសំ ភវតំ សមណព្រាហ្មណានំ ឧបាទានមក្ខាយតិ ។ តយិទំ សង្ខតំ ឱឡារិកំ អត្ថិ ខោ បន សង្ខារានំ និរោធោ អត្ថេតន្តិ ឥតិ វិទិត្វា តស្ស និស្សរណទស្សាវី តថាគតោ តទុបាតិវត្តោ ។

---

១ ឱ. ម. បច្ចត្តំយេវ ។

(៣៩) ម្នាលភិក្ខុទាំងឡាយ បណ្តាសមណព្រាហ្មណ៍ទាំងនោះ ពួកសមណព្រាហ្មណ៍ណា ជាអ្នកនិយាយយ៉ាងនេះ យល់ឃើញយ៉ាងនេះថា អត្តាក្តី លោកក្តី ជាសភាវៈទៀង ការយល់ឃើញនេះឯងត្រូវពិត ការយល់ឃើញដទៃ ជាមោឃៈ សមណព្រាហ្មណ៍ទាំងនោះ បើវៀរចាកសទ្ធា គឺការជឿ វៀរចាករុចិ គឺសេចក្តីគាប់ចិត្ត វៀរចាកអនុស្សវៈ គឺការឮតៗគ្នា វៀរចាកអាការបរិវិតក្កៈ គឺសេចក្តីត្រិះរិះតាមអាការ វៀរចាកទិដ្ឋិនិជ្ឈានក្ខន្តិ គឺការពេញចិត្តថាត្រូវគ្នានឹងលទ្ធិរបស់ខ្លួន (នោះ) ញាណដ៏បរិសុទ្ធផូរផង់ប្រាកដ ពាក្យដូច្នេះនេះ មិនសមហេតុឡើយ ។ ម្នាលភិក្ខុទាំងឡាយ កាលបើញាណបរិសុទ្ធផូរផង់ប្រាកដមិនមានហើយ សមណព្រាហ្មណ៍ដ៏ចម្រើនទាំងនោះ ញុំាងចំណែកនៃញាណប៉ុណ្ណោះឯង ឲ្យផូរផង់ក្នុងទិដ្ឋិនោះ ដោយហេតុណា ហេតុនោះឯង តថាគតពោលថាជាឧបាទាន របស់សមណព្រាហ្មណ៍ដ៏ចម្រើនទាំងនោះ ។ ទិដ្ឋិនោះជាសង្ខតធម៌គ្រោតគ្រាតនៅឡើយ ចំណែកខាងការរលត់សង្ខារទាំងឡាយមានពិត ព្រះនិព្វានក៏មានពិត លុះព្រះតថាគតដឹងច្បាស់ដូច្នេះហើយ ជាអ្នកឃើញនូវការរលាស់ចេញ នូវទិដ្ឋិនោះ កន្លងនូវទិដ្ឋិនោះ ។

(៣៦) តត្រ ភិក្ខវេ យេ តេ សមណព្រាហ្មណា ឯវំវាទិនោ ឯវំទិដ្ឋិនោ អសស្សតោ អត្តា ច លោកោ ច ឥទមេវ សច្ចំ មោឃមញ្ញន្តិ ។ បេ ។ សស្សតោ ច អសស្សតោ ច អត្តា ច លោកោ ច ... នេវ-សស្សតោ នាសស្សតោ អត្តា ច លោកោ ច ... អន្តវា អត្តា ច លោកោ ច ... អនន្តវា អត្តា ច លោកោ ច... អន្តវា ច អនន្តវា ច អត្តា ច លោកោ ច ... នេវន្តវា នានន្តវា អត្តា ច លោកោ ច ... ឯកត្តសញ្ញី អត្តា ច លោកោ ច ... នានត្តសញ្ញី អត្តា ច លោកោ ច ... បរិត្តសញ្ញី អត្តា ច លោកោ ច ... អប្បមាណសញ្ញី អត្តា ច លោកោ ច ... ឯកន្តសុខី អត្តា ច លោកោ ច ... ឯកន្តទុក្ខី អត្តា ច លោកោ ច ... សុខទុក្ខី អត្តា ច លោកោ ច ... អទុក្ខមសុខី អត្តា ច លោកោ ច ឥទមេវ សច្ចំ មោឃ-មញ្ញន្តិ តេសំ វត អញ្ញត្រេវ សទ្ធាយ អញ្ញត្រ រុចិយា

(៣៦) ម្នាលភិក្ខុទាំងឡាយ បណ្ដាសមណព្រាហ្មណ៍ទាំងនោះ ពួកសមណព្រាហ្មណ៍ណា ជាអ្នកនិយាយយ៉ាងនេះ យល់ឃើញយ៉ាងនេះថា អត្តាក្ដី លោកក្ដី ជាសភាវៈមិនទៀង ការយល់ឃើញនេះឯងត្រូវពិត ការយល់ឃើញដទៃ ជាមោឃៈ ។ បេ ។ អត្តាក្ដី លោកក្ដី ជាសភាវៈទៀងផង មិនទៀងផង .. អត្តាក្ដី លោកក្ដី ជាសភាវៈទៀងក៏មិនមែន មិនទៀងក៏មិនមែន ... អត្តាក្ដី លោកក្ដី មានទីបំផុត ... អត្តាក្ដី លោកក្ដី មិនមានទីបំផុត ... អត្តាក្ដី លោកក្ដី មានទីបំផុតផង មិនមានទីបំផុតផង ... អត្តាក្ដី លោកក្ដី មានទីបំផុតក៏មិនមែន មិនមានទីបំផុតក៏មិនមែន ... អត្តាក្ដី លោកក្ដី មានសញ្ញាដូចគ្នា ... អត្តាក្ដី លោកក្ដី មានសញ្ញាផ្សេងគ្នា ... អត្តាក្ដី លោកក្ដី មានសញ្ញាតិច ... អត្តាក្ដី លោកក្ដី មានសញ្ញាមិនមានប្រមាណ ... អត្តាក្ដី លោកក្ដី មានសេចក្ដីសុខតែមួយយ៉ាង ... អត្តាក្ដី លោកក្ដី មានសេចក្ដីទុក្ខតែមួយយ៉ាង ... អត្តាក្ដី លោកក្ដី មានសេចក្ដីសុខនិងទុក្ខ ... អត្តាក្ដី លោកក្ដី មានអារម្មណ៍មិនមែនជាទុក្ខមិនមែនជាសុខ ការយល់ឃើញនេះឯងត្រូវពិត ការយល់ឃើញដទៃ ជាមោឃៈ សមណ-ព្រាហ្មណ៍ទាំងនោះឯង បើវៀរចាកការជឿ វៀរចាកសេចក្ដីគាប់ចិត្ត

អញ្ញត្រ អនុស្សវា អញ្ញត្រ អាការបរិវិតក្កា អញ្ញត្រ ទិដ្ឋិនិជ្ឈានក្ខន្តិយា បច្ចត្តញ្ញេវ ញាណំ ភវិស្សតិ បរិសុទ្ធំ បរិយោទាតន្តិ នេតំ ឋានំ វិជ្ជតិ ។ បច្ចត្តំ ខោ បន ភិក្ខវេ ញាណេ អសតិ បរិសុទ្ធេ បរិយោទាតេ យទបិ តេ ភោន្តោ សមណព្រាហ្មណា តត្ថ ញាណភាគមត្តមេវ បរិយោទបេន្តិ តទបិ តេសំ ភវតំ សមណព្រាហ្មណានំ ឧបាទានមក្ខាយតិ ។ តយិទំ សង្ខតំ ឱឡារិកំ អត្ថិ ខោ បន សង្ខារានំ និរោធោ អត្ថេតន្តិ ឥតិ វិទិត្វា តស្ស និស្សរណទស្សាវី តថាគតោ តទុបាតិវត្តោ ។

(៣៧) ឥធ ភិក្ខវេ ឯកច្ចោ សមណោ វា ព្រាហ្មណោ វា បុព្វន្តានុទិដ្ឋីនញ្ច បដិនិស្សគ្គា អបរន្តានុទិដ្ឋីនញ្ច បដិនិស្សគ្គា សព្វសោ កាមសញ្ញោជនានំ(១) អនធិដ្ឋានា បវិវេកំ បីតឹ ឧបសម្បជ្ជ វិហរតិ ឯតំ សន្តំ ឯតំ បណីតំ យទិទំ បវិវេកំ បីតឹ ឧបសម្បជ្ជ វិហរាមីតិ ។

---

១ ឱ. ម. កាមសំយោជនានំ ។

វៀរចាកការឮតៗគ្នា វៀរចាកការត្រិះរិះតាមអាការ វៀរចាកការពេញចិត្តថាត្រូវគ្នានឹងលទ្ធិរបស់ខ្លួន (នោះ) ញាណនឹងបរិសុទ្ធផូរផង់ប្រាកដ ពាក្យដូច្នេះ នេះមិនសមហេតុឡើយ ។ ម្នាលភិក្ខុទាំងឡាយ កាលបើញាណបរិសុទ្ធផូរផង់ប្រាកដមិនមានហើយ សមណព្រាហ្មណ៍ដ៏ចម្រើនទាំងនោះ ញុំាងចំណែកនៃញាណប៉ុណ្ណោះឯង ឲ្យផូរផង់ក្នុងទិដ្ឋិនោះ ដោយហេតុណា ហេតុនោះឯង តថាគតពោលថាជាទោសរបស់សមណព្រាហ្មណ៍ដ៏ចម្រើនទាំងនោះ ។ ទិដ្ឋិនោះជាសង្ខតធម៌ដ៏គ្រោតគ្រាតនៅឡើយ ចំណែកខាងការរលត់សង្ខារទាំងឡាយមានពិត ព្រះនិព្វានក៏មានពិត លុះព្រះតថាគតដឹងច្បាស់ដូច្នេះហើយ ជាអ្នកឃើញនូវការរលាស់នូវទិដ្ឋិនោះ កន្លងនូវទិដ្ឋិនោះ ។

(៣៧) ម្នាលភិក្ខុទាំងឡាយ សមណៈឬព្រាហ្មណ៍ពួកខ្លះ ក្នុងលោកនេះ ព្រោះលះបង់នូវបុព្វន្តានុទិដ្ឋិ គឺសេចក្ដីយល់ឃើញនូវខន្ធជាចំណែកខាងដើមផង លះបង់នូវអបរន្តានុទិដ្ឋិ គឺសេចក្ដីយល់ឃើញនូវខន្ធជាចំណែកខាងមុខផង ទាំងមិនអធិដ្ឋានទុកនូវកាមសញ្ញោជនៈដោយសព្វគ្រប់ រមែងបានបីតិដែលស្ងប់ស្ងាត់ហើយ ក៏គិតថា អាត្មាអញបានបីតិដ៏ស្ងប់ស្ងាត់ ដែលជាគុណជាតស្ងប់រម្ងាប់ ជាគុណជាតថ្លៃថ្លា ។

តស្ស សា បវិវេកា បីតិ និរុជ្ឈតិ បវិវេកាយ បីតិយា និរោធា ឧប្បជ្ជតិ ទោមនស្សំ ទោមនស្សស្ស និរោធា ឧប្បជ្ជតិ បវិវេកា បីតិ ។ សេយ្យថាបិ ភិក្ខវេ យំ ឆាយា ជហាតិ តំ អាតបោ ផរតិ យំ អាតបោ ជហាតិ តំ ឆាយា ផរតិ ឯវមេវ ខោ ភិក្ខវេ បវិវេកាយ បីតិយា និរោធា ឧប្បជ្ជតិ ទោមនស្សំ ទោមនស្សស្ស និរោធា ឧប្បជ្ជតិ បវិវេកា បីតិ ។ តយិទំ ភិក្ខវេ តថាគតោ បជានាតិ អយំ ខោ ភវំ សមណោ វា ព្រាហ្មណោ វា បុព្វន្តានុទិដ្ឋិញ្ច បដិនិស្សគ្គា អបរន្តានុទិដ្ឋិញ្ច បដិនិស្សគ្គា សព្វសោ កាមសញ្ញោជនានំ អនធិដ្ឋានា បវិវេកំ បីតឹ ឧបសម្បជ្ជ វិហរតិ ឯតំ សន្តំ ឯតំ បណីតំ យទិទំ បវិវេកំ បីតឹ ឧបសម្បជ្ជ វិហរាមីតិ ។ តស្ស សា បវិវេកា បីតិ និរុជ្ឈតិ បវិវេកាយ បីតិយា និរោធា ឧប្បជ្ជតិ ទោមនស្សំ ទោមនស្សស្ស និរោធា ឧប្បជ្ជតិ

បីតិដ៏ស្ងប់ស្ងាត់ របស់សមណព្រាហ្មណ៍នោះ រមែងរលត់ទៅ លុះបីតិដ៏ស្ងប់ស្ងាត់រលត់ ទោមនស្សក៏កើតឡើង លុះទោមនស្សរលត់ បីតិដ៏ស្ងប់ស្ងាត់ក៏កើតឡើង ៗ ម្នាលភិក្ខុទាំងឡាយ ម្លប់លះបង់ទីណា កំដៅថ្ងៃ ក៏ផ្សាយទៅកាន់ទីនោះ កំដៅថ្ងៃលះបង់ទីណា ម្លប់ក៏ផ្សាយទៅកាន់ទីនោះ សេចក្តីនេះ មានឧបមាយ៉ាងណាមិញ ម្នាលភិក្ខុទាំង-ឡាយ កាលបីតិដ៏ស្ងប់ស្ងាត់រលត់ ទោមនស្សក៏កើតឡើង កាលទោមនស្សរលត់ បីតិដ៏ស្ងប់ស្ងាត់ក៏កើតឡើង ក៏មានឧបមេយ្យយ៉ាងនោះឯង ៗ ម្នាលភិក្ខុទាំងឡាយ តថាគតដឹងច្បាស់នូវដំណើរនោះថា សមណៈឬព្រាហ្មណ៍ដ៏ប្រសើរនេះ ព្រោះលះបង់នូវបុព្វន្តានុទិដ្ឋិផង លះបង់នូវអបរន្តានុទិដ្ឋិផង ទាំងមិនអធិដ្ឋានទុក នូវកាមសញ្ញោជនៈ ដោយសព្វគ្រប់ ក៏រមែងបានបីតិដ៏ស្ងប់ស្ងាត់ ហើយក៏គិតថា អាត្មាអញបានបីតិដ៏ស្ងប់ស្ងាត់ដែលជាគុណជាតស្ងប់រម្ងាប់ ជាគុណជាតថ្លៃថ្លា ៗ បីតិដ៏ស្ងប់ស្ងាត់ របស់សមណព្រាហ្មណ៍នោះ រមែងរលត់ លុះបីតិដ៏ស្ងប់ស្ងាត់រលត់ ទោមនស្សក៏កើតឡើង លុះទោមនស្សរលត់

បវិវេកា បីតិ ។ តយិទំ សង្ខតំ ឱឡារិកំ អត្ថិ ខោ បន សង្ខារានំ និរោធោ អត្ថេតន្តិ ឥតិ វិទិត្វា តស្ស និស្សរណទស្សាវី តថាគតោ តទុបាតិវត្តោ ។

(១៨) ឥធ បន ភិក្ខវេ ឯកច្ចោ សមណោ វា ព្រាហ្មណោ វា បុព្វន្តានុទិដ្ឋីនញ្ច បដិនិស្សគ្គា អបរន្តានុទិដ្ឋីនញ្ច បដិនិស្សគ្គា សព្វសោ កាម-សញ្ញោជនានំ អនធិដ្ឋានា បវិវេកាយ បីតិយា សម-តិក្កមា និរាមិសំ សុខំ ឧបសម្បជ្ជ វិហរតិ ឯតំ សន្តំ ឯតំ បណីតំ យទិទំ និរាមិសំ សុខំ ឧបសម្បជ្ជ វិហរាមីតិ ។ តស្ស តំ និរាមិសំ សុខំ និរុជ្ឈតិ និរាមិសស្ស សុខស្ស និរោធា ឧប្បជ្ជតិ បវិវេកា បីតិ បវិវេកាយ បីតិយា និរោធា ឧប្បជ្ជតិ និរាមិសំ សុខំ ។

បីតិដ៏ស្ងប់ស្ងាត់ក៏កើតឡើង ៗ ទិដ្ឋិនោះជាសង្ខតធម៌ ដ៏គ្រោតគ្រាតនៅឡើយ ចំណែកខាងការរលត់សង្ខារទាំងឡាយមានពិត ព្រះនិព្វានក៏មានពិត លុះព្រះតថាគតដឹងច្បាស់ដូច្នេះហើយ ជាអ្នកឃើញនូវការរលាស់ចេញនូវទិដ្ឋិនោះ កន្លងនូវទិដ្ឋិនោះ ៗ

(៣៨) ម្នាលភិក្ខុទាំងឡាយ សមណៈឬព្រាហ្មណ៍ពួកខ្លះ ក្នុងលោកនេះ ព្រោះលះបង់នូវបុព្វន្តានុទិដ្ឋិផង លះបង់នូវអបរន្តានុទិដ្ឋិផង ទាំងមិនអធិដ្ឋានទុកនូវកាមសញ្ញោជនៈ ដោយសព្វគ្រប់ កន្លងនូវបីតិដ៏ស្ងប់ស្ងាត់ ក៏បាននូវនិរាមិសសុខ គឺសេចក្តីសុខមិនមានអាមិសៈ ហើយគិតថា អាត្មាអញ បាននូវនិរាមិសសុខ ដែលជាគុណជាតដ៏ស្ងប់រម្ងាប់ ជាគុណជាតដ៏ថ្លៃថ្លា ៗ និរាមិសសុខរបស់សមណព្រាហ្មណ៍នោះ រមែងរលត់ លុះនិរាមិសសុខរលត់ បីតិដ៏ស្ងប់ស្ងាត់ ក៏កើតឡើង លុះបីតិដ៏ស្ងប់ស្ងាត់រលត់ និរាមិសសុខ ក៏កើតឡើង ៗ

សេយ្យថាបិ ភិក្ខវេ យំ ឆាយា ជហតិ តំ អាតបោ ផរតិ យំ អាតបោ ជហតិ តំ ឆាយា ផរតិ ឯវមេវ ខោ ភិក្ខវេ និរាមិសស សុខស្ស និរោធា ឧប្បជ្ជតិ បវិវេកា បីតិ បវិវេកាយ បីតិយា និរោធា ឧប្បជ្ជតិ និរាមិសំ សុខំ ។ តយិទំ ភិក្ខវេ តថាគតោ បជានាតិ អយំ ខោ ភវំ សមណោ វា ព្រាហ្មណោ វា បុព្វន្តានុទិដ្ឋីនញ្ច បដិនិស្សគ្គា អបរន្តានុទិដ្ឋីនញ្ច បដិនិស្សគ្គា សព្វសោ កាមសញ្ញោជនានំ អនធិដ្ឋានា បវិវេកាយ បីតិយា សមតិក្កមា និរាមិសំ សុខំ ឧបសម្បជ្ជ វិហរតិ ឯតំ សន្តំ ឯតំ បណីតំ យទិទំ និរាមិសំ សុខំ ឧបសម្បជ្ជ វិហរាមីតិ ។ តស្ស តំ និរាមិសំ សុខំ និរុជ្ឈតិ និរាមិសស្ស សុខស្ស និរោធា ឧប្បជ្ជតិ បវិវេកា បីតិ បវិវេកាយ បីតិយា និរោធា ឧប្បជ្ជតិ និរាមិសំ សុខំ ។ តយិទំ សង្ខតំ ឱឡារិកំ អត្ថិ ខោ បន សង្ខារានំ និរោធោ អត្ថេតន្តិ ឥតិ វិទិត្វា តស្ស និស្សរណទស្សាវី តថាគតោ តទុបាតិវត្តោ ។

ម្នាលភិក្ខុទាំងឡាយ ម្លប់លះបង់ទីណា កំដៅថ្ងៃក៏ផ្សាយទៅកាន់ទីនោះ កំដៅថ្ងៃលះបង់ទីណា ម្លប់ក៏ផ្សាយទៅកាន់ទីនោះ សេចក្តីនេះ មានឧបមាយ៉ាងណាមិញ ម្នាលភិក្ខុទាំងឡាយ កាលនិរាមិសសុខរលត់ បីតិដ៏ស្ងប់ស្ងាត់ ក៏កើតឡើង កាលបីតិដ៏ស្ងប់ស្ងាត់រលត់ និរាមិសសុខក៏កើតឡើង ក៏មានឧបមេយ្យយ៉ាងនោះឯង ។ ម្នាលភិក្ខុទាំងឡាយ ព្រះតថាគតដឹងច្បាស់នូវដំណើរនោះថា សមណៈឬព្រាហ្មណ៍ដ៏ចម្រើននេះ ព្រោះលះបង់នូវបុព្វន្តានុទិដ្ឋិផង លះបង់នូវអបរន្តានុទិដ្ឋិផង ទាំងមិនអធិដ្ឋានទុកនូវកាមសញ្ញោជនៈដោយសព្វគ្រប់ កន្លងនូវបីតិដ៏ស្ងប់ស្ងាត់ ក៏បាននូវនិរាមិសសុខ ហើយក៏គិតថា អាត្មាអញបាននូវនិរាមិសសុខ ដែលជាគុណជាតដ៏ស្ងប់រម្ងាប់ ជាគុណជាតដ៏ថ្លៃថ្លា ។ និរាមិសសុខរបស់សមណព្រាហ្មណ៍នោះ រមែងរលត់ លុះនិរាមិសសុខរលត់ បីតិដ៏ស្ងប់ស្ងាត់ក៏កើតឡើង លុះបីតិដ៏ស្ងប់ស្ងាត់រលត់ និរាមិសសុខក៏កើតឡើង ។ ទិដ្ឋិនោះជាសង្ខតធម៌ ដ៏គ្រោតគ្រាតនៅឡើយ ចំណែកខាងការរលត់នៃសង្ខារទាំងឡាយ មានពិត ព្រះនិព្វាន ក៏មានពិត លុះព្រះតថាគត ដឹងច្បាស់ដូច្នេះហើយ ជាអ្នកឃើញនូវការរលាស់ចេញនូវទិដ្ឋិនោះ កន្លងនូវទិដ្ឋិនោះ ។

(៣៩) ឥធ ភិក្ខវេ ឯកច្ចោ សមណោ វា ព្រាហ្មណោ វា បុព្វន្តានុទិដ្ឋីនញ្ច បដិនិស្សគ្គា អបរន្តានុទិដ្ឋីនញ្ច បដិនិស្សគ្គា សព្វសោ កាមសញ្ញោជនានំ អនធិដ្ឋានា បវិវេកាយ បីតិយា សមតិក្កមា និរាមិសស្ស សុខស្ស សមតិក្កមា អទុក្ខមសុខំ វេទនំ ឧបសម្បជ្ជ វិហរតិ ឯតំ សន្តំ ឯតំ បណីតំ យទិទំ អទុក្ខមសុខំ វេទនំ ឧបសម្បជ្ជ វិហរាមីតិ ។ តស្ស សា អទុក្ខមសុខា វេទនា និរុជ្ឈតិ អទុក្ខមសុខាយ វេទនាយ និរោធា ឧប្បជ្ជតិ និរាមិសំ សុខំ និរាមិសស្ស សុខស្ស និរោធា ឧប្បជ្ជតិ អទុក្ខមសុខា វេទនា ។ សេយ្យថាបិ ភិក្ខវេ យំ ឆាយា ជហតិ តំ អាតបោ ផរតិ យំ អាតបោ ជហតិ តំ ឆាយា ផរតិ ឯវមេវ ខោ ភិក្ខវេ អទុក្ខមសុខាយ វេទនាយ និរោធា ឧប្បជ្ជតិ និរាមិសំ សុខំ និរាមិសស្ស សុខស្ស និរោធា ឧប្បជ្ជតិ អទុក្ខមសុខា វេទនា ។ តយិទំ ភិក្ខវេ តថាគតោ បជានាតិ

(៣៩) ម្នាលភិក្ខុទាំងឡាយ សមណៈឬព្រាហ្មណ៍ពួកខ្លះ ក្នុងលោកនេះ ព្រោះលះបង់នូវបុព្វន្តានុទិដ្ឋិផង លះបង់នូវអបរន្តានុទិដ្ឋិផង ទាំងមិនអធិដ្ឋាននូវកាមសញ្ញោជនៈ ដោយសព្វគ្រប់ កន្លងនូវបីតិដ៏ស្ងប់ស្ងាត់ កន្លងនូវនិរាមិសសុខ ក៏បាននូវអទុក្ខមសុខវេទនា គឺទទួលអារម្មណ៍មិនជាទុក្ខមិនជាសុខ ហើយគិតថា អាត្មាអញបាននូវអទុក្ខមសុខវេទនា ដែលជាគុណជាតស្ងប់ស្ងាប់ ជាគុណជាតថ្លៃថ្លា ។ អទុក្ខមសុខវេទនារបស់សមណព្រាហ្មណ៍នោះ រមែងរលត់ លុះអទុក្ខមសុខវេទនារលត់ និរាមិសសុខ ក៏កើតឡើង លុះនិរាមិសសុខរលត់ អទុក្ខមសុខវេទនា ក៏កើតឡើង ។ ម្នាលភិក្ខុទាំងឡាយ ម្លប់លះបង់ទីណា កំដៅថ្ងៃ ក៏ផ្សាយទៅ កាន់ទីនោះ កំដៅថ្ងៃលះបង់ទីណា ម្លប់ក៏ផ្សាយទៅកាន់ទីនោះ សេចក្តីនេះ មានឧបមាយ៉ាងណាមិញ ម្នាលភិក្ខុទាំងឡាយ កាលអទុក្ខមសុខវេទនារលត់ និរាមិសសុខក៏កើតឡើង កាលនិរាមិសសុខរលត់ អទុក្ខមសុខវេទនាក៏កើតឡើង ក៏មានឧបមេយ្យយ៉ាងនោះឯង ។ ម្នាលភិក្ខុទាំងឡាយ ព្រះតថាគតដឹងច្បាស់នូវដំណើរនោះថា

អយំ វា តំ សមណោ វា ព្រាហ្មណោ វា
បុព្វន្តានុទិដ្ឋីនញ្ច បដិនិស្សគ្គា អបរន្តានុទិដ្ឋីនញ្ច
បដិនិស្សគ្គា សព្វសោ កាមសញ្ញោជនានំ អនធិដ្ឋានា
បវិវេកាយ បីតិយា សមតិក្កមា និរាមិសស្ស
សុខស្ស សមតិក្កមា អទុក្ខមសុខំ វេទនំ ឧបសម្បជ្ជ
វិហរតិ ឯតំ សន្តំ ឯតំ បណីតំ យទិទំ អទុក្ខមសុខំ
វេទនំ ឧបសម្បជ្ជ វិហរាមីតិ ។ តស្ស សា អទុក្ខ-
មសុខា វេទនា និរុជ្ឈតិ អទុក្ខមសុខាយ វេទនាយ
និរោធា ឧប្បជ្ជតិ និរាមិសំ សុខំ និរាមិសស្ស
សុខស្ស និរោធា ឧប្បជ្ជតិ អទុក្ខមសុខា វេទនា ។
តយិទំ សង្ខតំ ឱឡារិកំ អត្ថិ ខោ បន សង្ខារានំ
និរោធោ អត្ថេតន្តិ ឥតិ វិទិត្វា តស្ស និស្សរណទស្សាវី
តថាគតោ តទុបាតិវត្តោ ។

សមណៈឬព្រាហ្មណ៍ដ៏ចម្រើននេះ ព្រោះលះបង់នូវបុព្វន្តានុទិដ្ឋិផង លះបង់នូវអបរន្តានុទិដ្ឋិផង ព្រោះមិនអធិដ្ឋានទុកនូវកាមសញ្ញោជនៈដោយសព្វគ្រប់ កន្លងនូវបីតិដ៏ស្ងប់ស្ងាត់ កន្លងនូវនិរាមិសសុខ កំបាននូវអទុក្ខមសុខវេទនា ហើយគិតថា អាត្មាអញបាននូវអទុក្ខមសុខវេទនា ជាគុណជាតស្ងប់រម្ងាប់ ជាគុណជាតថ្លៃថ្លា ។ អទុក្ខមសុខវេទនា របស់សមណព្រាហ្មណ៍នោះ រមែងរលត់ លុះអទុក្ខមសុខវេទនា រលត់និរាមិសសុខ ក៏កើតឡើង លុះនិរាមិសសុខរលត់ អទុក្ខមសុខវេទនាក៏កើតឡើង ។ ទិដ្ឋិនោះ ជាសង្ខតធម៌ ដ៏គ្រោតគ្រាតនៅឡើយ បំណែកខាងការរលត់សង្ខារទាំងឡាយ មានពិត ព្រះនិព្វានក៏មានពិត លុះព្រះតថាគត ដឹងច្បាស់ដូច្នេះហើយ ជាអ្នកឃើញនូវការរលាស់ចេញនូវទិដ្ឋិនោះ កន្លងនូវទិដ្ឋិនោះ ។

(៤០) ឥធ បន ភិក្ខវេ ឯកច្ចោ សមណោ វា ព្រាហ្មណោ វា បុព្វន្តានុទិដ្ឋីនញ្ច បដិនិស្សគ្គា អបរន្តានុទិដ្ឋីនញ្ច បដិនិស្សគ្គា សព្វសោ កាមសញ្ញោជនានំ អនធិដ្ឋានា បវិវេកាយ បីតិយា សមតិក្កមា និរាមិសស្ស សុខស្ស សមតិក្កមា អទុក្ខមសុខាយ វេទនាយ សមតិក្កមា សន្តោហមស្មិ និព្វុតោហមស្មិ អនុបាទានោហមស្មីតិ សមនុបស្សតិ ។ តយិទំ ភិក្ខវេ តថាគតោ បជានាតិ អយំ ខោ ភវំ សមណោ វា ព្រាហ្មណោ វា បុព្វន្តានុទិដ្ឋីនញ្ច បដិនិស្សគ្គា អបរន្តានុទិដ្ឋីនញ្ច បដិនិស្សគ្គា សព្វសោ កាមសញ្ញោជនានំ អនធិដ្ឋានា បវិវេកាយ បីតិយា សមតិក្កមា និរាមិសស្ស សុខស្ស សមតិក្កមា អទុក្ខមសុខាយ វេទនាយ សមតិក្កមា សន្តោហមស្មិ និព្វុតោហមស្មិ អនុបាទានោហមស្មីតិ សមនុបស្សតិ ។ អទ្ធា អយមាយស្មា និព្វានសប្បាយមេវ[១] បដិបទំ អភិវទតិ

---

១ ម. និព្វានសប្បាយំយេវ ។

(៤០) ម្នាលភិក្ខុទាំងឡាយ សមណៈឬព្រាហ្មណ៍ពួកខ្លះ ក្នុងលោកនេះ ព្រោះលះបង់នូវបុព្វន្តានុទិដ្ឋិផង លះបង់នូវអបរន្តានុទិដ្ឋិផង ទាំងមិនអធិដ្ឋានទុកនូវកាមសញ្ញោជនៈ ដោយសព្វគ្រប់ កន្លងនូវបីតិដ៏ស្ងប់ស្ងាត់ កន្លងនូវនិរាមិសសុខ កន្លងនូវអទុក្ខមសុខវេទនា ក៏ពិចារណាឃើញថា អាត្មាអញជាអ្នកស្ងប់រម្ងាប់ អាត្មាអញជាអ្នករលត់ទុក្ខ អាត្មាអញជាអ្នកមិនមានសេចក្តីប្រកាន់ (ក្នុងបញ្ចក្ខន្ធ) ។ ម្នាលភិក្ខុទាំង-ឡាយ ព្រះតថាគតដឹងច្បាស់នូវដំណើរនោះថា សមណៈឬព្រាហ្មណ៍ដ៏ចម្រើននេះ ព្រោះលះបង់នូវបុព្វន្តានុទិដ្ឋិផង លះបង់នូវអបរន្តានុទិដ្ឋិផង ទាំងមិនអធិដ្ឋានទុកនូវកាមសញ្ញោជនៈ ដោយសព្វគ្រប់ កន្លងនូវបីតិដ៏ស្ងប់ស្ងាត់ កន្លងនូវនិរាមិសសុខ កន្លងនូវអទុក្ខមសុខវេទនា ក៏ពិចារណាឃើញថា អាត្មាអញជាអ្នកស្ងប់រម្ងាប់ អាត្មាអញជាអ្នករលត់ទុក្ខ អាត្មាអញជាអ្នកមិនមានសេចក្តីប្រកាន់ ។ សមណព្រាហ្មណ៍ដ៏មានអាយុនេះ តែងពោលសរសើរ នូវបដិបទាជាទីសប្បាយនៃព្រះនិព្វាន ដោយពិត

អថ(១) បនាយំ កំ សមណោ វា ព្រាហ្មណោ វា បុព្វន្តានុទិដ្ឋី វា ឧបាទិយមានោ ឧបាទិយតិ អបរន្តានុទិដ្ឋី វា ឧបាទិយមានោ ឧបាទិយតិ កាមសញ្ញោជនំ វា ឧបាទិយមានោ ឧបាទិយតិ បវិវេកំ វា បីតឹ ឧបាទិយមានោ ឧបាទិយតិ និរាមិសំ វា សុខំ ឧបាទិយមានោ ឧបាទិយតិ អទុក្ខមសុខំ វា វេទនំ ឧបាទិយមានោ ឧបាទិយតិ ។ យញ្ច ខោ អយមាយស្មា សន្តោហមស្មិ និព្វុតោហមស្មិ អនុបាទានោហមស្មីតិ សមនុបស្សតិ តទបិ ឥមស្ស ភោតោ សមណព្រាហ្មណស្ស ឧបាទានមក្ខាយតិ ។ តយិទំ សង្ខតំ ឱឡារិកំ អត្ថិ ខោ បន សង្ខារានំ និរោធោ អត្ថេតន្តិ ឥតិ វិទិត្វា តស្ស និស្សរណទស្សាវី តថាគតោ តទុបាតិវត្តោ ។

---

១ ឱ. ម. អថ៌ ប ។

ប៉ុន្តែសមណៈឬព្រាហ្មណ៍ដ៏ចម្រើននេះឯង ប្រកាន់មាំនូវបុព្វន្តានុទិដ្ឋិផង ប្រកាន់មាំនូវអបរន្តានុទិដ្ឋិផង ប្រកាន់មាំនូវកាមសញ្ញោជនៈផង ប្រកាន់មាំនូវបីតិដ៏ស្ងប់ស្ងាត់ផង ប្រកាន់មាំនូវនិរាមិសសុខផង ប្រកាន់មាំនូវអទុក្ខមសុខវេទនាផង ។ សមណព្រាហ្មណ៍មានអាយុនេះ ពិចារណាឃើញថា អាត្មាអញជាអ្នកស្ងប់រម្ងាប់ អាត្មាអញជាអ្នករលត់ទុក្ខ អាត្មាអញជាអ្នកមិនមានសេចក្តីប្រកាន់មាំ ដោយហេតុណា ហេតុនោះ ព្រះតថាគតពោលថាជាឧបាទាន (សេចក្តីប្រកាន់មាំ) របស់សមណ_ព្រាហ្មណ៍ដ៏ចម្រើននេះ ។ ឧបាទាននោះជាសង្ខតធម៌ ដ៏គ្រោតគ្រាតនៅឡើយ ចំណែកខាងការរលត់សង្ខារទាំងឡាយមានពិត ព្រះនិព្វានក៏មានពិត លុះព្រះតថាគតដឹងច្បាស់ដូច្នេះហើយ ជាអ្នកឃើញនូវការរលាស់ចេញនូវឧបាទាននោះ កន្លងនូវឧបាទាននោះ ។

(៦១) ឥធ បន ភិក្ខវេ តថាគតេន អនុត្តរំ សន្តំ វរំ បទំ(១) អភិសម្ពុទ្ធំ យទិទំ ឆន្នំ ផស្សាយតនានំ សមុទយញ្ច អត្ថង្គមញ្ច អស្សាទញ្ច អាទីនវញ្ច និស្សរណញ្ច យថាភូតំ វិទិត្វា អនុបាទាវិមោក្ខោ តយិទំ ភិក្ខវេ តថាគតេន អនុត្តរំ សន្តំ វរំ បទំ(២) អភិសម្ពុទ្ធំ យទិទំ ឆន្នំ ផស្សាយតនានំ សមុទយញ្ច អត្ថង្គមញ្ច អស្សាទញ្ច អាទីនវញ្ច និស្សរណញ្ច យថាភូតំ វិទិត្វា អនុបាទាវិមោក្ខោតិ ។ ឥទមវោច ភគវា អត្តមនា តេ ភិក្ខូ ភគវតោ ភាសិតំ អភិនន្ទុន្តិ ។

បញ្ចត្តយសុត្តំ ទុតិយំ និដ្ឋិតំ ។

---

១–២ ឱ. ម. សន្តិវរបទំ ។

(៤១) ម្នាលភិក្ខុទាំងឡាយ ការដឹងច្បាស់តាមពិត នូវកិរិយាកើតឡើងផង នូវកិរិយាវិនាសផង នូវអានិសង្សផង នូវទោសផង នូវកិរិយារលាស់ចេញផង នៃផស្សាយតនៈទាំង ៦ ហើយរួចចាកសេចក្តីប្រកាន់មាំណា នេះឯង ឈ្មោះថាសន្តិវេទ ដ៏ប្រសើរ ដែលព្រះតថាគតត្រាស់ដឹងហើយ ម្នាលភិក្ខុទាំងឡាយ ការដឹងច្បាស់តាមពិត នូវកិរិយាកើតឡើងផង នូវកិរិយាវិនាសផង នូវអានិសង្សផង នូវទោសផង នូវកិរិយារលាស់ចេញផង នៃផស្សាយតនៈទាំង ៦ ហើយ រួចចាកសេចក្តីប្រកាន់មាំណា នោះឯង ឈ្មោះថាសន្តិវេទ ដ៏ប្រសើរ ដែលព្រះតថាគតត្រាស់ដឹងហើយ ។ លុះព្រះមានបុណ្យបានសំដែងព្រះសូត្រនេះចប់ហើយ ភិក្ខុទាំងនោះ ក៏មានចិត្តត្រេកអរ រីករាយចំពោះភាសិត របស់ព្រះមានបុណ្យ ។

ចប់ បញ្ចត្តយសូត្រ ទី ២ ។

## តតិយំ កិន្តិសុត្តំ

(៦២) ឯវំមេ សុតំ ។ ឯកំ សមយំ ភគវា កុសិនារាយំ វិហរតិ ពលិហរណេ វនសណ្ឌេ ។ តត្រ ខោ ភគវា ភិក្ខូ អាមន្តេសិ ភិក្ខវោតិ ។ ភទន្តេតិ តេ ភិក្ខូ ភគវតោ បច្ចស្សោសុំ ។ ភគវា ឯតទវោច កិន្តិ វោ ភិក្ខវេ មយិ ហោតិ ចីវរហេតុ វា សមណោ គោតមោ ធម្មំ ទេសេតិ បិណ្ឌបាតហេតុ វា សមណោ គោតមោ ធម្មំ ទេសេតិ សេនាសនហេតុ វា សមណោ គោតមោ ធម្មំ ទេសេតិ ឥតិ ភវាភវហេតុ វា សមណោ គោតមោ ធម្មំ ទេសេតីតិ ។ ន ខោ នោ ភន្តេ ភគវតិ ឯវំ ហោតិ ចីវរហេតុ វា សមណោ គោតមោ ធម្មំ ទេសេតិ បិណ្ឌបាតហេតុ វា សមណោ គោតមោ ធម្មំ ទេសេតិ សេនាសនហេតុ វា សមណោ គោតមោ ធម្មំ ទេសេតិ ឥតិ ភវាភវហេតុ វា សមណោ គោតមោ ធម្មំ ទេសេតីតិ ។

# កិន្តិសូត្រ ទី ៣

(៤៦) ខ្ញុំបានស្តាប់មក យ៉ាងនេះ ។ សម័យមួយ ព្រះមានព្រះភាគទ្រង់គង់ ក្នុងដងព្រៃ ជាទីនាំមកនូវពលិការ ( ចំពោះភូត ) ជិតក្រុងកុសិនារា ។ ក្នុងទីនោះឯង ព្រះមានព្រះភាគ បានត្រាស់ហៅភិក្ខុទាំងឡាយថា ម្នាលភិក្ខុទាំងឡាយ ។ ភិក្ខុអម្បាលនោះទទួលព្រះពុទ្ធដីកាព្រះមានព្រះភាគថា ព្រះករុណា ព្រះអង្គ ។ ព្រះមានព្រះភាគបានត្រាស់សួរដូច្នេះថា ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយធ្លាប់មានសេចក្តីត្រិះរិះចំពោះតថាគតថា ព្រះសមណគោតមសំដែងធម៌ព្រោះហេតុចីវរខ្លះ ព្រះសមណគោតមសំដែងធម៌ ព្រោះហេតុបិណ្ឌបាតខ្លះ ព្រះសមណគោតមសំដែងធម៌ ព្រោះហេតុសេនាសនៈខ្លះ ព្រះសមណគោតមសំដែងធម៌ ព្រោះហេតុភពតូចភពធំខ្លះ ដូច្នេះដែរឬ ។ បពិត្រព្រះអង្គដ៏ចំរើន ខ្ញុំព្រះអង្គទាំងឡាយ ពុំដែលមានសេចក្តីត្រិះរិះចំពោះព្រះមានព្រះភាគថា ព្រះសមណគោតម សំដែងធម៌ ព្រោះហេតុចីវរខ្លះ ព្រះសមណគោតមសំដែងធម៌ ព្រោះហេតុបិណ្ឌបាតខ្លះ ព្រះសមណគោតមសំដែងធម៌ ព្រោះហេតុសេនាសនៈខ្លះ ព្រះសមណគោតមសំដែងធម៌ ព្រោះហេតុភពតូចភពធំខ្លះ ដូច្នេះឡើយ ។

(៤៣) ន ច ខោ វោ ភិក្ខវេ មយិ ឯវំ ហោតិ ចីវរហេតុ វា សមណោ គោតមោ ធម្មំ ទេសេតិ បិណ្ឌបាតហេតុ វា សមណោ គោតមោ ធម្មំ ទេសេតិ សេនាសនហេតុ វា សមណោ គោតមោ ធម្មំ ទេសេតិ ឥតិ ភវាភវហេតុ វា សមណោ គោតមោ ធម្មំ ទេសេតីតិ អថ កិញ្ចរហិ[1] វោ ភិក្ខវេ មយិ ហោតីតិ ។ ឯវំ ខោ នោ ភន្តេ ភគវតិ ហោតិ អនុកម្បកោ ភគវា ហិតេសី អនុកម្បំ ឧបាទាយ ធម្មំ ទេសេតីតិ ។

(៤៤) ឯវញ្ច[2] ខោ វោ ភិក្ខវេ មយិ ហោតិ អនុកម្បកោ ភគវា ហិតេសី អនុកម្បំ ឧបាទាយ ធម្មំ ទេសេតីតិ តស្មាតិហ ភិក្ខវេ យេ វោ មយា ធម្មា អភិញ្ញា ទេសិតា សេយ្យថីទំ ចត្តារោ សតិបដ្ឋានា ចត្តារោ សម្មប្បធានា

១ ឱ. ចរហីតិ ន ទិស្សតិ ។ ម. កិញ្ចរហីតិ ទិស្សតិ ។ ២ ឱ. ឯវំ ។

(៤៣) ម្នាលភិក្ខុទាំងឡាយ បើអ្នកទាំងឡាយ មិនជាប់មានគម្រិះចំពោះតថាគតថា ព្រះសមណគោតមសំដែងធម៌ ព្រោះហេតុចីវរខ្លះ ព្រះសមណគោតមសំដែងធម៌ ព្រោះហេតុបិណ្ឌបាតខ្លះ ព្រះសមណ-គោតមសំដែងធម៌ ព្រោះហេតុសេនាសនៈខ្លះ ព្រះសមណគោតមសំដែងធម៌ ព្រោះហេតុភពតូចភពធំខ្លះដូច្នេះទេ ម្នាលភិក្ខុទាំងឡាយ កាលបើដូច្នេះ ចុះឥឡូវនេះ អ្នកទាំងឡាយមានសេចក្តីត្រិះរិះចំពោះតថាគតដូចម្តេច ៗ បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គទាំងឡាយ មានសេចក្តីត្រិះរិះចំពោះព្រះមានព្រះភាគយ៉ាងនេះថា ព្រះមានព្រះភាគ ជាអ្នកអនុគ្រោះស្វែងរកប្រយោជន៍ អាស្រ័យនូវសេចក្តីអនុគ្រោះ ទើបទ្រង់សំដែងធម៌ ៗ

(៤៤) ម្នាលភិក្ខុទាំងឡាយ បានឮថា អ្នកទាំងឡាយមានសេចក្តីត្រិះរិះ ចំពោះតថាគតយ៉ាងនេះថា ព្រះមានព្រះភាគ ជាអ្នកអនុគ្រោះស្វែងរកប្រយោជន៍ អាស្រ័យ នូវសេចក្តីអនុគ្រោះ ទើបសំដែងធម៌ ម្នាលភិក្ខុទាំងឡាយ ព្រោះហេតុនោះ ធម៌ទាំងឡាយណាដែលតថាគតត្រាស់ដឹងហើយ សំដែងហើយ ដូចជាសតិប្បដ្ឋាន ៤ សម្មប្បធាន ៤

ចត្តារោ ឥទ្ធិបាទា បញ្ចិន្ទ្រិយានិ បញ្ច ពលានិ សត្ត ពោជ្ឈង្គា អរិយោ អដ្ឋង្គិកោ មគ្គោ តត្ថ សព្វេហេវ សមគ្គេហិ សម្មោទមានេហិ អវិវទមានេហិ សិក្ខិតព្វំ ។ តេសញ្ច វោ ភិក្ខវេ សមគ្គានំ សម្មោទមានានំ អវិវទមានានំ សិក្ខតំ សិយុំ(១) ទ្វេ ភិក្ខូ អភិធម្មេ នានាវាទា ។

(៤៨) តត្រ ចេ តុម្ហាកំ ឯវមស្ស ឥមេសំ ខោ អាយស្មន្តានំ អត្ថតោ ចេវ នានំ ព្យញ្ជនតោ ច នានន្តិ តត្ថ យំ ភិក្ខុំ សុវចតរំ មញ្ញេយ្យាថ សោ ឧបសង្កមិត្វា ឯវមស្ស វចនីយោ អាយស្មន្តានំ ខោ អត្ថតោ ចេវ នានំ ព្យញ្ជនតោ ច នានំ តទិមិនាបេតំ(២) អាយស្មន្តោ ជានាថ យថា អត្ថតោ ច នានំ ព្យញ្ជនតោ ច នានំ មា អាយស្មន្តោ វិវាទំ អាបជ្ជិត្ថ ។ អថាបរេសំ ឯកតោបក្ខិ-កានំ(៣) ភិក្ខូនំ យំ ភិក្ខុំ សុវចតរំ មញ្ញេយ្យាថ

---

១ ឱ. ម. សិយំសុ ។ ២ តទមិនាបេតន្តិបិ បាឋោ ទិស្សតិ ។ ៣ ឯកតោបក្ខិយានន្តិបត្តិ ។

ឥទ្ធិបាទ ៤ ឥន្ទ្រិយ ៥ ពលៈ ៥ ពោជ្ឈង្គ ៧ មគ្គដ៏ប្រសើរប្រកបដោយអង្គ ៨ អ្នកទាំងឡាយរាល់រូបគប្បីព្រមព្រៀងគ្នា គប្បីរីករាយរកគ្នា កុំវិវាទគ្នា គប្បីសិក្សាក្នុងធម៌ទាំងនោះចុះ ។ ម្នាលភិក្ខុទាំងឡាយ កាលបើអ្នកទាំងនោះ មានសេចក្តីព្រមព្រៀងគ្នា រីករាយរកគ្នា មិនវិវាទគ្នា កំពុងសិក្សា មានភិក្ខុ ២ រូប មានវាទៈផ្សេងគ្នា ក្នុងធម៌ដ៏វិសេស ។

(៤៨) បើអ្នកទាំងឡាយគួរនិយាយក្នុងដំណើរនោះថា ការសិក្សារបស់លោកមានអាយុទាំងនេះ ផ្សេងគ្នាដោយអត្ថផង ផ្សេងគ្នាដោយព្យញ្ជនៈផង ដូច្នេះបាន បណ្ដាភិក្ខុទាំងនោះ ភិក្ខុណាដែលអ្នកទាំង-ឡាយ សំគាល់ឃើញថា ប្រដៅងាយជាងគេ អ្នកទាំងឡាយគប្បីចូលទៅរកភិក្ខុនោះ ហើយនិយាយយ៉ាងនេះថា ការសិក្សារបស់លោកមានអាយុទាំងឡាយ ផ្សេងគ្នាដោយអត្ថផង ផ្សេងគ្នាដោយព្យញ្ជនៈផង លោកមានអាយុទាំងឡាយ ចូរដឹងនូវការសិក្សានោះ ដោយហេតុនេះ តាមដែលផ្សេងគ្នាដោយអត្ថផង តាមដែលផ្សេងគ្នាដោយព្យញ្ជនៈផងចុះ លោកមានអាយុទាំងឡាយ កុំដល់នូវសេចក្តីទាស់ទែងគ្នាឡើយ ។ មួយទៀត បណ្ដាភិក្ខុទាំងឡាយ ដទៃទៀត ដែលជាបក្សពួក ជាមួយគ្នា ភិក្ខុណាដែលអ្នកទាំងឡាយ សំគាល់ឃើញថា ប្រដៅងាយជាងគេ

សោ ឧបសង្កមិត្វា ឯវមស្ស វចនីយោ អាយស្មន្តានំ ខោ អត្ថតោ ចេវ នានំ ព្យញ្ជនតោ ច នានំ តទិមិនាបេតំ អាយស្មន្តោ ជានាថ យថា អត្ថតោ ច នានំ ព្យញ្ជនតោ ច នានំ មា អាយស្មន្តោ វិវាទំ អាបជ្ជិត្ថាតិ ។ ឥតិ ទុគ្គហិតំ ទុគ្គហិតតោ ធារេតព្វំ ទុគ្គហិតំ ទុគ្គហិតតោ ធារេត្វា យោ ធម្មោ យោ វិនយោ សោ ភាសិតព្វោ ។

(៤៦) តត្រ ចេ តុម្ហាកំ ឯវមស្ស ឥមេសំ ខោ អាយស្មន្តានំ អត្ថតោ ហិ ខោ នានំ ព្យញ្ជនតោ សមេតិ តត្ថ យំ ភិក្ខុំ សុវចតរំ មញ្ញេយ្យាថ សោ ឧបសង្កមិត្វា ឯវមស្ស វចនីយោ អាយស្មន្តានំ ខោ អត្ថតោ ហិ ខោ នានំ ព្យញ្ជនតោ សមេតិ

អ្នកទាំងឡាយគប្បីចូលទៅរកភិក្ខុនោះ ហើយនិយាយយ៉ាងនេះថា ការសិក្សារបស់លោកមានអាយុទាំងឡាយ ផ្សេងគ្នាដោយអត្ថផង ផ្សេងគ្នា ដោយព្យញ្ជនៈផង លោកមានអាយុទាំងឡាយ ចូរដឹងនូវការសិក្សានោះ ដោយហេតុនេះ តាមដែលផ្សេងគ្នាដោយអត្ថផង តាមដែលផ្សេងគ្នាដោយព្យញ្ជនៈផងចុះ លោកមានអាយុទាំងឡាយ កុំដល់នូវសេចក្តីទាស់ទែងគ្នាឡើយ ។ ដូច្នេះ អ្នកទាំងឡាយ គួរចាំទុកនូវការសិក្សាដែលគេកាន់យកមិនល្អ ថាជាការសិក្សាដែលគេកាន់យកមិនល្អចុះ លុះចាំទុកនូវការសិក្សាដែលគេកាន់យកមិនល្អ ថាជាការសិក្សាដែលគេកាន់យកមិនល្អហើយ ណា ជាធម៌ ណាជាវិន័យ គប្បីពោលធម៌វិន័យនោះ ។

(៦៦) បើអ្នកទាំងឡាយ គួរនិយាយក្នុងដំណើរនោះថា ការសិក្សារបស់លោកមានអាយុទាំងនេះ ផ្សេងគ្នាដោយអត្ថ តែសមគ្នាដោយព្យញ្ជនៈ ដូច្នេះបាន បណ្តាភិក្ខុទាំងនោះ ភិក្ខុណាដែលអ្នកទាំង-ឡាយ សំគាល់ឃើញថា ប្រដៅងាយជាងគេ អ្នកទាំងឡាយគប្បីចូលទៅរកភិក្ខុនោះ ហើយនិយាយយ៉ាងនេះថា ការសិក្សារបស់លោកមានអាយុទាំងឡាយ ផ្សេងគ្នាដោយអត្ថ តែសមគ្នា ដោយព្យញ្ជនៈ

តទិមិនាបេតំ អាយស្មន្តោ ជានាថ យថា អត្ថតោ ហិ ខោ នានំ ព្យញ្ជនតោ សមេតំ មា អាយស្មន្តោ វិវាទំ អាបជ្ជិត្ថាតិ ។ អថាបរេសំ ឯកតោបក្ខិកានំ ភិក្ខូនំ យំ ភិក្ខុំ សុវចតរំ មញ្ញេយ្យាថ សោ ឧបសង្កមិត្វា ឯវមស្ស វចនីយោ អាយស្មន្តានំ ខោ អត្ថតោ ហិ ខោ នានំ ព្យញ្ជនតោ សមេតិ តទិមិនាបេតំ អាយស្មន្តោ ជានាថ យថា អត្ថតោ ហិ ខោ នានំ ព្យញ្ជនតោ សមេតិ មា អាយស្មន្តោ វិវាទំ អាបជ្ជិត្ថាតិ ។ ឥតិ ទុគ្គហិតំ ទុគ្គហិតតោ ធារេតព្វំ សុគ្គហិតំ សុគ្គហិតតោ ធារេតព្វំ ទុគ្គហិតំ ទុគ្គហិតតោ ធារេត្វា សុគ្គហិតំ សុគ្គហិតតោ ធារេត្វា យោ ធម្មោ យោ វិនយោ សោ ភាសិតព្វោ ។

លោកមានអាយុទាំងឡាយ គួរដឹងនូវការសិក្សានុ៎ះ ដោយហេតុនេះ តាមដែលផ្សេងគ្នាដោយអត្ថ តែសមគ្នាដោយព្យញ្ជនៈចុះ លោកមានអាយុទាំងឡាយ កុំដល់នូវសេចក្តីទាស់ទែងគ្នាឡើយ ។ មួយទៀត បណ្តាភិក្ខុទាំងឡាយដទៃទៀត ដែលជាបក្សពួកជាមួយគ្នា ភិក្ខុណាដែលអ្នកទាំងឡាយសំគាល់ឃើញថា ប្រដៅងាយជាងគេ អ្នកទាំងឡាយគប្បីចូលទៅរកភិក្ខុនោះ ហើយនិយាយយ៉ាងនេះថា ការសិក្សារបស់លោកមានអាយុទាំងឡាយ ផ្សេងគ្នាដោយអត្ថ តែសមគ្នា ដោយព្យញ្ជនៈ លោកមានអាយុទាំងឡាយ ចូរដឹងនូវការសិក្សានុ៎ះ ដោយហេតុនេះ តាមដែលផ្សេងគ្នាដោយអត្ថ តែសមគ្នាដោយព្យញ្ជនៈចុះ លោកមានអាយុទាំងឡាយ កុំដល់នូវសេចក្តីទាស់ទែងគ្នាឡើយ ។ ដូច្នេះ អ្នកទាំងឡាយ គួរចាំទុកនូវការសិក្សាដែលគេកាន់យកមិនល្អ ថាជាការសិក្សាដែលគេកាន់យកមិនល្អ ទាំងគួរចាំទុកនូវការសិក្សាដែលគេកាន់យកល្អ ថាជាការសិក្សាដែលគេកាន់យកល្អចុះ លុះចាំទុកនូវការសិក្សាដែលគេកាន់យកមិនល្អ ថាជាការសិក្សាដែលគេកាន់យកមិនល្អ ទាំងចាំទុកនូវការសិក្សាដែលគេកាន់យកល្អ ថាជាការដែលគេកាន់យកល្អហើយ ណាជាធម៌ ណាជាវិន័យ គប្បីពោលធម៌វិន័យនោះ ។

(៤៧) តត្រ ចេ តុម្ហាកំ ឯវមស្ស ឥមេសំ ខោ អាយស្មន្តានំ អត្ថតោ ហិ ខោ សមេតិ ព្យញ្ជនតោ នានន្តិ តត្ថ យំ ភិក្ខុំ សុវចតរំ មញ្ញេយ្យាថ សោ ឧបសង្កមិតព្វោ ឯវមស្ស វចនីយោ អាយស្មន្តានំ ខោ អត្ថតោ ហិ ខោ សមេតិ ព្យញ្ជនតោ នានំ តទិមិនាបេតំ អាយស្មន្តោ ជានាថ យថា អត្ថតោ ហិ ខោ សមេតិ ព្យញ្ជនតោ នានំ អប្បមត្តកំ ខោ បនេតំ យទិទំ ព្យញ្ជនំ មា អាយស្មន្តោ អប្បមត្តកេ[១] វិវាទំ អាបជ្ជិត្ថាតិ ។ អថាបរេសំ ឯកតោបក្ខិកានំ ភិក្ខូនំ យំ ភិក្ខុំ សុវចតរំ មញ្ញេយ្យាថ សោ ឧបសង្កមិតព្វោ ឯវមស្ស វចនីយោ អាយស្មន្តានំ ខោ អត្ថតោ ហិ ខោ សមេតិ ព្យញ្ជនតោ នានំ តទិមិនាបេតំ អាយស្មន្តោ ជានាថ យថា អត្ថតោ ហិ ខោ សមេតិ

១ ឱ. អប្បមត្តកេហិ ។

( ៤៧ ) បើអកទាំងឡាយ គួរនិយាយក្នុងដំណើរនោះថា ការសិក្សារបស់លោកមានអាយុទាំងឡាយនេះ សមគ្នាដោយអត្ថ តែផ្សេងគ្នាដោយព្យញ្ជនៈ ដូច្នេះបាន បណ្ដាភិក្ខុទាំងនោះ ភិក្ខុណាដែលអ្នកទាំងឡាយសំគាល់ឃើញថា ជាអ្នកប្រដៅងាយជាងគេ អ្នកទាំងឡាយគប្បីចូលទៅរកភិក្ខុនោះ ហើយនិយាយយ៉ាងនេះថា ការសិក្សារបស់លោកមានអាយុទាំងឡាយ សមគ្នាដោយអត្ថ តែផ្សេងគ្នាដោយព្យញ្ជនៈ លោកមានអាយុទាំងឡាយ ចូរដឹងនូវការសិក្សានុ៎ះ ដោយហេតុនេះ តាមដែលសមគ្នាដោយអត្ថ តាមដែលផ្សេងគ្នាដោយព្យញ្ជនៈបុះ តែជាគ្រន់ព្យញ្ជនៈនុ៎ះ គ្រាន់តែជាការបន្តិចបន្តួចទេ លោកមានអាយុទាំងឡាយ កុំដល់នូវសេចក្ដីទាស់ទែងគ្នា ក្នុងព្យញ្ជនៈដែលគ្រាន់តែជាការបន្តិចបន្តួចឡើយ ។ មួយទៀត បណ្ដាភិក្ខុទាំងឡាយដទៃទៀត ដែលជាបក្សពួកជាមួយគ្នា ភិក្ខុណាដែលអ្នកទាំងឡាយ សំគាល់ឃើញថាជាអ្នកប្រដៅងាយជាងគេ អ្នកទាំងឡាយ គប្បីចូលទៅរកភិក្ខុនោះ ហើយនិយាយយ៉ាងនេះថា ការសិក្សារបស់លោកមានអាយុទាំងឡាយ សមគ្នាដោយអត្ថ តែផ្សេងគ្នាដោយព្យញ្ជនៈ លោកមានអាយុទាំងឡាយ ចូរដឹងនូវការសិក្សានុ៎ះ ដោយហេតុនេះ តាមដែលសមគ្នាដោយអត្ថ

ព្យញ្ជនតោ នានំ អប្បមត្តកំ ខោ បនេតំ យទិទំ ព្យញ្ជនំ មា អាយស្មន្តោ អប្បមត្តកេ(១) វិវាទំ អាបជ្ជិត្ថាតិ ។ ឥតិ សុគហិតំ សុគហិតតោ ធារេតព្វំ ទុគ្គហិតំ ទុគ្គហិតតោ ធារេតព្វំ សុគហិតំ សុគហិតតោ ធារេត្វា ទុគ្គហិតំ ទុគ្គហិតតោ ធារេត្វា យោ ធម្មោ យោ វិនយោ សោ ភាសិតព្វោ ។

(៤៨) តត្រ ចេ តុម្ហាកំ ឯវមស្ស ឥមេសំ ខោ អាយស្មន្តានំ អត្ថតោ ចេវ សមេតិ ព្យញ្ជនតោ ច សមេតីតិ តត្ថ យំ ភិក្ខុំ សុវចតរំ មញ្ញេយ្យាថ សោ ឧបសង្កមិតព្វោ ឯវមស្ស វចនីយោ អាយស្មន្តានំ ខោ អត្ថតោ ចេវ សមេតិ

១ ឱ. អប្បមត្តកេហិ ។

តាមដែលផ្សេងគ្នាដោយព្យញ្ជនៈចុះ តែជាត្រង់ព្យញ្ជនៈនុ៎ះ គ្រាន់តែជាការបន្តិចបន្តួចទេ លោកមានអាយុទាំងឡាយ កុំដល់នូវសេចក្តីទាស់ទែងគ្នា ក្នុងព្យញ្ជនៈ ដែលគ្រាន់តែជាការបន្តិចបន្តួចឡើយ ។ ដូច្នេះ លោកមានអាយុទាំងឡាយ គួរចាំទុកនូវការសិក្សា ដែលគេកាន់យកល្អ ថាជាការសិក្សាដែលគេកាន់យកល្អ គួរចាំទុកនូវការសិក្សាដែលគេកាន់យកមិនល្អ ថាជាការសិក្សាដែលគេកាន់យកមិនល្អចុះ លុះចាំទុកនូវការសិក្សាដែលគេកាន់យកល្អ ថាជាការសិក្សាដែលគេកាន់យកល្អ ចាំទុកនូវការសិក្សាដែលគេកាន់យកមិនល្អ ថាជាការសិក្សាដែលគេកាន់យកមិនល្អហើយ ណាជាធម៌ ណាជាវិន័យ គប្បីពោលធម៌វិន័យនោះ ។

(៤៨) បើអ្នកទាំងឡាយ គួរនិយាយក្នុងដំណើរនោះថា ការសិក្សារបស់លោក មានអាយុទាំងឡាយនេះ សមគ្នាដោយអត្ថផង សមគ្នា ដោយព្យញ្ជនៈផង ដូច្នេះបាន បណ្តាភិក្ខុទាំងនោះ ភិក្ខុណាដែលអ្នកទាំងឡាយ សំគាល់ឃើញថា ជាអ្នកប្រដៅងាយជាងគេ អ្នកទាំងឡាយ គប្បីចូលទៅរកភិក្ខុនោះ ហើយនិយាយយ៉ាងនេះថា ការសិក្សារបស់លោក មានអាយុទាំងឡាយ សមគ្នាដោយអត្ថផង

ព្យញ្ជនតោ ច សមេតិ តទិមិនាបេតំ អាយស្មន្តោ ជានាថ យថា អត្ថតោ ចេវ សមេតិ ព្យញ្ជនតោ ច សមេតិ មា អាយស្មន្តោ វិវាទំ អាបជ្ជិត្ថាតិ ។ អថាបរេសំ ឯកតោបក្ខិកានំ ភិក្ខូនំ យំ ភិក្ខុំ សុវចតរំ មញ្ញេយ្យាថ សោ ឧបសង្កមិត្វា ឯវមស្ស វចនីយោ អាយស្មន្តានំ ខោ អត្ថតោ ចេវ សមេតិ ព្យញ្ជនតោ ច សមេតិ តទិមិនាបេតំ អាយស្មន្តោ ជានាថ យថា អត្ថតោ ចេវ សមេតិ ព្យញ្ជនតោ ច សមេតិ មា អាយស្មន្តោ វិវាទំ អាបជ្ជិត្ថាតិ ។ ឥតិ សុគ្គហិតំ សុគ្គហិតតោ ធារេតព្វំ សុគ្គហិតំ សុគ្គហិតតោ ធារេត្វា យោ ធម្មោ យោ វិនយោ សោ ភាសិតព្វោ ។

សមគ្គាដោយព្យញ្ជនៈផង លោកមានអាយុទាំងឡាយ ចូរដឹងនូវការសិក្សានុ៎ះដោយហេតុនេះ តាមដែលសមគ្គាដោយអត្ថផង តាមដែលសមគ្គាដោយព្យញ្ជនៈផង លោកមានអាយុទាំងឡាយ កុំជល់នូវសេចក្តីទាស់ទែងគ្នាឡើយ ។ មួយទៀត បណ្តាភិក្ខុទាំងឡាយដទៃទៀត ដែលជាបក្ខពួកជាមួយគ្នា ភិក្ខុណាដែលអ្នកទាំងឡាយ សំគាល់ឃើញថា ជាអ្នកប្រដៅងាយជាងគេ អ្នកទាំងឡាយ គប្បីចូលទៅរកភិក្ខុនោះ ហើយនិយាយយ៉ាងនេះថា ការសិក្សារបស់លោកមានអាយុទាំងឡាយ សមគ្គាដោយអត្ថផង សមគ្គាដោយព្យញ្ជនៈផង លោកមានអាយុទាំងឡាយ ចូរដឹងនូវការសិក្សានុ៎ះ ដោយហេតុនេះ តាមដែលសមគ្គាដោយអត្ថផង តាមដែលសមគ្គាដោយព្យញ្ជនៈផង លោកមានអាយុទាំងឡាយ កុំជល់នូវសេចក្តីទាស់ទែងគ្នាឡើយ ។ ដូច្នេះ លោកមានអាយុទាំងឡាយ គួរចាំទុកនូវការសិក្សាដែលគេកាន់យកល្អ ថាជាការសិក្សាដែលគេកាន់យកល្អចុះ លុះចាំទុកនូវការសិក្សាដែលគេកាន់យកល្អ ថាជាការសិក្សាដែលគេកាន់យកល្អហើយ ណាជាធម៌ ណាជាវិន័យ គប្បីពោលធម៌វិន័យនោះ ។

(៤៩) តេសញ្ច វោ ភិក្ខវេ សមគ្គានំ សម្មោ-ទមានានំ អវិវទមានានំ សិក្ខតំ សិយា អញ្ញតរស្ស ភិក្ខុនោ អាបត្តិ សិយា វីតិក្កមោ ។ តត្រ ភិក្ខវេ ន ចោទនាយ ចោទិតព្វំ(១) បុគ្គលោ ឧបបរិក្ខិ-តព្វោ ឥតិ មយ្ហញ្ច អវិហេសា ភវិស្សតិ បរស្ស ច បុគ្គលស្ស អនុបឃាតោ បរោ ហិ បុគ្គលោ អក្កោ-ធនោ អនុបនាហី អទឡ្ហទិដ្ឋី(២) សុប្បដិនិស្សគ្គី សក្កោមិ ចាហំ ឯតំ បុគ្គលំ អកុសលា វុដ្ឋា-បេត្វា កុសលេ បតិដ្ឋាបេតុន្តិ ។ សចេ ភិក្ខវេ ឯវមស្ស កល្លំ វចនាយ ។ សចេ បន ភិក្ខវេ ឯវមស្ស មយ្ហំ ខោ អវិហេសា ភវិស្សតិ បរស្ស ច បុគ្គលស្ស ឧបឃាតោ បរោ ហិ បុគ្គលោ កោធ-នោ ឧបនាហី ទឡ្ហទិដ្ឋី សុប្បដិនិស្សគ្គី សក្កោមិ

១ ឱ. តរិតព្វំ ។ ២ ឱ. អទន្ធទិដ្ឋី ទិស្សតិ ។

(៤៩) ម្នាលភិក្ខុទាំងឡាយ កាលបើអ្នកទាំងឡាយនោះ ព្រមព្រៀងគ្នា រីករាយនឹងគ្នា មិនវិវាទគ្នា កំពុងសិក្សា មានភិក្ខុណាត្រូវអាបត្តិ ជាការប្រព្រឹត្តិល្មើស ។ ម្នាលភិក្ខុទាំងឡាយ ក្នុងហេតុនោះ អ្នកទាំងឡាយមិនគួរចោទគ្នាដោយពាក្យចោទទេ ត្រូវពិនិត្យមើលបុគ្គលឲ្យល្អសិនថា ដោយហេតុនេះ អាត្មាអញនឹងមិនមានសេចក្ដីលំបាកផង បុគ្គលដទៃក៏មិនមានសេចក្ដីអាក់អន់ផង ព្រោះថាបុគ្គលដទៃជាអ្នកមិនក្រោធ ជាអ្នកមិនចងពៀរ ជាអ្នកមិនមានទិដ្ឋិមាំ ជាអ្នកលះបង់បានងាយ តាំងខ្លួនអញក៏អាចឲ្យបុគ្គលនុ៎ះ ចេញចាកអកុសលធម៌ ឲ្យតាំងនៅក្នុងកុសលធម៌បាន ។ ម្នាលភិក្ខុទាំងឡាយ បើអ្នកទាំងឡាយពិនិត្យឃើញយ៉ាងនេះ ទើបគួរនិយាយ ។ ម្នាលភិក្ខុទាំងឡាយ តែបើអ្នកទាំងឡាយពិនិត្យឃើញ យ៉ាងនេះវិញថា អាត្មាអញនឹងមិនមានសេចក្ដីលំបាកទេ តែបុគ្គលដទៃមានសេចក្ដីអាក់អន់ ព្រោះថាបុគ្គលដទៃជាអ្នកក្រោធ ជាអ្នកចងពៀរ ជាអ្នកមានទិដ្ឋិមាំ តែជាអ្នកលះបង់បានងាយ

ចាហំ ឯតំ បុគ្គលំ អកុសលា វុដ្ឋាបេត្វា កុស-
លេ បតិដ្ឋាបេតុំ អប្បមត្តកំ ខោ បនេតំ យទិទំ
បរស្ស បុគ្គលស្ស ឧបឃាតោ អថខោ ឯតទេវ
ពហុតរំ ស្វាហំ(១) សក្កោមិ ឯតំ បុគ្គលំ អកុស-
លា វុដ្ឋាបេត្វា កុសលេ បតិដ្ឋាបេតុន្តិ ។ សចេ
ភិក្ខវេ ឯវមស្ស កល្លំ វចនាយ ។ សចេ បន
ភិក្ខវេ ឯវមស្ស មយ្ហំ ខោ វិហេសា ភវិស្សតិ
បរស្ស បុគ្គលស្ស អនុបឃាតោ បរោ ហិ បុគ្គលោ
អក្កោធនោ អនុបនាហី អទន្ធទិដ្ឋី សុប្បដិនិស្សគ្គី
សក្កោមិ ចាហំ ឯតំ បុគ្គលំ អកុសលា
វុដ្ឋាបេត្វា កុសលេ បតិដ្ឋាបេតុំ អប្បមត្តកំ
ខោ បនេតំ យទិទំ មយ្ហំ វិហេសា អថខោ
ឯតទេវ ពហុតរំ ស្វាហំ សក្កោមិ ឯតំ បុគ្គលំ
អកុសលា វុដ្ឋាបេត្វា កុសលេ បតិដ្ឋាបេតុន្តិ ។
សចេ ភិក្ខវេ ឯវមស្ស កល្លំ វចនាយ ។

---

១ ឱ. សាហំ ។

ពាំងអាត្មាអញក៏អាចញាំងបុគ្គលនុ៎ះ ឲ្យចេញចាកអកុសលធម៌ ឲ្យតាំងនៅក្នុងកុសលធម៌បាន ឯសេចក្ដីអាក់អន់របស់បុគ្គលដទៃនុ៎ះ គ្រាន់តែជាការបន្តិចបន្តួច ពោះបើត្រឡប់ទៅជាជំរុំវិញ អាត្មាអញនោះក៏អាចឲ្យបុគ្គលនុ៎ះចេញចាកអកុសលធម៌ ឲ្យតាំងនៅក្នុងកុសលធម៌បាន ។ ម្នាលភិក្ខុទាំងឡាយ បើអ្នកទាំងឡាយពិនិត្យឃើញយ៉ាងនេះ ទើបគួរនិយាយ ។ ម្នាលភិក្ខុទាំងឡាយ តែបើអ្នកទាំងឡាយ ពិនិត្យឃើញយ៉ាងនេះវិញថា អាត្មាអញនឹងមានសេចក្ដីលំបាក បុគ្គលដទៃមិនមានសេចក្ដីអាក់អន់ ព្រោះថាបុគ្គលដទៃ ជាអ្នកមិនក្រោធ ជាអ្នកមិនចងពៀរ ជាអ្នកមិនមានទិដ្ឋិមាំ ជាអ្នកលះបង់បានងាយ ពាំងអាត្មាអញក៏អាចញាំងបុគ្គលនោះឲ្យចេញចាកអកុសលធម៌ ឲ្យតាំងនៅក្នុងកុសលធម៌បាន ឯសេចក្ដីលំបាករបស់អាត្មាអញនុ៎ះ គ្រាន់តែជាការបន្តិចបន្តួច ពោះបើត្រឡប់ទៅជាការជំរុំវិញ អាត្មាអញក៏អាចញាំងបុគ្គលនុ៎ះឲ្យចេញចាកអកុសលធម៌ ឲ្យតាំងនៅក្នុងកុសលធម៌បាន ។ ម្នាលភិក្ខុទាំងឡាយ បើអ្នកទាំងឡាយពិនិត្យឃើញយ៉ាងនេះ ទើបគួរនិយាយ ។

សចេ ភិក្ខវេ ឯវមស្ស មយ្ហញ្ច ខោ វិហេសា ភវិស្សតិ បរស្ស ច បុគ្គលស្ស ឧបឃាតោ បរោ ហិ បុគ្គលោ កោធនោ ឧបនាហី ទឡ្ហទិដ្ឋី ទុប្បដិនិស្សគ្គី សក្កោមិ ចាហំ ឯតំ បុគ្គលំ អកុសលា វុដ្ឋាបេត្វា កុសលេ បតិដ្ឋាបេតុំ អប្បមត្តកំ ខោ បនេតំ យទិទំ មយ្ហញ្ច វិហេសា បរស្ស ច បុគ្គលស្ស ឧបឃាតោ អថខោ ឯតទេវ ពហុតរំ ស្វាហំ សក្កោមិ ឯតំ បុគ្គលំ អកុសលា វុដ្ឋាបេត្វា កុសលេ បតិដ្ឋាបេតុន្តិ ។ សចេ ភិក្ខវេ ឯវមស្ស កាលំ វចនាយ ។ សចេ បន ភិក្ខវេ ឯវមស្ស មយ្ហញ្ច ខោ វិហេសា ភវិស្សតិ បរស្ស ច បុគ្គលស្ស ឧបឃាតោ បរោ ហិ បុគ្គលោ កោធនោ ឧបនាហី ទឡ្ហទិដ្ឋី ទុប្បដិនិស្សគ្គី ន ចាហំ សក្កោមិ ឯតំ បុគ្គលំ អកុសលា វុដ្ឋាបេត្វា កុសលេ បតិដ្ឋាបេតុន្តិ ។ ឯវរូបេ បុគ្គលេ ឧបេក្ខា នាតិមញ្ញិតព្វា ។

ទេវទហវគ្គ កិមិលសូត្រ ការធ្វើជាអ្នកព្រងើយ

ម្នាលភិក្ខុទាំងឡាយ បើអ្នកទាំងឡាយ ពិនិត្យឃើញយ៉ាងនេះវិញថា អាត្មាអញនឹងមានសេចក្តីលំបាកផង បុគ្គលដទៃមានសេចក្តីអាក់អន់ផង ព្រោះថាបុគ្គលដទៃ ជាអ្នកក្រោធ ជាអ្នកចងពៀរ ជាអ្នកមានទិដ្ឋិមាំ ជាអ្នកលះបង់បានដោយក្រ តែអាត្មាអញអាចញុំាងបុគ្គលនុ៎ះ ឲ្យចេញចាកអកុសលធម៌ ឲ្យតាំងនៅក្នុងកុសលធម៌បាន ឯសេចក្តីលំបាករបស់អាត្មាអញ នឹងសេចក្តីអាក់អន់របស់បុគ្គលដទៃនុ៎ះ គ្រាន់តែជាការបន្តិចបន្តួចទេ ទោះបីត្រឡប់ទៅជាការធំដុំវិញ អាត្មាអញនោះក៏អាចញុំាងបុគ្គលនេះឲ្យចេញចាកអកុសលធម៌ ឲ្យតាំងនៅក្នុងកុសលធម៌បាន ។ ម្នាលភិក្ខុទាំងឡាយ បើអ្នកទាំងឡាយ ពិនិត្យឃើញយ៉ាងនេះ ទើបគួរនិយាយ ។ ម្នាលភិក្ខុទាំងឡាយ តែបើអ្នកទាំងឡាយពិនិត្យឃើញយ៉ាងនេះថា អាត្មាអញនឹងមានសេចក្តីលំបាកផង បុគ្គលដទៃមានសេចក្តីអាក់អន់ផង ព្រោះថាបុគ្គលដទៃជាអ្នកក្រោធ ជាអ្នកចងពៀរ ជាអ្នកមានទិដ្ឋិមាំ ជាអ្នកលះបង់បានដោយក្រ ទាំងអាត្មាអញក៏មិនអាចញុំាងបុគ្គលនុ៎ះឲ្យចេញចាកអកុសលធម៌ ឲ្យតាំងនៅក្នុងកុសលធម៌ទេ ។ អ្នកទាំងឡាយ គប្បីជាអ្នកព្រងើយ ក្នុងបុគ្គលមានសភាពយ៉ាងនេះ កុំគប្បីធ្វើធឹងឡើយ ។

(៥០) តេសញ្ច ខោ ភិក្ខវេ សមគ្គានំ សម្មោ-
ទមានានំ អវិវទមានានំ សិក្ខតំ អញ្ញមញ្ញស្ស វចី-
សង្ខារោ ឧប្បជ្ជេយ្យ ទិដ្ឋិបឡាសោ ចេតសោ អាឃា-
តោ អប្បច្ចយោ អនភិរទ្ធិ ។ តត្រ ឯកតោបក្ខិកានំ
ភិក្ខូនំ យំ ភិក្ខុំ សុវចតរំ មញ្ញេយ្យាថ សោ
ឧបសង្កមិត្វា ឯវមស្ស វចនីយោ យន្នោ អាវុសោ
អម្ហាកំ សមគ្គានំ សម្មោទមានានំ អវិវទមានានំ
សិក្ខតំ អញ្ញមញ្ញស្ស វចីសង្ខារោ ឧប្បន្នោ ទិដ្ឋិប-
ឡាសោ ចេតសោ អាឃាតោ អប្បច្ចយោ អនភិរទ្ធិ
តំ ជានមានោ សមណោ គរហេយ្យាតិ ។ សម្មា
ព្យាករមានោ ភិក្ខវេ ភិក្ខុ ឯវំ ព្យាករេយ្យ
យន្នោ អាវុសោ អម្ហាកំ សមគ្គានំ សម្មោទមានានំ

(៩០) ម្នាលភិក្ខុទាំងឡាយ កាលអ្នកទាំងឡាយនោះព្រមព្រៀងគ្នា រីករាយនឹងគ្នា មិនវិវាទគ្នា កំពុងសិក្សា តែវចីសង្ហារ ការលើកខ្លួនដោយទិដ្ឋិ ការបៀតបៀនគ្នាដោយចិត្ត ការមិនត្រេកអរ ការមិនមានសេចក្តីពេញចិត្ត គប្បីកើតឡើងដល់គ្នានិងគ្នា ។ បណ្តាភិក្ខុទាំងឡាយដែលជាបក្សពួកជាមួយគ្នាក្នុងទីនោះ អ្នកទាំងឡាយ សំគាល់ឃើញភិក្ខុណាថាជាអ្នកប្រដៅងាយជាងគេ អ្នកទាំងឡាយគប្បីចូលទៅរកភិក្ខុនោះហើយនិយាយយ៉ាងនេះថា ម្នាលអាវុសោ យើងទាំងឡាយជាអ្នកព្រមព្រៀងគ្នា រីករាយនឹងគ្នា មិនវិវាទគ្នា កំពុងសិក្សា តែវចីសង្ហារ ការលើកខ្លួនដោយទិដ្ឋិ ការបៀតបៀនដោយចិត្ត ការមិនត្រេកអរ ការមិនមានសេចក្តីពេញចិត្ត កើតឡើងដល់គ្នានិងគ្នា កាលបើសមណៈ (អ្នកសប់) ជ្រាបហេតុនោះ នឹងគប្បីតិះដៀលបាន ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុកាលនឹងពោលដោយប្រពៃ គប្បីពោលយ៉ាងនេះថា ម្នាលអាវុសោ យើងទាំងឡាយជាអ្នកព្រមព្រៀងគ្នា រីករាយនឹងគ្នា

ទេវទហវគ្គស្ស កិន្តិសុត្តេ សម្មាព្យាករណំ

អវិវទមានានំ សិក្ខតំ អញ្ញមញ្ញស្ស វចីសង្ហារោ ឧប្បន្នោ ទិដ្ឋិបឡាសោ ចេតសោ អាឃាតោ អប្បច្ចយោ អនភិរទ្ធិ តំ ជានមានោ សមណោ គរហេយ្យាតិ ។ ឯតម្បនាវុសោ ធម្មំ អប្បហាយ និព្វានំ សច្ឆិករេយ្យាតិ ។ សម្មា ព្យាករមានោ ភិក្ខវេ ភិក្ខុ ឯវំ ព្យាករេយ្យ ឯតំ ខោ អាវុសោ ធម្មំ អប្បហាយ ន និព្វានំ សច្ឆិករេយ្យាតិ ។ អថាបរេសំ ឯកតោបក្ខិកានំ ភិក្ខូនំ យំ ភិក្ខុំ សុវចតរំ មញ្ញេយ្យាថ សោ ឧបសង្កមិត្វា ឯវមស្ស វចនីយោ យន្នោ អាវុសោ អម្ហាកំ សមគ្គានំ សម្មោទមានានំ អវិវទមានានំ សិក្ខតំ អញ្ញមញ្ញស្ស វចីសង្ហារោ ឧប្បន្នោ ទិដ្ឋិបឡាសោ ចេតសោ អាឃាតោ អប្បច្ចយោ អនភិរទ្ធិ តំ ជានមានោ សមណោ គរហេយ្យាតិ ។ សម្មា ព្យាករមានោ ភិក្ខវេ ភិក្ខុ

មិនវិវាទគ្នា កំពុងសិក្សា តែវិចសង្ការ ការលើកខ្លួនដោយទិដ្ឋិ ការបៀតបៀនដោយចិត្ត ការមិនត្រេកអរ ការមិនមានសេចក្ដីពេញចិត្ត កើតឡើងដល់គ្នានិងគ្នា កាលបើសមណៈ ជ្រាបហេតុនោះ គប្បីតិះដៀលបាន ៗ ម្នាលអាវុសោ ភិក្ខុបើមិនលះបង់ធម៌នុ៎ះទេ នឹងធ្វើឲ្យជាក់ច្បាស់នូវព្រះនិព្វានដូចម្ដេចបាន ៗ ម្នាលភិក្ខុទាំងឡាយ ភិក្ខុកាលនឹងពោលដោយប្រពៃ គប្បីពោលយ៉ាងនេះថា ម្នាលអាវុសោ ភិក្ខុបើមិនលះបង់ធម៌នុ៎ះ នឹងមិនធ្វើឲ្យជាក់ច្បាស់នូវព្រះនិព្វានបានឡើយ ៗ មួយទៀត បណ្ដាភិក្ខុទាំងឡាយដទៃទៀត ជាបក្សពួកជាមួយគ្នា អ្នកទាំងឡាយសំគាល់ឃើញថា ភិក្ខុណាជាអ្នកប្រដៅងាយជាងគេ អ្នកទាំងឡាយគប្បីចូលទៅរកភិក្ខុនោះ ហើយនិយាយយ៉ាងនេះថា ម្នាលអាវុសោ យើងទាំងឡាយជាអ្នកព្រមព្រៀងគ្នា រីករាយរកគ្នា មិនវិវាទគ្នា កំពុងសិក្សា តែវិចសង្ការ ការលើកខ្លួនដោយទិដ្ឋិ ការបៀតបៀនគ្នាដោយចិត្ត ការមិនត្រេកអរ ការមិនមានសេចក្ដីពេញចិត្ត កើតឡើងដល់គ្នានិងគ្នា កាលបើសមណៈជ្រាបហេតុនោះ គប្បីតិះដៀលបាន ៗ ម្នាលភិក្ខុទាំងឡាយ ភិក្ខុកាលនឹងពោលដោយប្រពៃ

ឯវំ ព្យាករេយ្យ យន្នោ អាវុសោ អម្ហាកំ សមគ្គានំ សម្មោទមានានំ អវិវទមានានំ សិក្ខតំ អញ្ញមញ្ញស្ស វចីសង្សារោ ឧប្បន្នោ ទិដ្ឋិបឡាសោ ចេតសោ អា-ឃាតោ អប្បច្ចយោ អនភិរទ្ធិ តំ ជានមានោ សមណោ គរហេយ្យាតិ ។ ឯតម្បនាវុសោ ធម្មំ អប្បហាយ និព្ពានំ សច្ឆិករេយ្យាតិ ។ សម្មា ព្យាករមានោ ភិក្ខវេ ភិក្ខុ ឯវំ ព្យាករេយ្យ ឯតំ ខោ អាវុសោ ធម្មំ អប្ប-ហាយ ន និព្ពានំ សច្ឆិករេយ្យាតិ ។ តញ្ចេ ភិក្ខវេ ភិក្ខុំ បរេ ឯវំ បុច្ឆេយ្យុំ អាយស្មតា នោ ឯតេ ភិក្ខូ អកុសលា វុដ្ឋាបេត្វា កុសលេ បតិដ្ឋាបិតាតិ ។ សម្មា ព្យាករមានោ ភិក្ខវេ ភិក្ខុ ឯវំ ព្យាករេយ្យ ឥធាហំ អាវុសោ យេន ភគវា តេនុបសង្កមឹ តស្ស មេ ភគវា ធម្មំ ទេសេតិ[១] តស្សាហំ[២] ធម្មំ សុត្វា តេសំ ភិក្ខូនំ អភាសឹ តំ តេ ភិក្ខូ ធម្មំ សុត្វា

---

១ ឱ. ទេសេសីតិ ទិស្សតិ ។ ២ ឱ. ម. ពាហំ ។

គប្បីពោលយ៉ាងនេះថា ម្នាលអាវុសោ យើងទាំងឡាយ ជាអ្នកព្រមព្រៀងគ្នា មិនវិវាទគ្នា រីករាយរកគ្នា កំពុងសិក្សា តែវចីសង្សារ ការលើកខ្លួនដោយទិដ្ឋិ ការបៀតបៀនគ្នាដោយចិត្ត ការមិនត្រេកអរ ការមិនមានសេចក្តីពេញចិត្ត កើតឡើងដល់គ្នានិងគ្នា កាលបើសមណៈជ្រាបហេតុនោះ គប្បីតិះដៀលបាន ។ ម្នាលអាវុសោ ភិក្ខុបើមិនលះបង់ធម៌នុ៎ះទេ នឹងធ្វើឲ្យជាក់ច្បាស់នូវព្រះនិព្វានដូចម្តេចបាន ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុកាលនឹងពោលដោយប្រពៃ គប្បីពោលយ៉ាងនេះថា ម្នាលអាវុសោ ភិក្ខុ បើមិនលះបង់ធម៌នុ៎ះទេ នឹងមិនធ្វើឲ្យជាក់ច្បាស់នូវព្រះនិព្វានបានទេ ។ ម្នាលភិក្ខុទាំងឡាយ បើមានភិក្ខុពួកដទៃសួរភិក្ខុនោះយ៉ាងនេះថា លោកដ៏មានអាយុ មិនបានធ្វើភិក្ខុទាំងនេះ ឲ្យចេញចាកអកុសលធម៌ ឲ្យតាំងនៅក្នុងកុសលធម៌ ទេឬ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុកាលនឹងពោលដោយប្រពៃ គប្បីពោលយ៉ាងនេះថា ម្នាលអាវុសោ ក្នុងទីនេះ ខ្ញុំបានចូលទៅគាល់ព្រះមានព្រះភាគ ព្រះមានព្រះភាគ ទ្រង់សំដែងធម៌ ដល់ខ្ញុំ ខ្ញុំបានស្តាប់ធម៌ព្រះអង្គហើយបានសំដែងប្រាប់ភិក្ខុទាំងនោះ ភិក្ខុទាំងនោះ ក៏បានស្តាប់ធម៌នោះ

អកុសលា វុដ្ឋហឹសុ កុសលេ បតិដ្ឋហឹសូតិ ។ ឯវំ ព្យាករមានោ ខោ ភិក្ខវេ ភិក្ខុ ន ចេវត្តានុក្កំសេតិ[១] ន បរំ វម្ភេតិ ធម្មស្ស ចានុធម្មំ ព្យាករោតិ ន ច កោចិ សហធម្មិកោ វាទានុវាទោ គារយ្ហដ្ឋានំ អាគច្ឆតីតិ ។ ឥទមវោច ភគវា អត្តមនា តេ ភិក្ខូ ភគវតោ ភាសិតំ អភិនន្ទុន្តិ ។

កិន្តិសុត្តំ តតិយំ និដ្ឋិតំ ។

---

១ ម. នេវត្តានុក្កំសេតិ ។

ហើយចេញចាកអកុសលធម៌ បានតាំងនៅក្នុងកុសលធម៌ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុកាលពោលយ៉ាងនេះ មិនឈ្មោះថាលើកតម្កើងខ្លួន មិនឈ្មោះថា សង្កត់សង្កិនបុគ្គលដទៃទេ ឈ្មោះថាជាអ្នកពោលព្យាករនូវធម៌តាមធម៌ មួយទៀត វាទៈនិងអនុវាទៈ ដែលប្រកបដោយហេតុណាមួយ រមែងមិនមកកាន់ឋានៈ ដែលអ្នកប្រាជ្ញគប្បីតិះដៀលបានឡើយ ។ លុះព្រះមានព្រះភាគ ទ្រង់សំដែងព្រះសូត្រនេះចប់ហើយ ភិក្ខុទាំងនោះ ក៏មានចិត្តត្រេកអរ រីករាយ ចំពោះភាសិត របស់ព្រះមានព្រះភាគ ។

ចប់ កិន្តិសូត្រ ទី ៣ ។

# បតុត្ថំ សាមគាមសុត្តំ

(៨១) ឯវំ មេ សុតំ ។ ឯកំ សមយំ ភគវា សក្កេសុ វិហរតិ សាមគាមេ ។ តេន ខោ បន សមយេន និគណ្ឋោ នាដបុត្តោ បាវាយំ អធុនា កាលកតោ ហោតិ ។ តស្ស កាលកិរិយាយ ភិន្នា និគណ្ឋា ទ្វេឡ្ហកជាតា(១) ភណ្ឌនជាតា កលហជាតា វិវាទាបន្នា អញ្ញមញ្ញំ មុខសត្តីហិ វិតុទន្តា វិហរន្តិ ន ត្វំ ឥមំ ធម្មវិនយំ អាជានាសិ អហំ ឥមំ ធម្មវិនយំ អាជានាមិ កឹ ត្វំ ឥមំ ធម្មវិនយំ អាជានិស្សសិ មិច្ឆាបដិបន្នោ ត្វមសិ អហមស្មិ សម្មាបដិបន្នោ សហិតំ មេ អសហិតំ តេ បុរេ វចនីយំ បច្ឆា អវច បច្ឆា វចនីយំ បុរេ អវច អធិចិណ្ណំ តេ(២) វិបរាវត្តំ អារោបិតោ តេ វាទោ និគ្គហិតោសិ(៣) ចរ វាទប្បមោក្ខាយ និព្ពេឋេហិ វា សចេ បហោសីតិ ។ តេ អញ្ញមញ្ញំ កលហំ ករីសុ(៤) ។

---

១ ឱ ទ្វេធិកជាតាតិ ទិស្សតិ ។ ២ ឱ. អវិចិណ្ណន្តេ ។ ៣ ឱ. និគ្គហិតោ សី ។ ម. និគ្គហិតោសិ ។ ៤ ឱ. តេ អញ្ញមញ្ញំ កលហំ ករីសូតិ ន ទិស្សតិ ។

# សាមគាមសូត្រ ទី ៤

(៨១) ខ្ញុំបានស្តាប់មក យ៉ាងនេះ ។ សម័យមួយ ព្រះមានព្រះភាគ ទ្រង់គង់ក្នុងសាមគ្រាម ក្នុងដែនសក្កៈ ។ សម័យនោះឯង និគណ្ឋនាដបុត្រ ទើបតែនឹងធ្វើមរណកាល ក្នុងដែនបាវា ។ ព្រោះកាលកិរិយានៃនិគណ្ឋនាដបុត្រនោះ ពួកនិគ្រន្ថ (ជាអន្តេវាសិក) ក៏បែកបាក់គ្នាជាពីរពួក កើតប្រកួតប្រកាន់គ្នា ឈ្លោះទាស់ទែង ចាក់ដោតគ្នានឹងគ្នាដោយលំពែងគឺមាត់ថា អ្នកឯង មិនដឹងធម៌វិន័យនេះទេ យើងទើបដឹងធម៌វិន័យនេះ អ្នកឯងនឹងដឹងធម៌វិន័យនេះដូចម្តេចបាន អ្នកឯងប្រតិបត្តិខុស យើងទើបប្រតិបត្តិត្រូវ ពាក្យរបស់យើង ប្រកបដោយប្រយោជន៍ ពាក្យរបស់អ្នកឯង មិនប្រកបដោយប្រយោជន៍ទេ ពាក្យដែលគួរនិយាយមុន អ្នកឯងបែរជានិយាយក្រោយ ពាក្យដែលគួរនិយាយក្រោយ អ្នកឯងបែរជានិយាយមុន អ្នកឯងសន្សំតែវត្ថុដែលខុសៗ បើអ្នកឯងលើកវាទៈឡើង គេរមែងតិះដៀលបាន បើអ្នកឯងអាច ចូរប្រព្រឹត្តឲ្យរួចចាកវាទៈចុះ ។ ពួកនិគ្រន្ថទាំងនោះ ធ្វើនូវជម្លោះគ្នានឹងគ្នា ។

វធោយេវេកោ មញ្ញេ និគណ្ឋេសុ នាដបុត្តិយេសុ វត្តតិ ។ យេបិ និគណ្ឋស្ស នាដបុត្តស្ស សាវកា គិហី ឱទាតវសនា ។ តេបិ និគណ្ឋេសុ នាដបុត្តិយេសុ និព្វិន្នរូបា វិរត្តរូបា បដិវានរូបា យថាតំ ទុរក្ខាតេ ធម្មវិនយេ ទុប្បវេទិតេ អនិយ្យានិកេ អនុបសមសំវត្តនិកេ អសម្មាសម្ពុទ្ធប្បវេទិតេ ភិន្នថូបេ អប្បដិសរណេ ។

(៥២) អថខោ ចុន្ទោ សមណុទ្ទេសោ បាវាយំ វស្សំ វុត្ថោ[១] យេន សាមគ្គាមោ យេនាយស្មា អានន្ទោ តេនុបសង្កមិ ឧបសង្កមិត្វា អាយស្មន្តំ អានន្ទំ អភិវាទេត្វា ឯកមន្តំ និសីទិ ។ ឯកមន្តំ និសិន្នោ ខោ ចុន្ទោ សមណុទ្ទេសោ អាយស្មន្តំ អានន្ទំ ឯតទវោច និគណ្ឋោ ភន្តេ នាដបុត្តោ បាវាយំ អធុនា កាលកតោ តស្ស កាលកិរិយាយ ភិន្នា និគណ្ឋា ទ្វេធិកជាតា ។បេ ។

១ ឱ. វស្សំវុត្ថោ ។

សេចក្តីស្លាប់តែមួយនាក់ តែហាក់ដូចប្រព្រឹត្តទៅ ក្នុងពួកនិគ្រន្ថ ជាអន្តេវាសិក របស់និគណ្ឋនាដបុត្រ ។ ពួកសាវ័ករបស់និគណ្ឋនាដបុត្រណា ជាគ្រហស្ថ ស្លៀកពាក់ស ។ ពួកសាវ័កទាំងនោះ មានសភាពនឿយណាយ ប្រាសចាកសេចក្តីត្រេកអរ មានសភាពរួញរាក្នុងធម្មវិន័យ ដែលពួកនិគណ្ឋនាដបុត្រសំដែងខុស ប្រកាសខុស មិនមែនជានិយ្យានិកធម៌ មិនមែនប្រព្រឹត្ត ដើម្បីស្ងប់រម្ងាប់ មិនមែនព្រះសម្មាសម្ពុទ្ធសំដែង ជាថូបៈបែកធ្លាយ មិនមែនជាទីពំនាក់ឡើយ ។

(៤២) គ្រានោះ សមណុទ្ទេស ឈ្មោះចុន្ទៈ នៅចាំវស្សាក្នុងដែនបាវា ចូលទៅរកព្រះអានន្ទមានអាយុ ដែលគង់នៅក្នុងសាមគ្រាម លុះចូលទៅដល់ហើយ ក៏អភិវាទព្រះអានន្ទមានអាយុ រួចអង្គុយក្នុងទីសមគួរ ។ លុះចុន្ទសមណុទ្ទេស អង្គុយក្នុងទីសមគួរហើយ និយាយនឹងព្រះអានន្ទមានអាយុ ដូច្នេះថា បពិត្រលោកដ៏ចម្រើន និគណ្ឋនាដបុត្រ ទើបតែនឹងធ្វើមរណកាល ក្នុងដែនបាវា ព្រោះកាលកិរិយារបស់និគណ្ឋនាដបុត្រនោះ ពួកនិគ្រន្ថក៏បែកបាក់គ្នាជាពីរពួក ។ បេ ។

ភិន្នថូបេ អប្បដិសរណេតិ ។ ឯវំ វុត្តេ អាយស្មា អានន្ទោ ចុន្ទំ សមណុទ្ទេសំ ឯតទវោច អត្ថិ ខោ ឥទំ អាវុសោ ចុន្ទ កថាបាភតំ ភគវន្តំ ទស្សនាយ អាយាមាវុសោ ចុន្ទ យេន ភគវា តេនុបសង្កមិស្សាម ឧបសង្កមិត្វា ឯតមត្ថំ ភគវតោ អារោចេស្សាមាតិ ។ ឯវំ ភន្តេតិ ខោ ចុន្ទោ សមណុទ្ទេសោ អាយស្មតោ អានន្ទស្ស បច្ចស្សោសិ ។

(៨៣) អថខោ អាយស្មា ច[១] អានន្ទោ ចុន្ទោ ច សមណុទ្ទេសោ យេន ភគវា តេនុបសង្កមឹសុ ឧបសង្កមិត្វា ភគវន្តំ អភិវាទេត្វា ឯកមន្តំ និសីទឹសុ ។ ឯកមន្តំ និសិន្នោ ខោ អាយស្មា អានន្ទោ ភគវន្តំ ឯតទវោច អយំ ភន្តេ ចុន្ទោ សមណុទ្ទេសោ ឯវមាហ និគណ្ឋោ ភន្តេ នាដបុត្តោ បាវាយំ អធុនា កាលកតោ តស្ស កាលកិរិយាយ ភិន្នា និគណ្ឋា ទ្វេធិកជាតា ភណ្ឌនជាតា

១ ឱ. ចសទ្ទោ ន ទិស្សតិ ។

ជាដុំបះបែកធ្លាយ មិនមែនជាពិតាក់ទៀយ ។ កាលចុន្ទសមណុទ្ទេស និយាយ យ៉ាងនេះហើយ ព្រះអានន្ទមានអាយុ និយាយនឹងចុន្ទសមណុទ្ទេសយ៉ាងនេះថា ម្នាលអាវុសោចុន្ទៈ ពាក្យនេះ ជាពាក្យមានមូលគួរនឹងទៅគាល់ព្រះមានព្រះភាគណាស់ ម្នាលអាវុសោចុន្ទៈ មកយើងនឹងចូលទៅគាល់ព្រះមានព្រះភាគ លុះចូលទៅដល់ហើយ នឹងក្រាបបង្គំទូលសេចក្តីនេះ ចំពោះព្រះមានព្រះភាគ ។ ចុន្ទសមណុទ្ទេស ក៏ទទួលពាក្យព្រះអានន្ទមានអាយុថា ព្រះករុណា លោកម្ចាស់ ។

(៤៣) លំដាប់នោះ ព្រះអានន្ទមានអាយុនឹងចុន្ទសមណុទ្ទេស បានចូលទៅគាល់ព្រះមានព្រះភាគ លុះចូលទៅដល់ហើយ ក្រាបថ្វាយបង្គំព្រះមានព្រះភាគ ហើយអង្គុយក្នុងទីសមគួរ ។ លុះព្រះអានន្ទមានអាយុ គង់ក្នុងទីសមគួរហើយ ក៏ក្រាបបង្គំទូលព្រះមានព្រះភាគដូច្នេះថា បពិត្រព្រះអង្គដ៏ចំរើន ចុន្ទសមណុទ្ទេសនេះឯង បាននិយាយយ៉ាងនេះថា បពិត្រលោកដ៏ចំរើន និគណ្ឋនាដបុត្រ ទើបតែនឹងធ្វើមរណកាលក្នុងដែនបាវា ព្រោះកាលកិរិយារបស់និគណ្ឋនាដបុត្រនោះ ពួកនិគ្រន្ថក៏បែកបាក់គ្នាជាពីរពួក កើតទៅជាប្រកួតប្រកាន់

កលហជាតា ភណ្ឌនជាតា អញ្ញមញ្ញំ មុខសត្តីហិ វិតុទន្តា វិហរន្តិ ន ត្វំ ឥមំ ធម្មវិនយំ អាជានាសិ អហំ ឥមំ ធម្មវិនយំ អាជានាមិ ។ បេ ។ ភិន្នថូបេ អប្បដិសរណេតិ តស្ស មយ្ហំ ភន្តេ ឯវំ ហោតិ មា ហេវ ភគវតោ អច្ចយេន សង្ឃេ វិវាទោ ឧប្បជ្ជិ ស្វាស្ស[1] វិវាទោ ពហុជនាហិតាយ ពហុជនាសុខាយ ពហុនោ ជនស្ស អនត្ថាយ អហិតាយ ទុក្ខាយ ទេវមនុស្សានន្តិ ។

(៥៤) តំ កឹ មញ្ញសិ អានន្ទ យេ តេ មយា ធម្មា អភិញ្ញា ទេសិតា សេយ្យថីទំ ចត្តារោ ស-តិបដ្ឋានា ចត្តារោ សម្មប្បធានា ចត្តារោ ឥទ្ធិបាទា បញ្ចិន្ទ្រិយានិ បញ្ច ពលានិ សត្ត ពោជ្ឈង្គា អរិយោ អដ្ឋង្គិកោ មគ្គោ បស្សសិ នោ ត្វំ អានន្ទ ឥមេសុ ធម្មេសុ ទ្វេបិ ភិក្ខូ នានាវាទេ ។ យេ នោ[2] ភន្តេ ធម្មា ភគវតា អភិញ្ញា ទេសិតា

---

១ ឱ. ឧប្បជ្ជិ ហោតិ ទិស្សតិ ។ ម. ឧប្បជ្ជតុ ស្វាយន្តិ ទិស្សតិ ។ ២ ឱ. អ. មេ ។

ឈ្លោះទាស់ទែង ចាក់ដោតគ្នានឹងគ្នាដោយលំពែងគឺមាត់ថា អ្នកឯងមិនដឹងធម៌វិន័យនេះទេ យើងទើបដឹងធម៌វិន័យនេះ ។ បេ ។ ជាឋូបៈបែកធ្លាយ មិនមែនជាទីពំនាក់ឡើយ បពិត្រព្រះអង្គដ៏ចំរើន ខ្ញុំព្រះអង្គមានសេចក្ដីត្រិះរិះ យ៉ាងនេះថា អំណើះតអំពីព្រះមានព្រះភាគទៅ សូមកុំឲ្យវិវាទកើតឡើងក្នុងសង្ឃឡើយ ព្រោះថាវិវាទនោះ នឹងប្រព្រឹត្តទៅដើម្បីមិនជាគុណដល់ជនច្រើន មិនជាសុខដល់ជនច្រើន មិនជាប្រយោជន៍ មិនជាសេចក្ដីចម្រើនដល់ជនច្រើន ជាទុក្ខដល់ទេវតានិងមនុស្សទាំងឡាយ ។

( ៥៤ ) ព្រះមានព្រះភាគ ទ្រង់ត្រាស់ថា ម្នាលអានន្ទ អ្នកយល់សេចក្ដីនោះដូចម្ដេច ធម៌ទាំងឡាយដែលតថាគតត្រាស់ដឹងហើយ សំដែងហើយ ដល់អ្នកទាំងឡាយ ដូចជាសតិប្បដ្ឋាន ៤ សម្មប្បធាន ៤ ឥទ្ធិបាទ ៤ ឥន្ទ្រិយ ៥ ពលៈ ៥ ពោជ្ឈង្គ ៧ មគ្គដ៏ប្រសើរប្រកបដោយអង្គ ៨ ម្នាលអានន្ទ អ្នកដែលឃើញភិក្ខុពីររូបមានវាទៈផ្សេងគ្នាក្នុងធម៌ទាំងឡាយនេះដែរឬ ។ បពិត្រព្រះអង្គដ៏ចំរើន ធម៌ទាំងឡាយដែលព្រះមានព្រះភាគត្រាស់ដឹងហើយ សំដែងហើយ ដល់ខ្ញុំព្រះអង្គ

សេយ្យថីទំ ចត្តារោ សតិបដ្ឋានា ចត្តារោ សម្មប្បធានា ចត្តារោ ឥទ្ធិបាទា បញ្ចិន្ទ្រិយានិ បញ្ច ពលានិ សត្ត ពោជ្ឈង្គា អរិយោ អដ្ឋង្គិកោ មគ្គោ នាហំ បស្សាមិ ឥមេសុ ធម្មេសុ ទ្វេបិ ភិក្ខូ នានាវាទេ សន្តិ ច ខោ[១] ភន្តេ បុគ្គលា ភគវន្តំ បតិស្សយមានរូបា វិហរន្តិ តេ ភគវតោ អច្ចយេន សង្ឃេ វិវាទំ ជនេយ្យុំ អជ្ឈាជីវេ វា អធិបាតិមោក្ខេ វា ស្វាស្ស[២] វិវាទោ ពហុជនាហិតាយ ពហុជនាសុខាយ ពហុនោ ជនស្ស អនត្ថាយ អហិតាយ ទុក្ខាយ ទេវមនុស្សានន្តិ ។ អប្បមត្តកោ យោ[៣] អានន្ទ វិវាទោ យទិទំ អជ្ឈាជីវេ វា អធិបាតិមោក្ខេ វា មគ្គេ វាបិ អានន្ទ បដិបទាយ វា សង្ឃេ វិវាទោ ឧប្បជ្ជមានោ ឧប្បជ្ជេយ្យ ស្វាស្ស វិវាទោ ពហុជនាហិតាយ ពហុជនាសុខាយ ពហុនោ ជនស្ស អនត្ថាយ អហិតាយ ទុក្ខាយ ទេវមនុស្សានន្តិ ។

១ ឱ. យេ ច ខោ ។ ម. ខោ បនេ ទិស្សន្តិ ។ ២ ឱ. សោស្ស ។ ៣ ឱ. សោ ។

ទាំងឡាយ ដូចជាសតិប្បដ្ឋាន ៤ សម្មប្បធាន ៤ ឥទ្ធិបាទ ៤ ឥន្ទ្រិយ ៥ ពលៈ ៥ ពោជ្ឈង្គ ៧ មគ្គដ៏ប្រសើរប្រកបដោយអង្គ ៨ ខ្ញុំព្រះអង្គមិនដែលឃើញភិក្ខុពីររូបមានវាទៈផ្សេងគ្នា ក្នុងធម៌វិន័យនេះឡើយ បពិត្រព្រះអង្គដ៏ចំរើន មានតែពួកបុគ្គល ដែលជាអ្នកអែបអបនូវព្រះមានព្រះភាគទេ លុះអំណើះតអំពីព្រះមានព្រះភាគទៅ នឹងញុំាងវិវាទឲ្យកើតឡើងក្នុងព្រះសង្ឃ ព្រោះអាជីវៈជាហេតុខ្លះ ព្រោះអធិប្បាតិមោក្ខជាហេតុខ្លះ វិវាទនោះនឹងប្រព្រឹត្តទៅ ដើម្បីមិនជាគុណដល់ជនច្រើន មិនជាសុខដល់ជនច្រើន មិនជាប្រយោជន៍ មិនជាសេចក្តីចំរើនដល់ជនច្រើន ជាទុក្ខដល់ទេវតានិងមនុស្សទាំងឡាយ ។ ម្នាលអានន្ទ កាលវិវាទណាកើតឡើង ព្រោះអាស្រ័យអាជីវៈជាហេតុ ឬព្រោះអាស្រ័យអធិប្បាតិមោក្ខជាហេតុ វិវាទនោះ គ្រាន់តែជាការបន្តិចបន្តួចទេ ម្នាលអានន្ទមួយទៀត កាលវិវាទណា កើតឡើងក្នុងសង្ឃ ព្រោះអាស្រ័យមគ្គ ឬព្រោះអាស្រ័យបដិបទា វិវាទនោះនឹងប្រព្រឹត្តទៅ ដើម្បីមិនជាគុណដល់ជនច្រើន មិនជាសុខដល់ជនច្រើន មិនជាប្រយោជន៍ មិនជាសេចក្តីចំរើនដល់ជនច្រើន ជាទុក្ខដល់ទេវតានិងមនុស្សទាំងឡាយ ។

(៥៥) ឆយិមានិ អានន្ទ វិវាទមូលានិ កតមានិ ឆ ឥធានន្ទ ភិក្ខុ កោធនោ ហោតិ ឧបនាហី ។ យោ សោ អានន្ទ ភិក្ខុ កោធនោ ហោតិ ឧបនាហី សោ សត្ថរិបិ អគារវោ វិហរតិ អប្បតិស្សោ ធម្មេបិ អគារវោ វិហរតិ អប្បតិស្សោ សង្ឃេបិ អគារវោ វិហរតិ អប្បតិស្សោ សិក្ខាយបិ ន បរិបូរការី ហោតិ ។ យោ សោ អានន្ទ ភិក្ខុ សត្ថរិ អគារវោ វិហរតិ អប្បតិស្សោ ធម្មេ ... សង្ឃេបិ អគារវោ វិហរតិ អប្បតិស្សោ សិក្ខាយបិ ន បរិបូរការី[1] សោ សង្ឃេ វិវាទំ ជនេតិ ។ យោ ហោតិ វិវាទោ ពហុជនាហិតាយ ពហុជនាសុខាយ ពហុនោ ជនស្ស អនត្ថាយ អហិតាយ ទុក្ខាយ ទេវមនុស្សានំ ។ ឯវរូបញ្ចេ តុម្ហេ អានន្ទ វិវាទមូលំ អជ្ឈត្តំ វា ពហិទ្ធា វា សមនុបស្សេយ្យាថ តត្រ តុម្ហេ អានន្ទ

១ ម. ឯត្ថន្តរេ ហោតីតិ ទិស្សតិ ។

(៩៩) ម្នាលអានន្ទ វិវាទមូលនេះមាន ៦ ប្រការ វិវាទមូល ៦ ប្រការដូចម្តេច ម្នាលអានន្ទ ភិក្ខុក្នុងសាសនានេះ ជាអ្នកច្រើនក្រោធ ជាអ្នកច្រើនចងពៀរ ។ ម្នាលអានន្ទ ភិក្ខុណា ជាអ្នកច្រើនក្រោធ ជាអ្នកច្រើនចងពៀរ ភិក្ខុនោះ ឈ្មោះថាមិនគោរព មិនកោតក្រែងចំពោះព្រះសាស្តាផង មិនគោរព មិនកោតក្រែងចំពោះព្រះធម៌ផង មិនគោរព មិនកោតក្រែងចំពោះព្រះសង្ឃផង មិនធ្វើឲ្យពេញលេញក្នុងសិក្ខាផង ។ ម្នាលអានន្ទ ភិក្ខុណា មិនគោរព មិនកោតក្រែង ចំពោះព្រះសាស្តា ចំពោះព្រះធម៌... មិនគោរព មិនកោតក្រែងចំពោះព្រះសង្ឃផង មិនធ្វើឲ្យពេញលេញក្នុងសិក្ខាផង ភិក្ខុនោះ ឈ្មោះថាបង្កើតវិវាទក្នុងសង្ឃ ។ វិវាទ (ដែលកើតក្នុងសង្ឃ) តែងប្រព្រឹត្តទៅដើម្បីមិនជាគុណដល់ជនច្រើន មិនជាសុខដល់ជនច្រើន មិនជាប្រយោជន៍ មិនជាសេចក្តីចម្រើនដល់ជនច្រើន ជាទុក្ខដល់ពួកទេវតានិងមនុស្ស ។ ម្នាលអានន្ទ បើអ្នកទាំងឡាយ ពិចារណាឃើញវិវាទមូល មានសភាពយ៉ាងនេះ ពួកខាងក្នុងក្តី ពួកខាងក្រៅក្តី ម្នាលអានន្ទ ក្នុងរឿងនោះ អ្នកទាំងឡាយ

តស្សេវ បាបកស្ស វិវាទមូលស្ស បហានាយ វាយមេយ្យាថ ឯវរូបញ្ចេ តុម្ហេ អានន្ទ វិវាទមូលំ អជ្ឈត្តំ វា ពហិទ្ធា វា ន សមនុបស្សេយ្យាថ តត្រ តុម្ហេ អានន្ទ តស្សេវ បាបកស្ស វិវាទមូលស្ស អាយតឹ អនវស្សវាយ បដិបជ្ជេយ្យាថ ឯវមេតស្ស បាបកស្ស វិវាទមូលស្ស បហានំ ហោតិ ឯវមេតស្ស បាបកស្ស វិវាទមូលស្ស អាយតឹ អនវស្សវោ ហោតិ ។

(៤៦) បុន ចបរំ អានន្ទ ភិក្ខុ មក្ខី ហោតិ បឡាសី ... ឥស្សុកី ហោតិ មច្ឆរី ... សឋោ ហោតិ មាយាវី ... បាបិច្ឆោ ហោតិ មិច្ឆាទិដ្ឋី ... សន្ទិដ្ឋិបរាមាសី ហោតិ អាធានគ្គាហី ទុប្បដិនិស្សគ្គី ។ យោ សោ អានន្ទ ភិក្ខុ សន្ទិដ្ឋិបរាមាសី ហោតិ អាធានគ្គាហី ទុប្បដិនិស្សគ្គី សោ សត្ថរិបិ អគារវោ វិហរតិ អប្បតិស្សោ ធម្មេបិ អគារវោ វិហរតិ អប្បតិស្សោ សង្ឃេបិ អគារវោ វិហរតិ អប្បតិស្សោ សិក្ខាយបិ ន បរិបូរការី ហោតិ ។

គួរព្យាយាមលះវិវាទមូលដ៏លាមកនោះចេញ ម្នាលអានន្ទ បើអ្នកទាំងឡាយ ពិចារណាមិនឃើញវិវាទមូលមានសភាពយ៉ាងនេះ ក្នុងខាងក្នុងក្តី ក្នុងខាងក្រៅក្តី ម្នាលអានន្ទ ក្នុងដំណើរនោះ អ្នកទាំងឡាយ គួរប្រតិបត្តិ ដើម្បីកុំឲ្យវិវាទមូលដ៏លាមកនោះឯង ហូរហៀរតទៅទៀត ការលះបង់វិវាទមូលដ៏លាមកនុ៎ះ រមែងមាន ដោយប្រការយ៉ាងនេះ ការមិនឲ្យវិវាទមូលដ៏លាមក ហូរហៀរតទៅទៀត រមែងមាន ដោយប្រការយ៉ាងនេះ ។

(៥៦) ម្នាលអានន្ទ មួយទៀត ភិក្ខុជាអ្នកច្រើនលុបគុណគេ ជាអ្នកច្រើនលើកខ្លួន ... ជាអ្នកច្រើនច្រណែន ជាអ្នកកំណាញ់ ... ជាអ្នកអួតអាង ជាអ្នកមានមាយា ... ជាអ្នកមានប្រាថ្នាដ៏លាមក ជាអ្នកមានសេចក្តីឃើញខុស ... ជាអ្នកប្រកាន់តាមសេចក្តីយល់ឃើញរបស់ខ្លួន ជាអ្នកស្ទាបអង្អែល (ទុរាសីលនិនទិដ្ឋិ) ជាអ្នកប្រកាន់មាំ ជាអ្នកលះបង់បានដោយកម្រ ។ ម្នាលអានន្ទ ភិក្ខុណា ជាអ្នកប្រកាន់តាមសេចក្តីយល់ឃើញរបស់ខ្លួន ជាអ្នកស្ទាបអង្អែល ជាអ្នកប្រកាន់មាំ ជាអ្នកលះបង់បានដោយកម្រ ភិក្ខុនោះ ឈ្មោះថាមិនគោរព មិនកោតក្រែងចំពោះព្រះសាស្តាផង មិនគោរព មិនកោតក្រែងចំពោះព្រះធម៌ផង មិនគោរពមិនកោតក្រែងចំពោះព្រះសង្ឃផង ជាអ្នកមិនធ្វើឲ្យពេញលេញក្នុងសិក្ខា ។

យោ សោ អានន្ទ ភិក្ខុ សត្ថរិ អគារវោ វិហរតិ អប្បតិស្សោ ធម្មេ ... សង្ឃេ ... សិក្ខាយ ន បរិបូរការី ហោតិ សោ សង្ឃេ វិវាទំ ជនេតិ ។ យោ ហោតិ វិវាទោ ពហុជនាហិតាយ ពហុជនាសុខាយ ពហុនោ ជនស្ស អនត្ថាយ អហិតាយ ទុក្ខាយ ទេវមនុស្សា-នំ ។ ឯវរូបញ្ចេ តុម្ហេ អានន្ទ វិវាទមូលំ អជ្ឈត្តំ វា ពហិទ្ធា វា សមនុបស្សេយ្យាថ តត្រ តុម្ហេ អា-នន្ទ តស្សេវ បាបកស្ស វិវាទមូលស្ស បហានាយ វាយមេយ្យាថ ។ ឯវរូបញ្ចេ តុម្ហេ អានន្ទ វិវាទមូលំ អជ្ឈត្តំ វា ពហិទ្ធា វា ន សមនុបស្សេយ្យាថ តត្រ តុម្ហេ អានន្ទ តស្សេវ បាបកស្ស វិវាទមូលស្ស អាយតឹ អនវស្សវាយ បដិបជ្ជេយ្យាថ ឯវមេតស្ស បាបកស្ស វិវាទមូលស្ស បហានំ ហោតិ ឯវមេ-តស្ស បាបកស្ស វិវាទមូលស្ស អាយតឹ អនវស្សវោ ហោតិ ។ ឥមានិ ខោ អានន្ទ ឆ វិវាទមូលានិ ។

ម្នាលអានន្ទ ភិក្ខុណា មិនគោរព មិនកោតក្រែងចំពោះព្រះសាស្ដា ព្រះធម៌... ព្រះសង្ឃ... ជាអ្នកមិនធ្វើឲ្យពេញលេញក្នុងសិក្ខា ភិក្ខុនោះឈ្មោះជាបង្កើតវិវាទក្នុងសង្ឃ ៗ វិវាទ (ដែលកើតឡើង) រមែងប្រព្រឹត្តទៅដើម្បីមិនជាគុណដល់ជនច្រើន មិនជាសុខដល់ជនច្រើន មិនជាប្រយោជន៍ មិនជាសេចក្ដីចម្រើនដល់ជនច្រើន ជាទុក្ខដល់ពួកទេវតានិងមនុស្ស ៗ ម្នាលអានន្ទ បើអ្នកទាំងឡាយ ពិចារណាឃើញវិវាទមូល មានសភាពយ៉ាងនេះ ព្វជ៌ខាងក្នុងក្ដី ព្វជ៌ខាងក្រៅក្ដី ម្នាលអានន្ទ ក្នុងដំណើរនោះ អ្នកទាំងឡាយ គួរព្យាយាម លះបង់វិវាទមូលដ៏លាមកនោះចេញ ៗ ម្នាលអានន្ទ បើអ្នកទាំងឡាយពិចារណាមិនឃើញវិវាទមូលមានសភាពយ៉ាងនេះ ព្វជ៌ខាងក្នុងក្ដី ព្វជ៌ខាងក្រៅក្ដី ម្នាលអានន្ទ ក្នុងដំណើរនោះ អ្នកទាំងឡាយ គួរប្រតិបត្តិដើម្បីកុំឲ្យវិវាទមូលដ៏លាមកនោះឯង ហូរហៀរតទៅ ការលះបង់វិវាទដ៏លាមកនេះ រមែងមាន ដោយប្រការយ៉ាងនេះ ការមិនឲ្យវិវាទមូលដ៏លាមកនេះ ហូរហៀរតទៅ រមែងមាន ដោយប្រការយ៉ាងនេះ ៗ ម្នាលអានន្ទ នេះឯងវិវាទមូល ៦ យ៉ាង ៗ

(៤៧) ចត្តារិមានិ អានន្ទ អធិករណានិ កតមានិ ចត្តារិ វិវាទាធិករណំ អនុវាទាធិករណំ អាបត្តាធិករណំ កិច្ចាធិករណំ ឥមានិ ខោ អានន្ទ ចត្តារិ អធិករណានិ ។ សត្ត ខោ បនិមេ អានន្ទ អធិករណសមថា ឧប្បន្នុប្បន្នានំ អធិករណានំ សមថាយ វូបសមាយ សម្មុខាវិនយោ ទាតព្វោ សតិវិនយោ ទាតព្វោ អមូឡ្ហវិនយោ ទាតព្វោ បដិញ្ញាតករណំ(១) យេភុយ្យសិកា តស្សបាបិយសិកា តិណវត្ថារកោ ។

(៤៨) កថញ្ចានន្ទ សម្មុខាវិនយោ ហោតិ ។ ឥធានន្ទ ភិក្ខូ វិវទន្តិ ធម្មោតិ វា អធម្មោតិ វា វិនយោតិ វា អវិនយោតិ វា ។ តេហានន្ទ ភិក្ខូហិ សព្វេហេវ សមគ្គេហិ សន្និបតិតព្វំ ធម្មនេត្តិ សមនុមជ្ជិតព្វា ធម្មនេត្តិំ សមនុមជ្ជិត្វា យថា តត្ថ សមេតិ តថា តំ អធិករណំ វូបសមេតព្វំ ។

---

១ ម. ប. បដិញ្ញាយ ការេតព្វំ ។

(៨៧) ម្នាលអានន្ទ អធិករណ៍នេះមាន ៤ យ៉ាង អធិករណ៍ ៤ យ៉ាងដូចម្តេចខ្លះ អធិករណ៍ ៤ យ៉ាងគឺ វិវាទាធិករណ៍ ១ អនុវាទាធិករណ៍ ១ អាបត្តាធិករណ៍ ១ កិច្ចាធិករណ៍ ១ ម្នាលអានន្ទ នេះឯងជាអធិករណ៍ ៤ យ៉ាង ។ ម្នាលអានន្ទ អធិករណសមថៈនេះមាន ៧ យ៉ាង គឺសម្មុខាវិន័យ ១ សតិវិន័យ ១ អមូឡ្ហវិន័យ ១ បដិញ្ញាតករណៈ ១ យេភុយ្យសិកា ១ តស្សបាបិយសិកា ១ តិណវត្ថារកៈ ១ ដែលសង្ឃគប្បីឲ្យ ដើម្បីរម្ងាប់អធិករណ៍ដែលកើតឡើងហើយ ។

(៨៨) ម្នាលអានន្ទ ចុះសម្មុខាវិន័យ តើដូចម្តេច ។ ម្នាលអានន្ទ ភិក្ខុទាំងឡាយក្នុងសាសនានេះ ជជែកគ្នាថា នេះជាធម៌ ឬថានេះមិនមែនជាធម៌ ថានេះជាវិន័យ ឬថា នេះមិនមែនជាវិន័យ ។ ម្នាលអានន្ទ ភិក្ខុទាំងអស់នោះឯង គប្បីព្រមព្រៀងគ្នា ប្រជុំប្រៀបធៀបតាមបែបដែលជាធម៌ លុះប្រៀបធៀបតាមបែបដែលជាធម៌រួចហើយ គប្បីរម្ងាប់អធិករណ៍នោះ ដោយវិធីដែលគួររម្ងាប់តាមបែបដែលជាធម៌នោះ ។

ឯវំ ខោ អានន្ទ សម្មុខាវិនយោ ហោតិ ។ ឯវញ្ច បនិធេកច្ចានំ អធិករណានំ វូបសមោ ហោតិ យទិទំ សម្មុខាវិនយេន ។

(៤៩) កថញ្ចានន្ទ យេភុយ្យសិកា ហោតិ ។ តេ បន[១] អានន្ទ ភិក្ខូ ន សក្កោន្តិ តំ អធិ-ករណំ តស្មឹ អាវាសេ វូបសមេតុំ ។ តេហិ អានន្ទ[២] ភិក្ខូហិ យស្មឹ អាវាសេ ពហុតរា ភិក្ខូ សោ អាវាសោ គន្តព្វោ ។ តត្ថ សព្វេហេវ សមគ្គេហិ សន្និបតិតព្វំ សន្និបតិត្វា ធម្មនេត្តិ ស-មនុមជ្ជិតព្វា ធម្មនេត្តឹ សមនុមជ្ជិត្វា យថា តត្ថ សមេតិ តថា តំ អធិករណំ វូបសមេតព្វំ ។ ឯវំ ខោ អានន្ទ យេភុយ្យសិកា ហោតិ ។ ឯវញ្ច បនិធេកច្ចានំ អធិករណានំ វូបសមោ ហោតិ យទិទំ យេភុយ្យសិកាយ ។

១ ឱ. ម. ចេ ។ ២ ឱ. ម. តេហានន្ទ ។

ម្នាលអានន្ទ សម្មុខាវិន័យ យ៉ាងនេះឯង ។ ការរម្ងាប់អធិករណ៍ពួកខ្លះ ក្នុងសាសនានេះ រមែងមានដោយសម្មុខាវិន័យ យ៉ាងនេះឯង ។

(៥៩) ម្នាលអានន្ទ ចុះយេភុយ្យសិកាតើដូចម្តេច ។ ម្នាលអានន្ទ បើភិក្ខុទាំងនោះ មិនអាចរម្ងាប់អធិករណ៍នោះក្នុងអាវាសនោះបានទេ ។ ម្នាលអានន្ទ ក្នុងអាវាសណា មានភិក្ខុច្រើន ភិក្ខុទាំងនោះ គប្បីទៅកាន់អាវាសនោះ ។ ភិក្ខុទាំងអស់នោះ គួរមកប្រជុំគ្នាក្នុងអាវាសនោះ លុះប្រជុំគ្នាហើយ គួរប្រៀបធៀបតាមបែបដែលជាធម៌ លុះប្រៀបធៀបតាមបែបដែលជាធម៌ហើយ គប្បីរម្ងាប់អធិករណ៍នោះដោយវិធីដែលឲ្យរម្ងាប់តាមបែបដែលជាធម៌នោះ ។ ម្នាលអានន្ទ យេភុយ្យសិកា យ៉ាងនេះឯង ។ ការរម្ងាប់អធិករណ៍ពួកខ្លះ ក្នុងសាសនានេះ រមែងមានដោយយេភុយ្យសិកា យ៉ាងនេះឯង ។

(២០) កថញ្ចានន្ទ សតិវិនយោ ហោតិ ។ ឥធានន្ទ ភិក្ខូ ភិក្ខុំ ឯវរូបាយ គរុកាយ អាបត្តិយា ចោទេន្តិ បារាជិកេន វា បារាជិកសាមន្តេន វា សរតាយស្មា ឯវរូបំ គរុកំ អាបត្តឹ អាបជ្ជិតា បារាជិកំ វា បារាជិកសាមន្តំ វាតិ ។ សោ ឯវមាហ ន ខោ អហំ អាវុសោ សរាមិ ឯវរូបំ គរុកំ អាបត្តឹ អាបជ្ជិតា បារាជិកំ វា បារាជិកសាមន្តំ វាតិ ។ តស្ស ខោ ឯវំ អានន្ទ ភិក្ខុនោ សតិវិនយោ ទាតព្វោ ។ ឯវំ ខោ អានន្ទ សតិវិនយោ ហោតិ ។ ឯវញ្ច បនិធេកច្ចានំ អធិករណានំ វូបសមោ ហោតិ យទិទំ សតិវិនយេន ។

(៦០) ម្នាលអានន្ទ ចុះសតិវិន័យ តើដូចម្តេច ។ ម្នាលអានន្ទ ក្នុងសាសនានេះ ភិក្ខុទាំងឡាយ ចោទភិក្ខុ ដោយគរុកាបត្តិ មានសភាពយ៉ាងនេះ គឺអាបត្តិបារាជិកក្តី អាបត្តិវង[១] បារាជិកក្តីថា លោកមានអាយុ រលឹកនូវគរុកាបត្តិមានសភាពយ៉ាងនេះ គឺអាបត្តិបារាជិកក្តី អាបត្តិវងបារាជិកក្តី ដែលលោកត្រូវហើយ ឃើញឬទេ ។ ភិក្ខុនោះនិយាយយ៉ាងនេះថា ម្នាលអាវុសោ ខ្ញុំរលឹកនូវគរុកាបត្តិមានសភាពយ៉ាងនេះ គឺអាបត្តិបារាជិកក្តី អាបត្តិវងបារាជិកក្តី ដែលខ្ញុំត្រូវហើយមិនឃើញទេ ។ ម្នាលអានន្ទ យ៉ាងនេះ សង្ឃគប្បីឲ្យសតិវិន័យដល់ភិក្ខុនោះ ។ ម្នាលអានន្ទ សតិវិន័យ យ៉ាងនេះឯង ។ ការរម្ងាប់អធិករណ៍ពួកខ្លះ ក្នុងសាសនានេះ រមែងមាន ដោយសតិវិន័យ យ៉ាងនេះឯង ។

---

១ ពាក្យថា វង ក្នុងទីនេះ សំដៅសេចក្តីថា បន្ទាប់គ្នា ពីរយ៉ាង គឺ វងកងអាបត្តិ ១ វងអាបត្តិ ១ រាប់អាបត្តិរៀងតាមលំដាប់ដូច្នេះ គឺ កងអាបត្តិបារាជិក កងអាបត្តិសង្ឃាទិសេស កងអាបត្តិថុល្លច្ច័យ បាចិត្តិយៈ បាដិទេសនីយៈ ទុក្កដ ទុព្ភាសិត ឈ្មោះថា វងកងអាបត្តិ ។ អាបត្តិទុក្កដ ថុល្លច្ច័យ ដែលត្រូវមុខគរុកាបត្តិ ឈ្មោះថា វងអាបត្តិ ។

## ទេវទហវគ្គស្ស សាមគាមសុត្តេ អមូឡ្ហវិនយោ

(៦១) កថញ្ចានន្ទ អមូឡ្ហវិនយោ ហោតិ ។ ឥធា-
នន្ទ ភិក្ខុ ភិក្ខុំ ឯវរូបាយ គរុកាយ អាបត្តិយា ចោ-
ទេតិ បារាជិកេន វា បារាជិកសាមន្តេន វា សរតា-
យស្មា ឯវរូបំ គរុកំ អាបត្តឹ អាបជ្ជិតា បារាជិកំ វា
បារាជិកសាមន្តំ វាតិ ។ សោ ឯវមាហ ន ខោ អហំ
អាវុសោ សរាមិ ឯវរូបំ គរុកំ អាបត្តឹ អាបជ្ជិតា
បារាជិកំ វា បារាជិកសាមន្តំ វាតិ ។ តមេនំ សោ
និព្វេឋេន្តំ អតិវេឋេតិ[១] ឥង្ឃាយស្មា សាធុកមេវ
ជានាហិ យទិ សរសិ ឯវរូបំ គរុកំ អាបត្តឹ
អាបជ្ជិតា បារាជិកំ វា បារាជិកសាមន្តំ វាតិ ។
សោ ឯវមាហ អហំ ខោ អាវុសោ ឧម្មាទំ បាបុ-
ណឹ ចេតសោ វិបរិយេសំ តេន[២] មេ ឧម្មត្តកេន
ពហុំ អស្សាមណកំ អជ្ឈាចិណ្ណំ ភាសិតបរិក្កន្តំ

---

១ ឱ. ម. អតិវេឋេតិ ។ ២ ទ. វិបរិយាសំ តេន ។ ម. វិបរិយេសគតេន ។

(៦១) ម្នាលអានន្ទ ចុះអមូឡ្ហវិន័យតើដូចម្តេច ។ ម្នាលអានន្ទ ក្នុងសាសនានេះ ភិក្ខុទាំងឡាយ ចោទភិក្ខុដោយគរុកាបត្តិមានសភាពយ៉ាងនេះ គឺអាបត្តិបារាជិកក្តី អាបត្តិរងបារាជិកក្តីថា លោកមានអាយុរលឹកនូវគរុកាបត្តិមានសភាពយ៉ាងនេះ គឺអាបត្តិបារាជិកក្តី អាបត្តិរងបារាជិកក្តី ដែលលោកត្រូវហើយ ឃើញឬទេ ។ ភិក្ខុនោះនិយាយយ៉ាងនេះថា ម្នាលអាវុសោ ខ្ញុំរលឹកនូវគរុកាបត្តិមានសភាពយ៉ាងនេះ គឺអាបត្តិបារាជិកក្តី អាបត្តិរងបារាជិកក្តី ដែលខ្ញុំត្រូវហើយ មិនឃើញទេ ។ ភិក្ខុនោះញ៉ាំងភិក្ខុនេះ ដែលកំពុងបណ្តោះបណ្តៃ មិនឲ្យបណ្តោះបណ្តៃបានថា លោកដ៏មានអាយុ ណ្ហើយ លោកចូរទទួលដឹងដោយស្រួលចុះ បើលោករលឹកឃើញនូវគរុកាបត្តិមានសភាពយ៉ាងនេះ គឺអាបត្តិបារាជិកក្តី អាបត្តិរងបារាជិកក្តី ដែលលោកត្រូវហើយ ។ ភិក្ខុនោះនិយាយយ៉ាងនេះថា ម្នាលអាវុសោ ខ្ញុំជាមនុស្សឆ្កួត មានចិត្តវិបល្លាស ប្រែប្រួល កាលដែលខ្ញុំឆ្កួត មានចិត្តវិបល្លាសប្រែប្រួលនោះ បានប្រព្រឹត្តអនាចារ បានពោល បានព្យាយាមល្មើស នូវកិច្ចដែលមិនមែនជារបស់សមណៈជា

នាហំ តំ សរាមិ មូឡ្ហេន មេ ឯតំ កតន្តិ ។ តស្ស ខោ ឯវំ អានន្ទ ភិក្ខុនោ អមូឡ្ហវិនយោ ទាតព្វោ ។ ឯវំ ខោ អានន្ទ អមូឡ្ហវិនយោ ហោតិ ។ ឯវញ្ច បនិធេកច្ចានំ អធិករណានំ វូបសមោ ហោតិ យទិទំ អមូឡ្ហវិនយេន ។

(៦២) កថញ្ចានន្ទ បដិញ្ញាតករណំ ហោតិ ។ ឥធានន្ទ ភិក្ខុ ចុទិតោ វា អចុទិតោ វា(១) អាបត្តឹ សរតិ វិវរតិ ឧត្តានី(២) ករោតិ ។ តេន អានន្ទ ភិក្ខុនា វុឌ្ឍតរោ ភិក្ខុ(៣) ឧបសង្កមិត្វា ឯកំសំ ចីវរំ កត្វា បាទេ វន្ទិត្វា ឧក្កុដិកំ និសីទិត្វា អញ្ជលឹ បគ្គហេត្វា ឯវមស្ស វចនីយោ អហំ ភន្តេ ឥត្ថន្នាមំ អាបត្តឹ អាបន្នោ តំ បដិទេសេមីតិ ។ សោ ឯវមាហ បស្សសីតិ ។ បស្សាមីតិ(៤) ។ អាយតឹ សំវរំ អាបជ្ជេយ្យាសីតិ ។ សំវរំ អាបជ្ជិស្សាមីតិ ។ ឯវំ ខោ អានន្ទ បដិញ្ញាតករណំ ហោតិ ។ ឯវញ្ច បនិធេកច្ចានំ អធិករណានំ វូបសមោ ហោតិ យទិទំ បដិញ្ញាតករណេន ។

---

១ ឱ. ម. ចោទិតោ វា អចោទិតោ វា ។ ២ ម ឧត្តានិំ ។ ៣ ឱ. វុឌ្ឍតរោ ភិក្ខុ ។ ម. វុឌ្ឍតរេ ភិក្ខូ ។ ៤ ម. អាម បស្សាមីតិ ទិស្សតិ ។

ច្រើន ខ្ញុំលើកមិនឃើញអំពើនោះទេ អំពើនុ៎ះ ខ្ញុំបានធ្វើដោយសេចក្តីភ្លេច ៗ ម្នាលអានន្ទ យ៉ាងនេះឯង សង្ឃគប្បីឲ្យអមូឡ្ហវិន័យដល់ភិក្ខុនោះ ៗ ម្នាលអានន្ទ អមូឡ្ហវិន័យ យ៉ាងនេះឯង ៗ ការរម្ងាប់អធិករណ៍ពួកខ្លះ ក្នុងសាសនានេះ រមែងមានដោយអមូឡ្ហវិន័យ យ៉ាងនេះឯង ៗ

(៦៦) ម្នាលអានន្ទ ចុះបដិញ្ញាតករណៈតើដូចម្តេច ៗ ម្នាលអានន្ទ ភិក្ខុក្នុងសាសនានេះ ត្រូវគេចោទក្តី មិនត្រូវគេចោទក្តី តែងរលឹក តែងបើក តែងធ្វើឲ្យរាក់នូវអាបត្តិ ៗ ម្នាលអានន្ទ ភិក្ខុនោះគួរចូលមករកភិក្ខុចាស់ជាងខ្លួន ហើយធ្វើចីពរឆៀងស្មាម្ខាង ថ្វាយបង្គំបាទ អង្គុយច្រហោងផងអញ្ជលីរួច គួរពោលយ៉ាងនេះថា បពិត្រលោកដ៏ចម្រើន ខ្ញុំត្រូវអាបត្តិឈ្មោះនេះ ខ្ញុំសូមសំដែងនូវអាបត្តិនោះ ៗ ភិក្ខុចាស់នោះ ពោលយ៉ាងនេះថា លោកឃើញឬ ៗ ភិក្ខុខាងជើយថា ខ្ញុំឃើញ ៗ ភិក្ខុចាស់ពោលថា លោកត្រូវសង្រួមតទៅ ៗ ភិក្ខុនឹងឆ្លើយថា ខ្ញុំនឹងសង្រួម ៗ ម្នាលអានន្ទ បដិញ្ញាតករណៈ យ៉ាងនេះឯង ៗ ការរម្ងាប់អធិករណ៍ពួកខ្លះ ក្នុងសាសនានេះ រមែងមានដោយបដិញ្ញាតករណៈ យ៉ាងនេះឯង ៗ

(៦៣) កថញ្ចានន្ទ តស្សបាបិយសិកា ហោតិ ។ ឥធានន្ទ ភិក្ខុ ភិក្ខុំ ឯវរូបាយ គរុកាយ អាបត្តិយា ចោទេន្តិ បារាជិកេន វា បារាជិកសាមន្តេន វា សរតាយស្មា ឯវរូបំ គរុកំ អាបត្តឹ អាបជ្ជិតា បារាជិកំ វា បារាជិកសាមន្តំ វាតិ ។ សោ ឯវមាហ ន ខោ អហំ អាវុសោ សរាមិ ឯវរូបំ គរុកំ អាបត្តឹ អាបជ្ជិតា បារាជិកំ វា បារាជិកសាមន្តំ វាតិ ។ តមេនំ សោ និព្វេឋេន្តំ អតិវេឋេតិ ឥង្ឃាយស្មា សាធុកមេវ ជានាហិ យទិ សរសិ ឯវរូបំ គរុកំ អាបត្តឹ អាបជ្ជិតា បារាជិកំ វា បារាជិកសាមន្តំ វាតិ ។ សោ ឯវមាហ ន ខោ អហំ អាវុសោ សរាមិ ឯវរូបំ គរុកំ អាបត្តឹ អាបជ្ជិតា បារាជិកំ វា បារាជិកសាមន្តំ វា សរាមិ ច[១] ខោ អហំ[២] អាវុសោ ឯវរូបំ អប្បមត្តកំ អាបជ្ជិតាតិ ។ តមេនំ សោ[៣]

---

១ ឱ. បសត្ថោ ន ទិស្សតិ ។ ២ ឱ. អភន្តិ ន ទិស្សតិ ។ ៣ ឱ. ខោ ។

(៦៣) ម្នាលអានន្ទ ចុះតស្សបាបិយសិកាតើដូចម្តេច ។ ម្នាលអានន្ទ ក្នុងសាសនានេះ ភិក្ខុទាំងឡាយ ចោទភិក្ខុដោយគរុកាបត្តិ មានសភាពយ៉ាងនេះ គឺអាបត្តិបារាជិកក្តី អាបត្តិរេងបារាជិកក្តីថា លោកដ៏មានអាយុ ចូររលឹកនូវគរុកាបត្តិមានសភាពយ៉ាងនេះ គឺអាបត្តិបារាជិកក្តី អាបត្តិរេងបារាជិកក្តី ដែលលោកត្រូវហើយ ។ ភិក្ខុនោះនិយាយយ៉ាងនេះថា ម្នាលអាវុសោ ខ្ញុំរលឹកនូវគរុកាបត្តិមានសភាពយ៉ាងនេះ គឺអាបត្តិបារាជិកក្តី អាបត្តិរេងបារាជិកក្តី ដែលខ្ញុំត្រូវហើយ មិនឃើញទេ ។ ភិក្ខុនោះញ៉ាំងភិក្ខុនេះ ដែលកំពុងបណ្តោះបណ្តែ មិនឲ្យបណ្តោះបណ្តែ បានថា ម្នាលលោកដ៏មានអាយុ ណ្ហើយ លោកចូរទទួលដឹងដោយស្រួលចុះ បើលោករលឹកនូវគរុកាបត្តិមានសភាពយ៉ាងនេះ គឺអាបត្តិបារាជិកក្តី អាបត្តិរេងបារាជិកក្តី ដែលលោកត្រូវហើយបាន ។ ភិក្ខុនោះនិយាយយ៉ាងនេះថា ម្នាលអាវុសោ ខ្ញុំរលឹកនូវគរុកាបត្តិមានសភាពយ៉ាងនេះ គឺអាបត្តិបារាជិកក្តី អាបត្តិរេងបារាជិកក្តី ដែលខ្ញុំត្រូវហើយ មិនឃើញទេ ម្នាលអាវុសោ តែខ្ញុំរលឹកឃើញខ្លះ នូវអាបត្តិតិចតួច មានសភាពយ៉ាងនេះ ដែលខ្ញុំត្រូវហើយ ។ ភិក្ខុនោះញ៉ាំងភិក្ខុនេះ

និព្វេឋេន្តំ អតិវេឋេតិ ឥង្ឃាយស្មា សាធុកមេវ ជានាហិ យទិ សរសិ ឯវរូបំ គរុកំ អាបត្តឹ អាបជ្ជិតា បារាជិកំ វា បារាជិកសាមន្តំ វាតិ ។ សោ ឯវមាហ ឥមំ ហិ នាមាហំ អាវុសោ អប្បមត្តិកំ អាបត្តឹ អាបជ្ជិត្វា[១] អបុដ្ឋោ បដិជានិស្សាមិ កិម្បនាហំ ឯវរូបំ គរុកំ អាបត្តឹ អាបជ្ជិត្វា បារាជិកំ វា បារាជិកសាមន្តំ វា បុដ្ឋោ ន បដិជានិស្សាមីតិ ។ សោ ឯវមាហ ឥមញ្ច[២] នាម ត្វំ អាវុសោ អប្បមត្តិកំ អាបត្តឹ អាបជ្ជិត្វា អបុដ្ឋោ ន បដិជានិស្សសិ កឹ បន ត្វំ ឯវរូបំ គរុកំ អាបត្តឹ អាបជ្ជិត្វា បារាជិកំ វា បារាជិកសាមន្តំ វា អបុដ្ឋោ បដិជានិស្សសិ ឥង្ឃាយស្មា សាធុកមេវ ជានាហិ យទិ សរសិ ឯវរូបំ គរុកំ អាបត្តឹ អាបជ្ជិតា បារាជិកំ វា បារាជិកសាមន្តំ វាតិ ។ សោ

---

១ ឱ. អាបជ្ជិតា ។ ២ ឱ. ឥមំ ហិ ។ ម. ឥមញ្ហិ ។

ដែលកំពុងបណ្ដោះបណ្ដៃ មិនឲ្យបណ្ដោះបណ្ដៃបានថា ម្នាលលោកមានអាយុ ណ្ហើយ លោកចូរទទួលដឹងដោយស្រួលចុះ បើលោកលើកនូវគរុកាបត្តិមានសភាពយ៉ាងនេះ គឺអាបត្តិបារាជិកក្ដី អាបត្តិរងបារាជិកក្ដី ដែលលោកត្រូវហើយបាន ៗ ភិក្ខុនោះនិយាយយ៉ាងនេះថា ម្នាលអាវុសោ អម្បាលខ្ញុំ ត្រូវអាបត្តិបន្តិចបន្តួចប៉ុណ្ណោះ ដែលលោកមិនសួរសោះ ក៏គង់តែទទួលដឹងបាន ចំណង់បើខ្ញុំត្រូវគរុកាបត្តិមានសភាពយ៉ាងនេះ គឺអាបត្តិបារាជិកក្ដី អាបត្តិរងបារាជិកក្ដី ដែលលោកសួរហើយ នឹងមិនទទួលដឹងដូចម្ដេចបាន ៗ ភិក្ខុអ្នកចោទនោះ និយាយយ៉ាងនេះថា ម្នាលអាវុសោ អម្បាលលោកត្រូវអាបត្តិបន្តិចបន្តួចប៉ុណ្ណោះ ដែលខ្ញុំមិនសួរ ក៏នឹងមិនទទួលដឹង ចំណង់បើលោក ត្រូវគរុកាបត្តិមានសភាពយ៉ាងនេះ គឺអាបត្តិបារាជិកក្ដី អាបត្តិរងបារាជិកក្ដី ដែលខ្ញុំមិនសួរ នឹងទទួលដឹងដូចម្ដេចបាន ម្នាលលោកមានអាយុ ណ្ហើយ លោកចូរទទួលដឹងដោយស្រួលចុះ បើលោកលើកនូវគរុកាបត្តិមានសភាពយ៉ាងនេះ គឺអាបត្តិបារាជិកក្ដី អាបត្តិរងបារាជិកក្ដី ដែលលោកត្រូវហើយបាន ៗ ភិក្ខុនោះ

ឯវមាហ សរាមិ ខោ អហំ អាវុសោ ឯវរូបំ គរុកំ អាបត្តឹ អាបជ្ជិតា បារាជិកំ វា បារាជិកសាមន្តំ វា ទវា មេ ឯតំ វុត្តំ រវា មេ ឯតំ វុត្តំ នាហន្តំ សរាមិ ឯវរូបឹ គរុកំ អាបត្តឹ អាបជ្ជិតា បារាជិកំ វា បារាជិកសាមន្តំ វាតិ ។ ឯវំ ខោ អានន្ទ តស្សបាបិយសិកា ហោតិ ។ ឯវញ្ច បនិធេកច្ចានំ អធិករណានំ វូបសមោ ហោតិ យទិទំ តស្សបាបិយសិកាយ ។

(៦៤) កថញ្ចានន្ទ តិណវត្ថារកោ ហោតិ ។ ឥធានន្ទ ភិក្ខូនំ ភណ្ឌនជាតានំ កលហជាតានំ វិវាទាបន្នានំ វិហរតំ ពហុំ អស្សាមណកំ អជ្ឈាចិណ្ណំ ហោតិ ភាសិតបរិក្កន្តំ តេហានន្ទ ភិក្ខូហិ សព្វេហេវ សមគ្គេហិ សន្និបតិតព្វំ សន្និបតិត្វា ឯកតោបក្ខិកានំ ភិក្ខូនំ ព្យត្តេន[១] ភិក្ខុនា ឧដ្ឋាយាសនា ឯកំសំ ចីវរំ កត្វា អញ្ជលិម្បណាមេត្វា សង្ឃោ ញាបេតព្វោ សុណាតុ មេ ភន្តេ សង្ឃោ ឥទម្ហាកំ[២] ភណ្ឌនជាតានំ

១ ឱ. ម. ព្យត្តតរេន ។ ២ ឱ. ម. តទំ អម្ហាកំ ។

និយាយយ៉ាងនេះថា ម្នាលអាវុសោ ខ្ញុំរលឹកឃើញនូវគរុកាបត្តិមានសភាពយ៉ាងនេះ គឺអាបត្តិបារាជិកក្តី អាបត្តិរងបារាជិកក្តី ដែលខ្ញុំត្រូវហើយ ពាក្យនេះខ្ញុំនិយាយលេងទេ ពាក្យនេះខ្ញុំនិយាយក្លែងទេ ខ្ញុំរលឹកនូវគរុកាបត្តិ មានសភាពយ៉ាងនេះ គឺអាបត្តិបារាជិកក្តី អាបត្តិរងបារាជិកក្តី ដែលខ្ញុំត្រូវហើយ មិនឃើញឡើយ ។ ម្នាលអានន្ទ តស្សបាបិយសិកា យ៉ាងនេះឯង ។ ការរម្ងាប់អធិករណ៍ពួកខ្លះ ក្នុងសាសនានេះ រមែងមាន ដោយតស្សបាបិយសិកា យ៉ាងនេះឯង ។

(៦៤) ម្នាលអានន្ទ ចុះតិណវត្ថារកៈតើដូចម្តេច ។ ម្នាលអានន្ទ ក្នុងសាសនានេះ ភិក្ខុទាំងឡាយនាំគ្នាបង្កហេតុ ឈ្លោះទាស់ទែងគ្នា ហើយបានប្រព្រឹត្តអនាចារ បានពោល បានព្យាយាមល្មើស នូវកិច្ចមិនមែនជារបស់សមណៈជាច្រើន ម្នាលអានន្ទ ភិក្ខុទាំងអស់នោះឯង គប្បីព្រមព្រៀងប្រជុំគ្នា លុះប្រជុំគ្នាហើយ ភិក្ខុ ១ រូប ដែលជាអ្នកឈ្លាសជាងភិក្ខុដែលជាបក្ខពួកជាមួយគ្នា គប្បីក្រោកអំពីអាសនៈ ធ្វើចីវរឆៀងស្មាម្ខាង ប្រណម្យអញ្ជលីផ្តៀងសង្ឃថា បពិត្រព្រះសង្ឃដ៏ចម្រើន សូមសង្ឃស្តាប់ខ្ញុំ យើងខ្ញុំទាំងឡាយក្នុងទីនេះ នាំគ្នាបង្កហេតុ

កលហជាតានំ វិវាទាបន្នានំ វិហរតំ ពហុំ អស្សាម-
ណកំ អជ្ឈាចិណ្ណំ ភាសិតបរិក្កន្តំ យទិ
សង្ឃស្ស បត្តកល្លំ អហំ យា ចេវ ឥមេសំ
អាយស្មន្តានំ អាបត្តិ យា ច អត្តនោ អាបត្តិ
ឥមេសញ្ចេវ អាយស្មន្តានំ អត្ថាយ អត្តនោ ច
អត្ថាយ សង្ឃមជ្ឈេ តិណវត្ថារកេន ទេសេយ្យំ
ឋបេត្វា ថុល្លវជ្ជំ ឋបេត្វា គិហិបដិសំយុត្តន្តិ ។
អថាបរេសំ ឯកតោបក្ខិកានំ ភិក្ខូនំ ព្យត្តេន ភិក្ខុនា
ឧដ្ឋាយាសនា ឯកំសំ ចីវរំ កត្វា អញ្ជលិំ បណា-
មេត្វា សង្ឃោ ញាបេតព្វោ សុណាតុ មេ ភន្តេ
សង្ឃោ អម្ហាកំ ភណ្ឌនជាតានំ កលហជាតានំ
វិវាទាបន្នានំ វិហរតំ ពហុំ អស្សាមណកំ អជ្ឈា-
ចិណ្ណំ ភាសិតបរិក្កន្តំ យទិ សង្ឃស្ស បត្តកល្លំ

ឈ្មោះពាសវទន្តា ហើយបានប្រព្រឹត្តអនាចារ បានពោល បានព្យាយាមល្មើស នូវកិច្ចមិនមែនជារបស់សមណៈជាច្រើន បើកម្មមានកាលដ៏សមគួរដល់សង្ឃហើយ ខ្ញុំសូមសំដែងអាបត្តិរបស់លោកមានអាយុទាំងនេះផង អាបត្តិរបស់ខ្លួនខ្ញុំផង ដោយតិណវត្ថារកៈ ក្នុងកណ្តាលជំនុំសង្ឃ ជំនួសលោកមានអាយុទាំងឡាយនេះផង ដើម្បីខ្លួនខ្ញុំផង វៀរលែងតែអាបត្តិដែលមានទោសធ្ងន់ និងអាបត្តិដែលជាគិហិប្បដិសំយុត្ត ។ លំដាប់នោះ ភិក្ខុ ១ រូប ជាអ្នកឈ្លាសជាងភិក្ខុទាំងឡាយ ដែលជាបក្ខពួកជាមួយគ្នាដទៃទៀត គប្បីក្រោកអំពីអាសនៈ ធ្វើចីវរឆៀងស្មាម្ខាង ប្រណម្យអញ្ជលីផ្ទៀងសង្ឃថា បពិត្រព្រះសង្ឃដ៏ចម្រើន សូមសង្ឃស្តាប់ខ្ញុំ យើងខ្ញុំទាំងឡាយក្នុងទីនេះ នាំគ្នាបង្កហេតុ ឈ្លោះពាសវទន្តា បានប្រព្រឹត្តអនាចារ បានពោល បានព្យាយាមល្មើស នូវកិច្ចមិនមែនជារបស់សមណៈជាច្រើន បើកម្មមានកាលដ៏សមគួរដល់សង្ឃហើយ

អហំ យា ចេវ ឥមេសំ អាយស្មន្តានំ អាបត្តិ យា ច អត្តនោ អាបត្តិ ឥមេសញ្ចេវ អាយស្មន្តានំ អត្ថាយ អត្តនោ ច អត្ថាយ សង្ឃមជ្ឈេ តិណវត្ថារកេន ទេសេយ្យំ ឋបេត្វា ថុល្លវជ្ជំ ឋបេត្វា គិហិប្បដិសំយុត្តន្តិ ។ ឯវំ ខោ អានន្ទ តិណវត្ថារកោ ហោតិ ។ ឯវញ្ច បនិធេកច្ចានំ អធិករណានំ វូបសមោ ហោតិ យទិទំ តិណវត្ថារកេន ។

(៦៤) ឆយិមេ អានន្ទ ធម្មា សារាណីយា បិយករណា គរុករណា សង្គហាយ អវិវាទាយ សាមគ្គិយា ឯកីភាវាយ សំវត្តន្តិ កតមេ ឆ ឥធានន្ទ ភិក្ខុនោ មេត្តំ កាយកម្មំ បច្ចុបដ្ឋិតំ ហោតិ សព្រហ្មចារីសុ អាវិ ចេវ រហោ ច អយម្បិ ធម្មោ សារាណីយោ បិយករណោ គរុករណោ សង្គហាយ អវិវាទាយ សាមគ្គិយា ឯកីភាវាយ សំ-វត្តតិ បុន ចបរំ អានន្ទ ភិក្ខុនោ មេត្តំ វចីកម្មំ បច្ចុបដ្ឋិតំ ហោតិ ។ បេ ។ ឯកីភាវាយ សំវត្តតិ ។

ខ្ញុំសូមសំដែងអាបត្តិ របស់លោកមានអាយុទាំងឡាយនេះផង អាបត្តិរបស់ខ្ញុំផង ដោយតិណវត្ថារកៈ ក្នុងកណ្តាលជំនុំសង្ឃ ជំនួសលោកមានអាយុទាំងឡាយនេះផង ដើម្បីខ្លួនខ្ញុំផង វៀរលែងតែអាបត្តិដែលមានទោសធ្ងន់ និងអាបត្តិដែលជាគិហិប្បដិសំយុត្ត ។ ម្នាលអានន្ទ តិណវត្ថារកៈ យ៉ាងនេះឯង ។ ការរម្ងាប់អធិករណ៍ពួកខ្លះក្នុងសាសនានេះ រមែងមានដោយតិណវត្ថារកៈ យ៉ាងនេះឯង ។

(៦៤) ម្នាលអានន្ទ ធម៌ ៦ ប្រការនេះ ជាសារាណីយធម៌ (ធម៌នាំឲ្យរលឹករកគ្នា) ជាធម៌ធ្វើសេចក្តីស្រឡាញ់គ្នា ជាធម៌ធ្វើសេចក្តីគោរពគ្នា ប្រព្រឹត្តទៅដើម្បីសេចក្តីសង្គ្រោះគ្នា ដើម្បីមិនទាស់ទែងគ្នា ដើម្បីព្រមព្រៀងគ្នា ដើម្បីសេចក្តីស្ងប់ស្ងាត់ ធម៌ ៦ ប្រការ តើដូចម្តេចខ្លះ ម្នាលអានន្ទ ភិក្ខុក្នុងសាសនានេះ បានតាំងកាយកម្ម ប្រកបដោយមេត្តា ក្នុងពួកសព្រហ្មចារីបុគ្គល ទាំងក្នុងទីចំពោះមុខ ទាំងក្នុងទីកំបាំងមុខ នេះឯង ឈ្មោះថាសារាណីយធម៌ ជាធម៌ធ្វើសេចក្តីស្រឡាញ់គ្នា ជាធម៌ធ្វើសេចក្តីគោរពគ្នា ប្រព្រឹត្តទៅ ដើម្បីសេចក្តីសង្គ្រោះគ្នា ដើម្បីមិនទាស់ទែងគ្នា ដើម្បីព្រមព្រៀងគ្នា ដើម្បីសេចក្តីស្ងប់ស្ងាត់ ១ ។ ម្នាលអានន្ទ មួយទៀត ភិក្ខុបានតាំងវចីកម្ម ប្រកបដោយមេត្តា ។ បេ ។ ប្រព្រឹត្តទៅ ដើម្បីសេចក្តីស្ងប់ស្ងាត់ ១ ។

បុន ចបរំ អានន្ទ ភិក្ខុនោ មេត្តំ មនោកម្មំ
បច្ចុបដ្ឋិតំ ហោតិ សព្រហ្មចារីសុ អាវី ចេវ រហោ
ច អយម្បិ ធម្មោ សារណីយោ បិយករណោ គរុក-
រណោ សង្គហាយ អវិវាទាយ សាមគ្គិយា ឯកីភា-
វាយ សំវត្តតិ ។ បុន ចបរំ អានន្ទ ភិក្ខុ យេ
តេ លាភា ធម្មិកា ធម្មលទ្ធា អន្តមសោ បត្តបរិ-
យាបន្នមត្តម្បិ តថារូបេហិ លាភេហិ អប្បដិវិភត្ត-
ភោគី ហោតិ សីលវន្តេហិ សព្រហ្មចារីហិ សាធារ-
ណភោគី អយម្បិ ធម្មោ សារណីយោ បិយករ-
ណោ គរុករណោ សង្គហាយ អវិវាទាយ សាមគ្គិយា
ឯកីភាវាយ សំវត្តតិ ។ បុន ចបរំ អានន្ទ

ម្នាលអានន្ទ មួយទៀត ភិក្ខុបានតាំងមនោកម្ម ប្រកបដោយមេត្តា ក្នុងពួកសព្រហ្មចារីបុគ្គល ទាំងក្នុងទីចំពោះមុខ ទាំងក្នុងទីកំបាំងមុខ នេះឯង ឈ្មោះជាសារាណីយធម៌ ជាធម៌ធ្វើសេចក្តីស្រឡាញ់គ្នា ជាធម៌ធ្វើសេចក្តីគោរពគ្នា ប្រព្រឹត្តទៅដើម្បីសេចក្តីសង្គ្រោះគ្នា ដើម្បីមិនទាស់ទែងគ្នា ដើម្បីព្រមព្រៀងគ្នា ដើម្បីសេចក្តីស្ងប់ស្ងាត់ ១ ។ ម្នាលអានន្ទ មួយទៀត លាភទាំងឡាយណា ដែលប្រកបដោយធម៌ បានមក ដោយធម៌ ដោយហោចទៅ សូម្បីត្រឹមតែអាហារបិណ្ឌបាត ភិក្ខុមិនជាអ្នកហួងហែង បរិភោគលាភមានសភាពដូច្នោះឡើយ ជាអ្នកបរិភោគសាធារណ៍ (ជាមួយ) នឹងសព្រហ្មចារីបុគ្គល អ្នកមានសីលទាំងឡាយ នេះឯង ឈ្មោះជាសារាណីយធម៌ ជាធម៌ធ្វើសេចក្តីស្រឡាញ់គ្នា ជាធម៌ធ្វើសេចក្តីគោរពគ្នា ប្រព្រឹត្តទៅដើម្បីសេចក្តីសង្គ្រោះគ្នា ដើម្បីមិនទាស់ទែងគ្នា ដើម្បីព្រមព្រៀងគ្នា ដើម្បីសេចក្តីស្ងប់ស្ងាត់ ១ ។ ម្នាលអានន្ទ មួយទៀត

## ទេវទហវគ្គស្ស សាមគាមសុត្តេ ឆ សារណីយធម្មា

ភិក្ខុ យានិ តានិ សីលានិ អខណ្ឌានិ អច្ឆិទ្ទានិ អសពលានិ អកម្មាសានិ ភុជិស្សានិ វិញ្ញូបសត្ថានិ អបរាមដ្ឋានិ សមាធិសំវត្តនិកានិ តថារូបេសុ សីលេសុ សីលសាមញ្ញគតោ វិហរតិ សព្រហ្មចារីហិ អាវី ចេវ រហោ ច អយម្បិ ធម្មោ សារណីយោ បិយករណោ គរុករណោ សង្គហាយ អវិវាទាយ សាមគ្គិយា ឯកីភាវាយ សំវត្តតិ ។ បុន ចបរំ អានន្ទ ភិក្ខុ យាយំ ទិដ្ឋិ អរិយា និយ្យានិកា និយ្យាតិ តក្ករស្ស សម្មាទុក្ខក្ខយាយ តថារូបាយ ទិដ្ឋិយា ទិដ្ឋិសាមញ្ញគតោ វិហរតិ សព្រហ្មចារីហិ អាវី ចេវ រហោ ច អយម្បិ ធម្មោ សារណីយោ បិយករណោ គរុករណោ សង្គហាយ អវិវាទាយ សាមគ្គិយា

ទេវទហវគ្គ សាមគ្គាមសូត្រ សារាណីយធម៌ ៦ ប្រការ

សីលទាំងឡាយណា ដែលមិនដាច់ មិនធ្លុះ មិនពពាល មិនពព្រុះ ជាសីលដែលអ្នកប្រាជ្ញតែងសរសើរ ជាសីលដែលតណ្ហានិងទិដ្ឋិមិនបានប៉ះពាល់ ជាសីលប្រព្រឹត្តទៅ ដើម្បីសមាធិ ភិក្ខុជាអ្នកមានសីលស្មើគ្នា ក្នុងសីលទាំងឡាយ មានសភាពដូច្នោះ ( ជាមួយ ) និងសព្រហ្មចារីបុគ្គល ទាំងក្នុងទីចំពោះមុខ ទាំងក្នុងទីកំបាំងមុខ នេះឯង ឈ្មោះថា សារាណីយធម៌ ជាធម៌ធ្វើសេចក្ដីស្រឡាញ់គ្នា ជាធម៌ធ្វើសេចក្ដីគោរពគ្នា ប្រព្រឹត្តទៅដើម្បីសេចក្ដីសង្គ្រោះគ្នា ដើម្បីមិនទាស់ទែងគ្នា ដើម្បីព្រមព្រៀងគ្នា ដើម្បីសេចក្ដីស្ងប់ស្ងាត់ ១ ។ ម្នាលអានន្ទ មួយវិញទៀត ទិដ្ឋិណាដ៏ប្រសើរ ជាទិដ្ឋិនាំសត្វចេញចាកវដ្ដៈ តែងដឹកនាំបុគ្គលអ្នកធ្វើតាមនោះឲ្យអស់កងទុក្ខដោយប្រពៃ ភិក្ខុប្រកបដោយសេចក្ដីយល់ឃើញស្មើគ្នា ដោយទិដ្ឋិមានសភាពដូច្នោះ (ជាមួយ) និងសព្រហ្មចារីបុគ្គល ទាំងក្នុងទីចំពោះមុខ ទាំងក្នុងទីកំបាំងមុខ នេះឯង ឈ្មោះថាសារាណីយធម៌ ជាធម៌ធ្វើសេចក្ដីស្រឡាញ់គ្នា ជាធម៌ធ្វើសេចក្ដីគោរពគ្នា ប្រព្រឹត្តទៅដើម្បីសេចក្ដីសង្គ្រោះគ្នា ដើម្បីមិនទាស់ទែងគ្នា ដើម្បីព្រមព្រៀងគ្នា

ឯកីភាវាយ សំវត្តតិ ។ ឥមេ ខោ អានន្ទ ឆ សារាណីយា ធម្មា បិយករណា គរុករណា សង្គហាយ អវិវាទាយ សាមគ្គិយា ឯកីភាវាយ សំវត្តន្តិ ។

(៦៦) ឥមេ ចេ តុម្ហេ អានន្ទ ឆ សារាណីយេ ធម្មេ សមាទាយ សំវត្តេយ្យាថ បស្សថ នោ តុម្ហេ អានន្ទ តំ[១] វចនបថំ អណុំ វា ថូលំ វា យំ តុម្ហេ នាធិវាសេយ្យាថាតិ ។ នោ ហេតំ ភន្តេ ។ តស្មាតិហានន្ទ ឥមេ ឆ សារាណីយេ ធម្មេ សមាទាយ សំវត្តេយ្យាថ[២] តំ វោ ភវិស្សតិ ទីឃរត្តំ ហិតាយ សុខាយាតិ ។ ឥទមវោច ភគវា អត្តមនោ អាយស្មា អានន្ទោ ភគវតោ ភាសិតំ អភិនន្ទីតិ ។

សាមគាមសុត្តំ បឋមំ និដ្ឋិតំ ។

---

១ ឱ. តន្តិ ន ទិស្សតិ ។ ២ ឱ. វត្តេថាតិ ទិស្សតិ ។

ដើម្បីសេចក្តីស្ងប់ស្ងាត់ ១ ។ ម្នាលអានន្ទ សារាណីយធម៌ ៦ ប្រការនេះឯង ជាធម៌ធ្វើសេចក្តីស្រឡាញ់គ្នា ជាធម៌ធ្វើសេចក្តីគោរពគ្នា ប្រព្រឹត្តទៅ ដើម្បីសេចក្តីសង្គ្រោះគ្នា ដើម្បីមិនទាស់ទែងគ្នា ដើម្បីព្រមព្រៀងគ្នា ដើម្បីសេចក្តីស្ងប់ស្ងាត់ ។

(៦៦) ម្នាលអានន្ទ បើអ្នកទាំងឡាយ បានប្រព្រឹត្តសមាទាននូវសារាណីយធម៌ទាំង ៦ ប្រការនេះ ដោយប្រពៃហើយ ម្នាលអានន្ទ តើអ្នកទាំងឡាយ មិនដែលជួបគន្លងពាក្យ ជាពាក្យតូច ឬពាក្យថ្លោស ដែលគួរឲ្យអ្នកទាំងឡាយ អត់សង្កត់មិនបាន ដែរឬទេ ។ បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គទាំងឡាយ មិនដែលជួបពាក្យនុ៎ះទេ ។ ម្នាលអានន្ទ ព្រោះហេតុនោះ អ្នកទាំងឡាយគួរតែប្រព្រឹត្តសមាទាននូវសារាណីយធម៌ទាំង ៦ ប្រការនេះ ដោយប្រពៃចុះ ព្រោះថា ការប្រព្រឹត្តិសមាទាននូវសារាណីយធម៌ របស់អ្នកទាំងឡាយនោះ នឹងមានប្រយោជន៍ មានសេចក្តីសុខ អស់កាលជាអង្វែង ។ លុះព្រះមានព្រះភាគ សំដែងព្រះសូត្រនេះចប់ហើយ ព្រះអានន្ទមានអាយុ ក៏មានចិត្តត្រេកអរ រីករាយហើយ ចំពោះភាសិតរបស់ព្រះមានព្រះភាគ ។

ចប់ សាមគ្គាមសូត្រ ទី ៤ ។

## បញ្ចមំ សុនក្ខត្តសុត្តំ

(៦៧) ឯវំ មេ សុតំ ។ ឯកំ សមយំ ភគវា វេសា-
លិយំ វិហរតិ មហាវនេ កូដាគារសាលាយំ ។ តេន
ខោ បន សមយេន សម្ពហុលេហិ ភិក្ខូហិ ភគវតោ
សន្តិកេ អញ្ញា ព្យាកតា ហោតិ ខីណា ជាតិ
វុសិតំ ព្រហ្មចរិយំ កតំ ករណីយំ នាបរំ ឥត្ថត្តា-
យាតិ បជានាមាតិ ។

(៦៨) អស្សោសិ ខោ សុនក្ខត្តោ លិច្ឆវិបុត្តោ
សម្ពហុលេហិ កិរ ភិក្ខូហិ ភគវតោ សន្តិកេ អញ្ញា
ព្យាកតា ហោតិ ខីណា ជាតិ វុសិតំ ព្រហ្មចរិយំ
កតំ ករណីយំ នាបរំ ឥត្ថត្តាយាតិ បជានាមាតិ ។
អថខោ សុនក្ខត្តោ លិច្ឆវិបុត្តោ យេន ភគវា
តេនុបសង្កមិ ឧបសង្កមិត្វា ភគវន្តំ អភិវាទេត្វា

# សុនក្ខត្តសូត្រ ទី ៥

(៦៧) ខ្ញុំបានស្តាប់មក យ៉ាងនេះ ។ សម័យមួយ ព្រះមានព្រះភាគ ស្តេចគង់នៅក្នុងកូដាគារសាលា នាមហាវ័ន ជិតក្រុងវេសាលី ។ សម័យនោះឯង មានភិក្ខុច្រើនរូប ប្រកាសអរហត្តផលក្នុងសំណាក់ព្រះមានព្រះភាគថា ខ្ញុំព្រះអង្គទាំងឡាយដឹងច្បាស់ថា ជាតិអស់ហើយ ព្រហ្មចរិយធម៌ ខ្ញុំព្រះអង្គទាំងឡាយនៅចប់ហើយ កិច្ចដែលគួរធ្វើ ក៏ពួកខ្ញុំព្រះអង្គបានធ្វើស្រេចហើយ កិច្ចដទៃក្រៅពីនេះ មិនមានទៀតឡើយ ។

(៦៨) សុនក្ខត្តលិច្ឆវិបុត្រ បានឮថា មានភិក្ខុច្រើនរូបបានប្រកាសព្រះអរហត្តផល ក្នុងសំណាក់ព្រះមានព្រះភាគថា ខ្ញុំព្រះអង្គទាំងឡាយដឹងច្បាស់ថា ជាតិអស់ហើយ ព្រហ្មចរិយធម៌ ខ្ញុំព្រះអង្គទាំងឡាយនៅចប់ហើយ កិច្ចដែលគួរធ្វើ ក៏ពួកខ្ញុំព្រះអង្គបានធ្វើស្រេចហើយ កិច្ចដទៃក្រៅពីនេះ មិនមានទៀតឡើយ ។ ទើបសុនក្ខត្តលិច្ឆវិបុត្រ ចូលទៅគាល់ព្រះមានព្រះភាគ លុះចូលទៅដល់ហើយ ក៏ថ្វាយបង្គំព្រះមានព្រះភាគ

ឯកមន្តំ និសីទិ ។ ឯកមន្តំ និសិន្នោ ខោ សុនក្ខត្តោ លិច្ឆវិបុត្តោ ភគវន្តំ ឯតទវោច សុតំ មេតំ ភន្តេ សម្ពហុលេហិ កិរ ភិក្ខូហិ ភគវតោ សន្តិកេ អញ្ញា ព្យាកតា ខីណា ជាតិ វុសិតំ ព្រហ្មចរិយំ កតំ ករណីយ នាបរំ ឥត្ថត្តាយាតិ បជានាមាតិ យេ តេ[១] ភិក្ខូ ភគវតោ សន្តិកេ អញ្ញំ ព្យាកំសុ[២] ខីណា ជាតិ វុសិតំ ព្រហ្មចរិយំ កតំ ករណីយំ នាបរំ ឥត្ថត្តាយាតិ បជានាមាតិ កច្ចិ តេ ភន្តេ ភិក្ខូ សម្មទេវ អញ្ញំ ព្យាកំសុ ឧទាហុ សន្តេត្ថេកច្ចេ ភិក្ខូ អធិមានេន អញ្ញំ ព្យាកំសូតិ ។

១ ឱ. ម. ឯត្តទេ ភន្តេតិ ទិស្សតិ ។ ២ ព្យាករឹសូតិបិ ។

ប្រែអង្គុយក្នុងទីសមគួរ ។ លុះសុនក្ខត្តលិច្ឆវីបុត្រ អង្គុយក្នុងទីសមគួរហើយ បានក្រាបបង្គំទូលនឹងព្រះមានព្រះភាគយ៉ាងនេះថា បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គបានឮដូច្នេះថា មានភិក្ខុច្រើនរូប ប្រកាសព្រះអរហត្តផល ក្នុងសំណាក់ព្រះមានព្រះភាគថា ខ្ញុំព្រះអង្គទាំងឡាយដឹងច្បាស់ថា ជាតិអស់ហើយ ព្រហ្មចរិយធម៌ ខ្ញុំព្រះអង្គទាំងឡាយនៅចប់ហើយ កិច្ចដែលគួរធ្វើ ក៏ពួកខ្ញុំព្រះអង្គបានធ្វើស្រេចហើយ កិច្ចដទៃក្រៅពីនេះមិនមានទៀតឡើយ ភិក្ខុទាំងឡាយណា បានប្រកាសព្រះអរហត្តផល ក្នុងសំណាក់ព្រះមានព្រះភាគថា ខ្ញុំព្រះអង្គទាំងឡាយដឹងច្បាស់ថា ជាតិអស់ហើយ ព្រហ្មចរិយធម៌ ខ្ញុំព្រះអង្គទាំងឡាយនៅចប់ហើយ កិច្ចដែលគួរធ្វើ ក៏ពួកខ្ញុំព្រះអង្គបានធ្វើស្រេចហើយ កិច្ចដទៃក្រៅពីនេះ មិនមានទៀតឡើយ បពិត្រព្រះអង្គដ៏ចម្រើន ភិក្ខុទាំងនោះ បានប្រកាសព្រះអរហត្តផល ដោយប្រពៃមែនពិត ឬថា មានភិក្ខុពួកខ្លះ ក្នុងទីនេះ បានប្រកាសព្រះអរហត្តផល ដោយការស្មានដែរ ។

(៦៩) យេ តេ សុនក្ខត្ត ភិក្ខូ មម សន្តិកេ អញ្ញំ ព្យាកំសុ ខីណា ជាតិ វុសិតំ ព្រហ្មចរិយំ កតំ ករណីយំ នាបរំ ឥត្ថត្តាយាតិ បជានាមាតិ សន្តេត្ថេកច្ចេ ភិក្ខូ សម្មទេវ អញ្ញំ ព្យាកំសុ សន្តិ បនិធេកច្ចេ ភិក្ខូ អធិមានេនបិ អញ្ញំ ព្យាកំសុ ។ តត្រ សុនក្ខត្ត យេ តេ ភិក្ខូ សម្មទេវ អញ្ញំ ព្យាកំសុ តេសន្តំ តថេវ ហោតិ ។ យេ បន តេ ភិក្ខូ អធិមានេន អញ្ញំ ព្យាកំសុ តត្រ សុនក្ខត្ត តថាគតស្ស ឯវំ ហោតិ ធម្មំ នេសំ ទេសេស្សន្តិ[១] ។ ឯវញ្ចេត្ថ សុនក្ខត្ត តថាគតស្ស ហោតិ ធម្មំ នេសំ ទេសេស្សន្តិ[២] ។ អថ ច បនិធេកច្ចេ មោឃបុរិសា បញ្ហំ អភិសង្ខរិត្វា អភិសង្ខរិត្វា តថាគតំ ឧបសង្កមិត្វា បុច្ឆន្តិ តត្រ សុនក្ខត្ត យម្បិ តថាគតស្ស ឯវំ ហោតិ ធម្មំ នេសំ ទេសេស្សន្តិ តស្សបិ ហោតិ អញ្ញថត្តន្តិ ។

១-២ ឱ. ម. ទេសេយ្យន្តិ ទិស្សតិ ។

(៦៩) ម្នាលសុនក្ខត្ត ពួកភិក្ខុ ដែលប្រកាសអរហត្តផល ក្នុងសំណាក់តថាគតថា ខ្ញុំព្រះអង្គទាំងឡាយដឹងច្បាស់ថា ជាតិអស់ហើយ ព្រហ្មចរិយធម៌ ខ្ញុំព្រះអង្គទាំងឡាយនៅចប់ហើយ កិច្ចដែលគួរធ្វើ ក៏ពួកខ្ញុំព្រះអង្គបានធ្វើស្រេចហើយ កិច្ចដទៃក្រៅពីនេះមិនមានទៀតទេ នោះ ភិក្ខុខ្លះក្នុងទីនុ៎ះ ប្រកាសអរហត្តផល ដោយប្រពៃមែនក៏មាន ភិក្ខុពួកខ្លះក្នុងទីនុ៎ះ ប្រកាសអរហត្តផលដោយការស្មានក៏មាន ។ ម្នាលសុនក្ខត្ត បណ្ដាភិក្ខុអម្បាលនោះ ភិក្ខុពួកណា ប្រកាសអរហត្តផលដោយប្រពៃ ការប្រកាសនោះរបស់ភិក្ខុពួកនោះ លើកទុកមួយអន្លើចុះ ។ តែចំណែកខាងភិក្ខុពួកណា ប្រកាសអរហត្តផលដោយការស្មាន ម្នាលសុនក្ខត្ត ក្នុងរឿងនេះ តថាគត មានសេចក្ដីត្រិះរិះយ៉ាងនេះថា តថាគតនឹងសំដែងធម៌ ដល់ភិក្ខុពួកនោះ ។ ម្នាលសុនក្ខត្ត តថាគតមានសេចក្ដីត្រិះរិះក្នុងហេតុនុ៎ះយ៉ាងនេះថា តថាគតនឹងសំដែងធម៌ដល់ភិក្ខុពួកនោះ ដោយឧបាយដូចតទៅនេះ ។ កាលបើភិក្ខុពួកខ្លះ ជាមោឃបុរសក្នុងទីនេះ គាត់តែងសម្រឹតសម្រាំងនូវបញ្ហា ចូលមកសួរតថាគត ម្នាលសុនក្ខត្ត ក្នុងរឿងនោះ តថាគតមានសេចក្ដីត្រិះរិះយ៉ាងនេះថា តថាគតនឹងសំដែងធម៌ដល់ភិក្ខុទាំងនោះ ដោយប្រការដទៃ (អំពីបញ្ហារបស់ភិក្ខុទាំងនោះ) ។

ឯតស្ស ភគវា កាលោ ឯតស្ស សុគត កាលោ យំ ភគវា ធម្មំ ទេសេយ្យ ភគវតោ សុត្វា ភិក្ខូ ធារេស្សន្តីតិ ។ តេនហិ សុនក្ខត្ត សុណាហិ(១) សាធុកំ មនសិករោហិ ភាសិស្សាមីតិ ។ ឯវំ ភន្តេតិ ខោ សុនក្ខត្តោ លិច្ឆវិបុត្តោ ភគវតោ បច្ចស្សោសិ ។

(៧០) ភគវា ឯតទវោច បញ្ច ខោ ឥមេ សុនក្ខត្ត កាមគុណា កតមេ បញ្ច ចក្ខុវិញ្ញេយ្យា រូបា ឥដ្ឋា កន្តា មនាបា បិយរូបា កាមូបសំហិតា រជនីយា សោតវិញ្ញេយ្យា សទ្ទា ... ឃានវិញ្ញេយ្យា គន្ធា ... ជិវ្ហាវិញ្ញេយ្យា រសា ... កាយវិញ្ញេយ្យា ផោដ្ឋព្វា ឥដ្ឋា កន្តា មនាបា បិយរូបា កាមូបសំហិតា រជនីយា ឥមេ ខោ សុនក្ខត្ត បញ្ច កាមគុណា ។

១ ឱ. សុណោហិ ។

សុនក្ខត្តលិច្ឆវិបុត្រ ក្រាបបង្គំទូលថា បពិត្រព្រះមានព្រះភាគ កាលនេះ ជាកាលដែលព្រះមានព្រះភាគ គួរសំដែងធម៌ហើយ បពិត្រព្រះសុគត កាលនេះ ជាកាលដែលព្រះមានព្រះភាគ គួរសំដែងធម៌ហើយ ពួកភិក្ខុបានស្តាប់ព្រះមានព្រះភាគហើយ នឹងចងចាំទុក ។ ម្នាលសុនក្ខត្ត បើដូច្នោះ អ្នកចូរប្រុងស្តាប់ ចូរធ្វើទុកក្នុងចិត្តដោយប្រពៃចុះ តថាគតនឹងសំដែង ។ សុនក្ខត្តលិច្ឆវិបុត្រ ទទួលព្រះពុទ្ធដីកា របស់ព្រះមានព្រះភាគថា ព្រះករុណា ព្រះអង្គ ។

(៣០) ព្រះមានព្រះភាគ ទ្រង់ត្រាស់ដូច្នេះថា ម្នាលសុនក្ខត្ត កាមគុណនេះ មាន ៥ ប្រការ កាមគុណ ៥ ប្រការ តើដូចម្តេចខ្លះ កាមគុណ ៥ ប្រការនោះ គឺ រូប ដែលគួរដឹងច្បាស់ដោយចក្ខុ ជាទីប្រាថ្នា ជាទីត្រេកអរ ជាទីគាប់ចិត្ត មានសភាពគួរស្រឡាញ់ ប្រកបដោយកាម គួរជាទីរេករាយ ១ សំឡេង ដែលគប្បីដឹងច្បាស់ ដោយសោត ... ១ ក្លិន ដែលគប្បីដឹងច្បាស់ ដោយឃានៈ ... ១ រស ដែលគប្បីដឹងច្បាស់ ដោយជិវ្ហា ... ១ ផោដ្ឋព្វៈ ដែលគប្បីដឹងច្បាស់ ដោយកាយ ជាទីប្រាថ្នា ជាទីត្រេកអរ ជាទីគាប់ចិត្ត មានសភាពគួរស្រឡាញ់ ប្រកបដោយកាម គួរជាទីរេករាយ ១ ម្នាលសុនក្ខត្ត នេះឯង កាមគុណ ៥ ប្រការ ។

(៧១) ឋានំ ខោ បនេតំ សុនក្ខត្ត វិជ្ជតិ យំ ឥធេកច្ចោ បុរិសបុគ្គលោ លោកាមិសាធិមុត្តោ អស្ស ។ លោកាមិសាធិមុត្តស្ស ខោ សុនក្ខត្ត បុរិសបុគ្គលស្ស តប្បដិរូបី ចេវ កថា សណ្ឋាតិ តទនុធម្មញ្ច អនុវិតក្កេតិ អនុវិចារេតិ តញ្ច បុរិសំ ភជតិ តេន ច ចិត្តឹ(១) អាបជ្ជតិ អានេញ្ជប្បដិសំយុត្តាយ(២) ច បន កថាយ កច្ឆមានាយ ន សុស្សូសតិ(៣) ន ច(៤) សោតំ ឱទហតិ ន អញ្ញា ចិត្តំ ឧបដ្ឋបេតិ ន ច តំ បុរិសំ ភជតិ ន ច តេន ចិត្តឹ អាបជ្ជតិ ។ សេយ្យថាបិ សុនក្ខត្ត បុរិសោ សកម្ហា គាមា វា និគមា វា ចិរប្បវុត្ថោ អស្ស ។ សោ អញ្ញតរំ បុរិសំ បស្សេយ្យ តម្ហា គាមា វា និគមា វា អចិរប្បក្កន្តំ ។ សោ តំ បុរិសំ តស្ស គាមស្ស វា ខេមត្តញ្ច សុភិក្ខត្តញ្ច អប្បាពាធត្តញ្ច បុច្ឆេយ្យ ។

---

១ ឱ. ម. វិតិ ។ ២ អាណញ្ជបដិសំយុត្តាយាតប្បត្តិ ។ ៣ ឱ. សុស្សូសតិ ។ ៤ ឱ. ម. ចសទ្ទោ នត្ថិ ។

(៧១) ម្នាលសុនក្ខត្ត មួយទៀត ហេតុដែលនាំឲ្យបុរសបុគ្គលពួកខ្លះ ក្នុងលោកនេះ មានអធ្យាស្រ័យទន់ទៅរកលោកាមិសៈ រមែងមាន ។ ម្នាលសុនក្ខត្ត ពាក្យសំដីរបស់បុរសបុគ្គលដែលមានអធ្យាស្រ័យទន់ទៅរកលោកាមិសៈ តែងនិយាយឡើង រមែងប្រមៀលទៅរកកាមគុណផង បុរសបុគ្គលនោះតែងត្រិះរិះរឿយ ៗ ពិចារណារឿយ ៗ នូវហេតុដែលប្រព្រឹត្តទៅតាមកាមគុណនោះផង តែងគប់រកនូវបុរសបែបនោះផង តែងដល់នូវសេចក្ដីគោរព ទៅរកបុរសបែបនោះផង ចំណែកខាងពាក្យសំដីដែលគេនិយាយប្រកបដោយអានេញ្ជសមាបត្តិ បុរសបុគ្គលនោះ មិនចង់ស្ដាប់ផង មិនផ្ទៀងត្រចៀកផង មិនតាំងចិត្តដើម្បីដឹងផង មិនគប់រកនូវបុរសបែបនោះផង មិនដល់នូវសេចក្ដីគោរព ទៅរកបុរសបែបនោះផង ។ ម្នាលសុនក្ខត្ត ដូចជាបុរសចេញអំពីស្រុក ឬនិគមរបស់ខ្លួន ដែលជាទីធ្លាប់នៅយូរហើយ ៗ បុរសនោះ កាលបើឃើញបុរសណាមួយ ដែលទើបនឹងចេញអំពីស្រុកឬនិគមនោះ ៗ បុរសនោះ គប្បីសួរនូវភាពនៃស្រុកឬនិគមនោះ ដែលជាដែនមានសេចក្ដីក្សេមក្សាន្តផង ជាដែនមានភិក្ខាហារដ៏សម្បូណ៌ផង ជាដែនមិនមានអាពាធផង ចំពោះបុរសនោះ ៗ

តស្ស សោ បុរិសោ តស្ស គាមស្ស វា និគមស្ស វា ខេមត្តញ្ច សុភិក្ខត្តញ្ច អប្បាពាធត្តញ្ច សំសេយ្យ ។ តំ កឹ មញ្ញសិ សុនក្ខត្ត អបិ នុ សោ បុរិសោ តស្ស បុរិសស្ស សុស្សូសេយ្យ សោតំ ឱទហេយ្យ អញ្ញា ចិត្តំ ឧបដ្ឋបេយ្យ តញ្ច បុរិសំ ភជេយ្យ តេន ច វិត្តឹ អាបជ្ជេយ្យាតិ ។ ឯវំ ភន្តេ ។ ឯវមេវ ខោ សុនក្ខត្ត ឋានមេតំ វិជ្ជតិ យំ ឥធេកច្ចោ បុរិសបុគ្គលោ លោកាមិសាធិមុត្តោ អស្ស ។ លោកាមិសាធិមុត្តស្ស ខោ សុនក្ខត្ត បុរិសបុគ្គលស្ស តប្បតិរូបី ចេវ កថា សណ្ឋាតិ តទនុធម្មញ្ច អនុវិតក្កេតិ អនុវិចារេតិ តញ្ច បុរិសំ ភជតិ តេន ច វិត្តឹ អាបជ្ជតិ អានេញ្ជប្បដិសំយុត្តាយ ច បន កថាយ កច្ឆមានាយ ន សុស្សូសតិ ន សោតំ ឱទហតិ ន អញ្ញា ចិត្តំ ឧបដ្ឋបេតិ

បុរសនោះ គប្បីនិយាយប្រាប់នូវភាពនៃស្រុកឬនិគមនោះ ដែលជាដែនមានសេចក្តីក្សេមក្សាន្តផង ជាដែនមានភិក្ខាហារដ៏សម្បូណ៌ផង ជាដែនមិនមានអាពាធផង ដល់បុរសនោះ ។ ម្នាលសុនក្ខត្ត អ្នកសំគាល់សេចក្តីនោះដូចម្តេច តើបុរសនោះ គប្បីស្តាប់ពាក្យសំដីរបស់បុរសនោះ ផ្ទង់ត្រចៀកស្តាប់ តាំងចិត្តដើម្បីដឹង គប់រកនូវបុរសនោះផង ដល់នូវសេចក្តីគោរពទៅរកបុរសនោះផង ដែរឬ ។ សុនក្ខត្តលិច្ឆវីបុត្រ ក្រាបបង្គំទូលថា ព្រះករុណា ព្រះអង្គ ។ ព្រះអង្គត្រាស់ថា ម្នាលសុនក្ខត្ត ហេតុដែលនាំឲ្យបុរសបុគ្គលពួកខ្លះ ក្នុងលោកនេះ មានអធ្យាស្រ័យទន់ទៅក្នុងលោកាមិស: រមែងមាន ក៏មានឧបមេយ្យយ៉ាងនោះឯង ។ ម្នាលសុនក្ខត្ត បុរសបុគ្គល ដែលមានអធ្យាស្រ័យទន់ទៅក្នុងលោកា-មិស: តែងនិយាយឡើង រមែងប្រមៀលទៅរកកាមគុណផង បុរសបុគ្គលនោះ តែងត្រិះរិះរឿយ ៗ ពិចារណារឿយ ៗ នូវហេតុដែលប្រព្រឹត្តទៅតាមកាមគុណនោះផង តែងគប់រក នូវបុរសបែបនោះផង តែងដល់នូវសេចក្តីគោរព ទៅរកបុរសបែបនោះផង ឯពាក្យសំដីដែលគេនិយាយ ប្រកបដោយអានេញ្ជសមាបត្តិ បុរសបុគ្គលនោះ មិនចង់ស្តាប់ផង មិនផ្ទង់ត្រចៀកផង មិនតាំងចិត្ត ដើម្បីដឹងផង

ន ច តំ(១) បុរិសំ ភជតិ ន ច តេន វិត្តឹ អាបជ្ជតិ ។ សោ ឯវមស្ស វេទិតព្វោ លោកាមិសាធិមុត្តោ បុរិសបុគ្គលោតិ ។

(៧២) ឋានំ ខោ បនេតំ សុនក្ខត្ត វិជ្ជតិ យំ ឥធេកច្ចោ បុរិសបុគ្គលោ អានេញ្ជាធិមុត្តោ អស្ស ។ អានេញ្ជាធិមុត្តស្ស ខោ សុនក្ខត្ត បុរិសបុគ្គលស្ស តប្បដិរូបី ចេវ កថា សណ្ឋាតិ តទនុធម្មញ្ច អនុវិតក្កេតិ អនុវិចារេតិ តញ្ច បុរិសំ ភជតិ តេន ច វិត្តឹ អាបជ្ជតិ លោកាមិសប្បដិសំយុត្តាយ ច បន កថាយ កច្ឆមានាយ ន សុស្សូសតិ ន សោតំ ឱទហតិ ន អញ្ញា ចិត្តំ ឧបដ្ឋបេតិ ន ច តំ បុរិសំ ភជតិ ន ច តេន វិត្តឹ អាបជ្ជតិ ។ សេយ្យថាបិ សុនក្ខត្ត បណ្ឌុបលាសោ ពន្ធនា បមុត្តោ អភព្វោ ហរិតត្តាយ

១ ឱ. បេតំ ។

មិនគប់រកនូវបុរសបែបនោះផង មិនដល់នូវសេចក្តីគោរព ទៅរកបុរសបែបនោះផង ។ បុរសបុគ្គលនោះ បណ្ឌិតគប្បីដឹងថា ជាអ្នកមានអធ្យាស្រ័យខុនទៅក្នុងលោកាមិសៈ ដោយប្រការដូច្នេះ ។

(៧៤) ម្នាលសុនក្ខត្ត មួយទៀត ហេតុដែលនាំឲ្យបុរសបុគ្គលពួកខ្លះ ក្នុងលោកនេះ មានអធ្យាស្រ័យខុនទៅរកអានេញ្ជសមាបត្តិរមែងមាន ។ ម្នាលសុនក្ខត្ត ពាក្យសំដីបុរសបុគ្គលដែលមានអធ្យាស្រ័យខុនទៅរកអានេញ្ជសមាបត្តិ តែងនិយាយឡើង រមែងប្រមៀលទៅរកអានេញ្ជសមាបត្តិនោះ បុរសបុគ្គលនោះរមែងត្រិះរិះរឿយៗ ពិចារណារឿយៗនូវហេតុដែលប្រព្រឹត្តទៅតាមអានេញ្ជសមាបត្តិនោះផង តែងគប់រកនូវបុរសនោះផង តែងដល់នូវសេចក្តីគោរពទៅរកបុរសបែបនោះផង ចំណែកខាងពាក្យសំដីដែលគេនិយាយ ប្រកបដោយលោកាមិសៈ បុរសបុគ្គលនោះ មិនចង់ស្តាប់ផង មិនផ្ចង់ត្រចៀកផង មិនតាំងចិត្តដើម្បីដឹងផង មិនគប់រកនូវបុរសបែបនោះផង មិនដល់នូវសេចក្តីគោរពទៅរកបុរសបែបនោះផង ។ ម្នាលសុនក្ខត្ត ស្លឹកឈើទុំ មានពណ៌លឿង ជ្រុះចេញចាកទងហើយ មិនគួរដើម្បីនៅខៀវខ្ចីទៀតបានឡើយ

ឯវមេវ ខោ សុនក្ខត្ត អានេញ្ជាធិមុត្តស្ស បុរិសបុគ្គលស្ស យេ លោកាមិសសញ្ញោជនេ សេ វន្តេ ។ សោ ឯវមស្ស វេទិតព្វោ លោកាមិសសញ្ញោជនេន ហិ ខោ វិសំយុត្តោ អានេញ្ជាធិមុត្តោ បុរិសបុគ្គលោតិ ។

(៧.៣) ឋានំ ខោ បនេតំ សុនក្ខត្ត វិជ្ជតិ យំ ឥធេកច្ចោ បុរិសបុគ្គលោ អាកិញ្ចញ្ញាយតនាធិមុត្តោ អស្ស ។ អាកិញ្ចញ្ញាយតនាធិមុត្តស្ស ខោ សុនក្ខត្ត បុរិសបុគ្គលស្ស តប្បដិរូបី ចេវ កថា សណ្ឋាតិ តទនុធម្មញ្ច អនុវិតក្កេតិ អនុវិចារេតិ តញ្ច បុរិសំ ភជតិ តេន ច វិត្តឹ អាបជ្ជតិ អានេញ្ជបដិសំយុត្តាយ ច បន កថាយ កច្ឆមានាយ ច សុស្សូសតិ ន សោតំ ឱទហតិ ន អញ្ញា ចិត្តំ ឧបដ្ឋបេតិ ន ច តំ បុរិសំ ភជតិ ន ច តេន វិត្តឹ អាបជ្ជតិ ។

យ៉ាងណាមិញ ម្នាលសុនក្ខត្ត បុរសបុគ្គលដែលមានអធ្យាស្រ័យឱនទៅរកអានេញ្ជសមាបត្តិ រមែងជ្រុះចាកការប្រកបក្នុងលោកាមិសៈ ក៏យ៉ាងនោះដែរ ។ បុរសបុគ្គលនោះ បណ្ឌិតគប្បីដឹងថា ជាអ្នកមានអធ្យាស្រ័យឱនទៅរកអានេញ្ជសមាបត្តិ ប្រាសចាកការប្រកបក្នុងលោកាមិសៈហើយ ដោយប្រការដូច្នេះ ។

(៧៣) ម្នាលសុនក្ខត្ត មួយទៀត ហេតុដែលនាំឲ្យបុរសបុគ្គលពួកខ្លះ ក្នុងលោកនេះ មានអធ្យាស្រ័យឱនទៅរកអាកិញ្ចញ្ញាយតន-សមាបត្តិ រមែងមាន ។ ម្នាលសុនក្ខត្ត សំដីរបស់បុរសបុគ្គលដែលមានអធ្យាស្រ័យឱនទៅរកអាកិញ្ចញ្ញាយតនសមាបត្តិ តែងហានិយាយឡើង តែងប្រមៀលទៅរកអាកិញ្ចញ្ញាយតនសមាបត្តិនោះផង បុរសបុគ្គលនោះ តែងត្រិះរិះរឿយ ៗ ពិចារណារឿយ ៗ នូវហេតុដែលប្រព្រឹត្តទៅតាមអាកិញ្ចញ្ញាយតនសមាបត្តិនោះផង តែងគប់រកនូវបុរសបែបនោះផង តែងដល់នូវសេចក្ដីគោរព ទៅរកបុរសបែបនោះផង ចំណែកខាងពាក្យសំដីដែលគេនិយាយ ប្រកបដោយអានេញ្ជសមាបត្តិ បុរសបុគ្គលនោះមិនចង់ស្ដាប់ផង មិនផ្ចង់ត្រចៀកផង មិនតាំងចិត្តដើម្បីដឹងផង មិនគប់រកបុរសបែបនោះផង មិនដល់នូវសេចក្ដីគោរព ទៅរកបុរសបែបនោះផង ។

សេយ្យថាបិ សុនក្ខត្ត បុថុសិលា ទ្វេធា ភិន្នា អប្បដិសន្ធិកា ហោតិ ឯវមេវ ខោ សុនក្ខត្ត អាកិញ្ចញ្ញាយតនាធិមុត្តស្ស បុរិសបុគ្គលស្ស យេ អានេញ្ជសញ្ញោជនេ សេ ភិន្នេ ។ សោ ឯវមស្ស វេទិតព្វោ អានេញ្ជសញ្ញោជនេន ហិ ខោ វិសំយុត្តោ អាកិញ្ចញ្ញាយតនាធិមុត្តោ បុរិសបុគ្គលោតិ ។

[៧៤] ឋានំ ខោ បនេតំ សុនក្ខត្ត វិជ្ជតិ យំ ឥធេកច្ចោ បុរិសបុគ្គលោ នេវសញ្ញានាសញ្ញាយតនាធិមុត្តោ អស្ស ។ នេវសញ្ញានាសញ្ញាយតនាធិមុត្តស្ស ខោ សុនក្ខត្ត បុរិសបុគ្គលស្ស តប្បតិរូបី ចេវ កថា សណ្ឋាតិ តទនុធម្មញ្ច អនុវិតក្កេតិ អនុវិចារេតិ តញ្ច បុរិសំ ភជតិ តេន ច ចិត្តឹ អាបជ្ជតិ អាកិញ្ចញ្ញាយតនប្បដិសំយុត្តាយ ច បន កថាយ កច្ចមានាយ ន សុស្សូសតិ ន សោតំ ឱទហតិ ន អញ្ញា ចិត្តំ ឧបដ្ឋបេតិ

ម្នាលសុនក្ខត្ត ដូចដុំថ្មក្រាស់ បែកចេញជាពីរភាគ មិនជាប់គ្នាវិញបាន យ៉ាងណាមិញ ម្នាលសុនក្ខត្ត បុរសបុគ្គលដែលមានអធ្យាស្រ័យឱនទៅរកអាកិញ្ចញ្ញាយតនសមាបត្តិ រមែងបែកចេញអំពីការប្រកបក្នុងអានេញ្ជសមាបត្តិ ក៏យ៉ាងនោះឯង ៗ បុរសបុគ្គលនោះ បណ្ឌិតគប្បីដឹងថា ជាអ្នកមានអធ្យាស្រ័យឱនទៅរកអាកិញ្ចញ្ញាយតនសមាបត្តិ ប្រាសចាកការប្រកបក្នុងអានេញ្ជសមាបត្តិហើយ ដោយប្រការដូច្នេះ ៗ

(៧៤) ម្នាលសុនក្ខត្ត ហេតុដែលនាំឲ្យបុរសបុគ្គលពួកខ្លះ ក្នុងលោកនេះ មានអធ្យាស្រ័យឱនទៅរកនេវសញ្ញានាសញ្ញាយតនសមាបត្តិ រមែងមាន ៗ ម្នាលសុនក្ខត្ត បុរសបុគ្គលដែលមានអធ្យាស្រ័យឱនទៅរកនេវសញ្ញានាសញ្ញាយតនសមាបត្តិ តែងហាក់និយាយឡើង តែងប្រមៀលទៅរកនេវសញ្ញានាសញ្ញាយតនសមាបត្តិនោះផង បុរសបុគ្គលនោះ តែងត្រិះរិះរឿយ ៗ ពិចារណារឿយ ៗ នូវហេតុដែលប្រព្រឹត្តទៅតាមនេវសញ្ញានាសញ្ញាយតនសមាបត្តិនោះផង តែងគប់រកនូវបុរសបែបនោះផង តែងដល់នូវសេចក្តីគោរពទៅរកបុរសបែបនោះផង ព្រោះបើសំដីដែលគេនិយាយ ប្រកបដោយអាកិញ្ចញ្ញាយតនសមាបត្តិ ក៏បុរសបុគ្គលនោះ មិនចង់ស្តាប់ផង មិនផ្ចង់ត្រចៀកផង មិនតាំងចិត្តដើម្បីដឹងផង

ន ច តំ បុរិសំ ភជតិ ន ច តេន ចិត្តំ អាបជ្ជតិ ។ សេយ្យថាបិ សុនក្ខត្ត បុរិសោ មនុញ្ញភោជនំ ភុត្តាវី ឆឌ្ឌេយ្យ ។ តំ កឹ មញ្ញសិ សុនក្ខត្ត អបិ នុ តស្ស[១] តស្មឹ ភត្តេ សុនក្ខត្ត កម្យតា អស្សាតិ ។ នោ ហេតំ ភន្តេ ។ តំ កិស្ស ហេតុ អទុញ្ហិ[២] ភន្តេ ភត្តំ បដិក្កូលសម្មតន្តិ ។ ឯវមេវ ខោ សុនក្ខត្ត នេវសញ្ញានាសញ្ញាយតនាធិមុត្តស្ស បុរិសបុគ្គលស្ស យេ អាកិញ្ចញ្ញាយតនសញ្ញោជនេ សេ វន្តេ ។ សោ ឯវមស្ស វេទិតព្វោ អាកិញ្ចញ្ញាយតនសញ្ញោជនេន ហិ ខោ វិសំយុត្តោ នេវសញ្ញានាសញ្ញាយតនាធិមុត្តោ បុរិសបុគ្គលោតិ ។

[៧៨] ឋានំ ខោ បនេតំ សុនក្ខត្ត វិជ្ជតិ យំ ឥធេកច្ចោ បុរិសបុគ្គលោ សម្មានិព្វានាធិមុត្តោ អស្ស ។ សម្មានិព្វានាធិមុត្តស្ស ខោ សុនក្ខត្ត បុរិសបុគ្គលស្ស តប្បតិរូបី ចេវ កថា សណ្ឋាតិ

១ ឱ. ម. តស្ស បុរិសស្ស ។ ២ ឱ. អទុំ ហិ ។

មិនគប់រកនូវបុរសបែបនោះផង មិនដល់នូវសេចក្តីគោរពទៅរកបុរសបែបនោះផង ។ ម្នាលសុនក្ខត្ត ប្រៀបដូចបុរសបរិភោគរួចហើយ គប្បីចោលនូវភោជនជាទីគាប់ចិត្ត ។ ម្នាលសុនក្ខត្ត អ្នកសំគាល់សេចក្តីនោះដូចម្តេច ម្នាលសុនក្ខត្ត បុរសនោះ តើគប្បីមានសេចក្តីប្រាថ្នាក្នុងភត្តនោះទៀត ដែរឬទេ ។ បពិត្រព្រះអង្គដ៏ចម្រើន សេចក្តីប្រាថ្នាក្នុងភត្តរបស់បុរសនោះមិនមានទេ ដំណើរនុ៎ះ ព្រោះហេតុអ្វី បពិត្រព្រះអង្គដ៏ចម្រើន ព្រោះភត្តនោះ គេសន្មតថាជារបស់បដិកូល ។ ម្នាលសុនក្ខត្ត បុរសបុគ្គល ដែលមានអធ្យាស្រ័យចុះទៅរកនេវសញ្ញានាសញ្ញាយតនសមាបត្តិ រមែងខ្ជាក់ចោលនូវការប្រកបក្នុងអាកិញ្ចញ្ញាយតនសមាបត្តិនោះ ក៏មានឧបមេយ្យយ៉ាងនេះឯង ។ បុរសបុគ្គលនោះ បណ្ឌិតគប្បីដឹងថា ជាអ្នកមានអធ្យាស្រ័យចុះទៅរកនេវសញ្ញានាសញ្ញាយតនសមាបត្តិ ប្រាសចាកការប្រកបដោយអាកិញ្ចញ្ញាយតនសមាបត្តិហើយ ដោយប្រការដូច្នេះ ។

(៧៤) ម្នាលសុនក្ខត្ត មួយទៀត ហេតុដែលនាំឲ្យបុរសបុគ្គលពួកខ្លះ ក្នុងលោកនេះ មានអធ្យាស្រ័យចុះទៅរកព្រះនិព្វានដោយប្រពៃរមែងមាន ។ ម្នាលសុនក្ខត្ត បុគ្គលដែលមានអធ្យាស្រ័យចុះទៅរកព្រះនិព្វានដោយប្រពៃ តែងនិយាយឡើង តែងប្រមៀលទៅរកព្រះ

តទនុធម្មញ្ច អនុវិតក្កេតិ អនុវិចារេតិ តញ្ច បុរិសំ ភជតិ តេន ច វិត្តឹ អាបជ្ជតិ នេវសញ្ញានាសញ្ញាយតនសំយុត្តាយ ច បន កថាយ កច្ឆមានាយ ន សុស្សូសតិ ន សោតំ ឱទហតិ ន អញ្ញា ចិត្តំ ឧបដ្ឋបេតិ ន ច តំ បុរិសំ ភជតិ ន ច តេន វិត្តឹ អាបជ្ជតិ ។ សេយ្យថាបិ សុនក្ខត្ត តាលោ មត្ថកច្ឆិន្នោ អភព្វោ បុន វិរូឡ្ហិយា ឯវមេវ ខោ សុនក្ខត្ត សម្មានិញ្ជាធិមុត្តស្ស បុរិសបុគ្គលស្ស យេ នេវសញ្ញានាសញ្ញាយតនសញ្ញោជនេ សេ ឧច្ឆិន្នេ ឧច្ឆិន្នមូលេ តាលាវត្ថុកតេ អនភាវង្កតេ[១] អាយតឹ អនុប្បាទធម្មេ ។ សោ ឯវមស្ស វេទិតព្វោ នេវសញ្ញានាសញ្ញាយតនសញ្ញោជនេន ហិ ខោ វិសំយុត្តោ សម្មានិញ្ជាធិមុត្តោ បុរិសបុគ្គលោតិ ។

១ ឱ. អនភាវកតេ ។ ម. អនភាវង្កតេ ។

ទេវទហេតុ សុនក្ខត្តសូត្រ ភាពនៃបុគ្គលមានអធ្យាស្រ័យខុនទៅរកព្រះនិព្វានដោយប្រពៃ

និព្វាននោះផង បុរសបុគ្គលនោះរមែងត្រិះរិះរឿយ ៗ ពិចារណារឿយ ៗ នូវហេតុដែលប្រព្រឹត្តទៅតាមព្រះនិព្វាននោះផង គប់រកនូវបុរសបែបនោះផង តែងដល់នូវសេចក្តីគោរពទៅរកបុរសបែបនោះផង ទោះបីសំដីដែលគេនិយាយប្រកបដោយនេវសញ្ញានាសញ្ញាយតនសមាបត្តិ ក៏បុរសបុគ្គលនោះ មិនចង់ស្តាប់ផង មិនផ្ចង់ត្រចៀកផង មិនតំកល់ចិត្តដើម្បីដឹងផង មិនគប់រកនូវបុរសបែបនោះផង មិនដល់នូវសេចក្តីគោរពទៅរកបុរសបែបនោះផង ៗ ម្នាលសុនក្ខត្ត ដើមត្នោតកំបុតចុង មិនគួរដើម្បីដុះលូតលាស់ឡើងបាន យ៉ាងណាមិញ ម្នាលសុនក្ខត្ត បុរសបុគ្គលដែលមានអធ្យាស្រ័យខុនទៅរកព្រះនិព្វានដោយប្រពៃ រមែងផ្តាច់ផ្តិលនូវការប្រកបក្នុងនេវសញ្ញានាសញ្ញាយតនសមាបត្តិ ឲ្យអស់រលីងដូចជាដើមត្នោត ដែលគេក្រឡែលកាត់រំលើងឲ្យលែងដុះតទៅទៀតហើយ ធ្វើឲ្យលែងមានបែបភាពតទៅទៀតហើយ ឲ្យជាធម៌លែងមានកំណើត តទៅមុខទៀតហើយ ក៏យ៉ាងនោះឯង ៗ បុរសបុគ្គលនោះ បណ្ឌិតគប្បីដឹងថា ជាអ្នកមានអធ្យាស្រ័យខុនទៅរកព្រះនិព្វាន ដោយប្រពៃ ប្រាសចាកការប្រកបក្នុងនេវសញ្ញានាសញ្ញាយតនសមាបត្តិហើយ ដោយប្រការដូច្នេះ ៗ

(៧៦) ឋានំ ខោ បនេតំ សុនក្ខត្ត វិជ្ជតិ យំ ឥធេកច្ចស្ស ភិក្ខុនោ ឯវមស្ស តណ្ហា ខោ សល្លំ សមណេន វុត្តំ អវិជ្ជាវិសទោសោ ឆន្ទរាគព្យាបាទេហិ[១] រុប្បតិ តំ មេ តណ្ហាសល្លំ បហីនំ អបនីតោ អវិជ្ជាវិសទោសោ សម្មានិព្វានាធិមុត្តោហមស្មិតិ ឯវំមានិ[២] អស្ស អត្តំ សមានំ ។ សោ យានិ សម្មានិព្វានាធិមុត្តស្ស អសប្បាយានិ តានិ អនុយុញ្ជេយ្យ ។ អសប្បាយំ ចក្ខុនា រូបទស្សនំ អនុយុញ្ជេយ្យ អសប្បាយំ សោតេន សទ្ទំ អនុយុញ្ជេយ្យ អសប្បាយំ ឃានេន គន្ធំ អនុយុញ្ជេយ្យ អសប្បាយំ ជិវ្ហាយ រសំ អនុយុញ្ជេយ្យ អសប្បាយំ កាយេន ផោដ្ឋព្វំ អនុយុញ្ជេយ្យ អសប្បាយំ មនសា ធម្មំ អនុយុញ្ជេយ្យ ។ តស្ស អសប្បាយំ ចក្ខុនា រូបទស្សនំ អនុយុត្តស្ស អសប្បាយំ សោតេន សទ្ទំ អនុយុត្តស្ស អសប្បាយំ ឃានេន គន្ធំ អនុយុត្តស្ស ។

១ ឱ. ម. ឆន្ទរាគព្យាបាទេន ។ ២ ឱ. ឯវំ មានំ ។ ម. ឯវំ មានី ។

(៧៦) ម្នាលសុនក្ខត្ត ហេតុដែលនាំឲ្យភិក្ខុ ក្នុងសាសនានេះ មានសេចក្ដីត្រេកអរ យ៉ាងនេះថា សរ ព្រះសមណៈត្រាស់ហើយថា ជាតណ្ហា ទោសជាពិសគឺអវិជ្ជា ដែលកម្រើកឡើង ដោយសារឆន្ទរាគ និងព្យាបាទ សរ គឺតណ្ហានោះ អាត្មាអញបានលះបង់ហើយ ទោសជាពិសគឺអវិជ្ជា ក៏អាត្មាអញបាននាំចេញហើយដែរ អាត្មាអញមានអធ្យាស្រ័យទុនទៅរកព្រះនិព្វាន ដោយប្រពៃហើយ សេចក្ដីត្រេកអរយ៉ាងនេះ ដូច្នេះជាដើម ជាសេចក្ដីត្រេកអរមានប្រយោជន៍ ក៏រមែងមាន ។ តែភិក្ខុនោះ បែរជាប្រកបរឿយៗ នូវអារម្មណ៍មិនជាទីសប្បាយ សម្រាប់អ្នកដែលមានអធ្យាស្រ័យទុនទៅរកព្រះនិព្វានដោយប្រពៃ ។ គឺ ប្រកបរឿយ ៗ នូវរូបមិនជាទីសប្បាយ ដោយចក្ខុ ប្រកបរឿយ ៗ នូវសំឡេងមិនជាទីសប្បាយ ដោយសោតៈ ប្រកបរឿយ ៗ នូវក្លិនមិនជាទីសប្បាយ ដោយឃានៈ ប្រកបរឿយ ៗ នូវរសមិនជាទីសប្បាយដោយជិវ្ហា ប្រកបរឿយៗ នូវផោដ្ឋព្វៈមិនជាទីសប្បាយដោយកាយ ប្រកបរឿយ ៗ នូវធម៌មិនជាទីសប្បាយដោយចិត្ត ។ កាលភិក្ខុនោះ ប្រកបរឿយ ៗ នូវការឃើញរូបមិនជាទីសប្បាយដោយចក្ខុ ប្រកបរឿយ ៗ នូវសំឡេងមិនជាទីសប្បាយ ដោយសោតៈ ប្រកបរឿយ ៗ នូវក្លិនមិនជាទីសប្បាយ ដោយឃានៈ

អសប្បាយ ជិវ្ហាយ រស អនុយុត្តស្ស អសប្បាយំ
កាយេន ផោដ្ឋព្វំ អនុយុត្តស្ស អសប្បាយំ មនសា
ធម្មំ អនុយុត្តស្ស រាគោ ចិត្តំ អនុទ្ធំសេយ្យ ។ សោ
រាគានុទ្ធំសិតេន ចិត្តេន មរណំ វា និគច្ឆេយ្យ
មរណមត្តំ វា ទុក្ខំ ។ សេយ្យថាបិ សុនក្ខត្ត បុរិសោ
សល្លេន វិទ្ធោ អស្ស សវិសេន គាឡ្ហូបលេបនេន
តស្ស មិត្តាមច្ចា ញាតិសាលោហិតា ភិសក្កំ សល្ល-
កត្តំ ឧបដ្ឋបេយ្យុំ ។ តស្ស សោ ភិសក្កោ
សល្លកត្តោ សត្ថេន វណមុខំ បរិកន្តេយ្យ សត្ថេន
វណមុខំ បរិកន្តិត្វា ឯសនិយា សល្លំ ឯសេយ្យ
ឯសនិយា សល្លំ ឯសិត្វា សល្លំ អព្ពាហេយ្យ[១]
អបនេយ្យ វិសទោសំ សឧបាទិសេសំ អនុបាទិសេ-
សោតិ ជានមានោ[២] ។ សោ ឯវំ វទេយ្យ អម្ភោ
បុរិស ឧព្ភតំ[៣] ខោ តេ សល្លំ អបនីតោ វិសទោ-
សោ អនុបាទិសេសោ អលញ្ច តេ អនន្តរាយាយ

---

១ ម. អព្ពហេយ្យ ។ យ អព្ពុហេយ្យ ។ ២ ម. បញ្ញមានោ ។ ៣ ម. យ. ឧព្ភតំ ។

ប្រកបរឿយៗ នូវរសមិនជាទីសប្បាយ ដោយជិវ្ហា ប្រកបរឿយៗ នូវផោដ្ឋព្វៈមិនជាទីសប្បាយដោយកាយ ប្រកបរឿយៗ នូវធម្មារម្មណ៍មិនជាទីសប្បាយដោយចិត្ត រាគៈក៏គ្របសង្កត់ចិត្ត ។ ភិក្ខុនោះ លុះត្រូវរាគៈគ្របសង្កត់ចិត្តហើយ ក៏ដល់នូវមរណៈ ឬដល់នូវសេចក្តីទុក្ខស្មើ តមរណៈ ។ ម្នាលសុនក្ខត្ត ដូចបុរសត្រូវសរ ដែលត្រាំដោយថ្នាំពិស ជ្រាបជោកជាំហើយ មិត្តអាមាត្យ ញាតិសាលោហិត របស់បុរសនោះ ក៏ឲ្យពេទ្យវះ ជាអ្នកស្ទាត់ជំនាញក្រៃ ។ ពេទ្យវះអ្នកស្ទាត់ជំនាញនោះ វះមុខដំបៅរបស់បុរសនោះ ដោយគ្រឿងសស្ត្រា លុះវះមុខដំបៅដោយគ្រឿងសស្ត្រារួចហើយ ក៏រាវរកសរ ដោយគ្រឿងសម្រាប់រាវរក (ដង្កៀប) លុះរាវរកសរ ដោយគ្រឿងសម្រាប់រាវរកហើយ ក៏ដកចេញនូវសរមានពិសជាទោស ដែលសេសសល់នៅ ក៏ដឹងថា ពិសជាទោសនោះ មិនមាននៅសេសសល់ទេ ។ ពេទ្យវះនោះនិយាយយ៉ាងនេះថា នែបុរសដ៏ចម្រើន សរបស់អ្នក យើងបានដកចេញហើយ ពិសជាទោស យើងបាននាំចេញ ឥតមានសេសសល់ឡើយ ល្មមមិនមានអន្តរាយដល់អ្នកហើយ

សប្បាយានិ ចេវ ភោជនានិ ភុញ្ជេយ្យាសិ មា តេ អសប្បាយានិ ភោជនានិ ភុញ្ជតោ វណោ អស្សាវី អស្ស កាលេន កាលញ្ច វណំ ធោវេយ្យាសិ កាលេន កាលំ វណមុខំ អាលិម្បេយ្យាសិ មា តេ ន កាលេន កាលំ វណំ ធោវតោ កាលេន កាលំ វណមុខំ អាលិម្បតោ បុព្វលោហិតំ វណមុខំ បរិយោនទ្ធិ មា ច វាតាតបេ ចារិត្តំ អនុយុញ្ជិ មា តេ វាតាតបេ ចារិត្តំ អនុយុត្តស្ស រជោសុកំ វណមុខំ អនុទ្ធំសេសិ វណានុរក្ខី ច អម្ភោ បុរិស វិហរេយ្យាសិ វណសារោបីតិ ។ តស្ស ឯវមស្ស ឧព្ភហតំ ខោ មេ សល្លំ អបនីតោ វិសទោសោ អនុបាទិសេសោ អលញ្ច មេ អន្តរាយាយាតិ ។ សោ អសប្បាយានិ ចេវ ភោជនានិ ភុញ្ជេយ្យ តស្ស អសប្បាយានិ ភោជនានិ ភុញ្ជតោ វណោ អស្សាវី អស្ស ន ច កាលេន កាលំ វណំ ធោវេយ្យ

អ្នកគួរបរិភោគតែភោជនដែលជាទីសប្បាយ អ្នកកុំបរិភោគភោជនមិនជាទីសប្បាយ ឲ្យដំបៅរីកឡើយ អ្នកគួរលាងដំបៅតាមកាលដ៏សមគួរផង គួរលាបមុខដំបៅតាមកាលដ៏សមគួរផង អ្នកកុំមិនលាងដំបៅតាមកាលដ៏សមគួរ កុំមិនលាបមុខដំបៅតាមកាលដ៏សមគួរ ឲ្យមុខដំបៅដែលមានខ្ទុះនិងឈាមរុំជិតឡើយ អ្នកកុំដើរហាលខ្យល់និងកំដៅថ្ងៃ អ្នកកុំដើរហាលខ្យល់និងកំដៅថ្ងៃ ឲ្យលំអងធូលី រុំមុខដំបៅឡើយ នែបុរសដ៏ចម្រើន អ្នកត្រូវនៅរក្សាដំបៅ ត្រូវនៅផ្សះដំបៅចុះ ។ បុរសនោះមានសេចក្តីត្រិះរិះយ៉ាងនេះថា សរបស់អាត្មាអញ ពេទ្យបានដកយកចេញហើយ ពិសជាទោស ពេទ្យបាននាំចេញ ឥតមានសេសសល់ហើយ ល្មមមិនមានអន្តរាយដល់អាត្មាអញហើយ ។ បុរសនោះ ក៏បរិភោគភោជនមិនជាទីសប្បាយផង កាលដែលបុរសនោះ បរិភោគភោជនមិនជាទីសប្បាយ ដំបៅក៏ដេររីកឡើង ទាំងមិនលាងដំបៅតាមកាលដ៏សមគួរ

ន ច កាលេន កាលំ វណមុខំ អាលិម្បេយ្យ តស្ស ន កាលេន កាលំ វណំ ធោវតោ ន ច កាលេន កាលំ វណមុខំ អាលិម្បតោ បុព្វលោហិតំ វណមុខំ បរិយោនន្ធេយ្យ វាតាតបេ ច ចារិត្តំ អនុយុញ្ជេយ្យ តស្ស វាតាតបេ ចារិត្តំ អនុយុត្តស្ស រជោសុកំ វណមុខំ អនុទ្ធំសេយ្យ ន ច វណានុរក្ខី វិហរេយ្យ ន វណសារោបី តស្ស ឥមិស្សា ច អសប្បាយកិរិយាយ អសុចិវិសទោសោ អបនីតោ សឧបាទិសេសោ តទុភយេន វណោ បុថុត្តំ គច្ឆេយ្យ ។ សោ បុថុត្តំ គតេន វណេន មរណំ វា និគច្ឆេយ្យ មរណមត្តំ វា ទុក្ខំ ឯវមេវ ខោ សុនក្ខត្ត ឋានមេតំ វិជ្ជតិ យំ ឥធេកច្ចស្ស ភិក្ខុនោ ឯវមស្ស តណ្ហា ខោ សល្លំ សមណេន វុត្តំ អវិជ្ជាវិសទោសោ ឆន្ទរាគព្យាបាទេន រុប្បតិ

ចាំងមិនលាបមុខដំបៅតាមកាលដ៏សមគួរ កាលដែលបុរសនោះ មិនលាងមុខដំបៅតាមកាលដ៏សមគួរ មិនលាបដំបៅតាមកាលដ៏សមគួរ ខ្ទុះនិងឈាម ក៏បិទស្ទះមុខដំបៅ បុរសនោះប្រកបរឿយ ៗ នូវការដើរហាលខ្យល់និងកំដៅថ្ងៃ កាលដែលបុរសនោះ ប្រកបរឿយ ៗ នូវការដើរហាលខ្យល់និងកំដៅថ្ងៃ លំអងធូលីក៏រុំមុខដំបៅ បុរសនោះឈ្មោះថាមិនរក្សាដំបៅផង មិនផ្សះដំបៅផង បុរសនោះមិនបាននាំចេញនូវវត្ថុមិនស្អាត និងពិសជាទោសដែលនៅសេសសល់ ព្រោះកិរិយាមិនជាទីសប្បាយនេះឯង មុខដំបៅទើបដាលឡើង ដោយហេតុទាំងពីរនោះ ៗ បុរសនោះ ក៏ដល់នូវមរណៈ ឬដល់នូវទុក្ខស្មើរតែមរណៈ ដោយដំបៅដែលដាលឡើង សេចក្ដីនេះមានឧបមាយ៉ាងណា ម្នាលសុនក្ខត្ត មានឧបមេយ្យដូចហេតុដែលនាំឲ្យភិក្ខុរូបខ្លះ ក្នុងសាសនានេះ មានសេចក្ដីត្រិះរិះយ៉ាងនេះថា សរ ព្រះសមណៈត្រាស់ហើយថា ជាតណ្ហា ទោសជាពិស គឺអវិជ្ជា តែងកម្រើកឡើង ដោយសារឆន្ទរាគនិងព្យាបាទ

តំ មេ តណ្ហាសល្លំ បហីនំ អបនីតោ អវិជ្ជាវិសទោសោ សម្មានិព្វានាធិមុត្តោហមស្មីតិ ឯវំមានិ អស្ស អត្ថំ សមានំ ។ សោ យានិ សម្មានិព្វានាធិមុត្តស្ស អសប្បាយានិ តានិ អនុយុញ្ជេយ្យ អសប្បាយំ ចក្ខុនា រូបទស្សនំ អនុយុញ្ជេយ្យ អសប្បាយំ សោតេន សទ្ទំ អនុយុញ្ជេយ្យ អសប្បាយំ ឃានេន គន្ធំ អនុយុញ្ជេយ្យ អសប្បាយំ ជិវ្ហាយ រសំ អនុយុញ្ជេយ្យ អសប្បាយំ កាយេន ផោដ្ឋព្វំ អនុយុញ្ជេយ្យ អសប្បាយំ មនសា ធម្មំ អនុយុញ្ជេយ្យ ។ តស្ស អសប្បាយំ ចក្ខុនា រូបទស្សនំ អនុយុត្តស្ស អសប្បាយំ សោតេន សទ្ទំ អនុយុត្តស្ស អសប្បាយំ ឃានេន គន្ធំ អនុយុត្តស្ស អសប្បាយំ ជិវ្ហាយ រសំ អនុយុត្តស្ស អសប្បាយំ កាយេន ផោដ្ឋព្វំ អនុយុត្តស្ស អសប្បាយំ មនសា ធម្មំ អនុយុត្តស្ស សោ[1] រាគោ ចិត្តំ អនុទ្ធំសេយ្យ ។

---

១ ឱ. សោតិ បទំ ន ទិស្សតិ ។

សរតិតណ្ហានោះ អាត្មាអញបានលះបង់ហើយ ពោលជាពិសេសគឺអវិជ្ជា អាត្មាអញបានខាំចេញហើយ អាត្មាអញមានអធ្យាស្រ័យឱនទៅរកព្រះនិព្វានដោយប្រពៃហើយ សេចក្ដីត្រិះរិះយ៉ាងនេះដូច្នេះជាដើម ជាការមានប្រយោជន៍ ។ តែភិក្ខុនោះបែរជាប្រកបរឿយ ៗ នូវអារម្មណ៍មិនជាទីសប្បាយ សម្រាប់អ្នកដែលមានអធ្យាស្រ័យឱនទៅរកព្រះនិព្វានដោយប្រពៃ គឺប្រកបរឿយ ៗ នូវការឃើញរូប មិនជាទីសប្បាយ ដោយចក្ខុ ប្រកបរឿយៗនូវសំឡេងមិនជាទីសប្បាយ ដោយសោតៈ ប្រកបរឿយៗនូវក្លិនមិនជាទីសប្បាយ ដោយឃានៈ ប្រកបរឿយ ៗ នូវរសមិនជាទីសប្បាយ ដោយជិវ្ហា ប្រកបរឿយៗនូវផោដ្ឋព្វៈមិនជាទីសប្បាយ ដោយកាយ ប្រកបរឿយៗនូវធម្មារម្មណ៍មិនជាទីសប្បាយ ដោយចិត្ត ។ កាលភិក្ខុនោះប្រកបរឿយៗនូវការឃើញរូបមិនជាទីសប្បាយ ដោយចក្ខុ ប្រកបរឿយៗនូវសំឡេងមិនជាទីសប្បាយដោយសោតៈ ប្រកបរឿយៗនូវក្លិនមិនជាទីសប្បាយ ដោយឃានៈ ប្រកបរឿយ ៗនូវរសមិនជាទីសប្បាយដោយជិវ្ហា ប្រកបរឿយ ៗ នូវផោដ្ឋព្វៈមិនជាទីសប្បាយ ដោយកាយ ប្រកបរឿយៗនូវធម្មារម្មណ៍មិនជាទីសប្បាយ ដោយចិត្ត រាគៈក៏គ្របសង្កត់ចិត្ត។

សោ រាគានុទ្ធំសិតេន ចិត្តេន មរណំ វា និគច្ឆេយ្យ
មរណមត្តំ វា ទុក្ខំ ។ មរណញ្ហេតំ សុនក្ខត្ត
អរិយស្ស វិនយេ យោ សិក្ខំ បច្ចក្ខាយ
ហីនាយាវត្តតិ ។ មរណមត្តញ្ហេតំ សុនក្ខត្ត ទុក្ខំ
យោ អញ្ញតរំ សង្កិលិដ្ឋំ អាបត្តឹ អាបជ្ជតិ ។

(៧៧) ឋានំ ខោ បនេតំ សុនក្ខត្ត វិជ្ជតិ យំ
ឥធេកច្ចស្ស ភិក្ខុនោ ឯវមស្ស តណ្ហា ខោ
សល្លំ សមណេន វុត្តំ អវិជ្ជាវិសទោសោ ឆន្ទរាគ-
ព្យាបាទេន រុប្បតិ តំ មេ តណ្ហាសល្លំ បហីនំ
អបនីតោ អវិជ្ជាវិសទោសោ សម្មានិព្វានាធិមុត្តោហ-
មស្មីតិ ។ សម្មានិព្វានាធិមុត្តស្ស សតោ សោ

ភិក្ខុនោះ លុះត្រូវរាគគ្របសង្កត់ចិត្តហើយ ក៏ដល់នូវមរណៈ ឬដល់នូវទុក្ខស្មើរតែមរណៈ ។ ម្នាលសុនក្ខត្ត ពាក្យថា មរណៈ នេះ សំដៅយកភិក្ខុដែលពោលលាសិក្ខា ក្នុងវិន័យ របស់ព្រះអរិយៈ ហើយទៅប្រព្រឹត្តខ្លួនជាបុគ្គលថោកទាបវិញ ។ ម្នាលសុនក្ខត្ត ពាក្យថា ទុក្ខស្មើរតែមរណៈ នេះ សំដៅយកភិក្ខុដែលត្រូវអាបត្តិណាមួយ ដែលនាំឲ្យសៅហ្មងព្រម ។

(៧៧) ម្នាលសុនក្ខត្ត មួយទៀត ហេតុដែលនាំឲ្យភិក្ខុខ្លះ ក្នុងសាសនានេះ មានសេចក្ដីត្រិះរិះយ៉ាងនេះថា សរ ព្រះសមណៈត្រាស់ហើយថាជា តណ្ហា ទោសជាពិស គឺអវិជ្ជា ដែលកម្រើកឡើងដោយសារឆន្ទរាគនិងព្យាបាទ សរគឺតណ្ហានោះ អាត្មាអញបានលះបង់ហើយ ទោសជាពិសគឺអវិជ្ជា អាត្មាអញបាននាំចេញហើយ អាត្មាអញមានអធ្យាស្រ័យឱនទៅរកព្រះនិព្វានដោយប្រពៃហើយ ដូច្នេះ រមែងមាន ។ កាលដែលគេកំពុងមានអធ្យាស្រ័យឱនទៅរកព្រះនិព្វានដោយប្រពៃ ភិក្ខុនោះ

យានិ សម្មា និព្វានាធិមុត្តស្ស អសប្បាយានិ តានិ អនុយុញ្ជេយ្យ អសប្បាយ ចក្ខុនា រូបទស្សនំ អនុយុញ្ជេយ្យ អសប្បាយំ សោតេន សទ្ទំ អនុយុញ្ជេយ្យ អសប្បាយំ ឃានេន គន្ធំ អនុយុញ្ជេយ្យ អសប្បាយំ ជិវ្ហាយ រសំ អនុយុញ្ជេយ្យ អសប្បាយំ កាយេន ផោដ្ឋព្វំ អនុយុញ្ជេយ្យ អសប្បាយ មនសា ធម្មំ អនុយុញ្ជេយ្យ ។ តស្ស អសប្បាយំ ចក្ខុនា រូបទស្សនំ អនុយុត្តស្ស អសប្បាយំ សោតេន សទ្ទំ អនុយុត្តស្ស អសប្បាយំ ឃានេន គន្ធំ អនុយុត្តស្ស អសប្បាយំ ជិវ្ហាយ រសំ អនុយុត្តស្ស អសប្បាយំ កាយេន ផោដ្ឋព្វំ អនុយុត្តស្ស អសប្បាយំ មនសា ធម្មំ អនុយុត្តស្ស រាគោ ចិត្តំ អនុទ្ធំសេយ្យ ។ សោ រាគានុទ្ធំសិតេន ចិត្តេន មរណំ វា និគច្ឆេយ្យ មរណមត្តំ វា ទុក្ខំ ។ សេយ្យថាបិ សុនក្ខត្ត បុរិសោ សល្លេន វិទ្ធោ អស្ស សវិសេន គាឡ្ហូបលេបនេន ។

មិនប្រកបរឿយៗ នូវអារម្មណ៍មិនជាទីសប្បាយ សម្រាប់បុគ្គលអ្នកមានអធ្យាស្រ័យឱនទៅរកព្រះនិព្វាន ដោយប្រពៃឡើយ គឺមិនប្រកបរឿយៗ នូវការឃើញរូបមិនជាទីសប្បាយ ដោយចក្ខុ មិនប្រកបរឿយៗនូវសំឡេងមិនជាទីសប្បាយ ដោយសោតៈ មិនប្រកបរឿយៗនូវក្លិនមិនជាទីសប្បាយ ដោយឃានៈ មិនប្រកបរឿយៗនូវរសមិនជាទីសប្បាយ ដោយជិវ្ហា មិនប្រកបរឿយៗនូវផោដ្ឋព្វ មិនជាទីសប្បាយ ដោយកាយ មិនប្រកបរឿយៗ នូវធម្មារម្មណ៍មិនជាទីសប្បាយ ដោយចិត្ត ។ កាលភិក្ខុនោះ មិនប្រកបរឿយៗ នូវការឃើញរូបមិនជាទីសប្បាយ ដោយចក្ខុ មិនប្រកបរឿយៗ នូវសំឡេងមិនជាទីសប្បាយ ដោយសោត មិនប្រកបរឿយ ៗ នូវក្លិនមិនជាទីសប្បាយ ដោយឃានៈ មិនប្រកបរឿយៗនូវរសមិនជាទីសប្បាយ ដោយជិវ្ហា មិនប្រកបរឿយ ៗ នូវផោដ្ឋព្វៈមិនជាទីសប្បាយ ដោយកាយ មិនប្រកបរឿយៗនូវធម្មារម្មណ៍មិនជាទីសប្បាយ ដោយចិត្ត រាគៈក៏មិនគ្របសង្កត់ចិត្ត ។ លុះភិក្ខុនោះ មិនត្រូវរាគៈគ្របសង្កត់ចិត្តហើយ ក៏មិនដល់នូវមរណៈ ឬមិនដល់នូវទុក្ខស្មើរតែមរណៈទេ ។ ម្នាលសុនក្ខត្ត ដូចបុរសត្រូវសរ ដែលគ្រាំដោយថ្នាំពិស ជ្រាបដោយជាំហើយ ។

តស្ស មិត្តាមច្ចា ញាតិសាលោហិតា ភិសក្កំ សល្លកត្តំ ឧបដ្ឋបេយ្យុំ ។ តស្ស សោ ភិសក្កោ សល្លកត្តោ សត្ថេន វណមុខំ បរិកន្តេយ្យ សត្ថេន សល្លំ វណមុខំ បរិកន្តេត្វា ឯសនិយា សល្លំ ឯសេយ្យ ឯសនិយា ឯសិត្វា សល្លំ អព្ពុហេយ្យ អបនេយ្យ វិសទោសំ អនុបាទិសេសំ អនុបាទិសេសោតិ ជានមានោ ។ សោ ឯវំ វទេយ្យ អម្ភោ បុរិស ឧព្ភតំ ខោ តេ សល្លំ អបនីតោ វិសទោសោ អនុបាទិសេសោ អលញ្ច តេ អន្តរាយាយ សប្បាយានិ ចេវ ភោជនានិ ភុញ្ជេយ្យាសិ មា តេ អសប្បាយានិ ភោជនានិ ភុញ្ជតោ វណោ អស្សាវី អស្ស កាលេន កាលញ្ច វណំ ធោវេយ្យាសិ កាលេន កាលំ វណមុខំ អាលិម្បេយ្យាសិ មា តេ ន កាលេន កាលំ វណំ ធោវតោ កាលេន កាលំ វណមុខំ អាលិម្បតោ បុព្វលោហិតំ វណមុខំ បរិយោនទ្ធិ មា ច វាតាតបេ ចារិត្តំ អនុយុញ្ជិ

មិត្រអាមាត្យ ញាតិសាលោហិត របស់បុរសនោះ គប្បីឲ្យពេទ្យវះអ្នកស្ទាត់ជំនាញរក្សា ។ ពេទ្យវះ អ្នកស្ទាត់ជំនាញនោះ គប្បីវះនូវមុខដំបៅរបស់បុរសនោះ ដោយសស្ត្រា លុះវះនូវមុខដំបៅដែលមានសរដោយសស្ត្រារួចហើយ គប្បីរាវរកសរដោយគ្រឿងសម្រាប់រាវរក លុះរាវរកសរដោយគ្រឿងសម្រាប់រាវរករួចហើយ គប្បីដកចេញនូវសរដែលមានពិសជាទោស មិនឲ្យមាននៅសេសសល់ ពេទ្យវះនោះក៏ដឹងថាមិនមានពិសនៅសេសសល់ទេ ។ ពេទ្យវះនោះ និយាយយ៉ាងនេះថា នែបុរសដ៏ចម្រើន សររបស់អ្នក យើងបានដកចេញហើយ ពិសជាទោសយើងបាននាំចេញ ឥតមានសេសសល់ឡើយ ល្មមិនមានសេចក្តីអន្តរាយដល់អ្នកហើយ អ្នកគួរបរិភោគភោជនជាទីសប្បាយ អ្នកកុំបរិភោគភោជនមិនជាទីសប្បាយ ឲ្យរើកដំបៅឡើយ អ្នកគប្បីលាងដំបៅតាមកាលដ៏សមគួរផង គប្បីលាបមុខដំបៅតាមកាលដ៏សមគួរផង អ្នកកុំខានលាងដំបៅតាមកាលដ៏សមគួរ កុំខានលាបមុខដំបៅតាមកាលដ៏សមគួរ ឲ្យមុខដំបៅដែលមានខ្ទុះនិងឈាមរុំជិតឡើយ អ្នកកុំដើរហាលខ្យល់និងកំដៅថ្ងៃ

មា តេ វាតាតបេ ចារិត្តំ អនុយុត្តស្ស រជោសូកំ វណមុខំ អនុទ្ធំសេសិ វណានុរក្ខី ច អម្ភោ បុរិស វិហរេយ្យាសិ វណសារោបីតិ ។ តស្ស ឯវមស្ស ឧព្ភតំ ខោ មេ សល្លំ អបនីតោ វិសទោសោ អនុបាទិសេសោ អលញ្ច មេ អន្តរាយាយាតិ ។ សោ សប្បាយានិ ចេវ ភោជនានិ ភុញ្ជេយ្យ តស្ស សប្បាយានិ ភោជនានិ ភុញ្ជតោ វណោ ន អស្សាវី អស្ស កាលេន កាលញ្ច វណំ ធោវេយ្យ កាលេន កាលំ វណមុខំ អាលិម្បេយ្យ តស្ស កាលេន កាលំ វណំ ធោវតោ កាលេន កាលំ វណមុខំ អាលិម្បតោ បុព្វលោហិតំ វណមុខំ ន បរិយោនន្ធេយ្យ ន ច វាតាតបេ ចារិត្តំ អនុយុញ្ជេយ្យ តស្ស វាតាតបេ ចារិត្តំ អននុយុត្តស្ស រជោសូកំ វណមុខំ នានុទ្ធំសេយ្យ វណានុរក្ខី ច វិហរេយ្យ វណសារោបី តស្ស ឥមិស្សា ច សប្បាយកិរិយាយ អសុចិវិសទោសោ អបនីតោ អនុបាទិសេសោ

អ្នកកុំដើរហាលខ្យល់និងកំដៅថ្ងៃ ឲ្យលំអងធូលីរុំមុខដំបៅឡើយ នែបុរសដ៏ចម្រើន អ្នកគប្បីនៅរក្សាដំបៅផង គប្បីនៅផ្សះដំបៅផង ។ បុរសនោះមានសេចក្តីត្រិះរិះយ៉ាងនេះថា សររបស់អាត្មាអញ ពេទ្យវះបានដកចេញហើយ ពិសជាទោស ពេទ្យវះបាននាំចេញ ឥតមានសេសសល់ហើយ ល្មមមិនមានសេចក្តីអន្តរាយដល់អាត្មាអញហើយ ។ បុរសនោះគប្បីបរិភោគភោជន ជាទីសប្បាយ កាលបុរសនោះបរិភោគតែភោជនជាទីសប្បាយ ដំបៅក៏មិនរីកឡើង ទាំងលាងនូវដំបៅតាមកាលដ៏សមគួរ ទាំងលាបនូវមុខដំបៅតាមកាលដ៏សមគួរ កាលបុរសនោះលាងដំបៅតាមកាលដ៏សមគួរ លាបមុខដំបៅតាមកាលដ៏សមគួរហើយ ខ្ទុះនិងឈាម ក៏មិនរួបរឹតមុខដំបៅ បុរសនោះមិនប្រកបនូវការដើរហាលខ្យល់និងកំដៅថ្ងៃ កាលបុរសនោះមិនប្រកបនូវការដើរហាលខ្យល់និងកំ-ដៅថ្ងៃហើយ លំអងធូលីក៏មិនបានរុំមុខដំបៅ បុរសនោះឈ្មោះថាជាអ្នករក្សានូវដំបៅផង ជាអ្នកផ្សះនូវដំបៅផង បុរសនោះបាននាំចេញនូវពិសជាទោសមិនស្អុតដែលនៅសេសសល់ ព្រោះសេចក្តីសប្បាយនេះឯង

តទុភយេន វណោ វិរូហេយ្យ ។ សោ រូឡ្ហេន វណេន សញ្ឆវិនា នេវ មរណំ វា និគច្ឆេយ្យ ន មរណមត្តំ វា ទុក្ខំ ឯវមេវ ខោ សុនក្ខត្ត ឋានមេតំ វិជ្ជតិ យំ ឥធេកច្ចស្ស ភិក្ខុនោ ឯវមស្ស តណ្ហា ខោ សល្លំ សមណេន វុត្តំ អវិជ្ជាវិសទោសោ ឆន្ទរាគព្យាបាទេន រុប្បតិ តំ មេ តណ្ហាសល្លំ បហីនំ អបនីតោ អវិជ្ជាវិសទោសោ សម្មានិព្វានាធិមុត្តោហមស្មីតិ ។ សម្មានិព្វានាធិមុត្តស្សេវ សតោ សោ យានិ សម្មានិព្វានាធិមុត្តស្ស អសប្បាយានិ តានិ នានុយុញ្ជេយ្យ អសប្បាយំ ចក្ខុនា រូបទស្សនំ នានុយុញ្ជេយ្យ អសប្បាយ សោតេន សទ្ទំ នានុយុញ្ជេយ្យ អសប្បាយំ ឃានេន គន្ធំ នានុយុញ្ជេយ្យ អសប្បាយំ ជិវ្ហាយ រសំ នានុយុញ្ជេយ្យ អសប្បាយំ កាយេន ផោដ្ឋព្វំ នានុយុញ្ជេយ្យ អសប្បាយំ មនសា ធម្មំ នានុយុញ្ជេយ្យ ។

មុខដំបៅក៏ដុះឡើង ដោយហេតុទាំងពីរនោះ ។ បុរសនោះក៏មិនដល់នូវមរណៈ ឬមិនដល់នូវទុក្ខស្មើនឹងមរណៈឡើយ ព្រោះដំបៅដែលមានសម្បុរល្អដុះដាលឡើង សេចក្តីនេះមានឧបមាយ៉ាងណា ម្នាលសុនក្ខត្ត មានឧបមេយ្យដូច្នេះ ហេតុដែលនាំឲ្យកើតទុក្ខក្នុងសាសនានេះ មានសេចក្តីត្រិះរិះដូច្នេះថា សរ ព្រះសមណៈ ត្រាស់ហើយថា ជាតណ្ហា ទោសជាពិសគឺអវិជ្ជា តែងកម្រើកឡើងដោយឆន្ទរាគនិងព្យាបាទ សរគឺតណ្ហានោះ អាត្មាអញបានលះបង់ហើយ ទោសជាពិសគឺអវិជ្ជា អាត្មាអញបាននាំចេញហើយ អាត្មាអញមានអធ្យាស្រ័យឱនទៅរកព្រះនិព្វាន ដោយប្រពៃហើយ ដូច្នេះ រមែងមាន ។ កាលគេកំពុងមានអធ្យាស្រ័យឱនទៅរកព្រះនិព្វានដោយប្រពៃ ភិក្ខុនោះ មិនប្រកបរឿយ ៗ នូវអារម្មណ៍មិនជាទីសប្បាយ សម្រាប់អ្នកមានអធ្យាស្រ័យឱនទៅរកព្រះនិព្វាន ដោយប្រពៃ គឺមិនប្រកបរឿយៗ នូវការឃើញរូបមិនជាទីសប្បាយ ដោយចក្ខុ មិនប្រកបរឿយៗ នូវសំឡេងមិនជាទីសប្បាយ ដោយសោតៈ មិនប្រកបរឿយៗនូវក្លិនមិនជាទីសប្បាយ ដោយឃានៈ មិនប្រកបរឿយ ៗនូវរសមិនជាទីសប្បាយ ដោយជិវ្ហា មិនប្រកបរឿយ ៗនូវផោដ្ឋព្វៈមិនជាទីសប្បាយ ដោយកាយ មិនប្រកបរឿយៗនូវធម្មារម្មណ៍មិនជាទីសប្បាយដោយចិត្ត ។

តស្ស អសប្បាយំ ចក្ខុនា រូបទស្សនំ អនុយុត្តស្ស អសប្បាយំ សោតេន សទ្ទំ អនុយុត្តស្ស អសប្បាយំ ឃានេន គន្ធំ អនុយុត្តស្ស អសប្បាយំ ជិវ្ហាយ រសំ អនុយុត្តស្ស អសប្បាយំ កាយេន ផោដ្ឋព្វំ អនុយុត្តស្ស អសប្បាយំ មនសា ធម្មំ អនុយុត្តស្ស រាគោ ចិត្តំ អនុទ្ធំសេយ្យ ។ សោ ន រាគានុទ្ធំសិតេន ចិត្តេន នេវ មរណំ វា និគច្ឆេយ្យ ន មរណមត្តំ វា ទុក្ខំ ។ ឧបមា ខោ មេ អយំ សុនក្ខត្ត កតា អត្ថវិញ្ញាបនាយ[1] ។ អយមេវេត្ថ អត្ថោ ។ វណោតិ ខោ សុនក្ខត្ត ឆន្នេតំ អជ្ឈត្តិកានំ អាយតនានំ អធិវចនំ ។ វិសទោសោតិ ខោ សុនក្ខត្ត អវិជ្ជាយេតំ អធិវចនំ ។ សល្លន្តិ ខោ សុនក្ខត្ត តណ្ហាយេតំ អធិវចនំ ។ ឯសនីតិ ខោ សុនក្ខត្ត សតិយេតំ អធិវចនំ ។ សត្ថន្តិ ខោ សុនក្ខត្ត អរិយាយេតំ បញ្ញាយ អធិវចនំ ។

---

១ ឱ ម. អត្ថស្ស វិញ្ញាបនាយ ។

កាលភិក្ខុនោះ មិនប្រកបរឿយៗ នូវការឃើញរូបមិនជាទីសប្បាយ ដោយចក្ខុ មិនប្រកបរឿយៗនូវសំឡេងមិនជាទីសប្បាយ ដោយសោតៈ មិនប្រកបរឿយៗនូវក្លិនមិនជាទីសប្បាយ ដោយឃានៈ មិនប្រកបរឿយៗនូវរសមិនជាទីសប្បាយ ដោយជិវ្ហា មិនប្រកបរឿយៗ នូវផោដ្ឋព្វៈមិនជាទីសប្បាយ ដោយកាយ មិនប្រកបរឿយៗ នូវធម្មារម្មណ៍មិនជាទីសប្បាយ ដោយចិត្ត រាគៈក៏មិនអាចគ្របសង្កត់ចិត្តបាន ។ លុះភិក្ខុនោះ មិនត្រូវរាគៈគ្របសង្កត់ចិត្តហើយ ក៏មិនដល់នូវមរណៈ ឬមិនដល់នូវទុក្ខ ស្មើនឹងមរណៈឡើយ ។ ម្នាលសុនក្ខត្ត សេចក្តីឧបមានេះ តថាគតបានធ្វើ ដើម្បីនឹងញុំាងជនឲ្យដឹងសេចក្តី ។ ឯសេចក្តីក្នុងឧបមានុ៎ះដូចតទៅនេះ ។ ម្នាលសុនក្ខត្ត ពាក្យថា ដំបៅ នុ៎ះ ជាឈ្មោះនៃអាយតនៈ ដែលប្រព្រឹត្តទៅខាងក្នុងទាំង ៦ ។ ម្នាលសុនក្ខត្ត ពាក្យថា ពិសជាទោស នុ៎ះ ជាឈ្មោះនៃអវិជ្ជា ។ ម្នាលសុនក្ខត្ត ពាក្យថា សរ នុ៎ះ ជាឈ្មោះនៃតណ្ហា ។ ម្នាលសុនក្ខត្ត ពាក្យថា គ្រឿងសម្រាប់រាវរក នុ៎ះ ជាឈ្មោះនៃស្មារតី ។ ម្នាលសុនក្ខត្ត ពាក្យថា សស្ត្រា នុ៎ះ ជាឈ្មោះនៃបញ្ញាដ៏ប្រសើរ ។

ភិសក្កោ សល្លកត្តោតិ ខោ សុនក្ខត្ត តថាគតស្សេតំ អធិវចនំ អរហតោ សម្មាសម្ពុទ្ធស្ស ។ សោ វត សុនក្ខត្ត ភិក្ខុ ឆសុ ផស្សាយតនេសុ សំវុតការី ឧបធិ ទុក្ខមូលន្តិ[១] ឥតិ វិទិត្វា និរុបធិ ឧបធិសង្ខយេ វិមុត្តោ ឧបធិស្មឹ វា កាយំ ឧបសំហរិស្សតិ ចិត្តំ វា អនុប្បាទេស្សតីតិ[២] នេតំ ឋានំ វិជ្ជតិ ។ សេយ្យថាបិ សុនក្ខត្ត អាបានីយកំសោ វណ្ណសម្បន្នោ គន្ធសម្បន្នោ រសសម្បន្នោ សោ ច ខោ វិសេន សំសដ្ឋោ ។ អថ បុរិសោ អាគច្ឆេយ្យ ជីវិតុកាមោ អមរិតុកាមោ សុខកាមោ ទុក្ខប្បដិក្កូលោ ។ តំ កឹ មញ្ញសិ សុនក្ខត្ត អបិ នុ សោ បុរិសោ អមុំ អាបានីយកំសំ បិវេយ្យ យំ ជញ្ញា ឥមាហំ បិត្វា មរណំ វា និគច្ឆាមិ មរណមត្តំ វា ទុក្ខន្តិ ។ នោ ហេតំ ភន្តេ ។

(៧៨) ឯវមេវ ខោ សុនក្ខត្ត សោ វត ភិក្ខុ ឆសុ ផស្សាយតនេសុ សំវុតការី ឧបធិ ទុក្ខស្ស មូលន្តិ ។ បេ ។ នេតំ ឋានំ វិជ្ជតិ ។ សេយ្យថាបិ សុនក្ខត្ត

---

១ ឱ ម. ទុក្ខស្ស មូលន្តិ ។ ២ ឱ. ឧប្បាទេស្សតីតិ ។ ម. ឧប្បាទេស្សតីតិ ។

ម្នាលសុនក្ខត្ត ពាក្យថា ពេទ្យវះដ៏ជំនាញ នុ៎ះ ជាឈ្មោះនៃព្រះតថាគត អរហន្តសម្មាសម្ពុទ្ធ ។ ម្នាលសុនក្ខត្ត ភិក្ខុនោះឯង ជាអ្នកធ្វើនូវការសង្រួមក្នុងផស្សាយតនៈទាំង ៦ ដឹងច្បាស់ថា កិលេសជាឫសនៃសេចក្តីទុក្ខ លុះដឹងដូច្នេះហើយ ក៏ជាអ្នកមិនមានកិលេស ជាអ្នករួចស្រឡះហើយ ព្រោះការអស់ទៅនៃកិលេស មិនបង្អោនកាយ ឬមិនផ្តេកផ្តួលចិត្តទៅក្នុងកិលេស ពាក្យដូច្នេះនេះ មិនសមហេតុឡើយ ។ ម្នាលសុនក្ខត្ត ដូចផ្តិលសំរិទ្ធ ដល់ព្រមដោយពណ៌ ដោយក្លិន ដោយរស តែថាផ្តិលសំរិទ្ធនោះប្រឡាក់ដោយថ្នាំពិស ។ កាលបើមានបុរសអ្នកចង់រស់ មិនចង់ស្លាប់ ចង់សុខ ខ្ពើមទុក្ខ មកដល់ ។ ម្នាលសុនក្ខត្ត អ្នកសំគាល់សេចក្តីនោះថាដូចម្តេច តើបុរសនោះ គួរផឹកទឹក នឹងផ្តិលសំរិទ្ធឯណោះ ដែលខ្លួនដឹងថា អាត្មាអញផឹកទឹកនេះទៅហើយ នឹងដល់នូវមរណៈ ឬដល់នូវសេចក្តីទុក្ខស្មើរតែមរណៈដែរឬ ។ បពិត្រព្រះអង្គដ៏ចម្រើន មិនផឹកទឹកនឹងផ្តិលសំរិទ្ធនុ៎ះទេ ។

(៧៨) ម្នាលសុនក្ខត្ត សេចក្តីនេះមានឧបមេយ្យដូចភិក្ខុនោះឯង ជាអ្នកធ្វើនូវការសង្រួមក្នុងផស្សាយតនៈ ៦ ដឹងថាកិលេសជាឫសនៃសេចក្តីទុក្ខ ។បេ។ ពាក្យដូច្នេះនុ៎ះ មិនសមហេតុឡើយ ។ ម្នាលសុនក្ខត្ត ដូចជា

អាសីវិសោ ឃោរវិសោ ។ អថ បុរិសោ អាគច្ឆេយ្យ ជីវិតុកាមោ អមរិតុកាមោ សុខកាមោ ទុក្ខប្បដិក្កូលោ ។ តំ កឹ មញ្ញសិ សុនក្ខត្ត អបិ នុ សោ បុរិសោ អមុស្ស អាសីវិសស្ស ឃោរវិសស្ស ហត្ថំ វា អង្គុដ្ឋំ វា ទជ្ជា យំ ជញ្ញា ឥមិនាហំ ទដ្ឋោ មរណំ វា និគច្ឆាមិ មរណមត្តំ វា ទុក្ខន្តិ ។ នោ ហេតំ ភន្តេ ។

(៧៩) ឯវមេវ ខោ សុនក្ខត្ត សោ វត ភិក្ខុ ឆសុ ផស្សាយតនេសុ សំវុតការី ឧបធិ ទុក្ខមូលន្តិ ឥតិ វិទិត្វា និរុបធី ឧបធិសង្ខយេ វិមុត្តោ ឧបធិស្មឹ វា កាយំ ឧបសំហរិស្សតិ ចិត្តំ វា អនុប្បាទេស្សតីតិ នេតំ ឋានំ វិជ្ជតីតិ ។ ឥទមវោច ភគវា អត្តមនោ សុនក្ខត្តោ លិច្ឆវិបុត្តោ ភគវតោ ភាសិតំ អភិនន្ទីតិ ។

សុនក្ខត្តសុត្តំ បញ្ចមំ និដ្ឋិតំ ។

អាសិរពិស មានពិសដ៏ពន្លឹក ។ កាលបើបុរសអ្នកចង់រស់ មិនចង់ស្លាប់ ចង់សុខ ខ្ពើមទុក្ខ មកដល់ ។ ម្នាលសុនក្ខត្ត អ្នកសំគាល់សេចក្តីនោះដូចម្តេច តើបុរសនោះ គួរហុចដៃទាំងឡាយ ឬហុចមេដៃឲ្យដល់អាសិរពិសមានពិសដ៏ពន្លឹកឯណោះ ដែលខ្លួនដឹងថា អាសិរពិសនេះចឹកអាត្មាអញហើយ នឹងដល់នូវមរណៈ ឬដល់នូវសេចក្តីទុក្ខស្មើតែមរណៈដែរឬ ។ បពិត្រព្រះអង្គដ៏ចម្រើន មិនហុចឲ្យអាសិរពិសនោះទេ ។

(៧៩) ម្នាលសុនក្ខត្ត សេចក្តីនេះមានឧបមេយ្យដូចភិក្ខុនោះឯង ជាអ្នកធ្វើនូវការសង្រួមក្នុងផស្សាយតនៈ ៦ ដឹងច្បាស់ថា កិលេសជាឫសនៃសេចក្តីទុក្ខ លុះដឹងដូច្នេះហើយ ក៏ជាអ្នកមិនមានកិលេស រួចស្រឡះហើយ ព្រោះតែការអស់ទៅនៃកិលេស នឹងបង្អោនកាយ ឬផ្តេកផ្តួលចិត្តទៅរកកិលេស ពាក្យដូច្នេះនុ៎ះ មិនសមហេតុទើយ ។ លុះព្រះមានព្រះភាគសំដែងព្រះសូត្រនេះចប់ហើយ សុនក្ខត្តលិច្ឆវីបុត្រ មានចិត្តត្រេកអរ រីករាយហើយ ចំពោះភាសិត របស់ព្រះមានព្រះភាគ ។

ចប់ សុនក្ខត្តសូត្រ ទី ៥ ។

# ឆដ្ឋំ អានេញ្ជសប្បាយសុត្តំ

(៨០) ឯវំ មេ សុតំ ។ ឯកំ សមយំ ភគវា កុរូសុ វិហរតិ កម្មាសធម្ម នាម កុរូនំ និគមោ ។ តត្រ ខោ ភគវា ភិក្ខូ អាមន្តេសិ ភិក្ខវោតិ ។ ភទន្តេតិ តេ ភិក្ខូ ភគវតោ បច្ចស្សោសុំ ។

(៨១) ភគវា ឯតទវោច អនិច្ចា ភិក្ខវេ កាមា តុច្ឆា មុសា មោសធម្មា[១] មាយាកតមេតំ ភិក្ខវេ ពាលលាបនំ យេ ច ទិដ្ឋធម្មិកា កាមា យេ ច សម្បរាយិកា កាមា យា ច ទិដ្ឋធម្មិកា កាមសញ្ញា យា ច សម្បរាយិកា កាមសញ្ញា ឧភយមេតំ មារធេយ្យំ មារស្សេស[២] វិសយោ មារស្សេស និវាបោ មារស្សេស គោចរោ ឯត្ថេតេ បាបកា អកុសលា មានសា អភិជ្ឈាបិ ព្យាបាទាបិ

---

១ ឱ. មោឃធម្មា ។ ២ ម. មារស្សេវ ។

# អានេញ្ជសប្បាយសូត្រ ទី ៦

(៨០) ខ្ញុំបានស្តាប់មក យ៉ាងនេះ ។ សម័យមួយ ព្រះមានព្រះភាគ ទ្រង់គង់នៅក្នុងកម្មាសធម្មនិគម របស់អ្នកកុរុទាំងឡាយ ក្នុងកុរុជនបទ ។ នៅទីនោះឯង ព្រះមានព្រះភាគ ទ្រង់ត្រាស់ហៅភិក្ខុទាំងឡាយមកថា ម្នាលភិក្ខុទាំងឡាយ ។ ភិក្ខុទាំងនោះ ទទួលព្រះពុទ្ធដីកានៃព្រះមានព្រះភាគថា បពិត្រព្រះអង្គដ៏ចម្រើន ។

(៨១) ព្រះមានព្រះភាគ ទ្រង់ត្រាស់ដូច្នេះថា ម្នាលភិក្ខុទាំង-ឡាយ កាមទាំងឡាយជាសភាវៈមិនទៀង ជារបស់ទទេ ជារបស់កុហក មានការវិនាសជាធម្មតា ម្នាលភិក្ខុទាំងឡាយ ពាក្យថា កាមនេះ ដូចជាវត្ថុដែលគេធ្វើដោយមាយាកល[1] ជាសំដី របស់ជនពាល កាមណា ដែលប្រព្រឹត្តទៅក្នុងបច្ចុប្បន្នក្តី កាមណាដែលប្រព្រឹត្តទៅក្នុងបរលោកក្តី កាមសញ្ញាណា ដែលប្រព្រឹត្តទៅក្នុងបច្ចុប្បន្នក្តី កាមសញ្ញាណា ដែលប្រព្រឹត្តទៅក្នុងបរលោកក្តី ទាំងមួយគូនុ៎ះ ជាទីនៅនៃមារ នុ៎ះជាវិស័យរបស់មារ នុ៎ះជាចំណីរបស់មារ នុ៎ះជាទីគោចររបស់មារ អកុសលដ៏លាមកទាំងនុ៎ះ ដែលកើតអំពីចិត្ត ទោះជាអភិជ្ឈាក្តី ព្យាបាទក្តី

---

១ មាយាកលដែលគេធ្វើទឹកឲ្យទៅជាកែវមណី ស្លឹកពព្រាឲ្យទៅជាប្រាក់ បង្ហាញអ្នកដទៃបាន យ៉ាងណាមិញ កាមក៏ដូច្នោះឯង ។

សារម្ភាបិ សំវត្តន្តិ តេវ[១] អរិយសាវកស្ស ឥធមនុសិក្ខតោ អន្តរាយាយ សម្ភវន្តិ ។

(៨២) តត្រ ភិក្ខវេ អរិយសាវកោ ឥតិ បដិសញ្ចិក្ខតិ យេ ច ទិដ្ឋធម្មិកា កាមា យេ ច សម្បរាយិកា កាមា យា ច ទិដ្ឋធម្មិកា កាមសញ្ញា យា ច សម្បរាយិកា កាមសញ្ញា ឧភយមេតំ មារធេយ្យំ មារស្សេស វិសយោ មារស្សេស និវាបោ មារស្សេស គោចរោ ឯត្ថេតេ បាបកា អកុសលា មានសា អភិជ្ឈាបិ ព្យាបាទាបិ សារម្ភាបិ សំវត្តន្តិ តេវអរិយសាវកស្ស ឥធមនុសិក្ខតោ អន្តរាយាយ សម្ភវន្តិ យន្នូនាហំ វិបុលេន មហគ្គតេន ចេតសា វិហរេយ្យំ អភិភុយ្យ លោកំ អធិដ្ឋាយ មនសា វិបុលេន ហិ មេ មហគ្គតេន ចេតសោ វិហរតោ អភិភុយ្យ លោកំ

១ តេបាតិប្បតិ ។

សារម្ភៈ (ការប្រណាំងប្រជែង) ក្តី រមែងប្រព្រឹត្តទៅ ក្នុងកាមទាំងនុ៎ះ ឯកិលេសទាំង ៣ នោះ រមែងកើត ដើម្បីអន្តរាយដល់អរិយសាវ័ក អ្នកកំពុងសិក្សារៀយ ៗ ក្នុងសាសនានេះ ។

(៨៦) ម្នាលភិក្ខុទាំងឡាយ អរិយសាវ័ក តែងពិចារណាក្នុងកាមនោះដូច្នេះថា កាមណា ដែលប្រព្រឹត្តទៅក្នុងបច្ចុប្បន្នក្តី កាមណា ដែលប្រព្រឹត្តទៅក្នុងបរលោកក្តី កាមសញ្ញាណា ដែលប្រព្រឹត្តទៅក្នុងបច្ចុប្បន្នក្តី កាមសញ្ញាណា ដែលប្រព្រឹត្តទៅក្នុងបរលោកក្តី ទាំងមួយគ្នុ៎ះ ជាទីនៅនៃមារ នុ៎ះជាវិស័យរបស់មារ នុ៎ះជាចំណីរបស់មារ នុ៎ះជាទីគោចររបស់មារ អកុសលធម៌លាមកទាំងនេះដែលកើតអំពីចិត្ត គោះជាអភិជ្ឈាក្តី ព្យាបាទក្តី សារម្ភៈក្តី រមែងប្រព្រឹត្តទៅក្នុងកាមទាំងនុ៎ះ ឯកិលេសទាំង ៣ នោះ រមែងកើតដើម្បីអន្តរាយដល់អរិយសាវ័ក អ្នកកំពុងសិក្សារៀយ ៗ ក្នុងសាសនានេះ បើដូច្នោះ គួរតែអាត្មាអញយក មហគ្គតចិត្ត(១) ដ៏ទូលាយ ទៅគ្របសង្កត់ នូវលោកគឺកាមគុណ អធិដ្ឋាន (នូវឈានារម្មណ៍) ដោយចិត្ត ហើយសម្រេចសម្រាន្តនៅ ព្រោះថា កាលបើអាត្មាអញ យកមហគ្គតចិត្តដ៏ទូលាយ ទៅគ្របសង្កត់នូវលោកគឺកាមគុណ

១ រូបាវចរចិត្ត និងអរូបាវចរចិត្ត ។

អធិដ្ឋាយ មនសា យេ បាបកា អកុសលា មានសា អភិជ្ឈាបិ ព្យាបាទាបិ សារម្ភាបិ តេ ន ភវិស្សន្តិ តេសំ បហានា[១] អបរិត្តញ្ច មេ ចិត្តំ ភវិស្សតិ អប្បមាណំ សុភាវិតន្តិ ។ តស្ស ឯវំ បដិបន្នស្ស តព្ពហុលវិហារិនោ អាយតនេ ចិត្តំ បសីទតិ សម្បសាទេ សតិ ឯតរហិ វា អានេញ្ជំ សមាបជ្ជតិ បញ្ញាយ វា អធិមុច្ចតិ ។ កាយស្ស ភេទា បរម្មរណា ឋានមេតំ វិជ្ជតិ យន្តំ សំវត្តនិកំ វិញ្ញាណំ អស្ស អានេញ្ជូបគំ ។ អយំ ភិក្ខវេ បឋមា អានេញ្ជសប្បាយា បដិបទា អក្ខាយតិ ។

---

១ ម. បហានំ ។

អភិជ្ឈាន (នូវឈានារម្មណ៍) ដោយចិត្តហើយ អកុសលដ៏លាមកទាំង–ឡាយណា ដែលកើតអំពីចិត្ត ទោះជាអភិជ្ឈាក្តី ព្យាបាទក្តី សារម្ភៈក្តី អកុសលទាំងនោះ នឹងមិនមានតទៅ មួយទៀត ចិត្តរបស់អាត្មាអញនឹងមិនមែនជាបរិត្តចិត្តផង[1] ជាចិត្តប្រមាណមិនបានផង[2] ជាចិត្តដែលអាត្មាអញចម្រើនដោយល្អផង[3] ព្រោះលះបង់នូវអកុសលទាំងនោះ ។ កាលបើអរិយសាវកនោះ ប្រតិបត្តិយ៉ាងនេះ មានកិរិយានៅក្នុងសេចក្តីប្រតិបត្តិនោះដោយច្រើនហើយ ចិត្តរមែងជ្រះថ្លាក្នុងអាយតនៈគឺហេតុ[4] កាលបើសេចក្តីជ្រះថ្លាមានហើយ អរិយសាវកនោះ ក៏ដល់នូវអានេញ្ជ–ធម៌[5] ក្នុងកាលឥឡូវនេះផង ចុះចិត្តស៊ប់ដោយបញ្ញាផង[6] ។ លុះមានកាយបែកធ្លាយទៅ បន្ទាប់អំពីមរណៈ សំវត្តនិកវិញ្ញាណនោះក៏នឹងដល់នូវអានេញ្ជធម៌ ដោយហេតុណា ហេតុនុ៎ះ រមែងមាន ។ ម្នាលភិក្ខុទាំងឡាយ នេះអានេញ្ជសប្បាយប្បដិបទា[7] ទី ១ ។

---

១–២–៣ កាមាវចរចិត្ត ហៅថា បរិត្តចិត្ត ពាក្យថា មិនមែនជាបរិត្តចិត្ត បានខាងរូបាវចរ–ចិត្តនិងអរូបាវចរចិត្ត តែទាំង ៣ បទនេះ សំដៅយកលោកុត្តរចិត្ត ។ ៤ ហេតុក្នុងទីនេះសំដៅយកព្រះអរហត្ត វិបស្សនា ចតុត្ថជ្ឈាន ឬឧបចារនៃចតុត្ថជ្ឈាន ។ ៥ ធម៌មិនញាប់ញ័រ ក្នុងទីនេះសំដៅយកចតុត្ថជ្ឈាន ។ ៦ បានសម្រេចព្រះអរហត្ត ។ ៧ សេចក្តីប្រតិបត្តិជាទីសប្បាយនៃអានេញ្ជធម៌ ។

(៨៣) បុន ចបរំ ភិក្ខវេ អរិយសាវកោ ឥតិ បដិសញ្ចិក្ខតិ ៖ យេ ច ទិដ្ឋធម្មិកា កាមា យេ ច សម្បរាយិកា កាមា យា ច ទិដ្ឋធម្មិកា កាមសញ្ញា យា ច សម្បរាយិកា កាមសញ្ញា យំ[១] កិញ្ចិ រូបំ សព្វំ រូបំ ចត្តារិ មហាភូតានិ ចតុន្នញ្ច មហាភូតានំ ឧបាទាយ រូបន្តិ ។ តស្ស ឯវំ បដិបន្នស្ស តព្វហុលវិហារិនោ អាយតនេ ចិត្តំ បសីទតិ សម្បសាទេ សតិ ឯតរហិ វា អានេញ្ជំ សមាបជ្ជតិ បញ្ញាយ វា អធិមុច្ចតិ ។ កាយស្ស ភេទា បរម្មរណា ឋានមេតំ វិជ្ជតិ យន្តំ សំវត្តនិកំ វិញ្ញាណំ អស្ស អានេញ្ជូបគំ ។ អយំ ភិក្ខវេ ទុតិយា អានេញ្ជសប្បាយា បដិបទា អក្ខាយតិ ។

១ ម. យំ កិញ្ចិ រូបំ ចត្តារិ ច មហាភូតានីតិ ទិស្សតិ ។

(៨៣) ម្នាលភិក្ខុទាំងឡាយ មួយទៀត អរិយសាវ័ក តែងពិចារណាដូច្នេះថា កាមណា ដែលប្រព្រឹត្តទៅក្នុងបច្ចុប្បន្នក្តី កាមណា ដែលប្រព្រឹត្តទៅក្នុងបរលោកក្តី កាមសញ្ញាណា ដែលប្រព្រឹត្តទៅក្នុងបច្ចុប្បន្នក្តី កាមសញ្ញាណា ដែលប្រព្រឹត្តទៅក្នុងបរលោកក្តី រូបណានីមួយ រូបទាំងអស់ (នោះ) គឺមហាភូតរូប ៤ និងរូប[1] ដែលអាស្រ័យនូវមហាភូតរូប ៤ ក្តី ។ កាលបើអរិយសាវ័កនោះប្រតិបត្តិយ៉ាងនេះ មានកិរិយានៅក្នុងសេចក្តីប្រតិបត្តិនោះ ដោយច្រើនហើយ ចិត្តរមែងជ្រះថ្លាក្នុងអាយតនៈគឺហេតុ កាលបើសេចក្តីជ្រះថ្លាមានហើយ អរិយសាវ័កនោះក៏ដល់អានេញ្ជធម៌[2] ក្នុងកាលឥឡូវនេះផង ចុះចិត្តស៊ប់ដោយបញ្ញាផង ។ លុះមានខន្ធកាយបែកធ្លាយទៅ បន្ទាប់អំពីមរណៈ សំវត្តនិកវិញ្ញាណនោះ ក៏ទំនងដល់នូវអានេញ្ជធម៌ ដោយហេតុណា ហេតុនុ៎ះឯង តែងមាន ។ ម្នាលភិក្ខុទាំងឡាយ នេះអានេញ្ជសប្បាយប្បដិបទា ទី ២ ។

---

១ បានខាងឧបាទារូប ២៤ ។ ២ ក្នុងទីនេះសំដៅយកអាកាសានញ្ចាយតនជ្ឈាន ។

(៨៤) បុន ចបរំ ភិក្ខវេ អរិយសាវកោ ឥតិ បដិសញ្ចិក្ខតិ យេ ច ទិដ្ឋធម្មិកា កាមា យេ ច សម្បរាយិកា កាមា យា ច ទិដ្ឋធម្មិកា កាមសញ្ញា យា ច សម្បរាយិកា កាមសញ្ញា យេ ច ទិដ្ឋធម្មិកា រូបា យេ ច សម្បរាយិកា រូបា យា ច ទិដ្ឋធម្មិកា រូបសញ្ញា យា ច សម្បរាយិកា រូបសញ្ញា ឧភយមេតំ អនិច្ចំ យទនិច្ចំ តំ[១] នាលំ អភិនន្ទិតុំ នាលំ អភិវទិតុំ នាលំ អជ្ឈោសិតុន្តិ ។ តស្ស ឯវំ បដិបន្នស្ស តព្ពហុលវិហារិនោ អាយតនេ ចិត្តំ បសីទតិ សម្បសាទេ សតិ ឯតរហិ វា អានេញ្ជំ សមាបជ្ជតិ បញ្ញាយ វា អធិមុច្ចតិ កាយស្ស ភេទា បរម្មរណា ឋានមេតំ វិជ្ជតិ យន្តំ សំវត្តនិកំ វិញ្ញាណំ អស្ស អានេញ្ជូបគំ ។ អយំ ភិក្ខវេ តតិយា អានេញ្ជសប្បាយា បដិបទា អក្ខាយតិ ។

១ ម. យទនិច្ចំ តន្តំ ន ទំស្សតិ ។

(៨៤) ម្នាលភិក្ខុទាំងឡាយ មួយទៀត អរិយសាវក តែងពិចារណាដូច្នេះថា កាមណា ដែលប្រព្រឹត្តទៅ ក្នុងបច្ចុប្បន្នក្តី កាមណា ដែលប្រព្រឹត្តទៅក្នុងបរលោកក្តី កាមសញ្ញាណា ដែលប្រព្រឹត្តទៅក្នុងបច្ចុប្បន្នក្តី កាមសញ្ញាណា ដែលប្រព្រឹត្តទៅ ក្នុងបរលោកក្តី រូបណា ដែលប្រព្រឹត្តទៅក្នុងបច្ចុប្បន្នក្តី រូបណា ដែលប្រព្រឹត្តទៅក្នុងបរលោកក្តី រូបសញ្ញាណា ដែលប្រព្រឹត្តទៅក្នុងបច្ចុប្បន្នក្តី រូបសញ្ញាណា ដែលប្រព្រឹត្តទៅក្នុងបរលោកក្តី ទាំងមួយគូនុ៎ះ ជារបស់មិនទៀង ធម្មជាតណាមិនទៀង ធម្មជាតនោះ មិនគួរដើម្បីត្រេកអរទេ មិនគួរដើម្បីសរសើរ មិនគួរដើម្បីប្រកាន់ទុកទេ ។ កាលបើអរិយសាវកនោះ ប្រតិបត្តិយ៉ាងនេះ មានកិរិយានៅក្នុងសេចក្តីប្រតិបត្តិនោះ ដោយច្រើនហើយ ចិត្តក៏រមែងជ្រះថ្លាក្នុងអាយតនៈគឺហេតុ កាលបើសេចក្តីជ្រះថ្លាមានហើយ អរិយសាវកនោះ ក៏ដល់នូវអានេញ្ជធម៌ (១) ក្នុងកាលឥឡូវនេះផង ចុះចិត្តស៊ប់ដោយបញ្ញាផង ។ លុះមានរាងកាយបែកធ្លាយទៅ បន្ទាប់អំពីមរណៈ សំវត្តនិកវិញ្ញាណនោះ ក៏នឹងដល់នូវអានេញ្ជធម៌ ដោយហេតុណា ហេតុនុ៎ះ រមែងមាន ។ ម្នាលភិក្ខុទាំងឡាយ នេះ អានេញ្ជសប្បាយប្បដិបទា ទី ៣ ។

---

១ ក្នុងទីនេះសំដៅយក វិញ្ញាណញ្ចាយតនជ្ឈាន ។

(៨៥) បុន ចបរំ ភិក្ខវេ អរិយសាវកោ ឥតិ បដិសញ្ចិក្ខតិ យេ ច ទិដ្ឋធម្មិកា កាមា យេ ច សម្បរាយិកា កាមា យា ច ទិដ្ឋធម្មិកា កាមសញ្ញា យា ច សម្បរាយិកា កាមសញ្ញា យេ ច ទិដ្ឋធម្មិកា រូបា យេ ច សម្បរាយិកា រូបា យា ច ទិដ្ឋធម្មិកា រូបសញ្ញា យា ច សម្បរាយិកា រូបសញ្ញា យា ច អានេញ្ជសញ្ញា សព្វា សញ្ញា យត្ថេតា អបរិសេសា និរុជ្ឈន្តិ ឯតំ សន្តំ ឯតំ បណីតំ យទិទំ អាកិញ្ចញ្ញាយតនន្តិ ។ តស្ស ឯវំ បដិបន្នស្ស តព្ពហុលវិហារិនោ អាយតនេ ចិត្តំ បសីទតិ សម្បសាទេ សតិ ឯតរហិ វា អាកិញ្ចញ្ញាយតនំ សមាបជ្ជតិ បញ្ញាយ វា អធិមុច្ចតិ ។ កាយស្ស ភេទា បរម្មរណា ឋានមេតំ វិជ្ជតិ យន្តំ សំវត្តនិកំ វិញ្ញាណំ អស្ស អាកិញ្ចញ្ញាយតនូបគំ ។ អយំ ភិក្ខវេ បឋមា អាកិញ្ចញ្ញាយតនសប្បាយា បដិបទា អក្ខាយតិ ។

[៨៩] ម្នាលភិក្ខុទាំងឡាយ មួយទៀត អរិយសាវ័ក តែងពិចារណាដូច្នេះថា កាមណា ដែលប្រព្រឹត្តទៅ ក្នុងបច្ចុប្បន្នក្តី កាមណា ដែលប្រព្រឹត្តទៅក្នុងបរលោកក្តី កាមសញ្ញាណា ដែលប្រព្រឹត្តទៅក្នុងបច្ចុប្បន្នក្តី កាមសញ្ញាណា ដែលប្រព្រឹត្តទៅក្នុងបរលោកក្តី រូបណា ដែលប្រព្រឹត្តទៅក្នុងបច្ចុប្បន្នក្តី រូបណា ដែលប្រព្រឹត្តទៅ ក្នុងបរលោកក្តី រូបសញ្ញាណា ដែលប្រព្រឹត្តទៅក្នុងបច្ចុប្បន្នក្តី រូបសញ្ញាណា ដែលប្រព្រឹត្តទៅក្នុងបរលោកក្តី អានេញ្ជសញ្ញាណាក្តី សញ្ញាទាំងអស់នេះ រលត់ឥតមានសេសសល់ ក្នុងធម្មជាតណា ធម្មជាតនុ៎ះជាល្អិត ធម្មជាតនុ៎ះជាឧត្តម គឺអាកិញ្ចញ្ញាយតនជ្ឈាន ។ កាលបើអរិយសាវ័កនោះ ប្រតិបត្តិយ៉ាងនេះ មានកិរិយាទៅក្នុងសេចក្តីប្រតិបត្តិនោះដោយច្រើនហើយ ចិត្តក៏រមែងជ្រះថ្លា ក្នុងអាយតនៈគឺហេតុ កាលបើសេចក្តីជ្រះថ្លាមានហើយ អរិយសាវ័កនោះ ក៏ដល់នូវអាកិញ្ចញ្ញាយតនជ្ឈាន ក្នុងកាលឥឡូវនេះផង ចុះចិត្តស៊ប់ដោយបញ្ញាផង ។ លុះមានកាយបែកធ្លាយទៅ បន្ទាប់អំពីមរណៈ សំវត្តនិកវិញ្ញាណនោះ គប្បីដល់នូវអាកិញ្ចញ្ញាយតនជ្ឈាន ដោយហេតុណា ហេតុនុ៎ះ រមែងមាន ។ ម្នាលភិក្ខុទាំងឡាយ នេះ អាកិញ្ចញ្ញាយតនសប្បាយប្បដិបទា ទី ១ ។

(៨៦) បុន ចបរំ ភិក្ខវេ អរិយសាវកោ អរញ្ញគតោ វា រុក្ខមូលគតោ វា សុញ្ញាគារគតោ វា ឥតិ បដិសញ្ចិក្ខតិ សុញ្ញមិទំ អត្តេន វា អត្តនិយេន វាតិ ។ តស្ស ឯវំ បដិបន្នស្ស តព្ពហុលវិហារិនោ អាយតនេ ចិត្តំ បសីទតិ សម្ប-សាទេ សតិ ឯតរហិ វា អាកិញ្ចញ្ញាយតនំ សមាបជ្ជតិ បញ្ញាយ វា អធិមុច្ចតិ ។ កាយស្ស ភេទា បរម្មរណា ឋានមេតំ វិជ្ជតិ យន្តំ សំវត្តនិកំ វិញ្ញាណំ អស្ស អាកិញ្ចញ្ញាយតនូបគំ ។ អយំ ភិក្ខវេ ទុតិយា អាកិញ្ចញ្ញាយតនសប្បាយា បដិប-ទា អក្ខាយតិ ។

(៨៦) ម្នាលភិក្ខុទាំងឡាយ មួយទៀត អរិយសាវក ទៅនៅក្នុងព្រៃក្តី ទៅនៅក្រោមម្លប់ឈើក្តី ទៅនៅក្នុងផ្ទះដ៏ស្ងាត់ក្តី តែងពិចារណាដូច្នេះថា ធម្មជាតនេះ សូន្យ ចាកខ្លួន ឬចាករបស់ដែលអាស្រ័យនឹងខ្លួនក្តី ។ កាលបើអរិយសាវកនោះ ប្រតិបត្តិយ៉ាងនេះ មានកិរិយានៅក្នុងសេចក្តីប្រតិបត្តិនោះដោយច្រើនហើយ ចិត្តក៏រមែងជ្រះថ្លាក្នុងអាយតនៈគឺហេតុ កាលបើសេចក្តីជ្រះថ្លាមានហើយ អរិយសាវកនោះក៏ដល់នូវអាកិញ្ចញ្ញាយតនជ្ឈានក្នុងកាលឥឡូវនេះផង ចុះចិត្តស៊ប់ដោយបញ្ញាផង ។ លុះមានកាយបែកធ្លាយទៅ បន្ទាប់អំពីមរណៈ សំវត្តនិកវិញ្ញាណនោះ ក៏នឹងដល់នូវអាកិញ្ចញ្ញាយតនជ្ឈាន ដោយហេតុណា ហេតុនុ៎ះ រមែងមាន ។ ម្នាលភិក្ខុទាំងឡាយ នេះអាកិញ្ចញ្ញាយតនសប្បាយប្បដិបទា ទី ២ ។

(៨៧) បុន ចបរំ ភិក្ខវេ អរិយសាវកោ ឥតិ បដិសញ្ចិក្ខតិ ណាហំ ក្វចិនិ ន កស្សចិ(១) កិញ្ចនតស្មិំ ន ច មម ក្វចិនិ កិស្មិញ្ចិ កិញ្ចនំ នត្ថីតិ ។ តស្ស ឯវំ បដិបន្នស្ស តព្ពហុលវិហារិនោ អាយតនេ ចិត្តំ បសីទតិ សម្បសាទេ សតិ ឯតរហិ វា អាកិញ្ចញ្ញាយតនំ សមាបជ្ជតិ បញ្ញាយ វា អធិមុច្ចតិ ។ កាយស្ស ភេទា បរម្មរណា ឋានមេតំ វិជ្ជតិ យំ តំ សំវត្តនិកំ វិញ្ញាណំ អស្ស អាកិញ្ចញ្ញាយតនូបគំ ។ អយំ ភិក្ខវេ តតិយា អាកិញ្ចញ្ញាយតនសប្បាយា បដិបទា អក្ខាយតិ ។

---

១ ឱ. ម. ក្វចនិ កស្សចីតិ ទិស្សតិ ។

(៨៧) ម្នាលភិក្ខុទាំងឡាយ មួយទៀត អរិយសាវ័ក តែងពិចារណាដូច្នេះថា អាត្មាអញមិនបានឃើញ (នូវខ្លួន) ក្នុងទីបន្តិចបន្តួច មិនបានឃើញ ( នូវខ្លួន ) ដែលគួរបង្អោនទៅកាន់កង្វល់ របស់បុគ្គលណាមួយទេ មួយទៀត មិនបានឃើញ (នូវខ្លួន) របស់បុគ្គលដទៃក្នុងទីណាមួយ ឯកង្វល់របស់អាត្មាអញមិនមានឡើយ ។ កាលបើអរិយសាវ័កនោះ ប្រតិបត្តិយ៉ាងនេះ មានកិរិយានៅក្នុងសេចក្តីប្រតិបត្តិនោះ ដោយច្រើនហើយ ចិត្តក៏រមែងជ្រះថ្លា ក្នុងអាយតនៈគឺហេតុ កាលបើសេចក្តីជ្រះថ្លាមានហើយ អរិយសាវ័កនោះ ក៏ដល់នូវអាកិញ្ចញ្ញាយតនជ្ឈានក្នុងកាលឥឡូវនេះផង ចុះចិត្តស៊ប់ដោយបញ្ញាផង ។ លុះមានកាយបែកធ្លាយទៅ បន្ទាប់អំពីមរណៈ សំវត្តនិកវិញ្ញាណនោះ ក៏នឹងដល់នូវអាកិញ្ចញ្ញាយតនជ្ឈាន ដោយហេតុណា ហេតុនុ៎ះ រមែងមាន ។ ម្នាលភិក្ខុទាំងឡាយ នេះអាកិញ្ចញ្ញាយតនសប្បាយប្បដិបទា ទី ៣ ។

(៨៨) បុន ចបរំ ភិក្ខវេ អរិយសាវកោ ឥតិ បដិសញ្ចិក្ខតិ យេ ច ទិដ្ឋធម្មិកា កាមា យេ ច សម្បរាយិកា កាមា យា ច ទិដ្ឋធម្មិកា កាមសញ្ញា យា ច សម្បរាយិកា កាមសញ្ញា យេ ច ទិដ្ឋធម្មិកា រូបា យេ ច សម្បរាយិកា រូបា យា ច ទិដ្ឋធម្មិកា រូបសញ្ញា យា ច សម្បរាយិកា រូបសញ្ញា យា ច អានេញ្ជសញ្ញា យា ច អាកិញ្ចញ្ញាយតនសញ្ញា សព្វា សញ្ញា យត្ថេតា អបរិសេសា និរុជ្ឈន្តិ ឯតំ សន្តំ ឯតំ បណីតំ យទិទំ នេវសញ្ញានាសញ្ញាយតនន្តិ ។ តស្ស ឯវំ បដិបន្នស្ស តព្វហុលវិហារិនោ អាយតនេ ចិត្តំ បសីទតិ សម្បសាទេ សតិ ឯតរហិ វា នេវសញ្ញានាសញ្ញាយតនំ សមាបជ្ជតិ បញ្ញាយ វា អធិមុច្ចតិ ។ កាយស្ស ភេទា បរម្មរណា ឋានមេតំ វិជ្ជតិ យន្តំ សំវត្តនិកំ វិញ្ញាណំ អស្ស នេវសញ្ញានាសញ្ញាយតនូបគំ ។ អយំ ភិក្ខវេ នេវសញ្ញានាសញ្ញាយតនសប្បាយា បដិបទា អក្ខាយតីតិ ។

(៨៨) ម្នាលភិក្ខុទាំងឡាយ មួយទៀត អរិយសាវក តែងពិចារណាដូច្នេះថា កាមណា ដែលប្រព្រឹត្តទៅ ក្នុងបច្ចុប្បន្នក្តី កាមណា ដែលប្រព្រឹត្តទៅក្នុងបរលោកក្តី កាមសញ្ញាណា ដែលប្រព្រឹត្តទៅក្នុងបច្ចុប្បន្នក្តី កាមសញ្ញាណា ដែលប្រព្រឹត្តទៅក្នុងបរលោកក្តី រូបណា ដែលប្រព្រឹត្តទៅក្នុងបច្ចុប្បន្នក្តី រូបណា ដែលប្រព្រឹត្តទៅក្នុងបរលោកក្តី រូបសញ្ញាណា ដែលប្រព្រឹត្តទៅក្នុងបច្ចុប្បន្នក្តី រូបសញ្ញាណា ដែលប្រព្រឹត្តទៅក្នុងបរលោកក្តី អានេញ្ជសញ្ញាណាក្តី អាកិញ្ចញ្ញាយតនសញ្ញាណាក្តី សញ្ញាទាំងអស់នោះឯង តែងរលត់ឥតមានសេសសល់ ក្នុងធម្មជាតណា ធម្មជាតនុ៎ះដ៏ល្អិត ធម្មជាតនុ៎ះដ៏ឧត្តម គឺនេវសញ្ញានាសញ្ញាយតនជ្ឈាន ។ កាលបើអរិយសាវកនោះប្រតិបត្តិយ៉ាងនេះ មានកិរិយានៅក្នុងសេចក្តីប្រតិបត្តិនោះដោយច្រើនហើយ ចិត្តក៏រមែងជ្រះថ្លា ក្នុងអាយតនៈគឺហេតុ កាលបើសេចក្តីជ្រះថ្លាមានហើយ អរិយសាវកនោះ ក៏ដល់នូវនេវសញ្ញានាសញ្ញាយតនជ្ឈាន ក្នុងកាលឥឡូវនេះផង ចុះចិត្តស៊ប់ដោយបញ្ញាផង ។ លុះមានកាយបែកធ្លាយទៅ បន្ទាប់អំពីមរណៈ សំវត្តនិកវិញ្ញាណនោះ ក៏នឹងដល់នូវនេវសញ្ញានាសញ្ញាយតនជ្ឈាន ដោយហេតុណា ហេតុនុ៎ះរមែងមាន ។ ម្នាលភិក្ខុទាំងឡាយ នេះនេវសញ្ញានាសញ្ញាយតនសប្បាយប្បដិបទា ។

(៨៩) ឯវំ វុត្តេ អាយស្មា អានន្ទោ ភគវន្តំ ឯតទវោច ឥធ ភន្តេ ភិក្ខុ ឯវំ បដិបន្នោ ហោតិ នោចស្ស នោ ច មេ សិយា ន មេ ភវិស្សតិ[1] យទត្ថិ យម្ភូតំ[2] តំ បជហាមីតិ[3] ឧបេក្ខំ បដិលភតិ បរិនិព្ពាយេយ្យ នុ ខោ សោ ភន្តេ ភិក្ខុ ន វា បរិនិព្ពាយេយ្យាតិ ។ អបេត្ថេកច្ចោ អានន្ទ ភិក្ខុ បរិនិព្ពាយេយ្យ អបេត្ថេកច្ចោ ភិក្ខុ ន បរិនិព្ពាយេយ្យាតិ ។ កោ នុ ខោ ភន្តេ ហេតុ កោ បច្ចយោ យេនាបេត្ថេកច្ចោ ភិក្ខុ បរិនិព្ពាយេយ្យ អបេត្ថេកច្ចោ ភិក្ខុ ន បរិនិព្ពាយេយ្យាតិ ។

---

១ ឱ. ម. ន ភវិស្សតិ ន មេ ភវិស្សតីតិ ទិស្សន្តិ ។ ២ ឱ. ម. យំ ភូតំ ។ ៣ ឱ. ម. ឯត្ថន្តរេ ឯវន្តិ ទិស្សតិ ។

(៨៩) កាលបើព្រះមានព្រះភាគ ទ្រង់ត្រាស់យ៉ាងនេះហើយ ព្រះអានន្ទមានអាយុ ក៏ក្រាបបង្គំទូលចំពោះព្រះមានព្រះភាគ ដូច្នេះថា បពិត្រព្រះអង្គដ៏ចម្រើន ភិក្ខុក្នុងសាសនានេះ ជាអ្នកប្រតិបត្តិយ៉ាងនេះថា បើអាត្មាអញមិនបានធ្វើកម្មវដ្ដៈ ក្នុងកាលមុនទេ វិបាកវដ្ដៈក៏មិនគប្បីមានដល់អាត្មាអញក្នុងកាលឥឡូវនេះ បើអាត្មាអញមិនបានធ្វើកម្មវដ្ដៈក្នុងកាលឥឡូវនេះទេ វិបាកវដ្ដៈក៏នឹងមិនមានដល់អាត្មាអញក្នុងអនាគតកាល ខន្ធបញ្ចកៈណា ដែលមាន ដែលកើត ក្នុងកាលឥឡូវនេះ អាត្មាអញលះបង់នូវខន្ធបញ្ចកៈនោះ ភិក្ខុនោះបាននូវឧបេក្ខាយ៉ាងនេះ បពិត្រព្រះអង្គដ៏ចម្រើន ភិក្ខុនោះ គួររំលត់កិលេសបាន ឬមិនគួររំលត់កិលេសបានទេ ។ ម្នាលអានន្ទ ភិក្ខុខ្លះគួររំលត់កិលេសបាន ក្នុងឧបេក្ខានេះ ភិក្ខុខ្លះមិនគួររំលត់កិលេសបានក្នុងឧបេក្ខានេះទេ ។ បពិត្រព្រះអង្គដ៏ចម្រើន ចុះហេតុដូចម្ដេច បច្ច័យដូចម្ដេច ដែលនាំឲ្យភិក្ខុខ្លះ គួររំលត់កិលេសបានក្នុងឧបេក្ខានេះ ភិក្ខុខ្លះមិនគួររំលត់កិលេសបាន ក្នុងឧបេក្ខានេះ ។

(៩០) ឥធានន្ទ ភិក្ខុ ឯវំ បដិបន្នោ ហោតិ នោចស្ស នោ ច មេ សិយា ន មេ ភវិស្សតិ យទត្ថិ យម្ភូតំ តំ បជហាមីតិ ឧបេក្ខំ បដិលភតិ សោ តំ ឧបេក្ខំ អភិនន្ទតិ អភិវទតិ អជ្ឈោសាយ តិដ្ឋតិ តស្ស តំ ឧបេក្ខំ អភិនន្ទតោ អភិវទតោ អជ្ឈោសាយ តិដ្ឋតោ តន្និស្សិតំ ហោតិ វិញ្ញាណំ តទុបាទានំ សឧបាទានោ អានន្ទ ភិក្ខុ ន បរិនិព្វាយតីតិ ។ កហំ បន សោ ភន្តេ ភិក្ខុ ឧបាទិយមានោ ឧបាទិយតីតិ ។ នេវសញ្ញានាសញ្ញាយតនំ អានន្ទាតិ ។ ឧបាទានសេដ្ឋំ កិរ សោ ភន្តេ ភិក្ខុ ឧបាទិយមានោ ឧបាទិយតីតិ ។

(៩០) ម្នាលអានន្ទ ភិក្ខុក្នុងសាសនានេះ ជាអ្នកប្រតិបត្តិយ៉ាងនេះ ថា បើអាត្មាអញមិនបានធ្វើកម្មវដ្ដៈ ក្នុងកាលមុនទេ វិបាកវដ្ដៈក៏មិនគប្បីមានដល់អាត្មាអញ ក្នុងកាលឥឡូវនេះ បើអាត្មាអញមិនបានធ្វើកម្មវដ្ដៈក្នុងកាលឥឡូវនេះទេ វិបាកវដ្ដៈនឹងមិនមានដល់អាត្មាអញក្នុងអនាគតកាល ខន្ធបញ្ចកៈណាដែលមាន ដែលកើត ក្នុងកាលឥឡូវនេះ អាត្មាអញលះបង់នូវខន្ធបញ្ចកៈនោះ ភិក្ខុនោះបាននូវឧបេក្ខា (យ៉ាងនេះ) ភិក្ខុនោះក៏ត្រេកអរសរសើរនូវឧបេក្ខានោះ តាំងនៅដោយសេចក្ដីចូលចិត្តស៊ប់ កាលបើភិក្ខុនោះ ត្រេកអរសរសើរនូវឧបេក្ខានោះ តាំងនៅដោយសេចក្ដីចូលចិត្តស៊ប់ហើយ វិញ្ញាណណាដែលអាស្រ័យនូវវិបស្សនានោះ វិញ្ញាណនោះ ជាឧបាទាន[1] របស់ភិក្ខុនោះ ម្នាលអានន្ទ ភិក្ខុដែលប្រកបដោយឧបាទាន រមែងរំលត់កិលេសមិនបានឡើយ ។ បពិត្រព្រះអង្គដ៏ចម្រើន ចុះភិក្ខុនោះ កាលបើកាន់យកនូវបដិសន្ធិ តែងកាន់យកក្នុងទីណា ។ ម្នាលអានន្ទ ភិក្ខុនោះកាន់យកនូវបដិសន្ធិ ក្នុងនេវសញ្ញានាសញ្ញាយតនភព ។ បពិត្រព្រះអង្គដ៏ចម្រើន បានឮថា ភិក្ខុនោះកាលកាន់យកនូវបដិសន្ធិ តែងកាន់យកក្នុងភពដ៏ប្រសើរឬ ។

---

១ សេចក្ដីប្រកាន់មាំ សេចក្ដីអាស័យក្នុងវិបស្សនា ។

ឧបាទានសេដ្ឋំ សោ អានន្ទ ភិក្ខុ ឧបាទិយមានោ ឧបាទិយតិ ឧបាទានសេដ្ឋំ ហេតំ អានន្ទ យទិទំ នេវសញ្ញានាសញ្ញាយតនំ ។

(៩១) ឥធានន្ទ ភិក្ខុ ឯវំ បដិបន្នោ ហោតិ នោ ចស្ស នោ ច មេ សិយា ន មេ ភវិស្សតិ យទត្ថិ យំ ភូតំ តំ បជហាមីតិ ឧបេក្ខំ បដិលភតិ សោ តំ ឧបេក្ខំ នាភិនន្ទតិ នាភិវទតិ ន អជ្ឈោសាយ តិដ្ឋតិ តស្ស តំ ឧបេក្ខំ អនភិនន្ទតោ អនភិវទតោ អនជ្ឈោសាយ តិដ្ឋតោ ន តន្និស្សិតំ ហោតិ វិញ្ញាណំ(១) តទុបាទានំ អនុបាទានោ អានន្ទ ភិក្ខុ

១ ឱ. ម. ឯត្ថន្តរេ ន សន្តោ ទិស្សតិ ។

ម្នាលអានន្ទ ភិក្ខុនោះ កាលកាន់យកនូវបដិសន្ធិ តែងកាន់យកក្នុងភពដ៏ប្រសើរ ម្នាលអានន្ទ ឯភពដ៏ប្រសើរនុ៎ះ បានដល់នេវសញ្ញានាសញ្ញាយតនភព ។

(១១) ម្នាលអានន្ទ ភិក្ខុក្នុងសាសនានេះ ជាអ្នកប្រតិបត្តិយ៉ាងនេះ ថា បើអាត្មាអញមិនបានធ្វើកម្មវដ្ដៈក្នុងកាលមុនទេ វិបាកវដ្ដៈក៏មិនគប្បីមានដល់អាត្មាអញ ក្នុងកាលឥឡូវនេះ បើអាត្មាអញមិនបានធ្វើកម្មវដ្ដៈក្នុងកាលឥឡូវនេះទេ វិបាកវដ្ដៈក៏នឹងមិនមាន ដល់អាត្មាអញ ក្នុងអនាគតកាល ខន្ធបញ្ចកៈណា ដែលមាន ដែលកើត ក្នុងកាលឥឡូវនេះ អាត្មាអញលះបង់នូវខន្ធបញ្ចកៈនោះ ភិក្ខុនោះបាននូវឧបេក្ខា (យ៉ាងនេះ) តែភិក្ខុនោះមិនបានត្រេកអរ មិនបានសរសើរនូវឧបេក្ខានោះ មិនបានកាន់នៅដោយសេចក្ដីបូលចិត្តស៊ប់ កាលបើភិក្ខុនោះ មិនបានត្រេកអរ មិនបានសរសើរនូវឧបេក្ខានោះ មិនបានកាន់នៅដោយសេចក្ដីបូលចិត្តស៊ប់ វិញ្ញាណណាដែលមិនអាស្រ័យនូវវិបស្សនានោះ វិញ្ញាណនោះមិនមែនជាឧបាទានរបស់ភិក្ខុនោះឡើយ ម្នាលអានន្ទ ភិក្ខុមិនមានឧបាទាន

បរិនិព្វាយតីតិ ។ អច្ឆរិយំ ភន្តេ អព្ភុតំ ភន្តេ និស្សាយ និស្សាយ កិរ នោ ភន្តេ ភគវតា ឱឃស្ស និត្ថរណា[១] អក្ខាតា កតមោ បន ភន្តេ អរិយោ វិមោក្ខោតិ ។

(៩២) ឥធានន្ទ អរិយសាវកោ ឥតិ បដិសញ្ចិក្ខតិ យេ ច ទិដ្ឋធម្មិកា កាមា យេ ច សម្បរាយិកា កាមា យា ច ទិដ្ឋធម្មិកា កាមសញ្ញា យា ច សម្បរាយិកា កាមសញ្ញា យេ ច ទិដ្ឋធម្មិកា រូបា យេ ច សម្បរាយិកា រូបា យា ច ទិដ្ឋធម្មិកា រូបសញ្ញា យា ច សម្បរាយិកា រូបសញ្ញា យា ច អានេញ្ជសញ្ញា យា ច អាកិញ្ចញ្ញាយតនសញ្ញា យា ច នេវសញ្ញានាសញ្ញាយតនសញ្ញា ឯស សក្កាយោ យាវតា

---

១ ឱ. ម. ឱឃស្ស និត្ថរណា ។

រមែងរលត់កិលេសបាន ។ បពិត្រព្រះអង្គដ៏ចម្រើន អស្ចារ្យណាស់ បពិត្រព្រះអង្គដ៏ចម្រើន ចំឡែកណាស់ បពិត្រព្រះអង្គដ៏ចម្រើន ឮថា ព្រះមានព្រះភាគទ្រង់សំដែងធម៌ ជាគ្រឿងឆ្លងចាកឱឃៈ ដល់ខ្ញុំព្រះអង្គទាំងឡាយ ព្រោះអាស្រ័យរឿយៗ (នូវសមាបត្តិនោះ) បពិត្រព្រះអង្គដ៏ចម្រើន ចុះអរិយវិមោក្ខ តើដូចម្តេច ។

(៩២) ម្នាលអានន្ទ អរិយសាវក ក្នុងសាសនានេះ តែងពិចារណាដូច្នេះថា កាមណា ដែលប្រព្រឹត្តទៅក្នុងបច្ចុប្បន្នក្តី កាមណា ដែលប្រព្រឹត្តទៅក្នុងបរលោកក្តី កាមសញ្ញាណា ដែលប្រព្រឹត្តទៅក្នុងបច្ចុប្បន្នក្តី កាមសញ្ញាណា ដែលប្រព្រឹត្តទៅក្នុងបរលោកក្តី រូបណា ដែលប្រព្រឹត្តទៅក្នុងបច្ចុប្បន្នក្តី រូបណា ដែលប្រព្រឹត្តទៅក្នុងបរលោកក្តី រូបសញ្ញាណា ដែលប្រព្រឹត្តទៅក្នុងបច្ចុប្បន្នក្តី រូបសញ្ញាណា ដែលប្រព្រឹត្តទៅក្នុងបរលោកក្តី អានេញ្ជសញ្ញាណាក្តី អាកិញ្ចញ្ញាយតនសញ្ញាណាក្តី នេវសញ្ញានាសញ្ញាយតនសញ្ញាណាក្តី ទាំងអស់នេះ ឈ្មោះថាសក្កាយៈ (ចំណែកតេភូមិកវដ្តធម៌) ទាំងអម្បាលមានណាក៏ឈ្មោះថា

សក្កាយោ ឯតំ អមតំ យទិទំ អនុបាទា ចិត្តស្ស វិមោក្ខោ ។ ឥតិ ខោ អានន្ទ ទេសិតា មយា អានេញ្ជសប្បាយា បដិបទា ទេសិតា អាកិញ្ចញ្ញាយតនសប្បាយា បដិបទា ទេសិតា នេវសញ្ញានាសញ្ញាយតនសប្បាយា បដិបទា ទេសិតា និស្សាយ និស្សាយ ឱឃស្ស និត្ថរណា អរិយោ វិមោក្ខោ ។ យំ ខោ អានន្ទ សត្ថារា ករណីយំ សាវកានំ ហិតេសិនា អនុកម្បកេន អនុកម្បំ ឧបាទាយ កតំ វោ តំ មយា ឯតានិ អានន្ទ រុក្ខមូលានិ ឯតានិ សុញ្ញាគារានិ ។ ឈាយថានន្ទ មា បមាទត្ថ មា បច្ឆា វិប្បដិសារិនោ អហុវត្ថ អយំ វោ អម្ហាកំ អនុសាសនីតិ ។ ឥទមវោច ភគវា អត្តមនោ អាយស្មា អានន្ទោ ភគវតោ ភាសិតំ អភិនន្ទីតិ ។

អានេញ្ជសប្បាយសុត្តំ ឆដ្ឋំ និដ្ឋិតំ ។

សក្កាយៈដែរ សភាពដែលធ្វើចិត្តឲ្យរួចចាកកិលេស ព្រោះមិនមានប្រកាន់មាំ នុ៎ះឈ្មោះថា អមតៈ ។ ម្នាលអានន្ទ អានេញ្ជសប្បាយប្បដិបទា ដែលតថាគតបានសំដែងហើយក្តី អាកិញ្ចញ្ញាយតនសប្បាយប្បដិបទា ដែលតថាគតបានសំដែងហើយក្តី នេវសញ្ញានាសញ្ញាយតនសប្បាយប្បដិបទា ដែលតថាគតបានសំដែងហើយក្តី ធម៌ជាគ្រឿងឆ្លងចាកឱឃៈ ព្រោះអាស្រ័យរឿយ ៗ (នូវសមាបត្តិនោះ) ដែលតថាគតបានសំដែងហើយក្តី ដោយប្រការដូច្នេះ ឈ្មោះថា អរិយវិមោក្ខ ។ ម្នាលអានន្ទ អំពើណាដែលព្រះសាស្តាជាអ្នកស្វែងរកនូវប្រយោជន៍ ជាអ្នកអនុគ្រោះ គប្បីធ្វើដល់ពួកសាវ័ក ព្រោះអាស្រ័យសេចក្តីអនុគ្រោះ អំពើនោះ តថាគតបានធ្វើហើយដល់អ្នកទាំងឡាយ ម្នាលអានន្ទ ទីទាំងអម្បាលនេះ ហៅថា រុក្ខមូល ទីទាំងអម្បាលនេះ ហៅថា សុញ្ញាគារដ្ឋាន ។ ម្នាលអានន្ទ អ្នកទាំងឡាយ ចូរចម្រើនឈាន ចូរកុំប្រមាទ ចូរកុំមានសេចក្តីស្តាយក្រោយ ក្នុងកាលជាខាងក្រោយឡើយ នេះជាពាក្យប្រៀនប្រដៅនូវអ្នកទាំងឡាយ របស់តថាគត ។ លុះព្រះមានព្រះភាគទ្រង់សំដែងសូត្រនេះចប់ហើយ ព្រះអានន្ទមានអាយុ មានសេចក្តីត្រេកអរ រីករាយហើយនឹងភាសិត របស់ព្រះមានព្រះភាគ ។

ចប់ អានេញ្ជសប្បាយសូត្រ ទី ៦ ។

## សត្តមំ គណកមោគ្គល្លានសុត្តំ

(៩៣) ឯវំមេ សុតំ ។ ឯកំ សមយំ ភគវា សាវត្ថិយំ វិហរតិ បុព្វារាមេ មិគារមាតុ បាសាទេ ។ អថខោ គណកមោគ្គល្លានោ ព្រាហ្មណោ យេន ភគវា តេនុបសង្កមិ ឧបសង្កមិត្វា ភគវតា សទ្ធឹ សម្មោទិ សម្មោទនីយំ កថំ សារណីយំ វីតិសារេត្វា ឯកមន្តំ និសីទិ ។ ឯកមន្តំ និសិន្នោ ខោ គណកមោគ្គល្លានោ ព្រាហ្មណោ ភគវន្តំ ឯតទវោច សេយ្យថាបិ ភោ គោតម ឥមស្ស មិគារមាតុ បាសាទស្ស ទិស្សតិ អនុបុព្វសិក្ខា អនុបុព្វកិរិយា អនុបុព្វបដិបទា យទិទំ យាវ បច្ឆិមា សោបានកឡេវរា[1] ឥមេសម្បិ ហិ ភោ គោតម ព្រាហ្មណានំ ទិស្សតិ អនុបុព្វសិក្ខា អនុបុព្វកិរិយា អនុបុព្វបដិបទា យទិទំ អជ្ឈេនេ ឥមេសម្បិ ហិ ភោ គោតម ឥស្សាសានំ ទិស្សតិ

---

១ ឱ. សោបានកឡេវរា ។

# គណកមោគ្គល្លានសូត្រ ទី ៧

(៩៣) ខ្ញុំបានស្តាប់មក យ៉ាងនេះ ។ សម័យមួយ ព្រះមានព្រះភាគទ្រង់គង់ក្នុងមិគារមាតុប្រាសាទ(១) ក្នុងបុព្វារាម ជិតក្រុងសាវត្ថី ។ គ្រានោះឯង ព្រាហ្មណ៍ឈ្មោះគណកមោគ្គល្លាន ចូលទៅគាល់ព្រះមានព្រះភាគ លុះចូលទៅដល់ហើយ ក៏ធ្វើសេចក្តីរីករាយជាមួយនឹងព្រះមានព្រះភាគ លុះបញ្ចប់ពាក្យដែលគួររីករាយ និងពាក្យដែលគួររលឹក ហើយអង្គុយក្នុងទីសមគួរ ។ លុះគណកមោគ្គល្លានព្រាហ្មណ៍អង្គុយក្នុងទីសមគួរហើយ ក៏ក្រាបបង្គំទូលព្រះមានព្រះភាគ ដូច្នេះថា បពិត្រព្រះគោតមដ៏ចម្រើន មិគារមាតុប្រាសាទនេះ ប្រាកដជាមានការសិក្សាជាលំដាប់ មានការធ្វើជាលំដាប់ មានផ្លូវសម្រាប់ដើរទៅជាលំដាប់ គឺគិតតាំងអំពីកាំជណ្តើរជាន់ក្រោមបំផុតឡើងទៅ បពិត្រព្រះគោតមដ៏ចម្រើន ឯពួកព្រាហ្មណ៍ទាំងនេះ ក៏ប្រាកដជាមានការសិក្សាជាលំដាប់ មានការធ្វើជាលំដាប់ មានបដិបទាជាលំដាប់ក្នុងការរៀននូវវេទមន្ត បពិត្រព្រះគោតមដ៏ចម្រើន ឯពួកខ្មាន់ធ្នូទាំងនេះប្រាកដ

---

១ ប្រាសាទរបស់នាងវិសាខា ជាមាតានៃមិគារកុមារ ។

អនុបុព្វសិក្ខា អនុបុព្វកិរិយា អនុបុព្វបដិបទា យទិទំ ឥស្សត្ថេ អម្ហាកម្បិ ហិ ភោ គោតម គណកានំ គណនាជីវានំ ទិស្សតិ អនុបុព្វសិក្ខា អនុបុព្វកិរិយា អនុបុព្វបដិបទា យទិទំ សង្ខានេ មយំ ហិ ភោ គោតម អន្តេវាសឹ លភិត្វា បឋមំ ឯវំ គណាបេម ឯកំ ឯកកំ ទ្វេ ទុកា តីណិ តិកា ចត្តារិ ចតុក្កា បញ្ច បញ្ចកា ឆ ឆក្កា សត្ត សត្តកា អដ្ឋ អដ្ឋកា នវ នវកា ទស ទសកាតិ សតម្បិ មយំ ភោ គោតម គណាបេម[១] សក្កា នុ ខោ ភោ គោតម ឥមស្មឹបិ ធម្មវិនយេ ឯវមេវ អនុបុព្វសិក្ខា អនុបុព្វកិរិយា អនុបុព្វបដិបទា បញ្ញាបេតុន្តិ ។

---

១ ឯត្ថន្តរេ ភិយ្យោបិ គណាបេមាតិ កត្ថចិ អម្ហាកំ បោត្ថកេ ទិស្សតិ ។

ជាមានការសិក្សាជាលំដាប់ មានការធ្វើជាលំដាប់ មានបដិបទាជាលំដាប់ ក្នុងវិជ្ជារបស់ខ្លួនឬ បពិត្រព្រះគោតមដ៏ចម្រើន ឯយើងទាំងឡាយ ជាអ្នករាប់[១] អ្នកចិញ្ចឹមជីវិតដោយការរាប់ ក៏ប្រាកដជាមានការសិក្សាជាលំដាប់ មានការធ្វើជាលំដាប់ មានបដិបទាជាលំដាប់ ក្នុងការរាប់ បពិត្រព្រះគោតមដ៏ចម្រើន ព្រោះថា យើងទាំងឡាយបាននាំកូនសិស្សទាំងឡាយ រមែងបង្រៀនឲ្យរាប់ជាដំបូងយ៉ាងនេះថា មួយ ចំនួនមួយ ពីរ ចំនួនពីរ បី ចំនួនបី បួន ចំនួនបួន ប្រាំ ចំនួនប្រាំ ប្រាំមួយ ចំនួនប្រាំមួយ ប្រាំពីរ ចំនួនប្រាំពីរ ប្រាំបី ចំនួនប្រាំបី ប្រាំបួន ចំនួនប្រាំបួន ដប់ ចំនួនដប់ បពិត្រព្រះគោតមដ៏ចម្រើន យើងទាំងឡាយបង្រៀនឲ្យរាប់ដល់មួយរយក៏មាន យ៉ាងណាមិញ បពិត្រព្រះគោតមដ៏ចម្រើន ចុះព្រះអង្គអាចដើម្បីបញ្ញត្តនូវការសិក្សាជាលំដាប់ ការធ្វើជាលំដាប់ បដិបទាជាលំដាប់ ក្នុងធម្មវិន័យនេះបាន យ៉ាងនោះដែរឬ ។

---

១ ជាអ្នកចេះនឹងរៀនរាប់ ។

(៩៧) សក្កា ព្រាហ្មណ ឥមស្មឹ ធម្មវិនយេ អនុបុព្វសិក្ខា អនុបុព្វកិរិយា អនុបុព្វបដិបទា បញ្ញាបេតុំ ។ សេយ្យថាបិ ព្រាហ្មណ ទក្ខោ អស្សទមកោ ភទ្ទំ(១) អស្សាជានីយំ លភិត្វា បឋមេនេវ មុខាធានេ ការណំ ការេតិ អថ ឧត្តរឹ ការណំ ការេតិ ឯវមេវ ខោ ព្រាហ្មណ តថាគតោ បុរិសទម្មំ លភិត្វា បឋមំ ឯវំ វិនេតិ ឯហិ ត្វំ ភិក្ខុ សីលវា ហោហិ បាតិមោក្ខសំវរសំវុតោ វិហរាហិ អាចារគោចរសម្បន្នោ អណុមត្តេសុ វជ្ជេសុ ភយទស្សាវី សមាទាយ សិក្ខស្សុ សិក្ខាបទេសូតិ ។

(៩៨) យតោ ខោ ព្រាហ្មណ ភិក្ខុ សីលវា ហោតិ បាតិមោក្ខសំវរសំវុតោ វិហរតិ អាចារគោចរសម្បន្នោ អណុមត្តេសុ វជ្ជេសុ ភយទស្សាវី សមាទាយ សិក្ខតិ សិក្ខាបទេសុ តមេនំ តថាគតោ ឧត្តរឹ វិនេតិ ឯហិ ត្វំ ភិក្ខុ ឥន្ទ្រិយេសុ គុត្តទ្វារោ ហោហិ ចក្ខុនា រូបំ ទិស្វា

---

១ ម. ភទ្រំ ។

(៩៦) ព្រះអង្គត្រាស់ថា ម្នាលព្រាហ្មណ៍ តថាគតអាចដើម្បីបញ្ញត្តនូវការសិក្សាជាលំដាប់ ការធ្វើជាលំដាប់ បដិបទាជាលំដាប់ ក្នុងធម្មវិន័យនេះបាន ។ ម្នាលព្រាហ្មណ៍ បុរសអ្នកបង្ហាត់សេះជាអ្នកឈ្លាសវៃ បាននូវសេះអាជានេយ្យដ៏ល្អ តែងបង្វឹកបង្ហាត់ដោយខ្សែបង្ហៀរជាដំបូង រួចបង្វឹកបង្ហាត់តទៅជាលំដាប់ យ៉ាងណាមិញ ម្នាលព្រាហ្មណ៍ តថាគត បាននូវបុរសដែលគួរទូន្មាន រមែងទូន្មានជាដំបូង យ៉ាងនេះថា ម្នាលភិក្ខុ អ្នកចូរមក ចូរជាបុគ្គលមានសីល ចូរជាអ្នកសង្រួមក្នុងបាតិមោក្ខសំវរៈ ជាអ្នកបរិបូណ៌ដោយអាចារៈនិងគោចរៈ ជាអ្នកឃើញនូវភ័យក្នុងទោសទាំងឡាយ សូម្បីតែបន្តិចបន្តួច ចូរសមាទានសិក្សាក្នុងសិក្ខាបទទាំងឡាយ ក៏យ៉ាងនោះឯង ។

(៩៧) ម្នាលព្រាហ្មណ៍ កាលណាបើភិក្ខុជាអ្នកមានសីលសង្រួមក្នុងបាតិមោក្ខសំវរៈ បរិបូណ៌ដោយអាចារៈនិងគោចរៈ ឃើញនូវភ័យក្នុងទោសទាំងឡាយ សូម្បីតែបន្តិចបន្តួច សមាទានសិក្សាក្នុងសិក្ខាបទទាំងឡាយរួចហើយ តថាគត ក៏ទូន្មានភិក្ខុនោះតទៅថា ម្នាលភិក្ខុ អ្នកចូរមក ចូរជាអ្នកគ្រប់គ្រងក្នុងឥន្ទ្រិយទាំងឡាយ បើបានឃើញរូបដោយ

មា និមិត្តគ្គាហី ហោហិ មា អនុព្យញ្ជនគ្គាហី យត្វាធិករណមេនំ ចក្ខុន្ទ្រិយំ អសំវុតំ វិហរន្តំ អភិជ្ឈាទោមនស្សា បាបកា អកុសលា ធម្មា អន្វាស្សវេយ្យុំ តស្ស សំវរាយ បដិបជ្ជាហិ រក្ខាហិ ចក្ខុន្ទ្រិយំ ចក្ខុន្ទ្រិយេ សំវរំ អាបជ្ជាហិ[1] ។ សោតេន សទ្ទំ សុត្វា... ឃានេន គន្ធំ ឃាយិត្វា... ជិវ្ហាយ រសំ សាយិត្វា... កាយេន ផោដ្ឋព្វំ ផុសិត្វា... មនសា ធម្មំ វិញ្ញាយ មា និមិត្តគ្គាហី ហោហិ មា អនុព្យញ្ជនគ្គាហី យត្វាធិករណមេនំ មនិន្ទ្រិយំ អសំវុតំ វិហរន្តំ អភិជ្ឈាទោមនស្សា បាបកា អកុសលា ធម្មា អន្វាស្សវេយ្យុំ តស្ស សំវរាយ បដិបជ្ជាហិ រក្ខាហិ មនិន្ទ្រិយំ មនិន្ទ្រិយេ សំវរំ អាបជ្ជាហីតិ ។

១ ឱ. ចក្ខុន្ទ្រិយសំវរំ អាបជ្ជាតិ ទិស្សតិ ។

ចក្ខុ កុំកាន់យកនូវនិមិត្ត កុំកាន់យកនូវអនុព្យញ្ជនៈឡើយ អភិជ្ឈានិងទោមនស្សទាំងឡាយ ដែលជាអកុសលធម៌ដ៏លាមក គប្បីជាប់តាមនូវបុគ្គលដែលមិនបានសង្រួមនូវឥន្ទ្រិយគឺចក្ខុនុ៎ះ ព្រោះហេតុតែមិនបានសង្រួមនូវឥន្ទ្រិយគឺចក្ខុណា អ្នកចូរប្រតិបត្តិដើម្បីសង្រួមនូវឥន្ទ្រិយគឺចក្ខុនោះ ចូររក្សានូវឥន្ទ្រិយគឺចក្ខុ ចូរដល់នូវសេចក្តីសង្រួមក្នុងឥន្ទ្រិយគឺចក្ខុ ។ បានឮសំឡេងដោយត្រចៀក ... បានធុំក្លិនដោយច្រមុះ ... បានទទួលរសដោយអណ្តាត ... បានពាល់ត្រូវសម្ផស្សដោយកាយ ... បានដឹងច្បាស់ធម្មារម្មណ៍ដោយចិត្ត កុំកាន់យកនូវនិមិត្ត កុំកាន់យកនូវអនុព្យញ្ជនៈឡើយ អភិជ្ឈានិងទោមនស្ស ដែលជាអកុសលធម៌ដ៏លាមក គប្បីជាប់តាមនូវបុគ្គលដែលមិនបានសង្រួមនូវឥន្ទ្រិយគឺចិត្តនុ៎ះ ព្រោះហេតុតែមិនបានសង្រួមនូវឥន្ទ្រិយគឺចិត្តណា អ្នកចូរប្រតិបត្តិដើម្បីសង្រួមនូវឥន្ទ្រិយគឺចិត្តនោះ ចូររក្សានូវឥន្ទ្រិយគឺចិត្ត ចូរដល់នូវសេចក្តីសង្រួមក្នុងឥន្ទ្រិយគឺចិត្ត ។

(៩៦) យតោ ខោ ព្រាហ្មណ ភិក្ខុ ឥន្ទ្រិយេសុ គុត្តទ្វារោ ហោតិ តមេនំ តថាគតោ ឧត្តរឹ វិនេតិ ឯហិ ត្វំ ភិក្ខុ ភោជនេ មត្តញ្ញូ ហោហិ បដិសង្ខា យោនិសោ អាហារំ អាហារេយ្យាសិ នេវ ទវាយ ន មទាយ ន មណ្ឌនាយ ន វិភូសនាយ យាវទេវ ឥមស្ស កាយស្ស ឋិតិយា យាបនាយ វិហឹសុបរតិយា ព្រហ្មចរិយានុគ្គហាយ ឥតិ បុរាណញ្ច វេទនំ បដិហង្ខាមិ នវញ្ច វេទនំ ន ឧប្បាទេស្សាមិ យាត្រា ច មេ ភវិស្សតិ អនវជ្ជតា ច ផាសុវិហារោ ចាតិ ។

(៩៧) យតោ ខោ ព្រាហ្មណ ភិក្ខុ ភោជនេ មត្តញ្ញូ ហោតិ តមេនំ តថាគតោ ឧត្តរឹ វិនេតិ ឯហិ ត្វំ ភិក្ខុ ជាគរិយំ អនុយុត្តោ វិហរាហិ ទិវសំ ចង្កមេន និសជ្ជាយ អាវរណីយេហិ ធម្មេហិ ចិត្តំ បរិសោធេហិ

(៩៦) ម្នាលព្រាហ្មណ៍ កាលណាបើភិក្ខុបានរក្សាទ្វារក្នុងឥន្ទ្រិយទាំងឡាយហើយ តថាគត ក៏ទូន្មានភិក្ខុនោះតទៅថា ម្នាលភិក្ខុ អ្នកចូរមក ចូរជាអ្នកដឹងនូវប្រមាណក្នុងភោជន អ្នកគប្បីពិចារណាដោយឧបាយ ហើយបរិភោគអាហារ មិនគប្បីបរិភោគ ដើម្បីលេង មិនគប្បីបរិភោគ ដើម្បីសេចក្តីស្រវឹង មិនគប្បីបរិភោគ ដើម្បីប្រដាប់កាយ មិនគប្បីបរិភោគ ដើម្បីស្អិតស្អាងកាយ គប្បីបរិភោគ ដើម្បីតាំងនៅ ដើម្បីរស់នៅនៃកាយនេះជាកំណត់ ដើម្បីបំបាត់នូវសេចក្តីលំបាក ដើម្បីទំនុកបំរុងដល់ព្រហ្មចារ្យ គប្បីបរិភោគដោយគិតថា អាត្មាអញនឹងកំចាត់បង់នូវវេទនាចាស់ គឺសេចក្តីឃ្លានដែលមានហើយផង ទាំងញុំាងវេទនាថ្មី គឺឆ្អែតហួសប្រមាណ មិនឲ្យកើតឡើងបានផង កិរិយាប្រព្រឹត្តទៅនៃឥរិយាបថទាំង ៤ ក្តី សេចក្តីមិនមានទោស មានការមិនប្រមូសកាយប្រមូសចិត្តជាដើមក្តី កិរិយានៅសប្បាយ នឹងមានដល់អាត្មាអញ ។

(៩៧) ម្នាលព្រាហ្មណ៍ កាលណាបើ ភិក្ខុជាអ្នកដឹងប្រមាណក្នុងភោជនហើយ តថាគត ក៏ទូន្មានភិក្ខុនោះតទៅថា ម្នាលភិក្ខុ អ្នកចូរមក ចូរប្រកបរឿយ ៗ នូវសេចក្តីភ្ញាក់រលឹក ចូរជម្រះចិត្តឲ្យស្អាតចាកអាវរណីយធម៌ទាំងឡាយ[1] ដោយការចង្ក្រម ឬការអង្គុយក្នុងវេលាថ្ងៃ

---

១ ធម៌ជាគ្រឿងរាំងចិត្ត គួបផ្សំនឹងនីវរណៈនោះ ។

រត្តិយា បឋមំ យាមំ ចង្កមេន និសជ្ជាយ អាវរណីយេហិ ធម្មេហិ ចិត្តំ បរិសោធេហិ រត្តិយា មជ្ឈិមំ យាមំ ទក្ខិណេន បស្សេន សីហសេយ្យំ កប្បេយ្យាសិ បាទេ បាទំ អច្ចាធាយ សតោ សម្បជានោ ឧដ្ឋានសញ្ញំ មនសិករិត្វា រត្តិយា បច្ឆិមំ យាមំ បច្ចុដ្ឋាយ ចង្កមេន និសជ្ជាយ អាវរណីយេហិ ធម្មេហិ ចិត្តំ បរិសោធេហីតិ ។

(៥៨) យតោ ខោ ព្រាហ្មណ ភិក្ខុ ជាគរិយំ អនុយុត្តោ ហោតិ តមេនំ តថាគតោ ឧត្តរឹ វិនេតិ ឯហិ ត្វំ ភិក្ខុ សតិសម្បជញ្ញេន សមន្នាគតោ ហោហិ អភិក្កន្តេ បដិក្កន្តេ សម្បជានការី អាលោកិតេ វិលោកិតេ សម្បជានការី សម្មិញ្ជិតេ បសារិតេ សម្បជានការី សង្ឃាដិបត្តចីវរធារណេ សម្បជានការី អសិតេ បីតេ ខាយិតេ សាយិតេ សម្បជានការី

ចូរធ្វើចិត្តឲ្យស្អាតចាកអាវរណីយធម៌ទាំងឡាយ ដោយការចង្ក្រម ឬការអង្គុយក្នុងបឋមយាមនៃរាត្រី គប្បីសម្រេចនូវសីហសេយ្យា ផ្អៀងទៅខាងស្តាំ យកជើងត្រួតលើជើង មានសតិសម្បជញ្ញៈ ធ្វើទុកក្នុងចិត្តនូវឧដ្ឋានសញ្ញា (សំគាល់ថានឹងក្រោកឡើង) ក្នុងមជ្ឈិមយាមនៃរាត្រី លុះដល់បច្ឆិមយាមនៃរាត្រី ចូរក្រោកឡើង ធ្វើចិត្តឲ្យស្អាតចាកអាវរណីយធម៌ទាំងឡាយ ដោយការចង្ក្រម ឬការអង្គុយ ។

(៩៨) ម្នាលព្រាហ្មណ៍ កាលណាបើ ភិក្ខុបានប្រកបរឿយៗ នូវសេចក្តីភ្ញាក់រលឹកហើយ តថាគត ក៏ទូន្មានភិក្ខុនោះតទៅថា ម្នាលភិក្ខុ អ្នកចូរមក ចូរប្រកបដោយសតិសម្បជញ្ញៈ គឺធ្វើសេចក្តីដឹងខ្លួន ក្នុងការដើរឈានទៅមុខ ឈានថយក្រោយ ធ្វើសេចក្តីដឹងខ្លួន ក្នុងការក្រឡេកមើលត្រង់ ក្រឡេកមើលបំពៀង ធ្វើសេចក្តីដឹងខ្លួន ក្នុងការបត់អវយវៈចូល លាអវយវៈចេញ ធ្វើសេចក្តីដឹងខ្លួន ក្នុងការប្រើប្រាស់សង្ឃាដិ បាត្រ ចីវរ ធ្វើសេចក្តីដឹងខ្លួន ក្នុងការស៊ី ផឹក ទំពា ក្រេបជញ្ជក់

ឧច្ចារប្បស្សាវកម្មេ សម្បជានការី គតេ ឋិតេ
និសិន្នេ សុត្តេ ជាគរិតេ ភាសិតេ តុណ្ហីភាវេ
សម្បជានការីតិ ។

(៩៩) យតោ ខោ ព្រាហ្មណ ភិក្ខុ សតិសម្បជញ្ញេន សមន្នាគតោ ហោតិ តមេនំ តថាគតោ ឧត្តរឹ
វិនេតិ ឯហិ ត្វំ ភិក្ខុ វិវិត្តំ សេនាសនំ ភជ អរញ្ញំ
រុក្ខមូលំ បព្វតំ កន្ទរំ គិរិគុហំ សុសានំ វនបត្ថំ
អព្ភោកាសំ បលាលបុញ្ជន្តិ ។ សោ វិវិត្តំ សេនាសនំ
ភជតិ អរញ្ញំ រុក្ខមូលំ បព្វតំ កន្ទរំ គិរិគុហំ សុសានំ
វនបត្ថំ អព្ភោកាសំ បលាលបុញ្ជំ ។ សោ បច្ឆាភត្តំ
បិណ្ឌបាតប្បដិក្កន្តោ និសីទតិ បល្លង្កំ អាភុជិត្វា ឧជុំ
កាយំ បណិធាយ បរិមុខំ សតឹ ឧបដ្ឋបេត្វា ។ សោ
អភិជ្ឈំ លោកេ បហាយ វិគតាភិជ្ឈេន ចេតសា
វិហរតិ អភិជ្ឈាយ ចិត្តំ បរិសោធេតិ ព្យាបាទប្បទោសំ
បហាយ អព្យាបន្នចិត្តោ វិហរតិ សព្វបាណភូតហិតានុកម្បី ព្យាបាទប្បទោសា ចិត្តំ បរិសោធេតិ

ធ្វើសេចក្តីដឹងខ្លួន ក្នុងការបន្ទោបង់ឧច្ចារៈ បស្សាវៈ ធ្វើសេចក្តីដឹងខ្លួនក្នុងការ ដើរ ឈរ អង្គុយ ដេកលក់ ភ្ញាក់រលឹក និយាយ ស្ងៀម ។

(៩៩) ម្នាលព្រាហ្មណ៍ កាលណាបើ ភិក្ខុបានប្រកបដោយសតិសម្បជញ្ញៈហើយ តថាគតក៏ទូន្មានភិក្ខុនោះតទៅថា ម្នាលភិក្ខុ អ្នកចូរមក ចូរប្រើប្រាស់នូវសេនាសនៈស្ងាត់ គឺ ព្រៃ(១) ម្លប់ឈើ ភ្នំ ជ្រោះភ្នំ គុហាភ្នំ ព្រៃខ្មោច ព្រៃឆ្ងាយ(២) ទីវាលស្រឡះ ទីគំនរចំបើង ។ ភិក្ខុនោះ ក៏ប្រើប្រាស់នូវសេនាសនៈស្ងាត់ គឺព្រៃ ម្លប់ឈើ ភ្នំ ជ្រោះភ្នំ គុហាភ្នំ ព្រៃខ្មោច ព្រៃឆ្ងាយ ទីវាលស្រឡះ ទីគំនរចំបើង ។ ភិក្ខុនោះ ត្រឡប់មកអំពីបិណ្ឌបាត ក្នុងវេលាក្រោយភត្ត អង្គុយផ្គត់ភ្នែន តម្កល់កាយឲ្យត្រង់ ហើយផ្ចង់ស្មារតី ឲ្យមានមុខឆ្ពោះទៅរកកម្មដ្ឋាន ។ ភិក្ខុនោះ ក៏លះបង់នូវអភិជ្ឈា (កាមច្ឆន្ទៈ) ក្នុងលោកគឺកាយ មានចិត្តប្រាសចាកអភិជ្ឈា ធ្វើចិត្តឲ្យស្អាតចាកអភិជ្ឈា លះបង់នូវសេចក្តីប្រទូស្តគឺព្យាបាទ មានចិត្តមិនព្យាបាទ មានការផ្សងផ្តើមនឹងសេចក្តីអនុគ្រោះដល់សត្វមានជីវិតទាំងពួង ធ្វើចិត្តឲ្យស្អាតចាកសេចក្តីប្រទូស្តគឺព្យាបាទ

---

១ ទីព្រៃដែលនៅខាងក្រៅបង្គោលរបងស្រុក ។ ព្រៃឆ្ងាយ ព្រៃលក ព្រៃនាំឲ្យកើតសេចក្តីខ្លាច ព្រៃនាំឲ្យកើតរោមព្រឺក្រោម ព្រៃដាច់បំផុត ព្រៃគ្មានផ្ទះរបស់មនុស្ស ព្រៃកម្រមានមនុស្សចូលទៅ ។ វិភង្គ អដ្ឋកថា ។

ថីនមិទ្ធំ បហាយ វិគតថីនមិទ្ធោ[១] វិហរតិ អាលោកសញ្ញី សតោ សម្បជានោ ថីនមិទ្ធា ចិត្តំ បរិសោធេតិ ឧទ្ធច្ចកុក្កុច្ចំ បហាយ អនុទ្ធតោ វិហរតិ អជ្ឈត្តំ វូបសន្តចិត្តោ ឧទ្ធច្ចកុក្កុច្ចា ចិត្តំ បរិសោធេតិ វិចិកិច្ឆំ បហាយ តិណ្ណវិចិកិច្ឆោ វិហរតិ អកថំកថី កុសលេសុ ធម្មេសុ វិចិកិច្ឆាយ ចិត្តំ បរិសោធេតិ ។

(១០០) សោ ឥមេ បញ្ច នីវរណេ បហាយ ចេតសោ ឧបក្កិលេសេ បញ្ញាយ ទុព្វលីករណេ វិវិច្ចេវ កាមេហិ វិវិច្ច អកុសលេហិ ធម្មេហិ សវិតក្កំ សវិចារំ វិវេកជំ បីតិសុខំ បឋមំ ឈានំ ឧបសម្បជ្ជ វិហរតិ វិតក្កវិចារានំ វូបសមា ។ បេ ។ ទុតិយំ ឈានំ ឧបសម្បជ្ជ វិហរតិ បីតិយា ច វិរាគា ។ បេ ។ តតិយំ ឈានំ ឧបសម្បជ្ជ វិហរតិ សុខស្ស ច បហានា ។ បេ ។ ចតុត្ថំ ឈានំ ឧបសម្បជ្ជ វិហរតិ ។

១ កត្ថចិ អដ្ឋកថាបោត្ថកេ វិគតថីនមិទ្ធេន ចេតសាតិ ទិស្សតិ ។

លះបង់នូវថីនមិទ្ធៈ គឺសេចក្តីខ្ជិលច្រអូស មានចិត្តប្រាសចាកថីនមិទ្ធៈ មានសេចក្តីសំគាល់នូវពន្លឺ មានសតិសម្បជញ្ញៈ ធ្វើចិត្តឲ្យស្អាតចាកថីនមិទ្ធៈ លះបង់នូវឧទ្ធច្ចកុក្កុច្ចៈ គឺសេចក្តីរាយមាយនិងសេចក្តីរៅខានចិត្ត មានចិត្តមិនបានរាយមាយ មានចិត្តខាងក្នុងស្ងប់រម្ងាប់ហើយ ធ្វើចិត្តឲ្យស្អាតចាកឧទ្ធច្ចកុក្កុច្ចៈ លះបង់នូវវិចិកិច្ឆាគឺសេចក្តីសង្ស័យ ឆ្លងផុតសេចក្តីសង្ស័យហើយ ឥតមានសេចក្តីងឿងឆ្ងល់ ក្នុងកុសលធម៌ទាំងឡាយ ធ្វើចិត្តឲ្យស្អាតចាកវិចិកិច្ឆា ។

[១០០] ភិក្ខុនោះ ក៏លះបង់នូវនីវរណៈទាំង ៥ នេះ ដែលជាគ្រឿងសៅហ្មងនៃចិត្ត ជាធម្មជាតធ្វើបញ្ញាឲ្យមានកំឡាំងថយ ហើយក៏ស្ងាត់ចាកកាមទាំងឡាយ ស្ងាត់ចាកអកុសលធម៌ទាំងឡាយ បានដល់នូវបឋមជ្ឈានប្រកបដោយវិតក្កៈ ប្រកបដោយវិចារៈ មានបីតិនិងសុខៈដែលកើតអំពីសេចក្តីស្ងាត់ ព្រោះរម្ងាប់នូវវិតក្កៈនិងវិចារៈ ។ បេ ។ បានដល់នូវទុតិយជ្ឈាន ព្រោះមានចិត្តនឿយណាយចាកបីតិ ។ បេ ។ បានដល់នូវតតិយជ្ឈាន ព្រោះលះបង់នូវសុខៈ ។ បេ ។ បានដល់នូវចតុត្ថជ្ឈាន ។

យេ តេ ខោ ព្រាហ្មណ ភិក្ខូ សេក្ខា អប្បត្តមានសា អនុត្តរំ យោគក្ខេមំ បត្ថយមានា វិហរន្តិ តេសុ មេ អយំ ឯវរូបី អនុសាសនី ហោតិ ។ យេ បន តេ ភិក្ខូ អរហន្តោ ខីណាសវា វុសិតវន្តោ កតករណីយា ឱហិតភារា អនុប្បត្តសទត្ថា បរិក្ខីណភវសញ្ញោជនា សម្មទញ្ញា វិមុត្តា តេសំ ឥមេ ធម្មា ទិដ្ឋធម្មសុខវិហា-រាយ ចេវ សំវត្តន្តិ សតិសម្បជញ្ញាយ ចាតិ ។

(១០១) ឯវំ វុត្តេ គណកមោគ្គល្លានោ ព្រាហ្មណោ ភគវន្តំ ឯតទវោច កិន្នុ ខោ ភោតោ គោតមស្ស សាវកា ភោតា គោតមេន ឯវំ ឱវទិយមានា ឯវំ អនុសាសិយ-មានា សព្វេ អច្ចន្តំ និដ្ឋំ និព្វានំ អារាធេន្តិ ឧទាហុ

ម្នាលព្រាហ្មណ៍ ភិក្ខុទាំងឡាយណា ជាសេក្ខបុគ្គល មានអរហត្តផលចិត្ត មិនទាន់បានសម្រេចនៅឡើយ កំពុងប្រាថ្នានូវព្រះនិព្វានជាទីក្សេមចាកយោគៈ រកគុណជាតដទៃក្រៃលែងជាងគ្មាន តថាគតក៏តែងប្រើវាចានេះ ដែលជាពាក្យប្រៀនប្រដៅមានទំនងបែបនេះ ចំពោះភិក្ខុទាំងនោះ ៗ តែបើភិក្ខុទាំងឡាយណា ជាអរហន្ត មានអាសវៈអស់ហើយ មានព្រហ្មចរិយៈបានប្រព្រឹត្តគ្រប់គ្រាន់ហើយ មានសោឡសកិច្ចបានធ្វើស្រេចហើយ មានភារៈដាក់ចុះហើយ មានប្រយោជន៍របស់ខ្លួនបានសម្រេចហើយ មានភវសញ្ញោជនៈគឺតណ្ហាអស់រលីងហើយ មានចិត្តរួចស្រឡះហើយ ព្រោះដឹងច្បាស់ដោយប្រពៃ ភិក្ខុទាំងនោះ ឈ្មោះថាមានធម៌ទាំងឡាយនេះ ប្រព្រឹត្តទៅ ដើម្បីនៅជាសុខក្នុងបច្ចុប្បន្នផង ដើម្បីសតិសម្បជញ្ញៈផង (តថាគតពុំបានប្រៀនប្រដៅភិក្ខុទាំងនោះទេ)ៗ

(១០១) កាលបើព្រះមានព្រះភាគ ទ្រង់មានព្រះពុទ្ធដីកាយ៉ាងនេះហើយ គណកមោគ្គល្លានព្រាហ្មណ៍ ក៏ក្រាបបង្គំទូលសួរព្រះមានព្រះភាគដូច្នេះថា ចុះពួកសាវ័ក របស់ព្រះគោតមដ៏ចម្រើន ដែលព្រះគោតមដ៏ចម្រើនទូន្មានយ៉ាងនេះ ប្រៀនប្រដៅយ៉ាងនេះ សុទ្ធតែបានព្រះនិព្វាន ដែលជាគុណជាតចប់កិច្ចដោយពិត ទាំងអស់គ្នាឬ ឬថា

ឯកច្ចេ នារាធេន្តីតិ ។ អប្បេកច្ចេ ខោ ព្រាហ្មណ មម សាវកា មយា ឯវំ ឱវទិយមានា ឯវំ អនុសាសិយមានា អច្ចន្តនិដ្ឋំ និព្វានំ អារាធេន្តិ ឯកច្ចេ នារាធេន្តីតិ ។ កោ នុ ខោ ភោ គោតម ហេតុ កោ បច្ចយោ យន្តិដ្ឋតេវ និព្វានំ តិដ្ឋតិ និព្វានគាមិមគ្គោ តិដ្ឋតិ ភវំ គោតមោ សមាទបេតា អថ ច បន ភោតោ គោតមស្ស សាវកា ភោតា គោតមេន ឯវំ ឱវទិយមានា ឯវំ អនុសាសិយមានា អប្បេកច្ចេ អច្ចន្តនិដ្ឋំ និព្វានំ អារាធេន្តិ ឯកច្ចេ នារាធេន្តីតិ ។

(១០២) តេនហិ ព្រាហ្មណ តញ្ញេវេត្ថ បដិបុច្ឆិស្សាមិ យថា តេ ខមេយ្យ តថា នំ ព្យាករេយ្យាសិ តំ កឹ មញ្ញសិ ព្រាហ្មណ កុសលោ ត្វំ រាជគហគាមិស្ស មគ្គស្សាតិ ។ ឯវំ ភោ កុសលោ អហំ រាជគហគាមិស្ស មគ្គស្សាតិ ។ តំ កឹ មញ្ញសិ ព្រាហ្មណ ឥធ បុរិសោ អាគច្ឆេយ្យ រាជគហំ គន្តុកាមោ សោ តំ ឧបសង្កមិត្វា

ពួកខ្លះមិនបានដែរ ។ ម្នាលព្រាហ្មណ៍ ពួកសាវ័ក របស់តថាគត ដែលតថាគតទូន្មានយ៉ាងនេះ ប្រៀនប្រដៅយ៉ាងនេះ ពួកខ្លះក៏បាន ព្រះនិព្វាន ដែលជាគុណជាតចប់កិច្ចដោយពិត ពួកខ្លះ ក៏មិនបាន ដែរ ។ បពិត្រព្រះគោតមដ៏ចម្រើន ហេតុដូចម្តេច បច្ច័យដូចម្តេច បានជាព្រះនិព្វានក៏មាន ផ្លូវជាទីទៅកាន់ព្រះនិព្វានក៏មាន ព្រះគោតម ដ៏ចម្រើន ជាអ្នកកៀរគេ ប្រមូលសត្វក៏មាន ប៉ុន្តែពួកសាវ័ករបស់ព្រះ គោតមដ៏ចម្រើន ដែលព្រះគោតមដ៏ចម្រើន ទូន្មានយ៉ាងនេះ ប្រៀន ប្រដៅយ៉ាងនេះ ពួកខ្លះក៏បានព្រះនិព្វាន ដែលជាគុណជាតចប់កិច្ច ដោយពិត ពួកខ្លះក៏មិនបាន ។

(១០២) ម្នាលព្រាហ្មណ៍ បើដូច្នោះ តថាគតនឹងសួរតបចំពោះ អ្នកវិញក្នុងប្រស្នានុ៎ះ បើអ្នកពេញចិត្តយ៉ាងណា គប្បីដោះស្រាយនូវ ប្រស្នានោះយ៉ាងនោះចុះ ម្នាលព្រាហ្មណ៍ អ្នកសំគាល់នូវដំណើរនោះ ដូចម្តេច ខ្លួនអ្នកជាបុគ្គលឈ្លាស ក្នុងផ្លូវទៅកាន់ក្រុងរាជគហៈដែរឬ ។ ព្រះករុណាព្រះអង្គ ខ្ញុំព្រះអង្គជាអ្នកឈ្លាស ក្នុងផ្លូវទៅកាន់ក្រុងរាជគហៈ ដែរ ។ ម្នាលព្រាហ្មណ៍ អ្នកសំគាល់ដំណើរនោះដូចម្តេច បុរសប្រាថ្នា នឹងទៅកាន់ក្រុងរាជគហៈ គប្បីមកក្នុងទីនេះ បុរសនោះចូលមករកអ្នក

ឯវំ វទេយ្យ ឥច្ឆាមហំ ភន្តេ រាជគហំ គន្តុំ តស្ស មេ រាជគហស្ស មគ្គំ ឧបទិសាតិ ។ តមេនំ ត្វំ ឯវំ វទេយ្យាសិ ឯហម្ភោ បុរិស អយំ មគ្គោ រាជគហំ គច្ឆតិ តេន មុហុត្តំ គច្ឆ តេន មុហុត្តំ គន្ត្វា ទក្ខិស្សសិ អមុកំ នាម គាមំ តេន មុហុត្តំ គច្ឆ តេន មុហុត្តំ គន្ត្វា ទក្ខិស្សសិ អមុកំ នាម និគមំ តេន មុហុត្តំ គច្ឆ តេន មុហុត្តំ គន្ត្វា ទក្ខិស្សសិ រាជគហស្ស អារាមរាមណេយ្យកំ វនរាមណេយ្យកំ ភូមរាមណេយ្យកំ បោក្ខរណីរាមណេយ្យកន្តិ ។ សោ តយា ឯវំ ឱវទិយមានោ ឯវំ អនុសាសិយមានោ ឧម្មគ្គំ គហេត្វា បច្ឆាមុខោ គច្ឆេយ្យ ។ អថ ទុតិយោ បុរិសោ អាគច្ឆេយ្យ រាជគហំ គន្តុកាមោ ។ សោ តំ ឧបសង្កមិត្វា ឯវំ វទេយ្យ ឥច្ឆាមហំ ភន្តេ រាជគហំ គន្តុំ តស្ស មេ រាជគហស្ស មគ្គំ ឧបទិសាតិ ។ តមេនំ ត្វំ ឯវំ វទេយ្យាសិ ឯហម្ភោ បុរិស អយំ មគ្គោ រាជគហំ គច្ឆតិ

ហើយសួរយ៉ាងនេះថា នែអ្នកដ៏ចម្រើន ខ្ញុំបាទចង់ទៅក្រុងរាជគហៈ អ្នកចូរបង្ហាញផ្លូវ របស់ក្រុងរាជគហៈ ដល់ខ្ញុំបាទ ៗ អ្នកគប្បីប្រាប់បុរសនោះ យ៉ាងនេះថា នែបុរសដ៏ចម្រើន អ្នកចូរមក នេះផ្លូវទៅក្រុងរាជគហៈ អ្នកចូរដើរទៅតាមផ្លូវនោះមួយរំពេចចុះ លុះអ្នកដើរទៅតាមផ្លូវនោះមួយរំពេចហើយ នឹងបានឃើញស្រុកឯណោះ អ្នកចូរដើរទៅតាមផ្លូវនោះមួយរំពេចចុះ លុះអ្នកដើរទៅតាមផ្លូវនោះមួយរំពេចហើយ នឹងបានឃើញនិគមឯណោះទៀត អ្នកចូរដើរទៅតាមផ្លូវនោះមួយរំពេចចុះ លុះអ្នកដើរទៅតាមផ្លូវនោះមួយរំពេចហើយ នឹងបានឃើញសួនច្បារជាទីសប្បាយ ព្រៃឈើជាទីសប្បាយ ភូមិជាទីសប្បាយ ស្រះបោក្ខរណីជាទីសប្បាយ របស់ក្រុងរាជគហៈ មិនខាន ៗ បុរសនោះ កាលដែលអ្នកទូន្មានយ៉ាងនេះ ប្រៀនប្រដៅយ៉ាងនេះ ក៏កាន់យកផ្លូវខុស ហើយដើរឆ្ពោះទៅខាងក្រោយវិញ ៗ លំដាប់នោះ បុរសជាគំរប់ពីរ ប្រាថ្នានឹងទៅកាន់ក្រុងរាជគហៈ គប្បីមកទៀត ៗ បុរសនោះចូលមករកអ្នក ហើយសួរយ៉ាងនេះថា នែអ្នកដ៏ចម្រើន ខ្ញុំបាទចង់ទៅក្រុងរាជគហៈ អ្នកចូរបង្ហាញផ្លូវនៃក្រុងរាជគហៈ ដល់ខ្ញុំបាទផង ៗ អ្នកគប្បីប្រាប់បុរសនោះយ៉ាងនេះថា នែបុរសដ៏ចម្រើន អ្នកចូរមក នេះផ្លូវទៅកាន់ក្រុងរាជគហៈ

តេន មុហុត្តំ គច្ឆ តេន មុហុត្តំ គន្ត្វា ទក្ខិស្សសិ អមុកំ នាម គាមំ តេន មុហុត្តំ គច្ឆ តេន មុហុត្តំ គន្ត្វា ទក្ខិស្សសិ អមុកំ នាម និគមំ តេន មុហុត្តំ គច្ឆ តេន មុហុត្តំ គន្ត្វា ទក្ខិស្សសិ រាជគហស្ស អារាមរាមណេយ្យកំ វនរាមណេយ្យកំ ភូមិរាមណេយ្យកំ បោក្ខរណិរាមណេយ្យកន្តិ ។ សោ តយា ឯវំ ឱវទិយមានោ ឯវំ អនុសាសិយមានោ សោត្ថិនា រាជគហំ គច្ឆេយ្យ ។ កោ នុ ខោ ព្រាហ្មណ ហេតុ កោ បច្ចយោ យំ តិដ្ឋតេវ រាជគហំ តិដ្ឋតិ រាជគហគាមិមគ្គោ តិដ្ឋសិ ត្វំ សមាទបេតា អថ ច បន តយា ឯវំ ឱវទិយមានោ ឯវំ អនុសាសិយមានោ ឯកោ បុរិសោ ឧម្មគ្គំ គហេត្វា បច្ឆាមុខោ គច្ឆេយ្យ ឯកោ សោត្ថិនា រាជគហំ គច្ឆេយ្យាតិ ។ ឯត្ថ ក្យាហំ(១) ភោ គោតម ករោមិ មគ្គក្ខាយាហំ ភោ គោតមាតិ ។

---

១ ម. ក្វាហំ ។

អ្នកចូរដើរទៅតាមផ្លូវនោះមួយរំពេចចុះ លុះដើរទៅតាមផ្លូវនោះមួយរំពេចហើយ នឹងបានឃើញស្រុកឯណោះ អ្នកចូរដើរទៅតាមផ្លូវនោះមួយរំពេចចុះ លុះដើរទៅតាមផ្លូវនោះមួយរំពេចហើយ នឹងបានឃើញនិគមឯណោះទៀត អ្នកចូរដើរទៅតាមផ្លូវនោះមួយរំពេចចុះ លុះអ្នកដើរទៅតាមផ្លូវនោះមួយរំពេចហើយ នឹងបានឃើញនូវសួនច្បារជាទីសប្បាយ ព្រៃឈើជាទីសប្បាយ ភូមិជាទីសប្បាយ ស្រះបោក្ខរណីជាទីសប្បាយ របស់ក្រុងរាជគហៈមិនខាន ។ បុរសនោះ កាលបើអ្នកទូន្មានយ៉ាងនេះ ប្រៀនប្រដៅយ៉ាងនេះ ក៏ដើរទៅកាន់ក្រុងរាជគហៈ ដោយសួស្តី ។ ម្នាលព្រាហ្មណ៍ ចុះហេតុដូចម្តេច បច្ច័យដូចម្តេច បានជាក្រុងរាជគហៈក៏មាន ផ្លូវសម្រាប់ទៅក្រុងរាជគហៈក៏មាន អ្នកជាអ្នកបង្ហាញផ្លូវក៏មាន ប៉ុន្តែកាលដែលអ្នកទូន្មានយ៉ាងនេះ ប្រៀនប្រដៅយ៉ាងនេះ បុរសម្នាក់បែរជាកាន់យកផ្លូវខុស ដើរត្រឡប់មុខទៅខាងក្រោយវិញ ឯបុរសម្នាក់ទៀតបានដើរទៅដល់ក្រុងរាជគហៈដោយសួស្តី ។ បពិត្រព្រះគោតមដ៏ចំរើន ក្នុងរឿងនុ៎ះ ខ្ញុំព្រះអង្គនឹងធ្វើដូចម្តេចកើត បពិត្រព្រះគោតមដ៏ចំរើន ព្រោះខ្ញុំព្រះអង្គ គ្រាន់តែជាអ្នកប្រាប់ផ្លូវប៉ុណ្ណោះទេ ។

(១០៣) ឯវមេវ ខោ ព្រាហ្មណ តិដ្ឋតេវ និព្ពានំ តិដ្ឋតិ និព្ពានគាមិមគ្គោ តិដ្ឋាមហំ សមាទបេតា អថ ច បន មម សាវកា មយា ឯវំ ឱវទិយមានា ឯវំ អនុសាសិយមានា អប្បេកច្ចេ អច្ចន្តនិដ្ឋំ និព្ពានំ អារាធេន្តិ ឯកច្ចេ នារាធេន្តិ ឯត្ថ ក្យាហំ ព្រាហ្មណ ករោមិ មគ្គក្ខាយិ ព្រាហ្មណ តថាគតោតិ ។

(១០៤) ឯវំ វុត្តេ គណកមោគ្គល្លានោ ព្រាហ្មណោ ភគវន្តំ ឯតទវោច យេមេ ភោ គោតម បុគ្គលា អសទ្ធា ជីវិកត្ថា អាគារស្មា អនគារិយំ បព្វជិតា សឋា មាយាវិនោ កេដុភិនោ ឧទ្ធតា ឧន្នឡា ចបលា មុខរា វិកិណ្ណវាចា ឥន្ទ្រិយេសុ អគុត្តទ្វារា ភោជនេ អមត្តញ្ញុនោ ជាគរិយំ អននុយុត្តា សាមញ្ញេ អនបេក្ខវន្តោ សិក្ខាយ ន តិព្វគារវា

(១០៣) ម្នាលព្រាហ្មណ៍ សេចក្តីនេះ មានឧបមេយ្យដូច ព្រះនិព្វានក៏មាន ផ្លូវសម្រាប់ទៅកាន់ព្រះនិព្វានក៏មាន តថាគតជាអ្នកកៀរគរ ប្រមូលសត្វក៏មាន ប៉ុន្តែពួកសាវ័ករបស់តថាគត កាលបើតថាគតទូន្មានយ៉ាងនេះ ប្រៀនប្រដៅ យ៉ាងនេះ ពួកខ្លះ ក៏បាននូវព្រះនិព្វានដែលជាធម្មជាតចប់កិច្ចដោយពិត ពួកខ្លះ ក៏មិនបាន ម្នាលព្រាហ្មណ៍ ក្នុងរឿងនុ៎ះ តថាគតនឹងធ្វើដូចម្តេចកើត ម្នាលព្រាហ្មណ៍ ព្រោះថា តថាគតគ្រាន់តែជាអ្នកប្រាប់ផ្លូវប៉ុណ្ណោះ ។

(១០៤) កាលបើព្រះមានព្រះភាគ ទ្រង់មានព្រះពុទ្ធដីកាយ៉ាងនេះហើយ គណកមោគ្គល្លានព្រាហ្មណ៍ ក៏ក្រាបបង្គំទូលព្រះមានព្រះភាគដូច្នេះថា បពិត្រព្រះគោតមដ៏ចំរើន បុគ្គលទាំងឡាយណា ជាអ្នកមិនមានសទ្ធា ត្រូវការតែចិញ្ចឹមជីវិត ចេញចាកផ្ទះទៅបួសកាន់ផ្នួស ជាអ្នកលេង(១) ជាអ្នកបិទបាំងទោសខ្លួន ជាអ្នកបញ្ឆោត ជាអ្នកមានចិត្តរាយមាយ មានមានះដុះឡើង មានចិត្តឃ្លេងឃ្លោង មានមាត់រឹង មានវាចាពេយពាយ មិនបានរក្សាទ្វារ ក្នុងឥន្ទ្រិយទាំងឡាយ មិនដឹងប្រមាណក្នុងភោជន មិនប្រកបរឿយៗ នូវសេចក្តីភ្ញាក់រលឹក មិនរមិលមើល(២) ក្នុងសមណធម៌ (ផ្នួស) មិនមានការគោរពដ៏ក្លៀវក្លាក្នុងសិក្ខា

១ អ្នកសំដែងនូវគុណដែលមិនមានក្នុងខ្លួន ២ មិនប្រាថ្នា មិនត្រូវការ ។

ពាហុលិកា សាថលិកា ឱក្កមនេ បុព្វង្គមា បវិវេកេ និក្ខិត្តធុរា កុសីតា ហីនវីរិយា មុដ្ឋស្សតិនោ អសម្បជានា អសមាហិតា វិព្ភន្តចិត្តា ទុប្បញ្ញា ឯឡមូគា ន តេហិ ភវំ គោតមោ សទ្ធឹ សំវសតិ ។ យេ បន តេ កុលបុត្តា សទ្ធា អគារស្មា អនគារិយំ បព្វជិតា អសឋា អមាយាវិនោ អកេដុភិនោ អនុទ្ធតា អនុន្នឡា អចបលា អមុខរា អវិកិណ្ណវាចា ឥន្ទ្រិយេសុ គុត្តទ្វារា ភោជនេ មត្តញ្ញុនោ ជាគរិយំ អនុយុត្តា សាមញ្ញេ អបេក្ខវន្តោ សិក្ខាយ តិព្វគារវា ន ពាហុលិកា ន សាថលិកា ឱក្កមនេ និក្ខិត្តធុរា បវិវេកេ បុព្វង្គមា អារទ្ធវីរិយា បហិតត្តា ឧបដ្ឋិតស្សតិនោ សម្បជានា សមាហិតា ឯកគ្គចិត្តា បញ្ញវន្តោ អនេឡមូគា តេហិ ភវំ គោតមោ សទ្ធឹ សំវសតិ ។ សេយ្យថាបិ ភោ គោតម

ជាអ្នកលោភច្រើន ជាអ្នកប្រព្រឹត្តធូរ ជាប្រធានក្នុងការបន្ធូរបន្ថយព្យាយាម ដាក់ធុរៈចោលក្នុងទីស្ងាត់ ជាអ្នកខ្ជិលច្រអូស មានព្យាយាមក្នុងអំពើថោកទាប ភ្លេចស្មារតី មិនដឹងខ្លួន មានចិត្តមិនបានតម្កល់មាំ មានចិត្តវិលខុស ឥតបញ្ញា ជាអ្នកល្ងង់ខ្លៅ ព្រះគោតមដ៏ចម្រើន មិនបាននៅរួមជាមួយនឹងបុគ្គលទាំងនោះទេ ។ ឯកុលបុត្រទាំងឡាយណា ដែលចេញចាកផ្ទះបួសទៅកាន់ផ្នួស ដោយសទ្ធា មិនជាអ្នកលេង មិនបានបិទបាំងទោសខ្លួន មិនជាអ្នកបញ្ឆោត មានចិត្តមិនបានរាយមាយ មិនមានមានះធុះឡើង មិនមានចិត្តឃ្វេងឃ្វាង មិនមានមាត់រឹង មិនមានវាចារោយរាយ ជាអ្នករក្សាទ្វារក្នុងឥន្ទ្រិយទាំងឡាយ ជាអ្នកដឹងប្រមាណក្នុងភោជន ប្រកបរឿយ ៗ នូវសេចក្តីភ្ញាក់រលឹក ជាអ្នករមិលមើលក្នុងសមណធម៌ មានសេចក្តីគោរពដ៏ក្រៃក្លាក្នុងសិក្ខា មិនជាអ្នកលោភច្រើន មិនបានប្រព្រឹត្តធូរ ដាក់ធុរៈក្នុងការបន្ធូរបន្ថយព្យាយាមចោល ជាប្រធានក្នុងទីស្ងាត់ មានព្យាយាមតឹងតែង មានចិត្តបញ្ជូនទៅកាន់ព្រះនិព្វាន មានសតិតម្កល់ខ្ជាប់ ដឹងខ្លួន មានចិត្តតម្កល់មាំ មានចិត្តប្រកបដោយអារម្មណ៍តែមួយ មានបញ្ញា មិនល្ងង់ខ្លៅ ព្រះគោតមដ៏ចម្រើន រមែងនៅរួមជាមួយនឹងកុលបុត្រទាំងនោះ ។ បពិត្រព្រះគោតមដ៏ចម្រើន ដូចជា

យេ កេចិ មូលគន្ធា កាឡានុសារិកំ តេសំ អគ្គមក្ខាយតិ យេ កេចិ សារគន្ធា លោហិតចន្ទនំ តេសំ អគ្គមក្ខាយតិ យេ កេចិ បុប្ផគន្ធា វស្សិកំ តេសំ អគ្គមក្ខាយតិ ឯវមេវ ខោ ភោតោ គោតមស្ស ឱវាទោ បរមជ្ជធម្មេសុ អភិក្កន្តំ ភោ គោតម អភិក្កន្តំ ភោ គោតម សេយ្យថាបិ ភោ គោតម និក្កុជ្ជិតំ វា ឧក្កុជ្ជេយ្យ បដិច្ឆន្នំ វា វិវរេយ្យ មូឡ្ហស្ស វា មគ្គំ អាចិក្ខេយ្យ អន្ធការេ វា តេលបជ្ជោតំ ធារេយ្យ ចក្ខុមន្តោ រូបានិ ទក្ខិន្តីតិ ឯវមេវ ភោតា គោតមេន អនេកបរិយាយេន ធម្មោ បកាសិតោ ឯសាហំ ភវន្តំ គោតមំ សរណំ គច្ឆាមិ ធម្មញ្ច ភិក្ខុសង្ឃញ្ច ឧបាសកំ មំ ភវំ គោតមោ ធារេតុ អជ្ជតគ្គេ បាណុបេតំ សរណំ គតន្តិ ។

គណកមោគ្គល្លានសុត្តំ សត្តមំ និដ្ឋិតំ ។

ក្លិននៃឫស ឬមើម ណានីមួយ ឫសស្គារ ប្រាកដជាប្រសើរជាងក្លិននៃឫសឬមើម ទាំងអម្បាលនោះ ក្លិននៃខ្លឹម ណានីមួយ ខ្លឹមចន្ទន៍ក្រហម ប្រាកដជាប្រសើរជាងក្លិននៃខ្លឹម ទាំងអម្បាលនោះ ក្លិនផ្កាណាមួយ ផ្កាម្លិះលា ប្រាកដជាប្រសើរជាងក្លិននៃផ្កាទាំងអម្បាលនោះ យ៉ាងណាមិញ ឱវាទរបស់ព្រះគោតមដ៏ចម្រើន ក្នុងធម៌ជាគ្រឿងផុសខាត់ចិត្តនៃសត្វដទៃ (ឲ្យស្អាត) ក៏យ៉ាងនោះឯង បពិត្រព្រះគោតមដ៏ចម្រើន ភាសិតរបស់ព្រះអង្គច្បាស់ពេកណាស់ បពិត្រព្រះគោតមដ៏ចម្រើន ភាសិតរបស់ព្រះអង្គច្បាស់ពេកណាស់ បពិត្រព្រះគោតមដ៏ចម្រើន ដូចបុគ្គលផ្ងារឡើងនូវវត្ថុដែលផ្កាប់ ឬបើកនូវវត្ថុដែលគេបិទបាំង ពុំនោះ ដូចគេប្រាប់ផ្លូវដល់មនុស្សដែលវង្វេងផ្លូវ ពុំនោះសោត ដូចគេទ្រោលប្រទីបប្រេង បំភ្លឺក្នុងទីងងឹត ដោយគិតថា បុរសអ្នកមានភ្នែករមែងមើលឃើញរូបទាំងឡាយបាន យ៉ាងណាមិញ ធម៌ដែលព្រះគោតមដ៏ចម្រើន ទ្រង់សំដែងហើយ ដោយអនេកបរិយាយ ក៏យ៉ាងនោះឯង ខ្ញុំព្រះអង្គសូមដល់នូវព្រះគោតមដ៏ចម្រើន ទាំងព្រះធម៌ ទាំងព្រះភិក្ខុសង្ឃ ជាទីពឹងទីរលឹក សូមព្រះគោតមដ៏ចម្រើន ចាំទុកនូវខ្ញុំព្រះអង្គ ថាជាឧបាសក អ្នកដល់នូវសរណៈ ស្មើដោយជីវិត ក្នុងកាលមានថ្ងៃនេះជាដើមទៅ ។

ចប់ គណកមោគ្គល្លានសូត្រ ទី ៣ ។

# អដ្ឋមំ គោបកមោគ្គល្លានសុត្តំ

(១០៨) ឯវំមេ សុតំ ។ ឯកំ សមយំ អាយស្មា អានន្ទោ រាជគហេ វិហរតិ វេឡុវនេ កលន្ទកនិវាបេ អចិរបរិនិព្វុតេ ភគវតិ ។ តេន ខោ បន សមយេន រាជា មាគធោ អជាតសត្តុ វេទេហិបុត្តោ រាជគហំ បដិសង្ខារាបេតិ រញ្ញោ បជ្ជោតស្ស អាសង្កមានោ ។ អថ ខោ អាយស្មា អានន្ទោ បុព្វណ្ហសមយំ និវាសេត្វា បត្តចីវរមាទាយ រាជគហំ បិណ្ឌាយ បាវិសិ ។ អថ ខោ អាយស្មតោ អានន្ទស្ស ឯតទហោសិ អតិប្បគោ ខោ តាវ រាជគហេ បិណ្ឌាយ ចរិតុំ យន្នូនាហំ យេន គោបកមោគ្គល្លានស្ស ព្រាហ្មណស្ស កម្មន្តោ យេន គោបកមោគ្គល្លានោ ព្រាហ្មណោ តេនុបសង្កមេយ្យន្តិ ។ អថ ខោ អាយស្មា អានន្ទោ យេន គោបកមោគ្គល្លានស្ស ព្រាហ្មណស្ស កម្មន្តោ យេន គោបកមោគ្គល្លានោ ព្រាហ្មណោ តេនុបសង្កមិ ។ អទ្ទសា ខោ គោបកមោគ្គល្លានោ ព្រាហ្មណោ

# គោបកមោគ្គល្លានសូត្រ ទី ៨

(១០៥) ខ្ញុំបានស្តាប់មក យ៉ាងនេះ ។ សម័យមួយ កាលព្រះមានព្រះភាគទ្រង់បរិនិព្វានទៅ មិនទាន់បានយូរប៉ុន្មាន ព្រះអានន្ទមានអាយុ គង់នៅក្នុងវត្តវេឡុវ័ន ជាកលន្ទកនិវាបស្ថាន ជិតក្រុងរាជគហៈ ។ សម័យនោះឯង ព្រះរាជាទ្រង់ព្រះនាម អជាតសត្តុវេទេហីបុត្រ ជាធំក្នុងដែនមគធៈ ទ្រង់រង្កៀសនឹងព្រះរាជាទ្រង់ព្រះនាមបជ្ជោត ក៏ទ្រង់ត្រាស់ឲ្យរៀបចំក្រុងរាជគហៈ ។ លំដាប់នោះ ព្រះអានន្ទមានអាយុ ស្លៀកស្បង់ប្រដាប់ដោយបាត្រចីវរ ក្នុងបុព្វណ្ហសម័យចូលទៅក្រុងរាជគហៈ ដើម្បីបិណ្ឌបាត ។ គ្រានោះ ព្រះអានន្ទមានអាយុមានសេចក្តីត្រិះរិះដូច្នេះថា ការត្រាច់ទៅដើម្បីបិណ្ឌបាត ក្នុងក្រុងរាជគហៈ នៅព្រឹកពេកណាស់ បើដូច្នោះ គួរតែអាត្មាអញចូលទៅត្រង់ទីធ្វើការងាររបស់គោបកមោគ្គល្លានព្រាហ្មណ៍ និងទីដែលគោបកមោគ្គល្លានព្រាហ្មណ៍នៅសិន ។ ព្រះអានន្ទមានអាយុ ក៏ចូលទៅ ត្រង់ទីធ្វើការងាររបស់គោបកមោគ្គល្លានព្រាហ្មណ៍ និងទីដែលគោបកមោគ្គល្លានព្រាហ្មណ៍នៅ ។ ឯគោបកមោគ្គល្លានព្រាហ្មណ៍ បានឃើញព្រះ

អាយស្មន្តំ អានន្ទំ ទូរតោ អាគច្ឆន្តំ ទិស្វាន អាយស្មន្តំ អានន្ទំ ឯតទវោច ឯតុ ខោ ភវំ អានន្ទោ ស្វាគតំ ភោតោ អានន្ទស្ស ចិរស្សំ ខោ ភវំ អានន្ទោ ឥមំ បរិយាយមកាសិ យទិទំ ឥធាគមនាយ និសីទតុ ភវំ អានន្ទោ ឥទមាសនំ បញ្ញត្តន្តិ ។ និសីទិ ខោ អាយស្មា អានន្ទោ បញ្ញត្តេ អាសនេ ។ គោបកមោគ្គល្លានោបិ ខោ ព្រាហ្មណោ អញ្ញតរំ នីចំ អាសនំ គហេត្វា និសីទិ ។

(១០៦) ឯកមន្តំ និសិន្នោ ខោ គោបកមោគ្គល្លានោ ព្រាហ្មណោ អាយស្មន្តំ អានន្ទំ ឯតទវោច អត្ថិ នុ ខោ ភោ អានន្ទ ឯកភិក្ខុបិ តេហិ ធម្មេហិ សព្វេន សព្វំ សព្វថា សព្វំ សមន្នាគតោ យេហិ ធម្មេហិ សមន្នាគតោ សោ ភវំ គោតមោ អហោសិ អរហំ សម្មាសម្ពុទ្ធោតិ ។

អានន្ទមានអាយុ មកអំពីចម្ងាយ លុះបានឃើញហើយ ក៏ពោលទៅនឹងព្រះអានន្ទមានអាយុដូច្នេះថា សូមព្រះអានន្ទដ៏ចម្រើន និមន្តមក ព្រះអានន្ទដ៏ចម្រើន និមន្តមកជាការល្អ ព្រោះព្រះអានន្ទដ៏ចម្រើន បានធ្វើបរិយាយដើម្បីនិមន្តមកក្នុងទីនេះ អស់កាលយូរហើយ សូមព្រះអានន្ទដ៏ចម្រើនគង់ចុះ នេះអាសនៈដែលខ្ញុំក្រាលទុក ។ ព្រះអានន្ទមានអាយុក៏គង់លើអាសនៈ ដែលព្រាហ្មណ៍ក្រាលទុក ។ ឯគោបកមោគ្គល្លាន-ព្រាហ្មណ៍ ក៏កាន់យកនូវអាសនៈដ៏ទាបមួយ ហើយអង្គុយទៅ ។

(១០៦) លុះគោបកមោគ្គល្លានព្រាហ្មណ៍ អង្គុយក្នុងទីដ៏សមគួរហើយ ក៏សួរព្រះអានន្ទមានអាយុដូច្នេះថា បពិត្រព្រះអានន្ទដ៏ចម្រើន ព្រះគោតមដ៏ចម្រើនអង្គនោះ ជាអរហន្តសម្មាសម្ពុទ្ធ ប្រកបដោយធម៌[១] ទាំងឡាយណា ភិក្ខុមួយរូប ដែលប្រកបដោយធម៌ទាំងឡាយនោះ ដោយអាការទាំងពួង ដោយប្រការទាំងពួង មានដែរឬទេ ។

---

១ សំដៅយកសព្វញ្ញុតញ្ញាណ ។

នត្ថិ ខោ ព្រាហ្មណ ឯកភិក្ខុបិ តេហិ ធម្មេហិ សព្វេន សព្វំ សព្វថា សព្វំ សមន្នាគតោ យេហិ ធម្មេហិ សមន្នាគតោ សោ ភគវា អហោសិ អរហំ សម្មាសម្ពុទ្ធោ សោ ហិ ព្រាហ្មណ ភគវា អនុប្បន្នស្ស មគ្គស្ស ឧប្បាទេតា អសញ្ជាតស្ស មគ្គស្ស សញ្ជនេតា អនក្ខាតស្ស មគ្គស្ស អក្ខាតា មគ្គញ្ញូ មគ្គវិទូ មគ្គកោវិទោ មគ្គានុគា ច បន ឯតរហិ សាវកា វិហរន្តិ បច្ឆា សមន្នាគតាតិ ។ អយញ្ច ហិទំ អាយស្មតោ អានន្ទស្ស គោបកមោគ្គល្លានេន ព្រាហ្មណេន សទ្ធឹ អន្តរាកថា វិប្បកតា អហោសិ ។

(១០៧) អថខោ វស្សការោ ព្រាហ្មណោ មគធមហាមត្តោ រាជគហេ កម្មន្តេ អនុសញ្ញាយមានោ យេន គោបកមោគ្គល្លានស្ស ព្រាហ្មណស្ស កម្មន្តោ យេនាយស្មា អានន្ទោ តេនុបសង្កមិ ឧបសង្កមិត្វា អាយស្មតា អានន្ទេន សទ្ធឹ សម្មោទិ សម្មោទនីយំ កថំ សារណីយំ វីតិសារេត្វា

ព្រះអានន្ទឆ្លើយថា ម្នាលព្រាហ្មណ៍ ព្រះមានព្រះភាគអង្គនោះ ជាអរហន្តសម្មាសម្ពុទ្ធ ប្រកបដោយធម៌ទាំងឡាយណា សូម្បីភិក្ខុ មួយរូបដែលប្រកបដោយធម៌ទាំងឡាយនោះ ដោយអាការទាំងពួង ដោយប្រការទាំងពួង មិនមានទេ ម្នាលព្រាហ្មណ៍ ព្រោះថា ព្រះមានព្រះភាគអង្គនោះ ជាអ្នកបង្កើតផ្លូវដែលមិនទាន់កើតឡើង ជាអ្នករៀបចំផ្លូវដែលគេមិនទាន់រៀបចំ ជាអ្នកប្រាប់ផ្លូវដែលគេមិនដែលប្រាប់ ជាអ្នកស្គាល់ផ្លូវ ដឹងផ្លូវ ឈ្លាសវៃក្នុងផ្លូវ ពួកសាវកក្នុងកាលឥឡូវនេះ គ្រាន់តែជាអ្នកដើរតាមផ្លូវ ប្រកបតាមជាខាងក្រោយ ។ នេះឯងពាក្យជាចន្លោះ ដែលព្រះអានន្ទមានអាយុ ធ្វើមិនទាន់ស្រេច ជាមួយនឹងគោបកមោគ្គល្លានព្រាហ្មណ៍នៅឡើយ ។

[១០៧] លំដាប់នោះ វស្សការព្រាហ្មណ៍ ជាមហាមាត្យក្នុងដែនមគធៈ កាលដែលត្រួតត្រាការងារក្នុងរាជគហៈ ក៏ដើរចូលទៅត្រង់ទីធ្វើការងារ របស់គោបកមោគ្គល្លានព្រាហ្មណ៍ និងទីដែលព្រះអានន្ទមានអាយុគង់នៅ លុះចូលទៅដល់ហើយ ក៏ធ្វើសេចក្តីរីករាយ ជាមួយនឹងព្រះអានន្ទមានអាយុ លុះបញ្ចប់ពាក្យដែលគួររីករាយ និងពាក្យដែលគួរ

ឯកមន្តំ និសីទិ ។ ឯកមន្តំ និសិន្នោ ខោ វស្សការោ ព្រាហ្មណោ មគធមហាមត្តោ អាយស្មន្តំ អានន្ទំ ឯតទវោច កាយ នុត្ថ ភោ អានន្ទ ឯតរហិ កថាយ សន្និសិន្នា កា ច បន តេ[1] អន្តរាកថា វិប្បកតាតិ ។ ឥធ មំ ព្រាហ្មណ គោបកមោគ្គល្លានោ ព្រាហ្មណោ ឯវមាហ អត្ថិ នុ ខោ ភោ អានន្ទ ឯកភិក្ខុបិ តេហិ ធម្មេហិ សព្វេន សព្វំ សព្វថា សព្វំ សមន្នាគតោ យេហិ ធម្មេហិ សមន្នាគតោ សោ ភវំ គោតមោ អហោសិ អរហំ សម្មាសម្ពុទ្ធោតិ ឯវំ វុត្តេ អហំ ព្រាហ្មណ គោបកមោគ្គល្លានំ ព្រាហ្មណំ ឯតទវោចំ នត្ថិ ខោ ព្រាហ្មណ ឯកភិក្ខុបិ តេហិ ធម្មេហិ សព្វេន សព្វំ សព្វថា សព្វំ សមន្នាគតោ យេហិ ធម្មេហិ សមន្នាគតោ សោ ភគវា អហោសិ អរហំ សម្មាសម្ពុទ្ធោ សោ ហិ ព្រាហ្មណ ភគវា អនុប្បន្នស្ស មគ្គស្ស ឧប្បាទេតា អសញ្ជាតស្ស មគ្គស្ស សញ្ជនេតា អនក្ខាតស្ស មគ្គស្ស អក្ខាតា មគ្គញ្ញូ

---

១ ឱ. ម. វោ ។

រលឹកហើយ ក៏អង្គុយក្នុងទីសមគួរ ។ លុះវស្សការព្រាហ្មណ៍ ជាមហាមាត្យក្នុងដែនមគធៈ អង្គុយក្នុងទីសមគួរហើយ ក៏សួរព្រះអានន្ទមានអាយុដូច្នេះថា បពិត្រព្រះអានន្ទដ៏ចម្រើន ក្នុងកាលអម្បាញ់មិញនេះ លោកម្ចាស់ប្រជុំគ្នាពោល អំពីរឿងអ្វី មួយទៀត ពាក្យជាចន្លោះដូចម្តេច ដែលលោកម្ចាស់ធ្វើមិនទាន់ស្រេច ។ ព្រះអានន្ទឆ្លើយថា ម្នាលព្រាហ្មណ៍ គោបកមោគ្គល្លានព្រាហ្មណ៍ បានសួរអាត្មាក្នុងទីនេះយ៉ាងនេះថា បពិត្រព្រះអានន្ទដ៏ចម្រើន ព្រះគោតមដ៏ចម្រើនអង្គនោះ ជាអរហន្តសម្មាសម្ពុទ្ធ ប្រកបដោយធម៌ទាំងឡាយណា ភិក្ខុមួយរូប ដែលប្រកបដោយធម៌ទាំងឡាយនោះ ដោយអាការទាំងពួង ដោយប្រការទាំងពួង មានដែរឬទេ ម្នាលព្រាហ្មណ៍ កាលបើគោបកមោគ្គល្លានព្រាហ្មណ៍ សួរយ៉ាងនេះហើយ អាត្មាក៏បានប្រាប់ ទៅគោបកមោគ្គល្លានព្រាហ្មណ៍វិញ ដូច្នេះថា ម្នាលព្រាហ្មណ៍ ព្រះមានព្រះភាគអង្គនោះ ជាអរហន្តសម្មាសម្ពុទ្ធ ប្រកបដោយធម៌ទាំងឡាយណា សូម្បីភិក្ខុមួយរូប ដែលប្រកបដោយធម៌ទាំងឡាយនោះ ដោយអាការទាំងពួង ដោយប្រការទាំងពួង មិនមានទេ ព្រោះថា ព្រះមានព្រះភាគអង្គនោះ ជាអ្នកបង្កើតផ្លូវដែលមិនទាន់កើតឡើង ជាអ្នករៀបចំផ្លូវដែលមិនទាន់រៀបចំ ជាអ្នកប្រាប់ផ្លូវដែលគេមិនបានប្រាប់ ជាអ្នកស្គាល់ផ្លូវ

មគ្គវិទូ មគ្គកោវិទោ មគ្គានុគា ច បន ឯតរហិ សាវកា វិហរន្តិ បច្ឆា សមន្នាគតាតិ ។ អយំ ខោ នោ ព្រាហ្មណ គោបកមោគ្គល្លានេន ព្រាហ្មណេន សទ្ធឹ អន្តរាកថា វិប្បកតា អថ ត្វំ អនុប្បត្តោតិ ។

(១០៨) អត្ថិ នុ ខោ ភោ អានន្ទ ឯកភិក្ខុបិ តេន ភោតា គោតមេន ឋបិតោ អយំ វោ មមច្ចយេន បដិសរណំ ភវិស្សតីតិ យំ តុម្ហេ ឯតរហិ បដិធាវេយ្យាថាតិ[១] ។ នត្ថិ ខោ ព្រាហ្មណ ឯកភិក្ខុបិ តេន ភគវតា ជានតា បស្សតា អរហតា សម្មាសម្ពុទ្ធេន ឋបិតោ អយំ វោ មមច្ចយេន បដិសរណំ ភវិស្សតីតិ យំ មយំ ឯតរហិ បដិធាវេយ្យាមាតិ ។

---

១ ម. បដិធាទេយ្យាថាតិ ។

ដឹងផ្លូវ ឈ្លាសវៃក្នុងផ្លូវ ពួកសាវ័កក្នុងកាលឥឡូវនេះ គ្រាន់តែជាអ្នកដើរតាមផ្លូវ ប្រកបតាមជាខាងក្រោយប៉ុណ្ណោះ ម្នាលព្រាហ្មណ៍ ពាក្យជាចន្លោះនេះឯង ដែលយើងធ្វើមិនទាន់សម្រេច ជាមួយនឹងគោបកមោគ្គល្លានព្រាហ្មណ៍នៅឡើយ ក៏ស្រាប់តែអ្នកមកដល់ ។

(១០៨) បពិត្រព្រះអានន្ទដ៏ចម្រើន ក្នុងកាលឥឡូវនេះ លោកម្ចាស់ទាំងឡាយ គប្បីប្រតិបត្តិតាមបុគ្គលណា បុគ្គលនោះ សូម្បីជាភិក្ខុមួយរូប ដែលព្រះគោតមដ៏ចម្រើនអង្គនោះ បានតាំងទុកហើយថា ភិក្ខុនេះ អំណើះអំពីតថាគតទៅ នឹងបានជាទីពឹងនៃអ្នកទាំងឡាយ ដូច្នេះ មានដែរឬទេ ។ ម្នាលព្រាហ្មណ៍ ក្នុងកាលឥឡូវនេះ យើងទាំងឡាយ គប្បីប្រតិបត្តិតាមបុគ្គលណា បុគ្គលនោះ សូម្បីជាភិក្ខុមួយរូប ដែលព្រះមានព្រះភាគអង្គនោះ ជាអរហន្តសម្មាសម្ពុទ្ធ ទ្រង់ជ្រាបច្បាស់ ឃើញច្បាស់ បានតាំងទុកហើយថា ភិក្ខុនេះ អំណើះអំពីតថាគតទៅ នឹងបានជាទីពឹងនៃអ្នកទាំងឡាយ ដូច្នេះ មិនមានទេ ។

(១០៩) អត្ថិ បន ភោ អានន្ទ ឯកភិក្ខុបិ សង្ឃេន សម្មតោ សម្ពហុលេហិ ថេរេហិ ភិក្ខូហិ ឋបិតោ អយំ នោ ភគវតោ អច្ចយេន បដិសរណំ ភវិស្សតីតិ យំ តុម្ហេ ឯតរហិ បដិបាទេយ្យាថាតិ ។ នត្ថិ ខោ ព្រាហ្មណ ឯកភិក្ខុបិ សង្ឃេន សម្មតោ សម្ពហុលេហិ ថេរេហិ ភិក្ខូហិ ឋបិតោ អយំ នោ ភគវតោ អច្ចយេន បដិសរណំ ភវិស្សតីតិ យំ មយំ ឯតរហិ បដិបាទេយ្យាមាតិ ។ ឯវំ អប្បដិសរណេ ច បន ភោ អានន្ទ កោ ហេតុ ធម្មសាមគ្គិយាតិ(១) ។ ន ខោ មយំ ព្រាហ្មណ អប្បដិសរណា សប្បដិសរណា មយំ ព្រាហ្មណ ធម្មប្បដិសរណាតិ ។

១ ឱ. ម. សាមគ្គិយាតិ ។

ទេវទហវគ្គ គោបកមោគ្គល្លានសូត្រ ភាពនៃបុគ្គលមានធម៌ជាទីពឹង

[១០៩] បពិត្រព្រះអានន្ទដ៏ចម្រើន ក្នុងកាលឥឡូវនេះ លោកម្ចាស់ទាំងឡាយ គប្បីប្រតិបត្តិតាមបុគ្គលណា បុគ្គលនោះ សូម្បីជាភិក្ខុមួយរូប ដែលសង្ឃបានសន្មតហើយ ឬដែលពួកភិក្ខុជាថេរៈច្រើនអង្គ បានតាំងទុកហើយថា ភិក្ខុនេះ អំណើះអំពីព្រះមានព្រះភាគទៅ នឹងបានជាទីពឹងនៃយើងទាំងឡាយ ដូច្នេះ មាននៅឬទេ ។ ម្នាលព្រាហ្មណ៍ ក្នុងកាលឥឡូវនេះ យើងទាំងឡាយ គប្បីប្រតិបត្តិតាមបុគ្គលណា បុគ្គលនោះ សូម្បីជាភិក្ខុមួយរូប ដែលសង្ឃបានសន្មតហើយ ឬដែលពួកភិក្ខុជាថេរៈច្រើនអង្គ បានតាំងទុកហើយថា ភិក្ខុនេះ អំណើះអំពីព្រះមានព្រះភាគទៅ នឹងបានទៅទីពឹងនៃយើងទាំងឡាយ ដូច្នេះ មិនមានទេ ។ បពិត្រព្រះអានន្ទដ៏ចម្រើន កាលបើមិនមានទីពឹងយ៉ាងនេះហើយ ចុះធម៌ដូចម្តេច ដែលជាហេតុនាំឲ្យកើតធម៌សាមគ្គីបាន ។ ម្នាលព្រាហ្មណ៍ យើងទាំងឡាយ មិនមែនជាឥតទីពឹងទេ ម្នាលព្រាហ្មណ៍ យើងទាំងឡាយប្រកបដោយទីពឹង គឺមានធម៌ជាទីពឹង ។

(១១០) អត្ថិ នុ ខោ ភោ អានន្ទ ឯកភិក្ខុបិ តេន ភោតា គោតមេន ឋបិតោ អយំ វោ មមច្ចយេន បដិសរណំ ភវិស្សតីតិ យំ តុម្ហេ ឯតរហិ បដិបាទេយ្យាថាតិ ឥតិ បុដ្ឋោ សមានោ នត្ថិ ខោ ព្រាហ្មណ ឯកភិក្ខុបិ តេន ភគវតា ជានតា បស្សតា អរហតា សម្មាសម្ពុទ្ធេន ឋបិតោ អយំ វោ មមច្ចយេន បដិសរណំ ភវិស្សតីតិ យំ មយំ ឯតរហិ បដិបាទេយ្យាមាតិ វទេសិ ។ អត្ថិ បន ភោ[១] អានន្ទ ឯកភិក្ខុបិ សង្ឃេន សម្មតោ សម្ពហុលេហិ ថេរេហិ ភិក្ខូហិ ឋបិតោ អយំ នោ ភគវតោ អច្ចយេន បដិសរណំ ភវិស្សតីតិ យំ តុម្ហេ ឯតរហិ បដិបាទេយ្យាថាតិ ឥតិ បុដ្ឋោ សមានោ

១ ឱ. បន ភោ គោតិ ទិស្សតិ ។

(១១០) កាលខ្ញុំសួរថា បពិត្រព្រះអានន្ទដ៏ចំរើន ក្នុងកាលឥឡូវនេះ លោកម្ចាស់ទាំងឡាយ គប្បីប្រតិបត្តិតាមបុគ្គលណា បុគ្គលនោះ សូម្បីជាភិក្ខុមួយរូប ដែលព្រះគោតមដ៏ចំរើននោះ បានតាំងទុកហើយថា ភិក្ខុនេះ អំណើះអំពីតថាគតទៅ នឹងបានជាទីពឹងនៃអ្នកទាំងឡាយ ដូច្នេះ មានដែរឬទេ លោកម្ចាស់ឆ្លើយថា ម្នាលព្រាហ្មណ៍ ក្នុងកាលឥឡូវនេះ យើងទាំងឡាយគប្បីប្រតិបត្តិតាមបុគ្គលណា បុគ្គលនោះ សូម្បីជាភិក្ខុមួយរូប ដែលព្រះមានព្រះភាគអង្គនោះ ជាអរហន្តសម្មាសម្ពុទ្ធ ទ្រង់ជ្រាបច្បាស់ ឃើញច្បាស់ បានតាំងទុកហើយថា ភិក្ខុនេះ អំណើះអំពីតថាគតទៅ នឹងបានជាទីពឹងនៃអ្នកទាំងឡាយ ដូច្នេះ មិនមានទេ ។ កាលដែលខ្ញុំសួរថា បពិត្រព្រះអានន្ទដ៏ចំរើន ក្នុងកាលឥឡូវនេះ លោកម្ចាស់ទាំងឡាយ គប្បីប្រតិបត្តិតាមបុគ្គលណា បុគ្គលនោះ សូម្បីជាភិក្ខុមួយរូប ដែលសង្ឃសន្មតហើយ ឬដែលពួកភិក្ខុជាថេរៈច្រើនអង្គ បានតាំងទុកហើយថា ភិក្ខុនេះ អំណើះអំពីព្រះមានព្រះភាគទៅ នឹងបានជាទីពឹងនៃអ្នកទាំងឡាយ ដូច្នេះ មានដែរឬទេ

នត្ថិ ខោ ព្រាហ្មណ ឯកភិក្ខុបិ សង្ឃេន សម្មតោ សម្ពហុលេហិ ថេរេហិ ភិក្ខូហិ ឋបិតោ អយំ នោ ភគវតោ អច្ចយេន បដិសរណំ ភវិស្សតីតិ យំ អយំ ឯតរហិ បដិបជ្ជេយ្យាមាតិ វទេសិ ។ ឯវំ អប្បដិសរណេ ច បន ភោ អានន្ទ កោ ហេតុ ធម្មសាមគ្គិយាតិ ឥតិ បុដ្ឋោ សមានោ ន ខោ ព្រាហ្មណ អប្បដិ-សរណា សប្បដិសរណា មយំ ព្រាហ្មណ ធម្មប្បដិ-សរណាតិ វទេសិ ។ ឥមស្ស បន ភោ អានន្ទ ។ ភាសិតស្ស កថំ អត្ថោ ទដ្ឋព្វោតិ ។

(១១១) អត្ថិ ខោ ព្រាហ្មណ តេន ភគវតា ជានតា បស្សតា អរហតា សម្មាសម្ពុទ្ធេន ភិក្ខូនំ សិក្ខាបទំ បញ្ញត្តំ បាតិមោក្ខំ ឧទ្ទិដ្ឋំ តេ មយំ តទហុបោសថេ យាវតិកា ឯកំ គាមក្ខេត្តំ ឧប-និស្សាយ វិហរាម តេ សព្វេ ឯកជ្ឈំ សន្និបតាម សន្និបតិត្វា យស្ស តំ វត្តតិ តំ អជ្ឈេសាម

លោកម្ចាស់ឆ្លើយថា ម្នាលព្រាហ្មណ៍ ក្នុងកាលឥឡូវនេះ យើងទាំងឡាយ គប្បីប្រតិបត្តិតាមបុគ្គលណា បុគ្គលនោះ សូម្បីជាភិក្ខុមួយរូប ដែលសង្ឃបានសន្មតហើយ ឬដែលពួកភិក្ខុជាថេរៈច្រើនអង្គ បានតាំងទុកហើយថា ភិក្ខុនេះ អំណើះអំពីព្រះមានព្រះភាគទៅ នឹងបានជាទីពឹងនៃយើងទាំងឡាយ ដូច្នេះ មិនមានទេ ។ កាលខ្ញុំសួរថា បពិត្រព្រះអានន្ទដ៏ចម្រើន កាលបើមិនមានទីពឹងយ៉ាងនេះហើយ ចុះធម៌ដូចម្តេច ដែលជាហេតុនាំឲ្យកើតធម៌សាមគ្គីបាន លោកម្ចាស់ឆ្លើយថា ម្នាលព្រាហ្មណ៍ យើងទាំងឡាយ មិនមែនជាឥតទីពឹងទេ ម្នាលព្រាហ្មណ៍ យើងទាំងឡាយ ប្រកបដោយទីពឹង គឺមានធម៌ជាទីពឹង ។ បពិត្រព្រះអានន្ទដ៏ចម្រើន សេចក្តីនៃភាសិតនេះ ត្រូវយល់ដូចម្តេច ។

(១១១) ម្នាលព្រាហ្មណ៍ ព្រះមានព្រះភាគអង្គនោះ ជាអរហន្តសម្មាសម្ពុទ្ធ ទ្រង់ជ្រាបច្បាស់ ឃើញច្បាស់ បានបញ្ញត្តសិក្ខាបទទុកហើយ បានសំដែងបាតិមោក្ខដល់ភិក្ខុទាំងឡាយរួចហើយ យើងទាំងឡាយនោះ មានប៉ុន្មានរូប ក៏ចូលទៅអាស្រ័យនៅនឹងគាមខេត្តមួយ ប្រជុំគ្នាទាំងអស់ក្នុងកន្លែងមួយ នាថ្ងៃឧបោសថ លុះប្រជុំគ្នាហើយ ភិក្ខុណាចាំស្ទាត់នូវបាតិមោក្ខនោះ ក៏នាំគ្នាអារាធនាភិក្ខុនោះ ( ឲ្យសូត្រ )

តស្មិំ ចេ ភញ្ញមានេ ហោតិ ភិក្ខុស្ស អាបត្តិ ហោតិ វីតិក្កមោ តំ មយំ យថាធម្មំ យថានុសិដ្ឋំ ការេមាតិ ន កិរ នោ ភវន្តោ ការេន្តិ ធម្មោ នោ ការេតីតិ ។ អត្ថិ នុ ខោ ភោ អានន្ទ ឯកភិក្ខុបិ យំ តុម្ហេ ឯតរហិ សក្ករោថ គរុករោថ មានេថ បូជេថ សក្កត្វា គរុកត្វា ឧបនិស្សាយ វិហរថាតិ ។ អត្ថិ ខោ ព្រាហ្មណ ឯកភិក្ខុបិ យំ មយំ ឯតរហិ សក្ករោម គរុករោម មានេម បូជេម សក្កត្វា គរុកត្វា ឧបនិស្សាយ វិហរាមាតិ ។

(១១២) អត្ថិ នុ ខោ ភោ អានន្ទ ឯកភិក្ខុបិ តេន ភោតា គោតមេន ឋបិតោ អយំ វោ មមច្ចយេន បដិសរណំ ភវិស្សតីតិ យំ តុម្ហេ ឯតរហិ បដិបាទេយ្យាថាតិ ឥតិ បុដ្ឋោ សមានោ នត្ថិ ខោ ព្រាហ្មណ

កាលបើបាតិមោក្ខនោះ ភិក្ខុកំពុងសូត្រ ភិក្ខុណាត្រូវអាបត្តិ ឬប្រព្រឹត្ត កន្លង (បញ្ញត្តិ) យើងទាំងឡាយតែងញុំាងភិក្ខុនោះ ឲ្យធ្វើតាមធម៌ តាមពាក្យប្រៀនប្រដៅ ព្រោះហេតុនោះ តាមពិត លោកដ៏ចម្រើនទាំងឡាយមិនបានញុំាងភិក្ខុនោះឲ្យធ្វើទេ គឺធម៌ (ច្បាប់) ញុំាងភិក្ខុនោះឲ្យធ្វើ ៗ បពិត្រព្រះអានន្ទដ៏ចម្រើន ចុះភិក្ខុសូម្បីមួយរូប ដែលលោកម្ចាស់ទាំងឡាយ ធ្វើសក្ការៈ គោរព រាប់អាន បូជា ក្នុងកាលឥឡូវនេះ លុះធ្វើសក្ការៈ គោរពហើយ តែងនៅអាស្រ័យផង តើមានដែរឬទេ ៗ ម្នាលព្រាហ្មណ៍ ភិក្ខុសូម្បីមួយរូប ដែលយើងទាំងឡាយ ធ្វើសក្ការៈ គោរព រាប់អាន បូជា ក្នុងកាលឥឡូវនេះ លុះធ្វើសក្ការៈ គោរពហើយ តែងនៅអាស្រ័យផង មានដែរ ៗ

[១១២] កាលដែលខ្ញុំសួរថា បពិត្រព្រះអានន្ទដ៏ចម្រើន ក្នុងកាលឥឡូវនេះ លោកម្ចាស់ទាំងឡាយ គប្បីប្រតិបត្តិតាមបុគ្គលណា បុគ្គលនោះ សូម្បីជាភិក្ខុមួយរូប ដែលព្រះគោតមដ៏ចម្រើនអង្គនោះ បានតាំងទុកហើយថា ភិក្ខុនេះ អំណើះអំពីតថាគតទៅ នឹងបានជាទីពឹងនៃអ្នកទាំងឡាយ ដូច្នេះ មានដែរឬទេ លោកម្ចាស់ឆ្លើយថា ម្នាលព្រាហ្មណ៍

ឯកភិក្ខុបិ តេន ភគវតា ជានតា បស្សតា អរហតា សម្មាសម្ពុទ្ធេន ឋបិតោ អយំ វោ មមច្ចយេន បដិសរណំ ភវិស្សតីតិ យំ មយំ ឯតរហិ បដិបាទេយ្យាមាតិ វទេសិ ។ អត្ថិ បន ភោ អានន្ទ ឯកភិក្ខុបិ សង្ឃេន សម្មតោ សម្ពហុលេហិ ថេរេហិ ភិក្ខូហិ ឋបិតោ អយំ នោ ភគវតោ អច្ចយេន បដិសរណំ ភវិស្សតីតិ យំ តុម្ហេ ឯតរហិ បដិបាទេយ្យាថាតិ ឥតិ បុដ្ឋោ សមានោ នត្ថិ ខោ ព្រាហ្មណ ឯកភិក្ខុបិ សង្ឃេន សម្មតោ សម្ពហុលេហិ ថេរេហិ ភិក្ខូហិ ឋបិតោ អយំ នោ ភគវតោ អច្ចយេន បដិសរណំ ភវិស្សតីតិ យំ មយំ ឯតរហិ បដិបាទេយ្យាមាតិ វទេសិ ។ អត្ថិ នុ ខោ ភោ អានន្ទ ឯកភិក្ខុបិ យំ តុម្ហេ ឯតរហិ សក្ករោថ

ក្នុងកាលឥឡូវនេះ យើងទាំងឡាយ គប្បីប្រតិបត្តិ តាមបុគ្គលណា បុគ្គលនោះ សូម្បីជាភិក្ខុមួយរូប ដែលព្រះមានព្រះភាគអង្គនោះ ជាអរហន្តសម្មាសម្ពុទ្ធ ទ្រង់ជ្រាបច្បាស់ ឃើញច្បាស់ បានតាំងទុកហើយថា ភិក្ខុនេះ អំណើះអំពីតថាគតទៅ នឹងបានជាទីពឹងនៃអ្នកទាំងឡាយ ដូច្នេះ មិនមានទេ ។ កាលដែលខ្ញុំសួរថា បពិត្រព្រះអានន្ទដ៏ចម្រើន ក្នុងកាលឥឡូវនេះ លោកម្ចាស់ទាំងឡាយ គប្បីប្រតិបត្តិតាមបុគ្គលណា បុគ្គលនោះ សូម្បីជាភិក្ខុមួយរូប ដែលសង្ឃបានសន្មតហើយ ឬដែលពួកភិក្ខុជាថេរៈច្រើនអង្គ បានតាំងទុកហើយថា ភិក្ខុនេះ អំណើះអំពីព្រះមានព្រះភាគទៅ នឹងបានជាទីពឹងនៃយើងទាំងឡាយ ដូច្នេះ មានដែរឬទេ លោកម្ចាស់ឆ្លើយថា ម្នាលព្រាហ្មណ៍ ក្នុងកាលឥឡូវនេះ យើងទាំងឡាយ គប្បីប្រតិបត្តិតាមបុគ្គលណា បុគ្គលនោះ សូម្បីជាភិក្ខុមួយរូប ដែលសង្ឃបានសន្មតហើយ ឬដែលពួកភិក្ខុជាថេរៈច្រើនអង្គ បានតាំងទុកហើយថា ភិក្ខុនេះ អំណើះអំពីព្រះមានព្រះភាគទៅ នឹងបានជាទីពឹងនៃយើងទាំងឡាយ ដូច្នេះ មិនមានទេ ។ កាលដែលខ្ញុំសួរថា បពិត្រព្រះអានន្ទដ៏ចម្រើន ចុះភិក្ខុសូម្បីមួយរូប ដែលលោកម្ចាស់ទាំងឡាយ

គរុករេថ មានេថ បូជេថ សក្កត្វា គរុកត្វា ឧបនិស្សាយ វិហរថាតិ ឥតិ បុដ្ឋោ សមានោ នត្ថិ ខោ ព្រាហ្មណ ឯកភិក្ខុបិ យំ មយំ ឯតរហិ សក្ករេម គរុករេម មានេម បូជេម សក្កត្វា គរុកត្វា ឧបនិស្សាយ វិហរាមាតិ វទេសិ ។ ឥមស្ស ភោ អានន្ទ ភាសិតស្ស កថំ អត្ថោ ទដ្ឋព្វោតិ ។

(១១៣) អត្ថិ ខោ ព្រាហ្មណ តេន ភគវតា ជានតា បស្សតា អរហតា សម្មាសម្ពុទ្ធេន ទស បសាទនីយា ធម្មា អក្ខាតា យស្មឹ នោ តេ(១) ធម្មា សំវិជ្ជន្តិ តំ មយំ ឯតរហិ សក្ករោម គរុករោម មានេម បូជេម សក្កត្វា គរុកត្វា ឧបនិស្សាយ វិហរាម កតមេ ទស ឥធ ព្រាហ្មណ ភិក្ខុ សីលវា ហោតិ បាតិមោក្ខសំវរសំវុតោ វិហរតិ អាចារគោចរសម្បន្នោ អណុមត្តេសុ វជ្ជេសុ ភយទស្សាវី សមាទាយ សិក្ខតិ សិក្ខាបទេសុ ។

១ ឱ, ឥមេតិ ទិស្សតិ ។

ធ្វើសក្ការៈ គោរព រាប់អាន បូជា ក្នុងកាលឥឡូវនេះ លុះធ្វើសក្ការៈ គោរពហើយ តែងនៅអាស្រ័យផង តើមានដែរឬទេ លោកម្ចាស់ឆ្លើយថា ម្នាលព្រាហ្មណ៍ ភិក្ខុសង្ឃមួយរូប ដែលយើងទាំងឡាយ ធ្វើសក្ការៈ គោរព រាប់អាន បូជា ក្នុងកាលឥឡូវនេះ លុះធ្វើសក្ការៈ គោរពហើយ តែងនៅអាស្រ័យផង មានដែរ ។ បពិត្រព្រះអានន្ទដ៏ចម្រើន សេចក្តីនៃការសិតនេះ ត្រូវយល់ដូចម្តេច ។

(១១៣) ម្នាលព្រាហ្មណ៍ បសាទនីយធម៌ (ធម៌ជាទីតាំងនៃសេចក្តីជ្រះថ្លា) ១០ យ៉ាង ដែលព្រះមានព្រះភាគ អង្គនោះ ជាអរហន្តសម្មាសម្ពុទ្ធ ទ្រង់ជ្រាបច្បាស់ ឃើញច្បាស់ បានសំដែងហើយ រមែងមាន បសាទនីយធម៌ទាំងនោះឯង មាននៅក្នុងភិក្ខុណា ក្នុងកាលឥឡូវនេះ យើងទាំងឡាយ តែងធ្វើសក្ការៈ គោរព រាប់អាន បូជា លុះធ្វើសក្ការៈ គោរពហើយ ក៏តែងនៅអាស្រ័យនឹងភិក្ខុនោះ ឯបសាទ-នីយធម៌ ទាំង ១០ យ៉ាងនោះ តើដូចម្តេច ម្នាលព្រាហ្មណ៍ ភិក្ខុក្នុងសាសនានេះ ជាអ្នកមានសីល សង្រួមក្នុងបាតិមោក្ខសំវរៈ បរិបូណ៌ដោយអាចារៈនិងគោចរៈ ជាអ្នកឃើញនូវភ័យ ក្នុងទោសទាំងឡាយសូម្បីបន្តិចបន្តួច តែងសមាទានសិក្សា ក្នុងសិក្ខាបទទាំងឡាយ ១ ។

ពហុស្សុតោ ហោតិ សុតធរោ សុតសន្និចយោ យេ តេ ធម្មា អាទិកល្យាណា មជ្ឈេកល្យាណា បរិយោសានកល្យាណា សាត្ថា សព្យញ្ជនា[1] កេវលបរិបុណ្ណំ បរិសុទ្ធំ ព្រហ្មចរិយំ អភិវទន្តិ តថារូបស្ស ធម្មា ពហុស្សុតា ហោន្តិ ធតា វចសា បរិចិតា មនសានុបេក្ខិតា ទិដ្ឋិយា សុប្បដិវិទ្ធា ។ សន្តុដ្ឋោ ហោតិ ចីវរបិណ្ឌបាតសេនាសនគិលានប្បច្ចយភេសជ្ជបរិក្ខារេហិ ។ ចតុន្នំ ឈានានំ អាភិចេតសិកានំ ទិដ្ឋធម្មសុខវិហារានំ និកាមលាភី ហោតិ អកិច្ឆលាភី អកសិរលាភី ។ អនេកវិហិតំ ឥទ្ធិវិធំ បច្ចនុភោតិ ឯកោបិ ហុត្វា ពហុធា ហោតិ ពហុធាបិ ហុត្វា ឯកោ ហោតិ អាវិភាវំ តិរោភាវំ តិរោកុឌ្ឌំ តិរោបាការំ តិរោបព្វតំ អសជ្ជមានោ គច្ឆតិ សេយ្យថាបិ អាកាសេ បឋវិយាបិ ឧម្មុជ្ជនិម្មុជ្ជំ ករោតិ សេយ្យថាបិ ឧទកេបិ

១ ទី. ម. សាត្ថំ សព្យញ្ជនំ ។

ភិក្ខុជាពហុស្សូត ទ្រទ្រង់នូវពុទ្ធវចនៈ សន្សំទុកនូវពុទ្ធវចនៈ ធម៌ទាំងឡាយណា ដែលមានលំអខាងដើម មានលំអកណ្ដាល មានលំអខាងចុង បរិបូណ៌ដោយអត្ថ បរិបូណ៌ដោយព្យញ្ជនៈ រមែងប្រកាសនូវព្រហ្មចរិយៈដ៏បរិសុទ្ធ បរិបូណ៌គ្រប់គ្រាន់ ធម៌ទាំងឡាយមានសភាពដូច្នោះ ភិក្ខុនោះបានចេះចាំ ដោយច្រើន បានទ្រទ្រង់ទុក ចាំស្ទាត់ រត់មាត់ ចូលចិត្តច្បាស់លាស់ យល់ជ្រាលជ្រៅ ដោយទិដ្ឋិ គឺបញ្ញា ១ ។ ភិក្ខុជាអ្នកសន្តោស ដោយចីវរ បិណ្ឌបាត សេនាសនៈ គិលានប្បច្ចយភេសជ្ជ-បរិក្ខារ ១ ។ ភិក្ខុជាអ្នកបានដូចសេចក្ដីប្រាថ្នា បានដោយមិនលំបាក បានដោយមិនខុសកាលវេលា នូវឈានទាំង ៤ ដែលជាធម្មជាតអាស្រ័យនូវចិត្តដ៏ថ្លៃថ្លា ជាគ្រឿងនៅជាសុខ ក្នុងបច្ចុប្បន្ន ១ ។ ភិក្ខុបាននូវឫទ្ធិ ជាច្រើនប្រការ គឺមនុស្សម្នាក់ ធ្វើឲ្យទៅជាច្រើននាក់ក៏បាន មនុស្សច្រើននាក់ ធ្វើឲ្យទៅជាម្នាក់វិញក៏បាន ដើរ (ចេញពីខាងក្នុង) ទៅកាន់ទីវាល ទីខាងក្រៅក៏បាន ដើរទម្លុះទៅ ខាងក្រៅជញ្ជាំង ខាងក្រៅកំពែង ខាងក្រៅភ្នំក៏បាន ឥតទើសទាល់ ដូចជាដើរទៅក្នុងអាកាស ធ្វើនូវការងើបឡើងនិងមុជចុះក្នុងផែនដី ដូចមុជក្នុងទឹកក៏បាន

ឧទកេ អភិជ្ជមានេ គច្ឆតិ សេយ្យថាបិ បឋវិយំ អាកាសេបិ បល្លង្កេន កមតិ(១) សេយ្យថាបិ បក្ខី សកុណោ ឥមេបិ ចន្ទិមសុរិយេ ឯវំមហិទ្ធិកេ ឯវំមហានុភាវេ បាណិនា បរិមសតិ បរិមជ្ជតិ យាវ ព្រហ្មលោកាបិ កាយេន វសំ វត្តេតិ ។ ទិព្វាយ សោតធាតុយា វិសុទ្ធាយ អតិក្កន្តមានុសិកាយ ឧភោ សទ្ទេ សុណាតិ ទិព្វេ ច មានុសេ ច យេ ទូរេ សន្តិកេ ច ។ បរសត្តានំ បរបុគ្គលានំ ចេតសា ចេតោ បរិច្ច បជានាតិ ។ សរាគំ វា ចិត្តំ សរាគំ ចិត្តន្តិ បជានាតិ វីតរាគំ វា ចិត្តំ វីតរាគំ ចិត្តន្តិ បជានាតិ ។ សទោសំ វា ចិត្តំ សទោសំ ចិត្តន្តិ បជានាតិ វីតទោសំ វា ចិត្តំ វីតទោសំ ចិត្តន្តិ បជានាតិ ។ សមោហំ វា ចិត្តំ សមោហំ ចិត្តន្តិ បជានាតិ វីតមោហំ វា ចិត្តំ

១ ឱ. បក្កមតិ ។

ដើរទៅលើទឹកក៏មិនបែកធ្លាយទឹក ដូចជាដើរលើផែនដីក៏បាន ហោះទៅក្នុងអាកាសទាំងភ្នែន ដូចជាបក្សីសកុណជាតិក៏បាន យកដៃទៅស្ទាបអង្អែលចាប់ពាល់នូវព្រះចន្ទ្រនិងព្រះអាទិត្យទាំងនេះ ដែលមានឫទ្ធិច្រើនយ៉ាងនេះ មានអានុភាពច្រើនយ៉ាងនេះក៏បាន ញ៉ាំងអំណាចឲ្យប្រព្រឹត្តទៅដោយកាយ ដរាបដល់ព្រហ្មលោកក៏បាន ១ ។ ភិក្ខុមានសោតធាតុជាទិព្វដ៏បរិសុទ្ធ កន្លងនូវសោតធាតុ ជារបស់មនុស្សធម្មតា តែងឮនូវសំឡេងទាំងពីរ គឺសំឡេងជាទិព្វ និងសំឡេង ជារបស់មនុស្សធម្មតាដែលនៅក្នុងទីឆ្ងាយក្តី ក្នុងទីជិតក្តី ១ ។ ភិក្ខុកំណត់ដឹងចិត្តនៃពួកសត្វដទៃ នៃបុគ្គលដទៃ ដោយចិត្តរបស់ខ្លួនបាន ។ ចិត្តដែលប្រកបដោយរាគៈក្តី ក៏ដឹងច្បាស់ថា ចិត្តប្រកបដោយរាគៈ ចិត្តដែលប្រាសចាករាគៈក្តី ក៏ដឹងច្បាស់ថា ចិត្តប្រាសចាករាគៈ ។ ចិត្តដែលប្រកបដោយទោសៈក្តី ក៏ដឹងច្បាស់ថា ចិត្តប្រកបដោយទោសៈ ចិត្តដែលប្រាសចាកទោសៈក្តី ក៏ដឹងច្បាស់ថា ចិត្តប្រាសចាកទោសៈ ។ ចិត្តដែលប្រកបដោយមោហៈក្តី ក៏ដឹងច្បាស់ថា ចិត្តប្រកបដោយមោហៈ ចិត្តដែលប្រាសចាកមោហៈក្តី

វីតមោហំ ចិត្តន្តិ បជានាតិ ។ សង្ខិត្តំ វា ចិត្តំ សង្ខិត្តំ ចិត្តន្តិ បជានាតិ វិក្ខិត្តំ វា ចិត្តំ វិក្ខិត្តំ ចិត្តន្តិ បជានាតិ ។ មហគ្គតំ វា ចិត្តំ មហគ្គតំ ចិត្តន្តិ បជានាតិ អមហគ្គតំ វា ចិត្តំ អមហគ្គតំ ចិត្តន្តិ បជា-ជាតិ ។ សឧត្តរំ វា ចិត្តំ សឧត្តរំ ចិត្តន្តិ បជានាតិ អនុត្តរំ វា ចិត្តំ អនុត្តរំ ចិត្តន្តិ បជានាតិ ។

សមាហិតំ វា ចិត្តំ សមាហិតំ ចិត្តន្តិ បជានាតិ អសមាហិតំ វា ចិត្តំ អសមាហិតំ ចិត្តន្តិ បជា-ជាតិ ។ វិមុត្តំ វា ចិត្តំ វិមុត្តំ ចិត្តន្តិ បជានាតិ អវិមុត្តំ វា ចិត្តំ អវិមុត្តំ ចិត្តន្តិ បជានាតិ ។ អនេកវិហិតំ បុព្វេនិវាសំ អនុស្សរតិ សេយ្យថីទំ ឯកម្បិ ជាតឹ ទ្វេបិ ជាតិយោ តិស្សោបិ ជាតិយោ ចតស្សោបិ ជាតិយោ បញ្ចបិ ជាតិយោ ទសបិ ជាតិយោ វីសម្បិ ជាតិយោ តឹសម្បិ ជាតិយោ ចត្តាឡីសម្បិ ជាតិយោ បញ្ញាសម្បិ ជាតិយោ ជាតិសតម្បិ ជាតិសហស្សម្បិ

ក៏ដឹងច្បាស់ថា ចិត្តប្រាសចាកមោហៈ ។ ចិត្តដែលរួញរាក្តី ក៏ដឹងច្បាស់ថា ចិត្តរួញរា ចិត្តដែលរាយមាយក្តី ក៏ដឹងច្បាស់ថា ចិត្តរាយមាយ ។ ចិត្តដែលជាមហគ្គតៈ (ចិត្តដល់នូវភាពជាធំ បានដល់រូបាវចរៈនិងអរូបាវចរៈ ) ក្តី ក៏ដឹងច្បាស់ថា ចិត្តជាមហគ្គតៈ ចិត្តដែលមិនមែនជាមហគ្គតៈ គឺកាមាវចរៈក្តី ក៏ដឹងច្បាស់ថា ចិត្តមិនមែនជាមហគ្គតៈ ។ ចិត្តដែលជាសឧត្តរៈគឺជាកាមាវចរៈក្តី ក៏ដឹងច្បាស់ថាចិត្តជាសឧត្តរៈចិត្តដែលជាអនុត្តរៈ គឺជារូបាវចរៈនិងអរូបាវចរៈក្តី ក៏ដឹងច្បាស់ថា ចិត្តជាអនុត្តរៈ ។ ចិត្តដែលតាំងមាំក្តី ក៏ដឹងច្បាស់ថា ចិត្តតាំងមាំ ចិត្តដែលមិនតាំងមាំក្តី ក៏ដឹងច្បាស់ថា ចិត្តមិនតាំងមាំ ។ ចិត្តដែលរួចស្រឡះក្តី ក៏ដឹងច្បាស់ថា ចិត្តរួចស្រឡះ ចិត្តដែលមិនទាន់រួចស្រឡះក្តី ក៏ដឹងច្បាស់ថា ចិត្តមិនទាន់រួចស្រឡះ១ ។ ភិក្ខុរលឹកឃើញនូវបុព្វេនិវាស គឺរលឹកឃើញនូវខន្ធដែលខ្លួនធ្លាប់អាស្រ័យនៅហើយក្នុងកាលមុន ជាច្រើនប្រការ គឺរលឹកបាន ១ ជាតិខ្លះ ២ ជាតិខ្លះ ៣ ជាតិខ្លះ ៤ ជាតិខ្លះ ៥ ជាតិខ្លះ ១០ ជាតិខ្លះ ២០ ជាតិខ្លះ ៣០ ជាតិខ្លះ ៤០ ជាតិខ្លះ ៥០ ជាតិខ្លះ ១០០ ជាតិខ្លះ ១ ពាន់ជាតិខ្លះ

ជាតិសតសហស្សម្បិ អនេកេបិ សំវដ្ដកប្បេ អនេ-
កេបិ វិវដ្ដកប្បេ អនេកេ សំវដ្ដវិវដ្ដកប្បេ អមុត្រាសឹ
ឯវំនាមោ ឯវំគោត្តោ ឯវំវណ្ណោ ឯវមាហារោ ឯវំ
សុខទុក្ខប្បដិសំវេទី ឯវមាយុបរិយន្តោ សោ តតោ
ចុតោ អមុត្រ ឧទបាទឹ តត្រាបាសឹ ឯវំនាមោ
ឯវំគោត្តោ ឯវំវណ្ណោ ឯវមាហារោ ឯវំ សុខទុក្ខប្ប-
ដិសំវេទី ឯវមាយុបរិយន្តោ សោ តតោ ចុតោ
ឥធូបបន្នោតិ ។ ឥតិ សាការំ សឧទ្ទេសំ អនេ-
កវិហិតំ បុព្វេនិវាសំ អនុស្សរតិ ។ ទិព្វេន ចក្ខុនា
វិសុទ្ធេន អតិក្កន្តមានុសកេន សត្តេ បស្សតិ ចវមា-
នេ ឧបបជ្ជមានេ ហីនេ បណីតេ សុវណ្ណេ ទុព្វណ្ណេ

១សែនជាតិខ្លះ សំវដ្តកប្បជាច្រើនខ្លះ វិវដ្តកប្បជាច្រើនខ្លះ សំវដ្តវិវដ្តកប្បជាច្រើនខ្លះថា អាត្មាអញបានកើតក្នុងភពឯណោះ មានឈ្មោះយ៉ាងនេះ មានគោត្រយ៉ាងនេះ មានសម្បុរយ៉ាងនេះ មានអាហារយ៉ាងនេះ បានទទួលសុខនិងទុក្ខយ៉ាងនេះ មានកំណត់អាយុត្រឹមប៉ុណ្ណេះ លុះអាត្មាអញច្យុតចាកភពនោះទៅហើយ បានទៅកើត ក្នុងភពឯណោះទៀត ដែលអាត្មាអញបានកើតក្នុងភពនោះ មានឈ្មោះយ៉ាងនេះ មានគោត្រយ៉ាងនេះ មានសម្បុរយ៉ាងនេះ មានអាហារយ៉ាងនេះ បានទទួលសុខនិងទុក្ខយ៉ាងនេះ មានកំណត់អាយុត្រឹមប៉ុណ្ណេះ លុះអាត្មាអញច្យុតចាកភពនោះហើយ ទើបបានមកកើតក្នុងភពនេះ ។ ភិក្ខុរលឹកឃើញនូវបុព្វេនិវាសជាច្រើនប្រការ ព្រមទាំងអាការ ព្រមទាំងឧទ្ទេស ដោយប្រការដូច្នេះ ១ ។ ភិក្ខុមានចក្ខុទិព្វ ដ៏បរិសុទ្ធ កន្លងនូវចក្ខុជារបស់មនុស្សធម្មតា បានឃើញនូវសត្វទាំងឡាយ ដែលច្យុត ដែលកើត ជាសត្វថោកទាប ឧត្តម មានសម្បុរល្អ មានសម្បុរអាក្រក់

សុតេន ទុត្តេន ។ បេ ។ យថាកម្មូបគេ សត្តេ បជានាតិ ។ អាសវានំ ខយា អនាសវំ ចេតោវិមុត្តឹ បញ្ញាវិមុត្តឹ ទិដ្ឋេវ ធម្មេ សយំ អភិញ្ញា សច្ឆិកត្វា ឧបសម្បជ្ជ វិហរតិ ។ ឥមេ ខោ ព្រាហ្មណ តេន ភគវតា ជានតា បស្សតា អរហតា សម្មាសម្ពុទ្ធេន ទស បសាទនីយា ធម្មា អក្ខាតា យស្មឹ នោ ឥមេ ធម្មា សំវិជ្ជន្តិ តំ មយំ ឯតរហិ សក្ករោម គរុករោម មានេម បូជេម សក្កត្វា គរុកត្វា ឧបនិស្សាយ វិហរាមាតិ ។

(១១៦) ឯវំ វុត្តេ វស្សការោ ព្រាហ្មណោ មគធមហាមត្តោ ឧបនន្ទំ សេនាបតឹ អាមន្តេសិ តំ កឹ មញ្ញសិ ឯវំ សេនាបតិ យទិមេ ភោន្តោ សក្កាតព្វំ សក្ករោន្តិ គរុកាតព្វំ គរុករោន្តិ មានេតព្វំ មានេន្តិ

មានគតិល្អ មានគតិអាក្រក់ ។ បេ ។ តែងដឹងច្បាស់ នូវពួកសត្វដែលប្រព្រឹត្តទៅតាមកម្មរបស់ខ្លួន ១ ។ ភិក្ខុបានធ្វើឲ្យជាក់ច្បាស់ ដោយបញ្ញាដ៏ឧត្តម នៃខ្លួនឯង ក្នុងបច្ចុប្បន្ន នូវចេតោវិមុត្តិ និងបញ្ញាវិមុត្តិ ដែលមិនមានអាសវៈ ព្រោះអស់ទៅ នៃអាសវៈទាំងឡាយ ហើយសម្រេចសម្រាន្តនៅ ដោយឥរិយាបថទាំងបួន ១ ។ ម្នាលព្រាហ្មណ៍ នេះឯង បសាទនីយធម៌ ១០ ប្រការ ដែលព្រះមានព្រះភាគ ជាអរហន្តសម្មាសម្ពុទ្ធអង្គនោះ ទ្រង់ជ្រាបច្បាស់ ឃើញច្បាស់ បានសំដែងហើយ បសាទនីយធម៌ទាំងនេះ មាននៅក្នុងភិក្ខុណា ក្នុងកាលឥឡូវនេះ យើងទាំងឡាយ តែងធ្វើសក្ការៈ គោរព រាប់អាន បូជា លុះធ្វើសក្ការៈ គោរពហើយ ក៏នៅអាស្រ័យនឹងភិក្ខុនោះ ។

(១១៤) កាលព្រះអានន្ទមានអាយុ ពោលយ៉ាងនេះហើយ វស្សការព្រាហ្មណ៍ ជាមហាមាត្យ ក្នុងដែនមគធៈ ក៏ប្រាប់នឹងឧបនន្ទសេនាបតីថា ម្នាលសេនាបតី អ្នកសំគាល់នូវសេចក្តីនោះ ដូចម្តេច បើលោកដ៏ចម្រើនទាំងនេះ ធ្វើសក្ការៈនូវបុគ្គល ដែលគួរធ្វើសក្ការៈ ធ្វើការគោរពនូវបុគ្គលដែលគួរគោរព រាប់អាននូវបុគ្គល ដែលគួររាប់អាន

បូជេតព្វំ បូជេន្តិ តគ្ឃ មេ ភោន្តោ សក្កាតព្វំ សក្ករោន្តិ គរុកាតព្វំ គរុករោន្តិ មានេតព្វំ មានេន្តិ បូជេតព្វំ បូជេន្តិ ឥមញ្ច ហិ តេ ភោន្តោ ន សក្ករេយ្យុំ ន គរុករេយ្យុំ ន មានេយ្យុំ ន បូជេយ្យុំ អថ កិញ្ចរហិ តេ ភោន្តោ សក្ករេយ្យុំ គរុករេយ្យុំ មានេយ្យុំ បូជេយ្យុំ សក្កត្វា គរុកត្វា ឧបនិស្សាយ វិហរេយ្យុន្តិ ។

(១១៩) អថខោ វស្សការោ ព្រាហ្មណោ មគធមហាមត្តោ អាយស្មន្តំ អានន្ទំ ឯតទវោច កហំ បន ភវំ អានន្ទោ ឯតរហិ វិហរតីតិ ។ វេឡុវនេ ខោហំ ព្រាហ្មណ ឯតរហិ វិហរាមីតិ ។ កច្ចិ បន ភោ អានន្ទ វេឡុវនំ រមណីយញ្ចេវ អប្បសទ្ទញ្ច អប្បនិគ្ឃោសញ្ច វិជនវាតំ មនុស្សរាហស្សេយ្យកំ បដិសល្លានសារុប្បន្តិ ។ តគ្ឃ ព្រាហ្មណ វេឡុវនំ រមណីយញ្ចេវ អប្បសទ្ទញ្ច អប្បនិគ្ឃោសញ្ច វិជនវាតំ

បូជានូវបុគ្គលដែលគួរបូជា យ៉ាងនេះ ត្រូវណាស់ហើយ ដែលលោកដ៏ចម្រើនទាំងនេះ ធ្វើសក្ការៈនូវបុគ្គលដែលគួរធ្វើសក្ការៈ ធ្វើការគោរពនូវបុគ្គលដែលគួរគោរព រាប់អាននូវបុគ្គលដែលគួររាប់អាន បូជានូវបុគ្គលដែលគួរបូជា ព្រោះថា បើលោកដ៏ចម្រើនទាំងនោះ មិនធ្វើសក្ការៈ មិនគោរព មិនរាប់អាន មិនបូជានូវបុគ្គលបែបនេះទេ តើឲ្យលោកដ៏ចម្រើនទាំងនោះ ធ្វើសក្ការៈ គោរព រាប់អាន បូជា លុះធ្វើសក្ការៈ គោរពហើយ នៅអាស្រ័យនឹងបុគ្គលបែបណាវិញ ។

(១១៩) គ្រានោះ វស្សការព្រាហ្មណ៍ ជាមហាមាត្យក្នុងដែនមគធៈ ក៏សួរព្រះអានន្ទមានអាយុ ដូច្នេះថា ចុះព្រះអានន្ទ នៅក្នុងទីណា ឥឡូវនេះ ។ ព្រះអានន្ទឆ្លើយថា ម្នាលព្រាហ្មណ៍ ឥឡូវនេះ អាត្មានៅក្នុងវត្តវេឡុវ័ន ។ បពិត្រព្រះអានន្ទដ៏ចម្រើន ចុះវត្តវេឡុវ័ន ជាទីគួរត្រេកអរផង មានសំឡេងតិចផង មានសេចក្តីគឹកកងតិចផង មានខ្យល់រំភើយ ។ [1]ជាទីគួរធ្វើការសម្ងាត់របស់មនុស្ស ជាទីសមគួរនឹងពួនសម្ងំដែរឬ ។ អើ ព្រាហ្មណ៍ វត្តវេឡុវ័ន ជាទីគួរត្រេកអរផង មានសំឡេងតិចផង មានសេចក្តីគឹកកងតិចផង មានខ្យល់រំភើយ ។

១ ប្រាប ភាកខ្យ លពែលខ្សាយចេញ អំពីសរីរៈនៃជន ។ អដ្ឋកថា ។

មនុស្សរាហសេយ្យកំ បដិសល្លានសារុប្បំ យថាតំ តុម្ហាទិសេហិ រក្ខកេហិ គោបកេហីតិ ។

(១១៦) តគ្ឃ ភោ អានន្ទ វេឡុវនំ រមណីយញ្ចេវ អប្បសទ្ទញ្ច អប្បនិគ្ឃោសញ្ច វិជនវាតំ មនុស្សរាហសេយ្យកំ បដិសល្លានសារុប្បំ យថាតំ ភវន្តេហិ ឈាយីហិ ឈានសីលេហិ ឈាយិនោ ចេវ ភវន្តោ ឈានសីលិនោ ច ឯកមិទាហំ ភោ អានន្ទ សមយ សោ ភវំ គោតមោ វេសាលិយំ វិហរតិ មហាវនេ កូដាគារសាលាយំ អថខ្វាហំ ភោ អានន្ទ យេន មហាវនំ កូដាគារសាលា យេន សោ ភវំ គោតមោ តេនុបសង្កមឹ តត្រ ច បន សោ ភវំ គោតមោ អនេកបរិយាយេន ឈានកថំ កថេសិ ឈាយី ចេវ សោ ភវំ គោតមោ អហោសិ ឈានសីលោ ច សព្វញ្ច បន សោ ភវំ គោតមោ ឈានំ វណ្ណេសីតិ ។

ជាទីគួរធ្វើការសម្ងាត់ របស់មនុស្ស ជាទីសមគួរដល់ការពួនសម្ងំ ថែមទាំងមានបុគ្គលទាំងឡាយ ប្រហែលនឹងអ្នក ជាអ្នករក្សា គ្រប់គ្រងដោយពិត ។

(១១៦) អើ ព្រះអានន្ទដ៏ចម្រើន វត្តវេឡុវ័ន ជាទីគួរត្រេកអរផង មានសំឡេងតិចផង មានសេចក្តីគឹកកងតិចផង មានខ្យល់រំភើយ ។ ជាទីគួរធ្វើការសម្ងាត់របស់មនុស្ស ជាទីសមគួរដល់ការពួនសម្ងំ ថែមទាំងមានលោកដ៏ចម្រើនទាំងឡាយ ជាអ្នកប្រកបដោយឈាន មានឈានជាប្រក្រតី ដោយពិត ព្រោះលោកដ៏ចម្រើនទាំងឡាយ ជាអ្នកប្រកបដោយឈានផង មានឈានជាប្រក្រតីផង បពិត្រព្រះអានន្ទដ៏ចម្រើន សម័យមួយ ខ្ញុំមកក្នុងទីនេះ ព្រះគោតមដ៏ចម្រើនអង្គនោះ គង់នៅក្នុងកូដាគារសាលា នាមហាវ័ន ជិតក្រុងវេសាលី បពិត្រព្រះអានន្ទដ៏ចម្រើន គ្រានោះឯង ខ្ញុំបានចូលទៅរកព្រះគោតមដ៏ចម្រើននោះ ក្នុងកូដាគារសាលា នាមហាវ័ន ព្រះគោតមដ៏ចម្រើនអង្គនោះ ទ្រង់ពោលនូវឈានកថាជាអនេកបរិយាយ ក្នុងកូដាគារសាលានោះ ព្រោះព្រះគោតមដ៏ចម្រើនអង្គនោះ ជាអ្នកប្រកបដោយឈានផង មានឈានជាប្រក្រតីផង មិនតែប៉ុណ្ណោះ ព្រះគោតមដ៏ចម្រើនអង្គនោះ ទ្រង់សរសើរនូវឈានទាំងអស់ផង ។

(១១៧) ន ខោ ព្រាហ្មណ សោ ភគវា សព្វំ ឈានំ វណ្ណេសិ នាបិ សោ ភគវា សព្វំ ឈានំ ន វណ្ណេសិ ន កថំរូបញ្ច ព្រាហ្មណ សោ ភគវា ឈានំ ន វណ្ណេសិ ។ ឥធ ព្រាហ្មណ ឯកច្ចោ កាមរាគបរិយុដ្ឋិតេន ចេតសា វិហរតិ កាមរាគបរេតេន ឧប្បន្នស្ស ច កាមរាគស្ស និស្សរណំ យថាភូតំ នប្បជានាតិ សោ កាមរាគំយេវ អន្តរំ ករិត្វា ឈាយតិ បជ្ឈាយតិ និជ្ឈាយតិ អបជ្ឈាយតិ ។ ព្យាបាទបរិយុដ្ឋិតេន ចេតសា វិហរតិ ព្យាបាទបរេតេន ឧប្បន្នស្ស ច ព្យាបាទស្ស និស្សរណំ យថាភូតំ នប្បជានាតិ សោ ព្យាបាទំយេវ អន្តរំ ករិត្វា ឈាយតិ បជ្ឈាយតិ និជ្ឈាយតិ អបជ្ឈាយតិ ។ ថីនមិទ្ធបរិយុដ្ឋិតេន ចេតសា វិហរតិ ថីនមិទ្ធបរេតេន ឧប្បន្នស្ស ច ថីនមិទ្ធស្ស និស្សរណំ យថាភូតំ នប្បជានាតិ សោ ថីនមិទ្ធំយេវ អន្តរំ ករិត្វា ឈាយតិ បជ្ឈាយតិ និជ្ឈាយតិ អបជ្ឈាយតិ ។ ឧទ្ធច្ចកុក្កុច្ចបរិយុដ្ឋិតេន ចេតសា វិហរតិ

(១១៧) ម្នាលព្រាហ្មណ៍ ព្រះមានព្រះភាគអង្គនោះ មិនទ្រង់សរសើរ នូវឈានទាំងអស់ទេ ព្រះមានព្រះភាគអង្គនោះ មិនមែនជាមិនទ្រង់សរសើរ នូវឈានទាំងអស់ឡើយ ម្នាលព្រាហ្មណ៍ ព្រះមានព្រះភាគអង្គនោះ មិនមែនជាមិនទ្រង់សរសើរនូវឈានមានសភាពដូចម្តេចទេ ។ ម្នាលព្រាហ្មណ៍ ក្នុងលោកនេះ បុគ្គលពួកខ្លះ មានចិត្តត្រូវកាមរាគរួបរឹតហើយ ត្រូវកាមរាគគ្របសង្កត់ហើយ ក៏មិនដឹងច្បាស់តាមពិត នូវធម៌ជាគ្រឿងរលាស់ចោល នូវកាមរាគដែលកើតឡើង បុគ្គលនោះ ធ្វើនូវកាមរាគឲ្យឋិតនៅក្នុងចិត្ត ហើយក៏ស្ងួតស្ងប់ ជ្រប់ សញ្ចប់សញ្ចឹង ៗ មានចិត្តត្រូវព្យាបាទរួបរឹតហើយ ត្រូវព្យាបាទគ្របសង្កត់ហើយ ក៏មិនដឹងច្បាស់តាមពិត នូវធម៌ជាគ្រឿងរលាស់ចោល នូវព្យាបាទដែលកើតឡើង បុគ្គលនោះ ធ្វើនូវព្យាបាទឲ្យឋិតនៅក្នុងចិត្ត ហើយក៏ស្ងួតស្ងប់ ជ្រប់ សញ្ចប់សញ្ចឹង ៗ មានចិត្តត្រូវថីនមិទ្ធៈរួបរឹតហើយ ត្រូវថីនមិទ្ធៈគ្របសង្កត់ហើយ ក៏មិនដឹងច្បាស់តាមពិត នូវធម៌ជាគ្រឿងរលាស់ចោល នូវថីនមិទ្ធៈដែលកើតឡើង បុគ្គលនោះ ធ្វើនូវថីនមិទ្ធៈឲ្យឋិតនៅក្នុងចិត្ត ហើយក៏ស្ងួតស្ងប់ ជ្រប់ សញ្ចប់សញ្ចឹង ៗ មានចិត្តត្រូវឧទ្ធច្ចកុក្កុច្ចៈរួបរឹតហើយ

ឧទ្ធច្ចកុក្កុច្ចបរេតេន ឧប្បន្នស្ស ច ឧទ្ធច្ចកុក្កុច្ចស្ស និស្សរណំ យថាភូតំ នប្បជានាតិ សោ ឧទ្ធច្ចកុក្កុច្ចំយេវ អន្តរំ ករិត្វា ឈាយតិ បជ្ឈាយតិ និជ្ឈាយតិ អបជ្ឈាយតិ ។ វិចិកិច្ឆាបរិយុដ្ឋិតេន ចេតសា វិហរតិ វិចិកិច្ឆាបរេតេន ឧប្បន្នាយ ច វិចិកិច្ឆាយ និស្សរណំ យថាភូតំ នប្បជានាតិ សោ វិចិកិច្ឆំយេវ អន្តរំ ករិត្វា ឈាយតិ បជ្ឈាយតិ និជ្ឈាយតិ អបជ្ឈាយតិ ។ ន ឯវរូបំ ខោ ព្រាហ្មណ សោ ភគវា ឈានំ វណ្ណេសិ ។ កថំរូបញ្ច ព្រាហ្មណ សោ ភគវា ឈានំ វណ្ណេសិ ។ ឥធ ព្រាហ្មណ ភិក្ខុ វិវិច្ចេវ កាមេហិ វិវិច្ច អកុសលេហិ ធម្មេហិ សវិតក្កំ សវិចារំ វិវេកជំ បីតិសុខំ បឋមំ ឈានំ ឧបសម្បជ្ជ

ត្រូវឧទ្ធច្ចកុក្កុច្ចៈគ្របសង្កត់ហើយ ក៏មិនដឹងច្បាស់ តាមពិត នូវធម៌ជាគ្រឿងរលាស់ចោល នូវឧទ្ធច្ចកុក្កុច្ចៈ ដែលកើតឡើង បុគ្គលនោះធ្វើនូវឧទ្ធច្ចកុក្កុច្ចៈ ឲ្យឋិតនៅក្នុងចិត្ត ហើយក៏សូកសប់ ជ្រប់ សញ្ចប់សញ្ចឹង ៗ មានចិត្តត្រូវវិចិកិច្ឆារួបរឹតហើយ ត្រូវវិចិកិច្ឆាគ្របសង្កត់ហើយ ក៏មិនដឹងច្បាស់តាមពិត នូវធម៌ជាគ្រឿងរលាស់ចោល នូវវិចិកិច្ឆាដែលកើតឡើង បុគ្គលនោះ ធ្វើនូវវិចិកិច្ឆាឲ្យឋិតនៅក្នុងចិត្ត ហើយក៏សូកសប់ ជ្រប់ សញ្ចប់សញ្ចឹង ៗ ម្នាលព្រាហ្មណ៍ ព្រះមានព្រះភាគអង្គនោះ មិនទ្រង់សរសើរនូវឈានមានសភាពដូច្នេះទេ ៗ ម្នាលព្រាហ្មណ៍ ចុះព្រះមានព្រះភាគអង្គនោះ ទ្រង់សរសើរនូវឈានមានសភាពដូចម្តេចវិញ ៗ ម្នាលព្រាហ្មណ៍ ភិក្ខុក្នុងសាសនានេះ ស្ងាត់ចាកកាម ស្ងាត់ចាកអកុសលធម៌ទាំងឡាយ ហើយបានដល់នូវបឋមជ្ឈានប្រកបដោយវិតក្កៈ និងវិចារៈ មានបីតិនិងសុខៈកើតអំពីសេចក្តីស្ងាត់ហើយ

វិហរតិ វិតក្កវិចារានំ វូបសមា អជ្ឈត្តំ សម្បសាទនំ ចេតសោ ឯកោទិភាវំ អវិតក្កំ អវិចារំ សមាធិជំ បីតិសុខំ ទុតិយំ ឈានំ... តតិយំ ឈានំ... ចតុត្ថំ ឈានំ ឧបសម្បជ្ជ វិហរតិ ។ ឯវរូបំ ខោ ព្រាហ្មណ សោ ភគវា ឈានំ វណ្ណេសីតិ ។

(១១៨) គារយ្ហំ កិរ ភោ អានន្ទ សោ ភវំ គោតមោ ឈានំ គរហិ បាសំសំ បសំសិ ហន្ទ ចទានិ មយំ ភោ អានន្ទ គច្ឆាម ពហុកិច្ចា មយំ ពហុករ-ណីយាតិ ។ យស្សទានិ ត្វំ ព្រាហ្មណ កាលំ មញ្ញសីតិ ។ អថខោ វស្សការោ ព្រាហ្មណោ មគធមហាមត្តោ អាយស្មតោ អានន្ទស្ស ភាសិតំ អភិនន្ទិត្វា អនុមោទិត្វា ឧដ្ឋាយាសនា បក្កាមិ ។

សម្រាន្តទៅ ដោយឥរិយាបថទាំង ៤ (បានដល់) នូវទុតិយជ្ឈាន ជាធម្មជាតកើតមានក្នុងសន្តាននៃខ្លួន ប្រកបដោយសេចក្តីជ្រះថ្លាគឺសទ្ធា មានសភាពជាចិត្តខ្ពស់ឯក មិនមានវិតក្កៈ មិនមានវិចារៈ មានតែបីតិនិងសុខៈ កើតអំពីសមាធិគឺបឋមជ្ឈាន ព្រោះរម្ងាប់ នូវវិតក្កៈនិងវិចារៈ. បានដល់នូវតតិយជ្ឈាន... បានដល់នូវចតុត្ថជ្ឈាន ហើយសម្រាន្តទៅ ដោយឥរិយាបថទាំង ៤ ។ ម្នាលព្រាហ្មណ៍ ព្រះមានព្រះភាគអង្គនោះ ទ្រង់សរសើរនូវឈានមានសភាពដូច្នេះឯង ។

(៦១៨) បពិត្រព្រះអានន្ទដ៏ចម្រើន បានឮថា ព្រះគោតមដ៏ចម្រើនអង្គនោះ ទ្រង់តិះដៀលនូវឈានដែលគួរតិះដៀល ទ្រង់សរសើរនូវឈានដែលគួរសរសើរ បពិត្រព្រះអានន្ទដ៏ចម្រើន ណ្ហើយចុះ យើងខ្ញុំ នឹងសូមលាទៅ ក្នុងកាលឥឡូវនេះ ព្រោះយើងខ្ញុំមានកិច្ចច្រើន មានការច្រើន ។ ម្នាលព្រាហ្មណ៍ អ្នកចូរសំគាល់ នូវកាលដែលគួរនឹងអញ្ជើញទៅ ឥឡូវនេះចុះ ។ គ្រានោះ វស្សការព្រាហ្មណ៍ ជាមហាមាត្យ ក្នុងដែនមគធៈ ត្រេកអររីករាយនឹងភាសិត របស់ព្រះអានន្ទមានអាយុ ហើយក៏ក្រោកចាកអាសនៈ ចៀសចេញទៅ ។

(១១៩) អថខោ គោបកមោគ្គល្លានោ ព្រាហ្មណោ អចិរបក្កន្តេ វស្សការេ ព្រាហ្មណេ មគធមហាមត្តេ អាយស្មន្តំ អានន្ទំ ឯតទវោច យំ នោ មយំ ភវន្តំ អានន្ទំ អបុច្ឆិម្ហា តំ នោ ភវំ អានន្ទោ ន ព្យាកាសីតិ ។ ន នុ តេ ព្រាហ្មណ អវោចុម្ហា នត្ថិ ខោ ព្រាហ្មណ ឯកភិក្ខុបិ តេហិ ធម្មេហិ សព្វេន សព្វំ សព្វថា សព្វំ សមន្នាគតោ យេហិ ធម្មេហិ សមន្នាគតោ សោ ភគវា អហោសិ អរហំ សម្មាសម្ពុទ្ធោ សោ ហិ ព្រាហ្មណ ភគវា អនុប្បន្នស្ស មគ្គស្ស ឧប្បាទេតា អសញ្ជាតស្ស មគ្គស្ស សញ្ជនេតា អនក្ខាតស្ស មគ្គស្ស អក្ខាតា មគ្គញ្ញូ មគ្គវិទូ មគ្គកោវិទោ មគ្គានុគា ច បន ឯតរហិ សាវកា វិហរន្តិ បច្ឆា សមន្នាគតាតិ ។

គោបកមោគ្គល្លានសុត្តំ អដ្ឋមំ និដ្ឋិតំ ។

(១១៩) លំដាប់នោះ គោបកមោគ្គល្លានព្រាហ្មណ៍ កាលដែលវស្សការព្រាហ្មណ៍ ជាមហាមាត្យ ក្នុងដែនមគធៈ ចៀសចេញទៅមិនយូរប៉ុន្មាន ក៏ពោលទៅព្រះអានន្ទមានអាយុ ដូច្នេះថា បើយើងបានសួរព្រះអានន្ទដ៏ចម្រើន ចំពោះរឿងណា ព្រះអានន្ទដ៏ចម្រើនមិនទាន់ដោះស្រាយរឿងនោះឡើយ ។ ព្រះអានន្ទតបថា ម្នាលព្រាហ្មណ៍ ព្រះមានព្រះភាគ ជាអរហន្តសម្មាសម្ពុទ្ធ អង្គនោះ ប្រកបហើយដោយធម៌ទាំងឡាយណា ភិក្ខុសូម្បីមួយរូប ដែលប្រកបហើយដោយធម៌ទាំងឡាយនោះ ដោយអាការទាំងពួង ដោយប្រការទាំងពួង មិនមានទេ ម្នាលព្រាហ្មណ៍ ព្រោះថា ព្រះមានព្រះភាគអង្គនោះ ជាអ្នកបង្កើតផ្លូវដែលមិនទាន់កើតឡើង ជាអ្នករៀបចំផ្លូវដែលមិនទាន់រៀបចំ ជាអ្នកប្រាប់ផ្លូវដែលគេមិនដែលប្រាប់ ជាអ្នកស្គាល់ផ្លូវ ដឹងផ្លូវ ឈ្លាសវៃក្នុងផ្លូវ ពួកសាវ័ក ក្នុងកាលឥឡូវនេះ គ្រាន់តែជាអ្នកដើរតាមផ្លូវ ប្រកបតាមក្រោយប៉ុណ្ណោះ ទេតើ ។

ចប់ គោបកមោគ្គល្លានសូត្រ ទី ៨ ។

---

## នវមំ មហាបុណ្ណមសុត្តំ

(១២០) ឯវំ មេ សុតំ ។ ឯកំ សមយំ ភគវា សាវត្ថិយំ វិហរតិ បុព្វារាមេ មិគារមាតុ បាសាទេ ។ តេន ខោ បន សមយេន ភគវា តទហុបោសថេ បណ្ណរសេ បុណ្ណាយ បុណ្ណមាយ រត្តិយា ភិក្ខុសង្ឃបរិវុតោ អព្ភោកាសេ និសិន្នោ ហោតិ ។ អថខោ អញ្ញតរោ ភិក្ខុ ឧដ្ឋាយាសនា ឯកំសំ ចីវរំ កត្វា យេន ភគវា តេនញ្ជលិំ បណាមេត្វា ភគវន្តំ ឯតទវោច បុច្ឆេយ្យាហំ ភន្តេ ភគវន្តំ កិញ្ចិទេវ ទេសំ សចេ មេ ភគវា ឱកាសំ ករោតិ បញ្ហស្ស វេយ្យាករណាយាតិ ។ តេនហិ ត្វំ[១] ភិក្ខុ សកេ អាសនេ និសីទិត្វា បុច្ឆ យទាកង្ខសីតិ ។

(១២១) អថខោ សោ ភិក្ខុ សកេ អាសនេ និសីទិត្វា ភគវន្តំ ឯតទវោច ឥមេ នុ ខោ ភន្តេ បញ្ចុបាទានក្ខន្ធា សេយ្យថីទំ រូបុបាទានក្ខន្ធោ វេទនុបាទា-

---
១ ម. តំ ។

# មហាបុណ្ណមសូត្រ ទី ៩

(១៦០) ខ្ញុំបានស្តាប់មក យ៉ាងនេះ ។ សម័យមួយ ព្រះមានព្រះភាគ គង់ក្នុងមិគារមាតុប្រាសាទ ក្នុងបុព្វារាម ជិតក្រុងសាវត្ថី ។ សម័យនោះឯង ព្រះមានព្រះភាគ មានភិក្ខុសង្ឃចោមរោម ទ្រង់គង់ក្នុងទីវាល ក្នុងរាត្រីដែលមានព្រះចន្ទពេញវង់ ជាថ្ងៃឧបោសថ ទី ១៥ ។ គ្រានោះ ភិក្ខុមួយរូប ក្រោកអំពីអាសនៈ ធ្វើចីវរឆៀងស្មាម្ខាង ប្រណម្យអញ្ជលី ឆ្ពោះទៅរកព្រះមានព្រះភាគហើយ ក៏ក្រាបបង្គំទូលសួរព្រះមានព្រះភាគ ដូច្នេះថា បពិត្រព្រះអង្គដ៏ចំរើន បើព្រះមានព្រះភាគ ធ្វើឱកាសដើម្បីដោះស្រាយប្រស្នា របស់ខ្ញុំព្រះអង្គ ។ ទង់ សួរនូវហេតុបន្តិចបន្តួច ចំពោះព្រះមានព្រះភាគ ។ ព្រះអង្គត្រាស់ថា ម្នាលភិក្ខុ បើដូច្នោះ អ្នកចង់សួរប្រស្នាណា ចូរអង្គុយលើអាសនៈរបស់ខ្លួន សួរប្រស្នានោះចុះ ។

(១៦១) លំដាប់នោះ ភិក្ខុនោះ អង្គុយលើអាសនៈរបស់ខ្លួនហើយ ក៏ក្រាបបង្គំទូលសួរព្រះមានព្រះភាគ ដូច្នេះថា បពិត្រព្រះអង្គដ៏ចំរើន ទាំង៥ នេះឬ ដែលឈ្មោះថាឧបាទានក្ខន្ធ គឺរូបូបាទានក្ខន្ធ ១ វេទនូបា-

ទានក្ខន្ធោ សញ្ញូបាទានក្ខន្ធោ សង្ខារូបាទានក្ខន្ធោ វិញ្ញាណូបាទានក្ខន្ធោតិ ។ ឥមេ ខោ ភិក្ខុ បញ្ចុបាទានក្ខន្ធា សេយ្យថីទំ រូបូបាទានក្ខន្ធោ វេទនូបាទានក្ខន្ធោ សញ្ញូបាទានក្ខន្ធោ សង្ខារូបាទានក្ខន្ធោ វិញ្ញាណូបាទានក្ខន្ធោតិ ។ សាធុ ភន្តេតិ ខោ សោ ភិក្ខុ ភគវតោ ភាសិតំ អភិនន្ទិត្វា អនុមោទិត្វា ភគវន្តំ ឧត្តរឹ បញ្ហំ បុច្ឆិ ឥមេ បន ភន្តេ បញ្ចុបាទានក្ខន្ធា កឹមូលកាតិ ។ ឥមេ ខោ ភិក្ខុ បញ្ចុបាទានក្ខន្ធា ឆន្ទមូលកាតិ ។ តញ្ញេវ[១] នុ ខោ ភន្តេ ឧបាទានំ តេ បញ្ចុបាទានក្ខន្ធា ឧទាហុ អញ្ញត្រ[២] បញ្ចុបាទានក្ខន្ធេហិ ឧបាទានន្តិ ។ ន ខោ ភិក្ខុ តញ្ញេវ ឧបាទានំ តេ បញ្ចុបាទានក្ខន្ធា នាបិ អញ្ញត្រ បញ្ចុបាទានក្ខន្ធេហិ ឧបាទានំ យោ ខោ ភិក្ខុ បញ្ចុបាទានក្ខន្ធេសុ ឆន្ទរាគោ តំ តត្ថ ឧបាទានន្តិ ។

---

១ ឱ. ម. តំយេវ ។ ២ ម. អញ្ញត្ថ ។

ទានក្ខន្ធ១ សញ្ញុបាទានក្ខន្ធ១ សង្ខារុបាទានក្ខន្ធ១ វិញ្ញាណុបាទានក្ខន្ធ១ៗ ម្នាលភិក្ខុ ទាំង ៥ នេះហើយ ដែលឈ្មោះថាឧបាទានក្ខន្ធ គឺរូបុបាទា-នក្ខន្ធ ១ វេទនុបាទានក្ខន្ធ ១ សញ្ញុបាទានក្ខន្ធ ១ សង្ខារុបាទានក្ខន្ធ១ វិញ្ញាណុបាទានក្ខន្ធ ១ ៗ ភិក្ខុនោះ ត្រេកអររីករាយនឹងភាសិតរបស់ព្រះមានព្រះភាគថា ពីរោះហើយព្រះអង្គ ហើយក៏សួរប្រស្នាចំពោះព្រះមានព្រះភាគតទៅទៀតថា បពិត្រព្រះអង្គដ៏ចំរើន ចុះឧបាទានក្ខន្ធទាំង ៥ នេះ មានអ្វីជាមូលហេតុ ៗ ម្នាលភិក្ខុ ឧបាទានក្ខន្ធទាំង ៥ នេះមានឆន្ទៈ (សេចក្តីប្រាថ្នា) ជាមូលហេតុ ៗ បពិត្រព្រះអង្គដ៏ចំរើន ឧបាទាននោះឯង គឺឧបាទានក្ខន្ធទាំង ៥ នោះឬ ឬថាឧបាទានដទៃអំពីឧបាទានក្ខន្ធទាំង៥ ៗ ម្នាលភិក្ខុ ឧបាទាននោះឯង មិនមែនជាឧបាទា-នក្ខន្ធទាំង ៥ នោះទេ មួយទៀត ឧបាទានមិនមែនជាដទៃ អំពីឧបាទានក្ខន្ធទាំង ៥ ឡើយ ម្នាលភិក្ខុ សេចក្តីត្រេកត្រអាល ក្នុងឧបាទានក្ខន្ធទាំង ៥ ណា សេចក្តីត្រេកត្រអាលនោះ ក្នុងឧបាទានក្ខន្ធទាំង ៥ នោះ ឈ្មោះថា ឧបាទាន ៗ

(១២២) សិយា បន ភន្តេ សា[១] បញ្ចុបាទានក្ខន្ធេសុ ឆន្ទរាគវេមត្តតាតិ ។ សិយា ភិក្ខូតិ ភគវា អវោច ឥធ ភិក្ខុ ឯកច្ចស្ស ឯវំ ហោតិ ឯវំរូបោ សិយំ អនាគតមទ្ធានំ ឯវំវេទនោ សិយំ អនាគតមទ្ធានំ ឯវំសញ្ញោ សិយំ អនាគតមទ្ធានំ ឯវំសង្ខារោ សិយំ អនាគតមទ្ធានំ ឯវំវិញ្ញាណោ សិយំ អនាគតមទ្ធានន្តិ ឯវំ ខោ ភិក្ខុ សិយា[២] បញ្ចុបាទានក្ខន្ធេសុ ឆន្ទរាគវេមត្តតាតិ ។

(១២៣) កិត្តាវតា បន ភន្តេ ខន្ធានំ ខន្ធាធិវចនំ ហោតីតិ ។ យំ កិញ្ចិ ភិក្ខុ រូបំ អតីតានាគតបច្ចុប្បន្នំ អជ្ឈត្តំ វា ពហិទ្ធា វា ឱឡារិកំ វា សុខុមំ វា ហីនំ វា បណីតំ វា យំ ទូរេ សន្តិកេ វា អយំ រូបក្ខន្ធោ យា កាចិ វេទនា ... យា កាចិ សញ្ញា ... យេ កេចិ សង្ខារា ... យំ កិញ្ចិ វិញ្ញាណំ

១ ម. សាតិ បទំ ន ទិស្សតិ ។ ២ ម. សិយាតិ ន ទិស្សតិ ។

(១៦២) បពិត្រព្រះអង្គដ៏ចំរើន ចុះសេចក្ដីត្រេកត្រអាលផ្សេងគ្នា ក្នុងឧបាទានក្ខន្ធទាំង ៥ នោះ មានដែរឬ ។ ព្រះមានព្រះភាគទ្រង់ត្រាស់ថា ម្នាលភិក្ខុ មាន ដូច្នេះ ហើយទ្រង់ត្រាស់តទៅទៀតថា ម្នាលភិក្ខុ បុគ្គលពួកខ្លះ ក្នុងលោកនេះ មានសេចក្ដីប្រាថ្នាយ៉ាងនេះថា អាត្មាអញ គប្បីមានរូបយ៉ាងនេះ ក្នុងអនាគតកាល គប្បីមានវេទនាយ៉ាងនេះក្នុង អនាគតកាល គប្បីមានសញ្ញាយ៉ាងនេះ ក្នុងអនាគតកាល គប្បីមានសង្ខារយ៉ាងនេះ ក្នុងអនាគតកាល គប្បីមានវិញ្ញាណយ៉ាងនេះ ក្នុងអនាគតកាល ម្នាលភិក្ខុ សេចក្ដីត្រេកត្រអាលផ្សេងគ្នាក្នុងឧបាទានក្ខន្ធទាំង ៥ មាន យ៉ាងនេះឯង ។

(១៦៣) បពិត្រព្រះអង្គដ៏ចំរើន ចុះឈ្មោះរបស់ខន្ធមានប៉ុន្មានយ៉ាង ។ ម្នាលភិក្ខុ រូបណាមួយ ទោះជាអតីត អនាគត បច្ចុប្បន្ន ជាខាងក្នុងក្ដី ខាងក្រៅក្ដី គ្រោតគ្រាតក្ដី ល្អិតក្ដី ថោកទាបក្ដី ឧត្ដមក្ដី ទោះរូបណាឆ្ងាយក្ដី ជិតក្ដី នេះ ឈ្មោះជារូបខន្ធ វេទនា ណាមួយ... សញ្ញា ណាមួយ... សង្ខារ ណាមួយ វិញ្ញាណ ណាមួយ...

អតីតានាគតបច្ចុប្បន្នំ អជ្ឈត្តំ វា ពហិទ្ធា វា ឱឡារិកំ វា សុខុមំ វា ហីនំ វា បណីតំ វា យំ ទូរេ សន្តិកេ វា អយំ វិញ្ញាណក្ខន្ធោ ឯត្តាវតា ខោ ភិក្ខុ ខន្ធានំ ខន្ធាធិវចនំ ហោតីតិ ។

(១២៤) កោ នុ ខោ ភន្តេ ហេតុ កោ បច្ចយោ រូបក្ខន្ធស្ស បញ្ញាបនាយ កោ ហេតុ កោ បច្ចយោ វេទនាខន្ធស្ស បញ្ញាបនាយ កោ ហេតុ កោ បច្ចយោ សញ្ញាខន្ធស្ស បញ្ញាបនាយ កោ ហេតុ កោ បច្ចយោ សង្ខារក្ខន្ធស្ស បញ្ញាបនាយ កោ ហេតុ កោ បច្ចយោ វិញ្ញាណក្ខន្ធស្ស បញ្ញាបនាយាតិ ។ ចត្តារោ ខោ ភិក្ខុ មហាភូតា ហេតុ ចត្តារោ មហាភូតា បច្ចយោ រូបក្ខន្ធស្ស បញ្ញាបនាយ ផស្សោ ហេតុ ផស្សោ បច្ចយោ វេទនាខន្ធស្ស បញ្ញាបនាយ ផស្សោ ហេតុ ផស្សោ បច្ចយោ សញ្ញាខន្ធស្ស បញ្ញាបនាយ ផស្សោ ហេតុ ផស្សោ បច្ចយោ សង្ខារក្ខន្ធស្ស បញ្ញាបនាយ នាមរូបំ ខោ ភិក្ខុ ហេតុ នាមរូបំ បច្ចយោ វិញ្ញាណក្ខន្ធស្ស បញ្ញាបនាយាតិ ។

ទោះជាអតីត អនាគត បច្ចុប្បន្នក្តី ជាខាងក្នុងក្តី ខាងក្រៅក្តី គ្រោតគ្រាតក្តី ល្អិតក្តី ថោកទាបក្តី ឧត្តមក្តី ទោះវិញ្ញាណណា ឆ្ងាយក្តី ជិតក្តី នេះ ឈ្មោះថាវិញ្ញាណក្ខន្ធ ម្នាលភិក្ខុ ឈ្មោះរបស់ខន្ធ មានតែប៉ុណ្ណេះឯង ។

(១៦៤) បពិត្រព្រះអង្គដ៏ចម្រើន អ្វីហ្ន៎ ជាហេតុ អ្វីហ្ន៎ ជាបច្ច័យ ដែលនាំឲ្យបញ្ញត្តនូវរូបក្ខន្ធ អ្វី ជាហេតុ អ្វី ជាបច្ច័យ ដែលនាំឲ្យបញ្ញត្តនូវវេទនាក្ខន្ធ អ្វី ជាហេតុ អ្វី ជាបច្ច័យ ដែលនាំឲ្យបញ្ញត្តនូវសញ្ញាក្ខន្ធ អ្វី ជាហេតុ អ្វី ជាបច្ច័យ ដែលនាំឲ្យបញ្ញត្តនូវសង្ខារក្ខន្ធ អ្វី ជាហេតុ អ្វី ជាបច្ច័យ ដែលនាំឲ្យបញ្ញត្តនូវវិញ្ញាណក្ខន្ធ ។ ម្នាលភិក្ខុ មហាភូតទាំង ៤ ជាហេតុ មហាភូតទាំង ៤ ជាបច្ច័យ ដែលនាំឲ្យបញ្ញត្តនូវរូបក្ខន្ធ ផស្សៈជាហេតុ ផស្សៈជាបច្ច័យ ដែលនាំឲ្យបញ្ញត្តនូវវេទនាក្ខន្ធ ផស្សៈជាហេតុ ផស្សៈជាបច្ច័យ ដែលនាំឲ្យបញ្ញត្តនូវសញ្ញាក្ខន្ធ ផស្សៈជាហេតុ ផស្សៈជាបច្ច័យ ដែលនាំឲ្យបញ្ញត្តនូវសង្ខារក្ខន្ធ ម្នាលភិក្ខុ នាមរូបជាហេតុ នាមរូបជាបច្ច័យ ដែលនាំឲ្យបញ្ញត្តនូវវិញ្ញាណក្ខន្ធ ។

(១២៨) កថំ បន ភន្តេ សក្កាយទិដ្ឋិ ហោតីតិ ។ ឥធ ភិក្ខុ អស្សុតវា បុថុជ្ជនោ អរិយានំ អទស្សាវី អរិយធម្មស្ស អកោវិទោ អរិយធម្មេ អវិនីតោ សប្បុរិសានំ អទស្សាវី សប្បុរិសធម្មស្ស អកោវិទោ សប្បុរិសធម្មេ អវិនីតោ រូបំ អត្តតោ សមនុបស្សតិ រូបវន្តំ វា អត្តានំ អត្តនិ វា រូបំ រូបស្មឹ វា អត្តានំ វេទនំ អត្តតោ សមនុបស្សតិ វេទនាវន្តំ វា អត្តានំ អត្តនិ វា វេទនំ វេទនាយ វា អត្តានំ សញ្ញំ អត្តតោ សមនុបស្សតិ សញ្ញាវន្តំ វា អត្តានំ អត្តនិ វា សញ្ញំ សញ្ញាយ វា អត្តានំ សង្ខារេ អត្តតោ សមនុបស្សតិ សង្ខារវន្តំ វា អត្តានំ អត្តនិ វា សង្ខារេ សង្ខារេសុ វា អត្តានំ វិញ្ញាណំ អត្តតោ សមនុបស្សតិ វិញ្ញាណវន្តំ វា អត្តានំ អត្តនិ វា វិញ្ញាណំ វិញ្ញាណស្មឹ វា អត្តានំ ឯវំ ខោ ភិក្ខុ សក្កាយទិដ្ឋិ ហោតីតិ ។

(១២៥) បពិត្រព្រះអង្គដ៏ចម្រើន ចុះសក្កាយទិដ្ឋិ កើតមានដោយប្រការដូចម្តេច ។ ម្នាលភិក្ខុ បុថុជ្ជនក្នុងលោកនេះ ជាអ្នកមិនចេះដឹង មិនបានឃើញនូវព្រះអរិយបុគ្គល មិនឈ្លាសវៃក្នុងអរិយធម៌ មិនបានសិក្សាក្នុងអរិយធម៌ មិនបានឃើញនូវសប្បុរស មិនឈ្លាសវៃក្នុងសប្បុរសធម៌ មិនបានសិក្សាក្នុងសប្បុរសធម៌ តែងពិចារណាឃើញនូវរូបថាជាខ្លួន ឬឃើញនូវខ្លួនថាមានរូប ឬឃើញនូវរូបថាមានក្នុងខ្លួន ឬឃើញនូវខ្លួនថាមានក្នុងរូប តែងពិចារណាឃើញនូវវេទនាថាជាខ្លួន ឬឃើញនូវខ្លួនថាមានវេទនា ឬឃើញនូវវេទនាថាមានក្នុងខ្លួន ឬឃើញនូវខ្លួនថាមានក្នុងវេទនា តែងពិចារណាឃើញនូវសញ្ញាថាជាខ្លួន ឬឃើញនូវខ្លួនថាមានសញ្ញា ឬឃើញនូវសញ្ញាថាមានក្នុងខ្លួន ឬឃើញនូវខ្លួនថាមានក្នុងសញ្ញា តែងពិចារណាឃើញនូវសង្ខារថាជាខ្លួន ឬឃើញនូវខ្លួនថាមានសង្ខារ ឬឃើញនូវសង្ខារថាមានក្នុងខ្លួន ឬឃើញនូវខ្លួនថាមានក្នុងសង្ខារ តែងពិចារណាឃើញនូវវិញ្ញាណថាជាខ្លួន ឬឃើញនូវខ្លួនថាមានវិញ្ញាណ ឬឃើញនូវវិញ្ញាណថាមានក្នុងខ្លួន ឬឃើញនូវខ្លួនថាមានក្នុងវិញ្ញាណ ម្នាលភិក្ខុ សក្កាយទិដ្ឋិ តែងកើតមានយ៉ាងនេះឯង ។

(១២៦) កថំ បន ភន្តេ សក្កាយទិដ្ឋិ ន ហោតីតិ ។ ឥធ ភិក្ខុ សុតវា អរិយសាវកោ អរិយានំ ទស្សាវី អរិយធម្មស្ស កោវិទោ អរិយធម្មេ សុវិនីតោ សប្បុរិសានំ ទស្សាវី សប្បុរិសធម្មស្ស កោវិទោ សប្បុរិសធម្មេ សុវិនីតោ ន រូបំ អត្តតោ សមនុបស្សតិ ន រូបវន្តំ វា អត្តានំ ន អត្តនិ វា រូបំ ន រូបស្មឹ វា អត្តានំ ន វេទនំ អត្តតោ សមនុបស្សតិ ន វេទនាវន្តំ វា អត្តានំ ន អត្តនិ វា វេទនំ ន វេទនាយ វា អត្តានំ ន សញ្ញំ អត្តតោ សមនុបស្សតិ ន សញ្ញាវន្តំ វា អត្តានំ ន អត្តនិ វា សញ្ញំ ន សញ្ញាយ វា អត្តានំ ន សង្ខារេ អត្តតោ សមនុបស្សតិ ន សង្ខារវន្តំ វា អត្តានំ ន អត្តនិ វា សង្ខារេ ន សង្ខារេសុ វា អត្តានំ ន វិញ្ញាណំ អត្តតោ សមនុបស្សតិ ន វិញ្ញាណវន្តំ វា អត្តានំ ន អត្តនិ វា វិញ្ញាណំ ន វិញ្ញាណស្មឹ វា អត្តានំ ឯវំ ខោ ភិក្ខុ សក្កាយទិដ្ឋិ ន ហោតីតិ ។

[១២៦] បពិត្រព្រះអង្គដ៏ចម្រើន សក្កាយទិដ្ឋិ តែងមិនកើតមាន ដោយប្រការដូចម្តេច ។ ម្នាលភិក្ខុ អរិយសាវ័កក្នុងលោកនេះ ជាអ្នកចេះដឹង បានឃើញនូវអរិយបុគ្គល ឈ្លាសវៃក្នុងអរិយធម៌ បានសិក្សាដោយល្អក្នុងអរិយធម៌ បានឃើញនូវសប្បុរស ឈ្លាសវៃក្នុងសប្បុរស-ធម៌ បានសិក្សាដោយល្អ ក្នុងសប្បុរសធម៌ រមែងមិនឃើញរូបថាជាខ្លួន ឬមិនឃើញនូវខ្លួនថាមានរូប ឬមិនឃើញនូវរូបថាមានក្នុងខ្លួន ឬមិនឃើញនូវខ្លួនថាមានក្នុងរូប រមែងមិនឃើញនូវវេទនាថាជាខ្លួន ឬមិនឃើញនូវខ្លួនថាមានវេទនា ឬមិនឃើញនូវវេទនាថាមានក្នុងខ្លួន ឬមិនឃើញនូវខ្លួនថាមានក្នុងវេទនា រមែងមិនឃើញនូវសញ្ញាថាជាខ្លួន ឬមិនឃើញនូវខ្លួនថាមានសញ្ញា ឬមិនឃើញនូវសញ្ញាថាមានក្នុងខ្លួន ឬមិនឃើញនូវខ្លួនថាមានក្នុងសញ្ញា រមែងមិនឃើញនូវសង្ខារថាជាខ្លួន ឬមិនឃើញនូវខ្លួនថាមានសង្ខារ ឬមិនឃើញនូវសង្ខារថាមានក្នុងខ្លួន ឬមិនឃើញនូវខ្លួនថាមានក្នុងសង្ខារ រមែងមិនឃើញនូវវិញ្ញាណថាជាខ្លួន ឬមិនឃើញនូវខ្លួនថាមានវិញ្ញាណ ឬមិនឃើញនូវវិញ្ញាណថាមានក្នុងខ្លួន ឬមិនឃើញនូវខ្លួនថាមានក្នុងវិញ្ញាណ ម្នាលភិក្ខុ សក្កាយទិដ្ឋិ រមែងមិនកើតមាន យ៉ាងនេះឯង ។

(១៦៧) កោ នុ ខោ ភន្តេ រូបេ អស្សាទោ កោ អាទីនវោ កឹ និស្សរណំ កោ វេទនាយ អស្សាទោ កោ អាទីនវោ កឹ និស្សរណំ កោ សញ្ញាយ អស្សាទោ កោ អាទីនវោ កឹ និស្សរណំ កោ សង្ខារេសុ អស្សាទោ កោ អាទីនវោ កឹ និស្សរណំ កោ វិញ្ញាណេ អស្សាទោ កោ អាទីនវោ កឹ និស្សរណន្តិ ។ យំ ខោ ភិក្ខុ រូបំ បដិច្ច ឧប្បជ្ជតិ សុខំ សោមនស្សំ អយំ រូបេ អស្សាទោ យំ រូបំ អនិច្ចំ ទុក្ខំ វិបរិណាមធម្មំ អយំ រូបេ អាទីនវោ យោ រូបេ ឆន្ទរាគវិនយោ ឆន្ទរាគប្បហានំ ឥទំ រូបេ និស្សរណំ យញ្ច(១) កិញ្ចិ វេទនំ បដិច្ច ឧប្បជ្ជតិ សុខំ សោមនស្សំ អយំ វេទនាយ អស្សាទោ យា វេទនា អនិច្ចា ទុក្ខា វិបរិណាមធម្មា អយំ វេទនាយ អាទីនវោ

១ ឱ. ម. យំ ខោ ។

(១៦៧) បពិត្រព្រះអង្គដ៏ចំរើន អ្វី ជាគុណ[១] អ្វីជាទោស ក្នុងរូប អ្វី ជាគ្រឿងរលាស់ចោលនូវរូប អ្វី ជាគុណ អ្វី ជាទោស[២] ក្នុងវេទនា អ្វី ជាគ្រឿងរលាស់ចោលនូវវេទនា អ្វី ជាគុណ អ្វី ជាទោស ក្នុងសញ្ញា អ្វី ជាគ្រឿងរលាស់ចោលនូវសញ្ញា អ្វី ជាគុណ អ្វី ជាទោស ក្នុងសង្ខារ អ្វី ជាគ្រឿងរលាស់ចោលនូវសង្ខារ អ្វី ជាគុណ អ្វី ជាទោស ក្នុងវិញ្ញាណ អ្វី ជាគ្រឿងរលាស់ចោលនូវវិញ្ញាណ ។ ម្នាលភិក្ខុ សេចក្តីសុខ សោមនស្ស ណា តែងកើតឡើង ព្រោះអាស្រ័យរូប នេះជាគុណក្នុងរូប រូបណា មិនទៀង ជាទុក្ខ មានសេចក្តីប្រែប្រួលជាធម្មតា នេះជាទោសក្នុងរូប ការបន្ទោបង់នូវសេចក្តីត្រេកត្រអាល ដំណើរលះបង់នូវសេចក្តីត្រេកត្រអាល ក្នុងរូបណា នេះជាគ្រឿងរលាស់ចោលនូវរូប ម្នាលភិក្ខុ មួយទៀត សេចក្តីសុខ សោមនស្សណា តែងកើតឡើង ព្រោះអាស្រ័យវេទនា នេះជាគុណក្នុងវេទនា វេទនាណា មិនទៀង ជាទុក្ខ មានសេចក្តីប្រែប្រួលជាធម្មតា នេះ ជាទោសក្នុងវេទនា

---

១ ប្រែថាសេចក្តីជាប់ចិត្ត ឬពេញចិត្តក៏បាន ។ ២ សេចក្តីទាស់ចិត្តក៏បាន ។

យោ វេទនាយ ឆន្ទរាគវិនយោ ឆន្ទរាគប្បហានំ ឥទំ
វេទនាយ និស្សរណំ យញ្ច កិញ្ចិ សញ្ញំ បដិច្ច ឧប្បជ្ជតិ
សុខំ សោមនស្សំ អយំ សញ្ញាយ អស្សាទោ យា
សញ្ញា អនិច្ចា ទុក្ខា វិបរិណាមធម្មា អយំ សញ្ញាយ
អាទីនវោ យោ សញ្ញាយ ឆន្ទរាគវិនយោ ឆន្ទរាគ-
ប្បហានំ ឥទំ សញ្ញាយ និស្សរណំ យញ្ច កិញ្ចិ
សង្ខារេ បដិច្ច ឧប្បជ្ជតិ សុខំ សោមនស្សំ អយំ
សង្ខារេសុ អស្សាទោ យេ សង្ខារា អនិច្ចា ទុក្ខា
វិបរិណាមធម្មា អយំ សង្ខារេសុ អាទីនវោ យោ
សង្ខារេសុ ឆន្ទរាគវិនយោ ឆន្ទរាគប្បហានំ ឥទំ
សង្ខារេសុ និស្សរណំ យញ្ច កិញ្ចិ វិញ្ញាណំ បដិច្ច
-ឧប្បជ្ជតិ សុខំ សោមនស្សំ អយំ វិញ្ញាណេ អស្សា
ទោ យំ វិញ្ញាណំ អនិច្ចំ ទុក្ខំ វិបរិណាមធម្មំ អយំ
វិញ្ញាណេ អាទីនវោ យោ វិញ្ញាណេ ឆន្ទរាគវិនយោ
ឆន្ទរាគប្បហានំ ឥទំ វិញ្ញាណេ និស្សរណន្តិ ។

ការបន្ទោបង់នូវសេចក្តីត្រេកត្រអាល និងការលះបង់នូវសេចក្តីត្រេកត្រអាល ក្នុងវេទនាណា នេះជាគ្រឿងរលាស់ចោលនូវវេទនា ម្នាលភិក្ខុ មួយទៀត សេចក្តីសុខ សោមនស្សណា កើតឡើង ព្រោះអាស្រ័យសញ្ញា នេះជាគុណក្នុងសញ្ញា សញ្ញាណា មិនទៀង ជាទុក្ខ មានសេចក្តីប្រែប្រួលជាធម្មតា នេះជាទោសក្នុងសញ្ញា ការបន្ទោបង់នូវសេចក្តីត្រេកត្រអាល និងការលះបង់នូវសេចក្តីត្រេកត្រអាល ក្នុងសញ្ញាណា នេះជាគ្រឿងរលាស់ចោលនូវសញ្ញា ម្នាលភិក្ខុ មួយទៀត សេចក្តីសុខ សោមនស្សណា កើតឡើង ព្រោះអាស្រ័យសង្ខារ នេះជាគុណក្នុងសង្ខារ សង្ខារណា មិនទៀង ជាទុក្ខ មានសេចក្តីប្រែប្រួលជាធម្មតា នេះជាទោសក្នុងសង្ខារ ការបន្ទោបង់នូវសេចក្តីត្រេកត្រអាល និងការលះបង់នូវសេចក្តីត្រេកត្រអាល ក្នុងសង្ខារណា នេះជាគ្រឿងរលាស់ចោលនូវសង្ខារ ម្នាលភិក្ខុ មួយវិញទៀត សេចក្តីសុខ សោមនស្សណា កើតឡើង ព្រោះអាស្រ័យវិញ្ញាណ នេះជាគុណក្នុងវិញ្ញាណ វិញ្ញាណណា មិនទៀង ជាទុក្ខ មានសេចក្តីប្រែប្រួលជាធម្មតា នេះជាទោសក្នុងវិញ្ញាណ ការបន្ទោបង់នូវសេចក្តីត្រេកត្រអាល និងការលះបង់នូវសេចក្តីត្រេកត្រអាល ក្នុងវិញ្ញាណណា នេះជាគ្រឿងរលាស់ចោលនូវវិញ្ញាណ ។

(១២៨) កថំ បន ភន្តេ ជានតោ កថំ បស្សតោ ឥមស្មិញ្ច សវិញ្ញាណកេ កាយេ ពហិទ្ធា ច សព្វនិមិត្តេសុ អហង្ការមមង្ការមានានុសយា ន ហោន្តីតិ ។ យំ កិញ្ចិ ភិក្ខុ រូបំ អតីតានាគតបច្ចុប្បន្នំ អជ្ឈត្តំ វា ពហិទ្ធា វា ឱឡារិកំ វា សុខុមំ វា ហីនំ វា បណីតំ វា យំ ទូរេ សន្តិកេ វា សព្វំ រូបំ នេតំ មម នេសោហមស្មិ ន មេសោ អត្តាតិ ឯវមេតំ យថាភូតំ សម្មប្បញ្ញាយ បស្សតិ យា កាចិ វេទនា ... យា កាចិ សញ្ញា ... យេ កេចិ សង្ខារា ... យំ កិញ្ចិ វិញ្ញាណំ អតីតានាគតបច្ចុប្បន្នំ អជ្ឈត្តំ វា ពហិទ្ធា វា ឱឡារិកំ វា សុខុមំ វា ហីនំ វា បណីតំ វា យំ ទូរេ សន្តិកេ វា សព្វំ វិញ្ញាណំ នេតំ មម នេសោហមស្មិ ន មេសោ អត្តាតិ ឯវមេតំ យថាភូតំ សម្មប្បញ្ញាយ បស្សតិ

[ ១៤៨ ] បពិត្រព្រះអង្គដ៏ចម្រើន កាលបុគ្គលដឹងដូចម្តេច ឃើញដូចម្តេច អនុស័យគឺអហង្ការមានៈ (១) និងមមង្ការមានៈ (២) ក្នុងកាយ ដែលប្រកបដោយវិញ្ញាណនេះផង ក្នុងនិមិត្តទាំងពួងជាខាងក្រៅផង មិនមាន ។ ម្នាលភិក្ខុ រូបណាមួយ ទោះជាអតីត អនាគត បច្ចុប្បន្ន ជាខាងក្នុងក្តី ខាងក្រៅក្តី គ្រោតគ្រាតក្តី ល្អិតក្តី ថោកទាបក្តី ឧត្តមក្តី ទោះរូបណាដែលឆ្ងាយក្តី ជិតក្តី ទាំងអស់នោះ ឈ្មោះថារូប បុគ្គលឃើញនូវរូបនុ៎ះ ដោយបញ្ញាប្រពៃតាមពិត យ៉ាងនេះថា នុ៎ះមិនមែនជារបស់អញ នុ៎ះមិនមែនជាអាត្មាអញ នុ៎ះមិនមែនជាខ្លួនអញ វេទនាណាមួយ ... សញ្ញាណាមួយ ... សង្ខារណាមួយ ... វិញ្ញាណណាមួយ ទោះជាអតីត អនាគត បច្ចុប្បន្ន ជាខាងក្នុងក្តី ខាងក្រៅក្តី គ្រោតគ្រាតក្តី ល្អិតក្តី ថោកទាបក្តី ឧត្តមក្តី ទោះវិញ្ញាណណាដែលឆ្ងាយក្តី ជិតក្តី ទាំងអស់នោះ ឈ្មោះថាវិញ្ញាណ បុគ្គលឃើញនូវវិញ្ញាណនុ៎ះ ដោយបញ្ញាដ៏ប្រពៃតាមពិត យ៉ាងនេះថា នុ៎ះមិនមែនជារបស់អញ នុ៎ះមិនមែនជាអាត្មាអញ នុ៎ះមិនមែនជាខ្លួនរបស់អញ

---

១ សេចក្តីប្រកាន់ថាអញ ។ ២ សេចក្តីប្រកាន់ថា និមិត្តទាំងពួងជារបស់អញ ។

ឯវំ ខោ ភិក្ខុ ជានតោ ឯវំ បស្សតោ ឥមស្មិញ្ច សវិញ្ញាណកេ កាយេ ពហិទ្ធា ច សព្វនិមិត្តេសុ អហង្ការមមង្ការមានានុសយា ន ហោន្តីតិ ។

(១២៩) អថខោ អញ្ញតរស្ស ភិក្ខុនោ ឯវំ ចេ-តសោ បរិវិតក្កោ ឧទបាទិ ឥតិ កិរ ភោ រូបំ អនត្តា វេទនា អនត្តា សញ្ញា អនត្តា សង្ខារា អនត្តា វិញ្ញាណំ អនត្តា អនត្តកតានិ កម្មានិ កមត្តានំ ផុសិស្សន្តី-តិ[១] ។ អថខោ ភគវា តស្ស ភិក្ខុនោ ចេតសា ចេតោ បរិវិតក្កមញ្ញាយ ភិក្ខូ អាមន្តេសិ ឋានំ ខោ បនេតំ ភិក្ខវេ វិជ្ជតិ យំ ឥធេកច្ចោ មោឃបុរិសោ អ-វិទ្វា[២] អវិជ្ជាគតោ តណ្ហាធិបតេយ្យេន ចេតសា សត្ថុ សាសនំ អតិធាវិតព្វំ[៣] មញ្ញេយ្យ ឥតិ កិរ ភោ រូបំ អនត្តា វេទនា អនត្តា សញ្ញា អនត្តា សង្ខារា

១ ម. ផុសិយន្តីតិ ។ ២ ឱ. ម. អវិទ្វា ។ ៣ ឱ. ម៉. អតិធាវិតព្វំ ។

ម្នាលភិក្ខុ កាលបុគ្គលដឹងយ៉ាងនេះ ឃើញយ៉ាងនេះឯង អនុស័យ គឺអហង្ការមានះ និងមមង្ការមានះ ក្នុងកាយដែលប្រកបដោយវិញ្ញាណ នេះផង ក្នុងនិមិត្តទាំងពួងជាខាងក្រៅផង មិនមាន ។

(១៦៩) គ្រានោះ ភិក្ខុមួយរូប មានសេចក្តីត្រិះរិះក្នុងចិត្តកើតឡើង យ៉ាងនេះថា អើហ្ន៎ បានឮថា រូបជាអនត្តា វេទនាជាអនត្តា សញ្ញាជា អនត្តា សង្ខារជាអនត្តា វិញ្ញាណជាអនត្តា កម្មដែលអនត្តាធ្វើហើយ នឹងពាល់ត្រូវនូវខ្លួនដូចម្តេចបាន ។ លំដាប់នោះ ព្រះមានព្រះភាគទ្រង់ បានជ្រាបនូវសេចក្តីត្រិះរិះ នៃចិត្តរបស់ភិក្ខុនោះ ដោយព្រះហឫទ័យ របស់ព្រះអង្គហើយ ក៏ត្រាស់នឹងភិក្ខុទាំងឡាយថា ម្នាលភិក្ខុទាំងឡាយ ការណ៍នុ៎ះ រមែងមានពិត គឺត្រង់ដែលមោឃបុរសខ្លះ ក្នុងលោកនេះ ជាអ្នកមិនដឹង ប្រកបដោយអវិជ្ជា សំគាល់នូវសាសនា របស់ព្រះ សាស្តា ថាជាពាក្យគួរប្រព្រឹត្តកន្លងដោយចិត្តដែលមានតណ្ហាជាធំថា អើ ហ្ន៎ បានឮថា រូបជាអនត្តា វេទនាជាអនត្តា សញ្ញាជាអនត្តា សង្ខារ

អនត្តា វិញ្ញាណំ អនត្តា អនត្តកតានិ កម្មានិ កមត្តានំ ផុសិស្សន្តីតិ បដិបុច្ឆាមិ វិនីតា[១] ខោ មេ តុម្ហេ ភិក្ខវេ តត្រ តត្រ ធម្មេសុ តំ កឹ មញ្ញថ ភិក្ខវេ រូបំ និច្ចំ វា អនិច្ចំ វាតិ ។ អនិច្ចំ ភន្តេ ។ យម្បនានិច្ចំ ទុក្ខំ វា តំ សុខំ វាតិ ។ ទុក្ខំ ភន្តេ ។ យម្បនានិច្ចំ ទុក្ខំ វិបរិណាមធម្មំ កល្លំ នុ តំ សមនុបស្សិតុំ ឯតំ មម ឯសោហមស្មិ ឯសោ មេ អត្តាតិ ។ នោ ហេតំ ភន្តេ ។ តំ កឹ មញ្ញថ ភិក្ខវេ វេទនា ។បេ។ សញ្ញា ... សង្ខារា ... វិញ្ញាណំ និច្ចំ វា អនិច្ចំ វាតិ ។ អនិច្ចំ ភន្តេ ។ យម្បនានិច្ចំ ទុក្ខំ វា តំ សុខំ វាតិ ។ ទុក្ខំ ភន្តេ ។ យម្បនានិច្ចំ ទុក្ខំ វិបរិណាមធម្មំ

---

១ ឱ. បដិបូ វិនីតា ។ ម. បដិវិនីតា ។

ជាអនត្តា វិញ្ញាណជាអនត្តា កម្មដែលអនត្តាធ្វើហើយ នឹងពាល់ត្រូវនូវខ្លួនដូចម្តេចបាន ឥឡូវនេះ តថាគតនឹងសួរអ្នកវិញ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយ ដែលតថាគតទូន្មានហើយ ក្នុងធម៌ទាំងឡាយនោះ ៗ ថា ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយ សំគាល់នូវហេតុនោះដូចម្តេច រូបទៀង ឬមិនទៀងទេ ។ ភិក្ខុទាំងឡាយក្រាបទូលថា សូមទ្រង់ព្រះមេត្តាប្រោស មិនទៀងទេ ។ ចុះរបស់ណាដែលមិនទៀង របស់នោះជាទុក្ខ ឬជាសុខ ។ សូមទ្រង់ព្រះមេត្តាប្រោស ជាទុក្ខ ។ របស់ណាដែលមិនទៀង ជាទុក្ខ មានសេចក្តីប្រែប្រួលជាធម្មតា របស់នោះគួរដើម្បីពិចារណាឃើញថា នុ៎ះជារបស់អញ នុ៎ះជាអាត្មាអញ នុ៎ះជាខ្លួនរបស់អញដែរឬ ។ សូមទ្រង់ព្រះមេត្តាប្រោស មិនគួរឃើញដូច្នោះទេ ។ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយសំគាល់នូវហេតុនោះដូចម្តេច វេទនា ។ បេ ។ សញ្ញា... សង្ខារ ... វិញ្ញាណ ជារបស់ទៀង ឬមិនទៀង ។ សូមទ្រង់ព្រះមេត្តាប្រោស មិនទៀងទេ ។ ចុះរបស់ណា ដែលមិនទៀង របស់នោះជាទុក្ខ ឬជាសុខ ។ សូមទ្រង់ព្រះមេត្តាប្រោស ជាទុក្ខ ។ ចុះរបស់ណា ដែលមិនទៀង ជាទុក្ខ មានសេចក្តីប្រែប្រួលជាធម្មតា

កល្លំ នុ តំ សមនុបស្សិតុំ ឯតំ មម ឯសោហមស្មិ ឯសោ មេ អត្តាតិ ។ នោ ហេតំ ភន្តេ ។ តស្មាតិហ ភិក្ខវេ យំ កិញ្ចិ រូបំ អតីតានាគតប្បច្ចុប្បន្នំ អជ្ឈត្តំ វា ពហិទ្ធា វា ឱឡារិកំ វា សុខុមំ វា ហីនំ វា បណីតំ វា យំ ទូរេ សន្តិកេ វា សព្វំ រូបំ នេតំ មម នេសោហមស្មិ ន មេសោ អត្តាតិ ឯវមេតំ យថាភូតំ សម្មប្បញ្ញាយ ទដ្ឋព្វំ ។ យា កាចិ វេទនា... យា កាចិ សញ្ញា... យេ កេចិ សង្ខារា... យំ កិញ្ចិ វិញ្ញាណំ អតីតានាគតប្បច្ចុប្បន្នំ អជ្ឈត្តំ វា ពហិទ្ធា វា ឱឡារិកំ វា សុខុមំ វា ហីនំ វា បណីតំ វា យំ ទូរេ សន្តិកេ វា សព្វំ វិញ្ញាណំ នេតំ មម នេសោហមស្មិ ន មេសោ អត្តាតិ ឯវមេតំ យថាភូតំ សម្មប្បញ្ញាយ ទដ្ឋព្វំ ។ ឯវំ បស្សំ ភិក្ខវេ សុតវា អរិយសាវកោ រូបស្មឹបិ និព្វិន្ទតិ វេទនាយបិ និព្វិន្ទតិ

របស់នោះគួរដើម្បីពិចារណាឃើញថា នុ៎ះជារបស់អញ នុ៎ះជាអាត្មាអញ នុ៎ះជាខ្លួនរបស់អញ ដែរឬ ។ សូមទ្រង់ព្រះមេត្តាប្រោស មិនគួរឃើញដូច្នោះទេ ។ ម្នាលភិក្ខុទាំងឡាយ ព្រោះហេតុនោះ រូបណាមួយក្នុងលោកនេះ ទោះជាអតីត អនាគត បច្ចុប្បន្ន ជាខាងក្នុងក្តី ខាងក្រៅក្តី គ្រោតគ្រាតក្តី ល្អិតក្តី ថោកទាបក្តី ឧត្តមក្តី ទោះរូបណាដែលឆ្ងាយក្តី ជិតក្តី ឈ្មោះថារូបទាំងអស់ រូបនោះបុគ្គលគប្បីឃើញដោយបញ្ញាដ៏ប្រពៃ តាមពិតយ៉ាងនេះ ដូច្នេះថា នុ៎ះមិនមែនជារបស់អញ នុ៎ះមិនមែនជាអាត្មាអញ នុ៎ះមិនមែនជាខ្លួនរបស់អញទេ ។ វេទនាណាមួយ ... សញ្ញាណាមួយ ... សង្ខារណាមួយ ... វិញ្ញាណណាមួយ ទោះជាអតីត អនាគត បច្ចុប្បន្ន ជាខាងក្នុងក្តី ខាងក្រៅក្តី គ្រោតគ្រាតក្តី ល្អិតក្តី ថោកទាបក្តី ឧត្តមក្តី ទោះវិញ្ញាណណាដែលឆ្ងាយក្តី ជិតក្តី ឈ្មោះថាវិញ្ញាណទាំងអស់ វិញ្ញាណនុ៎ះបុគ្គលគប្បីឃើញដោយបញ្ញាដ៏ប្រពៃ តាមពិតយ៉ាងនេះដូច្នេះថា នុ៎ះមិនមែនជារបស់អញ នុ៎ះមិនមែនជាអាត្មាអញ នុ៎ះមិនមែនជាខ្លួនរបស់អញទេ ។ ម្នាលភិក្ខុទាំងឡាយ អរិយសាវកដែលជាអ្នកចេះដឹង កាលបើបានឃើញយ៉ាងនេះហើយ រមែងនឿយណាយក្នុងរូបផង នឿយណាយក្នុងវេទនាផង

សញ្ញាយបិ និព្វិន្ទតិ សង្ខារេសុបិ និព្វិន្ទតិ វិញ្ញាណស្មឹបិ និព្វិន្ទតិ និព្វិន្ទំ វិរជ្ជតិ វិរាគា វិមុច្ចតិ វិមុត្តស្មឹ វិមុត្តមិតិ ញាណំ ហោតិ ខីណា ជាតិ វុសិតំ ព្រហ្មចរិយំ កតំ ករណីយំ នាបរំ ឥត្ថត្តាយាតិ បជានាតីតិ ។ ឥទមវោច ភគវា អត្តមនា តេ ភិក្ខូ ភគវតោ ភាសិតំ អភិនន្ទុន្តិ ។ ឥមស្មិញ្ច បន វេយ្យាករណស្មឹ ភញ្ញមានេ សដ្ឋិមត្តានំ ភិក្ខូនំ អនុបាទាយ អាសវេហិ ចិត្តានិ វិមុច្ចឹសូតិ ។

មហាបុណ្ណមសុត្តំ បឋមំ និដ្ឋិតំ ។

នឿយណាយក្នុងសញ្ញាផង នឿយណាយក្នុងសង្ខារផង នឿយណាយក្នុងវិញ្ញាណផង កាលបើមានចិត្តនឿយណាយហើយ រមែងប្រាសចាកតម្រេក កាលបើមានចិត្តប្រាសចាកតម្រេកហើយ រមែងរួចស្រឡះ កាលបើមានចិត្តរួចស្រឡះហើយ សេចក្ដីដឹងថា ចិត្តរួចស្រឡះហើយ ក៏កើតឡើង មួយទៀត ដឹងច្បាស់ថា ជាតិអស់ហើយ មគ្គព្រហ្មចរិយៈ អាត្មាអញ ក៏បានប្រព្រឹត្តគ្រប់គ្រាន់ហើយ សោឡសកិច្ចអាត្មាអញបានធ្វើស្រេចហើយ មគ្គភាវនាកិច្ចដទៃ ប្រព្រឹត្តទៅដើម្បីសោឡសកិច្ចនេះទៀត មិនមានឡើយ ។ លុះព្រះមានព្រះភាគ ទ្រង់ត្រាស់សូត្រនេះចប់ហើយ ភិក្ខុទាំងនោះដែលជាអ្នកមានសេចក្ដីត្រេកអរ ក៏បានត្រេកអរចំពោះភាសិត របស់ព្រះមានព្រះភាគ ។ កាលដែលព្រះមានព្រះភាគកំពុងសំដែងវេយ្យាករណ៍នេះ ពួកភិក្ខុប្រមាណ ៦០ រូប ក៏មានចិត្តរួចស្រឡះចាកអាសវៈទាំងឡាយ ព្រោះមិនមានឧបាទាន ។

ចប់ មហាបុណ្ណមសូត្រ ទី ៩ ។

# ទសមំ ចូឡបុណ្ណមសុត្តំ

(១៣០) ឯវំ មេ សុតំ ។ ឯកំ សមយំ ភគវា សាវត្ថិយំ វិហរតិ បុព្វារាមេ មិគារមាតុ បាសាទេ ។ តេន ខោ បន សមយេន ភគវា តទហុបោសថេ បណ្ណរសេ បុណ្ណាយ បុណ្ណមាយ រត្តិយា ភិក្ខុសង្ឃ-បរិវុតោ អព្ភោកាសេ និសិន្នោ ហោតិ ។

(១៣១) អថខោ ភគវា តុណ្ហីភូតំ[១] ភិក្ខុសង្ឃំ អនុវិលោកេត្វា ភិក្ខូ អាមន្តេសិ ជានេយ្យ នុ ខោ ភិក្ខវេ អសប្បុរិសោ អសប្បុរិសំ អសប្បុរិសោ អយម្ភ-វន្តិ ។ នោ ហេតំ ភន្តេ ។ សាធុ ភិក្ខវេ អដ្ឋានមេតំ ភិក្ខវេ អនវកាសោ យំ អសប្បុរិសោ អសប្បុរិសំ ជានេយ្យ អសប្បុរិសោ អយម្ភវន្តិ ជានេយ្យ

១ ឱ. ម. តុណ្ហីភូតំ តុណ្ហីភូតន្តិ អាមេណ្ឌិតំ ទិស្សតិ ។

## ចូឡបុណ្ណមសូត្រ ទី ១០

(១៣០) ខ្ញុំបានស្ដាប់មក យ៉ាងនេះ ។ សម័យមួយ ព្រះមានព្រះភាគ ទ្រង់គង់ក្នុងមិគារមាតុប្រាសាទ ក្នុងបុព្វារាម ជិតក្រុងសាវត្ថី ។ សម័យនោះឯង ព្រះមានព្រះភាគ មានភិក្ខុសង្ឃចោមរោម ទ្រង់គង់ក្នុងវាលស្រឡះ ក្នុងវេលារាត្រី ដែលមានព្រះចន្ទពេញវង់ ជាថ្ងៃឧបោសថ ទី ១៥ ។

(១៣១) គ្រានោះ ព្រះមានព្រះភាគ ទ្រង់ទតចំពោះទៅភិក្ខុសង្ឃដែលនៅស្ងៀម ក៏មានព្រះបន្ទូលសួរភិក្ខុទាំងឡាយថា ម្នាលភិក្ខុទាំងឡាយ អសប្បុរស អាចស្គាល់នូវអសប្បុរសថា អ្នកនេះ ជាអសប្បុរសដែរឬហ្ន៎ ។ ភិក្ខុទាំងឡាយក្រាបទូលថា សូមទ្រង់ព្រះមេត្តាប្រោស មិនស្គាល់ដូច្នោះទេ ។ ម្នាលភិក្ខុទាំងឡាយ ត្រូវហើយ ម្នាលភិក្ខុទាំងឡាយ មិនមែនជាហេតុ មិនមែនជាឱកាសទេ ត្រង់ដែលអសប្បុរស អាចស្គាល់នូវអសប្បុរសថា អ្នកនេះ ជាអសប្បុរស

បន ភិក្ខវេ អសប្បុរិសោ សប្បុរិសំ សប្បុរិសោ អយន្តិ ។ នោ ហេតំ ភន្តេ ។ សាធុ ភិក្ខវេ ឯតម្បិ[1] ភិក្ខវេ អដ្ឋានំ អនវកាសោ យំ អសប្បុរិសោ សប្បុរិសំ ជានេយ្យ សប្បុរិសោ អយន្តិ ។

(១៣២) អសប្បុរិសោ ភិក្ខវេ អសទ្ធម្មសមន្នាគតោ ហោតិ អសប្បុរិសភត្តី ហោតិ អសប្បុរិសចិន្តី ហោតិ អសប្បុរិសមន្តី ហោតិ អសប្បុរិសវាចោ ហោតិ អសប្បុរិសកម្មន្តោ ហោតិ អសប្បុរិសទិដ្ឋី ហោតិ អសប្បុរិសទានំ ទេតិ ។

(១៣៣) កថញ្ច ភិក្ខវេ អសប្បុរិសោ អសទ្ធម្មសមន្នាគតោ ហោតិ ។ ឥធ ភិក្ខវេ អសប្បុរិសោ អស្សទ្ធោ ហោតិ អហិរិកោ ហោតិ អនោត្តប្បី ហោតិ អប្បស្សុតោ ហោតិ កុសីតោ ហោតិ មុដ្ឋស្សតី ហោតិ ទុប្បញ្ញោ ហោតិ ឯវំ ខោ ភិក្ខវេ អសប្បុរិសោ អសទ្ធម្មសមន្នាគតោ ហោតិ ។

---

១ ឱ. ឯតម្បិ ខោ ។ ម. ឯតំបិ ខោ ។

ម្នាលភិក្ខុទាំងឡាយ មួយទៀត អសប្បុរស អាចស្គាល់នូវសប្បុរសថា អ្នកនេះ ជាសប្បុរសដែរឬ ។ សូមទ្រង់ព្រះមេត្តាប្រោស មិនអាចស្គាល់ដូច្នោះទេ ។ ម្នាលភិក្ខុទាំងឡាយ ត្រូវហើយ ម្នាលភិក្ខុទាំង-ឡាយ មិនមែនជាហេតុ មិនមែនជាឱកាសដែរ ត្រង់ដែលអសប្បុរស អាចស្គាល់នូវសប្បុរសថា អ្នកនេះ ជាសប្បុរស ។

(១៣៤) ម្នាលភិក្ខុទាំងឡាយ អសប្បុរស ជាអ្នកប្រកបដោយអសទ្ធម្ម (ធម៌ដ៏លាមក) មានការសេពគប់ជាអសប្បុរស មានគំនិតជាអសប្បុរស មានសេចក្ដីប្រឹក្សាជាអសប្បុរស មានវាចាជាអសប្បុរស មានការងារជាអសប្បុរស មានទិដ្ឋិជាអសប្បុរស តែងឲ្យទានជាអសប្បុរស ។

(១៣៣) ម្នាលភិក្ខុទាំងឡាយ ចុះអសប្បុរស ប្រកបដោយអសទ្ធម្ម ដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ អសប្បុរស ក្នុងលោកនេះ មិនមានសទ្ធា មិនមានសេចក្ដីខ្មាសបាប មិនមានសេចក្ដីខ្លាចបាប ជាអ្នកចេះដឹងតិច ខ្ជិលច្រអូស ភ្លេចស្មារតី ឥតបញ្ញា ម្នាលភិក្ខុទាំងឡាយ អសប្បុរស ប្រកបដោយអសទ្ធម្ម យ៉ាងនេះឯង ។

(១៣៤) កថញ្ច ភិក្ខវេ អសប្បុរិសោ អសប្បុរិសភត្តី ហោតិ ។ ឥធ ភិក្ខវេ អសប្បុរិសស្ស យេ តេ សមណព្រាហ្មណា អស្សទ្ធា អហិរិកា អនោត្តប្បិនោ អប្បស្សុតា កុសីតា មុដ្ឋស្សតិនោ ទុប្បញ្ញា ត្យស្ស មិត្តា ហោន្តិ តេ សហាយា ឯវំ ខោ ភិក្ខវេ អសប្បុរិសោ អសប្បុរិសភត្តី ហោតិ ។

(១៣៥) កថញ្ច ភិក្ខវេ អសប្បុរិសោ អសប្បុរិសចិន្តី ហោតិ ។ ឥធ ភិក្ខវេ អសប្បុរិសោ អត្តព្យាពាធាយបិ ចេតេតិ បរព្យាពាធាយបិ ចេតេតិ ឧភយព្យាពាធាយបិ ចេតេតិ ឯវំ ខោ ភិក្ខវេ អសប្បុរិសោ អសប្បុរិសចិន្តី ហោតិ ។

(១៣៦) កថញ្ច ភិក្ខវេ អសប្បុរិសោ អសប្បុរិសមន្តី ហោតិ ។ ឥធ ភិក្ខវេ អសប្បុរិសោ អត្តព្យាពាធាយបិ មន្តេតិ បរព្យាពាធាយបិ មន្តេតិ ឧភយព្យាពាធាយបិ មន្តេតិ ឯវំ ខោ ភិក្ខវេ អសប្បុរិសោ អសប្បុរិសមន្តី ហោតិ ។

(១៣៤) ម្នាលភិក្ខុទាំងឡាយ ចុះអសប្បុរស មានការសេពគប់ជាអសប្បុរស តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ ពួកសមណព្រាហ្មណ៍ណា ក្នុងលោកនេះ ដែលមិនមានសទ្ធា មិនខ្មាសបាប មិនខ្លាចបាប ចេះដឹងតិច ខ្ជិលច្រអូស ភ្លេចស្មារតី ឥតបញ្ញា សមណព្រាហ្មណ៍ទាំងនោះ រមែងបានជាមិត្ត ជាសំឡាញ់ របស់អសប្បុរសនោះ ម្នាលភិក្ខុទាំងឡាយ អសប្បុរស សេពគប់នូវអសប្បុរស យ៉ាងនេះឯង ។

(១៣៥) ម្នាលភិក្ខុទាំងឡាយ ចុះអសប្បុរស មានគំនិតជាអសប្បុរស តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ អសប្បុរស ក្នុងលោកនេះ គិតដើម្បីបៀតបៀនខ្លួនឯងផង គិតដើម្បីបៀតបៀនអ្នកដទៃផង គិតដើម្បីបៀតបៀនទាំងពីរខាងផង ម្នាលភិក្ខុទាំងឡាយ អសប្បុរស មានគំនិតជាអសប្បុរស យ៉ាងនេះឯង ។

(១៣៦) ម្នាលភិក្ខុទាំងឡាយ ចុះអសប្បុរស មានសេចក្តីប្រឹក្សាជាអសប្បុរស តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ អសប្បុរស ក្នុងលោកនេះ ប្រឹក្សាដើម្បីបៀតបៀនខ្លួនឯងផង ប្រឹក្សាដើម្បីបៀតបៀនអ្នកដទៃផង ប្រឹក្សាដើម្បីបៀតបៀនទាំងពីរខាងផង ម្នាលភិក្ខុទាំងឡាយ អសប្បុរស មានសេចក្តីប្រឹក្សាជាអសប្បុរស យ៉ាងនេះឯង ។

(១៣៧) កថញ្ច ភិក្ខវេ អសប្បុរិសោ អសប្បុរិសតរោ ហោតិ ។ ឥធ ភិក្ខវេ អសប្បុរិសោ មុសាវាទី ហោតិ បិសុណាវាចោ ហោតិ ផរុសវាចោ ហោតិ សម្ផប្បលាបី ហោតិ ឯវំ ខោ ភិក្ខវេ អសប្បុរិសោ អសប្បុរិសតរោ ហោតិ ។

(១៣៨) កថញ្ច ភិក្ខវេ អសប្បុរិសោ អសប្បុរិសធម្មោ ហោតិ ។ ឥធ ភិក្ខវេ អសប្បុរិសោ បាណាតិបាតី ហោតិ អទិន្នាទាយី ហោតិ កាមេសុមិច្ឆាចារី ហោតិ ឯវំ ខោ ភិក្ខវេ អសប្បុរិសោ អសប្បុរិសធម្មោ ហោតិ ។

(១៣៩) កថញ្ច ភិក្ខវេ អសប្បុរិសោ អសប្បុរិសទិដ្ឋិ ហោតិ ។ ឥធ ភិក្ខវេ អសប្បុរិសោ ឯវំទិដ្ឋិកោ[១] ហោតិ នត្ថិ ទិន្នំ នត្ថិ យិដ្ឋំ នត្ថិ ហុតំ នត្ថិ សុកតទុក្កដានំ កម្មានំ ផលំ វិបាកោ នត្ថិ អយំ លោកោ នត្ថិ បរោ លោកោ

១ ឱ. ម. ឯវំទិដ្ឋី ។

(១៣៧) ម្នាលភិក្ខុទាំងឡាយ ចុះអសប្បុរស មានវាចាជាអសប្បុរស តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ អសប្បុរសក្នុងលោកនេះ មានពាក្យកុហក ពាក្យញុះញង់ ពាក្យទ្រគោះ ពាក្យរោយរាយឥតប្រយោជន៍ ម្នាលភិក្ខុទាំងឡាយ អសប្បុរស មានវាចាជាអសប្បុរស យ៉ាងនេះឯង ។

(១៣៨) ម្នាលភិក្ខុទាំងឡាយ ចុះអសប្បុរស មានការងារជាអសប្បុរស តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ អសប្បុរសក្នុងលោកនេះ ជាអ្នកសម្លាប់សត្វ លួចទ្រព្យគេ ប្រព្រឹត្តខុសក្នុងកាម ម្នាលភិក្ខុទាំងឡាយ អសប្បុរសមានការងារជាអសប្បុរស យ៉ាងនេះឯង ។

(១៣៩) ម្នាលភិក្ខុទាំងឡាយ ចុះអសប្បុរស មានទិដ្ឋិជាអសប្បុរស តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ អសប្បុរសក្នុងលោកនេះ មានសេចក្តីយល់ឃើញយ៉ាងនេះថា ទានដែលបុគ្គលឲ្យហើយ មិនមានផល ការបូជាធំ មិនមានផល ការបូជាតូច មិនមានផល ផលវិបាកនៃកម្មល្អនិងអាក្រក់ មិនមាន លោកនេះ មិនមាន លោកខាងមុខ មិនមាន

នត្ថិ មាតា នត្ថិ បិតា នត្ថិ សត្តា ឱបបាតិកា
នត្ថិ លោកេ សមណព្រាហ្មណា សម្មគ្គតា សម្មា-
បដិបន្នា យេ ឥមញ្ច លោកំ បរញ្ច លោកំ
សយំ អភិញ្ញា សច្ឆិកត្វា បវេទេន្តីតិ ឯវំ ខោ
ភិក្ខវេ អសប្បុរិសោ អសប្បុរិសទិដ្ឋិ ហោតិ ។

(១៨០) កថញ្ច ភិក្ខវេ អសប្បុរិសោ អសប្បុ-
រិសទានំ ទេតិ ។ ឥធ ភិក្ខវេ អសប្បុរិសោ អ-
សក្កច្ចំ ទានំ ទេតិ អសហត្ថា ទានំ ទេតិ អ-
ចិត្តីកត្វា ទានំ ទេតិ អបវិទ្ធំ ទានំ ទេតិ
អនាគមនទិដ្ឋិកោ ទានំ ទេតិ ឯវំ ខោ ភិក្ខវេ
អសប្បុរិសោ អសប្បុរិសទានំ ទេតិ ។

ការប្រតិបត្តិល្អអាក្រក់ក្នុងមាតា មិនមានផល ការប្រតិបត្តិល្អអាក្រក់ក្នុងបិតា មិនមានផល សត្វដែលជាឧបបាតិកៈ មិនមាន សមណព្រាហ្មណ៍ក្នុងលោកនេះ ដែលប្រព្រឹត្តល្អ ប្រតិបត្តិល្អ ធ្វើឲ្យជាក់ច្បាស់ដោយបញ្ញាដ៏ឧត្តម នៃខ្លួនឯង នូវលោកនេះផង លោកខាងមុខផង ហើយអាចប្រកាសបាន មិនមានឡើយ ម្នាលភិក្ខុទាំងឡាយ អសប្បុរស មានទិដ្ឋិជាអសប្បុរស យ៉ាងនេះឯង ។

(១៨០) ម្នាលភិក្ខុទាំងឡាយ ចុះអសប្បុរស ឲ្យអសប្បុរិសទាន តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ អសប្បុរសក្នុងលោកនេះ ឲ្យទានដោយមិនគោរព[១] ឲ្យទានមិនមែនឲ្យដោយដៃរបស់ខ្លួន ឲ្យទានមិនធ្វើសេចក្តីកោតក្រែង ឲ្យទានបោះគ្រវែងចោល មិនបានយល់ឃើញផលហើយឲ្យទាន ម្នាលភិក្ខុទាំងឡាយ អសប្បុរស ឲ្យអសប្បុរិសទាន យ៉ាងនេះឯង ។

---

១ មិនគោរពទេយ្យធម៌ ១ មិនគោរពបដិគ្គាហកបុគ្គល ១ ។

(១៤១) ស ខោ សោ ភិក្ខវេ អសប្បុរិសោ ឯវំ អសទ្ធម្មសមន្នាគតោ ឯវំ អសប្បុរិសភត្តី ឯវំ អសប្បុរិសចិន្តី ឯវំ អសប្បុរិសមន្តី ឯវំ អសប្បុរិសវាចោ ឯវំ អសប្បុរិសកម្មន្តោ ឯវំ អសប្បុរិសទិដ្ឋី ឯវំ អសប្បុរិសទានំ ទត្វា កាយស្ស ភេទា បរម្មរណា យា អសប្បុរិសានំ គតិ តត្ថ ឧបបជ្ជតិ ។

កា ច ភិក្ខវេ អសប្បុរិសានំ គតិ និរយោ វា តិរច្ឆានយោនិ វា ។

(១៤២) ជានេយ្យ នុ ខោ ភិក្ខវេ សប្បុរិសោ សប្បុរិសំ សប្បុរិសោ អយម្ភវន្តិ ។ ឯវំ ភន្តេ ។ សាធុ ភិក្ខវេ ឋានមេតំ ភិក្ខវេ វិជ្ជតិ យំ សប្បុរិសោ សប្បុរិសំ ជានេយ្យ សប្បុរិសោ អយម្ភវន្តិ ជានេយ្យ បន ភិក្ខវេ សប្បុរិសោ អសប្បុរិសំ អសប្បុរិសោ អយម្ភវន្តិ ។ ឯវំ ភន្តេ ។ សាធុ ភិក្ខវេ ឯតម្បិ ខោ ភិក្ខវេ ឋានំ វិជ្ជតិ យំ សប្បុរិសោ អសប្បុរិសំ ជានេយ្យ អសប្បុរិសោ អយម្ភវន្តិ ។

(១៤១) ម្នាលភិក្ខុទាំងឡាយ អសប្បុរសនោះឯង ប្រកបដោយអសទ្ធម្មយ៉ាងនេះ មានការសេពគប់ជាអសប្បុរសយ៉ាងនេះ មានគំនិតជាអសប្បុរសយ៉ាងនេះ មានសេចក្តីប្រឹក្សាជាអសប្បុរសយ៉ាងនេះ មានវាចាជាអសប្បុរសយ៉ាងនេះ មានការងារជាអសប្បុរសយ៉ាងនេះ មានទិដ្ឋិជាអសប្បុរសយ៉ាងនេះ ឲ្យទានជាអសប្បុរសយ៉ាងនេះហើយ លុះមានកាយបែកធ្លាយទៅ ខាងមុខបន្ទាប់អំពីមរណៈ តែងទៅកើតក្នុងគតិរបស់ពួកអសប្បុរស ។ ម្នាលភិក្ខុទាំងឡាយ ឯគតិរបស់ពួកអសប្បុរសតើដូចម្តេច គតិរបស់ពួកអសប្បុរស គឺ នរក ឬកំណើតតិរច្ឆាន ។

(១៤២) ម្នាលភិក្ខុទាំងឡាយ សប្បុរស អាចស្គាល់នូវសប្បុរសថា អ្នកនេះជាសប្បុរសដែរឬ ។ ព្រះករុណា ព្រះអង្គ ។ ម្នាលភិក្ខុទាំងឡាយ ត្រូវហើយ ម្នាលភិក្ខុទាំងឡាយ ការណ៍នុ៎ះរមែងមានពិត គឺត្រង់ដែលសប្បុរស អាចស្គាល់នូវសប្បុរសថា អ្នកនេះ ជាសប្បុរស ម្នាលភិក្ខុទាំងឡាយ មួយទៀត សប្បុរស អាចស្គាល់នូវអសប្បុរសថា អ្នកនេះជាអសប្បុរសដែរឬ ។ ព្រះករុណា ព្រះអង្គ ។ ម្នាលភិក្ខុទាំងឡាយ ត្រូវហើយ ម្នាលភិក្ខុទាំងឡាយ ការណ៍នុ៎ះក៏រមែងមានពិត គឺត្រង់ដែលសប្បុរស អាចស្គាល់នូវអសប្បុរសថា អ្នកនេះជាអសប្បុរស ។

(១៤៣) សប្បុរិសោ ភិក្ខវេ សទ្ធម្មសមន្នាគតោ ហោតិ សប្បុរិសភត្តី ហោតិ សប្បុរិសចិន្តី ហោតិ សប្បុរិសមន្តី ហោតិ សប្បុរិសវាចោ ហោតិ សប្បុរិសកម្មន្តោ ហោតិ សប្បុរិសទិដ្ឋី ហោតិ សប្បុរិសទានំ ទេតិ ។

(១៤៤) កថញ្ច ភិក្ខវេ សប្បុរិសោ សទ្ធម្មសមន្នាគតោ ហោតិ ។ ឥធ ភិក្ខវេ សប្បុរិសោ សទ្ធោ ហោតិ ហិរិមា ហោតិ ឱត្តប្បី ហោតិ ពហុស្សុតោ ហោតិ អារទ្ធវិរិយោ ហោតិ ឧបដ្ឋិតស្សតី ហោតិ បញ្ញវា ហោតិ ឯវំ ខោ ភិក្ខវេ សប្បុរិសោ សទ្ធម្មសមន្នាគតោ ហោតិ ។

(១៤៥) កថញ្ច ភិក្ខវេ សប្បុរិសោ សប្បុរិសភត្តី ហោតិ ។ ឥធ ភិក្ខវេ សប្បុរិសស្ស យេ តេ សមណព្រាហ្មណា សទ្ធា ហិរិមន្តោ ឱត្តប្បិនោ ពហុស្សុតា អារទ្ធវិរិយា ឧបដ្ឋិតស្សតិនោ បញ្ញវន្តោ ត្យស្ស មិត្តា ហោន្តិ សហាយា ឯវំ ខោ ភិក្ខវេ សប្បុរិសោ សប្បុរិសភត្តី ហោតិ ។

(១៤៣) ម្នាលភិក្ខុទាំងឡាយ សប្បុរស រមែងប្រកបដោយព្រះសទ្ធម្ម ជាអ្នកមានការសេពគប់ជាសប្បុរស មានគំនិតជាសប្បុរស មានសេចក្តីប្រឹក្សាជាសប្បុរស មានវាចាជាសប្បុរស មានការងារជាសប្បុរស មានទិដ្ឋិជាសប្បុរស តែងឲ្យទានជាសប្បុរស ។

(១៤៤) ម្នាលភិក្ខុទាំងឡាយ ចុះសប្បុរស ប្រកបដោយព្រះសទ្ធម្ម តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ សប្បុរសក្នុងលោកនេះ ជាអ្នកមានសទ្ធា មានសេចក្តីខ្មាសបាប មានសេចក្តីខ្លាចបាប ជាអ្នកចេះដឹងច្រើន មានព្យាយាមតឹងតែង មានស្មារតីតម្កល់ខ្ជាប់ មានបញ្ញា ម្នាលភិក្ខុទាំងឡាយ សប្បុរស រមែងប្រកបដោយព្រះសទ្ធម្ម យ៉ាងនេះឯង ។

(១៤៥) ម្នាលភិក្ខុទាំងឡាយ ចុះសប្បុរស មានការសេពគប់ជាសប្បុរស តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ ក្នុងលោកនេះ ពួកសមណព្រាហ្មណ៍ណា ដែលមានសទ្ធា មានសេចក្តីខ្មាសបាប មានសេចក្តីខ្លាចបាប ជាអ្នកចេះដឹងច្រើន មានព្យាយាមតឹងតែង មានស្មារតីតម្កល់ខ្ជាប់ មានបញ្ញា ពួកសមណព្រាហ្មណ៍នោះ រមែងបានជាមិត្ត ជាសំឡាញ់ នៃសប្បុរសនោះ ម្នាលភិក្ខុទាំងឡាយ សប្បុរស មានការសេពគប់ជាសប្បុរស យ៉ាងនេះឯង ។

(១៦៦) កថញ្ច ភិក្ខវេ សប្បុរិសោ សប្បុរិសចិន្តី ហោតិ ។ ឥធ ភិក្ខវេ សប្បុរិសោ នេវត្តព្យាពាធាយ ចេតេតិ ន បរព្យាពាធាយ ចេតេតិ ន ឧភយព្យាពាធាយ ចេតេតិ ឯវំ ខោ ភិក្ខវេ សប្បុរិសោ សប្បុរិសចិន្តី ហោតិ ។

(១៦៧) កថញ្ច ភិក្ខវេ សប្បុរិសោ សប្បុរិសមន្តី ហោតិ ។ ឥធ ភិក្ខវេ សប្បុរិសោ នេវត្តព្យាពាធាយ មន្តេតិ ន បរព្យាពាធាយ មន្តេតិ ន ឧភយព្យាពាធាយ មន្តេតិ ឯវំ ខោ ភិក្ខវេ សប្បុរិសោ សប្បុរិសមន្តី ហោតិ ។

(១៦៨) កថញ្ច ភិក្ខវេ សប្បុរិសោ សប្បុរិសវាចោ ហោតិ ។ ឥធ ភិក្ខវេ សប្បុរិសោ មុសាវាទា បដិវិរតោ ហោតិ បិសុណាយ វាចាយ បដិវិរតោ ហោតិ ផរុសាយ វាចាយ បដិវិរតោ ហោតិ សម្ផប្បលាបា បដិវិរតោ ហោតិ ឯវំ ខោ ភិក្ខវេ សប្បុរិសោ សប្បុរិសវាចោ ហោតិ ។

(១៤៦) ម្នាលភិក្ខុទាំងឡាយ ចុះសប្បុរស មានគំនិតជាសប្បុរស តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ សប្បុរសក្នុងលោកនេះ មិនគិតដើម្បីបៀតបៀនខ្លួនឯង មិនគិតដើម្បីបៀតបៀនអ្នកដទៃ មិនគិតដើម្បីបៀតបៀនទាំងពីរខាង ម្នាលភិក្ខុទាំងឡាយ សប្បុរស មានគំនិតជាសប្បុរស យ៉ាងនេះឯង ។

(១៤៧) ម្នាលភិក្ខុទាំងឡាយ ចុះសប្បុរស មានសេចក្តីប្រឹក្សាជាសប្បុរស តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ សប្បុរសក្នុងលោកនេះ មិនប្រឹក្សាដើម្បីបៀតបៀនខ្លួនឯង មិនប្រឹក្សាដើម្បីបៀតបៀនអ្នកដទៃ មិនប្រឹក្សាដើម្បីបៀតបៀនទាំងពីរខាង ម្នាលភិក្ខុទាំងឡាយ សប្បុរស មានសេចក្តីប្រឹក្សាជាសប្បុរស យ៉ាងនេះឯង ។

(១៤៨) ម្នាលភិក្ខុទាំងឡាយ ចុះសប្បុរស មានវាចាជាសប្បុរស តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ សប្បុរសក្នុងលោកនេះ វៀរចាកពាក្យកុហក វៀរចាកពាក្យញុះញង់ វៀរចាកពាក្យទ្រគោះ វៀរចាកពាក្យពេលពាយឥតប្រយោជន៍ ម្នាលភិក្ខុទាំងឡាយ សប្បុរស មានវាចាជាសប្បុរស យ៉ាងនេះឯង ។

(១៤៩) កថញ្ច ភិក្ខវេ សប្បុរិសោ សប្បុរិសកម្មន្តោ ហោតិ ។ ឥធ ភិក្ខវេ សប្បុរិសោ បាណាតិបាតា បដិវិរតោ ហោតិ អទិន្នាទានា បដិវិរតោ ហោតិ កាមេសុ មិច្ឆាចារា បដិវិរតោ ហោតិ ឯវំ ខោ ភិក្ខវេ សប្បុរិសោ សប្បុរិសកម្មន្តោ ហោតិ ។

(១៥០) កថញ្ច ភិក្ខវេ សប្បុរិសោ សប្បុរិសទិដ្ឋិ ហោតិ ។ ឥធ ភិក្ខវេ សប្បុរិសោ ឯវំ ទិដ្ឋិកោ ហោតិ អត្ថិ ទិន្នំ អត្ថិ យិដ្ឋំ អត្ថិ ហុតំ អត្ថិ សុកតទុក្កដានំ កម្មានំ ផលំ វិបាកោ អត្ថិ អយំ លោកោ អត្ថិ បរោ លោកោ អត្ថិ មាតា អត្ថិ បិតា អត្ថិ សត្តា ឱបបាតិកា

(១៤៩) ម្នាលភិក្ខុទាំងឡាយ ចុះសប្បុរស មានការផ្សារជាសប្បុរស តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ សប្បុរសក្នុងលោកនេះ វៀរចាកការសម្លាប់សត្វ វៀរចាកការលួចទ្រព្យគេ វៀរចាកការប្រព្រឹត្តខុសក្នុងកាមទាំងឡាយ ម្នាលភិក្ខុទាំងឡាយ សប្បុរសមានការផ្សារជាសប្បុរស យ៉ាងនេះឯង ។

(១៥០) ម្នាលភិក្ខុទាំងឡាយ ចុះសប្បុរស មានទិដ្ឋិជាសប្បុរស តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ សប្បុរស ក្នុងលោកនេះ មានសេចក្តីយល់ឃើញ យ៉ាងនេះថា ទាន ដែលបុគ្គលឲ្យហើយ មានផល ការបូជាធំ មានផល ការបូជាតូច មានផល ផលនិងវិបាកនៃកម្ម ដែលល្អនិងអាក្រក់ មាន លោកនេះ មាន លោកខាងមុខ មាន ការប្រតិបត្តិល្អអាក្រក់ក្នុងមាតា មានផល ការប្រតិបត្តិល្អអាក្រក់ ក្នុងបិតា មានផល សត្វជាឧបបាតិកៈ មាន

អត្ថិ លោកេ សមណព្រាហ្មណា សម្មគ្គតា សម្មាបដិបន្នា យេ ឥមញ្ច លោកំ បរញ្ច លោកំ សយំ អភិញ្ញា សច្ឆិកត្វា បវេទេន្តីតិ ឯវំ ខោ ភិក្ខវេ សប្បុរិសោ សប្បុរិសទិដ្ឋី ហោតិ ។

(១៨១) កថញ្ច ភិក្ខវេ សប្បុរិសោ សប្បុរិសទានំ ទេតិ ។ ឥធ ភិក្ខវេ សប្បុរិសោ សក្កច្ចំ ទានំ ទេតិ ចិត្តីកត្វា ទានំ ទេតិ បរិសុទ្ធំ ទានំ ទេតិ អាគមនទិដ្ឋិកោ ទានំ ទេតិ ឯវំ ខោ ភិក្ខវេ សប្បុរិសោ សប្បុរិសទានំ ទេតិ ។

(១៨២) ស ខោ សោ ភិក្ខវេ សប្បុរិសោ ឯវំ សទ្ធម្មសមន្នាគតោ ឯវំ សប្បុរិសភត្តី ឯវំ សប្បុរិសចិន្តី ឯវំ សប្បុរិសមន្តី ឯវំ សប្បុរិសវាចោ ឯវំ សប្បុរិសកម្មន្តោ ឯវំ សប្បុរិសទិដ្ឋី ឯវំ សប្បុរិសទានំ ទត្វា កាយស្ស ភេទា បរម្មរណា យា សប្បុរិសានំ គតិ តត្ថ ឧប្បជ្ជតិ កា ច ភិក្ខវេ សប្បុរិសានំ គតិ ទេវមហត្តតា វា មនុស្សមហត្តតា វាតិ ។

ពួកសមណព្រាហ្មណ៍ ក្នុងលោក ដែលប្រព្រឹត្តល្អ ប្រតិបត្តិល្អ ធ្វើឲ្យជាក់ច្បាស់ ដោយបញ្ញាដ៏ឧត្តម នៃខ្លួនឯង នូវលោកនេះផង លោកខាងមុខផង ហើយអាចនឹងប្រកាសបាន រមែងមាន ម្នាលភិក្ខុទាំងឡាយ សប្បុរស មានទិដ្ឋិជាសប្បុរស យ៉ាងនេះឯង ។

(១៨១) ម្នាលភិក្ខុទាំងឡាយ ចុះសប្បុរស តែងឲ្យទានជាសប្បុរស តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ សប្បុរស ក្នុងលោកនេះ ឲ្យទានដោយគោរព ធ្វើនូវសេចក្តីកោតក្រែងហើយឲ្យទាន ឲ្យទានដ៏បរិសុទ្ធ មានសេចក្តីយល់ឃើញនូវផល ហើយឲ្យទាន ម្នាលភិក្ខុទាំងឡាយ សប្បុរស តែងឲ្យទានជាសប្បុរស យ៉ាងនេះឯង ។

(១៨២) ម្នាលភិក្ខុទាំងឡាយ សប្បុរសនោះឯង ប្រកបដោយព្រះសទ្ធម្មយ៉ាងនេះ មានការសេពគប់ជាសប្បុរសយ៉ាងនេះ មានគំនិតជាសប្បុរសយ៉ាងនេះ មានសេចក្តីប្រឹក្សាជាសប្បុរសយ៉ាងនេះ មានវាចាជាសប្បុរសយ៉ាងនេះ មានការងារជាសប្បុរសយ៉ាងនេះ មានទិដ្ឋិជាសប្បុរសយ៉ាងនេះ ឲ្យទានជាសប្បុរសយ៉ាងនេះ លុះមានកាយបែកធ្លាយទៅ ខាងមុខបន្ទាប់អំពីមរណៈ តែងទៅកើតក្នុងគតិរបស់សប្បុរស ម្នាលភិក្ខុទាំងឡាយ ចុះគតិរបស់សប្បុរស តើដូចម្តេច គតិរបស់សប្បុរសនោះ គឺសភាពជាទេវតាដ៏ស្តុកស្តម្ភ ឬសភាពជាមនុស្សដ៏ស្តុកស្តម្ភ ។

ឥទមវោច ភគវា អត្តមនា តេ ភិក្ខូ ភគវតោ ភាសិតំ អភិនន្ទុន្តិ ។

ចូឡបុណ្ណមសុត្តំ ទសមំ និដ្ឋិតំ ។

ទេវទហវគ្គោ បឋមោ

តស្សុទ្ទានំ

ទេវទហបញ្ចត្តយកិន្តិ

និគណ្ឋោ អញ្ញវេយ្យាករណោ

កុរុគណកគោបកំ បុណ្ណមយោ

ទេវទហវគ្គោ បឋមោ បវេគ[1] ។

---

១ ឱ. ឥទំ ឧទ្ទានំ នត្ថិ ។ ម. តស្សុទ្ទានំ ទេវទហំ បញ្ចត្តយកិន្តិ សាមសុនក្ខត្តំ សប្បាយគណកគោបក មហាបុណ្ណចូឡបុណ្ណញ្ចាតិ បឋមោ បវរវគ្គោតិ ទិស្សតិ ។

លុះព្រះមានព្រះភាគ ទ្រង់ត្រាស់សូត្រនេះចប់ហើយ ភិក្ខុទាំងនោះ ជាអ្នកមានសេចក្តីត្រេកអរ ក៏បានត្រេកអរចំពោះភាសិត របស់ព្រះមានព្រះភាគ ។

ចប់ ចូឡបុណ្ណមសូត្រ ទី ១០ ។

ចប់ ទេវទហវគ្គ ទី ១ ។

## ឧទ្ទាននៃទេវទហវគ្គនោះ ដូច្នេះ

ទេវទហសូត្រ ១ បញ្ចត្តយសូត្រ ១ កិន្តិសូត្រ ១ រឿងនិគន្ថនាដបុត្រ ក្នុងសាមគ្គាមសូត្រ ១ ការព្យាករណ៍នូវអរហត្តផល ក្នុងសុនក្ខត្តសូត្រ ១ ដំណើរព្រះអង្គគង់ក្នុងកម្មាសធម្មនិគម ក្នុងដែនកុរុ ក្នុងអានេញ្ជសប្បាយសូត្រ ១ គណកមោគ្គល្លានសូត្រ ១ គោបកមោគ្គល្លានសូត្រ ១ រឿងព្រះអង្គគង់ក្នុងវាលក្នុងរាត្រី មានព្រះចន្ទ្រពេញវង់ ក្នុងមហាបុណ្ណមសូត្រ ១ ចូឡបុណ្ណមសូត្រ ១ ឈ្មោះថា ទេវទហវគ្គ ដ៏ប្រសើរជាវគ្គដំបូង ។

# អនុបទវគ្គោ

## បឋមំ អនុបទសុត្តំ

(១៥៣) ឯវំ មេ សុតំ ។ ឯកំ សមយំ ភគវា សាវត្ថិយំ វិហរតិ ជេតវនេ អនាថបិណ្ឌិកស្ស អារាមេ ។ តត្រ ខោ ភគវា ភិក្ខូ អាមន្តេសិ ភិក្ខវោតិ ។ ភទន្តេតិ តេ ភិក្ខូ ភគវតោ បច្ចស្សោសុំ ។

(១៥៤) ភគវា ឯតទវោច បណ្ឌិតោ ភិក្ខវេ សារីបុត្តោ មហាបញ្ញោ ភិក្ខវេ សារីបុត្តោ បុថុបញ្ញោ ភិក្ខវេ សារីបុត្តោ ហាសបញ្ញោ ភិក្ខវេ សារីបុត្តោ ជវនបញ្ញោ ភិក្ខវេ សារីបុត្តោ តិក្ខបញ្ញោ ភិក្ខវេ សារីបុត្តោ និព្វេធិកបញ្ញោ ភិក្ខវេ សារីបុត្តោ សារីបុត្តោ ភិក្ខវេ អឌ្ឍមាសំ អនុបទធម្មវិបស្សនំ វិបស្សតិ ។ តត្រិទំ ភិក្ខវេ សារីបុត្តស្ស អនុបទធម្មវិបស្សនាយ ហោតិ ។

# អនុបទវគ្គ

## អនុបទសូត្រ ទី ១

(១៩៣) ខ្ញុំបានស្តាប់មក យ៉ាងនេះ ។ សម័យមួយ ព្រះមានព្រះភាគ គង់ក្នុងវត្តជេតពន របស់អនាថបិណ្ឌិកសេដ្ឋី ជិតក្រុងសាវត្ថី ។ ក្នុងទីនោះឯង ព្រះមានព្រះភាគ ត្រាស់ហៅភិក្ខុទាំងឡាយថា ម្នាលភិក្ខុទាំងឡាយ ។ ភិក្ខុទាំងនោះ ទទួលព្រះពុទ្ធដីកា ព្រះមានព្រះភាគថា ព្រះករុណា ព្រះអង្គដ៏ចម្រើន ។

(១៩៤) ព្រះមានព្រះភាគ បានត្រាស់ដូច្នេះថា ម្នាលភិក្ខុទាំង-ឡាយ សារីបុត្រ ជាអ្នកប្រាជ្ញ ម្នាលភិក្ខុទាំងឡាយ សារីបុត្រ មានប្រាជ្ញាច្រើន ម្នាលភិក្ខុទាំងឡាយ សារីបុត្រ មានប្រាជ្ញាក្រាស់ ម្នាលភិក្ខុទាំងឡាយ សារីបុត្រ មានប្រាជ្ញារហ័ស ម្នាលភិក្ខុទាំងឡាយ សារី-បុត្រ មានប្រាជ្ញាវាងវៃ ម្នាលភិក្ខុទាំងឡាយ សារីបុត្រ មានប្រាជ្ញាមុត ម្នាលភិក្ខុទាំងឡាយ សារីបុត្រ មានប្រាជ្ញាជាគ្រឿងទម្លាយនូវកិលេស ម្នាលភិក្ខុទាំងឡាយ សារីបុត្រឃើញច្បាស់ នូវធម៌វិបស្សនាតាមលំដាប់ អស់កន្លះខែ (ក៏បានសម្រេចព្រះអរហត្ត) ។ ម្នាលភិក្ខុទាំងឡាយ ការណ៍នេះ សារីបុត្ររមែងមាន ក្នុងធម៌វិបស្សនាជាលំដាប់នោះ ។

(១៨៨) ឥធ ភិក្ខវេ សារីបុត្តោ វិវិច្ចេវ កាមេហិ វិវិច្ច អកុសលេហិ ធម្មេហិ សវិតក្កំ សវិចារំ វិវេកជំ បីតិសុខំ បឋមំ ឈានំ ឧបសម្បជ្ជ វិហរតិ ។ យេ ច បឋមេ ឈានេ(១) ធម្មា វិតក្កោ ច វិចារោ ច បីតិ ច សុខញ្ច ចិត្តេកគ្គតា ច ផស្សោ វេទនា សញ្ញា ចេតនា វិញ្ញាណំ(២) ឆន្ទោ អធិមោក្ខោ វីរិយំ សតិ ឧបេក្ខា មនសិការោ ត្យាស្ស ធម្មា អនុបទវវត្ថិតា ហោន្តិ ត្យាស្ស ធម្មា វិទិតា ឧប្បជ្ជន្តិ វិទិតា ឧបដ្ឋហន្តិ វិទិតា អព្ភត្ថំ គច្ឆន្តិ ។ សោ ឯវំ បជានាតិ ឯវំ កិរ មេ ធម្មា អហុត្វា សម្ភោន្តិ ហុត្វា បតិវេន្តីតិ(៣) ។ សោ តេសុ ធម្មេសុ អនុបាយោ(៤) អនបាយោ អនិស្សិតោ អប្បដិពទ្ធោ វិប្បមុត្តោ វិសំយុត្តោ វិមរិយាទិកតេន ចេតសា វិហរតិ ។ សោ អត្ថិ ឧត្តរឹ និស្សរណន្តិ បជានាតិ ។ តព្ពហុលីការា អត្ថិ ត្វេវស្ស ហោតិ ។

---

១ ឱ. ម. បឋមជ្ឈានេ ។ ២ ឱ. ម. បិត្តំ ។ ៣ កត្ថចិ អម្ហាកំ ហោត្វា បតិវេទេន្តីតិ ទិស្សតិ ។ ៤ អនុបាយោតិប្បត្តិ ។

(១៥៥) ម្នាលភិក្ខុទាំងឡាយ ក្នុងទីនេះ សារីបុត្តស្ងាត់ចាកកាមទាំងឡាយ ស្ងាត់ចាកអកុសលធម៌ទាំងឡាយ ហើយចូលបឋមជ្ឈាន មានវិតក្កៈវិចារៈបីតិនិងសុខៈដែលកើតអំពីវិវេក ។ ធម៌ទាំងឡាយ គឺវិតក្កៈ វិចារៈ បីតិ សុខៈ ចិត្តេកគ្គតា ផស្សៈ វេទនា សញ្ញា ចេតនា វិញ្ញាណ ឆន្ទៈ អធិមោក្ខៈ វិរិយៈ សតិ ឧបេក្ខា និងមនសិការៈ ណា ដែលមានក្នុងបឋមជ្ឈាន ធម៌ទាំងនោះ សារីបុត្តបានកំណត់តាមលំដាប់ហើយ ធម៌ទាំងនោះ ដែលសារីបុត្តដឹងច្បាស់ ក៏កើតឡើង ដឹងច្បាស់ក៏តាំងនៅ ដឹងច្បាស់ក៏ដល់នូវកិរិយារលត់ ។ សារីបុត្តនោះ ដឹងច្បាស់យ៉ាងនេះថា ធម៌ទាំងនេះមិនដែលមាន ត្រឡប់ជាមាន មានហើយត្រឡប់ជាគ្មានវិញយ៉ាងនេះ ។ សារីបុត្តនោះ មិនលុះក្នុងធម៌ទាំងនោះ (ដោយអំណាចរាគៈ) មិនលិចលង់ក្នុងធម៌ទាំងនោះ (ដោយបដិឃៈ) មិនអាស្រ័យក្នុងធម៌ទាំងនោះ (ដោយតណ្ហានិស្ស័យ និងទិដ្ឋិនិស្ស័យ) មិនជាប់ក្នុងធម៌ទាំងនោះ (ដោយឆន្ទរាគៈ) រួចស្រឡះ (ចាករាគៈ) ប្រាសចាក (យោគៈ) មានចិត្តមិនរពើតរពើង ។ សារីបុត្តនោះ ដឹងច្បាស់ថា និស្សរណធម៌ គឺការចេញចាកភព ទៅមានតទៅទៀត ។ ការធ្វើឲ្យច្រើន ៗ នូវនិស្សរណធម៌នោះ តែងមានដល់សារីបុត្តនោះ

(១៥៦) បុន ចបរំ ភិក្ខវេ សារីបុត្តោ វិតក្កវិចារានំ វូបសមា អជ្ឈត្តំ សម្បសាទនំ ចេតសោ ឯកោទិភាវំ អវិតក្កំ អវិចារំ សមាធិជំ បីតិសុខំ ទុតិយំ ឈានំ ឧបសម្បជ្ជ វិហរតិ ។ យេ ច ទុតិយេ ឈានេ ធម្មា អជ្ឈត្តំ សម្បសាទោ ច បីតិ ច សុខញ្ច ចិត្តេកគ្គតា ច ផស្សោ វេទនា សញ្ញា ចេតនា ចិត្តំ ឆន្ទោ អធិមោក្ខោ វិរិយំ សតិ ឧបេក្ខា មនសិការោ ត្យាស្ស ធម្មា អនុបទវវត្ថិតា ហោន្តិ ត្យាស្ស ធម្មា វិទិតា ឧប្បជ្ជន្តិ វិទិតា ឧបដ្ឋហន្តិ វិទិតា អព្ភត្ថំ គច្ឆន្តិ ។ សោ ឯវំ បជានាតិ ឯវំ កិរមេ ធម្មា អហុត្វា សម្ភោន្តិ ហុត្វា បដិវេន្តីតិ ។ សោ តេសុ ធម្មេសុ អនុបាយោ អនបាយោ អនិស្សិតោ អប្បដិពទ្ធោ វិប្បមុត្តោ វិសំយុត្តោ វិមរិយាទិកតេន ចេតសា វិហរតិ ។ សោ អត្ថិ ឧត្តរឹ និស្សរណន្តិ បជានាតិ ។ តព្ពហុលីការា អត្ថិត្វេវស្ស ហោតិ ។

(១៩៦) ម្នាលភិក្ខុទាំងឡាយ មួយទៀត សារីបុត្រព្រោះរម្ងាប់នូវវិតក្កៈនិងវិចារៈអស់ហើយ បានដល់ទុតិយជ្ឈាន ជាធម្មជាតកើតក្នុងសន្តាននៃខ្លួន ប្រកបដោយសេចក្តីជ្រះថ្លា គឺសទ្ធា មានសភាពជាចិត្តខ្ពស់ឯក មិនមានវិតក្កៈ មិនមានវិចារៈទេ មានតែបីតិនិងសុខៈដែលកើតអំពីសមាធិ គឺបឋមជ្ឈានប៉ុណ្ណោះ ក៏សម្រាន្តនៅដោយឥរិយាបថទាំង ៤ ។ ធម៌ទាំងឡាយគឺសេចក្តីជ្រះថ្លាក្នុងសន្តាន បីតិ សុខៈ ចិត្តេកគ្គតា ផស្សៈ វេទនា សញ្ញា ចេតនា វិញ្ញាណ ឆន្ទៈ អធិមោក្ខៈ វីរិយៈ សតិ ឧបេក្ខា និងមនសិការៈណា ដែលមានក្នុងទុតិយជ្ឈាន ធម៌ទាំងនោះ សារីបុត្របានកំណត់តាមលំដាប់ហើយ ធម៌ទាំងនោះ ដែលសារីបុត្រដឹងច្បាស់ ក៏កើតឡើង ដឹងច្បាស់ក៏តាំងនៅ ដឹងច្បាស់ក៏ដល់នូវកិរិយារលត់ ។ សារីបុត្រនោះ ដឹងច្បាស់យ៉ាងនេះថា ធម៌ទាំងនេះ មិនដែលមាន ត្រឡប់ជាមាន មានហើយ ត្រឡប់ជាគ្មានវិញ ។ សារីបុត្រនោះ មិនលុះ មិនលិចលង់ មិនអាស្រ័យ មិនជាប់នៅ ក្នុងធម៌ទាំងនោះ ជាអ្នករួចស្រឡះ (ចាកកាមរាគៈ) ប្រាសចាក (យោគៈ) មានចិត្តមិនរពើតរពើង ។ សារីបុត្រនោះ ដឹងច្បាស់ថា និស្សរណធម៌ គឺការរលាស់ខ្លួនចេញចាកភព នៅមានតទៅទៀត ។ ការធ្វើឲ្យរឿយ ៗ នូវនិស្សរណធម៌នោះ រមែងមានដល់សារីបុត្រនោះ ។

(៣៥៧) បុន ចបរំ ភិក្ខវេ សារីបុត្តោ បីតិយា ច វិរាគា ឧបេក្ខកោ ច វិហរតិ សតោ ច សម្បជានោ សុខញ្ច កាយេន បដិសំវេទេតិ យន្តំ អរិយា អាចិក្ខន្តិ ឧបេក្ខកោ សតិមា សុខវិហារីតិ តតិយំ ឈានំ ឧបសម្បជ្ជ វិហរតិ ។ យេ ច តតិយេ ឈានេ ធម្មា ឧបេក្ខា ច សុខញ្ច សតិ ច សម្បជញ្ញញ្ច ចិត្តេកគ្គតា ច ផស្សោ វេទនា សញ្ញា ចេតនា វិញ្ញាណំ ឆន្ទោ អធិមោក្ខោ វីរិយំ សតិ ឧបេក្ខា មនសិការោ ត្យាស្ស ធម្មា អនុប-ទវវត្ថិតា ហោន្តិ ត្យាស្ស ធម្មា វិទិតា ឧប្បជ្ជន្តិ វិទិតា ឧបដ្ឋហន្តិ វិទិតា អព្ភត្ថំ គច្ឆន្តិ ។ សោ ឯវំ បជានាតិ ឯវំ កិរមេ ធម្មា អហុត្វា សម្ភោន្តិ ហុត្វា បដិវេន្តីតិ ។ សោ តេសុ ធម្មេសុ អនុបាយោ អនបាយោ អនិស្សិតោ អប្បដិពទ្ធោ វិប្បមុត្តោ វិសំយុត្តោ វិមរិយាទិកតេន ចេតសា វិហរតិ ។ សោ អត្ថិ ឧត្តរិ និស្សរណន្តិ បជានាតិ ។ តព្ពហុលីការា អត្ថិ ត្វេវស្ស ហោតិ ។

(១៩៧) ម្នាលភិក្ខុទាំងឡាយ មួយទៀត សារីបុត្រ ព្រោះនឿយណាយចាកបីតិផង ជាអ្នកប្រកបដោយឧបេក្ខាផង មានស្មារតីផង មានសម្បជញ្ញៈផង ទទួលនូវសុខដោយនាមកាយផង ព្រះអរិយៈទាំងឡាយ តែងសរសើរនូវបុគ្គលដែលបាននូវតតិយជ្ឈាននោះថា ប្រកបដោយឧបេក្ខា មានស្មារតី មានធម៌ជាគ្រឿងនៅជាសុខដូច្នេះ ។ ធម៌ទាំងឡាយ គឺឧបេក្ខា សុខៈ សតិ សម្បជញ្ញៈ ចិត្តេកគ្គតា ផស្សៈ វេទនា សញ្ញា ចេតនា វិញ្ញាណ ឆន្ទៈ អធិមោក្ខៈ វីរិយៈ សតិ ឧបេក្ខា និងមនសិការៈណា ដែលមានក្នុងតតិយជ្ឈាន ធម៌ទាំងនោះ សារីបុត្រ បានកំណត់តាមលំដាប់ហើយ ធម៌ទាំងនោះ ដែលសារីបុត្រដឹងច្បាស់ ក៏កើតឡើង ដឹងច្បាស់ក៏តាំងឡើង ដឹងច្បាស់ក៏ដល់នូវកិរិយារលត់ ។ សារីបុត្រនោះ ដឹងច្បាស់យ៉ាងនេះថា ធម៌ទាំងនេះ មិនដែលមាន ត្រឡប់ជាមាន មានហើយ ត្រឡប់ជាគ្មានវិញ ។ សារីបុត្រនោះ មិនលុះ មិនលិចលង់ មិនអាស្រ័យនៅ មិនជាប់នៅ ក្នុងធម៌ទាំងនោះ ជាអ្នករួចស្រឡះ (ចាកកាមរាគៈ) ប្រាសចាក (យោគៈ) មានចិត្តមិនរពើតរពើន ។ សារីបុត្រនោះ ដឹងច្បាស់ថា និស្សរណធម៌ គឺការរលាស់ខ្លួនចេញចាកភព នៅមានតទៅទៀត ។ ការធ្វើឲ្យច្រើនៗនូវនិស្សរណធម៌នោះ តែងមានដល់សារីបុត្រនោះ ។

(១៥៨) បុន ចបរំ ភិក្ខវេ សារីបុត្តោ សុខស្ស ច បហានា ទុក្ខស្ស ច បហានា បុព្វេវ សោមនស្សទោមនស្សានំ អត្ថង្គមា អទុក្ខមសុខំ ឧបេក្ខាសតិបារិសុទ្ធឹ ចតុត្ថំ ឈានំ ឧបសម្បជ្ជ វិហរតិ ។ យេ ច ចតុត្ថេ ឈានេ ធម្មា ឧបេក្ខា អទុក្ខមសុខា វេទនា បស្សទ្ធត្តា ចេតសោ អនាភោគោ សតិបារិសុទ្ធិ ចិត្តេកគ្គតា ច ផស្សោ វេទនា សញ្ញា ចេតនា វិញ្ញាណំ ឆន្ទោ អធិមោក្ខោ វិរិយំ សតិ ឧបេក្ខា មនសិការោ ត្យាស្ស ធម្មា អនុបទវវត្ថិតា ហោន្តិ ត្យាស្ស ធម្មា វិទិតា ឧប្បជ្ជន្តិ វិទិតា ឧបដ្ឋហន្តិ វិទិតា អព្ភត្ថំ គច្ឆន្តិ ។ សោ ឯវំ បជានាតិ ឯវំ កិរមេ ធម្មា អហុត្វា សម្ភោន្តិ ហុត្វា បដិវេន្តីតិ ។ សោ តេសុ ធម្មេសុ អនុបាយោ អនបាយោ អនិស្សិតោ អប្បដិពទ្ធោ វិប្បមុត្តោ វិសំយុត្តោ វិមរិយាទិកតេន ចេតសា វិហរតិ ។ សោ អត្ថិ ឧត្តរឹ និស្សរណន្តិ បជានាតិ ។ តព្ពហុលីការា អត្ថិ ត្វេវស្ស ហោតិ ។

(១៤៨) ម្នាលភិក្ខុទាំងឡាយ មួយទៀត សារីបុត្រព្រោះលះបង់នូវសុខផង លះបង់នូវទុក្ខផង ដល់នូវសេចក្ដីវិនាសនៃសោមនស្ស និងទោមនស្ស ក្នុងកាលមុនផង ចូលកាន់ចតុត្ថជ្ឈាន មិនមានទុក្ខ មិនមានសុខ មានតែសតិដ៏បរិសុទ្ធ ដោយឧបេក្ខា ។ ធម៌ទាំងឡាយ គឺឧបេក្ខា អទុក្ខមសុខវេទនា សេចក្ដីបរិសុទ្ធិ ការមិនចងចិត្ត សតិបរិសុទ្ធិ ចិត្តេកគ្គតា ផស្សៈ វេទនា សញ្ញា ចេតនា វិញ្ញាណ ឆន្ទៈ អធិមោក្ខៈ វីរិយៈ សតិ ឧបេក្ខា និងមនសិការៈ ណា ដែលមានក្នុងចតុត្ថជ្ឈាន ធម៌ទាំងនោះ ដែលសារីបុត្រនោះ បានកំណត់តាមលំដាប់ហើយ ធម៌ទាំងនោះ ដែលសារីបុត្រនោះ ដឹងច្បាស់ក៏កើតឡើង ដឹងច្បាស់ក៏តាំងនៅ ដឹងច្បាស់ក៏ដល់ នូវកិរិយារលត់ ។ សារីបុត្រនោះ ដឹងច្បាស់យ៉ាងនេះថា ធម៌ទាំងនេះ មិនដែលមាន ត្រឡប់ទៅជាមាន មានហើយ ត្រឡប់ទៅជាគ្មានវិញយ៉ាងនេះ ។ សារីបុត្រនោះ មិនលុះ មិនលិចលង់ មិនអាស្រ័យនៅ មិនជាប់នៅក្នុងធម៌ទាំងនោះ ជាអ្នករួចស្រឡះ (ចាកកាមរាគៈ) ប្រាសចាក(យោគៈ) មានចិត្តមិនរវើតរវើង ។ សារីបុត្រនោះ ដឹងច្បាស់ថា និស្សរណធម៌ គឺការរលាស់ខ្លួនចេញចាកភព នៅមានតទៅទៀត ។ ការធ្វើឲ្យរឿយៗ នូវនិស្សរណធម៌នោះ តែងមានដល់សារីបុត្រនោះ ។

(១៨៩) បុន ចបរំ ភិក្ខវេ សារីបុត្តោ សព្វសោ រូបសញ្ញានំ សមតិក្កមា បដិឃសញ្ញានំ អត្ថង្គមា នានត្តសញ្ញានំ អមនសិការា អនន្តោ អាកាសោតិ អាកាសានញ្ចាយតនំ ឧបសម្បជ្ជ វិហរតិ ។ យេ ច អាកាសានញ្ចាយតនេ ធម្មា អាកាសានញ្ចាយតនសញ្ញា ច ចិត្តេកគ្គតា ច ផស្សោ វេទនា សញ្ញា ចេតនា វិញ្ញាណំ ឆន្ទោ អធិមោក្ខោ វីរិយំ សតិ ឧបេក្ខា មនសិការោ ត្យាស្ស ធម្មា អនុបទវវត្ថិតា ហោន្តិ ត្យាស្ស ធម្មា វិទិតា ឧប្បជ្ជន្តិ វិទិតា ឧបដ្ឋហន្តិ វិទិតា អព្ភត្ថំ គច្ឆន្តិ ។ សោ ឯវំ បជានាតិ ឯវំ កិរមេ ធម្មា អហុត្វា សម្ភោន្តិ ហុត្វា បដិវេន្តីតិ ។ សោ តេសុ ធម្មេសុ អនុបាយោ អនបាយោ អនិស្សិតោ អប្បដិពទ្ធោ វិប្បមុត្តោ វិសំយុត្តោ វិមរិយាទិកតេន ចេតសា វិហរតិ ។ សោ អត្ថិ ឧត្តរឹ និស្សរណន្តិ បជានាតិ ។ តព្ពហុលីការា អត្ថិ ត្វេវស្ស ហោតិ ។

[១៥៩] ម្នាលភិក្ខុទាំងឡាយ មួយទៀត សារីបុត្រ កន្លងបង់នូវរូបសញ្ញាទាំងឡាយ ដោយសព្វគ្រប់ ដល់នូវសេចក្តីវិនាសនៃបដិឃសញ្ញា មិនធ្វើទុកក្នុងចិត្តនូវនានត្តសញ្ញា ហើយចូលកាន់អាកាសានញ្ចាយតនជ្ឈាន ដោយបរិកម្មថា អាកាសមិនមានទីបំផុតដូច្នេះ ។ ធម៌ទាំងឡាយ គឺអាកាសានញ្ចាយតនសញ្ញា ចិត្តេកគ្គតា ផស្សៈ វេទនា សញ្ញា ចេតនា វិញ្ញាណ ឆន្ទៈ អធិមោក្ខៈ វីរិយៈ សតិ ឧបេក្ខា និងមនសិការៈណា ដែលមានក្នុងអាកាសានញ្ចាយតនជ្ឈាន ធម៌ទាំងនោះ ដែលសារីបុត្រនោះ បានកំណត់តាមលំដាប់ហើយ ធម៌ទាំងនោះ ដែលសារីបុត្រនោះ ដឹងច្បាស់ហើយ ក៏កើតឡើង ដឹងច្បាស់ហើយក៏តាំងនៅ ដឹងច្បាស់ហើយក៏ដល់នូវការរលត់ទៅ ។ សារីបុត្រនោះ ដឹងច្បាស់យ៉ាងនេះថា ធម៌ទាំងនេះ មិនដែលមាន ត្រឡប់ទៅជាមាន ធ្លាប់មាន ត្រឡប់ទៅជាគ្មានវិញ យ៉ាងនេះ ។ សារីបុត្រនោះ មិនលុះ មិនលិចលង់ មិនអាស្រ័យនៅ មិនជាប់នៅក្នុងធម៌ទាំងនោះ ជាអ្នករួចស្រឡះ(ចាកកាមរាគៈ) ប្រាសចាក(យោគៈ) មានចិត្តមិនរេពើតរេពើន ។ សារីបុត្រនោះ ដឹងច្បាស់ថា និស្សរណធម៌ គឺការរលាស់ខ្លួនចេញចាកភព នៅមានតទៅទៀត ។ ការធ្វើឲ្យច្រើនៗ នូវនិស្សរណធម៌នោះ តែងមានដល់សារីបុត្រនោះ ។

(១៤០) បុន ចបរំ ភិក្ខវេ សារិបុត្តោ សព្វសោ អាកាសានញ្ចាយតនំ សមតិក្កម្ម អនន្តំ វិញ្ញាណន្តិ វិញ្ញាណញ្ចាយតនំ ឧបសម្បជ្ជ វិហរតិ ។ យេ ច វិញ្ញាណញ្ចាយតនេ ធម្មា វិញ្ញាណញ្ចាយតនសញ្ញា ច ចិត្តេកគ្គតា ច ផស្សោ វេទនា សញ្ញា ចេតនា វិញ្ញាណំ ឆន្ទោ អធិមោក្ខោ វីរិយំ សតិ ឧបេក្ខា មនសិការោ ត្យាស្ស ធម្មា អនុបទវវត្ថិតា ហោន្តិ ត្យាស្ស ធម្មា វិទិតា ឧប្បជ្ជន្តិ វិទិតា ឧបដ្ឋហន្តិ វិទិតា អព្ភត្ថំ គច្ឆន្តិ ។ សោ ឯវំ បជានាតិ ឯវំ កិរមេ ធម្មា អហុត្វា សម្ភោន្តិ ហុត្វា បតិវេន្តីតិ ។ សោ តេសុ ធម្មេសុ អនុបាយោ អនបាយោ អនិស្សិតោ អប្បដិពទ្ធោ វិប្បមុត្តោ វិសំយុត្តោ វិមរិយាទិកតេន ចេតសា វិហរតិ ។ សោ អត្ថិ ឧត្តរឹ និស្សរណន្តិ បជានាតិ ។ តព្វហុលីការា អត្ថិត្វេវស្ស ហោតិ ។

(១៦០) ម្នាលភិក្ខុទាំងឡាយ មួយទៀត សារីបុត្រ កន្លងផុតនូវអាកាសានញ្ចាយតនជ្ឈាន ដោយប្រការទាំងពួង ហើយចូលកាន់វិញ្ញាណញ្ចាយតនជ្ឈាន ដោយបរិកម្មថា វិញ្ញាណមិនមានទីបំផុត ៗ ធម៌ទាំងឡាយ គឺវិញ្ញាណញ្ចាយតនសញ្ញា ចិត្តេកគ្គតា ផស្សៈ វេទនា សញ្ញា ចេតនា វិញ្ញាណ ឆន្ទៈ អធិមោក្ខៈ វីរិយៈ សតិ ឧបេក្ខា និងមនសិការៈ ណា ដែលមានក្នុងវិញ្ញាណញ្ចាយតនជ្ឈាន ដែលសារីបុត្រនោះ បានកំណត់តាមលំដាប់ហើយ ធម៌ទាំងនោះ ដែលសារីបុត្រនោះ ដឹងច្បាស់ហើយក៏កើតឡើង ដឹងច្បាស់ហើយក៏តាំងនៅ ដឹងច្បាស់ហើយ ក៏ដល់នូវកិរិយារលត់ទៅ ៗ សារីបុត្រនោះ ដឹងច្បាស់យ៉ាងនេះថា ធម៌ទាំងនេះ មិនដែលមាន ត្រឡប់ទៅជាមាន ដែលធ្លាប់មានហើយ ត្រឡប់ទៅជាគ្មានវិញ ៗ សារីបុត្រនោះ មិនលុះ មិនលិចលង់ មិនអាស្រ័យនៅ មិនជាប់ចំពាក់នៅ ក្នុងធម៌ទាំងនោះ ជាអ្នករួចស្រឡះចាកកាមរាគៈ ប្រាសចាកយោគៈ មានចិត្តមិនរើតរើង ៗ សារីបុត្រនោះ ដឹងច្បាស់ថា និស្សរណធម៌ គឺការរលាស់ខ្លួនចេញចាកភព នៅមានតទៅទៀត ៗ ការធ្វើឲ្យរឿយ ៗ នូវនិស្សរណធម៌នោះ រមែងមានដល់សារីបុត្រនោះ ៗ

(១៤១) បុន ចបរំ ភិក្ខវេ សារីបុត្តោ សព្វសោ វិញ្ញាណញ្ចាយតនំ សមតិក្កម្ម នត្ថិ កិញ្ចីតិ អាកិញ្ចញ្ញាយតនំ ឧបសម្បជ្ជ វិហរតិ ។ យេ ច អាកិញ្ចញ្ញាយតនេ ធម្មា អាកិញ្ចញ្ញាយតនសញ្ញា ច ចិត្តេកគ្គតា ច ផស្សោ វេទនា សញ្ញា ចេតនា វិញ្ញាណំ ឆន្ទោ អធិមោក្ខោ វីរិយំ សតិ ឧបេក្ខា មនសិការោ ត្យាស្ស ធម្មា អនុបទវវត្ថិតា ហោន្តិ ត្យាស្ស ធម្មា វិទិតា ឧប្បជ្ជន្តិ វិទិតា ឧបដ្ឋហន្តិ វិទិតា អព្ភត្ថំ គច្ឆន្តិ ។ សោ ឯវំ បជានាតិ ឯវំ កិរមេ ធម្មា អហុត្វា សម្ភោន្តិ ហុត្វា បដិវេន្តីតិ ។ សោ តេសុ ធម្មេសុ អនុបាយោ អនបាយោ អនិស្សិតោ អប្បដិពទ្ធោ វិប្បមុត្តោ វិសំយុត្តោ វិមរិយាទិកតេន ចេតសា វិហរតិ ។ សោ អត្ថិ ឧត្តរឹ និស្សរណន្តិ បជានាតិ ។ តព្ពហុលីការា អត្ថិត្វេវស្ស ហោតិ ។

(១៦១) ម្នាលភិក្ខុទាំងឡាយ មួយទៀត សារីបុត្រ កន្លងផុតនូវវិញ្ញាណញ្ចាយតនជ្ឈាន ដោយសព្វគ្រប់ ហើយចូលកាន់អាកិញ្ចញ្ញាយតនជ្ឈាន ដោយបរិកម្មថា វត្ថុតិចតួចមិនមានផងឡើយ ។ ធម៌ទាំងឡាយ គឺអាកិញ្ចញ្ញាយតនសញ្ញា ចិត្តេកគ្គតា ផស្សៈ វេទនា សញ្ញា ចេតនា វិញ្ញាណ ឆន្ទៈ អធិមោក្ខៈ វីរិយៈ សតិ ឧបេក្ខា និងមនសិការៈណា ដែលមានក្នុងអាកិញ្ចញ្ញាយតនជ្ឈាន ធម៌ទាំងនោះ គឺសារីបុត្រនោះ បានកំណត់តាមលំដាប់ហើយ ធម៌ទាំងនោះ ដែលសារីបុត្រនោះ ដឹងច្បាស់ហើយក៏កើតឡើង ដឹងច្បាស់ហើយក៏តាំងនៅ ដឹងច្បាស់ហើយក៏ដល់នូវកិរិយារលត់ ។ សារីបុត្រនោះ ដឹងច្បាស់យ៉ាងនេះថា ធម៌ទាំងនោះ មិនដែលមាន ត្រឡប់ទៅជាមាន ធ្លាប់មានហើយ ត្រឡប់ទៅជាគ្មានវិញ ។ សារីបុត្រនោះ មិនលុះ មិនលិចលង់ មិនអាស្រ័យនៅ មិនជាប់នៅក្នុងធម៌ទាំងនោះ ជាអ្នករួចស្រឡះចាកកាមរាគៈ ប្រាសចាកយោគៈ មានចិត្តមិនវើតវើង ។ សារីបុត្រនោះដឹងច្បាស់ថា និស្សរណធម៌ គឺការរលាស់ខ្លួនចេញចាកកព នៅមានតទៅទៀត ។ ការធ្វើឲ្យច្រើនៗ នូវនិស្សរណធម៌នោះ រមែងមានដល់សារីបុត្រនោះ ។

[១៦២] បុន ចបរំ ភិក្ខវេ សារិបុត្តោ សព្វសោ អាកិញ្ចញ្ញាយតនំ សមតិក្កម្ម នេវសញ្ញានាសញ្ញាយតនំ ឧបសម្បជ្ជ វិហរតិ ។ សោ តាយ សមាបត្តិយា សតោ វុដ្ឋាតិ (១) ។ សោ តាយ សមាបត្តិយា សតោ វុដ្ឋហិត្វា យេ ធម្មា អតីតា និរុទ្ធា វិបរិណតា តេ ធម្មេ សមនុបស្សតិ ឯវំ កិរមេ ធម្មា អហុត្វា សម្ភោន្តិ ហុត្វា បដិវេន្តីតិ ។ សោ តេសុ ធម្មេសុ អនុបាយោ អនបាយោ អនិស្សិតោ អប្បដិពទ្ធោ វិប្បមុត្តោ វិសំយុត្តោ វិមរិយាទិកតេន ចេតសា វិហរតិ ។ សោ នត្ថិ ឧត្តរឹ និស្សរណន្តិ បជានាតិ ។ តព្ពហុលីការា អត្ថិ ត្វេវស្ស ហោតិ ។

---

១ ឧ. វុដ្ឋហតិ ។

(១៦២) ម្នាលភិក្ខុទាំងឡាយ មួយទៀត សារីបុត្តកន្លងនូវអាកិញ្ចញ្ញាយតនជ្ឈាន ដោយសព្វគ្រប់ ហើយចូលកាន់នេវសញ្ញានាសញ្ញាយតនជ្ឈាន ។ សារីបុត្តនោះ ជាអ្នកមានស្មារតីចេញចាកសមាបត្តិនោះ ។ លុះសារីបុត្តនោះ មានស្មារតីចេញចាកសមាបត្តិនោះហើយ ក៏ពិចារណាឃើញ នូវពួកធម៌ ដែលកន្លងទៅ រលត់ទៅ ប្រែប្រួលទៅហើយថា ពួកធម៌ទាំងនោះ មិនដែលមាន ត្រឡប់ទៅជាមាន ដែលធ្លាប់មានហើយ ត្រឡប់ទៅជាគ្មានវិញ យ៉ាងនេះ ។ សារីបុត្តនោះ មិនលុះ មិនលិចលង់ មិនអាស្រ័យទៅ មិនជាប់នៅក្នុងធម៌ទាំងនោះឡើយ ជាអ្នករួចស្រឡះចាកកាមរាគៈ ប្រាសចាកយោគៈ មានចិត្តមិនរារែករារាំង ។ សារីបុត្តនោះ ដឹងច្បាស់ថា និស្សរណធម៌ គឺការរលាស់ខ្លួនចេញចាកភព នៅមានតទៅទៀត ។ ការធ្វើឲ្យច្រើនៗ នូវនិស្សរណធម៌នោះ រមែងមានដល់សារីបុត្តនោះ ។

(១៦៣) បុន ចបរំ ភិក្ខវេ សារីបុត្តោ សព្វសោ នេវសញ្ញានាសញ្ញាយតនំ សមតិក្កម្ម សញ្ញាវេទយិតនិរោធំ ឧបសម្បជ្ជ វិហរតិ ។ បញ្ញាយ បស្ស(១) ទិស្វា អាសវា បរិក្ខីណា ហោន្តិ ។ សោ តាយ សមាបត្តិយា សតោ វុដ្ឋាតិ ។ សោ តាយ សមាបត្តិយា សតោ វុដ្ឋហិត្វា យេ ធម្មា អតីតា និរុទ្ធា វិបរិណតា តេ ធម្មេ សមនុបស្សតិ ឯវំ កិរមេ ធម្មា អហុត្វា សម្ភោន្តិ ហុត្វា បដិវេន្តីតិ ។ សោ តេសុ ធម្មេសុ អនុបាយោ អនបាយោ អនិស្សិតោ អប្បដិពទ្ធោ វិប្បមុត្តោ វិសំយុត្តោ វិមរិយាទិកតេន ចេតសា វិហរតិ ។ សោ អត្ថិ ឧត្តរឹ និស្សរណន្តិ បជានាតិ ។ តព្ពហុលីការា អត្ថិ ត្វេវស្ស ហោតិ ។

(១៦៤) យំ ខោ តំ ភិក្ខវេ សម្មា វទមានោ វទេយ្យ វសិប្បត្តោ បារមិប្បត្តោ អរិយស្មឹ សីលស្មឹ វសិប្បត្តោ បារមិប្បត្តោ អរិយស្មឹ សមាធិស្មឹ

១ ឱ. បញ្ញាយ ចស្ស ។

(១៦៣) ម្នាលភិក្ខុទាំងឡាយ មួយទៀត សារីបុត្តកន្លងផុតនូវនេវសញ្ញានាសញ្ញាយតនជ្ឈាន ដោយសព្វគ្រប់ ហើយចូលកាន់សញ្ញាវេទយិតនិរោធ ។ អាសវធម៌អស់ទៅបាន ព្រោះសារីបុត្តនោះ ឃើញច្បាស់ដោយប្រាជ្ញា ។ សារីបុត្តនោះ មានស្មារតី ចេញចាកសមាបត្តិនោះ ។ លុះសារីបុត្តនោះ មានស្មារតី ចេញចាកសមាបត្តិនោះហើយ ក៏ពិចារណាឃើញនូវពួកធម៌ ដែលកន្លងទៅ រលត់ទៅ ប្រែប្រួលទៅហើយថា ពួកធម៌ទាំងនេះ មិនដែលមាន ត្រឡប់ទៅជាមានហើយ ត្រឡប់ទៅជាគ្មានវិញ យ៉ាងនេះ ។ សារីបុត្តនោះ មិនលុះ មិនលិចលង់ មិនអាស្រ័យនៅ មិនជាប់នៅក្នុងធម៌ទាំងនោះឡើយ ជាអ្នករួចស្រឡះចាកកាមរាគៈ ប្រាសចាកយោគៈ មិនមានចិត្តរតើករតើង ។ សារីបុត្តនោះ ដឹងច្បាស់ថា និស្សរណធម៌នៅមានតទៅទៀត ។ ការធ្វើឲ្យច្រើនៗ នូវនិស្សរណធម៌នោះ រមែងមានដល់សារីបុត្តនោះ ។

(១៦៤) ម្នាលភិក្ខុទាំងឡាយ មហាជន តែងនិយាយសរសើរភិក្ខុណាថា ភិក្ខុនេះដល់នូវការស្ទាត់ ដល់នូវកិរិយាសម្រេចក្នុងសីលដ៏ប្រសើរ ដល់នូវការស្ទាត់ ដល់នូវកិរិយាសម្រេចក្នុងសមាធិដ៏ប្រសើរ

វសិប្បត្តោ បារមិប្បត្តោ អរិយាយ បញ្ញាយ វសិប្បត្តោ បារមិប្បត្តោ អរិយាយ វិមុត្តិយាតិ សារិបុត្តមេវ តំ សម្មា វទមានោ វទេយ្យ វសិប្បត្តោ បារមិប្បត្តោ អរិយស្មឹ សីលស្មឹ វសិប្បត្តោ បារមិប្បត្តោ អរិយស្មឹ សមាធិស្មឹ វសិប្បត្តោ បារមិប្បត្តោ អរិយាយ បញ្ញាយ វសិប្បត្តោ បារមិប្បត្តោ អរិយាយ វិមុត្តិយាតិ ។

(១៦៨) យំ ខោ តំ ភិក្ខវេ សម្មា វទមានោ វទេយ្យ ភគវតោ បុត្តោ ឱរសោ មុខតោ ជាតោ ធម្មជោ ធម្មនិម្មិតោ ធម្មទាយាទោ នោ អាមិសទាយាទោតិ សារិបុត្តមេវ តំ សម្មា វទមានោ វទេយ្យ ភគវតោ បុត្តោ

ដល់នូវការស្ងាត់ ដល់នូវកិរិយាសម្រេចក្នុងបញ្ញាដ៏ប្រសើរ ដល់នូវការស្ងាត់ ដល់នូវកិរិយាសម្រេច ក្នុងវិមុត្តិដ៏ប្រសើរ ដែលមហាជនតែងនិយាយសរសើរ នូវភិក្ខុនោះ គឺសារីបុត្រហ្នឹងឯងថា ( សារីបុត្រនេះ ) ដល់នូវការស្ងាត់ ដល់នូវកិរិយាសម្រេចក្នុងសីលដ៏ប្រសើរ ដល់នូវការស្ងាត់ ដល់នូវកិរិយាសម្រេចក្នុងសមាធិដ៏ប្រសើរ ដល់នូវការស្ងាត់ ដល់នូវកិរិយាសម្រេចក្នុងបញ្ញាដ៏ប្រសើរ ដល់នូវការស្ងាត់ ដល់នូវកិរិយាសម្រេចក្នុងវិមុត្តិដ៏ប្រសើរ ។

[១៦៨] ម្នាលភិក្ខុទាំងឡាយ មហាជន តែងនិយាយសរសើរភិក្ខុណាថា (ភិក្ខុនេះ) ជាបុត្រ ជាឱរសរបស់ព្រះមានព្រះភាគ កើតពីព្រះឱស្ឋរបស់ព្រះមានព្រះភាគ កើតអំពីធម៌ ធម៌និម្មិតឲ្យមក មានធម៌ជាមត៌ក មិនមែនមានអាមិសៈជាមត៌កឡើយ ដែលមហាជនតែងនិយាយសរសើរ នូវភិក្ខុនោះ គឺសារីបុត្រហ្នឹងឯងថា (សារីបុត្រនេះ) ជាបុត្រ

ឱរសោ មុខតោ ជាតោ ធម្មជោ ធម្មនិម្មិតោ ធម្មទាយាទោ នោ អាមិសទាយាទោតិ ។ សារីបុត្តោ ភិក្ខវេ តថាគតេន អនុត្តរំ ធម្មចក្កំ បវត្តិតំ សម្មទេវ អនុប្បវត្តេតីតិ ។ ឥទមវោច ភគវា អត្តមនា តេ ភិក្ខូ ភគវតោ ភាសិតំ អភិនន្ទុំ ។

អនុបទសុត្តំ បឋមំ និដ្ឋិតំ ។

ជាឱរសរបស់ព្រះមានព្រះភាគ កើតពីព្រះឱស្ឋរបស់ព្រះមានព្រះភាគ កើតពីធម៌ ធម៌និម្មិតឲ្យមក មានធម៌ជាមត៌ក មិនមែនមានអាមិសៈជាមត៌កទេឡើយ ។ ម្នាលភិក្ខុទាំងឡាយ សារីបុត្របានញ៉ាំងធម្មចក្រដ៏ប្រសើរ ដែលតថាគតឲ្យប្រព្រឹត្តទៅហើយ ឲ្យប្រព្រឹត្តទៅតាមដោយប្រពៃបាន ។ ព្រះមានព្រះភាគ បានត្រាស់ភាសិតនេះចប់ហើយ ភិក្ខុទាំងនោះ ក៏មានចិត្តត្រេកអរ រីករាយហើយចំពោះភាសិត របស់ព្រះមានព្រះភាគ ។

ចប់ អនុបទសូត្រ ទី ១

# ទុតិយំ ឆវិសោធនសុត្តំ[១]

(១៦៦) ឯវំ មេ សុតំ ។ ឯកំ សមយំ ភគវា សា-
វត្ថិយំ វិហរតិ ជេតវនេ អនាថបិណ្ឌិកស្ស អារាមេ ។
តត្រ ខោ ភគវា ភិក្ខូ អាមន្តេសិ ភិក្ខវោតិ ។
ភទន្តេតិ តេ ភិក្ខូ ភគវតោ បច្ចស្សោសុំ ។

(១៦៧) ភគវា ឯតទវោច ឥធ ភិក្ខវេ ភិក្ខុ
អញ្ញំ ព្យាករោតិ ខីណា ជាតិ វុសិតំ ព្រហ្មចរិយំ
កតំ ករណីយំ នាបរំ ឥត្ថត្តាយាតិ បជានាមីតិ ។
តស្ស ភិក្ខវេ ភិក្ខុនោ ភាសិតំ នេវ អភិនន្ទិតព្វំ
នប្បដិក្កោសិតព្វំ ។ អនភិនន្ទិត្វា អប្បដិក្កោសិត្វា
បញ្ហោ បុច្ឆិតព្វោ ចត្តារោមេ អាវុសោ វោហារា

---

១ ឱ. ឆព្វិសោធនសុត្តំ ឥទ្ធកបាយម្ពី ឯវមេវ ។

# ឆវិសោធនសូត្រ ទី ២

(១៦៦) ខ្ញុំបានស្តាប់មក យ៉ាងនេះ ។ សម័យមួយ ព្រះមានព្រះភាគ គង់នៅក្នុងវត្តជេតពន របស់អនាថបិណ្ឌិកសេដ្ឋី ជិតក្រុងសាវត្ថី ។ ក្នុងទីនោះឯង ព្រះមានព្រះភាគ ទ្រង់ត្រាស់ហៅពួកភិក្ខុមកថា ម្នាលភិក្ខុទាំងឡាយ ។ ភិក្ខុទាំងនោះ បានទទួលព្រះពុទ្ធដីការបស់ព្រះមានព្រះភាគថា បពិត្រព្រះអង្គដ៏ចំរើន ។

(១៦៧) ព្រះមានព្រះភាគ ទ្រង់ត្រាស់ដូច្នេះថា ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ និយាយអួតអរហត្តផលចំពោះភិក្ខុទាំងឡាយថា ខ្ញុំដឹងច្បាស់ថា ជាតិអស់ហើយ ព្រហ្មចរិយៈ ខ្ញុំបានប្រព្រឹត្តហើយ សោឡសកិច្ចខ្ញុំបានធ្វើរួចហើយ មិនមានកិច្ចដទៃក្រៅពីនេះទៀតទេ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុមិនត្រូវត្រេកអរ មិនត្រូវហាមឃាត់ភាសិតរបស់ភិក្ខុនោះទេ ។ បើភិក្ខុមិនត្រេកអរ មិនហាមឃាត់ហើយ ត្រូវសួរប្រស្នាទៅវិញថា ម្នាលអាវុសោ វោហារ ៤ យ៉ាងនេះ

តេន ភគវតា ជានតា បស្សតា អរហតា សម្មាសម្ពុទ្ធេន សម្មទក្ខាតា កតមេ ចត្តារោ ទិដ្ឋេ ទិដ្ឋវាទិតា សុតេ សុតវាទិតា មុតេ មុតវាទិតា វិញ្ញាតេ វិញ្ញាតវាទិតា ឥមេ ខោ អាវុសោ ចត្តារោ វោហារា តេន ភគវតា ជានតា បស្សតា អរហតា សម្មាសម្ពុទ្ធេន សម្មទក្ខាតា ។ កថំ ជានតោ បនាយស្មតោ កថំ បស្សតោ ឥមេសុ ចតូសុ វោហារេសុ អនុបាទាយ អាសវេហិ ចិត្តំ វិមុត្តន្តិ ។

(១៦៨) ខីណាសវស្ស ភិក្ខវេ ភិក្ខុនោ វុសិតវតោ កតករណីយស្ស ឱហិតភារស្ស អនុប្បត្តសទត្ថស្ស បរិក្ខីណភវសញ្ញោជនស្ស សម្មទញ្ញាវិមុត្តស្ស អយមនុធម្មោ ហោតិ វេយ្យាករណាយ ទិដ្ឋេ ខោ អហំ អាវុសោ អនុបាយោ អនបាយោ អនិស្សិតោ អប្បដិពទ្ធោ

ព្រះមានព្រះភាគអរហន្តសម្មាសម្ពុទ្ធអង្គនោះ ទ្រង់ជ្រាប ទ្រង់ឃើញ ទ្រង់សំដែងទុកមកដោយប្រពៃហើយ វោហារ ៤ យ៉ាងតើដូចម្តេច គឺភាវៈនៃបុគ្គលនិយាយថាឃើញក្នុងរូបារម្មណ៍ដែលឃើញហើយ ១ ភាវៈនៃបុគ្គលនិយាយថាឮក្នុងសទ្ទារម្មណ៍ដែលឮហើយ ១ ភាវៈនៃបុគ្គលនិយាយថាទទួលរសារម្មណ៍ដែលបានទទួលហើយ ១ ភាវៈនៃបុគ្គលនិយាយថាដឹងច្បាស់ក្នុងអារម្មណ៍ដែលដឹងច្បាស់ហើយ ១ ម្នាលអាវុសោ វោហារទាំង ៤ យ៉ាងនេះឯង ដែលព្រះមានព្រះភាគអរហន្តសម្មាសម្ពុទ្ធអង្គនោះទ្រង់ជ្រាប ទ្រង់ឃើញ ទ្រង់សំដែងទុកមកហើយដោយប្រពៃ ។ ភិក្ខុនោះសួរថា ចុះលោកមានអាយុដឹងដូចម្តេចខ្លះ ឃើញដូចម្តេចខ្លះ បានជាចិត្តរួចស្រឡះចាកអាសវៈទាំងឡាយ មិនប្រកាន់ក្នុងវោហារទាំង ៤ យ៉ាងនេះ ។

(១៦៨) ម្នាលភិក្ខុទាំងឡាយ ភិក្ខុជាខីណាស្រព អ្នកមានព្រហ្មចរិយៈប្រព្រឹត្តហើយ មានកិច្ចការធ្វើរួចហើយ មានភារៈដាក់ចុះហើយ មានប្រយោជន៍សម្រាប់ខ្លួនសម្រេចហើយ មានភវសញ្ញោជនៈអស់ហើយ រួចស្រឡះចាកអកុសលធម៌ ព្រោះដឹងដោយប្រពៃ រមែងមានអនុធម៌នេះ[១] ដើម្បីព្យាករណ៍ថា ម្នាលអាវុសោ ខ្ញុំមិនលុះ មិនលិចលង់ មិនអាស្រ័យ មិនជាប់ចំពាក់នៅក្នុងអារម្មណ៍ ដែលឃើញហើយទ

១ សភាវៈ ។

វិប្បមុត្តោ វិសំយុត្តោ វិមរិយាទិកតេន ចេតសា វិហរាមិ សុតេ ខោ អហំ អាវុសោ ... មុតេ ខោ អហំ អាវុសោ វិញ្ញាតេ ខោ អាវុសោ ... អនុបាយោ អនបាយោ អនិស្សិតោ អប្បដិពទ្ធោ វិប្បមុត្តោ វិសំយុត្តោ វិមរិយាទិកតេន ចេតសា វិហរាមិ ឯវំ ខោ មេ អាវុសោ ជានតោ ឯវំ បស្សតោ ឥមេសុ ចតូសុ វោហារេសុ អនុបាទាយ អាសវេហិ ចិត្តំ វិមុត្តន្តិ ។ តស្ស ភិក្ខវេ ភិក្ខុនោ សាធូតិ ភាសិតំ អភិនន្ទិតព្វំ អនុមោទិតព្វំ ។ សាធូតិ ភាសិតំ អភិនន្ទិត្វា អនុមោទិត្វា ឧត្តរឹ បញ្ហោ បុច្ឆិតព្វោ បញ្ច ខោ ឥមេ អាវុសោ ឧបាទានក្ខន្ធា តេន ភគវតា ជានតា បស្សតា អរហតា សម្មាសម្ពុទ្ធេន សម្មទក្ខាតា កតមេ បញ្ច សេយ្យថីទំ រូបុបាទានក្ខន្ធោ វេទនុបាទានក្ខន្ធោ សញ្ញុបាទានក្ខន្ធោ សង្ខារុបាទានក្ខន្ធោ

រួចស្រឡះចាកកាមរាគ ព្រោះអស់បាតរយោគៈ ឥតមានចិត្តទើតរើពាំងទៀយ ម្នាលអាវុសោ ខ្ញុំ (មិនលះ) ក្នុងរសារម្មណ៍ដែលទទួលហើយទេ ... ម្នាលអាវុសោ ខ្ញុំ (មិនលះ) ក្នុងរសារម្មណ៍ដែលគ្នាហើយទេ ម្នាលអាវុសោ ខ្ញុំមិនលះ មិនលៃលក មិនអាល័យ មិនជាប់ចំពាក់នៅក្នុងអារម្មណ៍ដែលដឹងច្បាស់ហើយទេ ព្រោះ ... ចាកកាមរាគ ព្រោះស-ចាកយោគៈ ឥតមានចិត្តទើតរើពាំងទៀយ ម្នាលអាវុសោ ខ្ញុំដឹងយ៉ាងនេះ ឃើញយ៉ាងនេះ ... ជាចិត្តរួចស្រឡះចាកអាសវធម៌ទាំងឡាយ មិនប្រកាន់ក្នុងលោហារម្មណ៍ ... ៦ ម្នាលភិក្ខុទាំងឡាយ ភិក្ខុត្រូវត្រេកអរ អនុមោទនា ... ភាសិតរបស់ភិក្ខុនោះថា សាធុ ដូច្នេះ ។ លុះភិក្ខុត្រេកអរ អនុមោទនា ... ភាសិតថា សាធុ ដូច្នេះហើយ ត្រូវសួរប្រស្នាតទៅទៀតថា ម្នាលអាវុសោ ឧបាទានក្ខន្ធ ៥ នេះ ព្រះមានព្រះភាគអរហន្តសម្មាសម្ពុទ្ធនោះ ទ្រង់ជ្រាប ទ្រង់ឃើញ ទ្រង់សំដែងទុកមកហើយដោយប្រពៃ ឧបាទានក្ខន្ធទាំង ៥ តើដូចម្តេចខ្លះ គឺរូបូបា-ទានក្ខន្ធ ១ វេទនូបាទានក្ខន្ធ ១ សញ្ញូបាទានក្ខន្ធ ១ សង្ខារូបាទានក្ខន្ធ ១

វិញ្ញាណុបាទានក្ខន្ធោ ឥមេ ខោ អាវុសោ បញ្ចុបា-
ទានក្ខន្ធា តេន ភគវតា ជានតា បស្សតា អរហតា
សម្មាសម្ពុទ្ធេន សម្មទក្ខាតា ។ កថំ ជានតោ
បនាយស្មតោ កថំ បស្សតោ ឥមេសុ បញ្ចសុ ឧបា-
ទានក្ខន្ធេសុ អនុបាទាយ អាសវេហិ ចិត្តំ វិមុត្តន្តិ ។

(១៦៩) ខីណាសវស្ស ភិក្ខវេ ភិក្ខុនោ វុសិ-
តវតោ កតករណីយស្ស ឱហិតភារស្ស អនុប្បត្ត-
សទត្ថស្ស បរិក្ខីណភវសំយោជនស្ស សម្មទញ្ញាវិ-
មុត្តស្ស អយមនុធម្មោ ហោតិ វេយ្យាករណាយ រូបំ
ខោ អហំ អាវុសោ អពលំ វិរាគុនំ អនស្សាសិកន្តិ(១)
វិទិត្វា យេ រូបេ ឧបាយុបាទានា ចេតសោ អធិដ្ឋា-
នាភិនិវេសានុសយា តេសំ ខយា វិរាគា និរោធា ចាគា
បដិនិស្សគ្គា វិមុត្តំ មេ ចិត្តន្តិ បជានាមិ វេទនំ
ខោ អហំ អាវុសោ … សញ្ញំ ខោ អហំ អាវុសោ …

១ ម. វិរាគំ អនស្សាសិកំ ។

វិញ្ញាណធាតុ ១ ម្នាលអាវុសោ ធាតុទាំង ៦ នេះ ដែល
ព្រះមានព្រះភាគ អរហន្តសម្មាសម្ពុទ្ធនោះ ទ្រង់ជ្រាប ទ្រង់ឃើញ
ទ្រង់សំដែងទុកមកហើយដោយប្រពៃ ។ ចុះលោកមានអាយុ ដឹងដូច–
ម្តេច ឃើញដូចម្តេច ទើបជាចិត្តរួចស្រឡះចាកអាសវៈទាំងឡាយមិន
ប្រកាន់ក្នុងធាតុទាំង ៦ នេះ ។

(១២៩) ម្នាលភិក្ខុទាំងឡាយ ភិក្ខុជាខីណាស្រព អ្នកមាន
ព្រហ្មចរិយៈប្រព្រឹត្តស្រេចហើយ មានកិច្ចការធ្វើស្រេចហើយ មានភារៈ
ដាក់ចុះហើយ មានប្រយោជន៍ចំពោះខ្លួនសម្រេចហើយ មានភវសញ្ញោ–
ជនៈអស់ហើយ មានចិត្តផុតស្រឡះហើយ ព្រោះដឹងនូវធម៌ដោយ
ប្រពៃ រមែងមានអនុធម៌នេះដើម្បីព្យាករណ៍ថា ម្នាលអាវុសោ ខ្ញុំដឹង
ច្បាស់នូវរូបថា មានកម្លាំងថយ ដល់នូវសេចក្តីវិនាស មិនជាទីត្រេក–
អរ ហើយដឹងច្បាស់ថា ការប្រកាន់មាំ ការអធិដ្ឋាន ការចូលចិត្ត
ស៊ប់ និងការដេកនៅរបស់ចិត្ត ណា ក្នុងរូប ចិត្តរបស់ខ្ញុំ ផុតស្រឡះ
ព្រោះអស់ទៅ ព្រោះនឿយណាយ ព្រោះរលត់ ព្រោះលះបង់ ព្រោះ
កំចាត់បង់ នូវសេចក្តីប្រកាន់មាំជាដើមនោះ ម្នាលអាវុសោ ខ្ញុំ ( ដឹង
ច្បាស់ ) នូវវេទនា ... ម្នាលអាវុសោ ខ្ញុំ ( ដឹងច្បាស់ ) នូវសញ្ញា ...

សង្ខារេ ខោ អហំ អាវុសោ ។បេ។ វិញ្ញាណំ ខោ
អហំ អាវុសោ អពលំ វិរាគុនំ អនស្សាសិកន្តិ
វិទិត្វា យេ វិញ្ញាណេ ឧបាយុបាទានា ចេតសោ
អធិដ្ឋានាភិនិវេសានុសយា តេសំ ខយា វិរាគា
និរោធា ចាគា បដិនិស្សគ្គា វិមុត្តំ មេ ចិត្តន្តិ
បជានាមិ ឯវំ ខោ មេ អាវុសោ ជានតោ ឯវំ
បស្សតោ ឥមេសុ បញ្ចសុ ឧបាទានក្ខន្ធេសុ អនុ-
បាទាយ អាសវេហិ ចិត្តំ វិមុត្តន្តិ ។ តស្ស ភិក្ខវេ
ភិក្ខុនោ សាធូតិ ភាសិតំ អភិនន្ទិតព្វំ អនុមោ-
ទិតព្វំ ។ សាធូតិ ភាសិតំ អភិនន្ទិត្វា អនុមោទិត្វា
ឧត្តរឹ បញ្ហោ បុច្ឆិតព្វោ ។ ឆយិមាវុសោ ធាតុយោ តេន
ភគវតា ជានតា បស្សតា អរហតា សម្មា-
សម្ពុទ្ធេន សម្មទក្ខាតា កតមា ឆ បឋវីធាតុ

ម្នាលអាវុសោ ខ្ញុំ (ដឹងច្បាស់) វេទនាទាំងឡាយ ... ម្នាលអាវុសោ ខ្ញុំដឹងច្បាស់នូវវិញ្ញាណថា មានកម្លាំងថយ ដល់នូវការវិនាស មិនជាទីត្រេកអរ ហើយដឹងច្បាស់ថា សេចក្តីប្រកាន់មាំ ការអធិដ្ឋាន ការចូលចិត្តស៊ប់ និងការដេកនៅរបស់ចិត្តណា ក្នុងវិញ្ញាណ ចិត្តរបស់ខ្ញុំក៏ផុតស្រឡះ ព្រោះអស់ទៅ ព្រោះនឿយណាយ ព្រោះរលត់ ព្រោះលះបង់ ព្រោះកំចាត់បង់នូវសេចក្តីប្រកាន់មាំជាដើមនោះ ម្នាលអាវុសោ កាលបើខ្ញុំដឹងយ៉ាងនេះ ឃើញយ៉ាងនេះ ចិត្តក៏ផុតចាកអាសវធម៌ទាំងឡាយ ព្រោះមិនប្រកាន់មាំក្នុងឧបាទានក្ខន្ធទាំង ៥ នេះ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុត្រូវត្រេកអរអនុមោទនាចំពោះភាសិតរបស់ភិក្ខុនោះថា សាធុ ដូច្នេះ ។ លុះភិក្ខុត្រេកអរ អនុមោទនា ចំពោះភាសិតថា សាធុ ដូច្នេះហើយ ត្រូវសួរប្រស្នាតទៅទៀតថា ម្នាលអាវុសោ ធាតុ ៦ នេះ ព្រះមានព្រះភាគអរហន្តសម្មាសម្ពុទ្ធអង្គនោះជ្រាបច្បាស់ ឃើញច្បាស់ ទ្រង់ត្រាស់សំដែងដោយប្រពៃហើយ ធាតុទាំង ៦ តើដូចម្តេច គឺបឋវីធាតុ ១

អាបោធាតុ តេជោធាតុ វាយោធាតុ អាកាសធាតុ វិញ្ញាណធាតុ ឥមា ខោ អាវុសោ ឆ ធាតុយោ តេន ភគវតា ជានតា បស្សតា អរហតា សម្មាសម្ពុទ្ធេន សម្មទក្ខាតា ។ កថំ ជានតោ បនាយស្មតោ កថំ បស្សតោ ឥមាសុ ឆសុ ធាតូសុ អនុបាទាយ អាសវេហិ ចិត្ត វិមុត្តន្តិ ។

(១៧០) ខីណាសវស្ស ភិក្ខវេ ភិក្ខុនោ វុសិតវតោ កតករណីយស្ស ឱហិតភារស្ស អនុប្បត្តសទត្ថស្ស បរិក្ខីណភវសញ្ញោជនស្ស សម្មទញ្ញាវិមុត្តស្ស អយមនុធម្មោ ហោតិ វេយ្យាករណាយ បឋវីធាតុំ ខោ អហំ អាវុសោ អនត្តតោ ឧបគច្ឆិំ ន ច បឋវីធាតុនិស្សិតំ អត្តានំ យេ ច បឋវីធាតុនិស្សិតា ឧបាយុបាទានា ចេតសោ អធិដ្ឋានាភិនិវេសានុសយា តេសំ ខយា វិរាគា និរោធា ចាគា បដិនិស្សគ្គា វិមុត្តំ មេ ចិត្តន្តិ បជានាមិ,

អាបោធាតុ ១ តេជោធាតុ ១ វាយោធាតុ ១ អាកាសធាតុ ១ វិញ្ញាណធាតុ ១ ម្នាលអាវុសោ ធាតុទាំង ៦ នេះឯង ដែលព្រះមានព្រះភាគ អរហន្តសម្មាសម្ពុទ្ធ ជ្រាបច្បាស់ ឃើញច្បាស់ ទ្រង់ត្រាស់សំដែងដោយប្រពៃហើយ ។ ចុះលោកមានអាយុ ដឹងដូចម្តេច ឃើញដូចម្តេច បានជាចិត្តរួចស្រឡះចាកអាសវៈទាំងឡាយ ព្រោះមិនប្រកាន់ក្នុងធាតុទាំង ៦ នេះ ។

(១៧០) ម្នាលភិក្ខុទាំងឡាយ ភិក្ខុជាខីណាស្រព ដែលមានព្រហ្មចរិយធម៌ប្រព្រឹត្តគ្រប់គ្រាន់ហើយ មានកិច្ចធ្វើរួចហើយ មានភារៈដាក់ចុះហើយ មានប្រយោជន៍ចំពោះខ្លួនសម្រេចហើយ មានសញ្ញោជនៈក្នុងភពអស់ហើយ មានចិត្តផុតស្រឡះហើយ ព្រោះដឹងនូវធម៌ដោយប្រពៃ តែងមានអនុធម៌នេះ ដើម្បីព្យាករណ៍ថា ម្នាលអាវុសោ ខ្ញុំចូលចិត្ត នូវបឋវីធាតុ ថាមិនមែនខ្លួនផង មិនចូលចិត្ត នូវខ្លួនដែលអាស្រ័យនៅនឹងបឋវីធាតុផង មួយទៀត សេចក្តីប្រកាន់មាំ ការអធិដ្ឋាន ការចូលចិត្តស៊ប់ និងការដេកនៅរបស់ចិត្តណា ដែលអាស្រ័យនឹងបឋវីធាតុ ខ្ញុំដឹងច្បាស់ថា ចិត្តរបស់អាត្មាអញ ផុតស្រឡះហើយ ព្រោះអស់ ព្រោះនឿយណាយ ព្រោះរលត់ ព្រោះលះបង់ ព្រោះកំចាត់បង់ នូវសេចក្តីប្រកាន់មាំជាដើមនោះ

អាបោធាតុំ ខោ អហំ អាវុសោ... តេជោធាតុំ ខោ អហំ អាវុសោ... វាយោធាតុំ ខោ អហំ អាវុសោ... អាកាសធាតុំ ខោ អហំ អាវុសោ... វិញ្ញាណធាតុំ ខោ អហំ អាវុសោ អនត្តតោ ឧបគច្ឆឹ ន ច វិញ្ញាណធាតុនិស្សិតំ អត្តានំ យេ ច វិញ្ញាណធាតុនិស្សិតា ឧបាទានុបាទានា(១) ចេតសោ អធិដ្ឋានាភិនិវេសានុសយា តេសំ ខយា វិរាគា និរោធា ចាគា បដិនិស្សគ្គា វិមុត្តំ មេ ចិត្តន្តិ បជានាមិ ឯវំ ខោ មេ អាវុសោ ជានតោ ឯវំ បស្សតោ ឥមាសុ ឆសុ ធាតូសុ អនុបាទាយ អាសវេហិ ចិត្តំ វិមុត្តន្តិ ។ តស្ស ភិក្ខវេ ភិក្ខុនោ សាធូតិ ភាសិតំ អភិនន្ទិតព្វំ អនុមោទិតព្វំ ។ សាធូតិ ភាសិតំ អភិនន្ទិត្វា អនុមោទិត្វា ឧត្តរឹ បញ្ហោ បុច្ឆិតព្វោ

១ ឱ: ឧបាយុបាទានា ។

ម្នាលអាវុសោ ខ្ញុំចូលចិត្តនូវអាបោធាតុ ... ម្នាលអាវុសោ ខ្ញុំចូលចិត្តនូវតេជោធាតុ ... ម្នាលអាវុសោ ខ្ញុំចូលចិត្តនូវវាយោធាតុ ... ម្នាលអាវុសោ ខ្ញុំចូលចិត្តនូវអាកាសធាតុ ... ម្នាលអាវុសោ ខ្ញុំចូលចិត្តនូវវិញ្ញាណធាតុ ថាមិនមែនខ្លួនផង មិនចូលចិត្តខ្លួនដែលអាស្រ័យនៅនឹងវិញ្ញាណធាតុផង មួយទៀត ខ្ញុំដឹងច្បាស់ថា ការប្រកាន់មាំ ការអធិដ្ឋាន ការចូលចិត្តស៊ប់ និងការដេកនៅរបស់ចិត្តណា ដែលអាស្រ័យនឹងវិញ្ញាណ ចិត្តរបស់ខ្ញុំផុតស្រឡះហើយ ព្រោះអស់ ព្រោះនឿយណាយ ព្រោះរលត់ ព្រោះលះបង់ ព្រោះកំចាត់បង់ នូវសេចក្តីប្រកាន់មាំជាដើមនោះ ម្នាលអាវុសោ កាលបើខ្ញុំដឹងយ៉ាងនេះ ឃើញយ៉ាងនេះហើយ ចិត្តក៏ផុតចាកអាសវៈទាំងឡាយ ព្រោះមិនប្រកាន់ក្នុងធាតុទាំង ៦ នេះ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុត្រូវត្រេកអរ អនុមោទនានឹងភាសិតរបស់ភិក្ខុនោះថា សាធុ ដូច្នេះ ។ លុះភិក្ខុត្រេកអរអនុមោទនានូវភាសិតថា សាធុ ដូច្នេះហើយ ត្រូវសួរប្រស្នាតទៅទៀតថា

ឆ ខោ បនិមានិ អាវុសោ អជ្ឈត្តិកានិ ពាហិរានិ អាយតនានិ តេន ភគវតា ជានតា បស្សតា អរហតា សម្មាសម្ពុទ្ធេន សម្មទក្ខាតានិ កតមានិ ឆ ចក្ខុ ចេវ រូបា ច សោតំ សទ្ទា ច ឃានំ ច គន្ធា ច ជិវ្ហា ច រសា ច កាយោ ច ផោដ្ឋព្វា ច មនោ ច ធម្មា ច ឥមានិ ខោ អាវុសោ ឆ អជ្ឈត្តិកានិ ពាហិរានិ អាយតនានិ តេន ភគវតា ជានតា បស្សតា អរហតា សម្មាសម្ពុទ្ធេន សម្មទក្ខាតានិ ។ កថំ ជានតោ បនាយស្មតោ កថំ បស្សតោ ឥមេសុ ឆសុ អជ្ឈត្តិកពាហិរេសុ អាយតនេសុ អនុបាទាយ អាសវេហិ ចិត្តំ វិមុត្តន្តិ ។

(១៨១) ខីណាសវស្ស ភិក្ខវេ ភិក្ខុនោ វុសិតវតោ កតករណីយស្ស ឱហិតភារស្ស អនុប្បត្ត-

ម្នាលអាវុសោ ចុះអាយតនៈខាងក្នុង ខាងក្រៅតាំង ៦ នេះ ដែលព្រះមានព្រះភាគអរហន្តសម្មាសម្ពុទ្ធ ទ្រង់ជ្រាបច្បាស់ ឃើញច្បាស់ ទ្រង់សំដែងដោយប្រពៃហើយ អាយតនៈ ៦ តើដូចម្តេច គឺចក្ខុ ១ រូប ១ សោតៈ ១ សទ្ទៈ ១ ឃានៈ ១ គន្ធៈ ១ ជិវ្ហា ១ រសៈ ១ កាយៈ ១ ផោដ្ឋព្វៈ ១ មនៈ ១ ធម្មៈ ១ ម្នាលអាវុសោ អាយតនៈខាងក្នុងខាងក្រៅ ៦ នេះហើយ ដែលព្រះមានព្រះភាគ អរហន្តសម្មាសម្ពុទ្ធ ទ្រង់ជ្រាបច្បាស់ ឃើញច្បាស់ ទ្រង់ត្រាស់សំដែងដោយប្រពៃហើយ ។ ភិក្ខុសួរថា ចុះលោកមានអាយុ ដឹងដូចម្តេច ឃើញដូចម្តេច ទើបចិត្តផុតស្រឡះចាកអាសវៈទាំងឡាយ ព្រោះមិនប្រកាន់ក្នុងអាយតនៈខាងក្នុង ៦ ខាងក្រៅ ៦ នេះ ។

(១៣១) ម្នាលភិក្ខុទាំងឡាយ ភិក្ខុជាខីណាស្រព ដែលមានព្រហ្មចរិយធម៌ ប្រព្រឹត្តគ្រប់គ្រាន់ហើយ មានកិច្ចធ្វើស្រេចហើយ មានភារៈដាក់ចុះហើយ មានប្រយោជន៍ [illegible] ខ្លួន

សទត្ថស្ស បរិក្ខីណភវសញ្ញោជនស្ស សម្មទញ្ញា
វិមុត្តស្ស អយមនុធម្មោ ហោតិ វេយ្យាករណាយ
ចក្ខុស្មឹ អាវុសោ រូបេ ចក្ខុវិញ្ញាណេ ចក្ខុវិញ្ញាណ-
វិញ្ញាតព្វេសុ ធម្មេសុ យោ ឆន្ទោ យោ រាគោ យា
នន្ទិ យា តណ្ហា យេ ឧបាយុបាទានា ចេតសោ
អធិដ្ឋានាភិនិវេសានុសយា តេសំ ខយា វិរាគា
និរោធា ចាគា បដិនិស្សគ្គា វិមុត្តំ មេ ចិត្តន្តិ
បជានាមិ សោតស្មឹ អាវុសោ សទ្ទេ សោតវិញ្ញាណេ ...
ឃានស្មឹ អាវុសោ គន្ធេ ឃានវិញ្ញាណេ ... ជិវ្ហាយ
អាវុសោ រសេ ជិវ្ហាវិញ្ញាណេ ... កាយស្មឹ អាវុសោ

សម្រេចហើយ មានភវសញ្ញោជនៈអស់ហើយ មានចិត្តរួចស្រឡះហើយ ព្រោះដឹងនូវធម៌ដោយប្រពៃ តែងមានអនុធម៌នេះ ដើម្បីព្យាករណ៍ថា ម្នាលអាវុសោ ខ្ញុំដឹងច្បាស់ថា ឆន្ទៈ រាគៈ នន្ទិ តណ្ហា សេចក្តីប្រកាន់មាំ ការអធិដ្ឋាន ការចូលចិត្តស៊ប់ និងការដេកនៅ របស់ចិត្តណា ក្នុងចក្ខុ ក្នុងរូប ក្នុងចក្ខុវិញ្ញាណ ក្នុងធម្មារម្មណ៍ទាំងឡាយ ដែលបុគ្គលគប្បីដឹងច្បាស់ដោយចក្ខុវិញ្ញាណ ចិត្តរបស់អាត្មាអញ ក៏ផុតស្រឡះហើយ ព្រោះអស់ ព្រោះនឿយណាយ ព្រោះរលត់ ព្រោះលះបង់ ព្រោះកំចាត់បង់ នូវសភាវៈមានឆន្ទៈជាដើមនោះ ម្នាលអាវុសោ ខ្ញុំដឹងច្បាស់ថា ឆន្ទៈ រាគៈ នន្ទិ តណ្ហា សេចក្តីប្រកាន់មាំ ការអធិដ្ឋាន ការចូលចិត្តស៊ប់ និងការដេកនៅ របស់ចិត្ត ណា ៗ ក្នុងសោតៈ ក្នុងសទ្ទៈ ក្នុងសោតវិញ្ញាណ ... ក្នុងឃានៈ ក្នុងគន្ធៈ ក្នុងឃានវិញ្ញាណ ... ក្នុងជិវ្ហា ក្នុងរសៈ ក្នុងជិវ្ហាវិញ្ញាណ ... ក្នុងកាយ

ផោដ្ឋព្វេ កាយវិញ្ញាណេ ... មនស្មឹ អាវុសោ ធម្មេ មនោវិញ្ញាណេ មនោវិញ្ញាណវិញ្ញាតព្វេសុ ធម្មេសុ យោ ឆន្ទោ យោ រាគោ យា នន្ទី យា តណ្ហា យេ ឧបាទានុបាទានា ចេតសោ អធិដ្ឋានាភិនិវេសានុសយា តេសំ ខយា វិរាគា និរោធា ចាគា បដិនិស្សគ្គា វិមុត្តំ មេ ចិត្តន្តិ បជានាមិ ឯវំ ខោ មេ អាវុសោ ជានតោ ឯវំ បស្សតោ ឥមេសុ ចសុ អជ្ឈត្តិកពាហិរេសុ អាយតនេសុ អនុបាទាយ អាសវេហិ ចិត្តំ វិមុត្តន្តិ ។ តស្ស ភិក្ខវេ ភិក្ខុនោ សាធូតិ ភាសិតំ អភិនន្ទិតព្វំ អនុមោទិតព្វំ ។ សាធូតិ ភាសិតំ អភិនន្ទិត្វា អនុមោទិត្វា ឧត្តរឹ បញ្ហោ បុច្ឆិតព្វោ កថំ ជានតោ បនាយស្មតោ កថំ បស្សតោ ឥមស្មិញ្ច សវិញ្ញាណកេ កាយេ ពហិទ្ធា ច សព្វនិមិត្តេសុ អហង្ការមមង្ការមានានុសយា សុសមូហតាតិ ។

ក្នុងផោដ្ឋព្វៈ ក្នុងកាយវិញ្ញាណ .. ក្នុងមនៈ ក្នុងធម្មៈ ក្នុងមនោ-វិញ្ញាណ ក្នុងធម៌ទាំងឡាយ ដែលបុគ្គលត្រូវដឹងដោយមនោវិញ្ញាណ ចិត្តរបស់អាត្មាអញ ក៏ផុតស្រឡះ ព្រោះអស់ ព្រោះនឿយណាយ ព្រោះរលត់ ព្រោះលះបង់ ព្រោះកំចាត់បង់ នូវឧបយៈជាដើមនោះ ម្នាលអាវុសោ កាលបើខ្ញុំដឹងយ៉ាងនេះ ឃើញយ៉ាងនេះហើយ ចិត្តរបស់ខ្ញុំ ក៏រួចចាកអាសវៈទាំងឡាយ ព្រោះមិនប្រកាន់នូវអាយតនៈខាងក្នុង ៦ ខាងក្រៅ ៦ នេះឡើយ ម្នាលភិក្ខុទាំងឡាយ ភិក្ខុត្រូវត្រេកអរ អនុមោទនា នូវភាសិតរបស់ភិក្ខុនោះថា សាធុ ដូច្នេះ ។ លុះភិក្ខុត្រេកអរ អនុមោទនា នូវភាសិតថា សាធុ ដូច្នេះហើយ ត្រូវសួរប្រស្នាតទៅទៀតថា ចុះលោកមានអាយុ ដឹងដូចម្តេច ឃើញដូចម្តេច បានជាលោកដកនូវអហង្ការមានានុស័យ និងមមង្ការតណ្ហា-នុស័យ ក្នុងកាយដែលប្រកបដោយវិញ្ញាណនេះផង ក្នុងនិមិត្តទាំង-អស់ជាខាងក្រៅនេះផង ។

(១៧២) ខីណាសវស្ស ភិក្ខវេ ភិក្ខុនោ វុសិតវតោ កតករណីយស្ស ឱហិតភារស្ស អនុប្បត្តសទត្ថស្ស បរិក្ខីណភវសញ្ញោជនស្ស សម្មទញ្ញាវិមុត្តស្ស អយម-នុធម្មោ ហោតិ វេយ្យាករណាយ បុព្វេ ចាហំ អាវុសោ អាគារិយភូតោ សមានោ អវិទ្ទសុ អហោសឹ តស្ស មេ តថាគតោ វា តថាគតសាវកោ វា ធម្មំ ទេសេសិ តាហំ ធម្មំ សុត្វា តថាគតេ សទ្ធំ បដិលភឹ ។ សោ តេន សទ្ធាបដិលា-ភេន សមន្នាគតោ ឥតិ បដិសញ្ចិក្ខឹ សម្ពាធា(១) ឃរាវាសោ រជាបថោ អព្ភោកាសោ បព្វជ្ជា នយិទំ សុករំ អគារំ អជ្ឈាវសតា ឯកន្តបរិបុណ្ណំ ឯកន្ត-បរិសុទ្ធំ សង្ខលិខិតំ ព្រហ្មចរិយំ ចរិតុំ យន្នូនា-

១ ម. បដិសញ្ចិក្ខាមិ សំពាធោតិ ទិស្សតិ ។

[១៧២] ព្រះអង្គត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ភិក្ខុជាខីណាស្រព ដែលមានព្រហ្មចរិយធម៌ប្រព្រឹត្តគ្រប់គ្រាន់ហើយ មានកិច្ចការធ្វើរួចហើយ មានភារៈដាក់ចុះហើយ មានប្រយោជន៍របស់ខ្លួនសម្រេចហើយ មានភវសញ្ញោជនៈអស់រលីងហើយ មានចិត្តផុតហើយ ព្រោះដឹងធម៌ដោយប្រពៃ គឺមានអនុធម៌នេះ ដើម្បីព្យាករណ៍ថា ម្នាលអាវុសោ កាលពីដើម ខ្ញុំនៅជាគ្រហស្ថ ព្រះតថាគតក្តី សាវ័កព្រះតថាគតក្តី តែងសំដែងធម៌ដល់ខ្ញុំនោះ លុះខ្ញុំស្តាប់ធម៌នោះហើយ ក៏បាននូវសទ្ធាចំពោះព្រះតថាគត ។ ខ្ញុំនោះបរិបូណ៌ដោយការបាននូវសទ្ធានោះហើយ ក៏ពិចារណាឃើញដូច្នេះថា ឃរាវាស ចង្អៀតណាស់ ជាទ្វារបង្ហូរនូវធូលីគឺរាគៈ បព្វជ្ជា មើលមានទំនេរច្រើន កាលបើគ្នាអញ នៅគ្រប់គ្រងផ្ទះហើយ មិនងាយនឹងប្រព្រឹត្តព្រហ្មចារ្យ ឲ្យបរិបូណ៌ដោយចំណែកមួយ ឲ្យបរិសុទ្ធដោយចំណែកមួយ ដូចជាសង្ខដែលបុគ្គលដុសខាត់បានឡើយ បើដូច្នោះ

ហំ កេសមស្សុំ ឱហារេត្វា កាសាយានិ វត្ថានិ អច្ឆាទេត្វា អគារស្មា អនគារិយំ បព្វជេយ្យន្តិ ។ សោ ខោ អហំ អាវុសោ អបរេន សមយេន អប្បំ វា ភោគក្ខន្ធំ បហាយ មហន្តំ វា ភោគក្ខន្ធំ បហាយ អប្បំ វា ញាតិបរិវដ្ដំ បហាយ មហន្តំ វា ញាតិបរិវដ្ដំ បហាយ កេសមស្សុំ ឱហារេត្វា កាសាយានិ វត្ថានិ អច្ឆាទេត្វា អគារស្មា អនគារិយំ បព្វជឹ ។ សោ ឯវំ បព្វជិតោ សមានោ ភិក្ខូនំ សិក្ខាសាជីវសមាបន្នោ បាណាតិបាតំ បហាយ បាណាតិបាតា បដិវិរតោ អហោសឹ និហិតទណ្ឌោ និហិតសត្ថោ លជ្ជី ទយាបន្នោ សព្វបាណភូតហិតានុកម្បី អហោសឹ ។ អទិន្នាទានំ បហាយ អទិន្នាទានា បដិវិរតោ អហោសឹ ទិន្នាទាយី ទិន្នបាដិកង្ខី អថេនេន សុចិភូតេន អត្តនា វិហាសឹ ។ អព្រហ្មចរិយំ បហាយ ព្រហ្មចារី អហោសឹ

មានតែអាត្មាអញកោរសក់ ពុកមាត់ ពុកចង្កា ហើយស្លៀកសំពត់កាសាយៈ ចេញចាកផ្ទះ ចូលទៅកាន់ផ្នួស ។ ម្នាលអាវុសោ លុះសម័យជាខាងក្រោយមក ខ្ញុំនោះ បានលះបង់គំនរទ្រព្យតិចក្តី លះបង់គំនរទ្រព្យច្រើនក្តី លះបង់ញាតិវង្សតិចក្តី លះបង់ញាតិវង្សច្រើនក្តី ហើយកោរសក់ ពុកមាត់ ពុកចង្កា ស្លៀកសំពត់កាសាយៈ ចេញចាកផ្ទះ ចូលទៅកាន់ផ្នួស ។ លុះខ្ញុំបានបួសយ៉ាងនេះហើយ ក៏បរិបូណ៌ដោយសិក្ខានិងសាជីវៈរបស់ភិក្ខុ លះបង់បាណាតិបាត វៀរចាកបាណាតិបាត ដាក់ចុះនូវអាជ្ញា ដាក់ចុះនូវសស្ត្រា ជាអ្នកអៀនខ្មាស មានចិត្តអាណិតអាសូរ និងមានសេចក្តីអនុគ្រោះដល់សត្វ ដោយប្រយោជន៍ ។ ជាអ្នកលះបង់អទិន្នាទាន វៀរចាកអទិន្នាទាន កាន់យកតែទ្រព្យដែលគេឲ្យ ប្រាថ្នាចំពោះតែទ្រព្យដែលគេឱ្យ មានខ្លួនដ៏ស្អាត មិនមែនជាអ្នកលួច ។ ជាអ្នកលះបង់នូវអព្រហ្មចរិយធម៌ គឺធម៌មិនប្រសើរ ប្រព្រឹត្តនូវធម៌ដ៏ប្រសើរ

អារាចារី[1] វិរតោ មេថុនា គាមធម្មា ។ មុសាវាទំ បហាយ មុសាវាទា បដិវិរតោ ហោតិ សច្ចវាទី សច្ចសន្ធោ ថេតោ បច្ចយិកោ អវិសំវាទកោ លោកស្ស ។ បិសុណំ វាចំ បហាយ បិសុណាយ វាចាយ បដិវិរតោ ហោតិ ឥតោ សុត្វា ន អមុត្រ អក្ខាតា ឥមេសំ ភេទាយ អមុត្រ វា សុត្វា ន ឥមេសំ អក្ខាតា អមូសំ ភេទាយ ឥតិ ភិន្នានំ វា សន្ធាតា សហិតានំ វា អនុប្បទាតា សមគ្គារាមោ សមគ្គរតោ សមគ្គនន្ទី សមគ្គករណឹ វាចំ ភាសិតា ហោតិ ។ ផរុសំ វាចំ បហាយ ផរុសាយ វាចាយ បដិវិរតោ ហោតិ យា សា វាចា នេលា កណ្ណសុខា បេមនីយា ហទយង្គមា បោរី ពហុជនកន្តា ពហុជនមនាបា

១ អនាចារីតិបិ ។

ជាអ្នកចៀសវាង វៀរស្រឡះចាកមេថុន ដែលជាធម៌សម្រាប់អ្នកស្រុក ។ ជាអ្នកលះបង់មុសាវាទ វៀរចាកមុសាវាទ និយាយតែពាក្យពិត តនូវពាក្យពិត ជាអ្នកទៀងត្រង់ គួរគេជឿបាន មិននិយាយបំភាន់សត្វលោកឡើយ ។ ជាអ្នកលះបង់បិសុណាវាចា វៀរចាកបិសុណាវាចា គឺឮសំដីអំពីសំណាក់ជននេះ មិនប្រាប់ដល់ជនឯណោះ ដើម្បីនឹងបំបែកជនទាំងពីរនេះឡើយ ឬឮពីសំណាក់អ្នកឯណោះ មិនយកមកនិយាយប្រាប់អ្នកនេះ ដើម្បីនឹងបំបែកជនឯណោះឡើយ តែងតែជួយជ្រោមជ្រែងនូវពួកជនដែលបែកបាក់គ្នាហើយផង ជាអ្នកជួយទំនុកបម្រុងនូវពួកជនដែលត្រូវការនឹងប្រយោជន៍ផង ជាអ្នកត្រេកអរនឹងសេចក្តីព្រមព្រៀង ពេញចិត្តនឹងសេចក្តីព្រមព្រៀង ចូលចិត្តនឹងសេចក្តីព្រមព្រៀង និយាយតែពាក្យដែលនាំឲ្យកើតសេចក្តីព្រមព្រៀងដូច្នេះឯង ។ ជាអ្នកលះបង់ផរុសវាចា វៀរចាកផរុសវាចា វាចាណាមិនមានទោស ជាសុខដល់ត្រចៀក គួរឲ្យស្រឡាញ់ គួរឲ្យតម្កល់ទុកក្នុងហឫទ័យ ជាសំដីអ្នកក្រុង ជាទីស្រឡាញ់ដល់ជនច្រើន ជាទីពេញចិត្តដល់ជនច្រើន

តថារូបឹ វាចំ ភាសិតា អហោសិ ។ សម្ផប្បលាបំ បហាយ សម្ផប្បលាបា បដិវិរតោ អហោសិ កាលវាទី ភូតវាទី អត្ថវាទី ធម្មវាទី វិនយវាទី និធានវតឹ វាចំ ភាសិតា អហោសិ កាលេន សាបទេសំ បរិយន្តវតឹ អត្ថសញ្ហិតំ ។ សោ ពីជគាមភូតគាមសមារម្ភា បដិវិរតោ អហោសិ ឯកភត្តិកោ អហោសិ រត្តូបរតោ វិរតោ វិកាលភោជនា នច្ចគីតវាទិតវិសូកទស្សនា បដិវិរតោ អហោសិ មាលាគន្ធវិលេបនធារណមណ្ឌនវិភូសនដ្ឋានា បដិវិរតោ អហោសិ ឧច្ចាសយនមហាសយនា បដិវិរតោ អហោសិ ជាតរូបរជតប្បដិគ្គហណា បដិវិរតោ អហោសិ អាមកធញ្ញប្បដិគ្គហណា បដិវិរតោ អហោសិ អាមកមំសប្បដិគ្គហណា បដិវិរតោ អហោសិ ឥត្ថីកុមារិកាបដិគ្គហណា បដិវិរតោ អហោសិ ទាសីទាសប្បដិគ្គហណា បដិវិរតោ អហោសិ

ក៏និយាយតែវាចាមានសភាពដូច្នោះ ។ លះបង់សម្ផប្បលាបៈ វៀរចាកសម្ផប្បលាបៈ និយាយតាមកាល និយាយតែពាក្យពិត និយាយតែពាក្យនាំឲ្យកើតប្រយោជន៍ និយាយពីធម៌ និយាយពីវិន័យ និយាយតែពាក្យដែលគួរឲ្យគេតម្កល់ទុកក្នុងចិត្ត និយាយតែពាក្យមានគ្រឿងអាងតាមកាល ពាក្យមានទីបំផុត ពាក្យមានប្រយោជន៍ ។ ខ្ញុំនោះ ជាកវៀរចាកការផ្តិលផ្តាច់នូវពីជគាមនិងភូតគាម ជាអ្នកបរិភោគភត្តតែម្តង វៀរចាកការបរិភោគក្នុងរាត្រី វៀរចាកការបរិភោគក្នុងវេលាវិកាល វៀរចាកការរាំ ច្រៀង ប្រគំ និងការមើលនូវល្បែងដែលជាសត្រូវដល់កុសលធម៌ វៀរចាកការប្រដាប់តាក់តែង ស្អិតស្អាង ( ពងកាយ ) ដោយផ្កាកម្រងគ្រឿងក្រអូប និងគ្រឿងលាបផ្សេងៗ វៀរចាកការដេកអង្គុយលើសេនាសនៈដ៏ខ្ពស់ និងសេនាសនៈដ៏ប្រសើរ វៀរចាកការទទួលមាសនិងប្រាក់ វៀរចាកការទទួលស្រូវស្រស់ វៀរចាកការទទួលសាច់ឆៅ វៀរចាកការទទួលស្រីនិងក្មេងស្រី វៀរចាកការទទួលខ្ញុំស្រីនិងខ្ញុំប្រុស

អជេឡកប្បដិគ្គហណា បដិវិរតោ អហោសិ កុក្កុ-
ដសូករប្បដិគ្គហណា បដិវិរតោ អហោសិ ហត្ថិគ-
វស្សវឡវប្បដិគ្គហណា បដិវិរតោ អហោសិ ខេត្ត-
វត្ថុប្បដិគ្គហណា បដិវិរតោ អហោសិ ទូតេយ្យបហិ-
ណគមនានុយោគា បដិវិរតោ អហោសិ កយវិក្កយា
បដិវិរតោ អហោសិ តុលាកូដកំសកូដមានកូដា
បដិវិរតោ អហោសិ ឧក្កោដនវញ្ចននិកតិសាចិយោគា
បដិវិរតោ អហោសិ ឆេទនវធពន្ធនវិបរាមោសអាលោ-
បសហសាការា បដិវិរតោ អហោសិ ។ សោ
សន្តុដ្ឋោ អហោសិ កាយបរិហារិកេន ចីវរេន កុច្ឆិ-
បរិហារិកេន បិណ្ឌបាតេន យេន យេនេវ បក្កមិ
សមាទាយេវ បក្កមិ ។ សេយ្យថាបិ នាម បក្ខី
សកុណោ យេន យេនេវ ឌេតិ សបត្តភារោវ
ឌេតិ ឯវមេវ ខោ អហំ អាវុសោ សន្តុដ្ឋោ អហោសិ
កាយបរិហារិកេន ចីវរេន កុច្ឆិបរិហារិកេន បិណ្ឌបា-
តេន យេន យេនេវ បក្កមិ សមាទាយេវ បក្កមិ ។

វៀរចាកការទទួលពពែនិងចៀម វៀរចាកការទទួលមាន់និងជ្រូក វៀរចាកការទទួលដំរីគោសេះឈ្មោលនិងសេះញី វៀរចាកការទទួលស្រែនិងចំការ វៀរចាកការប្រកបកិច្ចជាទូតនាំសំបុត្រទៅមក វៀរចាកការលក់ដូរ វៀរចាកការឆបោកដោយជញ្ជីង ឆបោកដោយកាជន៍មាស ឆបោកដោយរង្វាស់ ជាអ្នកវៀរចាកការសេរើ បញ្ឆោត បន្លំ កោងកាច វៀរចាកការកាត់ (នូវអវយវៈមានដៃជាដើម) សម្លាប់ចាប់ចង ធ្វើមនុស្សឲ្យវង្វេងផ្លូវ ប្លន់កំហែងយកទ្រព្យ ។ ខ្ញុំនោះ ជាអ្នកសន្តោស ដោយចីវរគ្រឿងរក្សាកាយ ដោយបិណ្ឌបាតជាគ្រឿងរក្សាផ្ទៃ បើដើរចេញទៅទីណា ៗ ក៏កាន់យកតែចីវរនិងបិណ្ឌបាតនោះដើរចេញទៅ ៗ ដូចសត្វបក្សី ហើរទៅកាន់ទីណា ៗ ដោយតែស្លាបនិងរោមរបស់ខ្លួនប៉ុណ្ណោះយ៉ាងណា ម្នាលអាវុសោ ខ្ញុំជាអ្នកសន្តោស ដោយចីវរជាគ្រឿងរក្សាកាយ ដោយបិណ្ឌបាតជាគ្រឿងរក្សាផ្ទៃ បើចេញទៅទីណា ៗ ក៏កាន់យកតែចីវរនិងបិណ្ឌបាតដើរចេញទៅប៉ុណ្ណោះ យ៉ាងនោះដែរ ។

(១៧៣) សោ ឥមិនា អរិយេន សីលក្ខន្ធេន សមន្នាគតោ អជ្ឈត្តំ អនវជ្ជសុខំ បដិសំវេទេសឹ ។ សោ ចក្ខុនា រូបំ ទិស្វា ន និមិត្តគ្គាហី អហោសឹ នានុព្យញ្ជនគ្គាហី យត្វាធិករណមេនំ(១) ចក្ខុន្ទ្រិយំ អសំវុតំ វិហរន្តំ អភិជ្ឈាទោមនស្សា បាបកា អកុ-សលា ធម្មា អន្វាស្សវេយ្យុំ តស្ស សំវរាយ បដិបជ្ជឹ រក្ខឹ ចក្ខុន្ទ្រិយំ ចក្ខុន្ទ្រិយេ សំវរំ អាបជ្ជឹ សោតេន សទ្ទំ សុត្វា ... ឃានេន គន្ធំ ឃាយិត្វា ... ជិវ្ហាយ រសំ សាយិត្វា ... កាយេន ផោដ្ឋព្វំ ផុសិត្វា ... មនសា ធម្មំ វិញ្ញាយ ន និមិត្តគ្គាហី អហោសឹ នានុព្យញ្ជ-នគ្គាហី យត្វាធិករណមេនំ មនិន្ទ្រិយំ អសំវុតំ វិហរន្តំ អភិជ្ឈាទោមនស្សា បាបកា អកុសលា ធម្មា អន្វាស្សវេយ្យុំ តស្ស សំវរាយ បដិបជ្ជឹ រក្ខឹ មនិន្ទ្រិយំ មនិន្ទ្រិយេ សំវរំ អាបជ្ជឹ ។

១ ម. យតោធិករណមេនំ ។

(១៧៣) ខ្ញុំនោះ បរិបូណ៌ដោយសីលក្ខន្ធដ៏ប្រសើរនេះ ហើយទទួលសេចក្តីសុខដែលមិនមានទោសក្នុងសន្តាន ។ ខ្ញុំនោះ ឃើញរូបដោយភ្នែក ក៏មិនប្រកាន់នូវនិមិត្ត មិនប្រកាន់នូវអនុព្យញ្ជនៈឡើយ អកុសលធម៌ទាំងឡាយដ៏លាមក គឺអភិជ្ឈានិងទោមនស្ស គប្បីជាប់តាមនូវបុគ្គល ព្រោះហេតុមិនសង្រួមនូវចក្ខុន្ទ្រិយណា ខ្ញុំក៏ប្រតិបត្តិ ដើម្បីសង្រួមនូវចក្ខុន្ទ្រិយនោះ រក្សានូវចក្ខុន្ទ្រិយ ដល់នូវការសង្រួមក្នុងចក្ខុន្ទ្រិយ ឮសំឡេងដោយត្រចៀក ... ធុំក្លិនដោយច្រមុះ ... ទទួលរសដោយអណ្តាត ... ពាល់ត្រូវនូវផោដ្ឋព្វៈដោយកាយ ... ដឹងធម្មារម្មណ៍ដោយចិត្ត ក៏មិនប្រកាន់នូវនិមិត្ត មិនប្រកាន់នូវអនុព្យញ្ជនៈឡើយ ធម៌ទាំងឡាយជាអកុសលដ៏លាមក គឺអភិជ្ឈានិងទោមនស្ស គប្បីជាប់តាមនូវបុគ្គល ព្រោះហេតុមិនសង្រួមនូវមនិន្ទ្រិយណា ខ្ញុំក៏ប្រតិបត្តិ ដើម្បីសង្រួមនូវមនិន្ទ្រិយនោះ រក្សានូវមនិន្ទ្រិយ ដល់នូវការសង្រួម ក្នុងមនិន្ទ្រិយ ។

(១៧៤) សោ ឥមិនា អរិយេន ឥន្ទ្រិយសំវរេន សមន្នាគតោ អជ្ឈត្តំ អព្យាសេកសុខំ បដិសំវេទេតិ ។ អភិក្កន្តេ(១) បដិក្កន្តេ សម្បជានការី ហោតិ អាលោកិតេ វិលោកិតេ សម្បជានការី ហោតិ សមិញ្ជិតេ បសារិតេ សម្បជានការី ហោតិ សង្ឃាដិបត្តចីវរធារណេ សម្បជានការី ហោតិ អសិតេ បីតេ ខាយិតេ សាយិតេ សម្បជានការី ហោតិ ឧច្ចារបស្សាវកម្មេ សម្បជានការី ហោតិ គតេ ឋិតេ និសិន្នេ សុត្តេ ជាគរិតេ ភាសិតេ តុណ្ហីភាវេ សម្បជានការី ហោតិ ។

(១៧៥) សោ ឥមិនា ច អរិយេន សីលក្ខន្ធេន សមន្នាគតោ ឥមិនា ច អរិយេន ឥន្ទ្រិយសំវរេន សមន្នាគតោ ឥមិនា ច អរិយេន សតិសម្បជញ្ញេន សមន្នាគតោ វិវិត្តំ សេនាសនំ ភជតិ អរញ្ញំ រុក្ខមូលំ បព្វតំ កន្ទរំ គិរិគុហំ សុសានំ វនបត្ថំ អព្ភោកាសំ បលាលបុញ្ជំ ។ សោ បច្ឆាភត្តំ បិណ្ឌបាតបដិក្កន្តោ និសីទតិ

---

១ ឱ. ម. សោ អភិក្កន្តេ ។

(១៧ ) ខ្ញុំនោះ បរិបូណ៌ដោយការសង្រួមក្នុងឥន្ទ្រិយដ៏ប្រសើរនេះ ហើយបានទទួលនូវសេចក្តីសុខមិនមានទុក្ខក្នុងសន្តាន ។ ខ្ញុំមានកិរិយាដឹងច្បាស់ ក្នុងការឈានទៅមុខ ឈានថយក្រោយ ខ្ញុំមានកិរិយាដឹងច្បាស់ ក្នុងការមើលទៅមុខ ងាកមើលទៅខាង ខ្ញុំមានកិរិយាដឹងច្បាស់ ក្នុងការបត់ដៃចូល និងលាដៃចេញ ខ្ញុំមានកិរិយាដឹងច្បាស់ ក្នុងការប្រើប្រាស់សង្ឃាដិ បាត្រ ចីវរ ខ្ញុំមានកិរិយាដឹងច្បាស់ ក្នុងការស៊ី ផឹក ទំពា ទទួលរស ខ្ញុំមានកិរិយាដឹងច្បាស់ ក្នុងការធ្វើឧច្ចារៈ បស្សាវៈ ខ្ញុំមានកិរិយាដឹងច្បាស់ ក្នុងការដើរ ឈរ អង្គុយ ដេកលក់ ភ្ញាក់ និយាយ នៅស្ងៀម ។

(១៧៥) ខ្ញុំនោះ បរិបូណ៌ ដោយសីលក្ខន្ធដ៏ប្រសើរនេះផង បរិបូណ៌ ដោយឥន្ទ្រិយសំវរៈដ៏ប្រសើរនេះផង បរិបូណ៌ ដោយសតិនិងសម្បជញ្ញៈដ៏ប្រសើរនេះផង ក៏អាស្រ័យនៅនឹងសេនាសនៈដ៏ស្ងាត់ គឺព្រៃ ម្លប់ឈើ ភ្នំ ជ្រោះភ្នំ ព្រៃស្មសាន ដងព្រៃ ទីវាល គំនរចំបើង ។ ខ្ញុំនោះ ត្រឡប់មកពីបិណ្ឌបាតវិញ ក្នុងវេលាក្រោយភត្ត ក៏អង្គុយ

បល្លង្កំ អាភុជិត្វា ឧជុំ កាយំ បណិធាយ បរិមុខំ សតឹ ឧបដ្ឋបេត្វា ។ សោ អភិជ្ឈំ លោកេ បហាយ វិគតាភិជ្ឈេន ចេតសា វិហរតិ អភិជ្ឈាយ ចិត្តំ បរិសោធេតិ ព្យាបាទប្បទោសំ បហាយ អព្យាបន្នចិត្តោ វិហរតិ សព្វបាណភូតហិតានុកម្បី ព្យាបាទប្បទោសា ចិត្តំ បរិសោធេតិ ថីនមិទ្ធំ បហាយ វិគតថីនមិទ្ធោ វិហរតិ អាលោកសញ្ញី សតោ សម្បជានោ ថីនមិទ្ធា ចិត្តំ បរិសោធេតិ ឧទ្ធច្ចកុក្កុច្ចំ បហាយ អនុទ្ធតោ វិហរតិ អជ្ឈត្តំ វូបសន្តចិត្តោ ឧទ្ធច្ចកុក្កុច្ចា ចិត្តំ បរិសោធេតិ វិចិកិច្ឆំ បហាយ តិណ្ណវិចិកិច្ឆោ វិហរតិ អកថំកថី កុសលេសុ ធម្មេសុ វិចិកិច្ឆាយ ចិត្តំ បរិសោធេតិ ។

[១៧៦] សោ បញ្ច[1] នីវរណេ បហាយ ចេតសោ ឧបក្កិលេសេ បញ្ញាយ ទុព្វលីករណេ វិវិច្ចេវ កាមេហិ

១ ឱ. ឥមេ បញ្ច ឥតិ ទិស្សតិ ។ ម. សោ ឥមេ បញ្ច ឥតិ ទិស្សតិ ។

តែនៅក្នុងតម្រង់កាយឲ្យត្រង់ តាំងសតិបំពោះទៅរកកម្មដ្ឋាន ។ ខ្ញុំនោះ លះបង់នូវអភិជ្ឈាក្នុងលោកចេញ មានចិត្តប្រាសចាកអភិជ្ឈា ជម្រះចិត្តចាកអភិជ្ឈា លះបង់នូវព្យាបាទនិងសេចក្តីប្រទូស្ត មានចិត្តមិនព្យាបាទ ជាអ្នកអនុគ្រោះដោយប្រយោជន៍ដល់ពួកសត្វ ជម្រះចិត្តចាកព្យាបាទនិងសេចក្តីប្រទូស្ត លះបង់ថីនមិទ្ធៈ ប្រាសចាកថីនមិទ្ធៈ មានសេចក្តីសំគាល់នូវពន្លឺ មានសតិនិងសម្បជញ្ញៈ ជម្រះចិត្តចាកថីនមិទ្ធៈ លះបង់ឧទ្ធច្ចកុក្កុច្ចៈ មិនមានចិត្តអណ្តែតអណ្តូង មានចិត្តស្ងប់រម្ងាប់ក្នុងសន្តាន ជម្រះចិត្តចាកឧទ្ធច្ចកុក្កុច្ចៈ លះបង់វិចិកិច្ឆា ឆ្លងផុតវិចិកិច្ឆា មិនងឿងឆ្ងល់ ក្នុងធម៌ទាំងឡាយជាកុសល ជម្រះចិត្តចាកវិចិកិច្ឆា ។

(១៧៦) ខ្ញុំនោះ លះបង់នូវនីវរណៈទាំង៥ដែលជាឧបក្កិលេសរបស់ចិត្ត ជាធម្មជាតធ្វើប្រាជ្ញាឲ្យមានកម្លាំងថយចុះ ស្ងាត់ចាកកាមទាំងឡាយ

វិវិច្ច អកុសលេហិ ធម្មេហិ សវិតក្កំ សវិចារំ វិវេកជំ បីតិសុខំ បឋមំ ឈានំ ឧបសម្បជ្ជ វិហាសិ វិតក្កវិចារានំ វូបសមា អជ្ឈត្តំ សម្បសាទនំ ចេតសោ ឯកោទិភាវំ អវិតក្កំ អវិចារំ សមាធិជំ បីតិសុខំ ទុតិយំ ឈានំ... តតិយំ ឈានំ... ចតុត្ថំ ឈានំ ឧបសម្បជ្ជ វិហាសិ ។

(១៧៧) សោ[1] ឯវំ សមាហិតេ ចិត្តេ បរិសុទ្ធេ បរិយោទាតេ អនង្គណេ វិគតូបក្កិលេសេ មុទុភូតេ កម្មនិយេ ឋិតេ អានេញ្ជប្បត្តេ អាសវានំ ខយញ្ញាណាយ ចិត្តំ អភិនិន្នាមេសិ ។ សោ ឥទំ ទុក្ខន្តិ យថាភូតំ អព្ភញ្ញាសិ អយំ ទុក្ខសមុទយោតិ យថាភូតំ អព្ភញ្ញាសិ អយំ ទុក្ខនិរោធោតិ យថាភូតំ អព្ភញ្ញាសិ អយំ ទុក្ខនិរោធគាមិនី បដិបទាតិ យថាភូតំ អព្ភញ្ញាសិ ឥមេ អាសវាតិ យថាភូតំ អព្ភញ្ញាសិ អយំ អាសវសមុទយោតិ យថាភូតំ អព្ភញ្ញាសិ អយំ អាសវនិរោធោតិ យថាភូតំ អព្ភញ្ញាសិ

---

១ ឱ. សោតិ ន ទិស្សតិ ។

ស្ងាត់ចាកអកុសលធម៌ទាំងឡាយ ក៏ចូលដល់បឋមជ្ឈាន ដែលមានវិតក្កៈ វិចារៈ និងបីតិ សុខៈ ដែលកើតពីវិវេក ព្រោះរម្ងាប់នូវវិតក្កៈ និងវិចារៈ ក៏ចូលដល់ទុតិយជ្ឈាន ប្រកបដោយសេចក្ដីជ្រះថ្លាក្នុងសន្ដាន មានសភាពជាចិត្តខ្ពស់ឯក មិនមានវិតក្កៈនិងវិចារៈទេ មានតែបីតិនិងសុខៈ ដែលកើតពីសមាធិប៉ុណ្ណោះ ... ចូលដល់តតិយជ្ឈាន ... ចូលដល់ចតុត្ថជ្ឈាន សម្រេចសម្រាន្តនៅដោយឥរិយាបថ ។

(១៥៧) កាលបើចិត្តតាំងមាំ បរិសុទ្ធ ផូរផង់ មិនមានទីទួលគឺកិលេស ប្រាសចាកឧបក្កិលេស មានសភាពជាចិត្តទន់ គួរដល់ការនាកម្ម ជាចិត្តនឹងធឹង មិនរំជួយដោយអារម្មណ៍យ៉ាងនេះហើយ ខ្ញុំនោះ ក៏បង្អោនចិត្តទៅដើម្បីប្រាជ្ញាជាគ្រឿងអស់នៃអាសវៈទាំងឡាយ ។ ខ្ញុំនោះដឹងច្បាស់តាមពិតថា នេះជាទុក្ខ ដឹងច្បាស់តាមពិតថា នេះជាហេតុនាំឲ្យកើតទុក្ខ ដឹងច្បាស់តាមពិតថា នេះជាសេចក្ដីរលត់ទុក្ខ ដឹងច្បាស់តាមពិតថា នេះបដិបទាជាដំណើរទៅកាន់សេចក្ដីរលត់ទុក្ខ ដឹងច្បាស់តាមពិតថា នេះជាពួកអាសវៈ ដឹងច្បាស់តាមពិតថា នេះជាហេតុនាំឲ្យកើតអាសវៈ ដឹងច្បាស់តាមពិតថា នេះជាសេចក្ដីរលត់អាសវៈ

អយំ អាសវានំ ខយគាមិនី បដិបទាតិ យថាភូតំ អព្ភញ្ញាសឹ ។ តស្ស មេ ឯវំ ជានតោ ឯវំ បស្សតោ កាមាសវាបិ ចិត្តំ វិមុច្ចិត្ថ ភវាសវាបិ ចិត្តំ វិមុច្ចិត្ថ អវិជ្ជាសវាបិ ចិត្តំ វិមុច្ចិត្ថ វិមុត្តស្មឹ វិមុត្តមិតិ ញាណំ អហោសិ ខីណា ជាតិ វុសិតំ ព្រហ្មចរិយំ កតំ ករណីយំ នាបរំ ឥត្ថត្តាយាតិ អព្ភញ្ញាសឹ ។ ឯវំ ខោ មេ អាវុសោ ជានតោ ឯវំ បស្សតោ ឥមស្មិញ្ច សវិញ្ញាណកេ កាយេ ពហិទ្ធា ច (១) សព្ពនិមិត្តេសុ អហង្ការមមង្ការមានានុសយា សុសមូហតាតិ ។ តស្ស ភិក្ខវេ ភិក្ខុនោ សាធូតិ ភាសិតំ អភិនន្ទិតព្វំ អនុមោទិតព្វំ ។ សាធូតិ ភាសិតំ អភិនន្ទិត្វា អនុមោទិត្វា ឯវមស្ស វចនីយោ លាភា នោ អាវុសោ សុលទ្ធំ នោ អាវុសោ

១ ម. សព្ព ន ទិស្សតិ ។

ដឹងច្បាស់តាមពិតថា នេះបដិបទាជាដំណើរទៅកាន់សេចក្ដីរលត់អាសវៈ ។ កាលខ្ញុំនោះ ដឹងយ៉ាងនេះ ឃើញយ៉ាងនេះ ចិត្តក៏រួចចាកកាមាសវៈផង ចិត្តក៏រួចចាកភវាសវៈផង ចិត្តក៏រួចចាកអវិជ្ជាសវៈផង កាលបើចិត្តរួចស្រឡះហើយ ខ្ញុំក៏មានញាណ (ដឹងច្បាស់) ថា ចិត្តរបស់អាត្មាអញរួចស្រឡះហើយ ខ្ញុំបានដឹងច្បាស់ថា ជាតិអស់ហើយ ព្រហ្មចរិយៈអាត្មាអញបាននៅរួចហើយ កិច្ចដែលត្រូវធ្វើ អាត្មាអញបានធ្វើរួចហើយ មិនមានកិច្ចដទៃក្រៅពីនេះទៀតទេ ។ ភិក្ខុនោះនិយាយថា ម្នាលអាវុសោ កាលបើខ្ញុំដឹងយ៉ាងនេះ ឃើញយ៉ាងនេះ ខ្ញុំក៏ដកនូវអហង្ការមមង្ការមានានុស័យ ក្នុងកាយដែលប្រកបដោយវិញ្ញាណនេះផង ក្នុងនិមិត្តទាំងអស់ខាងក្រៅនេះផង ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុត្រូវត្រេកអរ អនុមោទនានឹងភាសិតរបស់ភិក្ខុនោះថា សាធុ ។ លុះភិក្ខុត្រេកអរ អនុមោទនានឹងភាសិតថា សាធុ ហើយ ត្រូវនិយាយថា ម្នាលអាវុសោ យើងពេញជាមានលាភ ម្នាលអាវុសោ អត្តភាពជាមនុស្សយើងបានល្អហើយ

យេ មយំ អាយស្មន្តំ តាទិសំ សព្រហ្មចារឹ សម-នុបស្សាមាតិ[១] ។ ឥទមវោច ភគវា អត្តមនា តេ ភិក្ខូ ភគវតោ ភាសិតំ អភិនន្ទុន្តិ ។

ឆវិសោធនសុត្តំ ទុតិយំ និដ្ឋិតំ ។

---

១ ឱ. ព្រហ្មចារឹ បស្សាមាតិ ។

ដោយយើងបានឃើញលោកមានអាយុ ជាអ្នកប្រព្រឹត្តធម៌ល្អប្រាកដ ដូច្នោះ ។ លុះព្រះមានព្រះភាគ បានសំដែងសូត្រនេះចប់ហើយ ភិក្ខុទាំងនោះ ក៏មានសេចក្តីពេញចិត្ត ត្រេកអរនឹងភាសិតរបស់ព្រះមានព្រះភាគ ។

ចប់ ឆព្វិសោធនសូត្រ ទី ២ ។

# តតិយំ សប្បុរិសសុត្តំ

(១៧៨) ឯវម្មេ សុតំ ។ ឯកំ សមយំ ភគវា សាវត្ថិយំ វិហរតិ ជេតវនេ អនាថបិណ្ឌិកស្ស អា-រាមេ ។ តត្រ ខោ ភគវា ភិក្ខូ អាមន្តេសិ ភិក្ខវោតិ ។ ភទន្តេតិ តេ ភិក្ខូ ភគវតោ បច្ចស្សោសុំ ។ ភគវា ឯតទវោច សប្បុរិសធម្មញ្ច វោ ភិក្ខវេ ទេសេស្សាមិ អសប្បុរិសធម្មញ្ច តំ សុណាថ សាធុកំ មនសិករោថ ភាសិស្សាមីតិ ។ ឯវំ ភន្តេតិ ខោ តេ ភិក្ខូ ភគវតោ បច្ចស្សោសុំ ។

(១៧៩) ភគវា ឯតទវោច កតមោ ច ភិក្ខវេ អសប្បុរិសធម្មោ ។ ឥធ ភិក្ខវេ អ-សប្បុរិសោ ឧច្ចាកុលា បព្វជិតោ ហោតិ ។ សោ ឥតិ បដិសញ្ចិក្ខតិ អហំ ខោម្ហិ ឧច្ចាកុលា

# សប្បុរិសសូត្រ ទី ៣

(១៧៨) ខ្ញុំបានស្តាប់មកយ៉ាងនេះ ។ សម័យមួយ ព្រះមានព្រះភាគ គង់ក្នុងវត្តជេតពន របស់អនាថបិណ្ឌិកសេដ្ឋី ជិតក្រុងសាវត្ថី ។ សម័យនោះ ព្រះមានព្រះភាគ ត្រាស់ហៅពួកភិក្ខុថា ម្នាលភិក្ខុទាំងឡាយ ។ ភិក្ខុទាំងនោះ បានទទួលព្រះពុទ្ធដីកា របស់ព្រះមានព្រះភាគថា ព្រះករុណាព្រះអង្គដ៏ចម្រើន ។ ព្រះមានព្រះភាគបានត្រាស់ពាក្យនេះថា ម្នាលភិក្ខុទាំងឡាយ តថាគត នឹងសំដែងនូវសប្បុរិសធម៌ និងអសប្បុរិសធម៌ដល់អ្នកទាំងឡាយ អ្នកទាំងឡាយ ចូរស្តាប់ធម៌នោះ ចូរធ្វើទុកក្នុងចិត្តឲ្យប្រពៃចុះ តថាគតនឹងសំដែង ។ ភិក្ខុទាំងនោះ ទទួលត្រង់ត្រាប់ភាសិតរបស់ព្រះមានព្រះភាគថា ព្រះករុណាព្រះអង្គ ។

(១៧៩) ព្រះមានព្រះភាគ ទ្រង់ត្រាស់ដូច្នេះថា ម្នាលភិក្ខុទាំងឡាយ ចុះអសប្បុរិសធម៌ តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ ក្នុងលោកនេះ មានមនុស្សអសប្បុរស ចេញចាកត្រកូលខ្ពស់[១] ហើយបួស ។ អសប្បុរសនោះ ពិចារណាឃើញដូច្នេះថា អញចេញពីត្រកូលខ្ពស់

---

១ ត្រកូលខ្ពស់ មាន ២ គឺខត្តិយត្រកូល ១ ព្រាហ្មណត្រកូល ១ ។ អដ្ឋកថា ។

បព្វជិតោ ឥមេ បនញ្ញេ ភិក្ខូ ន ឧច្ចាកុលា បព្វជិតាតិ ។ សោ តាយ ឧច្ចាកុលីនតាយ អត្តានុក្កំសេតិ បរំ វម្ភេតិ អយំ ភិក្ខវេ អសប្បុរិសធម្មោ ។ សប្បុរិសោ ច ខោ ភិក្ខវេ ឥតិ បដិសញ្ចិក្ខតិ ន ខោ ឧច្ចាកុលីនតាយ លោភធម្មា វា បរិក្ខយំ គច្ឆន្តិ ទោសធម្មា វា បរិក្ខយំ គច្ឆន្តិ មោហធម្មា វា បរិក្ខយំ គច្ឆន្តិ នោ ចេបិ ឧច្ចាកុលា បព្វជិតោ ហោតិ សោ ច ហោតិ ធម្មានុធម្មប្បដិបន្នោ សាមីចិប្បដិបន្នោ អនុធម្មចារី សោ តត្ថ បុជ្ជោ សោ តត្ថ បាសំសោតិ ។ សោ បដិបទំយេវ អន្តរំ ករិត្វា តាយ ឧច្ចាកុលីនតាយ នេវត្តានុក្កំសេតិ ន បរំ វម្ភេតិ អយំ ភិក្ខវេ សប្បុរិសធម្មោ ។

មកបួស ឯពួកភិក្ខុដទៃទាំងនេះ មិនមែនចេញពីត្រកូលខ្ពស់មកបួសទេ ។ អសប្បុរសនោះ រមែងលើកខ្លួនឯង បន្តុះបង្អាប់អ្នកដទៃ ព្រោះតែខ្លួនមានត្រកូលខ្ពស់នោះ ម្នាលភិក្ខុទាំងឡាយ នេះឯងឈ្មោះថា អសប្បុរិសធម៌ ។ ម្នាលភិក្ខុទាំងឡាយ ឯសប្បុរសតែងពិចារណាឃើញដូច្នេះថា លោភធម៌ទាំងឡាយ អស់ទៅក្តី ទោសធម៌ទាំងឡាយ អស់ទៅក្តី មោហធម៌ទាំងឡាយ អស់ទៅក្តី មិនមែនព្រោះតែកើតក្នុងត្រកូលខ្ពស់ទេ ប្រសិនបើ បុគ្គលមិនចេញចាកត្រកូលខ្ពស់មកបួសទេ តែអ្នកនោះប្រតិបត្តិធម៌តាមធម៌ ប្រតិបត្តិគួរដល់សេចក្តីកោតក្រែង ប្រតិបត្តិសមគួរតាមធម៌ ភិក្ខុនោះ គួរជាទីបូជារបស់ភិក្ខុទាំងនោះ ភិក្ខុនោះគួរជាទីសរសើររបស់ភិក្ខុទាំងនោះ ។ ភិក្ខុនោះធ្វើនូវបដិបទាឲ្យតាំងនៅខាងក្នុង ហើយមិនតម្កើងខ្លួនឯង មិនបន្តុះបង្អាប់អ្នកដទៃ ព្រោះហេតុតែខ្លួនកើតក្នុងត្រកូលខ្ពស់នោះឡើយ ម្នាលភិក្ខុទាំងឡាយ នេះឯង ឈ្មោះថាសប្បុរិសធម៌ ។

១៨០) បុន ចបរំ ភិក្ខវេ អសប្បុរិសោ មហាកុលា បព្វជិតោ ហោតិ មហាភោគកុលា បព្វជិតោ ហោតិ ឧឡារភោគកុលា បព្វជិតោ ហោតិ ។ សោ ឥតិ បដិសញ្ចិក្ខតិ អហំ ខោម្ហិ ឧឡារភោគកុលា បព្វជិតោ ឥមេ បនញ្ញេ ន ឧឡារភោគកុលា បព្វជិតាតិ ។ សោ តាយ ឧឡារភោគតាយ អត្តានុក្កំសេតិ បរំ វម្ភេតិ អយម្បិ ភិក្ខវេ អសប្បុរិសធម្មោ ។ សប្បុរិសោ ច ខោ ភិក្ខវេ ឥតិ បដិសញ្ចិក្ខតិ ន ខោ ឧឡារភោគតាយ លោភធម្មា វា បរិក្ខយំ គច្ឆន្តិ ទោសធម្មា វា បរិក្ខយំ គច្ឆន្តិ មោហធម្មា វា បរិក្ខយំ គច្ឆន្តិ នោ ចេបិ ឧឡារភោគកុលា បព្វជិតោ ហោតិ សោ ច ហោតិ ធម្មានុធម្មប្បដិបន្នោ សាមីចិប្បដិបន្នោ អនុធម្មចារី សោ តត្ថ បុជ្ជោ សោ តត្ថ បាសំសោ ។

## អនុបទវគ្គ សប្បុរិសសូត្រ ធម៌របស់សប្បុរសនិងអសប្បុរស

(១៨០) ម្នាលភិក្ខុទាំងឡាយ មួយទៀត មនុស្សអសប្បុរសចេញចាកមហាត្រកូល[1] មកបួស ចេញចាកមហាភោគត្រកូល[2] មកបួស ចេញចាកឧឡារភោគត្រកូល[3] មកបួស ។ អសប្បុរសនោះ ពិចារណាឃើញដូច្នេះថា អញចេញចាកឧឡារភោគត្រកូលមកបួស ឯពួកភិក្ខុដទៃទាំងនេះ មិនមែនចេញចាកឧឡារភោគត្រកូលមកបួសទេ ។ អសប្បុរសនោះ រមែងលើកតម្កើងខ្លួនឯង បន្តុះបង្អាប់អ្នកដទៃ ព្រោះតែខ្លួនកើតក្នុងឧឡារភោគត្រកូលនោះ ម្នាលភិក្ខុទាំងឡាយ នេះឈ្មោះថាអសប្បុរិសធម៌ ។ ម្នាលភិក្ខុទាំងឡាយ សប្បុរសតែងពិចារណាឃើញដូច្នេះថា លោភធម៌ទាំងឡាយ អស់ទៅក្តី ទោសធម៌ទាំងឡាយ អស់ទៅក្តី មោហធម៌ទាំងឡាយ អស់ទៅក្តី មិនមែនព្រោះតែកើតក្នុងឧឡារភោគត្រកូលនោះឡើយ ប្រសិនបើបុគ្គល មិនចេញចាកឧឡារភោគត្រកូលមកបួសទេ តែជាមនុស្សប្រតិបត្តិតាមធម៌ សមគួរដល់ធម៌ ប្រតិបត្តិដោយសេចក្តីគោរពក្រែង ប្រព្រឹត្តតាមធម៌ ភិក្ខុនោះ គួរជាទីបូជារបស់ភិក្ខុទាំងនោះ ភិក្ខុនោះ គួរជាទីសរសើររបស់ភិក្ខុទាំងនោះ ។

---

១ មហាត្រកូល គឺខត្តិយត្រកូល១ ព្រាហ្មណត្រកូល១ វេស្សត្រកូល១ ។ ២ មហាភោគត្រកូល គឺត្រកូលដែលបរិបូណ៌ដោយភោគៈច្រើន ។ ៣ ឧឡារភោគត្រកូល គឺត្រកូលដែលពេញដោយភោគៈដ៏ប្រសើរលើសលប ។ អដ្ឋកថា ។

សោ បដិបទំយេវ អន្តរំ ករិត្វា តាយ ឧឡារភោគ-តាយ នេវត្តានុក្កំសេតិ ន បរំ វម្ភេតិ អយម្បិ ភិក្ខវេ សប្បុរិសធម្មោ ។

(១៩១) បុន ចបរំ ភិក្ខវេ អសប្បុរិសោ ញាតោ ហោតិ យសស្សី ។ សោ ឥតិ បដិសញ្ចិក្ខតិ អហំ ខោម្ហិ ញាតោ យសស្សី ឥមេ បនញ្ញេ ភិក្ខូ អប្បញ្ញាតា អប្បេសក្ខាតិ ។ សោ តេន ញាតត្តេន អត្តានុក្កំសេតិ បរំ វម្ភេតិ អយម្បិ ភិក្ខវេ អសប្បុរិសធម្មោ ។ សប្បុរិសោ ច ខោ ភិក្ខវេ ឥតិ បដិសញ្ចិក្ខតិ ន ខោ ញាតត្តេន លោភធម្មា វា បរិក្ខយំ គច្ឆន្តិ ទោសធម្មា វា បរិក្ខយំ គច្ឆន្តិ មោហធម្មា វា បរិក្ខយំ គច្ឆន្តិ នោ ចេបិ ញាតោ ហោតិ យសស្សី សោ ច ហោតិ ធម្មានុធម្មប្បដិបន្នោ សាមីចិប្បដិបន្នោ

ភិក្ខុនោះ ធ្វើនូវបដិបទាឲ្យត្រង់ទៅខាងក្នុង ហើយមិនលើកតម្កើងខ្លួនឯង មិនបន្តុះបង្អាប់អ្នកដទៃ ព្រោះតែខ្លួនកើតក្នុងមហាភោគត្រកូលនោះទេ ម្នាលភិក្ខុទាំងឡាយ នេះឯង ឈ្មោះថាសប្បុរិសធម៌ ។

(១៨១) ម្នាលភិក្ខុទាំងឡាយ មួយទៀត អសប្បុរស ជាអ្នកមានកេរ្តិ៍ឈ្មោះ មានយសបរិវារ ។ អសប្បុរសនោះ តែងពិចារណាឃើញដូច្នេះថា អាត្មាអញជាអ្នកមានកេរ្តិ៍ឈ្មោះ មានយសបរិវារ ឯពួកភិក្ខុដទៃទាំងនេះ មិនមានកេរ្តិ៍ឈ្មោះ មានបុណ្យស័ក្តិតិច ។ អសប្បុរសនោះ រមែងលើកតម្កើងខ្លួនឯង បន្តុះបង្អាប់អ្នកដទៃ ព្រោះតែខ្លួនមានកេរ្តិ៍ឈ្មោះនោះ ម្នាលភិក្ខុទាំងឡាយ នេះឯង ឈ្មោះថាអសប្បុរិស-ធម៌ ។ ម្នាលភិក្ខុទាំងឡាយ ឯសប្បុរស តែងពិចារណាឃើញដូច្នេះថា លោភធម៌ទាំងឡាយ អស់ទៅក្តី ទោសធម៌ទាំងឡាយ អស់ទៅក្តី មោហ-ធម៌ទាំងឡាយ អស់ទៅក្តី មិនមែនព្រោះតែខ្លួនមានកេរ្តិ៍ឈ្មោះឡើយ ប្រសិនបើបុគ្គលមិនមានកេរ្តិ៍ឈ្មោះ មិនមានយសបរិវារទេ តែគេជាអ្នកប្រតិបត្តិតាមធម៌ សមគួរដល់ធម៌ ប្រតិបត្តិដោយសេចក្តីកោតក្រែង

អនុធម្មចារី សោ តត្ថ បុជ្ជោ សោ តត្ថ បាសំសោតិ ។ សោ បដិបទំយេវ អន្តរំ ករិត្វា តេន ញាតត្តេន នេវត្តានុក្កំសេតិ ន បរំ វម្ភេតិ អយម្បិ ភិក្ខវេ សប្បុរិសធម្មោ ។

(១៨២) បុន ចបរំ ភិក្ខវេ អសប្បុរិសោ លាភី ហោតិ ចីវរបិណ្ឌបាតសេនាសនគិលានប្បច្ចយភេសជ្ជបរិក្ខារានំ ។ សោ ឥតិ បដិសញ្ចិក្ខតិ អហំ ខោម្ហិ លាភី ចីវរបិណ្ឌបាតសេនាសនគិលានប្បច្ចយភេសជ្ជបរិក្ខារានំ ឥមេ បនញ្ញេ ភិក្ខូ ន លាភិនោ ចីវរបិណ្ឌបាតសេនាសនគិលានប្បច្ចយភេសជ្ជបរិក្ខារានន្តិ ។ សោ តេន លាភេន អត្តានុក្កំសេតិ បរំ វម្ភេតិ អយម្បិ ភិក្ខវេ អសប្បុរិសធម្មោ ។ សប្បុរិសោ ច ខោ ភិក្ខវេ ឥតិ បដិសញ្ចិក្ខតិ ន ខោ លាភេន លោភធម្មា វា បរិក្ខយំ គច្ឆន្តិ

ប្រព្រឹត្តតាមធម៌ ភិក្ខុនោះ គួរជាទីបូជារបស់ភិក្ខុទាំងនោះ ភិក្ខុនោះ គួរជាទីសរសើររបស់ភិក្ខុទាំងនោះ ។ ភិក្ខុនោះ ធ្វើនូវបដិបទាឲ្យតាំងនៅខាងក្នុង មិនលើកតម្កើងខ្លួនឯង មិនបន្តុះបង្អាប់អ្នកដទៃ ព្រោះហេតុតែខ្លួនមានកេរ្តិ៍ឈ្មោះនោះឡើយ ម្នាលភិក្ខុទាំងឡាយ នេះឯង ឈ្មោះជាសប្បុរិសធម៌ ។

(១៨៤) ម្នាលភិក្ខុទាំងឡាយ មួយទៀត អសប្បុរស ដែលជាអ្នកបាននូវចីវរ បិណ្ឌបាត សេនាសនៈ គិលានប្បច្ច័យភេសជ្ជបរិក្ខារទាំងឡាយ ។ អសប្បុរសនោះ តែងពិចារណាឃើញដូច្នេះថា អាត្មាអញ ជាអ្នកបាននូវចីវរ បិណ្ឌបាត សេនាសនៈ គិលានប្បច្ច័យភេ-សជ្ជបរិក្ខារទាំងឡាយ ឯពួកភិក្ខុទាំងនេះ មិនដែលបានចីវរ បិណ្ឌបាត សេនាសនៈ គិលានប្បច្ច័យភេសជ្ជបរិក្ខារទាំងឡាយទេ ។ ភិក្ខុនោះ លើកតម្កើងខ្លួនឯង បន្តុះបង្អាប់អ្នកដទៃ ព្រោះហេតុតែលាភនោះ ម្នាលភិក្ខុទាំងឡាយ នេះឯង ឈ្មោះជាអសប្បុរិសធម៌ ។ ម្នាលភិក្ខុទាំងឡាយ សប្បុរស តែងពិចារណាឃើញដូច្នេះថា លោភធម៌ទាំងឡាយ អស់ទៅក្តី

ទោសធម្មា វា បរិក្ខយំ គច្ឆន្តិ មោហធម្មា វា បរិក្ខយំ គច្ឆន្តិ សោ ចេបិ លាភី ហោតិ ចីវរបិណ្ឌបាតសេនាសនគិលានប្បច្ចយភេសជ្ជបរិក្ខារានំ សោ ច ហោតិ ធម្មានុធម្មប្បដិបន្នោ សាមីចិប្បដិបន្នោ អនុធម្មចារី សោ តត្ថ បុជ្ជោ សោ តត្ថ បាសំសោតិ ។ សោ បដិបត្តិំយេវ អន្តរំ ករិត្វា តេន លាភេន នេវត្តានុក្កំសេតិ ន បរំ វម្ភេតិ អយម្បិ ភិក្ខវេ សប្បុរិសធម្មោ ។

(១៨.៣) បុន ចបរំ ភិក្ខវេ អសប្បុរិសោ ពហុស្សុតោ ហោតិ ។ សោ ឥតិ បដិសញ្ចិក្ខតិ អហំ ខោម្ហិ ពហុស្សុតោ ឥមេ បនញ្ញេ ភិក្ខូ ន ពហុស្សុតាតិ ។ សោ តេន ពាហុសច្ចេន អត្តានុក្កំសេតិ បរំ វម្ភេតិ អយម្បិ ភិក្ខវេ អសប្បុរិសធម្មោ ។

ទោសធម៌ទាំងឡាយ អស់ទៅក្តី មោហធម៌ទាំងឡាយ អស់ទៅក្តី មិនមែនព្រោះតែលាភទេ បើភិក្ខុមិនខ្ជាប់បានចីវរ បិណ្ឌបាត សេនាសនៈ គិលានប្បច្ច័យភេសជ្ជបរិក្ខារទាំងឡាយទេ តែភិក្ខុនោះ ជាអ្នកប្រតិបត្តិតាមធម៌សមគួរដល់ធម៌ ជាអ្នកប្រតិបត្តិដោយសេចក្តីកោតក្រែង ជាអ្នកប្រព្រឹត្តតាមធម៌ ភិក្ខុនោះ ក៏គួរជាទីបូជារបស់ភិក្ខុទាំងនោះ ភិក្ខុនោះ គួរជាទីសរសើររបស់ភិក្ខុទាំងនោះ ។ ភិក្ខុនោះ ធ្វើនូវបដិបទាឲ្យតាំងនៅខាងក្នុង ហើយមិនលើកតម្កើងខ្លួនឯង មិនបន្តុះបង្អាប់អ្នកដទៃ ព្រោះហេតុតែលាភនោះទេ ម្នាលភិក្ខុទាំងឡាយ នេះឯង ឈ្មោះថា សប្បុរិសធម៌ ។

(១៨៣) ម្នាលភិក្ខុទាំងឡាយ មួយទៀត អសប្បុរស ជាពហុស្សុត ។ អសប្បុរសនោះ តែងពិចារណាឃើញដូច្នេះថា អាត្មាអញជាពហុស្សុត ឯពួកភិក្ខុឯទៀតទាំងនេះ មិនមែនជាពហុស្សុតទេ ។ អសប្បុរសនោះ លើកតម្កើងខ្លួនឯង បន្តុះបង្អាប់អ្នកដទៃ ព្រោះហេតុតែពហុស្សុតនោះ ម្នាលភិក្ខុទាំងឡាយ នេះឯង ឈ្មោះថាអសប្បុរិសធម៌ ។

សប្បុរិសោ ច ខោ ភិក្ខវេ ឥតិ បដិសញ្ចិក្ខតិ ន ខោ ពាហុសច្ចេន លោភធម្មា វា បរិក្ខយំ គច្ឆន្តិ ទោសធម្មា វា បរិក្ខយំ គច្ឆន្តិ មោហធម្មា វា បរិក្ខយំ គច្ឆន្តិ នោ ចេបិ ពហុស្សុតោ ហោតិ សោ ច ហោតិ ធម្មានុធម្មប្បដិបន្នោ សាមីចិប្បដិបន្នោ អនុធម្មចារី សោ តត្ថ បុជ្ជោ សោ តត្ថ បាសំសោតិ ។ សោ បដិបទំយេវ អន្តរំ ករិត្វា តេន ពាហុសច្ចេន នេវត្តានុក្កំសេតិ ន បរំ វម្ភេតិ អយម្បិ ភិក្ខវេ សប្បុរិសធម្មោ ។

(១៨៤) បុន ចបរំ ភិក្ខវេ អសប្បុរិសោ វិនយធរោ ហោតិ ។ សោ ឥតិ បដិសញ្ចិក្ខតិ

ម្នាលភិក្ខុទាំងឡាយ សប្បុរស តែងពិចារណាឃើញដូច្នេះថា លោភធម៌ទាំងឡាយ អស់ទៅក្តី ទោសធម៌ទាំងឡាយ អស់ទៅក្តី មោហធម៌ទាំងឡាយ អស់ទៅក្តី មិនព្រោះតែពហុស្សុតទេ បើភិក្ខុមិនមែនជាពហុស្សុតទេ តែភិក្ខុនោះប្រតិបត្តិតាមធម៌សមគួរដល់ធម៌ ប្រតិបត្តិដោយសេចក្តីគោរពក្រែង ជាអ្នកប្រព្រឹត្តតាមធម៌ ភិក្ខុនោះ គួរជាទីបូជារបស់ភិក្ខុទាំងនោះ ភិក្ខុនោះ គួរជាទីសរសើររបស់ភិក្ខុទាំងនោះ ។ ភិក្ខុនោះ ធ្វើនូវបដិបទាឲ្យតាំងនៅខាងក្នុង ហើយមិនលើកតម្កើងខ្លួនឯង មិនបន្តុះបង្អាប់អ្នកដទៃ ព្រោះហេតុតែពហុស្សុតនោះ ម្នាលភិក្ខុទាំងឡាយ នេះឯង ឈ្មោះថាសប្បុរិសធម៌ ។

(១៨៤) ម្នាលភិក្ខុទាំងឡាយ មួយទៀត អសប្បុរស ជាអ្នកទ្រទ្រង់នូវវិន័យ ។ អសប្បុរសនោះ តែងពិចារណាឃើញដូច្នេះថា

អហំ ខោម្ហិ វិនយធរោ ឥមេ បនញ្ញេ ភិក្ខូ ន វិនយធរាតិ ។ សោ តេន វិនយធរត្តេន អត្តានុក្កំសេតិ បរំ វម្ភេតិ អយម្បិ ភិក្ខវេ អសប្បុរិសធម្មោ ។ សប្បុរិសោ ច ខោ ភិក្ខវេ ឥតិ បដិសញ្ចិក្ខតិ ន ខោ វិនយធរត្តេន លោភធម្មា វា បរិក្ខយំ គច្ឆន្តិ ទោសធម្មា វា បរិក្ខយំ គច្ឆន្តិ មោហធម្មា វា បរិក្ខយំ គច្ឆន្តិ នោ ចេបិ វិនយធរោ ហោតិ សោ ច ហោតិ ធម្មានុធម្មប្បដិបន្នោ សាមីចិប្បដិបន្នោ អនុធម្មចារី សោ តត្ថ បុជ្ជោ សោ តត្ថ បាសំសោតិ ។ សោ បដិបទំយេវ អន្តរំ ករិត្វា តេន វិនយធរត្តេន នេវត្តានុក្កំសេតិ ន បរំ វម្ភេតិ អយម្បិ ភិក្ខវេ សប្បុរិសធម្មោ ។

អាត្មាអញជាអ្នកទ្រទ្រង់នូវវិន័យ ឯពួកភិក្ខុដទៃទាំងនេះ មិនមែនជាអ្នកទ្រទ្រង់នូវវិន័យទេ ។ ភិក្ខុនោះ លើកតម្កើងខ្លួនឯង បន្តុះបង្អាប់អ្នកដទៃ ព្រោះហេតុតែការទ្រទ្រង់នូវវិន័យនោះ ម្នាលភិក្ខុទាំងឡាយ នេះឯង ឈ្មោះថាអសប្បុរិសធម៌ ។ ម្នាលភិក្ខុទាំងឡាយ ឯសប្បុរស តែងពិចារណាឃើញដូច្នេះថា លោភធម៌ទាំងឡាយ អស់ទៅក្តី ទោសធម៌ទាំងឡាយ អស់ទៅក្តី មោហធម៌ទាំងឡាយ អស់ទៅក្តី មិនមែនព្រោះហេតុតែការទ្រទ្រង់នូវវិន័យទេ បើភិក្ខុមិនទ្រទ្រង់នូវវិន័យពិតមែន តែភិក្ខុនោះ ជាអ្នកប្រតិបត្តិតាមធម៌សមគួរដល់ធម៌ ប្រតិបត្តិដោយសេចក្តីកោតក្រែង ជាអ្នកប្រព្រឹត្តតាមធម៌ ភិក្ខុនោះគួរជាទីបូជារបស់ភិក្ខុទាំងនោះ ភិក្ខុនោះ គួរជាទីសរសើររបស់ភិក្ខុទាំងនោះ ។ ភិក្ខុនោះ ធ្វើនូវបដិបទាឲ្យតាំងនៅខាងក្នុង ហើយមិនលើកតំកើងខ្លួនឯង មិនបន្តុះបង្អាប់អ្នកដទៃ ព្រោះហេតុតែការទ្រទ្រង់នូវវិន័យនោះទេ ម្នាលភិក្ខុទាំងឡាយ នេះឯង ឈ្មោះថាសប្បុរិសធម៌ ។

(១៨៩) បុន ចបរំ ភិក្ខវេ អសប្បុរិសោ ធម្មកថិកោ ហោតិ ។ សោ ឥតិ បដិសញ្ចិក្ខតិ អហំ ខោម្ហិ ធម្មកថិកោ ឥមេ បនញ្ញេ ភិក្ខូ ន ធម្មកថិកាតិ ។ សោ តេន ធម្មកថិកត្តេន អត្តានុក្កំសេតិ បរំ វម្ភេតិ អយម្បិ ភិក្ខវេ អសប្បុរិសធម្មោ ។ សប្បុរិសោ ច ខោ ភិក្ខវេ ឥតិ បដិសញ្ចិក្ខតិ ន ខោ ធម្មកថិកត្តេន លោភធម្មា វា បរិក្ខយំ គច្ឆន្តិ ទោសធម្មា វា បរិក្ខយំ គច្ឆន្តិ មោហធម្មា វា បរិក្ខយំ គច្ឆន្តិ នោ ចេបិ ធម្មកថិកោ ហោតិ សោ ច ហោតិ ធម្មានុធម្មប្បដិបន្នោ សាមីចិប្បដិបន្នោ អនុធម្មចារី សោ តត្ថ បុជ្ជោ សោ តត្ថ បាសំសោតិ ។ សោ បដិបទំយេវ អន្តរំ ករិត្វា តេន ធម្មកថិកត្តេន នេវត្តានុក្កំសេតិ ន បរំ វម្ភេតិ អយម្បិ ភិក្ខវេ សប្បុរិសធម្មោ ។

អនុបទវគ្គ សប្បុរិសសូត្រ ធម៌របស់សប្បុរសនិងអសប្បុរស

(១៨៤) ម្នាលភិក្ខុទាំងឡាយ មួយទៀត អសប្បុរស ជាធម្មកថិក ។ អសប្បុរសនោះ ពិចារណាឃើញដូច្នេះថា អញជាធម្មកថិក ឯពួកភិក្ខុឯទៀតទាំងនេះ មិនមែនជាធម្មកថិកទេ ។ ភិក្ខុនោះលើកតំកើងខ្លួនឯង បន្តុះបង្អាប់អ្នកដទៃ ព្រោះហេតុតែខ្លួនជាធម្មកថិកនោះ ម្នាលភិក្ខុទាំងឡាយ នេះឯង ឈ្មោះថាអសប្បុរិសធម៌ ។ ម្នាលភិក្ខុទាំងឡាយ ឯសប្បុរស តែងពិចារណាឃើញដូច្នេះថា លោភធម៌ទាំងឡាយ អស់ទៅក្តី ទោសធម៌ទាំងឡាយ អស់ទៅក្តី មោហធម៌ទាំងឡាយ អស់ទៅក្តី មិនមែនព្រោះហេតុតែខ្លួនជាធម្មកថិកទេ បើភិក្ខុមិនមែនជាធម្មកថិកទេ តែភិក្ខុនោះប្រតិបត្តិតាមធម៌សមគួរដល់ធម៌ ប្រតិបត្តិដោយសេចក្តីគោរពក្រែង ប្រព្រឹត្តតាមធម៌ ភិក្ខុនោះ គួរជាទីបូជារបស់ភិក្ខុទាំងនោះ ភិក្ខុនោះ គួរជាទីសរសើររបស់ភិក្ខុទាំងនោះ ។ ភិក្ខុនោះធ្វើនូវបដិបទាឲ្យតាំងនៅខាងក្នុង ហើយមិនលើកតំកើងខ្លួនឯង មិនបន្តុះបង្អាប់អ្នកដទៃ ព្រោះហេតុតែខ្លួនជាធម្មកថិកនោះទេ ម្នាលភិក្ខុទាំងឡាយ នេះឯង ឈ្មោះថាសប្បុរិសធម៌ ។

(១៨៦) បុន ចបរំ ភិក្ខវេ អសប្បុរិសោ អារញ្ញកោ ហោតិ ។ សោ ឥតិ បដិសញ្ចិក្ខតិ អហំ ខោម្ហិ អារញ្ញកោ ឥមេ បនញ្ញេ ភិក្ខូ ន អារញ្ញកាតិ ។ សោ តេន អារញ្ញកត្តេន អត្តានុក្កំសេតិ បរំ វម្ភេតិ អយម្បិ ភិក្ខវេ អសប្បុរិសធម្មោ ។ សប្បុរិសោ ច ខោ ភិក្ខវេ ឥតិ បដិសញ្ចិក្ខតិ ន ខោ អារញ្ញកត្តេន លោភធម្មា វា បរិក្ខយំ គច្ឆន្តិ ទោសធម្មា វា បរិក្ខយំ គច្ឆន្តិ មោហធម្មា វា បរិក្ខយំ គច្ឆន្តិ នោ ចេបិ អារញ្ញកោ ហោតិ សោ ច ហោតិ ធម្មានុធម្មប្បដិបន្នោ សាមីចិប្បដិបន្នោ អនុធម្មចារី សោ តត្ថ បុជ្ជោ សោ តត្ថ បាសំសោតិ ។ សោ បដិបទំយេវ អន្តរំ ករិត្វា តេន អារញ្ញកត្តេន នេវត្តានុក្កំសេតិ ន បរំ វម្ភេតិ អយម្បិ ភិក្ខវេ សប្បុរិសធម្មោ ។

(១៨៦) ម្នាលភិក្ខុទាំងឡាយ មួយទៀត អសប្បុរស ជាអ្នកប្រព្រឹត្តនៅតែក្នុងព្រៃ ។ អសប្បុរសនោះ ពិចារណាឃើញដូច្នេះថា អាត្មាអញជាអ្នកនៅក្នុងព្រៃ ឯពួកភិក្ខុឯទៀតទាំងនេះ មិនមែនជាអ្នកប្រព្រឹត្តនៅក្នុងព្រៃទេ ។ ភិក្ខុនោះលើកតំកើងខ្លួនឯង បន្តុះបង្អាប់អ្នកដទៃ ព្រោះហេតុតែខ្លួនជាអ្នកនៅក្នុងព្រៃនោះ ម្នាលភិក្ខុទាំងឡាយ នេះឯង ឈ្មោះជាអសប្បុរសធម៌ ។ ម្នាលភិក្ខុទាំងឡាយ ឯសប្បុរស តែងពិចារណាឃើញដូច្នេះថា លោភធម៌ទាំងឡាយ អស់ទៅក្តី ទោស-ធម៌ទាំងឡាយ អស់ទៅក្តី មោហធម៌ទាំងឡាយ អស់ទៅក្តី មិនមែនព្រោះហេតុតែខ្លួនជាអ្នកនៅក្នុងព្រៃទេ បើភិក្ខុមិនមែនជាអ្នកនៅក្នុងព្រៃទេ តែភិក្ខុនោះ ប្រតិបត្តិតាមធម៌សមគួរដល់ធម៌ ប្រតិបត្តិដោយសេចក្តីគោរពក្រែង ប្រព្រឹត្តតាមធម៌ ភិក្ខុនោះ គួរជាទីបូជា របស់ភិក្ខុទាំងនោះ ភិក្ខុនោះ គួរជាទីសរសើរ របស់ភិក្ខុទាំងនោះ ។ ភិក្ខុនោះ ធ្វើនូវបដិបទាឲ្យតាំង នៅខាងក្នុង ហើយមិនលើកតំកើងខ្លួនឯង មិនបន្តុះបង្អាប់អ្នកដទៃ ព្រោះហេតុតែខ្លួននៅក្នុងព្រៃនោះឡើយ ម្នាលភិក្ខុទាំងឡាយ នេះឯង ឈ្មោះជាសប្បុរសធម៌ ។

(១៨៧) បុន ចបរំ ភិក្ខវេ អសប្បុរិសោ បំសុកូលិកោ ហោតិ ។ សោ ឥតិ បដិសញ្ចិក្ខតិ អហំ ខោម្ហិ បំសុកូលិកោ ឥមេ បនញ្ញេ ភិក្ខូ ន បំសុកូលិកាតិ ។ សោ តេន បំសុកូលិកត្តេន អត្តានុក្កំសេតិ បរំ វម្ភេតិ អយម្បិ ភិក្ខវេ អសប្បុរិសធម្មោ ។ សប្បុរិសោ ច ខោ ភិក្ខវេ ឥតិ បដិសញ្ចិក្ខតិ ន ខោ បំសុកូលិកត្តេន លោភធម្មា វា បរិក្ខយំ គច្ឆន្តិ ទោសធម្មា វា បរិក្ខយំ គច្ឆន្តិ មោហធម្មា វា បរិក្ខយំ គច្ឆន្តិ នោ ចេបិ បំសុកូលិកោ ហោតិ សោ ច ហោតិ ធម្មានុធម្មប្បដិបន្នោ សាមីចិប្បដិបន្នោ អនុធម្មចារី សោ តត្ថ បុជ្ជោ សោ តត្ថ បាសំសោតិ ។ សោ បដិបទំយេវ អន្តរំ ករិត្វា តេន បំសុកូលិកត្តេន នេវត្តានុក្កំសេតិ ន បរំ វម្ភេតិ អយម្បិ ភិក្ខវេ សប្បុរិសធម្មោ ។

(១៨៧) ម្នាលភិក្ខុទាំងឡាយ មួយទៀត អសប្បុរស ជាអ្នកប្រព្រឹត្តបង្សុកូល ។ អសប្បុរសនោះ ពិចារណាឃើញ ដូច្នេះថា អាត្មាអញជាអ្នកប្រព្រឹត្តបង្សុកូល ឯពួកភិក្ខុឯទៀតទាំងនេះ មិនមែនជាអ្នកប្រព្រឹត្តបង្សុកូលទេ ។ ភិក្ខុនោះ លើកតំកើងខ្លួនឯង បន្តុះបង្អាប់អ្នកដទៃ ព្រោះហេតុតែខ្លួនជាអ្នកប្រព្រឹត្តបង្សុកូលនោះ ម្នាលភិក្ខុទាំងឡាយ នេះឯង ឈ្មោះថាអសប្បុរិសធម៌ ។ ម្នាលភិក្ខុទាំងឡាយ ឯសប្បុរស តែងពិចារណាឃើញដូច្នេះថា លោភធម៌ទាំងឡាយ អស់ទៅក្តី ទោសធម៌ទាំងឡាយ អស់ទៅក្តី មោហធម៌ទាំងឡាយ អស់ទៅក្តី មិនមែនព្រោះហេតុតែខ្លួនប្រព្រឹត្តបង្សុកូលនោះទេ បើមិនមែនជាអ្នកប្រព្រឹត្តបង្សុកូលទេ តែភិក្ខុនោះប្រព្រឹត្តតាមធម៌សមគួរដល់ធម៌ ប្រតិបត្តិដោយសេចក្តីកោតក្រែង ប្រព្រឹត្តតាមធម៌ ភិក្ខុនោះ គួរជាទីបូជារបស់ភិក្ខុទាំងនោះ ភិក្ខុនោះ គួរជាទីសរសើររបស់ភិក្ខុទាំងនោះ ។ ភិក្ខុនោះ ធ្វើនូវបដិបទាឲ្យតាំងនៅខាងក្នុង ហើយមិនលើកតំកើងខ្លួនឯង មិនបន្តុះបង្អាប់អ្នកដទៃ ព្រោះហេតុតែខ្លួនប្រព្រឹត្តបង្សុកូលនោះ ម្នាលភិក្ខុទាំងឡាយ នេះឯង ឈ្មោះថាសប្បុរិសធម៌ ។

(១៨៨) បុន ចបរំ ភិក្ខវេ អសប្បុរិសោ បិណ្ឌបាតិកោ ហោតិ ។ សោ ឥតិ បដិសញ្ចិក្ខតិ អហំ ខោម្ហិ បិណ្ឌបាតិកោ ឥមេ បនញ្ញេ ភិក្ខូ ន បិណ្ឌបាតិកាតិ ។ សោ តេន បិណ្ឌបាតិកត្តេន អត្តានុក្កំសេតិ បរំ វម្ភេតិ អយម្បិ ភិក្ខវេ អសប្បុរិសធម្មោ ។ សប្បុរិសោ ច ខោ ភិក្ខវេ ឥតិ បដិសញ្ចិក្ខតិ ន ខោ បិណ្ឌបាតិកត្តេន លោភធម្មា វា បរិក្ខយំ គច្ឆន្តិ ទោសធម្មា វា បរិក្ខយំ គច្ឆន្តិ មោហធម្មា វា បរិក្ខយំ គច្ឆន្តិ នោ ចេបិ បិណ្ឌបាតិកោ ហោតិ សោ ច ហោតិ ធម្មានុធម្មប្បដិបន្នោ សាមីចិប្បដិបន្នោ អនុធម្មចារី សោ តត្ថ បុជ្ជោ សោ តត្ថ បាសំសោតិ ។ សោ បដិបទំយេវ អន្តរំ ករិត្វា តេន បិណ្ឌបាតិកត្តេន នេវត្តានុក្កំសេតិ ន បរំ វម្ភេតិ អយម្បិ ភិក្ខវេ សប្បុរិសធម្មោ ។

(១៨៨) ម្នាលភិក្ខុទាំងឡាយ មួយទៀត អសប្បុរស ជាអ្នកប្រព្រឹត្តបិណ្ឌបាត ។ អសប្បុរសនោះ ពិចារណាឃើញ ដូច្នេះថា អាត្មាអញជាអ្នកប្រព្រឹត្តបិណ្ឌបាត ឯពួកភិក្ខុដទៃទាំងនេះ មិនមែនជាអ្នកប្រព្រឹត្តបិណ្ឌបាតទេ ។ ភិក្ខុនោះ លើកតំកើងខ្លួនឯង បន្តុះបង្អាប់អ្នកដទៃ ព្រោះតែខ្លួនប្រព្រឹត្តបិណ្ឌបាតនោះ ម្នាលភិក្ខុទាំងឡាយ នេះឯង ឈ្មោះថាអសប្បុរិសធម៌ ។ ម្នាលភិក្ខុទាំងឡាយ ឯសប្បុរស តែងពិចារណាឃើញដូច្នេះថា លោភធម៌ទាំងឡាយ អស់ទៅក្តី ទោសធម៌ទាំងឡាយ អស់ទៅក្តី មោហធម៌ទាំងឡាយ អស់ទៅក្តី មិនមែនព្រោះហេតុតែខ្លួនប្រព្រឹត្តបិណ្ឌបាតទេ បើមិនជាអ្នកប្រព្រឹត្តបិណ្ឌបាតទេ តែភិក្ខុនោះជាអ្នកប្រតិបត្តិតាមធម៌សមគួរដល់ធម៌ ប្រតិបត្តិដោយសេចក្តីកោតក្រែង ប្រព្រឹត្តតាមធម៌ ភិក្ខុនោះ គួរជាទីបូជារបស់ភិក្ខុទាំងនោះ ភិក្ខុនោះ គួរជាទីសរសើររបស់ភិក្ខុទាំងនោះ ។ ភិក្ខុនោះ ធ្វើនូវបដិបទាឲ្យតាំងទៅខាងក្នុង ហើយមិនលើកតំកើងខ្លួនឯង មិនបន្តុះបង្អាប់អ្នកដទៃ ព្រោះហេតុតែខ្លួនប្រព្រឹត្តបិណ្ឌបាតនោះ ម្នាលភិក្ខុទាំងឡាយ នេះឯង ឈ្មោះថាសប្បុរិសធម៌ ។

(១៨៩) បុន ចបរំ ភិក្ខវេ អសប្បុរិសោ រុក្ខមូលិកោ ហោតិ ។ សោ ឥតិ បដិសញ្ចិក្ខតិ អហំ ខោម្ហិ រុក្ខមូលិកោ ឥមេ បនញ្ញេ ភិក្ខូ ន រុក្ខមូលិកាតិ ។ សោ តេន រុក្ខមូលិកត្តេន អត្តានុក្កំសេតិ បរំ វម្ភេតិ អយម្បិ ភិក្ខវេ អសប្បុរិសធម្មោ ។ សប្បុរិសោ ច ខោ ភិក្ខវេ ឥតិ បដិសញ្ចិក្ខតិ ន ខោ រុក្ខមូលិកត្តេន លោភធម្មា វា បរិក្ខយំ គច្ឆន្តិ ទោសធម្មា វា បរិក្ខយំ គច្ឆន្តិ មោហធម្មា វា បរិក្ខយំ គច្ឆន្តិ នោ ចេបិ រុក្ខមូលិកោ ហោតិ សោ ច ហោតិ ធម្មានុធម្មប្បដិបន្នោ សាមីចិប្បដិបន្នោ អនុធម្មចារី សោ តត្ថ បុជ្ជោ សោ តត្ថ បាសំសោតិ ។ សោ បដិបទំយេវ អន្តរំ ករិត្វា តេន រុក្ខមូលិកត្តេន នេវត្តានុក្កំសេតិ ន បរំ វម្ភេតិ អយម្បិ ភិក្ខវេ សប្បុរិសធម្មោ ។

## អនុបទវគ្គ សប្បុរិសសូត្រ ធម៌របស់សប្បុរសនិងអសប្បុរស

(១៨៩) ម្នាលភិក្ខុទាំងឡាយ មួយទៀត អសប្បុរស ជាអ្នកប្រព្រឹត្តរុក្ខមូល ៗ អសប្បុរសនោះ ពិចារណាឃើញ ដូច្នេះថា អាត្មាអញជាអ្នកប្រព្រឹត្តរុក្ខមូល ឯភិក្ខុដទៃទាំងនេះ មិនមែនជាអ្នកប្រព្រឹត្តរុក្ខមូលទេ ៗ ភិក្ខុនោះ លើកតម្កើងខ្លួនឯង បន្តុះបង្អាប់អ្នកដទៃ ព្រោះហេតុតែខ្លួនប្រព្រឹត្តរុក្ខមូលនោះ ម្នាលភិក្ខុទាំងឡាយ នេះឯង ឈ្មោះថាអសប្បុរិសធម៌ ៗ ម្នាលភិក្ខុទាំងឡាយ ឯសប្បុរស តែងពិចារណាឃើញដូច្នេះថា លោភធម៌ទាំងឡាយ អស់ទៅក្តី ទោសធម៌ទាំងឡាយ អស់ទៅក្តី មោហធម៌ទាំងឡាយ អស់ទៅក្តី មិនមែនព្រោះហេតុតែខ្លួនប្រព្រឹត្តរុក្ខមូលទេ បើមិនជាអ្នកប្រព្រឹត្តរុក្ខមូលទេ តែភិក្ខុនោះប្រតិបត្តិតាមធម៌ដ៏សមគួរដល់ធម៌ ប្រតិបត្តិដោយទៀង ប្រតិបត្តិកោតក្រែង ប្រព្រឹត្តតាមធម៌ ភិក្ខុនោះ គួរជាបូជារបស់ភិក្ខុទាំងនោះ ភិក្ខុនោះ គួរជាទីសរសើររបស់ភិក្ខុទាំងនោះ ៗ ភិក្ខុនោះ ធ្វើនូវបដិបទាឲ្យតាំងនៅខាងក្នុង ហើយមិនលើកតម្កើងខ្លួនឯង មិនបន្តុះបង្អាប់អ្នកដទៃ ព្រោះហេតុតែខ្លួនប្រព្រឹត្តរុក្ខមូលនោះ ម្នាលភិក្ខុទាំងឡាយ នេះឯង ឈ្មោះថាសប្បុរិសធម៌ ៗ

(១៩០) បុន ចបរំ ភិក្ខវេ អសប្បុរិសោ សោសានិកោ ហោតិ ... អព្ភោកាសិកោ ហោតិ ... នេសជ្ជិកោ ហោតិ ... យថាសន្ថតិកោ ហោតិ ... ឯកាសនិកោ ហោតិ ។ សោ ឥតិ បដិសញ្ចិក្ខតិ អហំ ខោម្ហិ ឯកាសនិកោ ឥមេ បនញ្ញេ ភិក្ខូ ន ឯកាសនិកាតិ ។ សោ តេន ឯកាសនិកត្តេន អត្តានុក្កំសេតិ បរំ វម្ភេតិ អយម្បិ ភិក្ខវេ អសប្បុរិសធម្មោ ។ សប្បុរិសោ ច ខោ ភិក្ខវេ ឥតិ បដិសញ្ចិក្ខតិ ន ខោ ឯកាសនិកត្តេន លោភធម្មា វា បរិក្ខយំ គច្ឆន្តិ ទោសធម្មា វា បរិក្ខយំ គច្ឆន្តិ មោហធម្មា វា បរិក្ខយំ គច្ឆន្តិ នោ ចេបិ ឯកាសនិកោ ហោតិ សោ ច ហោតិ ធម្មានុធម្មប្បដិបន្នោ សាមីចិប្បដិបន្នោ អនុធម្មចារី សោ តត្ថ បុជ្ជោ សោ តត្ថ បាសំសោ ។ សោ បដិបទំយេវ អន្តរំ ករិត្វា តេន ឯកាសនិកត្តេន នេវត្តានុក្កំសេតិ ន បរំ វម្ភេតិ អយម្បិ ភិក្ខវេ សប្បុរិសធម្មោ ។

[១៩០] ម្នាលភិក្ខុទាំងឡាយ មួយទៀត អសប្បុរស ជាអ្នកប្រព្រឹត្តទៅក្នុងព្រៃស្មសាន ប្រព្រឹត្តទៅក្នុងទីវាល ... ប្រព្រឹត្តតែនេសជ្ជិក ប្រព្រឹត្តតែយថាសន្ថតិកៈ ... ប្រព្រឹត្តតែឯកាសនិកៈ ។ ភិក្ខុនោះពិចារណាឃើញដូច្នេះថា អាត្មាអញជាអ្នកប្រព្រឹត្តឯកាសនិកៈ ឯពួកភិក្ខុដទៃទាំងនេះ មិនមែនជាអ្នកប្រព្រឹត្តឯកាសនិកៈទេ ។ ភិក្ខុនោះ លើកតំកើងខ្លួនឯង បន្តុះបង្អាប់អ្នកដទៃ ព្រោះហេតុតែខ្លួនប្រព្រឹត្តឯកាសនិកៈនោះ ម្នាលភិក្ខុទាំងឡាយ នេះឯង ឈ្មោះថាអសប្បុរិសធម៌ ។ ម្នាលភិក្ខុទាំងឡាយ ឯសប្បុរស តែងពិចារណាឃើញ ដូច្នេះថា លោភធម៌ទាំងឡាយ អស់ទៅក្តី ទោសធម៌ទាំងឡាយ អស់ទៅក្តី មោហធម៌ទាំងឡាយ អស់ទៅក្តី មិនមែនព្រោះតែខ្លួនប្រព្រឹត្តឯកាសនិកៈទេ បើមិនជាអ្នកប្រព្រឹត្តឯកាសនិកៈ តែភិក្ខុនោះជាអ្នកប្រតិបត្តិធម៌សមគួរដល់ធម៌ ប្រតិបត្តិដោយសេចក្តីគោរពក្រែង ប្រព្រឹត្តតាមធម៌ ភិក្ខុនោះ គួរជាទីបូជារបស់ភិក្ខុទាំងនោះ ភិក្ខុនោះ គួរជាទីសរសើររបស់ភិក្ខុទាំងនោះ ។ ភិក្ខុនោះ ធ្វើបដិបទាឲ្យតាំងនៅខាងក្នុង ហើយមិនលើកតំកើងខ្លួនឯង មិនបន្តុះបង្អាប់អ្នកដទៃ ព្រោះហេតុតែខ្លួនប្រព្រឹត្តឯកាសនិកៈនោះ ម្នាលភិក្ខុទាំងឡាយ នេះឯង ឈ្មោះថាសប្បុរិសធម៌ ។

(១៩១) បុន ចបរំ ភិក្ខវេ អសប្បុរិសោ វិវិច្ចេវ កាមេហិ វិវិច្ច អកុសលេហិ ធម្មេហិ សវិតក្កំ សវិចារំ វិវេកជំ បីតិសុខំ បឋមំ ឈានំ ឧបសម្បជ្ជ វិហរតិ ។ សោ ឥតិ បដិសញ្ចិក្ខតិ អហំ ខោម្ហិ បឋមជ្ឈានសមាបត្តិយា លាភី ឥមេ បនញ្ញេ ភិក្ខូ បឋមជ្ឈានសមាបត្តិយា ន លាភិនោតិ ។ សោ តាយ បឋមជ្ឈានសមាបត្តិយា អត្តានុក្កំសេតិ បរំ វម្ភេតិ អយម្បិ ភិក្ខវេ អសប្បុរិសធម្មោ ។ សប្បុរិសោ ច ខោ ភិក្ខវេ ឥតិ បដិសញ្ចិក្ខតិ បឋមជ្ឈានសមាបត្តិយាបិ ខោ អតម្មយតា[១] វុត្តា ភគវតា យេន យេន ហិ មញ្ញន្តិ តតោ តំ ហោតិ អញ្ញថាតិ ។ សោ អតម្មយតញ្ញេវ អន្តរំ ករិត្វា តាយ បឋមជ្ឈានសមាបត្តិយា នេវត្តានុក្កំសេតិ ន បរំ វម្ភេតិ អយម្បិ ភិក្ខវេ សប្បុរិសធម្មោ ។

---

១ អតម្មយតាតិបិ ។

(១៩១) ម្នាលភិក្ខុទាំងឡាយ មួយទៀត អសប្បុរស ស្ងាត់ចាកកាមទាំងឡាយ ស្ងាត់ចាកអកុសលធម៌ទាំងឡាយ ក៏ចូលកាន់បឋមជ្ឈាន ប្រកបដោយវិតក្កៈ វិចារៈ បីតិ សុខៈ ដែលកើតពីវិវេក ។ ភិក្ខុនោះ ពិចារណាឃើញដូច្នេះថា អាត្មាអញបាននូវបឋមជ្ឈានសមាបត្តិ ឯពួកភិក្ខុដទៃទាំងនេះ មិនមែនបាននូវបឋមជ្ឈានសមាបត្តិទេ ។ ភិក្ខុនោះ លើកតំកើងខ្លួនឯង បន្តុះបង្អាប់អ្នកដទៃ ព្រោះតែបាននូវបឋមជ្ឈានសមាបត្តិនោះ ម្នាលភិក្ខុទាំងឡាយ នេះឯង ឈ្មោះថាអសប្បុរិសធម៌ ។ ម្នាលភិក្ខុទាំងឡាយ ឯសប្បុរស តែងពិចារណាឃើញដូច្នេះថា សេចក្តីមិនញាប់ញ័រដោយអារម្មណ៍ ដែលព្រះមានព្រះភាគសំដែងហើយ ដោយបឋមជ្ឈានសមាបត្តិ ពួកភិក្ខុ រមែងសំគាល់នូវសេចក្តីមិនញាប់ញ័រនោះ ដោយធម្មជាតណា ៗ ធម្មជាតនោះ ៗ នឹងទៅជាដទៃវិញ ។ ភិក្ខុនោះ ធ្វើនូវសេចក្តីមិនញាប់ញ័រឲ្យតាំងនៅខាងក្នុង ហើយមិនលើកតំកើងខ្លួនឯង មិនបន្តុះបង្អាប់អ្នកដទៃ ព្រោះតែបឋមជ្ឈានសមាបត្តិនោះ ម្នាលភិក្ខុទាំងឡាយ នេះឯង ឈ្មោះថាសប្បុរិសធម៌ ។

[១៩២] បុន ចបរំ ភិក្ខវេ អសប្បុរិសោ វិតក្កវិចារានំ វូបសមា អជ្ឈត្តំ សម្បសាទនំ ចេតសោ ឯកោទិភាវំ អវិតក្កំ អវិចារំ សមាធិជំ បីតិសុខំ ទុតិយំ ឈានំ... តតិយំ ឈានំ... ចតុត្ថំ ឈានំ ឧបសម្បជ្ជ វិហរតិ ។ សោ ឥតិ បដិសញ្ចិក្ខតិ អហំ ខោម្ហិ ចតុត្ថជ្ឈានសមាបត្តិយា លាភី ឥមេ បនញ្ញេ ភិក្ខូ ចតុត្ថជ្ឈានសមាបត្តិយា ន លាភិនោតិ ។ សោ តាយ ចតុត្ថជ្ឈានសមាបត្តិយា អត្តានុក្កំសេតិ បរំ វម្ភេតិ អយម្បិ ភិក្ខវេ អសប្បុរិសធម្មោ ។ សប្បុរិសោ ច ខោ ភិក្ខវេ ឥតិ បដិសញ្ចិក្ខតិ ចតុត្ថជ្ឈានសមាបត្តិយាបិ ខោ អតម្មយតា វុត្តា ភគវតា យេន យេន ហិ មញ្ញន្តិ តតោ តំ ហោតិ អញ្ញថាតិ ។ សោ អតម្មយតញ្ញេវ អន្តរំ ករិត្វា តាយ ចតុត្ថជ្ឈានសមាបត្តិយា នេវត្តានុក្កំសេតិ ន បរំ វម្ភេតិ អយម្បិ ភិក្ខវេ សប្បុរិសធម្មោ ។

(១៩២) ម្នាលភិក្ខុទាំងឡាយ មួយទៀត អសប្បុរស ព្រោះរម្ងាប់វិតក្កៈវិចារៈរួចក៏ចូលកាន់ទុតិយជ្ឈាន ជាទីជ្រះថ្លាក្នុងសន្តាន មានសភាពជាចិត្តខ្ពស់ឯក ឥតមានវិតក្កៈវិចារៈទេ មានតែបីតិនិងសុខៈដែលកើតអំពីសមាធិប៉ុណ្ណោះ ... ចូលកាន់តតិយជ្ឈាន ... ចូលកាន់ចតុត្ថជ្ឈាន សម្រេចសម្រាន្តនៅដោយឥរិយាបថទាំង ៤ ។ អសប្បុរសនោះ ពិចារណាឃើញដូច្នេះថា អាត្មាអញជាអ្នកបាននូវចតុត្ថជ្ឈានសមាបត្តិ ឯពួកភិក្ខុដទៃទាំងនេះ មិនបានចតុត្ថជ្ឈានសមាបត្តិទេ ។ អសប្បុរសនោះ លើកតំកើងខ្លួនឯង បន្តុះបង្អាប់អ្នកដទៃ ព្រោះតែបានចតុត្ថជ្ឈានសមាបត្តិនោះ ម្នាលភិក្ខុទាំងឡាយ នេះឯង ឈ្មោះថាអសប្បុរិសធម៌ ។ ម្នាលភិក្ខុទាំងឡាយ ឯសប្បុរស តែងពិចារណាឃើញដូច្នេះថា សេចក្តីមិនញាប់ញ័រក្នុងអារម្មណ៍ ដែលព្រះអង្គសំដែងដោយចតុត្ថជ្ឈានសមាបត្តិ ពួកភិក្ខុ រមែងសំគាល់សេចក្តីមិនញាប់ញ័រដោយធម្មជាតណា ៗ ធម្មជាតនោះ ៗ នឹងទៅជាដទៃវិញ ។ ភិក្ខុនោះ ធ្វើសេចក្តីមិនញាប់ញ័រឲ្យតាំងនៅខាងក្នុង ហើយមិនលើកតំកើងខ្លួនឯង មិនបន្តុះបង្អាប់អ្នកដទៃ ព្រោះតែចតុត្ថជ្ឈានសមាបត្តិនោះ ម្នាលភិក្ខុទាំងឡាយ នេះឯង ឈ្មោះថាសប្បុរិសធម៌ ។

(១៩៣) បុន ចបរំ ភិក្ខវេ អសប្បុរិសោ រូបសញ្ញានំ សមតិក្កមា បដិឃសញ្ញានំ អត្ថង្គមា នានត្តសញ្ញានំ អមនសិការា អនន្តោ អាកាសោតិ អាកាសានញ្ចាយតនំ ឧបសម្បជ្ជ វិហរតិ ។ សោ ឥតិ បដិសញ្ចិក្ខតិ អហំ ខោម្ហិ អាកាសានញ្ចាយតនសមាបត្តិយា លាភី ឥមេ បនញ្ញេ ភិក្ខូ អាកាសានញ្ចាយតនសមាបត្តិយា ន លាភិនោតិ ។ សោ តាយ អាកាសានញ្ចាយតនសមាបត្តិយា អត្តានុក្កំសេតិ បរំ វម្ភេតិ អយម្បិ ភិក្ខវេ អសប្បុរិសធម្មោ ។ សប្បុរិសោ ច ខោ ភិក្ខវេ ឥតិ បដិសញ្ចិក្ខតិ អាកាសានញ្ចាយតនសមាបត្តិយាបិ ខោ អតម្មយតា វុត្តា ភគវតា យេន យេន ហិ មញ្ញន្តិ តតោ តំ ហោតិ អញ្ញថាតិ ។ សោ អតម្មយតញ្ញេវ អន្តរំ ករិត្វា តាយ អាកាសានញ្ចាយតនសមាបត្តិយា នេវត្តានុក្កំសេតិ ន បរំ វម្ភេតិ អយម្បិ ភិក្ខវេ សប្បុរិសធម្មោ ។

អនុបទវគ្គ សប្បុរិសសប្បុរិសសូត្រ ធម៌របស់សប្បុរសនិងអសប្បុរស

(១៩៣) ម្នាលភិក្ខុទាំងឡាយ មួយទៀត អសប្បុរស ព្រោះកន្លងផុតនូវរូបសញ្ញា ដោយនូវសេចក្តីវិនាសនៃបដិឃសញ្ញា មិនធ្វើទុកក្នុងចិត្តនូវនានត្តសញ្ញា ហើយចូលកាន់អាកាសានញ្ចាយតនសញ្ញាសមាបត្តិ ដោយបរិកម្មថា អាកាសមិនមានទីបំផុត ។ អសប្បុរសនោះពិចារណាឃើញដូច្នេះថា អាត្មាអញជាអ្នកបាននូវអាកាសានញ្ចាយតនសមាបត្តិ ឯភិក្ខុដទៃទាំងនេះ មិនបាននូវអាកាសានញ្ចាយតនសមាបត្តិទេ ។ អសប្បុរសនោះ លើកតំកើងខ្លួនឯង បន្តុះបង្អាប់អ្នកដទៃដោយអាកាសានញ្ចាយតនសមាបត្តិនោះ ម្នាលភិក្ខុទាំងឡាយ នេះឯង ឈ្មោះថាអសប្បុរិសធម៌ ។ ម្នាលភិក្ខុទាំងឡាយ ឯសប្បុរស រមែងពិចារណាឃើញដូច្នេះថា សេចក្តីមិនញាប់ញ័រ ក្នុងអារម្មណ៍ ដែលព្រះមានបុណ្យ សំដែងហើយ ដោយអាកាសានញ្ចាយតនសមាបត្តិពួកភិក្ខុតែងសំគាល់ដោយធម្មជាតណា ៗ ធម្មជាតនោះ ៗ នឹងទៅជាដទៃវិញ ។ ភិក្ខុនោះ ធ្វើនូវសេចក្តីមិនញាប់ញ័រឲ្យតាំងនៅខាងក្នុង ហើយមិនលើកតំកើងខ្លួនឯង មិនបន្តុះបង្អាប់អ្នកដទៃ ដោយអាកាសានញ្ចាយតនសមាបត្តិនោះ ម្នាលភិក្ខុទាំងឡាយ នេះឯង ឈ្មោះថាសប្បុរិសធម៌ ។

(១៩៤) បុន ចបរំ ភិក្ខវេ អសប្បុរិសោ សព្វសោ(១) អាកាសានញ្ចាយតនំ សមតិក្កម្ម អនន្តំ វិញ្ញាណន្តិ វិញ្ញាណញ្ចាយតនំ ឧបសម្បជ្ជ វិហរតិ ។ សោ ឥតិ បដិសញ្ចិក្ខតិ អហំ ខោម្ហិ វិញ្ញាណញ្ចាយតនសមាបត្តិយា លាភី ឥមេ បនញ្ញេ ភិក្ខូ វិញ្ញាណញ្ចាយតនសមាបត្តិយា ន លាភិនោតិ ។ សោ តាយ វិញ្ញាណញ្ចាយតនសមាបត្តិយា អត្តានុក្កំសេតិ បរំ វម្ភេតិ អយម្បិ ភិក្ខវេ អសប្បុរិសធម្មោ ។ សប្បុរិសោ ច ខោ ភិក្ខវេ ឥតិ បដិសញ្ចិក្ខតិ វិញ្ញាណញ្ចាយតនសមាបត្តិយាបិ ខោ អតម្មយតា វុត្តា ភគវតា យេន យេន ហិ មញ្ញន្តិ តតោ តំ ហោតិ អញ្ញថាតិ ។ សោ អតម្មយតញ្ញេវ អន្តរំ ករិត្វា តាយ វិញ្ញាណញ្ចាយតនសមាបត្តិយា នេវត្តានុក្កំសេតិ ន បរំ វម្ភេតិ អយម្បិ ភិក្ខវេ សប្បុរិសធម្មោ ។

១ ឱ. សព្វសោតិ ន ទិស្សតិ ។

(១៩៤) ម្នាលភិក្ខុទាំងឡាយ មួយទៀត អសប្បុរស ព្រោះកន្លងផុតអាកាសានញ្ចាយតនសមាបត្តិ ដោយសព្វគ្រប់ ហើយចូលកាន់វិញ្ញាណញ្ចាយតនសមាបត្តិ ដោយបរិកម្មថា វិញ្ញាណមិនមានទីបំផុត ។ អសប្បុរសនោះ ពិចារណាឃើញដូច្នេះថា អាត្មាអញជាអ្នកបាននូវវិញ្ញាណញ្ចាយតនសមាបត្តិ ឯពួកភិក្ខុដទៃទាំងនេះ មិនបាននូវវិញ្ញាណញ្ចាយតនសមាបត្តិទេ ។ អសប្បុរសនោះ លើកតំកើងខ្លួនឯង បន្តុះបង្អាប់អ្នកដទៃ ព្រោះហេតុវិញ្ញាណញ្ចាយតនសមាបត្តិនោះ ម្នាលភិក្ខុទាំងឡាយ នេះឯង ឈ្មោះថាអសប្បុរសធម៌ ។ ម្នាលភិក្ខុទាំងឡាយ ឯសប្បុរស រមែងពិចារណាឃើញដូច្នេះថា សេចក្តីមិនញាប់ញ័រ ដែលព្រះមានបុណ្យសំដែងហើយ ដោយវិញ្ញាណញ្ចាយតនសមាបត្តិ ពួកភិក្ខុតែងសំគាល់ នូវវិញ្ញាណញ្ចាយតនសមាបត្តិ ដោយធម្មជាតណា ៗ ធម្មជាតនោះ ៗ នឹងទៅជាដទៃវិញ ។ ភិក្ខុនោះ ធ្វើនូវសេចក្តីមិនញាប់ញ័រ ឲ្យតាំងនៅខាងក្នុង ហើយមិនលើកតំកើងខ្លួនឯង មិនបន្តុះបង្អាប់អ្នកដទៃ ព្រោះតែវិញ្ញាណញ្ចាយតនសមាបត្តិនោះ ម្នាលភិក្ខុទាំងឡាយ នេះឯង ឈ្មោះថាសប្បុរសធម៌ ។

(១៩៨) បុន ចបរំ ភិក្ខវេ អសប្បុរិសោ សព្វសោ វិញ្ញាណញ្ចាយតនំ សមតិក្កម្ម នត្ថិ កិញ្ចីតិ អាកិញ្ចញ្ញាយតនំ ឧបសម្បជ្ជ វិហរតិ ។ សោ ឥតិ បដិសញ្ចិក្ខតិ អហំ ខោម្ហិ អាកិញ្ចញ្ញាយតនសមាបត្តិយា លាភី ឥមេ បនញ្ញេ ភិក្ខូ អាកិញ្ចញ្ញាយតនសមាបត្តិយា ន លាភិនោតិ ។ សោ តាយ អាកិញ្ចញ្ញាយតនសមាបត្តិយា អត្តានុក្កំសេតិ បរំ វម្ភេតិ អយម្បិ ភិក្ខវេ អសប្បុរិសធម្មោ ។ សប្បុរិសោ ច ខោ ភិក្ខវេ ឥតិ បដិសញ្ចិក្ខតិ អាកិញ្ចញ្ញាយតនសមាបត្តិយាបិ ខោ អតម្មយតា វុត្តា ភគវតា យេន យេន ហិ មញ្ញន្តិ តតោ តំ ហោតិ អញ្ញថាតិ ។ សោ អតម្មយតញ្ញេវ អន្តរំ ករិត្វា តាយ អាកិញ្ចញ្ញាយតនសមាបត្តិយា នេវត្តានុក្កំសេតិ ន បរំ វម្ភេតិ អយម្បិ ភិក្ខវេ សប្បុរិសធម្មោ ។

(១៩៨) ម្នាលភិក្ខុទាំងឡាយ មួយទៀត អសប្បុរស ព្រោះកន្លងផុតវិញ្ញាណញ្ចាយតនសមាបត្តិ ដោយសព្វគ្រប់ ហើយចូលកាន់អាកិញ្ចញ្ញាយតនសមាបត្តិ ដោយបរិកម្មថា វត្ថុតិចតួចមិនមាន ៗ អសប្បុរសនោះ តែងពិចារណាឃើញដូច្នេះថា អាត្មាអញជាអ្នកបាននូវអាកិញ្ចញ្ញាយតនសមាបត្តិ ឯពួកភិក្ខុដទៃទាំងនេះ មិនមែនជាអ្នកបាននូវអាកិញ្ចញ្ញាយតនសមាបត្តិទេ ៗ អសប្បុរសនោះ លើកតំកើងខ្លួនឯង បន្តុះបង្អាប់អ្នកដទៃ ព្រោះតែអាកិញ្ចញ្ញាយតនសមាបត្តិនោះ ម្នាលភិក្ខុទាំងឡាយ នេះឯង ឈ្មោះថាអសប្បុរិសធម៌ ៗ ម្នាលភិក្ខុទាំងឡាយ ឯសប្បុរស រមែងពិចារណាឃើញដូច្នេះថា សេចក្តីមិនញាប់ញ័រ ដែលព្រះមានព្រះភាគសំដែងហើយ ដោយអាកិញ្ចញ្ញាយតនសមាបត្តិ ពួកភិក្ខុតែងសំគាល់ នូវអាកិញ្ចញ្ញាយតនសមាបត្តិ ដោយធម្មជាតណា ៗ ធម្មជាតនោះ ៗ នឹងទៅជាដទៃវិញ ៗ ភិក្ខុនោះ ធ្វើនូវសេចក្តីមិនញាប់ញ័រ ឲ្យតាំងនៅខាងក្នុង ហើយមិនលើកតំកើងខ្លួនឯង មិនបន្តុះបង្អាប់អ្នកដទៃ ព្រោះតែអាកិញ្ចញ្ញាយតនសមាបត្តិនោះ ម្នាលភិក្ខុទាំងឡាយ នេះឯង ឈ្មោះថាសប្បុរិសធម៌ ៗ

(១៩២) បុន ចបរំ ភិក្ខវេ អសប្បុរិសោ អាកិញ្ចញ្ញាយតនំ សមតិក្កម្ម នេវសញ្ញានាសញ្ញាយតនំ ឧបសម្បជ្ជ វិហរតិ ។ សោ ឥតិ បដិសញ្ចិក្ខតិ អហំ ខោម្ហិ នេវសញ្ញានាសញ្ញាយតនសមាបត្តិយា លាភី ឥមេ បនញ្ញេ ភិក្ខូ នេវសញ្ញានាសញ្ញាយតនសមាបត្តិយា ន លាភិនោតិ ។ សោ តាយ នេវសញ្ញានាសញ្ញាយតនសមាបត្តិយា អត្តានុក្កំសេតិ បរំ វម្ភេតិ អយម្បិ ភិក្ខវេ អសប្បុរិសធម្មោ ។ សប្បុរិសោ ច ខោ ភិក្ខវេ ឥតិ បដិសញ្ចិក្ខតិ នេវសញ្ញានាសញ្ញាយតនសមាបត្តិយាបិ ខោ អតម្មយតា វុត្តា ភគវតា យេន យេន ហិ មញ្ញន្តិ តតោ តំ ហោតិ អញ្ញថាតិ ។ សោ អតម្មយតញ្ញេវ អន្តរំ ករិត្វា តាយ នេវសញ្ញានាសញ្ញាយតនសមាបត្តិយា នេវត្តានុក្កំសេតិ ន បរំ វម្ភេតិ អយម្បិ ភិក្ខវេ សប្បុរិសធម្មោ ។

(១៩៦) ម្នាលភិក្ខុទាំងឡាយ មួយទៀត អសប្បុរស ព្រោះកន្លងផុតអាកិញ្ចញ្ញាយតនសមាបត្តិ ហើយចូលកាន់នេវសញ្ញានាសញ្ញាយតនសមាបត្តិ ។ អសប្បុរសនោះ តែងពិចារណាឃើញដូច្នេះថា អាត្មាអញ ជាអ្នកបាននូវនេវសញ្ញានាសញ្ញាយតនសមាបត្តិ ឯពួកភិក្ខុដទៃទាំងនេះ មិនមែនជាអ្នកបាននូវនេវសញ្ញានាសញ្ញាយតនសមាបត្តិទេ ។ អសប្បុរសនោះ លើកតំកើងខ្លួនឯង បន្តុះបង្អាប់អ្នកដទៃ ព្រោះតែនេវសញ្ញានាសញ្ញាយតនសមាបត្តិនោះ ម្នាលភិក្ខុទាំងឡាយ នេះឯង ឈ្មោះថាអសប្បុរិសធម៌ ។ ម្នាលភិក្ខុទាំងឡាយ ឯសប្បុរស រមែងពិចារណាឃើញដូច្នេះថា សេចក្តីមិនញាប់ញ័រក្នុងអារម្មណ៍ ដែលព្រះមានព្រះភាគសំដែងហើយ ដោយនេវសញ្ញានាសញ្ញាយតនសមាបត្តិ ពួកភិក្ខុសំគាល់ នូវនេវសញ្ញានាសញ្ញាយតនសមាបត្តិ ដោយធម្មជាតណា ៗ ធម្មជាតនោះ ៗ នឹងទៅជាដទៃវិញ ។ ភិក្ខុនោះ ធ្វើនូវសេចក្តីមិនញាប់ញ័រ ឲ្យតាំងនៅខាងក្នុង ហើយមិនលើកតម្កើងខ្លួនឯង មិនបន្តុះបង្អាប់អ្នកដទៃ ព្រោះតែនេវសញ្ញានាសញ្ញាយតនៈសមាបត្តិនោះ ម្នាលភិក្ខុទាំងឡាយ នេះឯង ឈ្មោះថា សប្បុរិសធម៌ ។

(១៩៧) បុន ចបរំ ភិក្ខវេ សប្បុរិសោ សព្ពសោ នេវសញ្ញានាសញ្ញាយតនំ សមតិក្កម្ម សញ្ញាវេទយិតនិរោធំ ឧបសម្បជ្ជ វិហរតិ ។ បញ្ញាយ ចស្ស ទិស្វា អាសវា បរិក្ខីណា ហោន្តិ[1] ។ អយំ ខោ[2] ភិក្ខវេ ភិក្ខុ ន កិញ្ចិ មញ្ញតិ ន កុហិញ្ចិ មញ្ញតិ ន កេនចិ មញ្ញតីតិ ។ ឥទមវោច ភគវា អត្តមនា តេ ភិក្ខូ ភគវតោ ភាសិតំ អភិនន្ទុន្តិ ។

សប្បុរិសសុត្តំ តតិយំ និដ្ឋិតំ ។

---

១ ម. បរិក្ខយា ហេន្តិ ទិស្សតិ ។ ២ ម. តយម្បិ ។

(១៩៧) ម្នាលភិក្ខុទាំងឡាយ មួយវិញទៀត សប្បុរស ព្រោះកន្លងផុតនេវសញ្ញានាសញ្ញាយតនសមាបត្តិ ដោយសព្វគ្រប់ ក៏ចូលកាន់សញ្ញាវេទយិតនិរោធ ។ អាសវៈទាំងឡាយរបស់ភិក្ខុនោះ រមែងអស់រលីងទៅ ព្រោះតែឃើញដោយប្រាជ្ញា ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុនេះឯង មិនបានសំគាល់នូវហេតុណាមួយ មិនសំគាល់ក្នុងហេតុណាមួយ មិនសំគាល់ ដោយហេតុណាមួយឡើយ ។ លុះព្រះមានព្រះភាគបានសំដែងព្រះសូត្រនេះហើយ ភិក្ខុទាំងនោះ ក៏មានសេចក្តីពេញចិត្ត ត្រេកអរហើយ ចំពោះភាសិតរបស់ព្រះមានព្រះភាគ ។

ចប់ សប្បុរិសសូត្រ ទី ៣ ។

## ចតុត្ថំ សេវិតព្វាសេវិតព្វសុត្តំ

(១៩៨) ឯវំមេ សុតំ ។ ឯកំ សមយំ ភគវា សាវត្ថិយំ វិហរតិ ជេតវនេ អនាថបិណ្ឌិកស្ស អារាមេ ។ តត្រ ខោ ភគវា ភិក្ខូ អាមន្តេសិ ភិក្ខវោតិ ។ ភទន្តេតិ តេ ភិក្ខូ ភគវតោ បច្ចស្សោសុំ ។ ភគវា ឯតទវោច សេវិតព្វាសេវិតព្វំ វោ ភិក្ខវេ ធម្មបរិយាយំ ទេសេស្សាមិ តំ សុណាថ សាធុកំ មនសិករោថ ភាសិស្សាមីតិ ។ ឯវំ ភន្តេតិ ខោ តេ ភិក្ខូ ភគវតោ បច្ចស្សោសុំ ។

(១៩៩) ភគវា ឯតទវោច កាយសមាចារំបាហំ ភិក្ខវេ ទុវិធេន វទាមិ សេវិតព្វម្បិ អសេវិតព្វម្បិ

# សេវិតព្វាសេវិតព្វសូត្រ ទី ៤

(១៩៨) ខ្ញុំបានស្តាប់មក យ៉ាងនេះ ។ សម័យមួយ ព្រះមានព្រះភាគទ្រង់គង់ក្នុងវត្តជេតពន របស់អនាថបិណ្ឌិកសេដ្ឋី ជិតក្រុងសាវត្ថី ។ ក្នុងទីនោះឯង ព្រះមានព្រះភាគទ្រង់ត្រាស់ហៅភិក្ខុទាំងឡាយថា ម្នាលភិក្ខុទាំងឡាយ ។ ភិក្ខុទាំងនោះ ទទួលស្តាប់ព្រះមានព្រះភាគថា ព្រះករុណា ព្រះអង្គដ៏ចំរើន ។ ព្រះមានព្រះភាគទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតនឹងសំដែងនូវធម្មបរិយាយ ដែលគួរសេពនិងមិនគួរសេព ដល់អ្នកទាំងឡាយ អ្នកទាំងឡាយ ចូរស្តាប់ធម្មបរិយាយនោះចុះ ចូរធ្វើទុកក្នុងចិត្តដោយប្រពៃចុះ តថាគតនឹងប្រាប់ ។ ភិក្ខុទាំងនោះ ទទួលស្តាប់ព្រះមានព្រះភាគថា ព្រះករុណា ព្រះអង្គ ។

(១៩៩) ព្រះមានព្រះភាគ ទ្រង់ត្រាស់យ៉ាងនេះថា ម្នាលភិក្ខុទាំងឡាយ តថាគតសំដែងកាយសមាចារ (សេចក្តីប្រព្រឹត្តិដោយកាយ) ថាមានពីរយ៉ាង គឺកាយសមាចារគួរសេព ១ មិនគួរសេព ១

តញ្ច អញ្ញមញ្ញំ កាយសមាចារំ វចីសមាចារំបាហំ

ភិក្ខវេ ទុវិធេន វទាមិ សេវិតព្វម្បិ អសេវិតព្វម្បិ

តញ្ច អញ្ញមញ្ញំ វចីសមាចារំ មនោសមាចារំបាហំ

ភិក្ខវេ ទុវិធេន វទាមិ សេវិតព្វម្បិ អសេវិតព្វម្បិ

តញ្ច អញ្ញមញ្ញំ មនោសមាចារំ ចិត្តុប្បាទំបាហំ

ភិក្ខវេ ទុវិធេន វទាមិ សេវិតព្វម្បិ អសេវិតព្វម្បិ

តញ្ច អញ្ញមញ្ញំ ចិត្តុប្បាទំ សញ្ញាបដិលាភំបាហំ

ភិក្ខវេ ទុវិធេន វទាមិ សេវិតព្វម្បិ អសេវិតព្វម្បិ

តញ្ច អញ្ញមញ្ញំ សញ្ញាបដិលាភំ ទិដ្ឋិប្បដិលា-

ភំបាហំ ភិក្ខវេ ទុវិធេន វទាមិ សេវិតព្វម្បិ

មួយទៀត តថាគតសំដែងកាយសមាចារនោះទីទៃ ៗ ពីគ្នា ម្នាលភិក្ខុទាំងឡាយ តថាគតសំដែងនូវវចីសមាចារ (សេចក្តីប្រព្រឹត្តដោយវាចា) ថាមានពីរយ៉ាង គឺវចីសមាចារគួរសេព ១ មិនគួរសេព ១ មួយទៀត តថាគតសំដែងវចីសមាចារនោះទីទៃ ៗ ពីគ្នា ម្នាលភិក្ខុទាំងឡាយ តថាគតសំដែងនូវមនោសមាចារ ( សេចក្តីប្រព្រឹត្តដោយចិត្ត ) ថាមានពីរយ៉ាង គឺមនោសមាចារគួរសេព ១ មិនគួរសេព ១ មួយទៀត តថាគតសំដែងនូវមនោសមាចារនោះ ទីទៃ ៗ ពីគ្នា ម្នាលភិក្ខុទាំងឡាយ តថាគតសំដែងនូវចិត្តុប្បាទ ( ការកើតឡើងនៃចិត្ត ) ថាមានពីរយ៉ាង គឺចិត្តុប្បាទគួរសេព ១ មិនគួរសេព ១ មួយទៀត តថាគតសំដែងនូវចិត្តុប្បាទនោះ ទីទៃ ៗ ពីគ្នា ម្នាលភិក្ខុទាំងឡាយ តថាគតសំដែងនូវការបានចំពោះនូវសញ្ញា ថាមានពីរយ៉ាង គឺការបានចំពោះនូវសញ្ញាគួរសេព ១ មិនគួរសេព ១ មួយទៀត តថាគតសំដែងនូវការបានចំពោះនូវសញ្ញានោះទីទៃ ៗ ពីគ្នា ម្នាលភិក្ខុទាំងឡាយ តថាគតសំដែង នូវការបានចំពោះនូវទិដ្ឋិ ថាមានពីរយ៉ាង គឺទិដ្ឋិគួរសេព ១

អសេវិតព្ពម្បិ តញ្ច អញ្ញមញ្ញំ ទិដ្ឋិប្បដិលាភំ អត្តភា-វប្បដិលាភម្បហំ ភិក្ខវេ ទុវិធេន វទាមិ សេវិតព្ពម្បិ អសេវិតព្ពម្បិ តញ្ច អញ្ញមញ្ញំ អត្តភាវប្បដិលាភន្តិ ។

(២០០) ឯវំ វុត្តេ អាយស្មា សារិបុត្តោ ភគវន្តំ ឯតទវោច ឥមស្ស ខោ អហំ ភន្តេ ភគវតា សង្ខិត្តេន ភាសិតស្ស វិត្ថារេន អត្ថំ អវិភត្តស្ស ឯវំ វិត្ថារេន អត្ថំ អាជានាមិ កាយសមាចារម្បហំ ភិក្ខវេ ទុវិធេន វទាមិ សេវិតព្ពម្បិ អសេវិតព្ពម្បិ តញ្ច អញ្ញមញ្ញំ កាយសមាចារន្តិ ឥតិ ខោ បនេតំ វុត្តំ ភគវតា កិញ្ចេតំ បដិច្ច វុត្តំ ។ យថារូបំ ភន្តេ កាយសមាចារំ សេវតោ អកុស-លា ធម្មា អភិវឌ្ឍន្តិ កុសលា ធម្មា បរិហាយន្តិ

មិនគួរសេព ១ មួយទៀត តថាគតសំដែងនូវការបានចំពោះនូវទិដ្ឋិនោះទីទៃៗ ពីគ្នា ម្នាលភិក្ខុទាំងឡាយ តថាគតសំដែងនូវការបានចំពោះនូវអត្តភាព ថាមានពីរយ៉ាង គឺការបានចំពោះនូវអត្តភាពគួរសេព ១ មិនគួរសេព ១ មួយទៀត តថាគតសំដែងនូវការបានចំពោះ នូវអត្តភាពនោះ ទីទៃ ៗ ពីគ្នា ។

[៤០០] កាលដែលព្រះមានព្រះភាគ ទ្រង់ត្រាស់យ៉ាងនេះហើយ ព្រះសារីបុត្តមានអាយុ បានក្រាបទូលព្រះមានព្រះភាគ យ៉ាងនេះថា បពិត្រព្រះអង្គដ៏ចំរើន ធម៌ដែលព្រះមានព្រះភាគ ទ្រង់សំដែងដោយសង្ខេប មិនទ្រង់ចែកសេចក្តីដោយពិស្តារនេះឯង ខ្ញុំព្រះអង្គយល់សេចក្តីដោយពិស្តារយ៉ាងនេះ គឺត្រង់ព្រះពុទ្ធដីកា ដែលព្រះមានព្រះភាគទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតសំដែងនូវកាយសមាចារ ថាមានពីរយ៉ាង គឺកាយសមាចារគួរសេព ១ មិនគួរសេព ១ មួយទៀត តថាគតសំដែងនូវកាយសមាចារនោះ ទីទៃ ៗ ពីគ្នា ដូច្នេះឯង តើព្រះពុទ្ធដីកានុ៎ះ ព្រះមានព្រះភាគត្រាស់សំដៅហេតុអ្វី ។ បពិត្រព្រះអង្គដ៏ចំរើន កាលបុគ្គលសេពនូវកាយសមាចារមានសភាពយ៉ាងណា អកុសលធម៌ទាំងឡាយតែងចំរើន កុសលធម៌ទាំងឡាយ តែងសាបសូន្យ

ឯវរូបោ កាយសមាចារោ ន សេវិតព្វោ ។ យថារូបញ្ច ខោ ភន្តេ កាយសមាចារំ សេវតោ អកុសលា ធម្មា បរិហាយន្តិ កុសលា ធម្មា អភិវឌ្ឍន្តិ ឯវរូបោ កាយសមាចារោ សេវិតព្វោ ។

[២០១] កថំរូបំ ភន្តេ កាយសមាចារំ សេវតោ អកុសលា ធម្មា អភិវឌ្ឍន្តិ កុសលា ធម្មា បរិហាយន្តិ ។ ឥធ ភន្តេ ឯកច្ចោ បាណាតិបាតី ហោតិ លុទ្ធោ លោហិតបាណី ហតប្បហតេ និវិដ្ឋោ អទយាបន្នោ បាណភូតេសុ អទិន្នាទាយី ខោ បន ហោតិ យំ តំ បរស្ស បរវិត្តូបករណំ គាមគតំ វា អរញ្ញគតំ វា តំ អទិន្នំ ថេយ្យសង្ខាតំ អាទាតា ហោតិ កាមេសុមិច្ឆាចារី ខោ បន ហោតិ យា តា មាតុរក្ខិតា បិតុរក្ខិតា មាតាបិតុរក្ខិតា ភាតុរក្ខិតា ភគិនិរក្ខិតា[១] ញាតិរក្ខិតា សស្សាមិកា

១ ម. ឯត្ថន្តរេ គោត្តរក្ខិតាតិ ទិស្សតិ ។

កាយសមាចារមានសភាពយ៉ាងនេះ បុគ្គលមិនគួរសេពឡើយ ។ បពិត្រព្រះអង្គដ៏ចំរើន កាលបុគ្គលសេពនូវកាយសមាចារ មានសភាពយ៉ាងណា អកុសលធម៌ទាំងឡាយ តែងសាបសូន្យ កុសលធម៌ទាំងឡាយតែងចំរើនឡើង កាយសមាចារមានសភាពយ៉ាងនេះ បុគ្គលគួរសេព ។

(២០១) បពិត្រព្រះអង្គដ៏ចំរើន កាលបុគ្គលសេពនូវកាយសមាចារមានសភាពដូចម្តេច អកុសលធម៌ទាំងឡាយ តែងចំរើនឡើង កុសលធម៌ទាំងឡាយតែងសាបសូន្យ ។ បពិត្រព្រះអង្គដ៏ចំរើន បុគ្គលពួកខ្លះក្នុងលោកនេះ ជាអ្នកសម្លាប់សត្វ ជាមនុស្សអាក្រក់ មានដៃប្រឡាក់ដោយឈាម ជាបុគ្គលតាំងមាំក្នុងការវាយកាប់សម្លាប់សត្វដទៃ មិនមានសេចក្តីអាណិតចំពោះសត្វទាំងឡាយ ជាអ្នកកាន់យករបស់ដែលគេមិនបានឲ្យ ទ្រព្យណាជារបស់អ្នកដទៃ ជាឧបករណ៍គ្រឿងត្រេកអររបស់បុគ្គលដទៃ ដែលនៅក្នុងស្រុកក្តី នៅក្នុងព្រៃក្តី ជាអ្នកកាន់យកនូវទ្រព្យនោះ ដែលគេមិនបានឲ្យ ដែលរាប់ចូលក្នុងការលួច ជាអ្នកប្រព្រឹត្តខុសក្នុងកាមទាំងឡាយ ពួកស្ត្រីណា ដែលមាតារក្សា បិតារក្សា មាតាបិតារក្សា បងប្អូនប្រុសរក្សា បងប្អូនស្រីរក្សា ញាតិរក្សា ជាស្ត្រីមានប្តី

សបរិទណ្ឌា អន្តមសោ មាលាគុណបរិក្ខិត្តាបិ(១) តថារូបាសុ ចារិត្តំ អាបជ្ជិតា ហោតិ ។ ឯវរូបំ ភន្តេ កាយសមាចារំ សេវតោ អកុសលា ធម្មា អភិវឌ្ឍន្តិ កុសលា ធម្មា បរិហាយន្តិ ។

(២០២) កថំរូបំ ភន្តេ កាយសមាចារំ សេវតោ អកុសលា ធម្មា បរិហាយន្តិ កុសលា ធម្មា អភិវឌ្ឍន្តិ ។ ឥធ ភន្តេ ឯកច្ចោ បាណាតិបាតំ បហាយ បាណាតិបាតា បដិវិរតោ ហោតិ និហិតទណ្ឌោ និហិតសត្ថោ លជ្ជី ទយាបន្នោ សព្វបាណភូតហិតានុកម្បី វិហរតិ អទិន្នាទានំ បហាយ អទិន្នាទានា បដិវិរតោ ហោតិ យន្តំ បរស្ស បរវិត្តូបករណំ គាមគតំ វា អរញ្ញគតំ វា តំ អទិន្នំ ថេយ្យសង្ខាតំ ន អាទាតា ហោតិ កាមេសុមិច្ឆាចារំ បហាយ

១ មាលាគុឡបរិក្ខិត្តាបីតិបិ ទិស្សតិ ។

ជាស្ត្រីប្រកបដោយអាជ្ញា ដោយហោចទៅ សូម្បីស្ត្រីដែលគេនាំទុកដោយផ្កាកម្រង ជាអ្នកប្រព្រឹត្តកន្លងស្ត្រីទាំងឡាយមានសភាពដូច្នោះ ។ បពិត្រព្រះអង្គដ៏ចំរើន កាលបុគ្គលសេពនូវកាយសមាចារ មានសភាពយ៉ាងនេះ អកុសលធម៌ទាំងឡាយ តែងចំរើនឡើង កុសលធម៌ទាំងឡាយ តែងសាបសូន្យ ។

(២០២) បពិត្រព្រះអង្គដ៏ចំរើន កាលបុគ្គលសេពនូវកាយសមាចារមានសភាពដូចម្តេច អកុសលធម៌ទាំងឡាយ តែងសាបសូន្យ កុសលធម៌ទាំងឡាយ តែងចំរើនឡើង ។ បពិត្រព្រះអង្គដ៏ចំរើន បុគ្គលពួកខ្លះក្នុងលោកនេះ លះបង់នូវបាណាតិបាត វៀរស្រឡះចាកបាណាតិបាត មានអាជ្ញាដាក់ចុះ មានគ្រឿងសស្ត្រាដាក់ចុះ មានសេចក្តីខ្មាសបាប មានសេចក្តីករុណាអនុគ្រោះដោយប្រយោជន៍ ដល់សត្វទាំងអស់ លះបង់នូវអទិន្នាទាន វៀរស្រឡះចាកអទិន្នាទាន ទ្រព្យណាជារបស់បុគ្គលដទៃ ជាឧបករណ៍គ្រឿងត្រេកអររបស់បុគ្គលដទៃ ដែលនៅក្នុងស្រុកក្តី នៅក្នុងព្រៃក្តី ជាអ្នកមិនកាន់យកនូវទ្រព្យនោះ ដែលគេមិនបានឲ្យ ដែលរាប់ចូលក្នុងការលួច លះបង់នូវកាមេសុមិច្ឆាចារ

កាមេសុមិច្ឆាចារា បដិវិរតោ ហោតិ យា តា មាតុរក្ខិតា បិតុរក្ខិតា មាតាបិតុរក្ខិតា ភាតុរក្ខិតា ភគិនិរក្ខិតា ញាតិរក្ខិតា សស្សាមិកា សបរិទណ្ឌា អន្តមសោ មាលាគុណបរិក្ខិត្តាបិ តថារូបាសុ ចារិត្តំ ន អាបជ្ជិតា ហោតិ ។ ឯវរូបំ ភន្តេ កាយសមាចារំ សេវតោ អកុសលា ធម្មា បរិហាយន្តិ កុសលា ធម្មា អភិវឌ្ឍន្តិ ។ កាយសមាចារំបាហំ ភិក្ខវេ ទុវិធេន វទាមិ សេវិតព្វម្បិ អសេវិតព្វម្បិ តញ្ច អញ្ញមញ្ញំ កាយសមាចារន្តិ ឥតិ យន្តំ វុត្តំ ភគវតា ឥទមេតំ បដិច្ច វុត្តំ ។

(២០៣) វចីសមាចារំបាហំ ភិក្ខវេ ទុវិធេន វទាមិ សេវិតព្វម្បិ អសេវិតព្វម្បិ តញ្ច អញ្ញមញ្ញំ វចីសមាចារន្តិ ឥតិ ខោ បនេតំ វុត្តំ ភគវតា កិញ្ចេតំ បដិច្ច វុត្តំ ។

ជាអ្នកវៀរស្រឡះចាកកាមេសុមិច្ឆាចារ ពួកស្ត្រីណា ដែលមាតារក្សា បិតារក្សា មាតាបិតារក្សា បងប្អូនប្រុសរក្សា បងប្អូនស្រីរក្សា ញាតិរក្សា ជាស្ត្រីមានប្តី ជាស្ត្រីប្រកបដោយអាជ្ញា ដោយហោចទៅ សូម្បីគេនាំទុកដោយផ្កាកម្រង ជាអ្នកមិនប្រព្រឹត្តកន្លង ចំពោះស្ត្រីមានសភាពដូច្នោះឡើយ ។ បពិត្រព្រះអង្គដ៏ចម្រើន កាលបុគ្គលសេពនូវកាយសមាចារមានសភាពដូច្នេះ អកុសលធម៌ទាំងឡាយ តែងសាបសូន្យ កុសលធម៌ទាំងឡាយ តែងចម្រើនឡើង ។ ត្រង់ព្រះពុទ្ធដីកា ដែលព្រះមានព្រះភាគត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតសំដែងនូវកាយសមាចារ ថាមានពីរយ៉ាង គឺកាយសមាចារគួរសេព ១ មិនគួរសេព ១ មួយទៀត តថាគតសំដែងនូវកាយសមាចារនោះ ទីទៃៗ ពីគ្នា ដូច្នេះនុ៎ះ គឺព្រះអង្គត្រាស់សំដៅយកហេតុនេះឯង ។

(៥០៣) ត្រង់ព្រះពុទ្ធដីកា ដែលព្រះមានព្រះភាគត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតសំដែងនូវវចីសមាចារ ថាមានពីរយ៉ាង គឺវចីសមាចារគួរសេព ១ មិនគួរសេព ១ មួយទៀត តថាគតសំដែងនូវវចីសមាចារនោះទីទៃៗពីគ្នា ដូច្នេះនុ៎ះឯង តើទ្រង់ត្រាស់សំដៅហេតុអ្វី ។

យថារូបំ ភន្តេ វចីសមាចារំ សេវតោ អកុសលា ធម្មា អភិវឌ្ឍន្តិ កុសលា ធម្មា បរិហាយ ឯវរូបោ វចីសមាចារោ ន សេវិតព្វោ ។ យថារូបញ្ច ខោ ភន្តេ វចីសមាចារំ សេវតោ អកុសលា ធម្មា បរិហាយន្តិ កុសលា ធម្មា អភិវឌ្ឍន្តិ ឯវរូបោ វចី-សមាចារោ សេវិតព្វោ ។

(២០៤) កថំរូបំ ភន្តេ វចីសមាចារំ សេវតោ អកុសលា ធម្មា អភិវឌ្ឍន្តិ កុសលា ធម្មា បរិ-ហាយន្តិ ។ ឥធ ភន្តេ ឯកច្ចោ មុសាវាទី ហោតិ សភគ្គតោ វា បរិសគ្គតោ វា ញាតិមជ្ឈគតោ វា បូគមជ្ឈគតោ វា រាជកុលមជ្ឈគតោ វា អភិនីតោ សក្ខីបុដ្ឋោ ឯហម្ភោ[1] បុរិស យំ ជានាសិ តំ វទេហីតិ ។ សោ អជានំ វា អាហ ជានាមីតិ ជានំ

១ ឱ. ឯហោ ។

បពិត្រព្រះអង្គដ៏ចម្រើន កាលបុគ្គលសេពនូវបិណ្ឌបាត មានសភាពយ៉ាងណា អកុសលធម៌ទាំងឡាយ តែងចម្រើនឡើង កុសលធម៌ទាំងឡាយតែងសាបសូន្យ បិណ្ឌបាតមានសភាពយ៉ាងនោះ បុគ្គលមិនគួរសេពឡើយ ។ បពិត្រព្រះអង្គដ៏ចម្រើន មួយវិញទៀត កាលបុគ្គលសេពនូវបិណ្ឌបាតមានសភាពយ៉ាងណា អកុសលធម៌ទាំងឡាយតែងសាបសូន្យ កុសលធម៌ទាំងឡាយ តែងចម្រើនឡើង បិណ្ឌបាតមានសភាពយ៉ាងនោះ បុគ្គលគួរសេព ។

(២០៤) បពិត្រព្រះអង្គដ៏ចម្រើន កាលបុគ្គលសេពនូវបិណ្ឌបាតមានសភាពដូចម្ដេច អកុសលធម៌ទាំងឡាយ តែងចម្រើនឡើង កុសលធម៌ទាំងឡាយ តែងសាបសូន្យ ។ បពិត្រព្រះអង្គដ៏ចម្រើន បុគ្គលពួកខ្លះ ក្នុងលោកនេះ ជាអ្នកពោលពាក្យកុហក ឋិតនៅក្នុងពេនប្រជុំក្តី ឋិតនៅក្នុងបរិស័ទក្តី ឋិតនៅក្នុងកណ្តាលញាតិក្តី ឋិតនៅក្នុងពួកសេនីក្តី ឋិតនៅក្នុងកណ្តាលរាជត្រកូលក្តី ដែលគេនាំមកសួរជាសាក្សីថា នែបុរសអើយ អ្នកចូរមកអាយ អ្នកដឹងនូវហេតុណា ចូរប្រាប់នូវហេតុនោះ ។ បុរសនោះ កាលមិនដឹង ក៏ពោលថា ខ្ញុំដឹងក្តី កាលដឹង

វា អាហ ន ជានាមីតិ អបស្សំ វា អាហ បស្សាមីតិ បស្សំ វា អាហ ន បស្សាមីតិ ឥតិ អត្តហេតុ វា បរហេតុ វា អាមិសកិញ្ចិក្ខហេតុ វា សម្បជានមុសា ភាសិតា ហោតិ បិសុណវាចោ ខោ បន ហោតិ ឥតោ សុត្វា អមុត្រ អក្ខាតា ឥមេសំ ភេទាយ អមុត្រ វា សុត្វា ឥមេសំ អក្ខាតា អមូសំ ភេទាយ ឥតិ សមគ្គានំ វា ភេទេតា[១] ភិន្នានំ វា អនុប្បទាតា វគ្គារាមោ វគ្គរតោ វគ្គនន្ទី វគ្គករណិំ វាចំ ភាសិតា ហោតិ ផរុសវាចោ ខោ បន ហោតិ យា សា វាចា អណ្ឌកា[២] កក្កសា កដុកា[៣] បរាភិសជ្ជនី កោធសាមន្តា អសមាធិសំវត្តនិកា តថារូបិំ វាចំ ភាសិតា ហោតិ សម្ផប្បលាបី ខោ បន ហោតិ អកាលវាទី អភូតវាទី អនត្ថវាទី អធម្មវាទី

១ ឱ. ភេត្តា ។ ម. ភេទកា ។ ២ ម. កណ្ឌកា ។ ៣ ឱ. បរកដុកា ។ ម ផរុសា បរកដុកា

ក៏ពោលថា ខ្ញុំមិនដឹងក្តី កាលមិនឃើញ ក៏ពោលថា ខ្ញុំឃើញក្តី កាលឃើញ ក៏ពោលថា ខ្ញុំមិនឃើញក្តី ជាអ្នកពោលសម្បជានមុសាវាទ ព្រោះហេតុខ្លួនក្តី ព្រោះហេតុអ្នកដទៃក្តី ព្រោះហេតុអាមិសៈ ដែលជាសំណូកបន្តិចបន្តួចក្តី ដោយប្រការដូច្នេះ មួយទៀត ជាអ្នកពោលពាក្យញុះញង់ គឺឮអំពីទីនេះ ទៅនិយាយក្នុងទីឯណោះ ដើម្បីបំបែកពួកជនទាំងនេះ ឬឮក្នុងទីឯណោះ មកប្រាប់ដល់ពួកជនទាំងនេះ ដើម្បីបំបែកពួកជនឯណោះ ឬបំបែកពួកជនកំពុងព្រមព្រៀងគ្នា ឬជួយជ្រោមជ្រែងពួកជនដែលបែកគ្នាហើយ មានពួកជាទីត្រេកអរ ត្រេកអរនឹងពួក រីករាយនឹងពួក ជាអ្នកពោលពាក្យបំបែកពួក ជាអ្នកពោលពាក្យអាក្រក់ សំដីណាជាសំដីទាក់ទូលចិត្ត ខ្ទោះខ្ទូរ ក្រហល់ក្រហាយ ស្ទាក់ដំណើរអ្នកដទៃ ជាសំដីជិតគ្នានឹងក្រោធ មិនប្រព្រឹត្តទៅ ដើម្បីសមាធិ ជាអ្នកពោលតែសំដីមានសភាពដូច្នោះ ជាអ្នកពោលពាក្យឥតប្រយោជន៍ និយាយមិនត្រូវតាមកាល និយាយមិនពិត និយាយពាក្យឥតប្រយោជន៍ និយាយពាក្យមិនមែនធម៌

អវិនយវាទី អនិធានវតឹ វាចំ ភាសិតា ហោតិ[១] អកាលេន អនប្បទេសំ អបរិយន្តវតឹ អនត្ថសញ្ហិតំ ។ ឯវរូបំ ខោ ភន្តេ វចីសមាចារំ សេវតោ អកុសលា ធម្មា អភិវឌ្ឍន្តិ កុសលា ធម្មា បរិហាយន្តិ ។

(២០៥) កថំរូបំ ភន្តេ វចីសមាចារំ សេវតោ អកុសលា ធម្មា បរិហាយន្តិ កុសលា ធម្មា អភិ-វឌ្ឍន្តិ ។ ឥធ ភន្តេ ឯកច្ចោ មុសាវាទំ បហាយ មុសាវាទា បដិវិរតោ ហោតិ សភគ្គតោ វា បរិសគ្គតោ វា ញាតិមជ្ឈគ្គតោ វា បូគមជ្ឈគ្គតោ វា រាជកុលមជ្ឈគ្គតោ វា អភិនីតោ សក្ខីបុដ្ឋោ ឯហម្ភោ បុរិស យំ ជានាសិ តំ វទេហីតិ ។ សោ អជានំ វា អាហ ន ជានាមីតិ ជានំ វា អាហ ជានាមីតិ អបស្សំ វា អាហ ន បស្សាមីតិ

១ ឱ. ហោតីតិ ទិស្សតិ ។

មិនមែនវិន័យ ជាអ្នកពោលពាក្យមិនគួរនឹងតាំងទុកក្នុងហឫទ័យ ជាអ្នកនិយាយក្នុងកាលដែលមិនគួរនិយាយ និយាយពាក្យដ៏គ្មានគ្រឿងអាង ជាសំដីរកកំណត់គ្មាន មិនប្រកបដោយប្រយោជន៍ ។ បពិត្រព្រះអង្គដ៏ចំរើន កាលបុគ្គលសេពនូវវចីសមាចារ មានសភាពយ៉ាងនេះ អកុសលធម៌ទាំងឡាយ តែងចំរើនឡើង កុសលធម៌ទាំងឡាយ តែងសាបសូន្យ ។

( ៦០៨ ) បពិត្រព្រះអង្គដ៏ចំរើន កាលបុគ្គលសេពនូវវចីសមាចារមានសភាពដូចម្តេច អកុសលធម៌ទាំងឡាយ តែងសាបសូន្យ កុសលធម៌ទាំងឡាយ តែងចំរើនឡើង ។ បពិត្រព្រះអង្គដ៏ចំរើន បុគ្គលពួកខ្លះ ក្នុងលោកនេះ លះបង់មុសាវាទ ជាអ្នកវៀរស្រឡះចាកមុសាវាទ ទោះបើគេទៅក្នុងទីប្រជុំក្តី បើគេទៅក្នុងបរិស័ទក្តី បើគេទៅកណ្តាលញាតិក្តី បើគេទៅ ក្នុងកណ្តាលសេនីក្តី បើគេទៅ ក្នុងកណ្តាលរាជត្រកូលក្តី ដែលគេនាំមកសួរជាសាក្សីថា នែបុរសអើយ អ្នកចូរមកអាយ អ្នកដឹងនូវហេតុណា ចូរពោលនូវហេតុនោះចុះ ។ បុរសនោះ កាលមិនដឹង ក៏និយាយថា ខ្ញុំមិនដឹងក្តី កាលដឹង ក៏និយាយថា ខ្ញុំដឹងក្តី កាលមិនឃើញ ក៏និយាយថា ខ្ញុំមិនឃើញក្តី

បស្សំ វា អាហ បស្សាមីតិ អត្តហេតុ វា បរហេតុ
វា អាមិសកិញ្ចិក្ខហេតុ វា ន សម្បជានមុសា
ភាសិតា ហោតិ បិសុណំ វាចំ បហាយ បិសុណាយ
វាចាយ បដិវិរតោ ហោតិ ឥតោ សុត្វា ន អមុត្រ
អក្ខាតា ឥមេសំ ភេទាយ អមុត្រ វា សុត្វា ន
ឥមេសំ អក្ខាតា អមូសំ ភេទាយ ឥតិ ភិន្នានំ វា
សន្ធាតា សហិតានំ វា អនុប្បទាតា សមគ្គារាមោ
សមគ្គរតោ សមគ្គនន្ទី សមគ្គករណឹ វាចំ ភាសិតា
ហោតិ ផរុសំ វាចំ បហាយ ផរុសាយ វាចាយ
បដិវិរតោ ហោតិ យា សា វាចា នេលា កណ្ណ-
សុខា បេមនិយា ហទយង្គមា បោរី ពហុជន-
កន្តា ពហុជនមនាបា តថារូបឹ វាចំ ភាសិតា
ហោតិ សម្ផប្បលាបំ បហាយ សម្ផប្បលាបា
បដិវិរតោ ហោតិ កាលវាទី ភូតវាទី អត្ថវាទី
ធម្មវាទី វិនយវាទី និធានវតឹ វាចំ ភាសិតា ហោតិ
កាលេន សាបទេសំ បរិយន្តវតឹ អត្ថសញ្ហិតំ ។

កាលឃើញ ក៏និយាយថា ខ្ញុំឃើញក្តី ជាអ្នកមិនពោលសម្បជានមុសាវាទ ព្រោះហេតុខ្លួនក្តី ព្រោះហេតុអ្នកដទៃក្តី ព្រោះហេតុអាមិសៈ ដែលជាសំណូកបន្តិចបន្តួចក្តី ជាអ្នកលះបង់នូវពាក្យញុះញង់ វៀរចាកពាក្យញុះញង់ គឺឮអំពីទីឯណេះ មិនប្រាប់ក្នុងទីឯណោះ ដើម្បីបំបែកពួកជនឯណេះ ឬឮក្នុងទីឯណោះ មិនប្រាប់ដល់ពួកជនឯណេះ ដើម្បីបំបែកពួកជនឯណោះឡើយ ឬផ្សះផ្សាពួកជនដែលបែកគ្នាហើយ ឬជួយជ្រោមជ្រែងពួកជន ដែលប្រកបដោយប្រយោជន៍ មានសេចក្តីព្រមព្រៀងគ្នាជាទីត្រេកអរ ត្រេកអរក្នុងសេចក្តីព្រមព្រៀងគ្នា រីករាយក្នុងសេចក្តីព្រមព្រៀង ជាអ្នកនិយាយតែសំដីដែលធ្វើនូវសេចក្តីព្រមព្រៀង លះបង់នូវផរុសវាចា ជាអ្នកវៀរស្រឡះចាកផរុសវាចា វាចាណាដែលឥតទោស សុខដល់ត្រចៀក គួរជាទីស្រឡាញ់ ពេញហឫទ័យ ជាសំដីអ្នកក្រុង ជាទីរីករាយដល់ជនច្រើន ជាទីពេញចិត្តដល់ជនច្រើន ជាអ្នកនិយាយតែសំដីមានសភាពដូច្នោះ ជាអ្នកលះបង់ពាក្យរោយរាយឥតប្រយោជន៍ វៀរស្រឡះចាកពាក្យរោយរាយឥតប្រយោជន៍ និយាយត្រូវតាមកាល និយាយពិត និយាយអាថ៌ និយាយធម៌ និយាយវិន័យ ជាអ្នកនិយាយតែសំដី ដែលគួរតាំងទុកក្នុងចិត្ត មានគ្រឿងអាង មានទីបំផុត ប្រកបដោយប្រយោជន៍តាមកាលគួរ ។

ឯវរូបំ ភន្តេ វចីសមាចារំ សេវតោ អកុសលា ធម្មា បរិហាយន្តិ កុសលា ធម្មា អភិវឌ្ឍន្តិ ។ វចីសមាចារំបហំ ភិក្ខវេ ទុវិធេន វទាមិ សេវិតព្វម្បិ អសេវិតព្វម្បិ តញ្ច អញ្ញមញ្ញំ វចីសមាចារន្តិ ឥតិ យន្តំ វុត្តំ ភគវតា ឥទមេតំ បដិច្ច វុត្តំ ។

(២០៦) មនោសមាចារំបហំ ភិក្ខវេ ទុវិធេន វទាមិ សេវិតព្វម្បិ អសេវិតព្វម្បិ តញ្ច អញ្ញមញ្ញំ មនោសមាចារន្តិ ឥតិ ខោ បនេតំ វុត្តំ ភគវតា កិញ្ចេតំ បដិច្ច វុត្តំ ។ យថារូបំ ភន្តេ មនោសមាចារំ សេវតោ អកុសលា ធម្មា អភិវឌ្ឍន្តិ កុសលា ធម្មា បរិហាយន្តិ ឯវរូបោ មនោសមាចារោ

បពិត្រព្រះអង្គដ៏ចម្រើន កាលបុគ្គលសេពនូវវចីសមាចារ មានសភាពយ៉ាងនេះ អកុសលធម៌ទាំងឡាយ តែងសាបសូន្យ កុសលធម៌ទាំងឡាយ តែងចម្រើនឡើងបាន ៗ ត្រង់ព្រះពុទ្ធដីកា ដែលព្រះមានព្រះភាគទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតសំដែងនូវវចីសមាចារ ថាមានពីរយ៉ាង គឺវចីសមាចារគួរសេព ១ មិនគួរសេព ១ មួយទៀត តថាគតសំដែងនូវវចីសមាចារ នោះទីទៃ ៗ ពីគ្នា ដូច្នេះនុ៎ះ គឺទ្រង់ត្រាស់សំដៅហេតុនេះឯង ៗ

[ ៦០៦ ] ត្រង់ព្រះពុទ្ធដីកា ដែលព្រះមានព្រះភាគត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតសំដែងនូវមនោសមាចារ ថាមានពីរយ៉ាង គឺមនោសមាចារគួរសេព ១ មិនគួរសេព ១ មួយទៀត តថាគតសំដែងនូវមនោសមាចារនោះទីទៃៗ ពីគ្នា ដូច្នេះនុ៎ះឯង តើទ្រង់ត្រាស់សំដៅហេតុអ្វី ៗ បពិត្រព្រះអង្គដ៏ចម្រើន កាលបុគ្គលសេពនូវមនោសមាចារ មានសភាពយ៉ាងណា អកុសលធម៌ទាំងឡាយ តែងចម្រើនឡើង កុសលធម៌ទាំងឡាយតែងសាបសូន្យ មនោសមាចារមានសភាពយ៉ាងនោះ

ន សេវិតព្វោ ។ យថារូបញ្ច ខោ ភន្តេ មនោសមាចារំ សេវតោ អកុសលា ធម្មា បរិហាយន្តិ កុសលា ធម្មា អភិវឌ្ឍន្តិ ឯវរូបោ មនោសមាចារោ សេវិតព្វោ ។

(២០៧) កថរូបំ ភន្តេ មនោសមាចារំ សេវតោ អកុសលា ធម្មា អភិវឌ្ឍន្តិ កុសលា ធម្មា បរិហាយន្តិ ។ ឥធ ភន្តេ ឯកច្ចោ អភិជ្ឈាលុ ហោតិ យន្តំ បរស្ស បរវិត្តូបករណំ តំ[1] អភិជ្ឈិតា ហោតិ អហោ វត យំ បរស្ស តំ មម អស្សាតិ ព្យាបន្នចិត្តោ ខោ បន ហោតិ បទុដ្ឋមនសង្កប្បោ ឥមេ សត្តា ហញ្ញន្តុ វា វជ្ឈន្តុ វា ឧច្ឆិជ្ជន្តុ វា វិនស្សន្តុ វា មា អហេសុំ វាតិ ។ ឯវរូបំ ភន្តេ មនោសមាចារំ សេវតោ អកុសលា ធម្មា អភិវឌ្ឍន្តិ កុសលា ធម្មា បរិហាយន្តិ ។

---

១ ម. តញ្ច ។

បុគ្គលមិនគួរសេពឡើយ ។ បពិត្រព្រះអង្គដ៏ចំរើន បុគ្គលសេពនូវមនោសមាចារ មានសភាពយ៉ាងណា អកុសលធម៌ទាំងឡាយ តែងសាបសូន្យ អកុសលធម៌ទាំងឡាយ តែងចំរើនឡើង មនោសមាចារមានសភាពយ៉ាងនោះ បុគ្គលគួរសេព ។

(២០៧) បពិត្រព្រះអង្គដ៏ចំរើន កាលបុគ្គលសេព នូវមនោសមាចារ មានសភាពដូចម្តេច អកុសលធម៌ទាំងឡាយ តែងចំរើនឡើង កុសលធម៌ទាំងឡាយតែងសាបសូន្យ ។ បពិត្រព្រះអង្គដ៏ចំរើន បុគ្គលពួកខ្លះ ក្នុងលោកនេះ ជាអ្នកច្រើនដោយអភិជ្ឈា ទ្រព្យណាជារបស់អ្នកដទៃ ជាឧបករណ៍របស់អ្នកដទៃ ជាអ្នកគយរំពៃតែរបស់នោះថា ឱហ្ន៎ ទ្រព្យណា ជារបស់បុគ្គលដទៃ សូមឲ្យទ្រព្យនោះបានមកជាទ្រព្យរបស់អាត្មាអញវិញដូច្នេះ ជាអ្នកមានចិត្តគុំគួន មានសេចក្តីត្រិះរិះក្នុងចិត្ត ដែលទោសប្រទូស្តហើយថា សូមសត្វពួកនេះ លំបាកឬបែកធ្លាយ សាបសូន្យ វិនាសទៅ កុំមានសល់នៅឡើយ ។ បពិត្រព្រះអង្គដ៏ចំរើន កាលបុគ្គលសេពនូវមនោសមាចារ មានសភាពយ៉ាងនេះ អកុសលធម៌ទាំងឡាយ តែងចំរើនឡើង កុសលធម៌ទាំងឡាយ តែងសាបសូន្យ ។

(២០៨) កថំរូបំ ភន្តេ មនោសមាចារំ សេវតោ អកុសលា ធម្មា បរិហាយន្តិ កុសលា ធម្មា អភិវឌ្ឍន្តិ ។ ឥធ ភន្តេ ឯកច្ចោ អនភិជ្ឈាលុ ហោតិ យន្តំ បរស្ស បរវិត្តូបករណំ តំ នាភិជ្ឈិតា ហោតិ អហោ វត យំ បរស្ស តំ មម អស្សាតិ អព្យាបន្នចិត្តោ ខោ បន ហោតិ អប្បទុដ្ឋមនសង្កប្បោ ឥមេ សត្តា[1] អព្យាបជ្ឈា អនីឃា សុខី អត្តានំ បរិហរន្តូតិ ។ ឯវរូបំ ភន្តេ មនោសមាចារំ សេវតោ អកុសលា ធម្មា បរិហាយន្តិ កុសលា ធម្មា អភិវឌ្ឍន្តិ ។ មនោសមាចារម្បាហំ ភិក្ខវេ ទុវិធេន វទាមិ សេវិតព្វម្បិ អសេវិតព្វម្បិ តញ្ច អញ្ញមញ្ញំ មនោសមាចារន្តិ ឥតិ យន្តំ វុត្តំ ភគវតា ឥទមេតំ បដិច្ច វុត្តំ ។

១ ឱ. ម. អវេរា ឯត្ថន្តរេ ទិស្សតិ ។

(២០៨) បពិត្រព្រះអង្គដ៏ចំរើន កាលបុគ្គលសេពខ្លួនមនោសមាចារ មានសភាពដូចម្តេច អកុសលធម៌ទាំងឡាយ តែងសាបសូន្យ កុសលធម៌ទាំងឡាយ តែងចំរើនឡើងបាន ។ បពិត្រព្រះអង្គដ៏ចំរើន បុគ្គលពួកខ្លះ ក្នុងលោកនេះ ជាអ្នកមិនបានអភិជ្ឈា ទ្រព្យណា ជារបស់បុគ្គលដទៃ ជាឧបករណ៍របស់បុគ្គលដទៃ ជាអ្នកមិនគយគន់របស់នោះថា ឱហ្ន៎ ទ្រព្យណា ជារបស់បុគ្គលដទៃ សូមឲ្យទ្រព្យនោះបានមកជារបស់អាត្មាអញវិញ ដូច្នេះឡើយ ជាអ្នកមិនមានចិត្តព្យាបាទ មិនមានសេចក្តីត្រិះរិះក្នុងចិត្ត ដែលទោសប្រទូស្តហើយថា សូមពួកសត្វទាំងនេះ កុំព្យាបាទគ្នា កុំឲ្យមានទុក្ខ ឲ្យមានតែសេចក្តីសុខបរិហារខ្លួនចុះ ។ បពិត្រព្រះអង្គដ៏ចំរើន កាលបើបុគ្គលសេពនូវមនោសមាចារមានសភាពយ៉ាងនេះ អកុសលធម៌ទាំងឡាយ តែងសាបសូន្យ កុសលធម៌ទាំងឡាយ តែងចំរើនឡើងបាន ។ ត្រង់ព្រះពុទ្ធដីកា ដែលព្រះមានព្រះភាគត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតសំដែងនូវមនោសមាចារ ថាមានពីរយ៉ាង គឺមនោសមាចារគួរសេព ១ មិនគួរសេព ១ មួយទៀត តថាគតសំដែងនូវមនោសមាចារនោះដទៃ ៗ ពីគ្នា ដូច្នេះខ្លះ គឺទ្រង់ត្រាស់សំដៅហេតុនេះឯង ។

(២០៩) ចិត្តុប្បាទំបាហំ ភិក្ខវេ ទុវិធេន វទាមិ សេវិតព្វម្បិ អសេវិតព្វម្បិ តញ្ច អញ្ញមញ្ញំ ចិត្តុប្បាទន្តិ ឥតិ ខោ បនេតំ វុត្តំ ភគវតា កិញ្ចេតំ បដិច្ច វុត្តំ ។ យថារូបំ ភន្តេ ចិត្តុប្បាទំ សេវតោ អកុសលា ធម្មា អភិវឌ្ឍន្តិ កុសលា ធម្មា បរិហាយន្តិ ឯវរូបោ ចិត្តុប្បាទោ ន សេវិតព្វោ ។ យថារូបញ្ច ខោ ភន្តេ ចិត្តុប្បាទំ សេវតោ អកុសលា ធម្មា បរិហាយន្តិ កុសលា ធម្មា អភិវឌ្ឍន្តិ ឯវរូបោ ចិត្តុប្បាទោ សេវិតព្វោ ។

(២១០) កថំរូបំ ភន្តេ ចិត្តុប្បាទំ សេវតោ អកុសលា ធម្មា អភិវឌ្ឍន្តិ កុសលា ធម្មា បរិហាយន្តិ ។ ឥធ ភន្តេ ឯកច្ចោ អភិជ្ឈាលុ ហោតិ អភិជ្ឈាសហគតេន ចេតសា វិហរតិ ព្យាបាទវា ហោតិ ព្យាបាទសហគតេន ចេតសា វិហរតិ

(២០៩) ត្រង់ព្រះពុទ្ធដីកាដែលព្រះអង្គត្រាស់ថា ម្នាលភិក្ខុទាំង-ឡាយ តថាគតសំដែងនូវចិត្តុប្បាទ ថាមានពីរយ៉ាង គឺចិត្តុប្បាទគួរសេព ១ មិនគួរសេព ១ មួយទៀត តថាគតសំដែងនូវចិត្តុប្បាទនោះទាំង ២ ពីគ្នា ដូច្នេះនុះ តើទ្រង់ត្រាស់សំដៅហេតុអ្វី បពិត្រព្រះអង្គដ៏ចម្រើន កាលបុគ្គលសេពនូវចិត្តុប្បាទ មានសភាពយ៉ាងណា អកុ-សលធម៌ទាំងឡាយ តែងចម្រើនឡើង កុសលធម៌ទាំងឡាយ តែងសាបសូន្យ ចិត្តុប្បាទមានសភាពដូច្នោះ បុគ្គលមិនគួរសេពឡើយ ។ បពិត្រព្រះអង្គដ៏ចម្រើន កាលបុគ្គលសេពនូវចិត្តុប្បាទ មានសភាពយ៉ាងណា អកុសលធម៌ទាំងឡាយ តែងសាបសូន្យ កុសលធម៌ទាំងឡាយ តែងចម្រើនឡើង ចិត្តុប្បាទមានសភាពដូច្នោះ បុគ្គលគួរសេព ។

(២១០) បពិត្រព្រះអង្គដ៏ចម្រើន កាលបុគ្គលសេព នូវចិត្តុប្បាទ មានសភាពដូចម្តេច អកុសលធម៌ទាំងឡាយ តែងចម្រើនឡើង កុសលធម៌ទាំងឡាយ តែងសាបសូន្យ ។ បពិត្រព្រះអង្គដ៏ចម្រើន បុគ្គលពួកខ្លះ ក្នុងលោកនេះ ជាអ្នកមានអភិជ្ឈា មានចិត្តប្រកបដោយអភិជ្ឈា ជាអ្នកមានព្យាបាទ មានចិត្តប្រកបដោយព្យាបាទ

វិហេសកោ ហោតិ វិហេសាសហគតេន ចេតសា វិហរតិ ។ ឯវរូបំ ភន្តេ ចិត្តុប្បាទំ សេវតោ អកុសលា ធម្មា អភិវឌ្ឍន្តិ កុសលា ធម្មា បរិហាយន្តិ ។

[២១១] កថំរូបំ ភន្តេ ចិត្តុប្បាទំ សេវតោ អកុសលា ធម្មា បរិហាយន្តិ កុសលា ធម្មា អភិវឌ្ឍន្តិ ។ ឥធ ភន្តេ ឯកច្ចោ អនភិជ្ឈាលុ ហោតិ អនភិជ្ឈាសហគតេន ចេតសា វិហរតិ អព្យាបាទវា ហោតិ អព្យាបាទសហគតេន ចេតសា វិហរតិ អវិហេសកោ ហោតិ អវិហេសាសហគតេន ចេតសា វិហរតិ ។ ឯវរូបំ ភន្តេ ចិត្តុប្បាទំ សេវតោ អកុសលា ធម្មា បរិហាយន្តិ កុសលា ធម្មា អភិវឌ្ឍន្តិ ។ ចិត្តុប្បាទំបាហំ ភិក្ខវេ ទុវិធេន វទាមិ សេវិតព្វម្បិ អសេវិតព្វម្បិ តញ្ច អញ្ញមញ្ញំ ចិត្តុប្បាទន្តិ ឥតិ យំ តំ វុត្តំ ភគវតា ឥទមេតំ បដិច្ច វុត្តំ ។

ជាអ្នកមានសេចក្តីបៀតបៀន មានចិត្តប្រកបដោយការបៀតបៀន ។ បពិត្រព្រះអង្គដ៏ចំរើន កាលបើបុគ្គលសេពនូវចិត្តុប្បាទ មានសភាពយ៉ាងនេះ អកុសលធម៌ទាំងឡាយ តែងចំរើនឡើង កុសលធម៌ទាំង-ឡាយ តែងសាបសូន្យ ។

(៤១១) បពិត្រព្រះអង្គដ៏ចំរើន កាលបុគ្គលសេពនូវចិត្តុប្បាទមានសភាពដូចម្តេច អកុសលធម៌ទាំងឡាយ តែងសាបសូន្យ កុសល-ធម៌ទាំងឡាយ តែងចំរើនឡើង ។ បពិត្រព្រះអង្គដ៏ចំរើន បុគ្គលពួកខ្លះ ក្នុងលោកនេះ ជាអ្នកមិនមានអភិជ្ឈា មានចិត្តមិនប្រកបដោយអភិជ្ឈា ជាអ្នកមិនមានព្យាបាទ មានចិត្តមិនប្រកបដោយព្យាបាទ ជាអ្នកមិនមានសេចក្តីបៀតបៀន មានចិត្តមិនប្រកបដោយសេចក្តីបៀត-បៀន ។ បពិត្រព្រះអង្គដ៏ចំរើន កាលបើបុគ្គលសេព នូវចិត្តុប្បាទមានសភាពយ៉ាងនេះ អកុសលធម៌ទាំងឡាយតែងសាបសូន្យ កុសល-ធម៌ទាំងឡាយ តែងចំរើនឡើង ។ ត្រង់ព្រះពុទ្ធដីកា ដែលព្រះមានព្រះភាគត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតសំដែងនូវចិត្តុប្បាទថាមានពីរយ៉ាង គឺចិត្តុប្បាទគួរសេព ១ មិនគួរសេព ១ មួយទៀត តថាគតសំដែងនូវចិត្តុប្បាទនោះ ទីទៃៗ ពីគ្នា ដូច្នេះនុ៎ះ គឺទ្រង់ត្រាស់សំដៅហេតុនេះឯង ។

(២១២) សញ្ញាបដិលាភំបាហំ ភិក្ខវេ ទុវិធេន វទាមិ សេវិតព្វម្បិ អសេវិតព្វម្បិ តញ្ច អញ្ញមញ្ញំ សញ្ញាបដិលាភន្តិ ឥតិ ខោ បនេតំ វុត្តំ ភគវតា កិញ្ចេតំ បដិច្ច វុត្តំ ។ យថារូបំ ភន្តេ សញ្ញាបដិលាភំ សេវតោ អកុសលា ធម្មា អភិវឌ្ឍន្តិ កុសលា ធម្មា បរិហាយន្តិ ឯវរូបោ សញ្ញាបដិលាភោ ន សេវិតព្វោ ។ យថារូបញ្ច ខោ ភន្តេ សញ្ញាបដិលាភំ សេវតោ អកុសលា ធម្មា បរិហាយន្តិ កុសលា ធម្មា អភិវឌ្ឍន្តិ ឯវរូបោ សញ្ញាបដិលាភោ សេវិតព្វោ ។

(២១៣) កថំរូបំ ភន្តេ សញ្ញាបដិលាភំ សេវតោ អកុសលា ធម្មា អភិវឌ្ឍន្តិ កុសលា ធម្មា បរិហាយន្តិ ។ ឥធ ភន្តេ ឯកច្ចោ អភិជ្ឈាលុ ហោតិ អភិជ្ឈាសហគតាយ សញ្ញាយ វិហរតិ ព្យាបាទវា ហោតិ ព្យាបាទសហគតាយ សញ្ញាយ វិហរតិ

(៦១២) ត្រង់ព្រះពុទ្ធដីកាដែលព្រះមានព្រះភាគត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតសំដែងនូវការបានចំពោះសញ្ញា ថាមានពីរយ៉ាង គឺការបានចំពោះនូវសញ្ញាគួរសេព ១ មិនគួរសេព ១ មួយទៀត តថាគតសំដែងនូវការបានចំពោះនូវសញ្ញានោះ ទាំង ២ ពីគ្នាដូច្នេះនុ៎ះ តើទ្រង់ត្រាស់ដោយហេតុដូចម្តេច ។ បពិត្រព្រះអង្គដ៏ចំរើន កាលបុគ្គលសេពនូវការបានចំពោះសញ្ញា មានសភាពយ៉ាងណា អកុសលធម៌ទាំងឡាយ តែងចំរើនឡើង កុសលធម៌ទាំងឡាយតែងសាបសូន្យ ការបានចំពោះសញ្ញាមានសភាពយ៉ាងនោះ បុគ្គលមិនគួរសេពឡើយ ។ បពិត្រព្រះអង្គដ៏ចំរើន កាលបើបុគ្គលសេពនូវការបានចំពោះសញ្ញា មានសភាពយ៉ាងណា អកុសលធម៌ទាំងឡាយ តែងសាបសូន្យ កុសលធម៌ទាំងឡាយ តែងចំរើនឡើងបាន ការបានចំពោះសញ្ញាមានសភាពដូច្នោះ បុគ្គលគួរសេព ។

(៦១៣) បពិត្រព្រះអង្គដ៏ចំរើន កាលបុគ្គលសេព នូវការបានចំពោះនូវសញ្ញាមានសភាពដូចម្តេច អកុសលធម៌ទាំងឡាយ តែងចំរើនឡើង កុសលធម៌ទាំងឡាយសាបសូន្យ ។ បពិត្រព្រះអង្គដ៏ចំរើន បុគ្គលពួកខ្លះក្នុងលោកនេះ ជាអ្នកមានអភិជ្ឈា មានសញ្ញាប្រកបដោយអភិជ្ឈា ជាអ្នកមានព្យាបាទ មានសញ្ញាប្រកបដោយព្យាបាទ

វិហេសកំ ហោតិ វិហេសកសហគតាយ សញ្ញាយ វិហរតិ ។ ឯវរូបំ ភន្តេ សញ្ញាបដិលាភំ សេវតោ អកុសលា ធម្មា អភិវឌ្ឍន្តិ កុសលា ធម្មា បរិហាយន្តិ ។

(២១៤) កថំរូបំ ភន្តេ សញ្ញាបដិលាភំ សេវតោ អកុសលា ធម្មា បរិហាយន្តិ កុសលា ធម្មា អភិវឌ្ឍន្តិ ។ ឥធ ភន្តេ ឯកច្ចោ អនភិជ្ឈាលុ ហោតិ អនភិជ្ឈាសហគតាយ សញ្ញាយ វិហរតិ អព្យាបាទោ ហោតិ អព្យាបាទសហគតាយ សញ្ញាយ វិហរតិ អវិហេសកំ ហោតិ អវិហេសកសហគតាយ សញ្ញាយ វិហរតិ ។ ឯវរូបំ ភន្តេ សញ្ញាបដិលាភំ សេវតោ អកុសលា ធម្មា បរិហាយន្តិ កុសលា ធម្មា អភិវឌ្ឍន្តិ ។

ជាអ្នកមានសេចក្ដីបៀតបៀន មានសញ្ញាប្រកបដោយសេចក្ដីបៀតបៀន ។ បពិត្រព្រះអង្គដ៏ចម្រើន កាលបើបុគ្គលសេព នូវការបានចំពោះសញ្ញា មានសភាពយ៉ាងនេះ អកុសលធម៌ទាំងឡាយ តែងចម្រើនឡើង កុសលធម៌ទាំងឡាយ តែងសាបសូន្យ ។

(៦១៤) បពិត្រព្រះអង្គដ៏ចម្រើន កាលបុគ្គលសេពនូវការបានចំពោះសញ្ញាមានសភាពដូចម្ដេច អកុសលធម៌ទាំងឡាយ តែងសាបសូន្យ កុសលធម៌ទាំងឡាយ តែងចម្រើនឡើង ។ បពិត្រព្រះអង្គដ៏ចម្រើន បុគ្គលពួកខ្លះក្នុងលោកនេះ ជាអ្នកមិនមានអភិជ្ឈា មានសញ្ញាមិនប្រកបដោយអភិជ្ឈា ជាអ្នកមិនមានព្យាបាទ មានសញ្ញាមិនប្រកបដោយព្យាបាទ ជាអ្នកមិនមានសេចក្ដីបៀតបៀន មានសញ្ញាមិនប្រកបដោយសេចក្ដីបៀតបៀន ។ បពិត្រព្រះអង្គដ៏ចម្រើន កាលបើបុគ្គលសេព នូវការបានចំពោះសញ្ញា មានសភាពយ៉ាងនេះ ពួកអកុសលធម៌តែងសាបសូន្យ ពួកកុសលធម៌ តែងចម្រើនឡើង ។

សញ្ញាបដិលាភំបហំ ភិក្ខវេ ទុវិធេន វទាមិ សេវិតព្វម្បិ អសេវិតព្វម្បិ តញ្ច អញ្ញមញ្ញំ សញ្ញាបដិលាភន្តិ ឥតិ យន្តំ វុត្តំ ភគវតា ឥទមេតំ បដិច្ច វុត្តំ ។

(២១៩) ទិដ្ឋិប្បដិលាភំបហំ ភិក្ខវេ ទុវិធេន វទាមិ សេវិតព្វម្បិ អសេវិតព្វម្បិ តញ្ច អញ្ញមញ្ញំ ទិដ្ឋិប្បដិលាភន្តិ ឥតិ ខោ បនេតំ វុត្តំ ភគវតា កិញ្ចេតំ បដិច្ច វុត្តំ ។ យថារូបំ ភន្តេ ទិដ្ឋិប្បដិលាភំ សេវតោ អកុសលា ធម្មា អភិវឌ្ឍន្តិ កុសលា ធម្មា បរិហាយន្តិ ឯវរូបោ ទិដ្ឋិប្បដិលាភោ ន សេវិតព្វោ ។ យថារូបញ្ច ខោ ភន្តេ ទិដ្ឋិប្បដិលាភំ សេវតោ អកុសលា ធម្មា បរិហាយន្តិ កុសលា ធម្មា អភិវឌ្ឍន្តិ ឯវរូបោ ទិដ្ឋិប្បដិលាភោ សេវិតព្វោ ។

ត្រង់ព្រះពុទ្ធដីកា ដែលព្រះមានព្រះភាគត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតសំដែងនូវការបានចំពោះសញ្ញា ថាមានពីរយ៉ាង គឺការបានចំពោះសញ្ញាគួរសេព ១ មិនគួរសេព ១ មួយទៀត តថាគតសំដែងនូវការបានចំពោះសញ្ញានោះ ទីទៃ ៗ ពីគ្នា ដូច្នេះនុ៎ះ តើទ្រង់ត្រាស់សំដៅហេតុនេះឯង ។

(៦១៩) ត្រង់ព្រះពុទ្ធដីកា ដែលព្រះមានព្រះភាគត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតសំដែងនូវការបានចំពោះទិដ្ឋិ ថាមានពីរយ៉ាង គឺការបានចំពោះនូវទិដ្ឋិគួរសេព ១ មិនគួរសេព ១ មួយទៀត តថាគតសំដែងនូវការបានចំពោះទិដ្ឋិនោះទីទៃ ៗ ពីគ្នា ដូច្នេះនុ៎ះ តើទ្រង់ត្រាស់សំដៅហេតុអ្វី ។ បពិត្រព្រះអង្គដ៏ចំរើន កាលបុគ្គលសេពនូវការបានចំពោះទិដ្ឋិមានសភាពយ៉ាងណា អកុសលធម៌ទាំងឡាយ តែងចំរើនឡើង កុសលធម៌ទាំងឡាយ តែងសាបសូន្យ ការបានចំពោះទិដ្ឋិមានសភាពដូច្នោះ បុគ្គលមិនគួរសេពឡើយ ។ បពិត្រព្រះអង្គដ៏ចំរើន កាលបុគ្គលសេព នូវការបានចំពោះទិដ្ឋិមានសភាពយ៉ាងណា អកុសលធម៌ទាំងឡាយ តែងសាបសូន្យ កុសលធម៌ទាំងឡាយ តែងចំរើនឡើង ការបានចំពោះទិដ្ឋិ មានសភាពដូច្នោះ បុគ្គលគួរសេព ។

(២១៦) កថំរូបំ ភន្តេ ទិដ្ឋិបដិលាភំ សេវតោ អកុសលា ធម្មា អភិវឌ្ឍន្តិ កុសលា ធម្មា បរិហាយន្តិ ។ ឥធ ភន្តេ ឯកច្ចោ ឯវំទិដ្ឋិកោ ហោតិ នត្ថិ ទិន្នំ នត្ថិ យិដ្ឋំ នត្ថិ ហុតំ នត្ថិ សុកតទុក្កដានំ កម្មានំ ផលំ វិបាកោ នត្ថិ អយំ លោកោ នត្ថិ បរោ លោកោ នត្ថិ មាតា នត្ថិ បិតា នត្ថិ សត្តា ឱបបាតិកា នត្ថិ លោកេ សមណព្រាហ្មណា សម្មគ្គតា សម្មាបដិបន្នា យេ ឥមញ្ច លោកំ បរញ្ច លោកំ សយំ អភិញ្ញា សច្ឆិកត្វា បវេទេន្តីតិ ។ ឯវរូបំ ភន្តេ ទិដ្ឋិបដិលាភំ សេវតោ អកុសលា ធម្មា អភិវឌ្ឍន្តិ កុសលា ធម្មា បរិហាយន្តិ ។

(៦១៦) បពិត្រព្រះអង្គដ៏ចម្រើន កាលបុគ្គលសេពនូវការបានចំពោះទិដ្ឋិមានសភាពដូចម្តេច អកុសលធម៌ទាំងឡាយ តែងចម្រើនឡើង កុសលធម៌ទាំងឡាយ តែងសាបសូន្យ ។ បពិត្រព្រះអង្គដ៏ចម្រើន បុគ្គលពួកខ្លះ ក្នុងលោកនេះ មានសេចក្តីយល់ឃើញយ៉ាងនេះថា ទានដែលបុគ្គលឲ្យហើយមិនមានផល ការបូជាតូចឥតផល ការបូជាធំឥតផល ផលវិបាករបស់កម្មដែលបុគ្គលធ្វើល្អ និងធ្វើអាក្រក់មិនមាន លោកនេះមិនមាន លោកខាងមុខមិនមាន មាតាមិនមានគុណ[១] បិតាមិនមានគុណ[១] សត្វជាឧបបាតិកៈកំណើត មិនមាន សមណព្រាហ្មណ៍ក្នុងលោក មានសេចក្តីព្រមព្រៀង ជាអ្នកប្រតិបត្តិត្រូវ ធ្វើឲ្យជាក់ច្បាស់នូវលោកនេះផង លោកខាងមុខផង ដោយប្រាជ្ញាដ៏ក្រៃលែងដោយខ្លួនឯងក៏មិនមាន ។ បពិត្រព្រះអង្គដ៏ចម្រើន កាលបើបុគ្គលសេពនូវការបានចំពោះទិដ្ឋិ មានសភាពយ៉ាងនេះ អកុសលធម៌ទាំងឡាយ តែងចម្រើនឡើង កុសលធម៌ទាំងឡាយ តែងសាបសូន្យ ។

---

១ សំដៅយកការប្រតិបត្តិល្អអាក្រក់ ចំពោះមាតាបិតានោះ គ្មានគុណ គ្មានទោស ។ អដ្ឋកថា ។

(២១៧) កថំរូបំ ភន្តេ ទិដ្ឋិប្បដិលាភំ សេវតោ អកុសលា ធម្មា បរិហាយន្តិ កុសលា ធម្មា អភិវឌ្ឍន្តិ ។ ឥធ ភន្តេ ឯកច្ចោ ឯវំទិដ្ឋិកោ ហោតិ អត្ថិ ទិន្នំ អត្ថិ យិដ្ឋំ អត្ថិ ហុតំ អត្ថិ សុកតទុក្កដានំ កម្មានំ ផលំ វិបាកោ អត្ថិ អយំ លោកោ អត្ថិ បរោ លោកោ អត្ថិ មាតា អត្ថិ បិតា អត្ថិ សត្តា ឱបបាតិកា អត្ថិ លោកេ សមណព្រាហ្មណា សម្មគ្គតា សម្មាបដិបន្នា យេ ឥមញ្ច លោកំ បរញ្ច លោកំ សយំ អភិញ្ញា សច្ឆិកត្វា បវេទេន្តីតិ ។ ឯវរូបំ ភន្តេ ទិដ្ឋិប្បដិលាភំ សេវតោ អកុសលា ធម្មា បរិហាយន្តិ កុសលា ធម្មា អភិវឌ្ឍន្តិ ។ ទិដ្ឋិប្បដិលាភំបហំ ភិក្ខវេ ទុវិធេន វទាមិ សេវិតព្វម្បិ អសេវិតព្វម្បិ តញ្ច អញ្ញមញ្ញំ ទិដ្ឋិប្បដិលាភន្តិ ឥតិ យន្តំ វុត្តំ ឥទមេតំ បដិច្ច វុត្តំ ។

(៦១៧) បពិត្រព្រះអង្គដ៏ចម្រើន កាលបុគ្គលសេពនូវការបានចំពោះទិដ្ឋិ មានសភាពដូចម្តេច អកុសលធម៌ទាំងឡាយ តែងសាបសូន្យ កុសលធម៌ទាំងឡាយ តែងកើតឡើង ។ បពិត្រព្រះអង្គដ៏ចម្រើន បុគ្គលពួកខ្លះ ក្នុងលោកនេះ ជាអ្នកមានសេចក្តីយល់ឃើញយ៉ាងនេះថា ទានដែលបុគ្គលឲ្យហើយមានផល ការបូជាតូចមានផល ការបូជាធំមានផល ផលវិបាករបស់កម្មដែលសត្វធ្វើល្អ និងធ្វើអាក្រក់មានផល លោកនេះមាន លោកខាងមុខមាន មាតាមាន បិតាមាន សត្វជាឧបបាតិកៈកំណើតមាន ពួកសមណព្រាហ្មណ៍ក្នុងលោក មានសេចក្តីព្រមព្រៀង ជាអ្នកប្រតិបត្តិត្រូវ ធ្វើឲ្យជាក់ច្បាស់នូវលោកនេះនិងលោកខាងមុខ ដោយប្រាជ្ញាដ៏ក្រៃលែងដោយខ្លួនឯង មាន ។ បពិត្រព្រះអង្គដ៏ចម្រើន កាលបុគ្គលសេពនូវការបានចំពោះទិដ្ឋិ មានសភាពយ៉ាងនេះ អកុសលធម៌ទាំងឡាយ តែងសាបសូន្យ កុសលធម៌ទាំងឡាយ តែងចម្រើនឡើង ។ ត្រង់ព្រះពុទ្ធដីកាដែលព្រះមានព្រះភាគត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតសំដែងនូវការបានចំពោះទិដ្ឋិថាមានពីរយ៉ាង គឺការបានចំពោះនូវទិដ្ឋិគួរសេព ១ មិនគួរសេព ១ មួយទៀត តថាគតសំដែងនូវការបានចំពោះទិដ្ឋិនោះ ដទៃៗ ពីគ្នា ដូច្នេះនុ៎ះ គឺទ្រង់ត្រាស់សំដៅហេតុនេះឯង ។

(២១៨) អត្តភាវប្បដិលាភំបហំ ភិក្ខវេ ទុវិធេន វទាមិ សេវិតព្វម្បិ អសេវិតព្វម្បិ តញ្ច អញ្ញមញ្ញំ អត្តភាវប្បដិលាភន្តិ ឥតិ ខោ បនេតំ វុត្តំ ភគវតា កិញ្ចេតំ បដិច្ច វុត្តំ ។ យថារូបំ ភន្តេ អត្តភាវប្បដិលាភំ សេវតោ អកុសលា ធម្មា អភិវឌ្ឍន្តិ កុសលា ធម្មា បរិហាយន្តិ ឯវរូបោ អត្តភាវប្បដិលាភោ ន សេវិតព្វោ ។ យថារូបញ្ច ខោ ភន្តេ អត្តភាវប្បដិលាភំ សេវតោ អកុសលា ធម្មា បរិហាយន្តិ កុសលា ធម្មា អភិវឌ្ឍន្តិ ឯវរូបោ អត្តភាវប្បដិលាភោ សេវិតព្វោ ។

(៦១៨) ត្រង់ព្រះពុទ្ធដីកា ដែលព្រះមានព្រះភាគត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតសំដែងនូវការបានចំពោះអត្តភាព ថាមានពីរយ៉ាង គឺការបានចំពោះអត្តភាពគួរសេព ១ មិនគួរសេព ១ មួយទៀត តថាគតសំដែងនូវការបានចំពោះអត្តភាពនោះ ទីទៃ ៗ ពីគ្នា ដូច្នេះនុ៎ះ តើទ្រង់ត្រាស់សំដៅហេតុដូចម្តេច ។ បពិត្រព្រះអង្គដ៏ចម្រើន កាលបុគ្គលសេពនូវការបានចំពោះអត្តភាព មានសភាពយ៉ាងណា អកុសលធម៌ទាំងឡាយ តែងចម្រើនឡើង កុសលធម៌ទាំងឡាយ តែងសាបសូន្យ ការបានចំពោះអត្តភាពមានសភាពដូច្នោះ បុគ្គលមិនគួរសេព ។ បពិត្រព្រះអង្គដ៏ចម្រើន កាលបុគ្គលសេពនូវការបានចំពោះអត្តភាព មានសភាពយ៉ាងណា អកុសលធម៌ទាំងឡាយ តែងសាបសូន្យ កុសលទាំងឡាយ តែងចម្រើនឡើង ការបានចំពោះអត្តភាព មានសភាពដូច្នោះ បុគ្គលគួរសេព ។

(២១៩) កថំរូបំ ភន្តេ អត្តភាវប្បដិលាភំ សេវតោ អកុសលា ធម្មា អភិវឌ្ឍន្តិ កុសលា ធម្មា បរិហាយន្តិ ។ ព្យាបជ្ជំ[(១)] ភន្តេ អត្តភាវប្បដិលាភំ អភិនិព្វត្តស្ស យតោ[(២)] អបរិនិដ្ឋិតភាវាយ អកុសលា ធម្មា អភិវឌ្ឍន្តិ កុសលា ធម្មា បរិហាយន្តិ ។

(២២០) កថំរូបំ ភន្តេ អត្តភាវប្បដិលាភំ សេវតោ អកុសលា ធម្មា បរិហាយន្តិ កុសលា ធម្មា អភិវឌ្ឍន្តិ ។ អព្យាបជ្ជំ ភន្តេ អត្តភាវប្បដិលាភំ

១ ឱ. សព្យាបជ្ឈំ ។ ម. សព្យាបជ្ជំ ។ ២ ម. អភិនិព្វត្តយតោ ។

លុះទម្លាយរាងកាយ បន្ទាប់អំពីសេចក្តីស្លាប់ទៅ ក៏ទៅកើតក្នុងអបាយ ទុគ្គតិ វិនិបាត នរក ព្រោះកាយសុចរិតនោះជាហេតុ កាយសុចរិតនោះជាបច្ច័យ ការណ៍នុះមិនសមហេតុទេ ៗ ទាំងដឹងច្បាស់ថា ការណ៍នុះទើបត្រូវមែន ត្រង់ដែលបុគ្គលបរិបូណ៌ដោយកាយសុចរិត លុះទម្លាយរាងកាយបន្ទាប់អំពីសេចក្តីស្លាប់ ក៏ទៅកើតក្នុងសុគតិ សួគ៌ ទេវលោក ព្រោះកាយសុចរិតនោះជាហេតុ កាយសុចរិតនោះជាបច្ច័យ ការណ៍នុះទើបសមហេតុ ៗ ដឹងច្បាស់ថា ការណ៍នុះឥតហេតុ ឥតបច្ច័យទេ ត្រង់ដែលបុគ្គលបរិបូណ៌ដោយវចីសុចរិត ... ត្រង់ដែលបុគ្គលបរិ-បូណ៌ដោយមនោសុចរិត លុះទម្លាយរាងកាយ បន្ទាប់អំពីសេចក្តីស្លាប់ ក៏ទៅកើតក្នុងអបាយ ទុគ្គតិ វិនិបាត នរក ព្រោះមនោសុចរិតនោះជាហេតុ មនោសុចរិតនោះជាបច្ច័យ ការណ៍នុះមិនសមហេតុទេ ៗ ទាំងដឹងច្បាស់ថា ការណ៍នុះទើបត្រូវមែន ត្រង់ដែលបុគ្គលបរិបូណ៌ដោយវចីសុចរិត ... ត្រង់ដែលបុគ្គលបរិបូណ៌ដោយមនោសុចរិត លុះទម្លាយរាងកាយ បន្ទាប់អំពីសេចក្តីស្លាប់ ក៏ទៅកើតក្នុងសុគតិ សួគ៌ ទេវលោក ព្រោះមនោសុចរិតនោះជាហេតុ មនោសុចរិតនោះជាបច្ច័យ ការណ៍នុះទើបសមហេតុ ៗ ម្នាលអានន្ទ ការណ៍ដែលគួរហៅថា ភិក្ខុអ្នកឈ្លាសក្នុងហេតុនិងមិនមែនហេតុ ដោយហេតុប៉ុណ្ណេះឯង ៗ

(២៤៦) ឯវំ វុត្តេ អាយស្មា អានន្ទោ ភគវន្តំ ឯតទវោច អច្ឆរិយំ ភន្តេ អព្ភុតំ ភន្តេ កោ នាមោ អយំ ភន្តេ ធម្មបរិយាយោតិ ។ តស្មាតិហ ត្វំ អានន្ទ ឥមំ ធម្មបរិយាយំ ពហុធាតុកោតិបិ នំ ធារេហិ ចតុប្បរិវដ្ដោតិបិ នំ ធារេហិ ធម្មាទាសោតិបិ នំ ធារេហិ អមតទុន្ទុភីតិបិ(១) នំ ធារេហិ អនុត្តរោ សង្គាមវិជយោតិបិ នំ ធារេហីតិ ។ ឥទមវោច ភគវា អត្តមនោ អាយស្មា អានន្ទោ ភគវតោ ភាសិតំ អភិនន្ទីតិ ។

ពហុធាតុកសុត្តំ បញ្ចមំ និដ្ឋិតំ ។

---

១ ម. អមតទុទ្រភីតិបិ ។

[៤៤៦] កាលដែលព្រះមានព្រះភាគ ទ្រង់ត្រាស់យ៉ាងនេះហើយ ព្រះអានន្ទមានអាយុ បានក្រាបទូលព្រះមានព្រះភាគយ៉ាងនេះថា បពិត្រព្រះអង្គដ៏ចម្រើន អស្ចារ្យណាស់ បពិត្រព្រះអង្គដ៏ចម្រើន ចំឡែកណាស់ បពិត្រព្រះអង្គដ៏ចម្រើន ចុះធម្មបរិយាយនេះ តើឈ្មោះអ្វី ។ ព្រះអង្គត្រាស់ថា ម្នាលអានន្ទ ព្រោះហេតុនោះ អ្នកចូរចាំទុកនូវធម្មបរិយាយនេះ ឈ្មោះថាពហុធាតុកៈ(១) ដូច្នេះក៏បាន ចូរចាំទុកនូវធម្មបរិយាយនោះ ឈ្មោះថាចតុប្បរិវដ្ដៈ(២) ដូច្នេះក៏បាន ចូរចាំនូវធម្មបរិយាយនោះ ឈ្មោះថាធម្មាទាសៈ(៣) ដូច្នេះក៏បាន ចូរចាំទុកនូវធម្មបរិយាយនោះ ឈ្មោះថាអមតទុន្ទុភិ(៤) ដូច្នេះក៏បាន ចូរចាំទុកនូវធម្មបរិយាយនោះ ឈ្មោះថា សង្គាមវិជយដ៏ប្រសើរ(៥) ដូច្នេះក៏បាន ។ លុះព្រះមានព្រះភាគ ទ្រង់ត្រាស់ព្រះសូត្រនេះចប់ហើយ ព្រះអានន្ទមានអាយុ ក៏មានចិត្តត្រេកអររីករាយហើយ ចំពោះភាសិតរបស់ព្រះមានព្រះភាគ ។

ចប់ ពហុធាតុកសូត្រ ទី ៥ ។

---

១ ដែលហៅថាពហុធាតុកៈ ព្រោះសំដែងពីធាតុច្រើនយ៉ាង ។ ២ ប្រព្រឹត្តទៅដោយធម៌ ៤ យ៉ាង គឺធាតុ អាយតនៈ បដិច្ចសមុប្បាទនិងឋានាឋានៈ ។ ៣ កញ្ចក់ធម៌ ។ ៤ស្គរដ៏យមហាក–ទិញាន ។ ៥ ជាក្បួនពិធីយសង្គ្រាមយ៉ាងប្រសើរបំផុត ។

# ឆដ្ឋំ ឥសិគិលិសុត្តំ

(២៤៧) ឯវម្មេ សុតំ ។ ឯកំ សមយំ ភគវា រាជគហេ វិហរតិ ឥសិគិលិស្មឹ បព្វតេ ។ តត្រ ខោ ភគវា ភិក្ខូ អាមន្តេសិ ភិក្ខវោតិ ។ ភទន្តេតិ តេ ភិក្ខូ ភគវតោ បច្ចស្សោសុំ ។

(២៤៨) ភគវា ឯតទវោច បស្សថ នោ តុម្ហេ ភិក្ខវេ ឯតំ វេភារំ បព្វតន្តិ ។ ឯវម្ភន្តេ ។ ឯតស្ស ខោ[១] ភិក្ខវេ វេភារស្ស បព្វតស្ស អញ្ញាវ សមញ្ញា អហោសិ អញ្ញា បញ្ញត្តិ ។ បស្សថ នោ តុម្ហេ ភិក្ខវេ ឯតំ បណ្ឌវំ បព្វតន្តិ ។ ឯវម្ភន្តេ ។ ឯតស្សបិ ខោ ភិក្ខវេ បណ្ឌវស្ស បព្វតស្ស អញ្ញាវ សមញ្ញា អហោសិ អញ្ញា បញ្ញត្តិ ។ បស្សថ នោ តុម្ហេ ភិក្ខវេ ឯតំ វេបុល្លំ បព្វតន្តិ ។ ឯវម្ភន្តេ ។ ឯតស្សបិ ខោ ភិក្ខវេ វេបុល្លស្ស បព្វតស្ស អញ្ញាវ សមញ្ញា អហោសិ អញ្ញា បញ្ញត្តិ ។ បស្សថ នោ តុម្ហេ ភិក្ខវេ ឯតំ គិជ្ឈកូដំ បព្វតន្តិ ។ ឯវម្ភន្តេ ។

---

១ ឱ. ម. ឯតស្សបិ ខោ ។

## ឥសិគិលិសូត្រ ទី ៦

(២៤៧) ខ្ញុំបានស្តាប់មកយ៉ាងនេះ ។ សម័យមួយ ព្រះមានព្រះភាគគង់នៅលើភ្នំឥសិគិលិ ជិតក្រុងរាជគ្រឹះ ។ ក្នុងទីនោះ ព្រះមានព្រះភាគត្រាស់ហៅភិក្ខុទាំងឡាយថា ម្នាលភិក្ខុទាំងឡាយ ។ ភិក្ខុទាំងនោះ ទទួលព្រះវាចាព្រះមានព្រះភាគថា ព្រះករុណាព្រះអង្គដ៏ចំរើន ។

(២៤៨) ព្រះមានព្រះភាគ ទ្រង់ត្រាស់យ៉ាងនេះថា ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយ ឃើញភ្នំវេភារៈនុ៎ះឬទេ ។ ភិក្ខុទាំងឡាយក្រាបទូលថា ព្រះករុណាព្រះអង្គ ឃើញ ។ ម្នាលភិក្ខុទាំងឡាយ ភ្នំវេភារៈនុ៎ះឯង មានឈ្មោះផ្សេង មានបញ្ញត្តិផ្សេង ។ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយឃើញភ្នំបណ្ឌវៈនុ៎ះឬទេ ។ ព្រះករុណាព្រះអង្គ ឃើញ ។ ម្នាលភិក្ខុទាំងឡាយ ភ្នំបណ្ឌវៈនុ៎ះឯង ក៏មានឈ្មោះផ្សេង មានបញ្ញត្តិផ្សេង ។ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយឃើញភ្នំវេបុល្លៈនុ៎ះឬទេ ។ ព្រះករុណាព្រះអង្គ ឃើញ ។ ម្នាលភិក្ខុទាំងឡាយ ភ្នំវេបុល្លៈនុ៎ះឯង ក៏មានឈ្មោះផ្សេង មានបញ្ញត្តិផ្សេងដែរ ។ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយ ឃើញភ្នំគិជ្ឈកូដនុ៎ះឬទេ ។ ព្រះករុណា ព្រះអង្គ ឃើញ ។

ឯតស្សបិ ខោ ភិក្ខវេ គិជ្ឈកូដស្ស បព្វតស្ស អញ្ញា វ សមញ្ញា អហោសិ អញ្ញា បញ្ញត្តិ ។ បស្សថ នោ តុម្ហេ ភិក្ខវេ ឥមំ ឥសិគិលឹ បព្វតន្តិ ។ ឯវម្ភន្តេ ។ ឥមស្ស ខោ បន ភិក្ខវេ ឥសិគិលិស្ស បព្វតស្ស ឯសាវ សមញ្ញា អហោសិ ឯសា បញ្ញត្តិ ។

(២៤៩) ភូតបុព្វំ ភិក្ខវេ បញ្ច បច្ចេកពុទ្ធសតានិ ឥមស្មឹ ឥសិគិលិស្មឹ បព្វតេ ចិរនិវាសិនោ អហេសុំ ។ តេ ឥមំ បព្វតំ បវិសន្តា ទិស្សន្តិ បវិដ្ឋា ន ទិស្សន្តិ តមេនំ មនុស្សា ទិស្វា ឯវមាហំសុ អយំ បព្វតោ ឥមេ ឥសី[១] គិលតីតិ ឥសិគិលិ ឥសិគិលិត្វេវ សមញ្ញា ឧទបាទិ ។ អាចិក្ខិស្សាមិ[២] ភិក្ខវេ បច្ចេកពុទ្ធានំ នាមានិ កិត្តយិស្សាមិ ភិក្ខវេ បច្ចេកពុទ្ធានំ នាមានិ ទេសិស្សាមិ ភិក្ខវេ បច្ចេកពុទ្ធានំ នាមានិ តំ សុណាថ

១ ម. ឥសយោ ។ ២ ម. ពីដ រោតិ ទស្សតិ ។

ម្នាលភិក្ខុទាំងឡាយ ភ្នំគិជ្ឈកូដនុ៎ះឯង មានឈ្មោះផ្សេង មានបញ្ញត្តិផ្សេងដែរ ។ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយឃើញភ្នំឥសិគិលិនេះឬទេ ។ ព្រះករុណាព្រះអង្គ ឃើញ ។ ម្នាលភិក្ខុទាំងឡាយ ឯភ្នំឥសិគិលិនេះឯង មានឈ្មោះយ៉ាងហ្នឹង មានបញ្ញត្តិយ៉ាងហ្នឹងតែម្យ៉ាង ។

[២៤៩] ម្នាលភិក្ខុទាំងឡាយ កាលពីព្រេងនាយ មានព្រះបច្ចេកពុទ្ធ ៥០០ អង្គ នៅនាភ្នំឥសិគិលិនេះ អស់កាលយូរ ។ ព្រះបច្ចេកពុទ្ធទាំងនោះ កាលចូលទៅកាន់ភ្នំនេះ មនុស្សឃើញប្រាកដ លុះចូលស៊ប់ទៅហើយ មនុស្សមិនឃើញទេ ។ លុះពួកមនុស្សឃើញហេតុនោះហើយ ក៏នាំគ្នានិយាយយ៉ាងនេះថា ភ្នំនេះលេបនូវពួកឥសីទាំងនេះ ព្រោះហេតុនោះ បានជាមានឈ្មោះកើតឡើងថា ឥសិគិលិ ឥសិគិលិ (ភ្នំលេបឥសី) ដូច្នេះ ។ ម្នាលភិក្ខុទាំងឡាយ តថាគតប្រាប់ឈ្មោះព្រះបច្ចេកពុទ្ធទាំងឡាយ ម្នាលភិក្ខុទាំងឡាយ តថាគត ចង្អុលបង្ហាញឈ្មោះព្រះបច្ចេកពុទ្ធទាំងឡាយ ម្នាលភិក្ខុទាំងឡាយ តថាគតសំដែងឈ្មោះព្រះបច្ចេកពុទ្ធទាំងឡាយ អ្នកទាំងឡាយ ចូរប្រុងស្តាប់នូវរឿងនោះចុះ

សាធុកំ មនសិករោថ ភាសិស្សាមីតិ ។ ឯវម្ភន្តេតិ ខោ តេ ភិក្ខូ បច្ចស្សោសុំ ។

(៤៨០) ភគវា ឯតទវោច អរិដ្ឋោ នាម ភិក្ខវេ បច្ចេកសម្ពុទ្ធោ[១] ឥមស្មឹ ឥសិគិលិស្មឹ បព្វតេ ចិរនិវាសី អហោសិ ។ ឧបរិដ្ឋោ នាម ភិក្ខវេ បច្ចេកសម្ពុទ្ធោ ឥមស្មឹ ឥសិគិលិស្មឹ បព្វតេ ចិរនិវាសី អហោសិ ។ តគរសិខី នាម ភិក្ខវេ បច្ចេកសម្ពុទ្ធោ ឥមស្មឹ ឥសិគិលិស្មឹ បព្វតេ ចិរនិវាសី អហោសិ ។ យសស្សី នាម ភិក្ខវេ បច្ចេកសម្ពុទ្ធោ ឥមស្មឹ ឥសិគិលិស្មឹ បព្វតេ ចិរនិវាសី អហោសិ ។ សុទស្សនោ នាម ភិក្ខវេ បច្ចេកសម្ពុទ្ធោ ឥមស្មឹ ឥសិគិលិស្មឹ បព្វតេ ចិរនិវាសី អហោសិ ។ បិយទស្សី នាម ភិក្ខវេ បច្ចេកសម្ពុទ្ធោ ឥមស្មឹ ឥសិគិលិស្មឹ បព្វតេ ចិរនិវាសី អហោសិ ។ គន្ធារោ នាម ភិក្ខវេ បច្ចេកសម្ពុទ្ធោ ឥមស្មឹ ឥសិគិលិស្មឹ បព្វតេ ចិរនិវាសី អហោសិ ។

១ ឱ. បច្ចេកពុទ្ធោ ។

ចូរផ្ដើមទុកក្នុងចិត្តឲ្យប្រពៃចុះ តថាគតនឹងសំដែងប្រាប់ ។ ភិក្ខុទាំងឡាយនោះ ទទួលស្ដាប់ព្រះវាចានៃព្រះមានព្រះភាគថា ព្រះករុណាព្រះអង្គ ។

[៦៨០] ព្រះមានព្រះភាគបានត្រាស់យ៉ាងនេះថា ម្នាលភិក្ខុទាំងឡាយ ព្រះបច្ចេកសម្ពុទ្ធឈ្មោះអរិដ្ឋៈ បាននៅនាក្នុងឥសិគិលិនេះអស់កាលយូរ ។ ម្នាលភិក្ខុទាំងឡាយ ព្រះបច្ចេកសម្ពុទ្ធឈ្មោះឧបរិដ្ឋៈ បាននៅនាក្នុងឥសិគិលិនេះអស់កាលយូរ ។ ម្នាលភិក្ខុទាំងឡាយ ព្រះបច្ចេកសម្ពុទ្ធឈ្មោះតគរសិខី បាននៅនាក្នុងឥសិគិលិនេះអស់កាលយូរ ។ ម្នាលភិក្ខុទាំងឡាយ ព្រះបច្ចេកសម្ពុទ្ធ ឈ្មោះយសស្សី បាននៅនាក្នុងឥសិគិលិនេះ អស់កាលយូរ ។ ម្នាលភិក្ខុទាំងឡាយ ព្រះបច្ចេកសម្ពុទ្ធ ឈ្មោះសុទស្សនៈ បាននៅនាក្នុងឥសិគិលិនេះអស់កាលយូរ ។ ម្នាលភិក្ខុទាំងឡាយ ព្រះបច្ចេកសម្ពុទ្ធ ឈ្មោះបិយទស្សី បាននៅនាក្នុងឥសិគិលិនេះ អស់កាលយូរ ។ ម្នាលភិក្ខុទាំងឡាយ ព្រះបច្ចេកសម្ពុទ្ធឈ្មោះគន្ធារៈ បាននៅនាក្នុងឥសិគិលិនេះអស់កាលយូរ ។

បិណ្ឌោលោ នាម ភិក្ខវេ បច្ចេកសម្ពុទ្ធោ ឥមស្មឹ ឥសិគិលិស្មឹ បព្វតេ ចិរនិវាសី អហោសិ ។ ឧបាសភោ នាម ភិក្ខវេ បច្ចេកសម្ពុទ្ធោ ឥមស្មឹ ឥសិគិលិស្មឹ បព្វតេ ចិរនិវាសី អហោសិ ។ នីតោ នាម ភិក្ខវេ បច្ចេកសម្ពុទ្ធោ ឥមស្មឹ ឥសិគិលិស្មឹ បព្វតេ ចិរនិវាសី អហោសិ ។ តថោ នាម ភិក្ខវេ បច្ចេកសម្ពុទ្ធោ ឥមស្មឹ ឥសិគិលិស្មឹ បព្វតេ ចិរនិវាសី អហោសិ ។ សុតវា នាម ភិក្ខវេ បច្ចេកសម្ពុទ្ធោ ឥមស្មឹ ឥសិគិលិស្មឹ បព្វតេ ចិរនិវាសី អហោសិ ។ ភាវិតត្តោ នាម ភិក្ខវេ បច្ចេកសម្ពុទ្ធោ ឥមស្មឹ ឥសិគិលិស្មឹ បព្វតេ ចិរនិវាសី អហោសិ ។

(២៤១) យេ សត្តសារា អនិឃា(១) និរាសា
បច្ចេកមេវជ្ឈគមុំ សុពោធឹ
តេសំ វិសល្លាន(២) នរុត្តមានំ
នាមានិ មេ កិត្តយតោ សុណាថ

១ ម. អនីឃា ។ ២ ឱ. វិសល្លានំ ។

ម្នាលភិក្ខុទាំងឡាយ ព្រះបច្ចេកសម្ពុទ្ធឈ្មោះបិណ្ឌោលៈ បាននៅនាភ្នំឥសិគិលិនេះអស់កាលដ៏យូរ ។ ម្នាលភិក្ខុទាំងឡាយ ព្រះបច្ចេកសម្ពុទ្ធឈ្មោះឧបាសភៈ បាននៅនាភ្នំឥសិគិលិនេះអស់កាលដ៏យូរ ។ ម្នាលភិក្ខុទាំងឡាយ ព្រះបច្ចេកសម្ពុទ្ធឈ្មោះនីថៈ បាននៅនាភ្នំឥសិគិលិនេះអស់កាលដ៏យូរ ។ ម្នាលភិក្ខុទាំងឡាយ ព្រះបច្ចេកសម្ពុទ្ធឈ្មោះតថៈ បាននៅនាភ្នំឥសិគិលិនេះ អស់កាលដ៏យូរ ។ ម្នាលភិក្ខុទាំងឡាយ ព្រះបច្ចេកសម្ពុទ្ធឈ្មោះសុតវា បាននៅនាភ្នំឥសិគិលិនេះ អស់កាលដ៏យូរ ។ ម្នាលភិក្ខុទាំងឡាយ ព្រះបច្ចេកសម្ពុទ្ធឈ្មោះភាវិតត្តៈ បាននៅនាភ្នំឥសិគិលិនេះ អស់កាលដ៏យូរ ។

(៤៨១) ព្រះបច្ចេកពុទ្ធទាំងឡាយណា ជាខ្លឹមរបស់សត្វ
អស់ទុក្ខ អស់ចំណង់ បានត្រាស់ដឹងហើយ នូវបច្ចេក–
សម្ពោធិញ្ញាណ កាលបើតថាគត សំដែងឈ្មោះរបស់ព្រះ
បច្ចេកពុទ្ធទាំងនោះ ដែលមានសរដកចេញហើយ ដ៏ឧត្តម
ជាងជន អ្នកទាំងឡាយចូរស្តាប់ចុះ ព្រះបច្ចេកពុទ្ធទាំងឡាយ

អរិដ្ឋោ ឧបរិដ្ឋោ តគរសិខី យសស្សី
សុទស្សនោ បិយទស្សី ច ពុទ្ធោ
គន្ធារោ បិណ្ឌោលោ ឧបាសភោ ច
និតោ តថោ សុតវា ភាវិតត្តោ
សុម្ភោ សុភោ មេតុលោ អដ្ឋមោ ច
អថស្សុមេឃោ អនិឃោ សុទាឋោ
បច្ចេកពុទ្ធា ភវនេត្តិខីណា
ហិង្គូ ច ហិង្គោ ច មហានុភាវា
ទ្វេ ជាលិនោ មុនិនោ អដ្ឋកោ ច
អថ កោសល្លោ ពុទ្ធោ អថោ សុបាហុ
ឧបនេមិសោ នេមិសោ សន្តចិត្តោ
សច្ចោ តថោ វិរជោ បណ្ឌិតោ ច
កាឡូបកាឡា វិជិតោ ជិតោ ច
អង្គោ ច បង្គោ ច គុត្តិជិតោ(១) ច
បស្សី ជហិ ឧបធឹ ទុក្ខមូលំ
អបរាជិតោ មារពលំ អជេសិ

១ ឱ. ម. គុត្តិជ្ជីតោ ។

ឈ្មោះអរិដ្ឋៈ ១ ឧបរិដ្ឋៈ ១ តគរសិខី ១ យសស្សី ១ សុទស្សនៈ ១ បច្ចេកពុទ្ធឈ្មោះបិយទស្សី ១ គន្ធារៈ ១ បិណ្ឌោលៈ ១ ឧបាសភៈ ១ នីថៈ ១ តថៈ ១ សុតវា ១ ភាវិតត្តៈ ១ សុម្ភៈ ១ សុភៈ ១ មេថុលៈ ១ អដ្ឋមៈ ១ អស្សុមេឃៈ ១ អនិឃៈ ១ សុទាឋៈ ១ ជាបច្ចេកពុទ្ធមានតណ្ហានាំទៅកាន់ភពអស់ហើយ ព្រះបច្ចេកពុទ្ធឈ្មោះហិង្គុ ១ ហិង្គៈ ១ មានអានុភាពច្រើន ព្រះបច្ចេកពុទ្ធឈ្មោះជាលី ២ គឺចុល្លជាលី ១ មហាជាលី ១ ជាអ្នកប្រាជ្ញ ឈ្មោះអដ្ឋកៈ ១ ព្រះបច្ចេកពុទ្ធឈ្មោះកោសល្លៈ ១ សុពាហុ ១ ឧបនេមិសៈ ១ នេមិសៈ ១ សន្តចិត្តៈ ១ សច្ចៈ ១ តថៈ ១ វិរជៈ ១ បណ្ឌិតៈ ១ កាឡៈ ១ ឧបកាឡៈ ១ វិជិតៈ ១ ជិតៈ ១ អង្គៈ ១ បង្គៈ ១ គុត្តិជិតៈ ១ ព្រះបច្ចេកពុទ្ធឈ្មោះ បស្សី ១ បានលះឧបធិកិលេស ជាឫសនៃសេចក្តីទុក្ខហើយ ព្រះបច្ចេកពុទ្ធ ឈ្មោះអបរាជិតៈ បានផ្ចាញ់នូវមារនិងពលនៃមារហើយ

សន្តា បរត្តា សរភង្គោ លោមហំសោ
ឧច្ចង្គមាយោ អសិតោ អនាសវោ
មនោមយោ មានច្ឆិទោ ច ពន្ធុមា
តទាធិមុត្តោ វិមលោ ច កេតុមា
កេតុម្ភរាគោ (១) ច មាតង្គោ អរិយោ
អថច្ចុតោ អច្ចុតគាមព្យាមកោ
សុមង្គលោ ទព្វិលោ សុបតិដ្ឋិតោ
អសយ្ហោ ខេមាភិរតោ ច សោរតោ
ទុរន្នយោ សង្ឃោ អថោបិ ឧជ្ជយោ
អបរោ មុនិ សយ្ហោ អនោមនិក្កមោ
អានន្ទនន្ទោ ឧបនន្ទោ ទ្វាទស
ភារទ្វាជោ អន្តិមទេហធារី
ពោធិ មហានាមោ អថោបិ ឧត្តរោ
កេសី សិខី សុន្ទរោ ភារទ្វាជោ
តិស្សុបតិស្សា ភវពន្ធនច្ឆិទា

១ ម. កេតុំភរាគោ ។ ឱ. កេតុម្ភរាគោ ។

ព្រះបច្ចេកពុទ្ធឈ្មោះសត្តា ១ បវត្តា ១ សរភង្គៈ ១ លោមហង្ស ១ ឧច្ចង្គមាយៈ ១ អសិតៈ ១ អនាសវៈ ១ មនោមយៈ ១ ពន្ធុមា ជាអ្នកផ្តាច់បង់នូវមានះ ១ ឈ្មោះតទាធិមុត្តៈ ១ វិមលៈ ១ កេតុមា ១ កេតុម្ភរាគៈ ១ មាតង្គៈ ១ អរិយៈ ១ អច្ចុតៈ ១ អច្ចុតគាមព្យាមកៈ ១ សុមង្គលៈ ១ ទព្វិលៈ ១ សុបតិដ្ឋិតៈ ១ អសយ្ហៈ ១ ខេមាភិរតៈ ១ សោរតៈ ១ ទុរន្នយៈ ១ សង្ឃៈ ១ ឧជ្ជយៈ ១ និងបច្ចេកពុទ្ធដទៃ ឈ្មោះសយ្ហៈ ជាអ្នកប្រាជ្ញមានព្យាយាមមិនថោកថយ ព្រះបច្ចេកពុទ្ធ ១២ អង្គទៀត ឈ្មោះអានន្ទៈ (៤ អង្គ) នន្ទៈ (៤ អង្គ) ឧបនន្ទៈ (៤ អង្គ) ភារទ្វាជៈ អ្នកទ្រទ្រង់នូវកាយមានក្នុងទីបំផុតភព ១ ពោធិ ១ មហានាមៈ ១ ឧត្តរៈ ១ កេសី ១ សិខី ១ សុន្ទរៈ ១ ភារទ្វាជៈ ១ តិស្ស ១ ឧបតិស្សៈ ១ ជាអ្នកផ្តាច់បង់នូវចំណងនៃភព

ឧបសីទរី[១] តណ្ហច្ឆិទោ ច សីទរី

ពុទ្ធោ អហុ មង្គលោ វីតរាគោ

ឧសភច្ឆិទា ជាលិនិំ ទុក្ខមូលំ

សន្តំ បទំ អជ្ឈគមូបណីតោ

ឧពោសថោ សុន្ទរោ សច្ចនាមោ

ជេតោ ជយន្តោ បទុមោ ឧប្បលោ ច

បទុមុត្តរោ រក្ខិតោ បព្វតោ ច

មានត្ថទ្ធោ សោភិតោ វីតរាគោ

កណ្ហោ ច ពុទ្ធោ សុវិមុត្តចិត្តោ

ឯតេ ច អញ្ញេ ច មហានុភាវា

បច្ចេកពុទ្ធា ភវនេត្តិខីណា

តេ សព្វសង្គាតិគតេ មហេសី

បរិនិព្វុតេ វន្ទថ អប្បមេយ្យេតិ ។

ឥសិគិលិសុត្តំ ឆដ្ឋំ និដ្ឋិតំ ។

---

១ ម. ឧបសិទិ ។

ឈ្មោះឧបសីទរី១ សីទរីជាអ្នកផ្តាច់បង់តណ្ហា១ បច្ចេកពុទ្ធ ឈ្មោះមង្គលៈ មានរាគៈទៅប្រាសហើយ១ ឈ្មោះឧសភៈ បានផ្តាច់បង់នូវតណ្ហាជាឫសនៃទុក្ខ១ ឧបណីតៈបានដល់នូវចំណែកដ៏ស្ងប់ស្ងាប់១ ឧបោសថៈ១ សុន្ទរៈ១ សច្ចនាមៈ១ ជេតៈ១ ជយន្តៈ១ បទុមៈ ១ ឧប្បលៈ ១ បទុមុត្តរៈ ១ រក្ខិតៈ១ បព្វតៈ១ មានត្ថទ្ធៈ១ សោភិតៈ១ វីតរាគៈ ១ កណ្ហៈ ១ បានត្រាស់ដឹងហើយ មានចិត្តរួចស្រឡះហើយ ព្រះបច្ចេកពុទ្ធ មានឈ្មោះប៉ុណ្ណោះ និងនៅមានឈ្មោះដទៃទៀត មានអានុភាពច្រើន មានតណ្ហាជាគ្រឿងនាំទៅកាន់ភពអស់ហើយ អ្នកទាំងឡាយ ចូរថ្វាយបង្គំនូវព្រះបច្ចេកពុទ្ធទាំងឡាយនោះ ដែលកន្លងនូវកិលេស ជាគ្រឿងជាប់ចំពាក់ទាំងពួង ស្វែងរកនូវគុណដ៏ប្រសើរ មានគុណរកប្រមាណមិនបាន ដែលបរិនិព្វានទៅហើយ ។

ចប់ ឥសិគិលិសូត្រ ទី ៦

# សត្តមំ មហាចត្តារីសកសុត្តំ

(២៨២) ឯវំ មេ សុតំ ។ ឯកំ សមយំ ភគវា សាវត្ថិយំ វិហរតិ ជេតវនេ អនាថបិណ្ឌិកស្ស អារាមេ ។ តត្រ ខោ ភគវា ភិក្ខូ អាមន្តេសិ ភិក្ខវោតិ ។ ភទន្តេតិ តេ ភិក្ខូ ភគវតោ បច្ចស្សោសុំ ។ ភគវា ឯតទវោច អរិយំ វោ ភិក្ខវេ សម្មាសមាធឹ ទេសិស្សាមិ សឧបនិសំ សបរិក្ខារំ តំ សុណាថ សាធុកំ មនសិករោថ ភាសិស្សាមីតិ ។ ឯវំ ភន្តេតិ ខោ តេ ភិក្ខូ ភគវតោ បច្ចស្សោសុំ ។

(២៨៣) ភគវា ឯតទវោច កតមោ ច ភិក្ខវេ អរិយោ សម្មាសមាធិ សឧបនិសោ សបរិក្ខារោ សេយ្យថីទំ សម្មាទិដ្ឋិ សម្មាសង្កប្បោ សម្មាវាចា សម្មាកម្មន្តោ

# មហាចត្តារីសកសូត្រ ទី ៧

(២៨២) ខ្ញុំបានស្តាប់មក យ៉ាងនេះ ។ សម័យមួយ ព្រះមានព្រះភាគទ្រង់គង់ ក្នុងវត្តជេតពន របស់អនាថបិណ្ឌិកសេដ្ឋី ជិតក្រុងសាវត្ថី ។ ក្នុងទីនោះឯង ព្រះមានព្រះភាគទ្រង់ត្រាស់ហៅភិក្ខុទាំងឡាយថា ម្នាលភិក្ខុទាំងឡាយ ។ ភិក្ខុទាំងឡាយនោះ ទទួលស្តាប់ព្រះមានព្រះភាគថា ព្រះករុណាព្រះអង្គដ៏ចំរើន ។ ព្រះមានព្រះភាគទ្រង់ត្រាស់យ៉ាងនេះថា ម្នាលភិក្ខុទាំងឡាយ តថាគតនឹងសំដែងនូវសម្មាសមាធិដែលឥតទោស ព្រមទាំងបច្ច័យ ព្រមទាំងបរិក្ខារ អ្នកទាំងឡាយ ចូរស្តាប់នូវសម្មាសមាធិនោះចុះ ចូរធ្វើទុកក្នុងចិត្តឲ្យប្រពៃចុះ តថាគតនឹងសំដែងប្រាប់ ។ ភិក្ខុទាំងនោះទទួលស្តាប់ព្រះមានព្រះភាគថា ព្រះករុណាព្រះអង្គ ។

(២៨៣) ព្រះមានព្រះភាគទ្រង់ត្រាស់យ៉ាងនេះថា ម្នាលភិក្ខុទាំងឡាយ សម្មាសមាធិដែលឥតទោស ព្រមទាំងបច្ច័យ ព្រមទាំងបរិក្ខារ តើដូចម្តេចខ្លះ គឺសម្មាទិដ្ឋិ សម្មាសង្កប្បៈ សម្មាវាចា សម្មាកម្មន្តៈ

សម្មាអាជីវោ សម្មាវាយាមោ សម្មាសតិ យា ខោ ភិក្ខវេ ឥមេហិ សត្តង្គេហិ[១] ចិត្តស្ស ឯកគ្គតា បរិក្ខតា អយំ វុច្ចតិ ភិក្ខវេ អរិយោ សម្មាសមាធិ សឧបនិសោ ឥតិបិ សបរិក្ខារោ ឥតិបិ[២] ។

(២៥៦) តត្រ ភិក្ខវេ សម្មាទិដ្ឋិ បុព្វង្គមា ហោតិ ។ កថញ្ច ភិក្ខវេ សម្មាទិដ្ឋិ បុព្វង្គមា ហោតិ ។ មិច្ឆាទិដ្ឋឹ មិច្ឆាទិដ្ឋីតិ បជានាតិ សម្មាទិដ្ឋឹ សម្មាទិដ្ឋីតិ បជានាតិ ។ សាស្ស ហោតិ សម្មាទិដ្ឋិ ។

(២៥៧) កតមា ច ភិក្ខវេ មិច្ឆាទិដ្ឋិ ។ នត្ថិ ទិន្នំ នត្ថិ យិដ្ឋំ នត្ថិ ហុតំ នត្ថិ សុកតទុក្កដានំ កម្មានំ ផលំ វិបាកោ នត្ថិ អយំ លោកោ នត្ថិ

១ ម. សត្តហង្គេហិ ។ ២ ឱ. ម. ឥតិបរោ ឧក្កំ ។

សម្មាអាជីវៈ សម្មាវាយាមៈ សម្មាសតិ ម្នាលភិក្ខុទាំងឡាយ ភាពនៃចិត្តមានអារម្មណ៍តែមួយណា មានអង្គទាំង ៧ នេះ ហោមរោមហើយ ម្នាលភិក្ខុទាំងឡាយ ភាពនៃចិត្តមានអារម្មណ៍តែមួយនេះ តថាគតហៅថា សម្មាសមាធិឥតទោស ព្រមទាំងបច្ច័យដូច្នេះផង ព្រមទាំងបរិវារដូច្នេះផង ។

[២៧៦] ម្នាលភិក្ខុទាំងឡាយ បណ្តាអង្គមគ្គទាំងនោះ សម្មាទិដ្ឋិ ជាធម្មជាតិដល់មុន (ជាប្រធាន) ។ ម្នាលភិក្ខុទាំងឡាយ ឯសម្មាទិដ្ឋិ ជាធម្មជាតិដល់មុន តើដូចម្តេច ។ បុគ្គល ដឹងច្បាស់នូវមិច្ឆាទិដ្ឋិ ថាជាមិច្ឆាទិដ្ឋិ ដឹងច្បាស់នូវសម្មាទិដ្ឋិ ថាជាសម្មាទិដ្ឋិ ។ សេចក្តីដឹងនោះ ជាសម្មាទិដ្ឋិ របស់បុគ្គលនោះ ។

[២៧៧] ម្នាលភិក្ខុទាំងឡាយ មិច្ឆាទិដ្ឋិ តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ សេចក្តីយល់ថា ទានដែលបុគ្គលឲ្យហើយ មិនមានផល គ្រឿងបូជាតូច មិនមានផល គ្រឿងបូជាធំ មិនមានផល ផលវិបាករបស់កម្ម ដែលសត្វធ្វើល្អនិងអាក្រក់ មិនមាន លោកនេះ មិនមាន

បរោ លោកោ នត្ថិ មាតា នត្ថិ បិតា នត្ថិ សត្តា ឱបបាតិកា នត្ថិ លោកេ សមណព្រាហ្មណា សម្មគ្គតា សម្មាបដិបន្នា យេ ឥមញ្ច លោកំ បរញ្ច លោកំ សយំ អភិញ្ញា សច្ឆិកត្វា បវេទេន្តីតិ អយំ ភិក្ខវេ មិច្ឆាទិដ្ឋិ ។

(២៨៦) កតមា ច ភិក្ខវេ សម្មាទិដ្ឋិ ។ សម្មាទិដ្ឋិម្បហំ ភិក្ខវេ ទ្វយំ វទាមិ អត្ថិ ភិក្ខវេ សម្មាទិដ្ឋិ សាសវា បុញ្ញភាគិយា ឧបធិវេបក្កា អត្ថិ ភិក្ខវេ សម្មាទិដ្ឋិ អរិយា អនាសវា លោកុត្តរា មគ្គង្គា ។

(២៨៧) កតមា ច ភិក្ខវេ សម្មាទិដ្ឋិ សាសវា បុញ្ញភាគិយា ឧបធិវេបក្កា ។ អត្ថិ ទិន្នំ អត្ថិ យិដ្ឋំ អត្ថិ ហុតំ អត្ថិ សុកតទុក្កដានំ កម្មានំ ផលំ វិបាកោ អត្ថិ អយំ លោកោ អត្ថិ បរោ លោកោ

លោកខាងមុខមិនមាន មាតាមិនមានគុណ បិតាមិនមានគុណ សត្វជាឧបបាតិកៈកំណើតមិនមាន ពួកសមណព្រាហ្មណ៍ក្នុងលោកដែលព្រមព្រៀង ប្រតិបត្តិត្រូវ ធ្វើឲ្យជាក់ច្បាស់ដោយប្រាជ្ញាដ៏ក្រៃលែងខ្លួនឯង ស្រាប់ដឹងនូវលោកនេះនិងលោកខាងមុខមិនមាន នេះឈ្មោះជាមិច្ឆាទិដ្ឋិ ។

(២៤៦) ម្នាលភិក្ខុទាំងឡាយ សម្មាទិដ្ឋិ តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ តថាគតសំដែងនូវសម្មាទិដ្ឋិថាមានពីរយ៉ាង ម្នាលភិក្ខុទាំងឡាយ គឺសម្មាទិដ្ឋិប្រកបដោយអាសវៈ ជាចំណែកនៃបុណ្យ ឲ្យផលជាឧបធិក្កិលេសក៏មាន ម្នាលភិក្ខុទាំងឡាយ សម្មាទិដ្ឋិដ៏ប្រសើរ មិនមានអាសវៈ ជាលោកុត្តរៈ ជាអង្គនៃមគ្គក៏មាន ។

(២៤៧) ម្នាលភិក្ខុទាំងឡាយ សម្មាទិដ្ឋិប្រកបដោយអាសវៈ ជាចំណែកនៃបុណ្យ ឲ្យផលជាឧបធិក្កិលេស តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ សេចក្តីយល់ថា ទានដែលបុគ្គលឲ្យហើយ មានផល បូជាតូច មានផល បូជាធំ មានផល ផលវិបាករបស់កម្ម ដែលសត្វធ្វើល្អ និងធ្វើអាក្រក់ មាន លោកនេះ មាន លោកខាងមុខ មាន

អត្ថិ មាតា អត្ថិ បិតា អត្ថិ សត្តា ឱបបាតិកា អត្ថិ លោកេ សមណព្រាហ្មណា សម្មគ្គតា សម្មាបដិបន្នា យេ ឥមញ្ច លោកំ បរញ្ច លោកំ សយំ អភិញ្ញា សច្ឆិកត្វា បវេទេន្តីតិ អយំ ភិក្ខវេ សម្មាទិដ្ឋិ សាសវា បុញ្ញភាគិយា ឧបធិវេបក្កា ។

(២៥៨) កតមា ច ភិក្ខវេ សម្មាទិដ្ឋិ អរិយា អនាសវា លោកុត្តរា មគ្គង្គា ។ យា ខោ ភិក្ខវេ អរិយចិត្តស្ស អនាសវចិត្តស្ស អរិយមគ្គសមង្គិនោ អរិយមគ្គំ ភាវយតោ បញ្ញា បញ្ញិន្ទ្រិយំ បញ្ញាពលំ ធម្មវិចយសម្ពោជ្ឈង្គោ សម្មាទិដ្ឋិ មគ្គង្គំ អយំ ភិក្ខវេ សម្មាទិដ្ឋិ អរិយា អនាសវា លោកុត្តរា មគ្គង្គា ។ សោ[១] មិច្ឆាទិដ្ឋិយា បហានាយ វាយមតិ សម្មាទិដ្ឋិយា ឧបសម្បទាយ ។ ស្វាស្ស[២] ហោតិ សម្មាវាយាមោ ។ សោ សតោ មិច្ឆាទិដ្ឋឹ បជហតិ សតោ សម្មាទិដ្ឋឹ ឧបសម្បជ្ជ វិហរតិ ។

១ ឱ យោ ។ ២ ឱ សាស្ស ។ ម. ស្វាយំ ។

មាតាមានគុណ បិតាមានគុណ សត្វជាឧបបាតិកៈកំណើតមាន ពួកសមណព្រាហ្មណ៍ក្នុងលោក ដែលព្រមព្រៀង ប្រតិបត្តិត្រូវ ធ្វើឲ្យជាក់ច្បាស់ ដោយប្រាជ្ញាដ៏ក្រៃលែងខ្លួនឯង ប្រកាសនូវលោកនេះផង លោកខាងមុខក៏មាន ម្នាលភិក្ខុទាំងឡាយ នេះឈ្មោះជាសម្មាទិដ្ឋិប្រកបដោយអាសវៈ ជាចំណែកនៃបុណ្យ ឲ្យផលជាឧបធិក្កិលេស ។

(២៥៨) ម្នាលភិក្ខុទាំងឡាយ សម្មាទិដ្ឋិដ៏ប្រសើរមិនមានអាសវៈ ជាលោកុត្តរៈ ជាអង្គនៃមគ្គ តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ បញ្ញា បញ្ញិន្ទ្រិយ បញ្ញាពលៈ ធម្មវិចយសម្ពោជ្ឈង្គ សម្មាទិដ្ឋិ អង្គនៃមគ្គ របស់បុគ្គលមានចិត្តជាអរិយៈ មានចិត្តមិនមានអាសវៈ អ្នកបរិបូណ៌ដោយអរិយមគ្គ អ្នកចំរើននូវអរិយមគ្គ ម្នាលភិក្ខុទាំងឡាយ នេះឈ្មោះជាសម្មាទិដ្ឋិដ៏ប្រសើរមិនមានអាសវៈ ជាលោកុត្តរៈ ជាអង្គនៃមគ្គ ។ បុគ្គលនោះព្យាយាម ដើម្បីលះបង់នូវមិច្ឆាទិដ្ឋិ បំពេញនូវសម្មាទិដ្ឋិ ។ សេចក្តីព្យាយាមនោះ ឈ្មោះជាសម្មាវាយាមៈរបស់បុគ្គលនោះ ។ បុគ្គលនោះមានសតិលះបង់នូវមិច្ឆាទិដ្ឋិ មានសតិផ្តេកផ្តួលចិត្តទៅកាន់សម្មាទិដ្ឋិ ។

សាស្ស[១] ហោតិ សម្មាសតិ ។ ឥតិស្សិមេ[២] តយោ ធម្មា សម្មាទិដ្ឋឹ អនុបរិធាវន្តិ អនុបរិវត្តន្តិ សេយ្យថីទំ សម្មាទិដ្ឋិ សម្មាវាយាមោ សម្មាសតិ ។

(២៥៩) តត្រ ភិក្ខវេ សម្មាទិដ្ឋិ បុព្វង្គមា ហោតិ ។ កថញ្ច ភិក្ខវេ សម្មាទិដ្ឋិ បុព្វង្គមា ហោតិ ។ មិច្ឆាសង្កប្បំ មិច្ឆាសង្កប្បោតិ បជានាតិ សម្មាសង្កប្បំ សម្មាសង្កប្បោតិ បជានាតិ ។ សាស្ស ហោតិ សម្មាទិដ្ឋិ ។

(២៦០) កតមោ ច ភិក្ខវេ មិច្ឆាសង្កប្បោ ។ កាមសង្កប្បោ ព្យាបាទសង្កប្បោ វិហឹសាសង្កប្បោ អយំ ភិក្ខវេ មិច្ឆាសង្កប្បោ ។

(២៦១) កតមោ ច ភិក្ខវេ សម្មាសង្កប្បោ ។ សម្មាសង្កប្បំបហំ ភិក្ខវេ ទ្វយំ វទាមិ អត្ថិ ភិក្ខវេ សម្មាសង្កប្បោ សាសវោ បុញ្ញភាគិយោ

---

១ សាយំ ។ ២ ម. ឥតិយិមេ ។

សតិនោះ ជាសម្មាសតិរបស់បុគ្គលនោះ ៗ ធម៌ទាំង ៣ ប្រការនេះ គឺសម្មាទិដ្ឋិ សម្មាវាយាមៈ សម្មាសតិ តែងតាមទៅតាមកេមនូវសម្មាទិដ្ឋិ ដោយប្រការដូច្នេះឯង ៗ

(២៥៩) ម្នាលភិក្ខុទាំងឡាយ បណ្ដាអង្គមគ្គទាំងនោះ សម្មាទិដ្ឋិ ជាធម្មជាតិដល់មុន ៗ ម្នាលភិក្ខុទាំងឡាយ សម្មាទិដ្ឋិជាធម្មជាតិដល់មុន តើដូចម្ដេច ៗ បុគ្គលដឹងច្បាស់នូវមិច្ឆាសង្កប្បៈ ថាជាមិច្ឆាសង្កប្បៈ ដឹងច្បាស់នូវសម្មាសង្កប្បៈ ថាជាសម្មាសង្កប្បៈ ៗ សេចក្ដីដឹងច្បាស់នោះ ជាសម្មាទិដ្ឋិរបស់បុគ្គលនោះ ៗ

(២៦០) ម្នាលភិក្ខុទាំងឡាយ មិច្ឆាសង្កប្បៈ តើដូចម្ដេច ៗ សេចក្ដីត្រិះរិះក្នុងកាម សេចក្ដីត្រិះរិះក្នុងការព្យាបាទ សេចក្ដីត្រិះរិះក្នុងការបៀតបៀន ម្នាលភិក្ខុទាំងឡាយ នេះឈ្មោះថា មិច្ឆាសង្កប្បៈ ៗ

(២៦១) ម្នាលភិក្ខុទាំងឡាយ សម្មាសង្កប្បៈ តើដូចម្ដេច ៗ ម្នាលភិក្ខុទាំងឡាយ តថាគតសំដែងនូវសម្មាសង្កប្បៈ ថាមានពីរយ៉ាង ម្នាលភិក្ខុទាំងឡាយ សម្មាសង្កប្បៈប្រកបដោយអាសវៈ ជាចំណែកនៃបុណ្យ

ឧបធិវេបក្កោ អត្ថិ ភិក្ខវេ សម្មាសង្កប្បោ អរិយោ អនាសវោ លោកុត្តរោ មគ្គង្គោ ។

(២៦២) កតមោ ច ភិក្ខវេ សម្មាសង្កប្បោ សាសវោ បុញ្ញភាគិយោ ឧបធិវេបក្កោ ។ នេក្ខម្ម-សង្កប្បោ អព្យាបាទសង្កប្បោ អវិហឹសាសង្កប្បោ អយំ ភិក្ខវេ សម្មាសង្កប្បោ សាសវោ បុញ្ញភាគិយោ ឧ-បធិវេបក្កោ ។

(២៦៣) កតមោ ច ភិក្ខវេ សម្មាសង្កប្បោ អរិយោ អនាសវោ លោកុត្តរោ មគ្គង្គោ ។ យោ ខោ ភិក្ខវេ អរិយចិត្តស្ស អនាសវចិត្តស្ស អរិយមគ្គសមង្គិនោ អរិយមគ្គំ ភាវយតោ តក្កោ វិតក្កោ សង្កប្បោ អប្បនា-ព្យប្បនា ចេតសោ អភិនិរោបនា វចីសង្ខារោ អយំ ភិក្ខវេ សម្មាសង្កប្បោ អរិយោ អនាសវោ លោកុត្តរោ មគ្គង្គោ ។ សោ មិច្ឆាសង្កប្បស្ស បហានាយ វាយមតិ សម្មាសង្កប្បស្ស ឧបសម្បទាយ ។ ស្វាស្ស[១] ហោតិ សម្មាវាយាមោ ។ សោ សតោ មិច្ឆាសង្កប្បំ បជហតិ

១ ឱ. សោស្ស ។

ឲ្យផលជាឧបធិក្កិលេសក៏មាន ម្នាលភិក្ខុទាំងឡាយ សម្មាសង្កប្បៈ ដ៏ប្រសើរ មិនមានអាសវៈ ជាលោកុត្តរៈ ជាអង្គនៃមគ្គក៏មាន ។

(៦៦៦) ម្នាលភិក្ខុទាំងឡាយ សម្មាសង្កប្ប ប្រកបដោយអាសវៈ ជាចំណែកនៃបុណ្យ ឲ្យផលជាឧបធិក្កិលេស តើដូចម្តេច ។ សេចក្តីត្រិះរិះក្នុងការចេញចាកកាម ត្រិះរិះក្នុងការមិនព្យាបាទ ត្រិះរិះក្នុងការមិនបៀតបៀន ម្នាលភិក្ខុទាំងឡាយ នេះឈ្មោះថាសម្មាសង្កប្បៈ ប្រកបដោយអាសវៈ ជាចំណែកនៃបុណ្យ ឲ្យផលជាឧបធិក្កិលេស ។

(៦៦៧) ម្នាលភិក្ខុទាំងឡាយ សម្មាសង្កប្បៈដ៏ប្រសើរ មិនមានអាសវៈ ជាលោកុត្តរៈ ជាអង្គនៃមគ្គ តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ សេចក្តីដញ្ជឹង រំពឹង ត្រិះរិះ ការញុំាងចិត្តឲ្យអប់នៃប ការឲ្យដិតស្អិត ការលើកចិត្ត សការៈតាក់តែងនូវវាចា របស់បុគ្គលមានចិត្តជាអរិយៈ មានចិត្តឥតអាសវៈ បរិបូណ៌ដោយអរិយមគ្គ អ្នកចំរើនអរិយមគ្គ ម្នាលភិក្ខុទាំងឡាយ នេះឈ្មោះថាសម្មាសង្កប្បៈដ៏ប្រសើរ ឥតអាសវៈ ជាលោកុត្តរៈ ជាអង្គនៃមគ្គ ។ បុគ្គលនោះ ព្យាយាមដើម្បីលះបង់នូវមិច្ឆាសង្កប្បៈ ដើម្បីបំពេញនូវសម្មាសង្កប្បៈ ។ សេចក្តីព្យាយាមនោះ ជាសម្មាវាយាមៈរបស់បុគ្គលនោះ ។ បុគ្គលនោះ មានសតិលះបង់នូវមិច្ឆាសង្កប្បៈ

សតោ សម្មាសតិយា ឧបសម្បជ្ជ វិហរតិ ។ សាស្ស ហោតិ សម្មាសតិ ។ ឥតិស្សិមេ តយោ ធម្មា សម្មាទិដ្ឋឹ អនុបរិធាវន្តិ អនុបរិវត្តន្តិ សេយ្យថីទំ សម្មាទិដ្ឋិ សម្មាវាយាមោ សម្មាសតិ ។

(២៦៤) តត្រ ភិក្ខវេ សម្មាទិដ្ឋិ បុព្វង្គមា ហោតិ ។ កថញ្ច ភិក្ខវេ សម្មាទិដ្ឋិ បុព្វង្គមា ហោតិ ។ មិច្ឆាវាចំ មិច្ឆាវាចាតិ បជានាតិ សម្មាវាចំ សម្មាវាចាតិ បជានាតិ ។ សាស្ស ហោតិ សម្មាទិដ្ឋិ ។

(២៦៥) កតមា ច ភិក្ខវេ មិច្ឆាវាចា ។ មុសាវាទោ បិសុណា វាចា ផរុសា វាចា សម្ផប្បលាបោ អយំ ភិក្ខវេ មិច្ឆាវាចា ។

(២៦៦) កតមា ច ភិក្ខវេ សម្មាវាចា ។ សម្មាវាចំបហំ ភិក្ខវេ ទ្វយំ វទាមិ អត្ថិ ភិក្ខវេ សម្មាវាចា សាសវា បុញ្ញភាគិយា ឧបធិវេបក្កា អត្ថិ ភិក្ខវេ សម្មាវាចា អរិយា អនាសវា លោកុត្តរា មគ្គង្គា ។

មានសតិផ្ចិតផ្ចង់ចិត្តទៅតាមសម្មាសង្កប្ប កំសម្រេចសម្រាន្តនៅ ។ សតិនោះ ឈ្មោះថាសម្មាសតិរបស់បុគ្គលនោះ ។ ធម៌ទាំង ៣ ប្រការនេះ គឺសម្មាទិដ្ឋិ សម្មាវាយាមៈ សម្មាសតិ រមែងហាមរា តាមកោមនូវសម្មាសង្កប្បៈ ដោយប្រការដូច្នេះឯង ។

(២៦៨) ម្នាលភិក្ខុទាំងឡាយ បណ្ដាមគ្គទាំងនោះ សម្មាទិដ្ឋិជាធម្មជាតិដល់មុន ។ ម្នាលភិក្ខុទាំងឡាយ សម្មាទិដ្ឋិជាធម្មជាតិដល់មុន តើដូចម្ដេច ។ បុគ្គល ដឹងច្បាស់នូវមិច្ឆាវាចា ថាជាមិច្ឆាវាចា ដឹងច្បាស់នូវសម្មាវាចា ថាជាសម្មាវាចា ។ សេចក្ដីដឹងច្បាស់នោះ ជាសម្មាទិដ្ឋិ របស់បុគ្គលនោះ ។

(២៦៩) ម្នាលភិក្ខុទាំងឡាយ មិច្ឆាវាចា តើដូចម្ដេច ។ ការនិយាយកុហក សំដីញុះញង់ សំដីអាក្រក់ សំដីឥតប្រយោជន៍ ម្នាលភិក្ខុទាំងឡាយ នេះឈ្មោះថាមិច្ឆាវាចា ។

(២៧០) ម្នាលភិក្ខុទាំងឡាយ សម្មាវាចា តើដូចម្ដេច ។ ម្នាលភិក្ខុទាំងឡាយ តថាគតសំដែងនូវសម្មាវាចា ថាមានពីរយ៉ាង ម្នាលភិក្ខុទាំងឡាយ សម្មាវាចាប្រកបដោយអាសវៈ ជាចំណែកនៃបុណ្យ ឲ្យផលជាឧបធិក្កិលេសក៏មាន ម្នាលភិក្ខុទាំងឡាយ សម្មាវាចាដ៏ប្រសើរ មិនមានអាសវៈ ជាលោកុត្តរៈ ជាអង្គនៃមគ្គក៏មាន ។

(២៦៧) កតមា ច ភិក្ខវេ សម្មាវាចា សាសវា បុញ្ញាភាគិយា ឧបធិវេបក្កា។ មុសាវាទា វេរមណី បិសុណាយ វាចាយ វេរមណី ផរុសាយ វាចាយ វេរមណី សម្ផប្បលាបា វេរមណី អយំ ភិក្ខវេ សម្មាវាចា សាសវា បុញ្ញាភាគិយា ឧបធិវេបក្កា។

(២៦៨) កតមា ច ភិក្ខវេ សម្មាវាចា អរិយា អនាសវា លោកុត្តរា មគ្គង្គា។ យា ខោ ភិក្ខវេ អរិយចិត្តស្ស អនាសវចិត្តស្ស អរិយមគ្គសមង្គិនោ អរិយមគ្គំ ភាវយតោ ចតូហិបិ វចីទុច្ចរិតេហិ អារតិ វិរតិ បដិវិរតិ វេរមណី អយំ ភិក្ខវេ សម្មាវាចា អរិយា អនាសវា លោកុត្តរា មគ្គង្គា។ សោ មិច្ឆាវាចាយ បហានាយ វាយមតិ

(២៦៧) ម្នាលភិក្ខុទាំងឡាយ សម្មាវាចាប្រកបដោយអាសវៈ ជាចំណែកនៃបុណ្យ ឲ្យផលជាឧបធិក្កិលេស តើដូចម្តេច ។ ការវៀរចាកមុសាវាទ វៀរចាកវាចាញុះញង់ វៀរចាកវាចាអាក្រក់ វៀរចាកពាក្យឥតប្រយោជន៍ ម្នាលភិក្ខុទាំងឡាយ នេះឈ្មោះថា សម្មាវាចាប្រកបដោយអាសវៈ ជាចំណែកនៃបុណ្យ ឲ្យផលជាឧបធិក្កិលេស ។

(២៦៨) ម្នាលភិក្ខុទាំងឡាយ សម្មាវាចាដ៏ប្រសើរ មិនមានអាសវៈ ជាលោកុត្តរៈ ជាអង្គនៃមគ្គ តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ ការខម ចៀស គេច វៀរចាកវចីទុច្ចរិតទាំង ៤ ប្រការ របស់បុគ្គលមានចិត្តជាអរិយៈ មានចិត្តឥតអាសវៈ បរិបូណ៌ដោយអរិយមគ្គ ចម្រើនអរិយមគ្គ ម្នាលភិក្ខុទាំងឡាយ នេះឈ្មោះថាសម្មាវាចាដ៏ប្រសើរ មិនមានអាសវៈ ជាលោកុត្តរៈ ជាអង្គនៃមគ្គ ។ បុគ្គលនោះ ព្យាយាមដើម្បីលះបង់នូវមិច្ឆាវាចា

សម្មាវាចាយ ឧបសម្បទាយ ។ សាស្ស ហោតិ សម្មាវាយាមោ ។ សោ សតោ មិច្ឆាវាចំ បជហតិ សតោ សម្មាវាចំ ឧបសម្បជ្ជ វិហរតិ ។ សាស្ស ហោតិ សម្មាសតិ ។ ឥតិស្សិមេ តយោ ធម្មា សម្មាវាចំ អនុបរិធាវន្តិ អនុបរិវត្តន្តិ សេយ្យថីទំ សម្មាទិដ្ឋិ សម្មាវាយាមោ សម្មាសតិ ។

(២៦៩) តត្រ ភិក្ខវេ សម្មាទិដ្ឋិ បុព្វង្គមា ហោតិ ។ កថញ្ច ភិក្ខវេ សម្មាទិដ្ឋិ បុព្វង្គមា ហោតិ ។ មិច្ឆាកម្មន្តំ មិច្ឆាកម្មន្តោតិ បជានាតិ សម្មាកម្មន្តំ សម្មាកម្មន្តោតិ បជានាតិ ។ សាស្ស ហោតិ សម្មាទិដ្ឋិ ។

(២៧០) កតមោ ច ភិក្ខវេ មិច្ឆាកម្មន្តោ ។ បាណាតិបាតោ អទិន្នាទានំ កាមេសុមិច្ឆាចារោ អយំ ភិក្ខវេ មិច្ឆាកម្មន្តោ ។

បំពេញនូវសម្មាវាចា ។ សេចក្តីព្យាយាមនោះ ជាសម្មាវាយាមៈរបស់បុគ្គលនោះ ។ បុគ្គលនោះ មានសតិរលឹកបង់នូវមិច្ឆាវាចា មានសតិផ្ដេកផ្ដួលចិត្តទៅរកសម្មាវាចា ។ សតិនោះ ជាសម្មាសតិរបស់បុគ្គលនោះ ។ ធម៌ទាំង ៣ ប្រការនេះ គឺសម្មាទិដ្ឋិ សម្មាវាយាមៈ សម្មាសតិ រមែងតាមចោមរោមនូវសម្មាវាចា ដោយប្រការដូច្នេះ ។

(៦៦៩) ម្នាលភិក្ខុទាំងឡាយ បណ្តាមគ្គទាំងនោះ សម្មាទិដ្ឋិជាធម្មជាតដល់មុន ។ ម្នាលភិក្ខុទាំងឡាយ សម្មាទិដ្ឋិជាធម្មជាតដល់មុន តើដូចម្តេច ។ បុគ្គល ដឹងច្បាស់នូវមិច្ឆាកម្មន្តៈ ថាជាមិច្ឆាកម្មន្តៈ ដឹងច្បាស់នូវសម្មាកម្មន្តៈ ថាជាសម្មាកម្មន្តៈ ។ សេចក្តីដឹងច្បាស់នោះ ជាសម្មាទិដ្ឋិរបស់បុគ្គលនោះ ។

(៦៧០) ម្នាលភិក្ខុទាំងឡាយ មិច្ឆាកម្មន្តៈ តើដូចម្តេច ។ ការសម្លាប់សត្វ ការលួចទ្រព្យគេ ការប្រព្រឹត្តខុសក្នុងកាមទាំងឡាយ ម្នាលភិក្ខុទាំងឡាយ នេះឈ្មោះថាមិច្ឆាកម្មន្តៈ ។

(២៧១) កតមោ ច ភិក្ខវេ សម្មាកម្មន្តោ ។ សម្មាកម្មន្តម្បហំ ភិក្ខវេ ទ្វយំ វទាមិ អត្ថិ ភិក្ខវេ សម្មាកម្មន្តោ សាសវោ បុញ្ញភាគិយោ ឧបធិវេបក្កោ អត្ថិ ភិក្ខវេ សម្មាកម្មន្តោ អរិយោ អនាសវោ លោកុត្តរោ មគ្គង្គោ ។

(២៧២) កតមោ ច ភិក្ខវេ សម្មាកម្មន្តោ សាសវោ បុញ្ញភាគិយោ ឧបធិវេបក្កោ ។ ឥធ ភិក្ខវេ បាណាតិបាតា វេរមណី អទិន្នាទានា វេរមណី កាមេសុ មិច្ឆាចារា វេរមណី អយំ ភិក្ខវេ សម្មាកម្មន្តោ សាសវោ បុញ្ញភាគិយោ ឧបធិវេបក្កោ ។

(២៧៣) កតមោ ច ភិក្ខវេ សម្មាកម្មន្តោ អរិយោ អនាសវោ លោកុត្តរោ មគ្គង្គោ ។ យា ខោ ភិក្ខវេ អរិយចិត្តស្ស អនាសវចិត្តស្ស អរិយមគ្គសមង្គិនោ អរិយមគ្គំ ភាវយតោ តីហិបិ កាយទុច្ចរិតេហិ អារតិ វិរតិ បដិវិរតិ វេរមណី អយំ ភិក្ខវេ សម្មាកម្មន្តោ អរិយោ អនាសវោ

(២៧១) ម្នាលភិក្ខុទាំងឡាយ សម្មាកម្មន្តៈ តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ តថាគតសំដែងនូវសម្មាកម្មន្តៈថាមានពីរយ៉ាង ម្នាលភិក្ខុទាំងឡាយ គឺសម្មាកម្មន្តៈប្រកបដោយអាសវៈ ជាចំណែកនៃបុណ្យ ឲ្យផលជាឧបធិក្កិលេសក៏មាន ម្នាលភិក្ខុទាំងឡាយ សម្មាកម្មន្តៈ ដ៏ប្រសើរ មិនមានអាសវៈ ជាលោកុត្តរៈ ជាអង្គនៃមគ្គក៏មាន ។

(២៧២) ម្នាលភិក្ខុទាំងឡាយ សម្មាកម្មន្តៈប្រកបដោយអាសវៈ ជាចំណែកនៃបុណ្យ ឲ្យផលជាឧបធិក្កិលេស តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ ការវៀរចាកសម្លាប់សត្វ វៀរចាកលួចទ្រព្យគេ វៀរចាកប្រព្រឹត្តខុសក្នុងកាមទាំងឡាយ ម្នាលភិក្ខុទាំងឡាយ នេះឈ្មោះថាសម្មាកម្មន្តៈ ប្រកបដោយអាសវៈ ជាចំណែកនៃបុណ្យ ឲ្យផលជាឧបធិក្កិលេស ។

(២៧៣) ម្នាលភិក្ខុទាំងឡាយ សម្មាកម្មន្តៈដ៏ប្រសើរ មិនមានអាសវៈ ជាលោកុត្តរៈ ជាអង្គនៃមគ្គ តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ ការតម ចៀស គេច វៀរចាកកាយទុច្ចរិតទាំង ៣ ប្រការ របស់បុគ្គលមានចិត្តជាអរិយៈ មានចិត្តមិនមានអាសវៈ បរិបូណ៌ដោយអរិយមគ្គ អ្នកចម្រើននូវអរិយមគ្គ ម្នាលភិក្ខុទាំងឡាយ នេះឈ្មោះថាសម្មាកម្មន្តៈ ដ៏ប្រសើរ មិនមានអាសវៈ

លោកុត្តរា មគ្គង្គា ។ សោ មិច្ឆាកម្មន្តស្ស បហា-
នាយ វាយមតិ សម្មាកម្មន្តស្ស ឧបសម្បទាយ ។
សាស្ស ហោតិ សម្មាវាយាមោ ។ សោ សតោ
មិច្ឆាកម្មន្តំ បជហតិ សតោ សម្មាកម្មន្តំ ឧបសម្បជ្ជ
វិហរតិ សាស្ស ហោតិ សម្មាសតិ ។ ឥតិស្សិមេ
តយោ ធម្មា សម្មាកម្មន្តំ អនុបរិធាវន្តិ អនុបរិវត្តន្តិ
សេយ្យថីទំ សម្មាទិដ្ឋិ សម្មាវាយាមោ សម្មាសតិ ។

(២៧៦) តត្រ ភិក្ខវេ សម្មាទិដ្ឋិ បុព្វង្គមា ហោ-
តិ ។ កថញ្ច ភិក្ខវេ សម្មាទិដ្ឋិ បុព្វង្គមា ហោតិ ។
មិច្ឆាអាជីវំ មិច្ឆាអាជីវោតិ បជានាតិ សម្មាអាជីវំ
សម្មាអាជីវោតិ បជានាតិ ។ សាស្ស ហោតិ
សម្មាទិដ្ឋិ ។

(២៧៧) កតមោ ច ភិក្ខវេ មិច្ឆាអាជីវោ ។
កុហនា លបនា នេមិត្តកតា និប្បេសិកតា លាភេន
លាភំ និជិគីសនតា អយំ ភិក្ខវេ មិច្ឆាអាជីវោ

ជាលោកុត្តរៈ ជាអង្គនៃមគ្គ ។ បុគ្គលនោះ ព្យាយាមដើម្បីលះបង់នូវមិច្ឆាកម្មន្តៈ ដើម្បីបំពេញនូវសម្មាកម្មន្តៈ ។ សេចក្តីព្យាយាមនោះជាសម្មាវាយាមៈរបស់បុគ្គលនោះ ។ បុគ្គលនោះ មានសតិលះបង់នូវមិច្ឆាកម្មន្តៈ មានសតិផ្តេកផ្តួលចិត្តទៅរកសម្មាកម្មន្តៈ ហើយសម្រេចសម្រាន្តនៅ ។ សតិនោះ ជាសម្មាសតិរបស់បុគ្គលនោះ ។ ធម៌ទាំង ៣ ប្រការនេះ គឺសម្មាទិដ្ឋិ សម្មាវាយាមៈ សម្មាសតិ តែងតាមចោមរោមនូវសម្មាកម្មៈ ដោយប្រការដូច្នេះ ។

(២៧៤) ម្នាលភិក្ខុទាំងឡាយ បណ្តាមគ្គទាំងនោះ សម្មាទិដ្ឋិជាធម្មជាតិដល់មុន ។ ម្នាលភិក្ខុទាំងឡាយ សម្មាទិដ្ឋិជាធម្មជាតិដល់មុនតើដូចម្តេច ។ បុគ្គលដឹងច្បាស់នូវមិច្ឆាអាជីវៈ ថាជាមិច្ឆាអាជីវៈ ដឹងច្បាស់នូវសម្មាអាជីវៈ ថាជាសម្មាអាជីវៈ ។ សេចក្តីដឹងច្បាស់នោះជាសម្មាទិដ្ឋិរបស់បុគ្គលនោះ ។

(២៧៥) ម្នាលភិក្ខុទាំងឡាយ មិច្ឆាអាជីវៈ តើដូចម្តេច ។ ការធ្វើសត្វលោកឲ្យស្ងើច និយាយលួងចិត្តគ្រហស្ថ ធ្វើបញ្ចិតបញ្ចៀងអ្នក លើកគេកើតខ្លួន ស្វែងលាភតាក់លាភ ម្នាលភិក្ខុទាំងឡាយ នេះឈ្មោះថាមិច្ឆាអាជីវៈ ។

(២៧៦) កតមោ ច ភិក្ខវេ សម្មាអាជីវោ ។ សម្មាអាជីវម្បហំ ភិក្ខវេ ទ្វយំ វទាមិ អត្ថិ ភិក្ខវេ សម្មាអាជីវោ សាសវោ បុញ្ញភាគិយោ ឧបធិវេបក្កោ អត្ថិ ភិក្ខវេ សម្មាអាជីវោ អរិយោ អនាសវោ លោកុត្តរោ មគ្គង្គោ ។

(២៧៧) កតមោ ច ភិក្ខវេ សម្មាអាជីវោ សាសវោ បុញ្ញភាគិយោ ឧបធិវេបក្កោ ។ ឥធ ភិក្ខវេ អរិយសាវកោ មិច្ឆាអាជីវំ បហាយ សម្មាអាជីវេន ជីវិកំ កប្បេតិ អយំ ភិក្ខវេ សម្មាអាជីវោ សាសវោ បុញ្ញភាគិយោ ឧបធិវេបក្កោ ។

(២៧៨) កតមោ ច ភិក្ខវេ សម្មាអាជីវោ អរិយោ អនាសវោ លោកុត្តរោ មគ្គង្គោ ។ យោ ខោ ភិក្ខវេ អរិយចិត្តស្ស អនាសវចិត្តស្ស អរិយមគ្គសមង្គិនោ អរិយមគ្គំ ភាវយតោ មិច្ឆាអាជីវា អារតិ វិរតិ បដិវិរតិ វេរមណី អយំ ភិក្ខវេ សម្មាអាជីវោ អរិយោ អនាសវោ លោកុត្តរោ

(២៧៦) ម្នាលភិក្ខុទាំងឡាយ សម្មាអាជីវៈ តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ តថាគតពោលនូវសម្មាអាជីវៈ ជាពីរយ៉ាង ម្នាលភិក្ខុទាំងឡាយ គឺសម្មាអាជីវៈប្រកបដោយអាសវៈ ជាចំណែកនៃបុណ្យ ឲ្យផលជាឧបធិក្កិលេសក៏មាន ម្នាលភិក្ខុទាំងឡាយ សម្មាអាជីវៈ ដ៏ប្រសើរ មិនមានអាសវៈ ជាលោកុត្តរៈ ជាអង្គនៃមគ្គក៏មាន ។

(២៧៧) ម្នាលភិក្ខុទាំងឡាយ សម្មាអាជីវៈប្រកបដោយអាសវៈ ជាចំណែកនៃបុណ្យ ឲ្យផលជាឧបធិក្កិលេស តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ អរិយសាវ័កក្នុងសាសនានេះ លះបង់នូវមិច្ឆាអាជីវៈ ចិញ្ចឹមជីវិតដោយសម្មាអាជីវៈ ម្នាលភិក្ខុទាំងឡាយ នេះឈ្មោះថា សម្មាអាជីវៈ ប្រកបដោយអាសវៈ ជាចំណែកនៃបុណ្យ ឲ្យផលជាឧបធិក្កិលេស ។

(២៧៨) ម្នាលភិក្ខុទាំងឡាយ សម្មាអាជីវៈដ៏ប្រសើរមិនមានអាសវៈ ជាលោកុត្តរៈ ជាអង្គនៃមគ្គ តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ ការតម ទៀស គេច វៀរចាកមិច្ឆាអាជីវៈរបស់បុគ្គលមានចិត្តជាអរិយៈ មានចិត្តមិនមានអាសវៈ បរិបូណ៌ដោយអរិយមគ្គ ចម្រើននូវអរិយមគ្គ ម្នាលភិក្ខុទាំងឡាយនេះឈ្មោះថាសម្មាអាជីវៈដ៏ប្រសើរមិនមានអាសវៈជាលោកុត្តរៈ

មគ្គង្គោ ។ សោ មិច្ឆាអាជីវស្ស បហានាយ វាយមតិ សម្មាអាជីវស្ស ឧបសម្បទាយ ។ ស្វាស្ស ហោតិ សម្មាវាយាមោ ។ សោ សតោ មិច្ឆាអាជីវំ បជហតិ សតោ សម្មាអាជីវំ ឧបសម្បជ្ជ វិហរតិ ។ សាស្ស ហោតិ សម្មាសតិ ។ ឥតិស្សិមេ តយោ ធម្មា សម្មាអាជីវំ អនុបរិធាវន្តិ អនុបរិវត្តន្តិ សេយ្យថីទំ សម្មាទិដ្ឋិ សម្មាវាយាមោ សម្មាសតិ ។

(២៣៩) តត្រ ភិក្ខវេ សម្មាទិដ្ឋិ បុព្វង្គមា ហោតិ។ កថញ្ច ភិក្ខវេ សម្មាទិដ្ឋិ បុព្វង្គមា ហោតិ ។ សម្មាទិដ្ឋិស្ស ភិក្ខវេ សម្មាសង្កប្បោ បហោតិ សម្មាសង្កប្បស្ស សម្មាវាចា បហោតិ សម្មាវាចស្ស សម្មាកម្មន្តោ បហោតិ សម្មាកម្មន្តស្ស សម្មាអាជីវោ បហោតិ សម្មាអាជីវស្ស សម្មាវាយាមោ បហោតិ

ជាអង្គនៃមគ្គ ។ បុគ្គលនោះ ព្យាយាមដើម្បីលះបង់នូវមិច្ឆាអាជីវៈ បំពេញនូវសម្មាអាជីវៈ ។ សេចក្តីព្យាយាមនោះ ជាសម្មាវាយាមៈរបស់បុគ្គលនោះ ។ បុគ្គលនោះ មានសតិលះបង់នូវមិច្ឆាអាជីវៈ មានសតិផ្តេកផ្តួលចិត្តទៅរកសម្មាអាជីវៈ ហើយសម្រេចសម្រាន្តនៅ ។ សតិនោះ ជាសម្មាសតិរបស់បុគ្គលនោះ ។ ធម៌ទាំង ៣ ប្រការនេះ គឺ សម្មាទិដ្ឋិ សម្មាវាយាមៈ សម្មាសតិ តែងតាមហោមរោមនូវសម្មាអាជីវៈនោះ ដោយប្រការដូច្នេះ ។

(២៧៩) ម្នាលភិក្ខុទាំងឡាយ បណ្តាមគ្គទាំងនោះ សម្មាទិដ្ឋិជាធម្មជាតិដល់មុន ។ ម្នាលភិក្ខុទាំងឡាយ សម្មាទិដ្ឋិជាធម្មជាតិដល់មុន តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ សម្មាសង្កប្បៈ កើតមានដល់បុគ្គលមានសម្មាទិដ្ឋិ សម្មាវាចា កើតមានដល់បុគ្គលមានសម្មាសង្កប្បៈ សម្មាកម្មន្តៈ កើតមានដល់បុគ្គលមានសម្មាវាចា សម្មាអាជីវៈ កើតមានដល់បុគ្គលមានសម្មាកម្មន្តៈ សម្មាវាយាមៈ កើតមានដល់បុគ្គលមានសម្មាអាជីវៈ

សម្មាវាយាមស្ស សម្មាសតិ បហោតិ សម្មាសតិស្ស សម្មាសមាធិ បហោតិ សម្មាសមាធិស្ស សម្មាញាណំ បហោតិ សម្មាញាណស្ស សម្មាវិមុត្តិ បហោតិ ។ ឥតិ ខោ ភិក្ខវេ អដ្ឋង្គសមន្នាគតោ សេក្ខោ[1] ទសង្គសមន្នាគតោ អរហា ហោតិ ។

(២៨០) តត្រ ភិក្ខវេ សម្មាទិដ្ឋិ បុព្វង្គមា ហោតិ ។ កថញ្ច ភិក្ខវេ សម្មាទិដ្ឋិ បុព្វង្គមា ហោតិ ។ សម្មាទិដ្ឋិស្ស ភិក្ខវេ មិច្ឆាទិដ្ឋិ និជ្ជិណ្ណា ហោតិ ។ យេ ច មិច្ឆាទិដ្ឋិបច្ចយា អនេកេ បាបកា អកុសលា ធម្មា សម្ភវន្តិ តេ ចស្ស និជ្ជិណ្ណា ហោន្តិ សម្មាទិដ្ឋិបច្ចយា ច អនេកេ កុសលា ធម្មា ភាវនាបារិបូរឹ គច្ឆន្តិ ។ សម្មាសង្កប្បស្ស ភិក្ខវេ មិច្ឆាសង្កប្បោ និជ្ជិណ្ណោ ហោតិ ។ បេ ។ សម្មាវាចស្ស ភិក្ខវេ មិច្ឆាវាចា និជ្ជិណ្ណា ហោតិ... សម្មាកម្មន្តស្ស ភិក្ខវេ មិច្ឆាកម្មន្តោ និជ្ជិណ្ណោ ហោតិ... សម្មាអាជីវស្ស ភិក្ខវេ

[1] ឱ. សេខោ បដិបទោ ។

សម្មាសតិ កើតមានដល់បុគ្គលមានសម្មាវាយាមៈ សម្មាសមាធិ កើតមានដល់បុគ្គលមានសម្មាសតិ សម្មាញាណៈ កើតមានដល់បុគ្គលមានសម្មាសមាធិ សម្មាវិមុត្តិ កើតមានដល់បុគ្គលមានសម្មាញាណៈ ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលប្រកបដោយអង្គ ៨ ឈ្មោះជាសេខៈ ប្រកបដោយអង្គ ១០ ឈ្មោះជាអរហន្ត ដោយប្រការដូច្នេះ ។

(៦៨០) ម្នាលភិក្ខុទាំងឡាយ បណ្ដាអង្គទាំងនោះ សម្មាទិដ្ឋិ ជាធម្មជាតិដល់មុន ។ ម្នាលភិក្ខុទាំងឡាយ សម្មាទិដ្ឋិជាធម្មជាតិដល់មុន តើដូចម្ដេច ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលមានសម្មាទិដ្ឋិ មិច្ឆាទិដ្ឋិតែងសាបសូន្យទៅ ។ អកុសលធម៌ទាំងឡាយណា ដ៏លាមកច្រើនប្រការ ដែលកើតឡើង ដោយមិច្ឆាទិដ្ឋិជាបច្ច័យ អកុសលធម៌ទាំងឡាយនោះ របស់បុគ្គលនោះ តែងសាបសូន្យ កុសលធម៌ទាំងឡាយដ៏ច្រើន ក៏ដល់នូវការបរិបូណ៌ដោយការចំរើន ព្រោះសម្មាទិដ្ឋិជាបច្ច័យ ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលមានសម្មាសង្កប្បៈ មិច្ឆាសង្កប្បៈ តែងសាបសូន្យ ។ បេ ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលមានសម្មាវាចា មិច្ឆាវាចា តែងសាបសូន្យ ... ម្នាលភិក្ខុទាំងឡាយ បុគ្គលមានសម្មាកម្មន្តៈ មិច្ឆាកម្មន្តៈតែងសាបសូន្យ... ម្នាលភិក្ខុទាំងឡាយ បុគ្គលមានសម្មាអាជីវៈ

មិច្ឆាអាជីវោ និជ្ជិណ្ណោ ហោតិ ... សម្មាវាយាមស្ស ភិក្ខវេ មិច្ឆាវាយាមោ និជ្ជិណ្ណោ ហោតិ ... សម្មាសតិស្ស ភិក្ខវេ មិច្ឆាសតិ និជ្ជិណ្ណា ហោតិ ... សម្មាសមាធិស្ស ភិក្ខវេ មិច្ឆាសមាធិ និជ្ជិណ្ណោ ហោតិ ... សម្មាញាណស្ស ភិក្ខវេ មិច្ឆាញាណំ និជ្ជិណ្ណំ ហោតិ ... សម្មាវិមុត្តិស្ស ភិក្ខវេ មិច្ឆាវិមុត្តិ និជ្ជិណ្ណា ហោតិ ។ យេ ច មិច្ឆាវិមុត្តិប្បច្ចយា អនេកេ បាបកា អកុសលា ធម្មា សម្ភវន្តិ តេ ចស្ស និជ្ជិណ្ណា ហោន្តិ សម្មាវិមុត្តិប្បច្ចយា ច អនេកេ កុសលា ធម្មា ភាវនាបារិបូរឹ គច្ឆន្តិ ។ ឥតិ ខោ ភិក្ខវេ វីសតិ កុសលបក្ខា វីសតិ អកុសលបក្ខា ។ មហាចត្តារីសកោ ធម្មបរិយាយោ បវត្តិតោ អប្បដិវត្តិយោ សមណេន វា ព្រាហ្មណេន វា ទេវេន វា មារេន វា ព្រហ្មុនា វា កេនចិ វា លោកស្មិន្តិ[១]

---

១ ឱ. ឥតិសទ្ទោ នត្ថិ ។

មិច្ឆាអាជីវៈតែងសាបសូន្យ ... ម្នាលភិក្ខុទាំងឡាយ បុគ្គលមានសម្មា-វាយាមៈ មិច្ឆាវាយាមៈតែងសាបសូន្យ... ម្នាលភិក្ខុទាំងឡាយ បុគ្គលមានសម្មាសតិ មិច្ឆាសតិ តែងសាបសូន្យ.. ម្នាលភិក្ខុទាំងឡាយ បុគ្គលមានសម្មាសមាធិ មិច្ឆាសមាធិ តែងសាបសូន្យ ... ម្នាលភិក្ខុទាំងឡាយ បុគ្គលមានសម្មាញាណៈ មិច្ឆាញាណៈ តែងសាបសូន្យ... ម្នាលភិក្ខុទាំងឡាយ បុគ្គលមានសម្មាវិមុត្តិ មិច្ឆាវិមុត្តិ តែងសាប-សូន្យ ។ អកុសលធម៌ទាំងឡាយណា ដ៏លាមកច្រើនប្រការ ដែលកើតដោយមិច្ឆាវិមុត្តិជាបច្ច័យ អកុសលធម៌ទាំងឡាយនោះ របស់បុគ្គលនោះ រមែងសាបសូន្យ កុសលធម៌ទាំងឡាយច្រើនប្រការ ក៏ដល់នូវការបរិបូណ៌ដោយភាវនាបាន ព្រោះសម្មាវិមុត្តិជាបច្ច័យ ។ ម្នាលភិក្ខុទាំងឡាយ ចំណែកខាងកុសល ៤០ ចំណែកខាងអកុសល ៤០ ដោយប្រការដូច្នេះ ។ ធម្មបរិយាយឈ្មោះមហាចត្តារីសកៈ ដែលតថាគតឲ្យប្រព្រឹត្តទៅហើយ សមណៈឬព្រាហ្មណ៍ ទេវតា មារ ឬព្រហ្ម បុគ្គលណាមួយក្នុងលោក ឲ្យប្រព្រឹត្តទៅមិនបានឡើយ ។

(២៨១) យេ ហិ កេចិ ភិក្ខវេ សមណា វា ព្រាហ្មណា វា ឥមំ មហាចត្តារីសកំ ធម្មបរិយាយំ គរហិតព្វំ បដិក្កោសិតព្វំ មញ្ញេយ្យុំ តស្ស ទិដ្ឋេវ ធម្មេ ទស សហធម្មិកា វាទានុវាទា គារយ្ហដ្ឋានំ(១) អាគច្ឆន្តិ ។ សម្មាទិដ្ឋិញ្ចេ ភវំ គរហតិ យេ ច មិច្ឆាទិដ្ឋី សមណព្រាហ្មណា តេ ភោតោ បុជ្ជា តេ ភោតោ បាសំសា ។ សម្មាសង្កប្បញ្ចេ ភវំ គរហតិ យេ ច មិច្ឆាសង្កប្បា សមណព្រាហ្មណា តេ ភោតោ បុជ្ជា តេ ភោតោ បាសំសា ។ សម្មាវាចញ្ចេ ភវំ គរហតិ... សម្មាកម្មន្តញ្ចេ ភវំ គរហតិ... សម្មាអាជីវញ្ចេ ភវំ គរហតិ... សម្មាវាយាមញ្ចេ ភវំ គរហតិ... សម្មាសតិញ្ចេ ភវំ គរហតិ... សម្មាសមាធិញ្ចេ ភវំ គរហតិ... សម្មាញាណញ្ចេ ភវំ គរហតិ... សម្មាវិមុត្តិញ្ចេ ភវំ គរហតិ យេ មិច្ឆាវិមុត្តី

---

១ ឧ. គារយ្ហំ ឋានំ ។ ម. គារយ្ហដ្ឋានា ។

(២៨១) ម្នាលភិក្ខុទាំងឡាយ សមណៈឬព្រាហ្មណ៍ណាមួយ គប្បីសំគាល់នូវធម្មបរិយាយ ឈ្មោះមហាចត្តារីសកៈនេះថា គួរតិះដៀល គួរហាមប្រាម ពាក្យទាំងឡាយប្រកបដោយធម៌ ១០ ប្រការ របស់បុគ្គលនោះ រមែងដល់នូវឋានៈគួរតិះដៀល ក្នុងបច្ចុប្បន្ន ។ បើអ្នកដ៏ចំរើនតិះដៀល នូវសម្មាទិដ្ឋិ ពួកសមណព្រាហ្មណ៍ណា ជាមិច្ឆាទិដ្ឋិ គួរអ្នកដ៏ចំរើនបូជា ពួកសមណព្រាហ្មណ៍នោះ គួរអ្នកដ៏ចំរើនសរសើរពួកសមណព្រាហ្មណ៍ នោះ ។ បើអ្នកដ៏ចម្រើនតិះដៀលនូវសម្មាសង្កប្បៈ ពួកសមណព្រាហ្មណ៍ ណា ជាមិច្ឆាសង្កប្បៈ គួរអ្នកដ៏ចម្រើនបូជាពួកសមណព្រាហ្មណ៍នោះ គួរអ្នកដ៏ចម្រើនសរសើរពួកសមណព្រាហ្មណ៍នោះ ។ បើអ្នកដ៏ចម្រើន តិះដៀលនូវសម្មាវាចា ... បើអ្នកដ៏ចម្រើនតិះដៀលនូវសម្មាកម្មន្តៈ ... បើ អ្នកដ៏ចម្រើនតិះដៀលនូវសម្មាអាជីវ... បើអ្នកដ៏ចម្រើនតិះដៀលនូវសម្មា វាយាមៈ... បើអ្នកដ៏ចម្រើនតិះដៀលនូវសម្មាសតិ ... បើអ្នកដ៏ចម្រើនតិះ ដៀលនូវសម្មាសមាធិ... បើអ្នកដ៏ចម្រើនតិះដៀលនូវសម្មាញាណៈ... បើ អ្នកដ៏ចម្រើនតិះដៀលនូវសម្មាវិមុត្តិ ពួកសមណព្រាហ្មណ៍ណាជាមិច្ឆាវិមុត្តិ

សមណព្រាហ្មណា តេ ភោតោ បុជ្ជា តេ ភោតោ បាសំសា ។ យេ ហិ កេចិ ភិក្ខវេ សមណា វា ព្រាហ្មណា វា ឥមំ មហាចត្តារីសកំ ធម្មបរិយាយំ គរហិតព្វំ បដិក្កោសិតព្វំ មញ្ញេយ្យុំ តស្ស ទិដ្ឋេវ ធម្មេ ឥមេ ទស សហធម្មិកា វាទានុវាទា គារយ្ហដ្ឋានំ អាគច្ឆន្តិ ។ យេបិ តេ ភិក្ខវេ អហេសុំ ឧក្កលា[១] វស្សភញ្ញា អហេតុវាទា អកិរិយវាទា នត្ថិកវាទា តេបិ មហាចត្តារីសកំ ធម្មបរិយាយំ ន គរហិតព្វំ ន បដិក្កោសិតព្វំ មញ្ញេយ្យុំ តំ កិស្ស ហេតុ និន្ទាព្យារោសឧបារម្ភភយាតិ ។ ឥទមវោច ភគវា អត្តមនា តេ ភិក្ខូ ភគវតោ ភាសិតំ អភិនន្ទុន្តិ ។

មហាចត្តារីសកសុត្តំ សត្តមំ និដ្ឋិតំ ។

១ ឱ. ឧក្កលា ។

គួរអ្នកដ៏ចម្រើនបូជាពួកសមណព្រាហ្មណ៍នោះ គួរអ្នកដ៏ចំរើនសរសើរពួកសមណព្រាហ្មណ៍នោះ ៗ ម្នាលភិក្ខុទាំងឡាយ ពួកសមណៈឬព្រាហ្មណ៍ណាមួយ គប្បីសំគាល់ នូវធម្មបរិយាយឈ្មោះមហាចត្តារីសកៈនេះ ថាគួរតិះដៀល គួរឃាត់ហាម វាទានុវាទប្រកបដោយអង្គ ១០ ប្រការនេះ របស់បុគ្គលនោះ តែងដល់នូវឋានៈគួរតិះដៀលក្នុងបច្ចុប្បន្ន ៗ ម្នាលភិក្ខុទាំងឡាយ ជនទាំងឡាយណា នៅក្នុងឧក្កលជនបទ ឈ្មោះវស្សៈ ១ ភញ្ញៈ ១ ជាអហេតុវាទ អកិរិយវាទ នត្ថិកវាទ ជនទាំងឡាយនោះ មិនគប្បីសំគាល់នូវធម្មបរិយាយឈ្មោះមហាចត្តារីសកៈថា គួរតិះដៀល មិនសំគាល់ថា គួរឃាត់ហាម ដំណើរនោះ ព្រោះហេតុអ្វី ព្រោះខ្លាចការនិន្ទា ប្រទូស្ត លើកទោស ៗ លុះព្រះមានព្រះភាគទ្រង់ត្រាស់ព្រះសូត្រនេះចប់ហើយ ភិក្ខុទាំងនោះ មានចិត្តត្រេកអរ រីករាយហើយ ចំពោះភាសិតរបស់ព្រះមានព្រះភាគ ៗ

ចប់ មហាចត្តារីសកសូត្រ ទី ៧ ។

# អដ្ឋមំ អានាបានស្សតិសុត្តំ

(២៨២) ឯវម្មេ សុតំ ។ ឯកំ សមយំ ភគវា សាវត្ថិយំ វិហរតិ បុព្វារាមេ មិគារមាតុ បាសាទេ សម្ពហុលេហិ អភិញ្ញាតេហិ អភិញ្ញាតេហិ ថេរេហិ សាវកេហិ សទ្ធឹ អាយស្មតា ច សារីបុត្តេន អាយស្មតា ច មហាមោគ្គល្លានេន អាយស្មតា ច មហាកស្សបេន អាយស្មតា ច មហាកច្ចាយនេន អាយស្មតា ច មហាកោដ្ឋិតេន អាយស្មតា ច មហាកប្បិនេន អាយស្មតា ច មហាចុន្ទេន អាយស្មតា ច រេវតេន អាយស្មតា ច អានន្ទេន អញ្ញេហិ ច អភិញ្ញាតេហិ អភិញ្ញាតេហិ ថេរេហិ សាវកេហិ សទ្ធឹ ។ តេន ខោ បន សមយេន ថេរា ភិក្ខូ(១) ឱវទន្តិ អនុសាសន្តិ ។ អប្បេកច្ចេ ថេរា ភិក្ខូ ទសបិ ភិក្ខូ ឱវទន្តិ អនុសាសន្តិ

---

១ ឱ. ម. នវេ ភិក្ខូ ឯត្ថន្តរេ ទិស្សតិ ។

# អានាបានស្សតិសូត្រ ទី ៨

(២៨២) ខ្ញុំបានស្ដាប់មក យ៉ាងនេះ ។ សម័យមួយ ព្រះមានព្រះភាគ ទ្រង់គង់នៅក្នុងប្រាសាទមិគារមាតា ក្នុងបុព្វារាម ជិតក្រុងសាវត្ថី ព្រមដោយសាវ័កទាំងឡាយ ជាថេរៈច្រើនរូប ដែលមានកេរ្តិ៍ឈ្មោះល្បីល្បាញជាងគេ គឺព្រះសារីបុត្រមានអាយុ ១ ព្រះមហាមោគ្គល្លានមានអាយុ ១ ព្រះមហាកស្សបមានអាយុ ១ ព្រះមហាកច្ចាយនៈមានអាយុ ១ ព្រះមហាកោដ្ឋិតៈមានអាយុ ១ ព្រះមហាកប្បិនៈមានអាយុ ១ ព្រះមហាចុន្ទមានអាយុ ១ ព្រះរេវតមានអាយុ ១ ព្រះអានន្ទមានអាយុ ១ ព្រមដោយសាវ័កទាំងឡាយជាថេរៈដទៃ ៗ ទៀត ដែលមានឈ្មោះល្បីល្បាញ ។ ក៏សម័យនោះឯង ភិក្ខុទាំងឡាយជាថេរៈ តែងទូន្មាន ប្រៀនប្រដៅ ( ពួកភិក្ខុថ្មី ៗ ) ភិក្ខុជាថេរៈពួកខ្លះ ទូន្មាន ប្រៀនប្រដៅភិក្ខុ ១០ រូប ក៏មាន

អប្បេកច្ចេ ថេរា ភិក្ខូ វីសម្បិ ភិក្ខូ ឱវទន្តិ អនុសាសន្តិ អប្បេកច្ចេ ថេរា ភិក្ខូ តឹសម្បិ ភិក្ខូ ឱវទន្តិ អនុសាសន្តិ អប្បេកច្ចេ ថេរា ភិក្ខូ ចត្តាឡីសម្បិ ភិក្ខូ ឱវទន្តិ អនុសាសន្តិ ។ តេ ច នវា ភិក្ខូ ថេរេហិ ភិក្ខូហិ ឱវទិយមានា អនុសាសិយមានា ឱឡារំ បុព្វេនាបរំ វិសេសំ បជានន្តិ(១) ។

(២៨៣) តេន ខោ បន សមយេន ភគវា តទហុ-បោសថេ បណ្ណរសេ បវារណាយ បុណ្ណាយ បុណ្ណមាយ រត្តិយា ភិក្ខុសង្ឃបរិវុតោ អព្ភោកាសេ និសិន្នោ ហោតិ ។ អថ ខោ ភគវា តុណ្ហីភូតំ(២) ភិក្ខុសង្ឃំ អនុវិលោកេត្វា ភិក្ខូ អាមន្តេសិ អារទ្ធោស្មិ ភិក្ខវេ ឥមាយ បដិបទាយ អារទ្ធចិត្តោស្មិ ភិក្ខវេ ឥមាយ បដិបទាយ តស្មាតិហ ភិក្ខវេ ភិយ្យោសោ មត្តាយ វីរិយំ អារភថ អប្បត្តស្ស បត្តិយា អនធិគតស្ស អធិគមាយ អសច្ឆិកតស្ស សច្ឆិកិរិយាយ ឥធេវាហំ សាវត្ថិយំ កោមុទឹ ចាតុមាសិនឹ អាគមេស្សាមីតិ ។

១ ឱ. ជានន្តិ ។ ម. សញ្ជានន្តិ ។ ឱ. ម. តុណ្ហីភូតំ តុណ្ហីភូតន្តិ ទិស្សតិ ។

ភិក្ខុជាថេរៈពួកខ្លះ ទូន្មាន ប្រៀនប្រដៅភិក្ខុ ២០ រូបក៏មាន ភិក្ខុជាថេរៈពួកខ្លះ ទូន្មាន ប្រៀនប្រដៅភិក្ខុ ៣០ រូបក៏មាន ភិក្ខុជាថេរៈពួកខ្លះ ទូន្មាន ប្រៀនប្រដៅភិក្ខុ ៤០ រូបក៏មាន ។ ចំណែកខាងភិក្ខុថ្មីអម្បាលនោះ កាលភិក្ខុទាំងឡាយជាថេរៈ កំពុងទូន្មាន ប្រៀនប្រដៅ ក៏ដឹងគុណវិសេសជាឧឡារិកជាងដើម ។

(២៨៣) សម័យនោះឯង ព្រះមានព្រះភាគ មានភិក្ខុសង្ឃចោមរោម ទ្រង់គង់ក្នុងទីវាលស្រឡះ នាថ្ងៃបណ្ណរសទុបោសថនោះ គឺជាថ្ងៃបវារណាដ៏ប្រពៃ ក្នុងរាត្រីមានព្រះចន្ទពេញវង់ ។ លំដាប់នោះ ព្រះមានព្រះភាគទ្រង់ទតភិក្ខុសង្ឃ ដែលអង្គុយស្ងៀម ហើយត្រាស់នឹងភិក្ខុទាំងឡាយថា ម្នាលភិក្ខុទាំងឡាយ តថាគតត្រេកអរចំពោះបដិបទានេះ ម្នាលភិក្ខុទាំងឡាយ តថាគតមានចិត្តត្រេកអរចំពោះបដិបទានេះ ម្នាលភិក្ខុទាំងឡាយ ព្រោះហេតុនោះ អ្នកទាំងឡាយ ចូរប្រារព្ធសេចក្តីព្យាយាម ឲ្យលើសជាងប្រមាណចុះ ដើម្បីឲ្យដល់ធម៌ ដែលខ្លួនមិនទាន់ដល់ ដើម្បីសម្រេចធម៌ដែលខ្លួនមិនទាន់បានសម្រេច ដើម្បីធ្វើឲ្យជាក់ច្បាស់នូវធម៌ ដែលខ្លួនមិនទាន់ធ្វើឲ្យជាក់ច្បាស់ តថាគតនឹងរង់ចាំអ្នកទាំងឡាយក្នុងក្រុងសាវត្ថីនេះឯង អស់ទីបំផុតនៃខែបួន ដែលជាកាលមានផ្កាកុមុទរីក ( ខែកត្តិក ) ។

អស្សោសុំ ខោ ជានបទា ភិក្ខូ ភគវា កិរ តត្ថ សាវត្ថិយំ កោមុទឹ ចាតុម្មាសិនឹ អាគមេស្សតីតិ ។ តេ(១) ជានបទា ភិក្ខូ សាវត្ថិយំ ឱសរន្តិ ភគវន្តំ ទស្សនាយ ។ តេ ច(២) ថេរា ភិក្ខូ ភិយ្យោសោ មត្តាយ នវេ ភិក្ខូ ឱវទន្តិ អនុសាសន្តិ ។ អប្បេកច្ចេ ថេរា ភិក្ខូ ទសបិ ភិក្ខូ ឱវទន្តិ អនុសាសន្តិ អប្បេកច្ចេ ថេរា ភិក្ខូ វីសម្បិ ភិក្ខូ ឱវទន្តិ អនុសាសន្តិ អប្បេកច្ចេ ថេរា ភិក្ខូ តឹសម្បិ ភិក្ខូ ឱវទន្តិ អនុសាសន្តិ អប្បេកច្ចេ ថេរា ភិក្ខូ ចត្តាឡីសម្បិ ភិក្ខូ ឱវទន្តិ អនុសាសន្តិ ។ តេ ច នវា ភិក្ខូ ថេរេហិ ភិក្ខូហិ ឱវទិយមានា អនុសាសិយមានា ឧឡារំ បុព្វេនាបរំ វិសេសំ បជានន្តិ ។

[២៨៦] តេន ខោ បន សមយេន ភគវា តទហុបោសថេ បណ្ណរសេ កោមុទិយា ចាតុម្មាសិនិយា បុណ្ណាយ បុណ្ណមាយ រត្តិយា ភិក្ខុសង្ឃបរិវុតោ អព្ភោកាសេ និសិន្នោ ហោតិ ។

---

១ ឱ. តេបិ ។ ២ ម. ថេរា ។

ភិក្ខុទាំងឡាយអ្នកនៅក្នុងជនបទ បានឮដំណឹងថា ព្រះមានព្រះភាគ នឹងនៅចាំក្នុងក្រុងសាវត្ថីនោះឯង អស់ទីបំផុតនៃខែបួន ដែលជាកាលមានផ្កាកម្ពុទរីក ។ ទើបភិក្ខុអ្នកនៅក្នុងជនបទទាំងនោះ ប្រជុំគ្នាក្នុងក្រុងសាវត្ថី ដើម្បីជួបនឹងព្រះមានព្រះភាគ ។ ចំណែកភិក្ខុទាំងឡាយជាថេរៈនោះ ក៏ទូន្មាន ប្រៀនប្រដៅពួកភិក្ខុថ្មីឲ្យលើសជាងប្រមាណ ។ ភិក្ខុជាថេរៈពួកខ្លះ ទូន្មាន ប្រៀនប្រដៅភិក្ខុ ១០ រូបក៏មាន ភិក្ខុជាថេរៈពួកខ្លះ ទូន្មាន ប្រៀនប្រដៅភិក្ខុ ២០ រូបក៏មាន ភិក្ខុជាថេរៈពួកខ្លះ ទូន្មាន ប្រៀនប្រដៅភិក្ខុ ៣០ រូបក៏មាន ភិក្ខុជាថេរៈពួកខ្លះ ទូន្មាន ប្រៀនប្រដៅភិក្ខុ ៤០ រូបក៏មាន ។ ចំណែកភិក្ខុថ្មីអម្បាលនោះ កាលពួកភិក្ខុជាថេរៈ កំពុងទូន្មាន ប្រៀនប្រដៅ ក៏ដឹងគុណវិសេសជាឧឡារិក ជាងដើមតទៅទៀត ។

[២៨៨] ក៏សម័យនោះឯង ព្រះមានព្រះភាគ មានភិក្ខុសង្ឃចោមរោម ទ្រង់គង់នៅក្នុងទីវាល ក្នុងរាត្រីមានព្រះចន្ទពេញវង់ ជារាត្រីមានវេលាភ្លឺគ្រប់គ្រាន់ហើយ ជាទីបំផុតនៃខែបួន ជាកាលមានផ្កាកម្ពុទរីក ជាថ្ងៃឧបោសថទី ១៥ គឺពេញបូណ៌មីខែកត្តិក ។

អថខោ ភគវា តុណ្ហីភូតំ ភិក្ខុសង្ឃំ អនុវិលោកេត្វា ភិក្ខូ អាមន្តេសិ អបលាបាយំ ភិក្ខវេ បរិសា និប្បលា-បាយំ ភិក្ខវេ បរិសា សុទ្ធា សារេ បតិដ្ឋិតា ។ តថារូបោ អយំ ភិក្ខវេ ភិក្ខុសង្ឃោ តថារូបា អយំ ភិក្ខវេ បរិសា យថារូបា បរិសា អាហុនេយ្យា បាហុនេយ្យា ទក្ខិណេយ្យា អញ្ជលិករណីយា[១] អនុត្តរំ បុញ្ញក្ខេត្តំ លោកស្ស[២] ។ តថារូបោ អយំ ភិក្ខវេ ភិក្ខុសង្ឃោ តថារូបា អយំ ភិក្ខវេ បរិសា យថារូបាយ បរិសាយ អប្បំ ទិន្នំ ពហុ[៣] ហោតិ ពហុ[៤] ទិន្នំ ពហុតរំ ។ តថារូបោ អយំ ភិក្ខវេ ភិក្ខុសង្ឃោ តថារូបា អយំ ភិក្ខវេ បរិសា យថារូបា បរិសា ទុល្លភា ទស្សនាយ លោកស្ស ។

---

១ ម. អាហុនេយ្យោ បាហុនេយ្យោ ទក្ខិណេយ្យោ អញ្ជលិករណីយោតិ ទិស្សតិ ។ ២ ម. លោកស្សាតិ ទិស្សតិ ។ ៣-៤ ម. ពហុំ ។

លំដាប់នោះ ព្រះមានព្រះភាគទ្រង់ទតភិក្ខុសង្ឃ ដែលអង្គុយស្ងៀម ហើយត្រាស់នឹងភិក្ខុទាំងឡាយថា ម្នាលភិក្ខុទាំងឡាយ បរិស័ទនេះស្ងាត់ ហើយ ម្នាលភិក្ខុទាំងឡាយ បរិស័ទនេះស្ងាត់ចាកការបេរោ ហើយឋិតនៅក្នុងធម៌ដែលជាខ្លឹមសារដ៏បរិសុទ្ធ ។ បរិស័ទមានសភាពយ៉ាងណា ដែលគួរដល់ការបូជា គួរដល់អាគន្តុកទាន គួរដល់ទក្ខិណាទាន គួរដល់អញ្ជលិកម្ម ជាបុញ្ញក្ខេត្តដ៏ប្រសើររបស់សត្វលោក ម្នាលភិក្ខុទាំងឡាយ ភិក្ខុសង្ឃនេះមានសភាពយ៉ាងនោះ ម្នាលភិក្ខុទាំងឡាយ បរិស័ទនេះក៏មានសភាពយ៉ាងនោះដែរ ។ ទានតិចតួចដែលបុគ្គលឲ្យហើយ នៅជាទានមានផលច្រើន ឬទានច្រើនដែលបុគ្គលឲ្យហើយ ក៏រឹតតែមានផលច្រើន ក្នុងបរិស័ទមានសភាពយ៉ាងណា ម្នាលភិក្ខុទាំងឡាយ ភិក្ខុសង្ឃនេះ ក៏មានសភាពយ៉ាងនោះ ម្នាលភិក្ខុទាំងឡាយ បរិស័ទនេះ ក៏មានសភាពយ៉ាងនោះដែរ ។ បរិស័ទមានសភាពយ៉ាងណា ដែលសត្វលោកបានឃើញដោយក្រ ម្នាលភិក្ខុទាំងឡាយ ភិក្ខុសង្ឃនេះក៏មានសភាពយ៉ាងនោះ ម្នាលភិក្ខុទាំងឡាយ បរិស័ទនេះ ក៏មានសភាពយ៉ាងនោះដែរ ។

តថារូបោ អយំ ភិក្ខវេ ភិក្ខុសង្ឃោ តថារូបាយំ ភិក្ខវេ បរិសា យថារូប បរិសំ អលំ យោជនគណនានិ ទស្សនាយ គន្តុំ បុដំសេបិ(១) ។

(២៨៨) សន្តិ ភិក្ខវេ ភិក្ខូ ឥមស្មឹ ភិក្ខុសង្ឃេ អរហន្តោ ខីណាសវា វុសិតវន្តោ កតករណីយា ឱហិតភារា អនុប្បត្តសទត្ថា បរិក្ខីណភវសំយោជនា សម្មទញ្ញា វិមុត្តា ឯវរូបាបិ ភិក្ខវេ សន្តិ ភិក្ខូ ឥមស្មឹ ភិក្ខុសង្ឃេ ។ សន្តិ ភិក្ខវេ ភិក្ខូ ឥមស្មឹ ភិក្ខុសង្ឃេ បញ្ចន្នំ ឱរម្ភាគិយានំ សំយោជនានំ បរិក្ខយា ឱបបាតិកា តត្ថ បរិនិព្វាយិនោ អនាវត្តិធម្មា តស្មា លោកា ឯវរូបាបិ ភិក្ខវេ សន្តិ ភិក្ខូ ឥមស្មឹ ភិក្ខុសង្ឃេ ។ សន្តិ ភិក្ខវេ ភិក្ខូ ឥមស្មឹ ភិក្ខុសង្ឃេ

១ ឱ. ម. បុដោសេនាបិ ទិស្សតិ ។ ឥតោ បរំ តថារូបោ អយំ ភិក្ខវេ ភិក្ខុសង្ឃោ តថារូបាយំ ភិក្ខវេ បរិសាតិបិ តថារូបោ អយំ ភិក្ខវេ ភិក្ខុសង្ឃោតិបិ កត្ថចិ បោត្ថកេ ទិស្សន្តិ ។

បរិស័ទមានសភាពយ៉ាងណា ដែលបុគ្គលគួរស្ពាយស្បៀង ដើរតាមរកមើលអស់ទីរាប់ដោយយោជន៍ ម្នាលភិក្ខុទាំងឡាយ ភិក្ខុសង្ឃនេះក៏មានសភាពយ៉ាងនោះ ម្នាលភិក្ខុទាំងឡាយ បរិស័ទនេះ ក៏មានសភាពយ៉ាងនោះដែរ ។

(២៨៥) ម្នាលភិក្ខុទាំងឡាយ ក្នុងភិក្ខុសង្ឃនេះ តែងមានពួកភិក្ខុជាអរហន្តខីណាស្រព មានព្រហ្មចរិយធម៌នៅរួចហើយ បានធ្វើកិច្ចដែលគួរធ្វើស្រេចហើយ មានភារៈដាក់ចុះហើយ មានប្រយោជន៍ចំពោះខ្លួនសម្រេចហើយ មានសំយោជនៈក្នុងភពអស់ហើយ មានចិត្តផុតវិសេសហើយ ព្រោះដឹងដោយប្រពៃ ម្នាលភិក្ខុទាំងឡាយ ពួកភិក្ខុមានសភាពយ៉ាងនេះ តែងមាននៅក្នុងភិក្ខុសង្ឃនេះ ។ ម្នាលភិក្ខុទាំងឡាយ ក្នុងភិក្ខុសង្ឃនេះ មានពួកភិក្ខុជាឧបបាតិកៈកំណើត ហើយបរិនិព្វានក្នុងលោកនោះ មិនវិលត្រឡប់ចាកលោកនោះមកវិញទៀយ ( សុទ្ធាវាស ) ព្រោះអស់សំយោជនៈជាចំណែកខាងក្រោម ៥ ម្នាលភិក្ខុទាំងឡាយ ពួកភិក្ខុមានសភាពយ៉ាងនេះ តែងមាននៅក្នុងភិក្ខុសង្ឃនេះ ។ ម្នាលភិក្ខុទាំងឡាយ ក្នុងភិក្ខុសង្ឃនេះ

តិណ្ណំ សញ្ញោជនានំ បរិក្ខយា រាគទោសមោហានំ តនុត្តា សកទាគាមិនោ សកិទេវ ឥមំ លោកំ អាគន្ត្វា ទុក្ខស្សន្តំ ករិស្សន្តិ ឯវរូបាបិ ភិក្ខវេ សន្តិ ភិក្ខូ ឥមស្មឹ ភិក្ខុសង្ឃេ ។ សន្តិ ភិក្ខវេ ភិក្ខូ ឥមស្មឹ ភិក្ខុសង្ឃេ តិណ្ណំ សញ្ញោជនានំ បរិក្ខយា សោតាបន្នា អវិនិបាតធម្មា និយតា សម្ពោធិបរាយណា ឯវរូបាបិ ភិក្ខវេ សន្តិ ភិក្ខូ ឥមស្មឹ ភិក្ខុសង្ឃេ ។ សន្តិ ភិក្ខវេ ភិក្ខូ ឥមស្មឹ ភិក្ខុសង្ឃេ ចតុន្នំ សតិបដ្ឋានានំ ភាវនានុយោគមនុយុត្តា វិហរន្តិ ឯវរូបាបិ ភិក្ខវេ សន្តិ ភិក្ខូ ឥមស្មឹ ភិក្ខុសង្ឃេ ។

(២៨៦) សន្តិ ភិក្ខវេ ភិក្ខូ ឥមស្មឹ ភិក្ខុសង្ឃេ ចតុន្នំ សម្មប្បធានានំ ភាវនានុយោគមនុយុត្តា វិហរន្តិ ... ចតុន្នំ ឥទ្ធិបាទានំ ... បញ្ចន្នំ ឥន្ទ្រិយានំ ...

មានភិក្ខុជាសកទាគាមី នឹងមកកាន់លោកនេះម្តងទៀត ហើយធ្វើនូវទីបំផុតនៃទុក្ខបាន ព្រោះអស់សំយោជនៈ ៣ ព្រោះមានរាគៈទោសៈនិងមោហៈស្រាលស្តើង ម្នាលភិក្ខុទាំងឡាយ ពួកភិក្ខុមានសភាពយ៉ាងនេះ តែងមាននៅក្នុងភិក្ខុសង្ឃនេះ ៗ ម្នាលភិក្ខុទាំងឡាយ ក្នុងភិក្ខុសង្ឃនេះ មានពួកភិក្ខុជាសោតាបន្នៈ មានសភាពមិនធ្លាក់ចុះក្នុងអបាយ ជាបុគ្គលទៀង មានសម្ពោធិញាណប្រព្រឹត្តទៅខាងមុខ ព្រោះអស់សំយោជនៈ ៣ ម្នាលភិក្ខុទាំងឡាយ ពួកភិក្ខុមានសភាពយ៉ាងនេះ តែងមាននៅក្នុងភិក្ខុសង្ឃនេះ ៗ ម្នាលភិក្ខុទាំងឡាយ ក្នុងភិក្ខុសង្ឃនេះ មានពួកភិក្ខុជាអ្នកប្រកបរឿយៗ នូវសេចក្តីព្យាយាម ជាគ្រឿងចម្រើននូវសតិប្បដ្ឋានទាំង ៤ សម្រាន្តនៅដោយឥរិយាបថទាំង ៤ ម្នាលភិក្ខុទាំងឡាយ ពួកភិក្ខុមានសភាពយ៉ាងនេះ តែងមានក្នុងភិក្ខុសង្ឃនេះ ៗ

(៤៨៦) ម្នាលភិក្ខុទាំងឡាយ ក្នុងភិក្ខុសង្ឃនេះ មានពួកភិក្ខុជាអ្នកប្រកបរឿយ ៗ នូវសេចក្តីព្យាយាមជាគ្រឿងចម្រើននូវសម្មប្បធាន ៤ សម្រាន្តនៅដោយឥរិយាបថទាំង៤ ... ឥទ្ធិបាទ ៤... ឥន្ទ្រិយ ៥ ...

បញ្ចន្នំ ពលានំ... សត្តន្នំ ពោជ្ឈង្គានំ... អរិយស្ស
អដ្ឋង្គិកស្ស មគ្គស្ស ភាវនានុយោគមនុយុត្តា វិហរន្តិ
ឯវរូបាបិ ភិក្ខវេ សន្តិ ភិក្ខូ ឥមស្មឹ ភិក្ខុសង្ឃេ ។
សន្តិ ភិក្ខវេ ភិក្ខូ ឥមស្មឹ ភិក្ខុសង្ឃេ មេត្តាភាវនា-
នុយោគមនុយុត្តា វិហរន្តិ... ករុណាភាវនានុយោគមនុ-
យុត្តា វិហរន្តិ... មុទិតាភាវនានុយោគមនុយុត្តា វិហ-
រន្តិ ឧបេក្ខាភាវនានុយោគមនុយុត្តា វិហរន្តិ... អសុ-
ភភាវនានុយោគមនុយុត្តា វិហរន្តិ... អនិច្ចសញ្ញាភាវ-
នានុយោគមនុយុត្តា វិហរន្តិ ឯវរូបាបិ ភិក្ខវេ សន្តិ
ភិក្ខូ ឥមស្មឹ ភិក្ខុសង្ឃេ ។

ពលៈ ៥ ... ពោជ្ឈង្គ ៧ ... ជាអ្នកប្រកបរឿយ ៗ នូវសេចក្តីព្យាយាមជាគ្រឿងចម្រើននូវមគ្គប្រកបដោយអង្គ ៨ ដ៏ប្រសើរ សម្រាន្តនៅដោយឥរិយាបថទាំង ៤ ម្នាលភិក្ខុទាំងឡាយ ពួកភិក្ខុមានសភាពយ៉ាងនេះតែងមាននៅក្នុងភិក្ខុសង្ឃនេះ ៗ ម្នាលភិក្ខុទាំងឡាយ ក្នុងភិក្ខុសង្ឃនេះមានពួកភិក្ខុជាអ្នកប្រកបរឿយ ៗ នូវសេចក្តីព្យាយាមជាគ្រឿងចម្រើននូវមេត្តា សម្រាន្តនៅដោយឥរិយាបថទាំង ៤ ... ជាអ្នកប្រកបរឿយ ៗ នូវសេចក្តីព្យាយាមជាគ្រឿងចម្រើននូវករុណា សម្រាន្តនៅដោយឥរិយាបថទាំង ៤ ... ជាអ្នកប្រកបរឿយ ៗ នូវសេចក្តីព្យាយាមជាគ្រឿងចម្រើននូវមុទិតា សម្រាន្តនៅដោយឥរិយាបថទាំង ៤ ... ជាអ្នកប្រកបរឿយ ៗ នូវសេចក្តីព្យាយាមជាគ្រឿងចម្រើននូវឧបេក្ខា សម្រាន្តនៅដោយឥរិយាបថទាំង ៤ ... ជាអ្នកប្រកបរឿយ ៗ នូវសេចក្តីព្យាយាមជាគ្រឿងចម្រើននូវអសុភ សម្រាន្តនៅដោយឥរិយាបថទាំង ៤ .. ជាអ្នកប្រកបរឿយ ៗ នូវសេចក្តីព្យាយាមជាគ្រឿងចម្រើននូវអនិច្ចសញ្ញា សម្រាន្តនៅដោយឥរិយាបថទាំង ៤ ម្នាលភិក្ខុទាំងឡាយ ពួកភិក្ខុមានសភាពយ៉ាងនេះតែងមាននៅក្នុងភិក្ខុសង្ឃនេះ ៗ

(២៨៧) សន្តិ ភិក្ខវេ ភិក្ខូ ឥមស្មឹ ភិក្ខុសង្ឃេ អានាបានស្សតិភាវនានុយោគមនុយុត្តា វិហរន្តិ ។ អានាបានស្សតិ ភិក្ខវេ ភាវិតា ពហុលីកតា មហប្ផលា ហោតិ មហានិសំសា ។ អានាបានស្សតិ ភិក្ខវេ ភាវិតា ពហុលីកតា ចត្តារោ សតិបដ្ឋានេ បរិបូរេន្តិ[១] ។ ចត្តារោ សតិបដ្ឋានា ភាវិតា ពហុលីកតា សត្ត ពោជ្ឈង្គេ បរិបូរេន្តិ ។ សត្ត ពោជ្ឈង្គា ភាវិតា ពហុលីកតា វិជ្ជាវិមុត្តឹ បរិបូរេន្តិ ។

(២៨៨) កថំ ភាវិតា ច ភិក្ខវេ អានាបានស្សតិ កថំ ពហុលីកតា[២] មហប្ផលា ហោតិ មហានិសំសា ។ ឥធ ភិក្ខវេ ភិក្ខុ អរញ្ញគតោ វា រុក្ខមូលគតោ វា សុញ្ញាគារគតោ វា និសីទតិ បល្លង្កំ អាភុជិត្វា ឧជុំ កាយំ បណិធាយ បរិមុខំ សតឹ ឧបដ្ឋបេត្វា ។

---

១ ឱ. បរិបូរេតិ ។ ២ ឱ. ឯត្ថន្តរេ ពិន្ទុ ទិស្សតិ ។

(២៨៧) ម្នាលភិក្ខុទាំងឡាយ ក្នុងភិក្ខុសង្ឃនេះ មានពួកភិក្ខុជាអ្នកប្រកបរឿយៗ នូវសេចក្តីព្យាយាមជាគ្រឿងចម្រើននូវអានាបានស្សតិ សម្រាន្តនៅដោយឥរិយាបថទាំង ៤ ។ ម្នាលភិក្ខុទាំងឡាយ អានាបានស្សតិ ដែលបុគ្គលបានចម្រើន បានធ្វើឲ្យរឿយ ៗ ហើយ រមែងមានផលច្រើន មានអានិសង្សច្រើន ។ ម្នាលភិក្ខុទាំងឡាយ អានាបានស្សតិដែលបុគ្គលបានចម្រើន បានធ្វើឲ្យរឿយ ៗ ហើយ រមែងញុំាងសតិប្បដ្ឋានទាំង ៤ ឲ្យពេញបរិបូណ៌បាន ។ សតិប្បដ្ឋានទាំង៤ ដែលបុគ្គលបានចម្រើន បានធ្វើឲ្យរឿយ ៗ ហើយ រមែងញុំាងពោជ្ឈង្គទាំង ៧ ឲ្យពេញបរិបូណ៌បាន ។ ពោជ្ឈង្គទាំង ៧ ដែលបុគ្គលបានចម្រើន បានធ្វើឲ្យរឿយ ៗ ហើយ រមែងញុំាងវិជ្ជានិងវិមុត្តិ ឲ្យពេញបរិបូណ៌បាន ។

(២៨៨) ម្នាលភិក្ខុទាំងឡាយ អានាបានស្សតិដែលបុគ្គលបានចម្រើនដូចម្តេច បានធ្វើឲ្យរឿយ ៗ ដូចម្តេច ទើបមានផលច្រើន មានអានិសង្សច្រើន ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ទៅកាន់ព្រៃក្តី ទៅកាន់ម្លប់ឈើក្តី ទៅកាន់ផ្ទះស្ងាត់ក្តី អង្គុយពែនភ្នែន តាំងកាយឲ្យត្រង់ តម្កល់ស្មារតីឲ្យមានមុខឆ្ពោះទៅរក ( កម្មដ្ឋាន ) ។

សោ សតោវ អស្សសតិ សតោ បស្សសតិ ។ ទីឃំ វា អស្សសន្តោ ទីឃំ អស្សសាមីតិ បជានាតិ ទីឃំ វា បស្សសន្តោ ទីឃំ បស្សសាមីតិ បជានាតិ ។ រស្សំ វា អស្សសន្តោ រស្សំ អស្សសាមីតិ បជានាតិ រស្សំ វា បស្សសន្តោ រស្សំ បស្សសាមីតិ បជានាតិ ។ សព្វកាយប្បដិសំវេទី អស្សសិស្សាមីតិ សិក្ខតិ សព្វកាយប្បដិសំវេទី បស្សសិស្សាមីតិ សិក្ខតិ ។ បស្សម្ភយំ កាយសង្ខារំ អស្សសិស្សាមីតិ សិក្ខតិ បស្សម្ភយំ កាយសង្ខារំ បស្សសិស្សាមីតិ សិក្ខតិ ។ បីតិប្បដិសំវេទី អស្សសិស្សាមីតិ សិក្ខតិ បីតិប្បដិសំវេទី បស្សសិស្សាមីតិ សិក្ខតិ ។ សុខប្បដិសំវេទី អស្សសិស្សាមីតិ សិក្ខតិ សុខប្បដិសំវេទី បស្សសិស្សាមីតិ សិក្ខតិ ។ ចិត្តសង្ខារប្បដិសំវេទី អស្សសិស្សាមីតិ សិក្ខតិ ចិត្តសង្ខារប្បដិសំវេទី បស្សសិស្សាមីតិ សិក្ខតិ ។ បស្សម្ភយំ ចិត្តសង្ខារំ អស្សសិស្សាមីតិ សិក្ខតិ

ភិក្ខុនោះ មានស្មារតីដកដង្ហើមចេញ មានស្មារតីដកដង្ហើមចូល ។ កាលដកដង្ហើមចេញវែង ក៏ដឹងច្បាស់ថា អាត្មាអញដកដង្ហើមចេញវែង កាលដកដង្ហើមចូលវែង ក៏ដឹងច្បាស់ថា អាត្មាអញដកដង្ហើមចូលវែង ។ កាលដកដង្ហើមចេញខ្លី ក៏ដឹងច្បាស់ថា អាត្មាអញដកដង្ហើមចេញខ្លី កាលដកដង្ហើមចូលខ្លី ក៏ដឹងច្បាស់ថា អាត្មាអញដកដង្ហើមចូលខ្លី ។ ភិក្ខុសិក្សាថា អាត្មាអញដឹងច្បាស់នូវកាយ គឺដកដង្ហើមចេញទាំងពួង នឹងដកដង្ហើមចេញ សិក្សាថា អាត្មាអញដឹងច្បាស់នូវកាយ គឺ ដកដង្ហើមចូលទាំងពួង នឹងដកដង្ហើមចូល ។ សិក្សាថា អាត្មាអញរម្ងាប់នូវកាយសង្ខារ គឺដង្ហើមចេញចូល នឹងដកដង្ហើមចេញ សិក្សាថា អាត្មាអញរម្ងាប់នូវកាយសង្ខារ នឹងដកដង្ហើមចូល ។ សិក្សាថា អាត្មាអញដឹងច្បាស់នូវបីតិ នឹងដកដង្ហើមចេញ សិក្សាថា អាត្មាអញដឹងច្បាស់នូវបីតិ នឹងដកដង្ហើមចូល ។ សិក្សាថា អាត្មាអញដឹងច្បាស់នូវសុខ នឹងដកដង្ហើមចេញ សិក្សាថា អាត្មាអញដឹងច្បាស់នូវសុខ នឹងដកដង្ហើមចូល ។ សិក្សាថា អាត្មាអញដឹងច្បាស់នូវចិត្តសង្ខារ គឺវេទនា១ និងសញ្ញា១ នឹងដកដង្ហើមចេញ សិក្សាថា អាត្មាអញដឹងច្បាស់នូវចិត្តសង្ខារ នឹងដកដង្ហើមចូល ។ សិក្សាថា អាត្មាអញរម្ងាប់នូវចិត្តសង្ខារ ( ដែលគ្រោតគ្រាត ) នឹងដកដង្ហើមចេញ

៣៦១

អនុបទវគ្គស្ស អានាបានស្សតិសុត្តេ មហានិសំសភាវោ

បស្សម្ភយំ ចិត្តសង្ខារំ បស្សសិស្សាមីតិ សិក្ខតិ ។ ចិត្តប្បដិសំវេទី អស្សសិស្សាមីតិ សិក្ខតិ ចិត្តប្បដិសំវេទី បស្សសិស្សាមីតិ សិក្ខតិ ។ អភិប្បមោទយំ ចិត្តំ អស្សសិស្សាមីតិ សិក្ខតិ អភិប្បមោទយំ ចិត្តំ បស្សសិស្សាមីតិ សិក្ខតិ ។ សមាទហំ ចិត្តំ អស្សសិស្សាមីតិ សិក្ខតិ សមាទហំ ចិត្តំ បស្សសិស្សាមីតិ សិក្ខតិ ។ វិមោចយំ ចិត្តំ អស្សសិស្សាមីតិ សិក្ខតិ វិមោចយំ ចិត្តំ បស្សសិស្សាមីតិ សិក្ខតិ ។ អនិច្ចានុបស្សី អស្សសិស្សាមីតិ សិក្ខតិ អនិច្ចានុបស្សី បស្សសិស្សាមីតិ សិក្ខតិ ។ វិរាគានុបស្សី អស្សសិស្សាមីតិ សិក្ខតិ វិរាគានុបស្សី បស្សសិស្សាមីតិ សិក្ខតិ ។ និរោធានុបស្សី អស្សសិស្សាមីតិ សិក្ខតិ និរោធានុបស្សី បស្សសិស្សាមីតិ សិក្ខតិ ។

សិក្សាថា អាត្មាអញរម្ងាប់នូវចិត្តសង្ខារ (ដែលគ្រោតគ្រាត) នឹងដកដង្ហើមចូល ។ សិក្សាថា អាត្មាអញដឹងច្បាស់នូវចិត្ត នឹងដកដង្ហើមចេញ សិក្សាថា អាត្មាអញដឹងច្បាស់នូវចិត្ត នឹងដកដង្ហើមចូល ។ សិក្សាថា អាត្មាអញធ្វើចិត្តឲ្យរីករាយ នឹងដកដង្ហើមចេញ សិក្សាថា អាត្មាអញធ្វើចិត្តឲ្យរីករាយ នឹងដកដង្ហើមចូល ។ សិក្សាថា អាត្មាអញតាំងចិត្តឲ្យស្មើ (ក្នុងអារម្មណ៍) នឹងដកដង្ហើមចេញ សិក្សាថា អាត្មាអញតាំងចិត្តឲ្យស្មើ (ក្នុងអារម្មណ៍) នឹងដកដង្ហើមចូល សិក្សាថា អាត្មាអញធ្វើចិត្តឲ្យរួចចាកនីវរណធម៌ជាដើម នឹងដកដង្ហើមចេញ សិក្សាថា អាត្មាអញធ្វើចិត្តឲ្យរួចចាកនីវរណធម៌ជាដើម នឹងដកដង្ហើមចូល ។ សិក្សាថា អាត្មាអញឃើញរឿយ ៗ នូវបញ្ចក្ខន្ធថាមិនទៀង នឹងដកដង្ហើមចេញ សិក្សាថា អាត្មាអញឃើញរឿយ ៗ នូវបញ្ចក្ខន្ធថាមិនទៀង នឹងដកដង្ហើមចូល ។ សិក្សាថា អាត្មាអញឃើញរឿយ ៗ នូវធម៌ជាគ្រឿងធ្វើចិត្តឲ្យប្រាសចាកតម្រេក គឺវិបស្សនានិងមគ្គ នឹងដកដង្ហើមចេញ សិក្សាថា អាត្មាអញឃើញរឿយ ៗ នូវធម៌ជាគ្រឿងធ្វើចិត្តឲ្យប្រាសចាកតម្រេក នឹងដកដង្ហើមចូល ។ សិក្សាថា អាត្មាអញឃើញរឿយ ៗ នូវសេចក្តីរលត់នៃកងទុក្ខ នឹងដកដង្ហើមចេញ សិក្សាថា អាត្មាអញឃើញរឿយ ៗ នូវសេចក្តីរលត់នៃកងទុក្ខ នឹងដកដង្ហើមចូល ។

បដិនិស្សគ្គានុបស្សី អស្សសិស្សាមីតិ សិក្ខតិ បដិ-និស្សគ្គានុបស្សី បស្សសិស្សាមីតិ សិក្ខតិ ។ ឯវំ ភាវិតា ខោ ភិក្ខវេ អានាបានស្សតិ ឯវំ ពហុលីកតា មហប្ផលា ហោតិ មហានិសំសា ។

(២៨៩) កថំ ភាវិតា ច ភិក្ខវេ អានាបា-នស្សតិ កថំ ពហុលីកតា ចត្តារោ សតិបដ្ឋានេ បរិបូរេតិ[១] ។ យស្មិំ សមយេ ភិក្ខវេ ភិក្ខុ ទីឃំ វា អស្សសន្តោ ទីឃំ អស្សសាមីតិ បជានាតិ ទីឃំ វា បស្សសន្តោ ទីឃំ បស្សសាមីតិ បជានាតិ រស្សំ វា អស្សសន្តោ រស្សំ អស្សសាមីតិ បជានាតិ រស្សំ វា បស្សសន្តោ រស្សំ បស្សសាមីតិ បជានា-តិ សព្វកាយបដិសំវេទី អស្សសិស្សាមីតិ សិក្ខតិ សព្វកាយបដិសំវេទី បស្សសិស្សាមីតិ សិក្ខតិ បស្សម្ភយំ កាយសង្ខារំ បស្សសិស្សាមីតិ សិក្ខតិ

១ ម. បរិបូរេតិ ។

សិក្សាថា អាត្មាអញឃើញរឿយ ៗ នូវធម៌ជាគ្រឿងរលាស់ចិត្តចេញចាកកិលេស ( ព្រមទាំងខន្ធនិងអភិសង្ខារ បានដល់វិបស្សនានិងមគ្គ ) និងដកដង្ហើមចេញ សិក្សាថា អាត្មាអញឃើញរឿយ ៗ នូវធម៌ជាគ្រឿងរលាស់ចិត្តចេញចាកកិលេស និងដកដង្ហើមចូល ។ ម្នាលភិក្ខុទាំងឡាយ អានាបានស្សតិ ដែលបុគ្គលបានចម្រើនយ៉ាងនេះ បានធ្វើឲ្យរឿយ ៗ យ៉ាងនេះ ទើបមានផលច្រើន មានអានិសង្សច្រើន ។

(៤៨៩) ម្នាលភិក្ខុទាំងឡាយ អានាបានស្សតិដែលបុគ្គលបានចម្រើនដូចម្ដេច បានធ្វើឲ្យរឿយៗ ដូចម្ដេច ទើបញុំាងសតិប្បដ្ឋានទាំង ៤ ឲ្យពេញបរិបូណ៌បាន ។ ម្នាលភិក្ខុទាំងឡាយ ក្នុងសម័យណា ភិក្ខុកាលដកដង្ហើមចេញវែង ក៏ដឹងច្បាស់ថា អាត្មាអញដកដង្ហើមចេញវែង កាលដកដង្ហើមចូលវែង ក៏ដឹងច្បាស់ថា អាត្មាអញដកដង្ហើមចូលវែង កាលដកដង្ហើមចេញខ្លី ក៏ដឹងច្បាស់ថា អាត្មាអញដកដង្ហើមចេញខ្លី កាលដកដង្ហើមចូលខ្លី ក៏ដឹងច្បាស់ថា អាត្មាអញដកដង្ហើមចូលខ្លី សិក្សាថា អាត្មាអញដឹងច្បាស់នូវកាយទាំងពួង និងដកដង្ហើមចេញ សិក្សាថា អាត្មាអញដឹងច្បាស់នូវកាយទាំងពួង និងដកដង្ហើមចូល សិក្សាថា អាត្មាអញរម្ងាប់នូវកាយសង្ខារ និងដកដង្ហើមចេញ សិក្សាថា អាត្មាអញរម្ងាប់នូវកាយស-ង្ខារ និងដកដង្ហើមចូល ម្នាលភិក្ខុទាំងឡាយ ក្នុងសម័យនោះ ភិក្ខុឈ្មោះ

កាយេ កាយានុបស្សី ភិក្ខវេ តស្មឹ សមយេ ភិក្ខុ វិហរតិ អាតាបី សម្បជានោ សតិមា វិនេយ្យ លោកេ អភិជ្ឈាទោមនស្សំ ។ កាយេសុ កាយញ្ញតរាហំ ភិក្ខវេ ឯតំ វទាមិ យទិទំ អស្សាសបស្សាសំ ។ តស្មាតិហ ភិក្ខវេ កាយេ កាយានុបស្សី តស្មឹ សមយេ ភិក្ខុ វិហរតិ អាតាបី សម្បជានោ សតិមា វិនេយ្យ លោកេ អភិជ្ឈាទោមនស្សំ ។ យស្មឹ សមយេ ភិក្ខវេ ភិក្ខុ បីតិប្បដិសំវេទី អស្សសិស្សាមីតិ សិក្ខតិ បីតិប្បដិសំវេទី បស្សសិស្សាមីតិ សិក្ខតិ សុខប្បដិសំវេទី អស្សសិស្សាមីតិ សិក្ខតិ សុខប្បដិសំវេទី បស្សសិស្សាមីតិ សិក្ខតិ ចិត្តសង្ខារប្បដិសំវេទី អស្សសិស្សាមីតិ សិក្ខតិ ចិត្តសង្ខារប្បដិសំវេទី អស្សសិស្សាមីតិ សិក្ខតិ បស្សម្ភយំ ចិត្តសង្ខារំ អស្សសិស្សាមីតិ សិក្ខតិ បស្សម្ភយំ ចិត្តសង្ខារំ បស្សសិស្សាមីតិ សិក្ខតិ

ជាពិចារណាឃើញរឿយ ៗ នូវកាយក្នុងកាយ មានព្យាយាមជាគ្រឿងដុតកំដៅនូវកិលេស ប្រកបដោយប្រាជ្ញាដឹងសព្វ មានស្មារតីជាគ្រឿងកំណត់ បន្ទោបង់នូវអភិជ្ឈានិងទោមនស្សក្នុងលោកចេញ ។ ម្នាលភិក្ខុទាំងឡាយ បណ្ដាកាយទាំងឡាយ តថាគតពោលចំពោះតែកាយណានីមួយ ដែលដកដង្ហើមចេញចូលប៉ុណ្ណោះ ។ ម្នាលភិក្ខុទាំងឡាយ ព្រោះហេតុនោះភិក្ខុក្នុងសាសនានេះ ឈ្មោះថាពិចារណាឃើញរឿយៗ នូវកាយក្នុងកាយ មានព្យាយាមជាគ្រឿងដុតកំដៅនូវកិលេស ប្រកបដោយប្រាជ្ញាដឹងសព្វ មានស្មារតីជាគ្រឿងកំណត់ បន្ទោបង់នូវអភិជ្ឈានិងទោមនស្សក្នុងលោកចេញ ក្នុងសម័យនោះ ។ សម័យណា ភិក្ខុសិក្សាថា អាត្មាអញដឹងច្បាស់នូវបីតី នឹងដកដង្ហើមចេញ សិក្សាថា អាត្មាអញដឹងច្បាស់នូវបីតិ នឹងដកដង្ហើមចូល សិក្សាថា អាត្មាអញដឹងច្បាស់នូវសុខ នឹងដកដង្ហើមចេញ សិក្សាថា អាត្មាអញដឹងច្បាស់នូវសុខ នឹងដកដង្ហើមចូល សិក្សាថា អាត្មាអញដឹងច្បាស់នូវចិត្តសង្ខារ នឹងដកដង្ហើមចេញ សិក្សាថា អាត្មាអញដឹងច្បាស់នូវចិត្តសង្ខារ នឹងដកដង្ហើមចូល សិក្សាថា អាត្មាអញរម្ងាប់នូវចិត្តសង្ខារ (ដែលគ្រោតគ្រាត) នឹងដកដង្ហើមចេញ សិក្សាថា អាត្មាអញរម្ងាប់នូវចិត្តសង្ខារ នឹងដកដង្ហើមចូល

វេទនាសុ វេទនានុបស្សី ភិក្ខវេ តស្មឹ សមយេ ភិក្ខុ វិហរតិ អាតាបី សម្បជានោ សតិមា វិនេយ្យ លោកេ អភិជ្ឈាទោមនស្សំ ។ វេទនាសុ វេទនញ្ញតរាហំ ភិក្ខវេ ឯតំ វទាមិ យទិទំ អស្សាសបស្សាសានំ សាធុកំ មនសិការំ ។ តស្មាតិហ ភិក្ខវេ វេទនាសុ វេទនានុបស្សី តស្មឹ សមយេ ភិក្ខុ វិហរតិ អាតាបី សម្បជានោ សតិមា វិនេយ្យ លោកេ អភិជ្ឈាទោមនស្សំ ។ យស្មឹ សមយេ ភិក្ខវេ ភិក្ខុ ចិត្តប្បដិសំវេទី អស្សសិស្សាមីតិ សិក្ខតិ ចិត្តប្បដិសំវេទី បស្សសិស្សាមីតិ សិក្ខតិ អភិប្បមោទយំ ចិត្តំ អស្សសិស្សាមីតិ សិក្ខតិ អភិប្បមោទយំ ចិត្តំ បស្សសិស្សាមីតិ សិក្ខតិ សមាទហំ ចិត្តំ អស្សសិស្សាមីតិ សិក្ខតិ សមាទហំ ចិត្តំ បស្សសិស្សាមីតិ សិក្ខតិ

ម្នាលភិក្ខុទាំងឡាយ ក្នុងសម័យនោះ ភិក្ខុឈ្មោះថាពិចារណាឃើញរឿយ ៗ នូវវេទនាក្នុងវេទនាទាំងឡាយ មានព្យាយាមជាគ្រឿងដុតកំដៅកិលេស ប្រកបដោយប្រាជ្ញាដឹងសព្វ មានស្មារតីជាគ្រឿងកំណត់ បន្ទោបង់នូវអភិជ្ឈានិងទោមនស្សក្នុងលោក ។ ម្នាលភិក្ខុទាំងឡាយ បណ្ដាវេទនាទាំងឡាយ តថាគតពោលបំពោះតែវេទនាណាមួយ គឺវេទនាដែលដកដង្ហើមចេញចូល ធ្វើទុកក្នុងចិត្តឲ្យសម្រេចប្រយោជន៍ប៉ុណ្ណោះ ។ ម្នាលភិក្ខុទាំងឡាយ ព្រោះហេតុនោះ ភិក្ខុក្នុងសាសនានេះ ឈ្មោះថាពិចារណាឃើញរឿយ ៗ នូវវេទនាក្នុងវេទនាទាំងឡាយ មានព្យាយាមជាគ្រឿងដុតកំដៅកិលេស ប្រកបដោយប្រាជ្ញាដឹងសព្វ មានស្មារតីជាគ្រឿងកំណត់ បន្ទោបង់នូវអភិជ្ឈានិងទោមនស្សក្នុងលោក ក្នុងសម័យនោះ ។ ម្នាលភិក្ខុទាំងឡាយ ក្នុងសម័យណា ភិក្ខុសិក្សាថា អាត្មាអញដឹងច្បាស់នូវចិត្ត នឹងដកដង្ហើមចេញ សិក្សាថា អាត្មាអញដឹងច្បាស់នូវចិត្ត នឹងដកដង្ហើមចូល សិក្សាថា អាត្មាអញធ្វើចិត្តឲ្យរីករាយ ដកដង្ហើមចេញ សិក្សាថា អាត្មាអញធ្វើចិត្តឲ្យរីករាយ នឹងដកដង្ហើមចូល សិក្សាថា អាត្មាអញតាំងចិត្តឲ្យស្មើក្នុងអារម្មណ៍ នឹងដកដង្ហើមចេញ សិក្សាថា អាត្មាអញតាំងចិត្តឲ្យស្មើក្នុងអារម្មណ៍ នឹងដកដង្ហើមចូល

វិមោចយំ ចិត្តំ អស្សសិស្សាមីតិ សិក្ខតិ វិមោចយំ ចិត្តំ បស្សសិស្សាមីតិ សិក្ខតិ ចិត្តេ ចិត្តានុបស្សី ភិក្ខវេ តស្មឹ សមយេ ភិក្ខុ វិហរតិ អាតាបី សម្បជានោ សតិមា វិនេយ្យ លោកេ អភិជ្ឈាទោមនស្សំ ។ នាហំ ភិក្ខវេ មុដ្ឋស្សតិស្ស អសម្បជានស្ស អានាបានស្សតិ(១) វទាមិ ។ តស្មាតិហ ភិក្ខវេ ចិត្តេ ចិត្តានុបស្សី តស្មឹ សមយេ ភិក្ខុ វិហរតិ អាតាបី សម្បជានោ សតិមា វិនេយ្យ លោកេ អភិជ្ឈាទោមនស្សំ ។ យស្មឹ សមយេ ភិក្ខវេ ភិក្ខុ អនិច្ចានុបស្សី អស្សសិស្សាមីតិ សិក្ខតិ អនិច្ចានុបស្សី បស្សសិស្សាមីតិ សិក្ខតិ វិរាគានុបស្សី អស្សសិស្សាមីតិ សិក្ខតិ

១ ឱ. អានាបានស្សតិការិនំ ។

សិក្សាថា អាត្មាអញ នឹងធ្វើចិត្តឲ្យរួចចាកនីវរណធម៌ជាដើម នឹងដកដង្ហើមចេញ សិក្សាថា អាត្មាអញនឹងធ្វើចិត្តឲ្យរួចចាកនីវរណធម៌ជាដើម នឹងដកដង្ហើមចូល ម្នាលភិក្ខុទាំងឡាយ ក្នុងសម័យនោះ ភិក្ខុឈ្មោះថាពិចារណា ឃើញរឿយៗ នូវចិត្តក្នុងចិត្ត មានព្យាយាមជាគ្រឿងដុតកំដៅកិលេស ប្រកបដោយប្រាជ្ញាដឹងសព្វ មានស្មារតីជាគ្រឿងកំណត់ បន្ទោបង់នូវអភិជ្ឈានិងទោមនស្សក្នុងលោក ។ ម្នាលភិក្ខុទាំងឡាយ តថាគតមិនបានពោល នូវអានាបានស្សតិរបស់ភិក្ខុដែលភ្លេចស្មារតី មិនប្រកបដោយប្រាជ្ញាដឹងសព្វទេ ។ ម្នាលភិក្ខុទាំងឡាយ ព្រោះហេតុនោះ ភិក្ខុក្នុងសាសនានេះ ឈ្មោះថាពិចារណាឃើញរឿយៗ នូវចិត្តក្នុងចិត្ត មានព្យាយាមជាគ្រឿងដុតកំដៅកិលេស ប្រកបដោយប្រាជ្ញាដឹងសព្វ មានស្មារតីជាគ្រឿងកំណត់ បន្ទោបង់នូវអភិជ្ឈានិងទោមនស្ស ក្នុងលោក ក្នុងសម័យនោះ ។ ម្នាលភិក្ខុទាំងឡាយ ក្នុងសម័យណា ភិក្ខុសិក្សាថា អាត្មាអញឃើញរឿយៗ នូវបញ្ចក្ខន្ធថាមិនទៀង នឹងដកដង្ហើមចេញ សិក្សាថា អាត្មាអញឃើញរឿយៗ នូវបញ្ចក្ខន្ធថាមិនទៀង នឹងដកដង្ហើមចូល សិក្សាថា អាត្មាអញឃើញរឿយៗ នូវធម៌ជាគ្រឿងធ្វើចិត្តឲ្យប្រាសចាកតម្រេក គឺវិបស្សនានិងមគ្គ នឹងដកដង្ហើមចេញ

វិរាគានុបស្សី បស្សសិស្សាមីតិ សិក្ខតិ និរោធានុបស្សី អស្សសិស្សាមីតិ សិក្ខតិ និរោធានុបស្សី បស្សសិ-ស្សាមីតិ សិក្ខតិ បដិនិស្សគ្គានុបស្សី អស្សសិស្សាមីតិ សិក្ខតិ បដិនិស្សគ្គានុបស្សី បស្សសិស្សាមីតិ សិក្ខតិ ធម្មេសុ ធម្មានុបស្សី ភិក្ខវេ តស្មឹ សមយេ ភិក្ខុ វិហរតិ អាតាបី សម្បជានោ សតិមា វិនេយ្យ លោកេ អភិជ្ឈាទោមនស្សំ ។ សោ យន្តំ អភិជ្ឈាទោមនស្សានំ បហានំ បញ្ញាយ ទិស្វា សាធុកំ អជ្ឈុបេក្ខិតា ហោតិ ។ តស្មាតិហ ភិក្ខវេ ធម្មេសុ ធម្មានុបស្សី តស្មឹ សមយេ ភិក្ខុ វិហរតិ អាតាបី សម្បជានោ

សិក្សាថា អាត្មាអញឃើញរឿយ ៗ នូវធម៌ជាគ្រឿងធ្វើចិត្តឲ្យប្រាសចាកតម្រេក នឹងដកដង្ហើមចូល សិក្សាថា អាត្មាអញឃើញរឿយ ៗ នូវសេចក្តីរលត់នៃកងទុក្ខ នឹងដកដង្ហើមចេញ សិក្សាថា អាត្មាអញឃើញរឿយ ៗ នូវសេចក្តីរលត់នៃកងទុក្ខ នឹងដកដង្ហើមចូល សិក្សាថា អាត្មាអញឃើញរឿយ ៗ នូវធម៌ជាគ្រឿងរលាស់ចិត្តចេញចាកកិលេស ព្រមទាំងខន្ធនិងអភិសង្ខារ បានដល់វិបស្សនានិងមគ្គ នឹងដកដង្ហើមចេញ សិក្សាថា អាត្មាអញឃើញរឿយ ៗ នូវធម៌ជាគ្រឿងរលាស់ចិត្តចេញចាកកិលេស នឹងដកដង្ហើមចូល ម្នាលភិក្ខុទាំងឡាយ ក្នុងសម័យនោះ ភិក្ខុឈ្មោះថា ពិចារណាឃើញរឿយ ៗ នូវធម៌ក្នុងធម៌ទាំងឡាយ មានព្យាយាមជាគ្រឿងដុតកំដៅកិលេស ប្រកបដោយប្រាជ្ញាដឹងសព្វ មានស្មារតីជាគ្រឿងកំណត់ បន្ទោបង់នូវអភិជ្ឈានិងទោមនស្សក្នុងលោកចេញបាន ។ ការលះបង់នូវអភិជ្ឈានិងទោមនស្សណា ភិក្ខុនោះ បានឃើញដោយប្រាជ្ញាហើយព្រងើយកន្តើយ ដោយការលះបង់នោះ ។ ម្នាលភិក្ខុទាំងឡាយ ព្រោះហេតុនោះ ភិក្ខុក្នុងសាសនានេះ ឈ្មោះថា ពិចារណាឃើញរឿយ ៗ នូវធម៌ទាំងឡាយ មានព្យាយាមជាគ្រឿងដុតកំដៅកិលេស ប្រកបដោយប្រាជ្ញាដឹងសព្វ

សតិមា វិនេយ្យ លោកេ អភិជ្ឈាទោមនស្សំ ។ ឯវំ ភាវិតា ខោ ភិក្ខវេ អានាបានស្សតិ ឯវំ ពហុលីកតា ចត្តារោ សតិបដ្ឋានេ បរិបូរេន្តិ ។

(២៩០) កថំ ភាវិតា ច ភិក្ខវេ ចត្តារោ សតិបដ្ឋានា កថំ ពហុលីកតា សត្ត ពោជ្ឈង្គេ បរិបូរេន្តិ ។ យស្មឹ សមយេ ភិក្ខវេ ភិក្ខុ កាយេ កាយានុបស្សី វិហរតិ អាតាបី សម្បជានោ សតិមា វិនេយ្យ លោកេ អភិជ្ឈាទោមនស្សំ ឧបដ្ឋិតស្ស តស្មឹ សមយេ សតិ ហោតិ អសម្មុដ្ឋា[១] ។ យស្មឹ សមយេ ភិក្ខវេ ភិក្ខុនោ ឧបដ្ឋិតា សតិ ហោតិ អសម្មុដ្ឋា[២] សតិសម្ពោជ្ឈង្គោ តស្មឹ សមយេ ភិក្ខុនោ អារទ្ធោ ហោតិ សតិសម្ពោជ្ឈង្គំ តស្មឹ សមយេ ភិក្ខុ ភាវេតិ សតិសម្ពោជ្ឈង្គោ តស្មឹ សមយេ ភិក្ខុនោ ភាវនាបារិបូរឹ គច្ឆតិ ។ សោ តថា សតោ វិហរន្តោ តំ ធម្មំ បញ្ញាយ បវិចិនតិ បវិចរតិ[៣] បរិវីមំសំ អាបជ្ជតិ ។ យស្មឹ សមយេ ភិក្ខវេ

---

១-២ ម. យ. អសម្មុដ្ឋា ។ ៣ ម. បវិចយតិ ។

មានស្មារតីជាគ្រឿងកំណត់ បន្ទោបង់នូវអភិជ្ឈានិងទោមនស្សក្នុងលោក បាន ក្នុងសម័យនោះ ។ ម្នាលភិក្ខុទាំងឡាយ អានាបានស្សតិដែលបុគ្គលបានចំរើនយ៉ាងនេះ បានធ្វើឲ្យច្រើនៗ យ៉ាងនេះហើយ រមែងញុំាងសតិប្បដ្ឋានទាំង៤ ឲ្យពេញបរិបូណ៌បាន ។

(២៩១) ម្នាលភិក្ខុទាំងឡាយ សតិប្បដ្ឋានទាំង ៤ ដែលបុគ្គលបានចំរើនដូចម្តេច បានធ្វើឲ្យច្រើន ៗ ដូចម្តេច ទើបញុំាងពោជ្ឈង្គទាំង ៧ ឲ្យពេញបរិបូណ៌បាន ។ ម្នាលភិក្ខុទាំងឡាយ ក្នុងសម័យណា ភិក្ខុពិចារណាឃើញច្រើន ៗ នូវកាយក្នុងកាយ មានព្យាយាមជាគ្រឿងដុតកំដៅកិលេស ប្រកបដោយប្រាជ្ញាដឹងសព្វ មានស្មារតីជាគ្រឿងកំណត់ បន្ទោបង់នូវអភិជ្ឈានិងទោមនស្សក្នុងលោកចេញ ក្នុងសម័យនោះ ស្មារតីដែលភិក្ខុនោះតំកល់ខ្ជាប់ហើយ ក៏មិនបានវង្វេង ។ ម្នាលភិក្ខុទាំងឡាយ ក្នុងសម័យណា ស្មារតីដែលភិក្ខុតំកល់ខ្ជាប់ហើយមិនបានវង្វេង ក្នុងសម័យនោះ សតិសម្ពោជ្ឈង្គក៏ឈ្មោះថាភិក្ខុប្រារព្ធហើយ សម័យនោះ ភិក្ខុឈ្មោះថាបានចំរើនសតិសម្ពោជ្ឈង្គ ក្នុងសម័យនោះ សតិសម្ពោជ្ឈង្គក៏ដល់នូវកិរិយាពេញបរិបូណ៌ ដោយការចំរើនរបស់ភិក្ខុ ។ ភិក្ខុនោះជាអ្នកមានស្មារតីដូច្នោះ ក៏ជ្រើសរើស ត្រិះរិះ ដល់នូវកិរិយាល្បងនូវធម៌នោះ ដោយប្រាជ្ញា ។ ម្នាលភិក្ខុទាំងឡាយ ក្នុងសម័យណា

ភិក្ខុ តថាភូតោ វិហរន្តោ តំ ធម្មំ បញ្ញាយ បវិចិនតិ បវិចរតិ បរិវីមំសំ អាបជ្ជតិ ធម្មវិចយសម្ពោជ្ឈង្គោ តស្មិំ សមយេ ភិក្ខុនោ អារទ្ធោ ហោតិ ធម្មវិចយសម្ពោជ្ឈង្គំ តស្មិំ សមយេ ភិក្ខុ ភាវេតិ ធម្មវិចយសម្ពោជ្ឈង្គោ តស្មិំ សមយេ ភិក្ខុនោ ភាវនាបារិបូរឹ គច្ឆតិ ។ តស្ស ធម្មំ[(១)] បញ្ញាយ បវិចិនតោ បវិចរតោ[(២)] បរិវីមំសំ អាបជ្ជតោ អារទ្ធំ ហោតិ វីរិយំ អសល្លីនំ ។ យស្មិំ សមយេ ភិក្ខវេ ភិក្ខុនោ តំ ធម្មំ បញ្ញាយ បវិចិនតោ បវិចរតោ បរិវីមំសំ អាបជ្ជតោ អារទ្ធំ ហោតិ វីរិយំ អសល្លីនំ វីរិយសម្ពោជ្ឈង្គោ តស្មិំ សមយេ ភិក្ខុនោ អារទ្ធោ ហោតិ វីរិយសម្ពោជ្ឈង្គំ តស្មិំ សមយេ ភិក្ខុ ភាវេតិ វីរិយសម្ពោជ្ឈង្គោ តស្មិំ សមយេ ភិក្ខុនោ ភាវនាបារិបូរឹ គច្ឆតិ ។ អារទ្ធវីរិយស្ស ឧប្បជ្ជតិ បីតិ និរាមិសា ។ យស្មិំ សមយេ ភិក្ខវេ ភិក្ខុនោ អារទ្ធវីរិយស្ស ឧប្បជ្ជតិ បីតិ និរាមិសា

---

១ ឱ. ម. តំ ធម្មំ ។ ២ ម. បវិចយតោ ។

ភិក្ខុមានស្មារតីដូច្នោះ ជ្រើសរើស ត្រិះរិះ ដល់នូវកិរិយាល្បងនូវធម៌នោះ ដោយប្រាជ្ញាហើយ ក្នុងសម័យនោះ ធម្មវិចយសម្ពោជ្ឈង្គ ក៏ឈ្មោះថាភិក្ខុប្រារព្ធហើយ ក្នុងសម័យនោះ ភិក្ខុឈ្មោះថាបានចំរើនធម្មវិចយសម្ពោជ្ឈង្គ ក្នុងសម័យនោះធម្មវិចយសម្ពោជ្ឈង្គ ក៏ដល់នូវកិរិយាពេញបរិបូណ៌ ដោយការចំរើនរបស់ភិក្ខុ ។ ភិក្ខុនោះ កំពុងជ្រើសរើស កំពុងត្រិះរិះ ដល់នូវកិរិយាល្បងនូវធម៌នោះដោយប្រាជ្ញាហើយ ក៏ប្រារព្ធនូវសេចក្តីព្យាយាមមិនឲ្យធូរថយឡើយ ។ ម្នាលភិក្ខុទាំងឡាយ ក្នុងសម័យណា ភិក្ខុជ្រើសរើស ត្រិះរិះ ដល់នូវកិរិយាល្បងនូវធម៌នោះដោយប្រាជ្ញា បានប្រារព្ធសេចក្តីព្យាយាមមិនឲ្យធូរថយហើយ ក្នុងសម័យនោះ វីរិយសម្ពោជ្ឈង្គក៏ឈ្មោះថាភិក្ខុប្រារព្ធហើយ ក្នុងសម័យនោះ ភិក្ខុឈ្មោះថាបានចម្រើនវីរិយសម្ពោជ្ឈង្គ ក្នុងសម័យនោះ វីរិយសម្ពោជ្ឈង្គ ក៏ដល់នូវកិរិយាពេញបរិបូណ៌ដោយការចម្រើនរបស់ភិក្ខុ ។ បីតិដែលប្រាសចាកអាមិសៈ ក៏កើតឡើងដល់ភិក្ខុដែលប្រារព្ធព្យាយាម ។ ម្នាលភិក្ខុទាំងឡាយ ក្នុងសម័យណា បីតិដែលប្រាសចាកអាមិសៈ កើតឡើងដល់ភិក្ខុអ្នកប្រារព្ធព្យាយាមហើយ

បីតិសម្ពោជ្ឈង្គោ តស្មឹ សមយេ ភិក្ខុនោ អារទ្ធោ ហោតិ បីតិសម្ពោជ្ឈង្គំ តស្មឹ សមយេ ភិក្ខុ ភាវេតិ បីតិសម្ពោជ្ឈង្គោ តស្មឹ សមយេ ភិក្ខុនោ ភាវនាបារិបូរឹ គច្ឆតិ ។ បីតិមនស្ស កាយោបិ បស្សម្ភតិ ចិត្តម្បិ បស្សម្ភតិ ។ យស្មឹ សមយេ ភិក្ខុនោ បីតិមនស្ស កាយោបិ បស្សម្ភតិ ចិត្តម្បិ បស្សម្ភតិ បស្សទ្ធិសម្ពោជ្ឈង្គោ តស្មឹ សមយេ ភិក្ខុនោ អារទ្ធោ ហោតិ បស្សទ្ធិសម្ពោជ្ឈង្គំ តស្មឹ សមយេ ភិក្ខុ ភាវេតិ បស្សទ្ធិសម្ពោជ្ឈង្គោ តស្មឹ សមយេ ភិក្ខុនោ ភាវនាបារិបូរឹ គច្ឆតិ ។ បស្សទ្ធកាយស្ស សុខិនោ ចិត្តំ សមាធិយតិ ។ យស្មឹ សមយេ ភិក្ខុនោ បស្សទ្ធកាយស្ស សុខិនោ ចិត្តំ សមាធិយតិ សមាធិសម្ពោជ្ឈង្គោ តស្មឹ សមយេ ភិក្ខុនោ អារទ្ធោ ហោតិ សមាធិសម្ពោជ្ឈង្គំ តស្មឹ សមយេ ភិក្ខុ ភាវេតិ សមាធិសម្ពោជ្ឈង្គោ តស្មឹ សមយេ ភិក្ខុនោ ភាវនាបារិបូរឹ គច្ឆតិ ។ សោ តថាសមាហិតំ ចិត្តំ សាធុកំ អជ្ឈុបេក្ខិតា ហោតិ ។

ក្នុងសម័យនោះ បីតិសម្ពោជ្ឈង្គក៏ឈ្មោះថាភិក្ខុប្រារព្ធហើយ ក្នុងសម័យនោះភិក្ខុឈ្មោះថាបានចំរើនបីតិសម្ពោជ្ឈង្គ ក្នុងសម័យនោះ បីតិសម្ពោជ្ឈង្គក៏ដល់នូវកិរិយាពេញបរិបូណ៌ ដោយការចំរើនរបស់ភិក្ខុ ។ កាយរបស់ភិក្ខុដែលមានចិត្តប្រកបដោយបីតិ ក៏ស្ងប់ស្ងាត់ ទាំងចិត្តក៏ស្ងប់ស្ងាត់ផង ម្នាលភិក្ខុទាំងឡាយ ក្នុងសម័យណា បើកាយរបស់ភិក្ខុមានចិត្តប្រកបដោយបីតិស្ងប់ស្ងាត់ ទាំងចិត្តសោតក៏ស្ងប់ស្ងាត់ហើយ ក្នុងសម័យនោះ បស្សទ្ធិសម្ពោជ្ឈង្គក៏ឈ្មោះថាភិក្ខុប្រារព្ធហើយ ក្នុងសម័យនោះ ភិក្ខុឈ្មោះថាបានចំរើនបស្សទ្ធិសម្ពោជ្ឈង្គ ក្នុងសម័យនោះ បស្សទ្ធិសម្ពោជ្ឈង្គក៏ដល់នូវកិរិយាពេញបរិបូណ៌ ដោយការចំរើនរបស់ភិក្ខុ ។ ចិត្តរបស់ភិក្ខុដែលមានកាយស្ងប់ស្ងាត់ ទាំងមានសេចក្ដីសុខ ក៏តាំងនៅខ្ជាប់ ។ ម្នាលភិក្ខុទាំងឡាយ ក្នុងសម័យណា ចិត្តរបស់ភិក្ខុដែលមានកាយស្ងប់ស្ងាត់ ទាំងមានសេចក្ដីសុខតាំងនៅខ្ជាប់ហើយ ក្នុងសម័យនោះ សមាធិសម្ពោជ្ឈង្គ ក៏ឈ្មោះថាភិក្ខុប្រារព្ធហើយ ក្នុងសម័យនោះ ភិក្ខុឈ្មោះថា បានចំរើនសមាធិសម្ពោជ្ឈង្គ ក្នុងសម័យនោះ សមាធិសម្ពោជ្ឈង្គក៏ដល់នូវកិរិយាពេញបរិបូណ៌ ដោយការចំរើនរបស់ភិក្ខុ ។ ភិក្ខុនោះញុំាងចិត្តដែលតាំងនៅខ្ជាប់ដូច្នោះ ឲ្យព្រងើយកន្តើយដោយស្រួល ។

យស្មឹ សមយេ ភិក្ខវេ ភិក្ខុ តថាសមាហិតំ ចិត្តំ សាធុកំ អជ្ឈុបេក្ខិតា ហោតិ ឧបេក្ខាសម្ពោជ្ឈង្គោ តស្មឹ សមយេ ភិក្ខុនោ អារទ្ធោ ហោតិ ឧបេក្ខា-សម្ពោជ្ឈង្គំ តស្មឹ សមយេ ភិក្ខុ ភាវេតិ ឧបេក្ខា-សម្ពោជ្ឈង្គោ តស្មឹ សមយេ ភិក្ខុនោ ភាវនាបារិបូរឹ គច្ឆតិ ។ យស្មឹ សមយេ ភិក្ខវេ ភិក្ខុ វេទនាសុ ... ចិត្តេ ... ធម្មេសុ ធម្មានុបស្សី វិហរតិ អាតាបី សម្ប-ជានោ សតិមា វិនេយ្យ លោកេ អភិជ្ឈាទោមនស្សំ ឧបដ្ឋិតស្ស តស្មឹ សមយេ សតិ ហោតិ អសម្មុដ្ឋា ។ យស្មឹ សមយេ ភិក្ខវេ ភិក្ខុនោ ឧបដ្ឋិតា សតិ ហោតិ អសម្មុដ្ឋា សតិសម្ពោជ្ឈង្គោ តស្មឹ សមយេ ភិក្ខុនោ អារទ្ធោ ហោតិ សតិសម្ពោជ្ឈង្គំ តស្មឹ សមយេ ភិក្ខុ ភាវេតិ សតិសម្ពោជ្ឈង្គោ តស្មឹ សមយេ ភិក្ខុនោ ភាវនាបារិបូរឹ គច្ឆតិ ។ សោ តថាសតោ វិហរន្តោ តំ ធម្មំ បញ្ញាយ បវិចិនតិ បវិចរតិ បរិវីមំសំ អាបជ្ជតិ ។

ម្នាលភិក្ខុទាំងឡាយ សម័យណា ភិក្ខុញុំាងចិត្តដែលតាំងនៅខ្ជាប់ដូច្នោះ ឲ្យព្រងើយកន្តើយ ដោយស្រួលហើយ ក្នុងសម័យនោះ ឧបេក្ខាសម្ពោ-ជ្ឈង្គ ក៏ឈ្មោះថាភិក្ខុប្រារព្ធហើយ ក្នុងសម័យនោះ ភិក្ខុឈ្មោះថាបាន ចំរើនឧបេក្ខាសម្ពោជ្ឈង្គ ក្នុងសម័យនោះ ឧបេក្ខាសម្ពោជ្ឈង្គក៏ដល់នូវកិរិយាពេញបរិបូណ៌ ដោយការចំរើនរបស់ភិក្ខុ ។ ម្នាលភិក្ខុទាំងឡាយ ក្នុងសម័យណា ភិក្ខុ (ពិចារណាឃើញរឿយៗ នូវវេទនា) ក្នុងវេទនាទាំងឡាយ... នូវចិត្តក្នុងចិត្ត ... ពិចារណាឃើញរឿយៗ នូវធម៌ ក្នុងធម៌ទាំងឡាយ មានព្យាយាមជាគ្រឿងដុតកំដៅកិលេស ប្រកបដោយប្រាជ្ញាដឹងសព្វ មានស្មារតីជាគ្រឿងកំណត់ បន្ទោបង់នូវអភិជ្ឈា និងទោមនស្សក្នុងលោក ក្នុងសម័យនោះ ស្មារតី ក៏ឈ្មោះថាភិក្ខុបានតំកល់ខ្ជាប់ មិនវង្វេងភ្លេច ។ ម្នាលភិក្ខុទាំងឡាយ ក្នុងសម័យណា ស្មារតីដែលភិក្ខុតំកល់ខ្ជាប់ មិនវង្វេងភ្លេចហើយ ក្នុងសម័យនោះ សតិ-សម្ពោជ្ឈង្គក៏ឈ្មោះថាភិក្ខុប្រារព្ធហើយ សម័យនោះ ភិក្ខុឈ្មោះថា បានចំរើនសតិសម្ពោជ្ឈង្គ ក្នុងសម័យនោះ សតិសម្ពោជ្ឈង្គ ក៏ដល់នូវកិរិយាពេញបរិបូណ៌ ដោយការចំរើនរបស់ភិក្ខុ ។ ភិក្ខុនោះមានស្មារតីដូច្នោះ តែងជ្រើសរើស ត្រិះរិះ ដល់នូវកិរិយាល្បងនូវធម៌នោះដោយប្រាជ្ញា ។

យស្មឹ សមយេ ភិក្ខវេ ភិក្ខុ តថាសតោ វិហរន្តោ តំ ធម្មំ បញ្ញាយ បវិចិនតិ បវិចរតិ បរិវីមំសំ អាបជ្ជតិ ធម្មវិចយសម្ពោជ្ឈង្គោ តស្មឹ សមយេ ភិក្ខុនោ អារទ្ធោ ហោតិ ធម្មវិចយសម្ពោជ្ឈង្គំ តស្មឹ សមយេ ភិក្ខុ ភាវេតិ ធម្មវិចយសម្ពោជ្ឈង្គោ តស្មឹ សមយេ ភិក្ខុនោ ភាវនាបារិបូរឹ គច្ឆតិ ។ តស្ស តំ ធម្មំ បញ្ញាយ បវិចិនតោ បវិចរតោ បរិវីមំសំ អាបជ្ជតោ អារទ្ធំ ហោតិ វីរិយំ អសល្លីនំ ។ យស្មឹ សមយេ ភិក្ខវេ ភិក្ខុនោ តំ ធម្មំ បញ្ញាយ បវិចិនតោ បវិចរតោ បរិវីមំសំ អាបជ្ជតោ អារទ្ធំ ហោតិ វីរិយំ អសល្លីនំ វីរិយសម្ពោជ្ឈង្គោ តស្មឹ សមយេ ភិក្ខុនោ អារទ្ធោ ហោតិ វីរិយសម្ពោជ្ឈង្គំ តស្មឹ សមយេ ភិក្ខុ ភាវេតិ វីរិយសម្ពោជ្ឈង្គោ តស្មឹ សមយេ ភិក្ខុនោ ភាវនាបារិបូរឹ គច្ឆតិ ។ អារទ្ធវីរិយស្ស ឧប្បជ្ជតិ បីតិ និរាមិសា ។ យស្មឹ សមយេ ភិក្ខវេ ភិក្ខុនោ អារទ្ធវីរិយស្ស ឧប្បជ្ជតិ បីតិ និរាមិសា

ម្នាលភិក្ខុទាំងឡាយ ក្នុងសម័យណា ភិក្ខុមានស្មារតីប្រព្រឹត្ត តែងជ្រើសរើស ត្រិះរិះ ដល់នូវកិរិយាល្បងនូវធម៌នោះដោយប្រាជ្ញាហើយ ធម្មវិចយសម្ពោជ្ឈង្គ ក៏ឈ្មោះថាភិក្ខុប្រារព្ធហើយ ក្នុងសម័យនោះ ភិក្ខុឈ្មោះថាបានចំរើនធម្មវិចយសម្ពោជ្ឈង្គ ក្នុងសម័យនោះ ធម្មវិចយសម្ពោជ្ឈង្គ ក៏ដល់នូវកិរិយាពេញបរិបូណ៌ ដោយការចំរើនរបស់ភិក្ខុ ។ កាលភិក្ខុនោះ កំពុងជ្រើសរើស កំពុងត្រិះរិះ ដល់នូវកិរិយាល្បងមើលនូវធម៌នោះ ដោយប្រាជ្ញាហើយ ក៏ឈ្មោះថាបានប្រារព្ធសេចក្តីព្យាយាម មិនឲ្យធូរថយឡើយ ។ ម្នាលភិក្ខុទាំងឡាយ ក្នុងសម័យណា ភិក្ខុកំពុងជ្រើសរើស កំពុងត្រិះរិះ ដល់នូវកិរិយាល្បងនូវធម៌នោះដោយប្រាជ្ញា បានប្រារព្ធព្យាយាមមិនឲ្យធូរថយហើយ ក្នុងសម័យនោះ វិរិយសម្ពោជ្ឈង្គក៏ឈ្មោះថាភិក្ខុប្រារព្ធហើយ ក្នុងសម័យនោះ ភិក្ខុឈ្មោះថាបានចំរើនវិរិយសម្ពោជ្ឈង្គ ក្នុងសម័យនោះ វិរិយសម្ពោជ្ឈង្គក៏ដល់នូវកិរិយាពេញបរិបូណ៌ ដោយការចំរើនរបស់ភិក្ខុ ។ បីតិដែលប្រាសចាកអាមិសៈ ក៏កើតឡើងដល់ភិក្ខុដែលប្រារព្ធព្យាយាម ។ ម្នាលភិក្ខុទាំងឡាយ ក្នុងសម័យណា បីតិដែលប្រាសចាកអាមិសៈ កើតឡើងដល់ភិក្ខុដែលប្រារព្ធព្យាយាមហើយ

បីតិសម្ពោជ្ឈង្គោ តស្មឹ សមយេ ភិក្ខុនោ អារទ្ធោ ហោតិ បីតិសម្ពោជ្ឈង្គំ តស្មឹ សមយេ ភិក្ខុ ភាវេតិ បីតិសម្ពោជ្ឈង្គោ តស្មឹ សមយេ ភិក្ខុនោ ភាវនាបារិបូរឹ គច្ឆតិ ។ បីតិមនស្ស កាយោបិ បស្សម្ភតិ ចិត្តម្បិ បស្សម្ភតិ ។ យស្មឹ សមយេ ភិក្ខវេ ភិក្ខុនោ បីតិមនស្ស កាយោបិ បស្សម្ភតិ ចិត្តម្បិ បស្សម្ភតិ បស្សទ្ធិសម្ពោជ្ឈង្គោ តស្មឹ សមយេ ភិក្ខុនោ អារទ្ធោ ហោតិ បស្សទ្ធិសម្ពោជ្ឈង្គំ តស្មឹ សមយេ ភិក្ខុ ភាវេតិ បស្សទ្ធិសម្ពោជ្ឈង្គោ តស្មឹ សមយេ ភិក្ខុនោ ភាវនាបារិបូរឹ គច្ឆតិ ។ បស្សទ្ធកាយស្ស សុខិនោ ចិត្តំ សមាធិយតិ ។ យស្មឹ សមយេ ភិក្ខវេ ភិក្ខុនោ បស្សទ្ធកាយស្ស សុខិនោ ចិត្តំ សមាធិយតិ សមាធិសម្ពោជ្ឈង្គោ តស្មឹ សមយេ ភិក្ខុនោ អារទ្ធោ ហោតិ សមាធិសម្ពោជ្ឈង្គំ តស្មឹ សមយេ ភិក្ខុ ភាវេតិ សមាធិសម្ពោជ្ឈង្គោ តស្មឹ សមយេ ភិក្ខុនោ ភាវនាបារិបូរឹ គច្ឆតិ ។ សោ តថាសមាហិតំ ចិត្តំ សាធុកំ អជ្ឈុបេក្ខិតា ហោតិ ។

ក្នុងសម័យនោះ បីតិសម្ពោជ្ឈង្គក៏ឈ្មោះថាភិក្ខុប្រារព្ធហើយ ក្នុងសម័យនោះភិក្ខុឈ្មោះថាបានចំរើនបីតិសម្ពោជ្ឈង្គ ក្នុងសម័យនោះបីតិសម្ពោជ្ឈង្គដល់នូវកិរិយាពេញបរិបូណ៌ ដោយការចំរើនរបស់ភិក្ខុ ៗ កាយរបស់ភិក្ខុដែលមានចិត្តប្រកបដោយបីតិ ក៏ស្ងប់ស្ងាត់ ទាំងចិត្តសោតក៏ស្ងប់ស្ងាត់ៗ ម្នាលភិក្ខុទាំងឡាយ ក្នុងសម័យណា បើកាយរបស់ភិក្ខុដែលមានចិត្តប្រកបដោយបីតិ ក៏ស្ងប់ស្ងាត់ ទាំងចិត្តសោត ក៏ស្ងប់ស្ងាត់ហើយ ក្នុងសម័យនោះ បស្សទ្ធិសម្ពោជ្ឈង្គ ក៏ឈ្មោះថាភិក្ខុប្រារព្ធហើយ ក្នុងសម័យនោះ ភិក្ខុឈ្មោះថាបានចំរើនបស្សទ្ធិសម្ពោជ្ឈង្គ ក្នុងសម័យនោះ បស្សទ្ធិសម្ពោជ្ឈង្គ ក៏ដល់នូវកិរិយាពេញបរិបូណ៌ ដោយការចំរើនរបស់ភិក្ខុ ៗ ចិត្តរបស់ភិក្ខុដែលមានកាយស្ងប់ស្ងាត់ ទាំងមានសេចក្តីសុខ ក៏តាំងនៅខ្ជាប់ ៗ ម្នាលភិក្ខុទាំងឡាយ ក្នុងសម័យណា ចិត្តរបស់ភិក្ខុដែលមានកាយស្ងប់ស្ងាត់ ទាំងមានសេចក្តីសុខតាំងនៅខ្ជាប់ហើយ ក្នុងសម័យនោះ សមាធិសម្ពោជ្ឈង្គ ក៏ឈ្មោះថាភិក្ខុប្រារព្ធហើយ ក្នុងសម័យនោះ ភិក្ខុឈ្មោះថាបានចំរើនសមាធិសម្ពោជ្ឈង្គ ក្នុងសម័យនោះ សមាធិសម្ពោជ្ឈង្គក៏ដល់នូវកិរិយាពេញបរិបូណ៌ ដោយការចំរើនរបស់ភិក្ខុ ៗ ភិក្ខុនោះញុំាងចិត្តដែលតាំងនៅខ្ជាប់ដូច្នោះ ឲ្យព្រងើយកន្តើយដោយស្រួល ៗ

យស្មឹ សមយេ ភិក្ខវេ ភិក្ខុ តថាសមាហិតំ ចិត្តំ សាធុកំ អជ្ឈុបេក្ខិតា ហោតិ ឧបេក្ខាសម្ពោជ្ឈង្គោ តស្មឹ សមយេ ភិក្ខុនោ អារទ្ធោ ហោតិ ឧបេក្ខាសម្ពោជ្ឈង្គំ តស្មឹ សមយេ ភិក្ខុ ភាវេតិ ឧបេក្ខាសម្ពោជ្ឈង្គោ តស្មឹ សមយេ ភិក្ខុនោ ភាវនាបារិបូរឹ គច្ឆតិ ។ ឯវំ ភាវិតា ខោ ភិក្ខវេ ចត្តារោ សតិបដ្ឋានា ឯវំ ពហុលីកតា សត្ត ពោជ្ឈង្គេ បរិបូរេន្តិ ។

(២៩១) កថំ ភាវិតា ច ភិក្ខវេ សត្ត ពោជ្ឈង្គា កថំ ពហុលីកតា វិជ្ជាវិមុត្តឹ បរិបូរេន្តិ ។ ឥធ ភិក្ខវេ ភិក្ខុ សតិសម្ពោជ្ឈង្គំ ភាវេតិ វិវេកនិស្សិតំ វិរាគនិស្សិតំ និរោធនិស្សិតំ វោស្សគ្គបរិណាមឹ ។ ធម្មវិចយសម្ពោជ្ឈង្គំ ភាវេតិ ... វីរិយសម្ពោជ្ឈង្គំ ភាវេតិ ... បីតិសម្ពោជ្ឈង្គំ ភាវេតិ ...

ម្នាលភិក្ខុទាំងឡាយ ក្នុងសម័យណា ភិក្ខុញុំាងចិត្តដែលតាំងនៅខ្ជាប់ខ្ជួន ឲ្យព្រងើយកន្តើយដោយស្រួលហើយ ក្នុងសម័យនោះ ឧបេក្ខាសម្ពោជ្ឈង្គ ក៏ឈ្មោះថាភិក្ខុប្រារព្ធហើយ ក្នុងសម័យនោះ ភិក្ខុឈ្មោះថាបាន ចំរើនឧបេក្ខាសម្ពោជ្ឈង្គ ក្នុងសម័យនោះ ឧបេក្ខាសម្ពោជ្ឈង្គក៏ដល់នូវ កិរិយាពេញបរិបូណ៌ដោយការចំរើនរបស់ភិក្ខុ ។ ម្នាលភិក្ខុទាំងឡាយ សតិប្បដ្ឋានទាំង ៤ ដែលបុគ្គលបានចំរើនយ៉ាងនេះ បានធ្វើឲ្យច្រើន ។ យ៉ាងនេះ រមែងញុំាងពោជ្ឈង្គទាំង ៧ ឲ្យពេញបរិបូណ៌បាន ។

(៤៤១) ម្នាលភិក្ខុទាំងឡាយ ពោជ្ឈង្គទាំង ៧ ដែលបុគ្គល ចំរើនហើយ ដូចម្តេច បានធ្វើឲ្យច្រើន ។ ហើយ ដូចម្តេច ទើប ញុំាងវិជ្ជានិងវិមុត្តិឲ្យពេញបរិបូណ៌បាន ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុង សាសនានេះ ចំរើនសតិសម្ពោជ្ឈង្គ ដែលអាស្រ័យវិវេក អាស្រ័យវិរាគៈ អាស្រ័យនិរោធ ជាធម្មជាតបង្អោនចិត្តទៅដើម្បីលះបង់ ។ ភិក្ខុចំរើន ធម្មវិចយសម្ពោជ្ឈង្គ... ចំរើនវីរិយសម្ពោជ្ឈង្គ... ចំរើនបីតិសម្ពោជ្ឈង្គ...

បស្សទ្ធិសម្ពោជ្ឈង្គំ ភាវេតិ ... សមាធិសម្ពោជ្ឈង្គំ ភាវេតិ ... ឧបេក្ខាសម្ពោជ្ឈង្គំ ភាវេតិ វិវេកនិស្សិតំ វិរាគនិស្សិតំ និរោធនិស្សិតំ វោស្សគ្គបរិណាមឹ ។ ឯវំ ភាវិតា ខោ ភិក្ខវេ សត្ត ពោជ្ឈង្គា ឯវំ ពហុលីកតា វិជ្ជាវិមុត្តឹ បរិបូរេន្តីតិ ។ ឥទមវោច ភគវា អត្តមនា តេ ភិក្ខូ ភគវតោ ភាសិតំ អភិនន្ទុន្តិ ។

អានាបានស្សតិសុត្តំ អដ្ឋមំ និដ្ឋិតំ ។

ចំរើនបស្សទ្ធិសម្ពោជ្ឈង្គ ... ចំរើនសមាធិសម្ពោជ្ឈង្គ ... ចំរើនឧបេក្ខាសម្ពោជ្ឈង្គ ដែលអាស្រ័យវិវេក អាស្រ័យវិរាគៈ អាស្រ័យនិរោធ ជាធម្មជាតបង្អោនចិត្តទៅ ដើម្បីលះបង់ ។ ម្នាលភិក្ខុទាំងឡាយ ពោជ្ឈង្គទាំង ៧ ដែលបុគ្គលចំរើនហើយយ៉ាងនេះ បានធ្វើឲ្យច្រើន ៗ ហើយយ៉ាងនេះ ទើបញ៉ាំងវិជ្ជានិងវិមុត្តិ ឲ្យពេញបរិបូណ៌បាន ។ លុះព្រះមានព្រះភាគ ទ្រង់សំដែងនូវអានាបានស្សតិសូត្រនេះចប់ហើយ ភិក្ខុទាំងនោះ មានសេចក្តីពេញចិត្ត ត្រេកអរហើយចំពោះភាសិត របស់ព្រះមានព្រះភាគ ។

ចប់ អានាបានស្សតិសូត្រ ។

# នវមំ កាយគតាសតិសុត្តំ

(២៩២) ឯវម្មេ សុតំ ។ ឯកំ សមយំ ភគវា សាវត្ថិយំ វិហរតិ ជេតវនេ អនាថបិណ្ឌិកស្ស អារាមេ ។ អថខោ សម្ពហុលានំ ភិក្ខូនំ បច្ឆាភត្តំ បិណ្ឌបាតបដិក្កន្តានំ ឧបដ្ឋានសាលាយំ សន្និសិន្នានំ សន្និបតិតានំ អយមន្តរាកថា ឧទបាទិ អច្ឆរិយំ អាវុសោ អព្ភុតំ អាវុសោ យាវញ្ចិទំ តេន ភគវតា ជានតា បស្សតា អរហតា សម្មាសម្ពុទ្ធេន កាយគតាសតិ ភាវិតា ពហុលីកតា មហប្ផលា វុត្តា មហានិសំសាតិ ។ អយញ្ច ខោ[១] ហិទំ តេសំ ភិក្ខូនំ អន្តរាកថា វិប្បកតា ហោតិ ។

---

១ ម. ខោសទ្ទោ នត្ថិ ។

# កាយគតាសតិសូត្រ ទី ៩

(២៩២) ខ្ញុំបានស្ដាប់មក យ៉ាងនេះ ។ សម័យមួយ ព្រះមានព្រះភាគ ទ្រង់គង់នៅក្នុងជេតវនារាម របស់អនាថបិណ្ឌិកសេដ្ឋី ទៀបក្រុងសាវត្ថី ។ គ្រានោះឯង ភិក្ខុទាំងឡាយ ច្រើនរូប ត្រឡប់មកពីបិណ្ឌបាតវិញ ក្នុងវេលាក្រោយភត្ត ក៏អង្គុយប្រជុំគ្នាក្នុងឧបដ្ឋានសាលា កើតកថាក្នុងចន្លោះនេះថា ម្នាលអ្នកមានអាយុទាំងឡាយ អស្ចារ្យណាស់ ម្នាលអ្នកមានអាយុទាំងឡាយ ចំឡែកណាស់ កាយគតាសតិ ដែលបុគ្គលបានចម្រើន បានធ្វើឲ្យរឿយៗ ហើយ ព្រះមានព្រះភាគ ជាអរហន្តសម្មាសម្ពុទ្ធអង្គនោះ ទ្រង់ជ្រាបច្បាស់ ឃើញច្បាស់ ត្រាស់សរសើរថា មានផលច្រើន មានអានិសង្សច្រើន ដោយពិត ៗ នេះឯង ជាកថាក្នុងចន្លោះ ដែលភិក្ខុទាំងអម្បាលនោះនិយាយមិនទាន់ចប់ ។

(២៩៣) អថខោ ភគវា សាយណ្ហសមយំ បដិសល្លានា វុដ្ឋិតោ យេន ឧបដ្ឋានសាលា តេនុបសង្កមិ ឧបសង្កមិត្វា បញ្ញត្តេ អាសនេ និសីទិ ។ និសជ្ជ ខោ ភគវា ភិក្ខូ អាមន្តេសិ កាយ នុត្ថ ភិក្ខវេ ឯតរហិ កថាយ សន្និសិន្នា កា ច បន វោ អន្តរាកថា វិប្បកតាតិ ។ ឥធ ភន្តេ អម្ហាកំ បច្ឆាភត្តំ បិណ្ឌបាតប្បដិក្កន្តានំ ឧបដ្ឋានសាលាយំ សន្និសិន្នានំ សន្និបតិតានំ អយមន្តរាកថា ឧទបាទិ អច្ឆរិយំ អាវុសោ អព្ភុតំ អាវុសោ យាវញ្ចិទំ តេន ភគវតា ជានតា បស្សតា អរហតា សម្មាសម្ពុទ្ធេន កាយគតា សតិ ភាវិតា ពហុលីកតា មហប្ផលា វុត្តា មហានិសំសាតិ អយំ(១) ខោ ភន្តេ អន្តរាកថា វិប្បកតា អថ(២) ភគវា អនុប្បត្តោតិ ។

១ ម. អយំ ខោ ។ ២ ម. អថខោ ។

(៤៩៣) លំដាប់នោះ ព្រះមានព្រះភាគទ្រង់ចេញចាកផលសមាបត្តិ ក្នុងវេលាសៀល ហើយស្តេចចូលទៅកាន់ឧបដ្ឋានសាលា លុះចូលទៅដល់ហើយ ទ្រង់គង់លើអាសនៈដែលគេតែងតាំងថ្វាយ ។ លុះព្រះមានព្រះភាគ គង់ស្រេចហើយ បានត្រាស់នឹងភិក្ខុទាំងឡាយថា ម្នាលភិក្ខុទាំងឡាយ អម្បាញ់មិញនេះ អ្នកទាំងឡាយអង្គុយប្រជុំគ្នាដោយកថាអ្វី មួយទៀត កថាអ្វីក្នុងចន្លោះនេះ ដែលអ្នកទាំងឡាយនិយាយមិនទាន់ចប់ ។ ភិក្ខុទាំងឡាយក្រាបបង្គំទូលថា បពិត្រព្រះអង្គដ៏ចម្រើន ក្នុងទីនេះ ពួកខ្ញុំព្រះអង្គត្រឡប់មកពីបិណ្ឌបាតវិញ ក្នុងវេលាក្រោយភត្ត ក៏អង្គុយប្រជុំគ្នាក្នុងឧបដ្ឋានសាលា កើតកថាក្នុងចន្លោះនេះថា ម្នាលអ្នកមានអាយុទាំងឡាយ អស្ចារ្យណាស់ ម្នាលអ្នកមានអាយុទាំងឡាយ ចំឡែកណាស់ កាយគតាសតិ ដែលបុគ្គលបានចម្រើន បានធ្វើឲ្យរឿយ ៗ ហើយ ព្រះមានព្រះភាគ ជាអរហន្តសម្មាសម្ពុទ្ធអង្គនោះ ទ្រង់ជ្រាបច្បាស់ ឃើញច្បាស់ ត្រាស់សរសើរថា មានផលច្រើន មានអានិសង្សច្រើន ដោយពិត បពិត្រព្រះអង្គដ៏ចម្រើន នេះជាកថាក្នុងចន្លោះ ដែលពួកខ្ញុំព្រះអង្គនិយាយមិនទាន់ចប់ ស្រាប់តែព្រះអង្គស្តេចមកដល់ ។

(២៩៤) កថំ ភាវិតា ច ភិក្ខវេ កាយគតាសតិ កថំ ពហុលីកតា មហប្ផលា ហោតិ មហានិសំសា ។ ឥធ ភិក្ខវេ ភិក្ខុ អរញ្ញគតោ វា រុក្ខមូលគតោ វា សុញ្ញាគារគតោ វា និសីទតិ បល្លង្កំ អាភុជិត្វា ឧជុំ កាយំ បណិធាយ បរិមុខំ សតឹ ឧបដ្ឋបេត្វា ។ សោ សតោវ អស្សសតិ សតោ បស្សសតិ ។ ទីឃំ វា អស្សសន្តោ ទីឃំ អស្សសាមីតិ បជានាតិ ទីឃំ វា បស្សសន្តោ ទីឃំ បស្សសាមីតិ បជានាតិ ។ រស្សំ វា អស្សសន្តោ រស្សំ អស្សសាមីតិ បជានាតិ រស្សំ វា បស្សសន្តោ រស្សំ បស្សសាមីតិ បជានាតិ ។ សព្វកាយប្បដិសំវេទី អស្សសិស្សាមីតិ សិក្ខតិ សព្វកាយប្បដិសំវេទី បស្សសិស្សាមីតិ សិក្ខតិ ។ បស្សម្ភយំ កាយសង្ខារំ អស្សសិស្សាមីតិ សិក្ខតិ បស្សម្ភយំ កាយសង្ខារំ បស្សសិស្សាមីតិ សិក្ខតិ ។

(២៩៤) ព្រះអង្គត្រាស់ថា ម្នាលភិក្ខុទាំងឡាយ កាយគតាសតិ ដែលបុគ្គលបានចម្រើន ដូចម្ដេច បានធ្វើឲ្យរឿយ ៗ ដូចម្ដេច ទើបមានផលច្រើន មានអានិសង្សច្រើន ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ទៅកាន់ព្រៃក្ដី ទៅកាន់ម្លប់ឈើក្ដី ទៅកាន់ផ្ទះស្ងាត់ក្ដី អង្គុយពែនភ្នែន តាំងកាយឲ្យត្រង់ តំកល់ស្មារតីឲ្យមានមុខឆ្ពោះទៅរក (កម្មដ្ឋាន) ។ ភិក្ខុនោះ មានស្មារតី ដកដង្ហើមចេញ មានស្មារតី ដកដង្ហើមចូល ។ ភិក្ខុកាលដកដង្ហើមចេញវែង ក៏ដឹងច្បាស់ថា អាត្មាអញដកដង្ហើមចេញវែង កាលដកដង្ហើមចូលវែង ក៏ដឹងច្បាស់ថា អាត្មាអញដកដង្ហើមចូលវែង ។ កាលដកដង្ហើមចេញខ្លី ក៏ដឹងច្បាស់ថា អាត្មាអញដកដង្ហើមចេញខ្លី កាលដកដង្ហើមចូលខ្លី ក៏ដឹងច្បាស់ថា អាត្មាអញដកដង្ហើមចូលខ្លី ។ ភិក្ខុសិក្សាថា អាត្មាអញដឹងច្បាស់នូវកាយ គឺដង្ហើមចេញទាំងពួង នឹងដកដង្ហើមចេញ សិក្សាថា អាត្មាអញដឹងច្បាស់នូវកាយ គឺដង្ហើមចូលទាំងពួង នឹងដកដង្ហើមចូល ។ សិក្សាថា អាត្មាអញ រម្ងាប់នូវកាយសង្ខារគឺដង្ហើមចេញ នឹងដកដង្ហើមចេញ សិក្សាថាអាត្មាអញ រម្ងាប់នូវកាយសង្ខារគឺដង្ហើមចូល នឹងដកដង្ហើមចូល ។

តស្ស ឯវំ អប្បមត្តស្ស [១] អាតាបិនោ បហិតត្តស្ស វិហរតោ យេ [២] គេហសិតា សរសង្កប្បា តេ បហីយន្តិ ។ តេសំ បហានា អជ្ឈត្តមេវ ចិត្តំ សន្តិដ្ឋតិ សន្និសីទតិ ឯកោទិហោតិ សមាធិយតិ ឯវម្បិ ភិក្ខវេ ភិក្ខុ កាយគតំ សតឹ ភាវេតិ ។

[២៩៨] បុន ចបរំ ភិក្ខវេ ភិក្ខុ គច្ឆន្តោ វា គច្ឆាមីតិ បជានាតិ ឋិតោ វា ឋិតោម្ហីតិ បជានាតិ និសិន្នោ វា និសិន្នោម្ហីតិ បជានាតិ សយានោ វា សយានោម្ហីតិ បជានាតិ ។ យថា យថា វា បនស្ស កាយោ បណិហិតោ ហោតិ តថា តថា នំ បជានាតិ ។ តស្ស ឯវំ អប្បមត្តស្ស អាតាបិនោ បហិតត្តស្ស វិហរតោ យេ គេហសិតា សរសង្កប្បា តេ បហីយន្តិ ។ តេសំ បហានា អជ្ឈត្តមេវ ចិត្តំ សន្តិដ្ឋតិ សន្និសីទតិ ឯកោទិហោតិ សមាធិយតិ ឯវម្បិ ភិក្ខវេ ភិក្ខុ កាយគតំ សតឹ ភាវេតិ ។

---

១. ឯវមប្បមត្តស្ស ។ ២ ឱ. យេ កេ ។

កាលភិក្ខុនោះមិនប្រមាទ មានព្យាយាមជាគ្រឿងដុតកំដៅកិលេស មានចិត្តបញ្ជូនទៅកាន់ព្រះនិព្វានយ៉ាងនេះ ក៏បានលះបង់ នូវសេចក្តីត្រិះរិះដែលស្ទុះទៅ ដែលអាស្រ័យកាមគុណទាំង ៥ ។ ព្រោះលះបង់នូវសេចក្តីត្រិះរិះ ដែលស្ទុះទៅទាំងអម្បាលនោះចេញបាន ចិត្តខាងក្នុងក៏តំកល់មាំ តំកល់ខ្ជាប់ ដល់នូវភាវៈខ្ពស់ឯក ឈ្មោះថាភិក្ខុតំកល់មាំ ម្នាលភិក្ខុទាំងឡាយ ភិក្ខុចម្រើនកាយគតាសតិ ដោយវិធីយ៉ាងនេះក៏បាន ។

(២៩៥) ម្នាលភិក្ខុទាំងឡាយ មួយទៀត ភិក្ខុ (ក្នុងសាសនានេះ ទោះដើរ ក៏ដឹងច្បាស់ថា អាត្មាអញដើរ ទោះឈរ ក៏ដឹងច្បាស់ថា អាត្មាអញឈរ ទោះអង្គុយ ក៏ដឹងច្បាស់ថា អាត្មាអញអង្គុយ ទោះដេក ក៏ដឹងច្បាស់ថា អាត្មាអញដេក ។ ឬកាយរបស់ភិក្ខុនោះតំកល់នៅ ដោយអាការយ៉ាងណា ៗ ភិក្ខុក៏ដឹងច្បាស់នូវកាយនោះ ដោយអាការយ៉ាងនោះ ៗ ។ កាលភិក្ខុនោះ មិនប្រមាទ មានព្យាយាមជាគ្រឿងដុតកំដៅកិលេស មានចិត្តបញ្ជូនទៅកាន់ព្រះនិព្វានយ៉ាងនេះ ក៏បានលះបង់នូវសេចក្តីត្រិះរិះដែលស្ទុះទៅ ដែលអាស្រ័យនូវកាមគុណទាំង ៥ បាន ។ លុះលះបង់នូវសេចក្តីត្រិះរិះ ដែលស្ទុះទៅទាំងអម្បាលនោះបានហើយ ចិត្តខាងក្នុងក៏តំកល់មាំ តំកល់ខ្ជាប់ ដល់នូវភាវៈខ្ពស់ឯក ឈ្មោះថាភិក្ខុតំកល់មាំ ម្នាលភិក្ខុទាំងឡាយ ភិក្ខុចម្រើនកាយគតាសតិ ដោយវិធីយ៉ាងនេះក៏បាន ។

(២៩៦) បុន ចបរំ ភិក្ខវេ ភិក្ខុ អភិក្កន្តេ បដិក្កន្តេ សម្បជានការី ហោតិ អាលោកិតេ វិលោកិតេ សម្បជានការី ហោតិ សម្មិញ្ជិតេ បសារិតេ សម្បជានការី ហោតិ សង្ឃាដិបត្តចីវរធារណេ សម្បជានការី ហោតិ អសិតេ បីតេ ខាយិតេ សាយិតេ សម្បជានការី ហោតិ ឧច្ចារបស្សាវកម្មេ សម្បជានការី ហោតិ គតេ ឋិតេ និសិន្នេ សុត្តេ ជាគរិតេ ភាសិតេ តុណ្ហីភាវេ សម្បជានការី ហោតិ ។ តស្ស ឯវំ អប្បមត្តស្ស អាតាបិនោ បហិតត្តស្ស វិហរតោ យេ គេហសិតា សរសង្កប្បា តេ បហីយន្តិ ។ តេសំ បហានា អជ្ឈត្តមេវ ចិត្តំ សន្តិដ្ឋតិ សន្និសីទតិ ឯកោទិ ហោតិ សមាធិយតិ ឯវម្បិ ភិក្ខវេ ភិក្ខុ កាយគតំ សតឹ ភាវេតិ ។

(៤៩៦) ម្នាលភិក្ខុទាំងឡាយ មួយទៀត ភិក្ខុធ្វើនូវសេចក្ដីដឹងខ្លួនក្នុងការទៅមុខ និងការថយក្រោយ ធ្វើនូវសេចក្ដីដឹងខ្លួន ក្នុងការក្រឡេកមើលទៅមុខ និងក្រឡេកមើលទៅទិសផ្សេងៗ ធ្វើនូវសេចក្ដីដឹងខ្លួនក្នុងការបត់ដៃជើង និងលាដៃជើង ធ្វើនូវសេចក្ដីដឹងខ្លួន ក្នុងការទ្រទ្រង់នូវសង្ឃាដី បាត្រ និងចីវរ ធ្វើនូវសេចក្ដីដឹងខ្លួន ក្នុងការបរិភោគភោជន ផឹកទឹក ទំពាស៊ីខាទនីយៈ និងជញ្ជក់ (នូវភេសជ្ជៈមានសប្បិជាដើម) ធ្វើនូវសេចក្ដីដឹងខ្លួន ក្នុងការបន្ទោបង់នូវឧច្ចារៈបស្សាវៈ ធ្វើនូវសេចក្ដីដឹងខ្លួនក្នុងការដើរ ឈរ អង្គុយ ដេកលក់ ភ្ញាក់ឡើង និយាយនឹងនៅស្ងៀម ៗ កាលភិក្ខុនោះមិនប្រមាទ មានព្យាយាមជាគ្រឿងដុតកំដៅកិលេស មានចិត្តបញ្ជូនទៅកាន់ព្រះនិព្វានយ៉ាងនេះ ក៏លះបង់នូវសេចក្ដីត្រិះរិះដែលស្ទុះទៅ ដែលអាស្រ័យកាមគុណទាំង ៥ បាន ៗ លុះលះបង់សេចក្ដីត្រិះរិះដែលស្ទុះទៅទាំងអម្បាលនោះបានហើយ ចិត្តខាងក្នុងក៏តាំងនៅមាំ តាំងនៅខ្ជាប់ ដល់នូវភាវៈខ្ពស់ឯក ឈ្មោះថាភិក្ខុតាំងនៅមាំ ម្នាលភិក្ខុទាំងឡាយ ភិក្ខុចម្រើនកាយគតាសតិ ដោយវិធីយ៉ាងនេះក៏បាន ៗ

(២៩៧) បុន ចបរំ ភិក្ខវេ ភិក្ខុ ឥមមេវ កាយំ ឧទ្ធំ បាទតលា អធោ កេសមត្ថកា តចបរិយន្តំ បូរន្នានប្បការស្ស អសុចិនោ បច្ចវេក្ខតិ អត្ថិ ឥមស្មឹ កាយេ កេសា លោមា នខា ទន្តា តចោ មំសំ នហារុ អដ្ឋី អដ្ឋិមិញ្ជំ វក្កំ ហទយំ យកនំ កិលោមកំ បិហកំ បប្ផាសំ អន្តំ អន្តគុណំ ឧទរិយំ ករីសំ បិត្តំ សេម្ហំ បុព្វោ លោហិតំ សេទោ មេទោ អស្សុ វសា ខេឡោ សិង្ឃាណិកា លសិកា មុត្តន្តិ [១] ។ សេយ្យថាបិ ភិក្ខវេ ឧភតោមុខា មុតោលី [២] បូរា នានាវិហិតស្ស ធញ្ញស្ស សេយ្យថីទំ សាលីនំ វីហីនំ មុគ្គានំ មាសានំ តិលានំ តណ្ឌុលានំ តមេនំ ចក្ខុមា បុរិសោ មុញ្ចិត្វា បច្ចវេក្ខេយ្យ ឥមេ សាលី ឥមេ វីហី ឥមេ មុគ្គា ឥមេ មាសា ឥមេ តិលា ឥមេ តណ្ឌុលាតិ

---

១ ម. ឥតិសទ្ទោ នត្ថិ ។ ២ ម. បូតោលិ ។

(៤៩៧) ម្នាលភិក្ខុទាំងឡាយ មួយទៀត ភិក្ខុពិចារណាឃើញច្បាស់នូវកាយនេះឯង ខាងលើតាំងអំពីបាតជើងឡើងទៅ ខាងក្រោមតាំងអំពីចុងសក់ចុះមក ដែលមានស្បែកបិទជុំវិញ ពេញដោយវត្ថុមិនស្អាត មានប្រការផ្សេងៗ ដូច្នេះថា ក្នុងកាយនេះមានសក់ រោម ក្រចក ធ្មេញ ស្បែក សាច់ សរសៃ ឆ្អឹង ខួរក្នុងឆ្អឹង តម្រងបស្សាវៈ បេះដូង ថ្លើម វាវ ក្រពះ សួត ពោះវៀនធំ ពោះវៀនតូច អាហារថ្មី អាហារចាស់ ប្រមាត់ ស្លេស្ម ខ្ទុះ ឈាម ញើស ខ្លាញ់ខាប់ ទឹកភ្នែក ខ្លាញ់រាវ ទឹកមាត់ ទឹកសំបោរ ទឹករអិល ទឹកមូត្រ ។ ម្នាលភិក្ខុទាំងឡាយ ថង់ដែលមានមាត់ទាំងពីរខាង ពេញដោយធញ្ញជាតិមានប្រការផ្សេងៗ ធញ្ញជាតិទាំងនោះ គឺស្រូវខ្សាយស ស្រូវខ្សាយក្រហម សណ្ដែកបាយ សណ្ដែកកជមាស ល្ង អង្ករ បុរសដែលមានចក្ខុគប្បីស្រាយនូវថង់នោះ ហើយពិនិត្យមើលដូច្នេះថា នេះស្រូវខ្សាយស នេះស្រូវខ្សាយក្រហម នេះសណ្ដែកបាយ នេះសណ្ដែកកជមាស នេះល្ង នេះអង្ករ មានឧបមា

ឯវមេវ ខោ ភិក្ខវេ ភិក្ខុ [(១)] ឥមមេវ កាយំ ឧទ្ធំ បាទតលា អធោ កេសមត្ថកា តចបរិយន្តំ បូរន្នានប្បការស្ស អសុចិនោ បច្ចវេក្ខតិ អត្ថិ ឥមស្មឹ កាយេ កេសា លោមា នខា ទន្តា តចោ មំសំ នហារូ អដ្ឋី អដ្ឋិមិញ្ជំ វក្កំ ហទយំ យកនំ កិលោមកំ បិហកំ បប្ផាសំ អន្តំ អន្តគុណំ ឧទរិយំ ករីសំ បិត្តំ សេម្ហំ បុព្វោ លោហិតំ សេទោ មេទោ អស្សុវសា ខេឡោ សិង្ឃាណិកា លសិកា មុត្តន្តិ ។

តស្ស ឯវំ អប្បមត្តស្ស អាតាបិនោ បហិតត្តស្ស វិហរតោ យេ គេហសិតា សរសង្កប្បា តេ បហីយន្តិ ។ តេសំ បហានា អជ្ឈត្តមេវ ចិត្តំ សន្តិដ្ឋតិ សន្និសីទតិ ឯកោទិហោតិ សមាធិយតិ ឯវម្បិ ភិក្ខវេ ភិក្ខុ កាយគតំ សតឹ ភាវេតិ ។

---

១ ឱ. ភិក្ខូតិ ន ទិស្សតិ ។

ដូចម្តេចមិញ ម្នាលភិក្ខុទាំងឡាយ ភិក្ខុពិចារណាឃើញច្បាស់នូវកាយនេះឯង ខាងលើតាំងអំពីបាតជើងឡើងទៅ ខាងក្រោមតាំងអំពីចុងសក់ចុះមក ដែលមានស្បែកបិទជុំវិញ ពេញដោយវត្ថុមិនស្អាត មានប្រការផ្សេងៗ ដូច្នេះថា ក្នុងកាយនេះមានសក់ រោម ក្រចក ធ្មេញ ស្បែក សាច់ សរសៃ ឆ្អឹង ខួរក្នុងឆ្អឹង តម្រងបស្សាវៈ បេះដូង ថ្លើម វាវ ក្រពះ សួត ពោះវៀនធំ ពោះវៀនតូច អាហារថ្មី អាហារចាស់ ប្រមាត់ ស្លេស្ម ខ្ទុះ ឈាម ញើស ខ្លាញ់ខាប់ ទឹកភ្នែក ទឹកវ ទឹកមាត់ ទឹកសម្បោរ ទឹករំអិល ទឹកមូត្រ ក៏មានឧបមេយ្យដូច្នោះឯង ។ កាលភិក្ខុនោះមិនប្រមាទ មានព្យាយាមជាគ្រឿងដុតកំដៅកិលេស មានចិត្តបញ្ជូនទៅកាន់ព្រះនិព្វានយ៉ាងនេះហើយ ក៏លះបង់នូវសេចក្តីត្រិះរិះដែលស្ទុះទៅ ដែលអាស្រ័យកាមគុណទាំង ៥ បាន ។ លុះលះបង់នូវសេចក្តីត្រិះរិះ ដែលស្ទុះទៅទាំងអម្បាលនោះបានហើយ ចិត្តខាងក្នុងក៏តំកល់មាំ តំកល់ខ្ជាប់ ដល់នូវភាវៈខ្ពស់ឯក ឈ្មោះថាភិក្ខុតំកល់មាំ ម្នាលភិក្ខុទាំងឡាយ ភិក្ខុចម្រើនកាយគតាសតិ ដោយវិធីយ៉ាងនេះក៏មាន ។

[២៩៨] បុន ចបរំ ភិក្ខវេ ភិក្ខុ ឥមមេវ កាយំ យថាឋិតំ យថាបណិហិតំ ធាតុសោ បច្ចវេក្ខតិ អត្ថិ ឥមស្មឹ កាយេ បឋវីធាតុ អាបោធាតុ តេជោធាតុ វាយោធាតូតិ(១) ។ សេយ្យថាបិ ភិក្ខវេ ទក្ខោ គោឃាតកោ វា គោឃាតកន្តេវាសី វា គាវឹ វធិត្វា ចាតុម្មហាបថេ វិលសោ(២) បដិវិភជិត្វា និសិន្នោ អស្ស ឯវមេវ ខោ ភិក្ខវេ ភិក្ខុ ឥមមេវ កាយំ យថាឋិតំ យថាបណិហិតំ ធាតុសោ បច្ចវេក្ខតិ អត្ថិ ឥមស្មឹ កាយេ បឋវីធាតុ អាបោធាតុ តេជោធាតុ វាយោធាតូតិ ។ តស្ស ឯវំ អប្បមត្តស្ស អាតាបិនោ បហិតត្តស្ស វិហរតោ យេ គេហសិតា សរសង្កប្បា តេ បហីយន្តិ ។ តេសំ បហានា អជ្ឈត្តមេវ ចិត្តំ សន្តិដ្ឋតិ សន្និសីទតិ ឯកោទិភោតិ សមាធិយតិ ឯវម្បិ ភិក្ខវេ ភិក្ខុ កាយគតំ សតឹ ភាវេតិ ។

១ ឱ. ឥតិសទ្ទោ នត្ថិ ។ ២ ឱ. ពិលសោ ។

[២៩៨] ម្នាលភិក្ខុទាំងឡាយ មួយទៀត ភិក្ខុពិចារណាឃើញច្បាស់នូវកាយនេះឯង ដែលឋិតនៅយ៉ាងណា ដែលតំកល់នៅយ៉ាងណា ដោយកំណត់ថាគ្រាន់តែជាធាតុ ដូច្នេះថា ក្នុងកាយនេះមានធាតុដី ធាតុទឹក ធាតុភ្លើង ធាតុខ្យល់ ។ ម្នាលភិក្ខុទាំងឡាយ បុរសអ្នកពិឃាតគោក្តី កូនសិស្សនៃបុរសអ្នកពិឃាតគោក្តី ដែលប៉ិនប្រសប់ គប្បីសម្លាប់គោ ហើយវែកជាចំណែក ៗ អង្គុយនៅទៀបផ្លូវធំបែកជា ៤ មានឧបមាដូចម្តេចមិញ ម្នាលភិក្ខុទាំងឡាយ ភិក្ខុពិចារណាឃើញច្បាស់នូវកាយនេះឯង ដែលឋិតនៅយ៉ាងណា ដែលតំកល់នៅយ៉ាងណា ដោយកំណត់គ្រាន់តែជាធាតុ ដូច្នេះថា ក្នុងកាយនេះមានធាតុដី ធាតុទឹក ធាតុភ្លើង ធាតុខ្យល់ ក៏មានឧបមេយ្យដូច្នោះឯង ។ កាលភិក្ខុនោះមិនប្រមាទ មានព្យាយាមដាក់គ្រឿងដុតកំដៅកិលេស មានចិត្តបញ្ជូនទៅកាន់ព្រះនិព្វានយ៉ាងនេះហើយ ក៏លះបង់នូវសេចក្តីត្រិះរិះ ដែលស្ទុះទៅ ដែលអាស្រ័យកាមគុណទាំង ៥ បាន ។ លុះលះបង់នូវសេចក្តីត្រិះរិះដែលស្ទុះទៅទាំងអម្បាលនោះបានហើយ ចិត្តខាងក្នុងក៏តំកល់មាំ តំកល់ខ្ជាប់ ដល់នូវភាវៈខ្ពស់ឯក ឈ្មោះថា ភិក្ខុតំកល់មាំ ម្នាលភិក្ខុទាំងឡាយ ភិក្ខុចម្រើនកាយគតាសតិ ដោយវិធីយ៉ាងនេះក៏បាន ។

(២៩៩) បុន ចបរំ ភិក្ខវេ ភិក្ខុ សេយ្យថាបិ បស្សេយ្យ សរីរំ សីវថិកាយ ឆឌ្ឌិតំ ឯកាហមតំ វា ទ្វិហមតំ វា តីហមតំ វា ឧទ្ធុមាតកំ វិនីលកំ វិបុព្វកជាតំ ។ សោ ឥមមេវ កាយំ ឧបសំហរតិ អយម្បិ ខោ កាយោ ឯវំធម្មោ ឯវំភាវី ឯវំអនតីតោតិ ។ តស្ស ឯវំ អប្បមត្តស្ស អាតាបិនោ បហិតត្តស្ស វិហរតោ យេ គេហសិតា សរសង្កប្បា តេ បហីយន្តិ ។ តេសំ បហានា អជ្ឈត្តមេវ ចិត្តំ សន្តិដ្ឋតិ សន្និសីទតិ ឯកោទិហោតិ សមាធិយតិ ឯវម្បិ ភិក្ខវេ ភិក្ខុ កាយគតំ សតឹ ភាវេតិ ។

(៣០០) បុន បបរំ ភិក្ខវេ ភិក្ខុ សេយ្យថាបិ បស្សេយ្យ សរីរំ សីវថិកាយ ឆឌ្ឌិតំ កាកេហិ វា ខជ្ជមានំ គិជ្ឈេហិ វា ខជ្ជមានំ កុលលេហិ វា ខជ្ជមានំ សុភណោហិ វា ខជ្ជមានំ សិង្គាលេហិ វា ខជ្ជមានំ

(២៩៩) ម្នាលភិក្ខុទាំងឡាយ មួយទៀត ភិក្ខុគប្បីឃើញនូវ សរីរៈស្លាប់ ដែលគេចោលក្នុងព្រៃស្មសាន ទោះស្លាប់អស់ថ្ងៃ ១ ក្តី ស្លាប់អស់ថ្ងៃ ២ ក្តី ស្លាប់អស់ថ្ងៃ ៣ ក្តី ដែលកំពុងហើម មានសម្បុរខៀវ ដោយច្រើន មានខ្ទុះហូរចេញតាមទ្វារផ្សេង ៗ ដូចម្តេចមិញ ៗ ភិក្ខុនោះ (ក៏បង្អោនសរីរៈស្លាប់នោះ) មកប្រៀបផ្ទឹមនឹងកាយនេះឯង ដូច្នេះ ថា សូម្បីកាយនេះសោត ក៏គង់នឹងមានសភាពយ៉ាងនេះ គង់នឹងក្លាយទៅជាយ៉ាងនេះ នឹងកន្លងភាវៈយ៉ាងនេះ ពុំបានឡើយ ៗ កាលភិក្ខុនោះ មិនប្រមាទ មានព្យាយាមជាគ្រឿងដុតកំដៅកិលេស មានចិត្តបញ្ជូន ទៅកាន់ព្រះនិព្វានយ៉ាងនេះហើយ ក៏លះបង់នូវសេចក្តីត្រិះរិះដែលស្ទុះ ទៅ ដែលអាស្រ័យកាមគុណទាំង ៥ បាន ៗ លុះលះបង់នូវសេចក្តី ត្រិះរិះដែលស្ទុះទៅទាំងអម្បាលនោះបានហើយ ចិត្តខាងក្នុង ក៏តំកល់មាំ តំកល់ខ្ជាប់ ដល់ភាវៈខ្ពស់ឯក ឈ្មោះថាភិក្ខុតំកល់មាំ ម្នាលភិក្ខុទាំងឡាយ ភិក្ខុចំរើននូវកាយគតាសតិ ដោយវិធីយ៉ាងនេះក៏បាន ៗ

(៣០០) ម្នាលភិក្ខុទាំងឡាយ មួយទៀត ភិក្ខុគប្បីឃើញនូវ សរីរៈស្លាប់ ដែលគេចោលក្នុងព្រៃស្មសាន ក្អែកទាំងឡាយ កំពុងចឹក ស៊ីក្តី ត្មាតទាំងឡាយ កំពុងចឹកស៊ីក្តី ត្រដក់ទាំងឡាយ កំពុងចឹកស៊ីក្តី ស្វានទាំងឡាយ កំពុងកកេរស៊ីក្តី ចចកទាំងឡាយ កំពុងកកេរស៊ីក្តី

វិវិធេហិ វា បាណកជាតេហិ ខជ្ជមានំ ។ សោ ឥមមេវ កាយំ ឧបសំហរតិ អយម្បិ ខោ កាយោ ឯវំធម្មោ ឯវំភាវី ឯវំអនតីតោតិ ។ តស្ស ឯវំ អប្បមត្តស្ស ។ បេ[១] ។ ឯវម្បិ ភិក្ខវេ ភិក្ខុ កាយគតំ សតិំ ភាវេតិ ។

(៣០១) បុន ចបរំ ភិក្ខវេ ភិក្ខុ សេយ្យថាបិ បស្សេយ្យ សរីរំ សិវថិកាយ ឆឌ្ឌិតំ អដ្ឋិសង្ខលិកំ[២] សមំសលោហិតំ នហារុសម្ពន្ធំ... អដ្ឋិសង្ខលិកំ និម្មំសលោហិតមក្ខិតំ នហារុសម្ពន្ធំ... អដ្ឋិសង្ខលិកំ អបគតមំសលោហិតំ នហារុសម្ពន្ធំ... អដ្ឋិកានិ អបគតនហារុសម្ពន្ធានិ ទិសា វិទិសា វិក្ខិត្តានិ អញ្ញេន ហត្ថដ្ឋិកំ អញ្ញេន បាទដ្ឋិកំ អញ្ញេន ជង្ឃដ្ឋិកំ អញ្ញេន ឩរុដ្ឋិកំ អញ្ញេន កដិដ្ឋិកំ អញ្ញេន បិដ្ឋិកណ្ដកំ... អញ្ញេន សីសកដាហំ ។ សោ

---

១ ឱ. បេយ្យាលោ ន ទិស្សតិ ។ ២ ម. អដ្ឋិកសង្ខលិកំ ។

បាណកជាតិ ( សត្វតូច ៗ មានដង្កូវជាដើម ) ទាំងឡាយផ្សេង ៗ កំពុងជញ្ជាក់ស៊ីក្តី ដូចម្តេចមិញ ។ ភិក្ខុនោះ ( គឺបង្អោនសរីរៈស្លាប់នោះ ) មកប្រៀបផ្ទឹមនឹងកាយនេះឯងថា សូម្បីកាយនេះក៏គង់នឹងមានសភាពយ៉ាងនេះ គង់នឹងក្លាយទៅជាយ៉ាងនេះ មិនកន្លងនូវភាវៈយ៉ាងនេះពុំបានឡើយ ។ កាលភិក្ខុនោះ មិនប្រមាទយ៉ាងនេះ ។ បេ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុចម្រើនកាយគតាសតិ ដោយវិធីយ៉ាងនេះក៏បាន ។

(៣០១) ម្នាលភិក្ខុទាំងឡាយ មួយទៀត ភិក្ខុគប្បីឃើញនូវសរីរៈស្លាប់ ដែលគេចោលក្នុងព្រៃស្មសាន នៅសល់តែរាងឆ្អឹង ប្រកបដោយសាច់និងឈាម នៅមានសរសៃជាគ្រឿងចង... នៅសល់តែរាងឆ្អឹងឥតសាច់ តែនៅប្រឡាក់ដោយឈាម មានសរសៃជាគ្រឿងចង ... នៅសល់តែរាងឆ្អឹង ប្រាសចាកសាច់និងឈាម តែនៅមានសរសៃជាគ្រឿងចង... នៅសល់តែឆ្អឹងទទេ ប្រាសចាកសរសៃជាគ្រឿងចង ខ្ចាត់ខ្ចាយពាត់ពាយទៅក្នុងទិសតូចនិងទិសធំ គឺឆ្អឹងដៃទៅដោយឡែក ឆ្អឹងជើងទៅដោយឡែក ឆ្អឹងស្មងទៅដោយឡែក ឆ្អឹងភ្លៅទៅដោយឡែក ឆ្អឹងចង្កេះទៅដោយឡែក ឆ្អឹងខ្នងទៅដោយឡែក... លលាដ៍ក្បាលទៅដោយឡែក ដូចម្តេចមិញ ។ ភិក្ខុនោះ ( គឺបង្អោនសរីរៈស្លាប់នោះ)

ឥមមេវ កាយំ ឧបសំហរតិ អយម្បិ ខោ កាយោ ឯវំធម្មោ ឯវំភាវី ឯវំអនតីតោតិ ។ តស្ស ឯវំ អប្បមត្តស្ស ។ បេ ។ ឯវម្បិ ភិក្ខវេ ភិក្ខុ កាយគតំ សតឹ ភាវេតិ ។

[៣០២] បុន ចបរំ ភិក្ខវេ ភិក្ខុ សេយ្យថាបិ បស្សេយ្យ សរីរំ សិវថិកាយ ឆឌ្ឌិតំ អដ្ឋិកានិ សេតានិ សង្ខវណ្ណបដិភាគានិ[១] អដ្ឋិកានិ បុញ្ជកិតានិ[២] តេរោវស្សិកានិ... អដ្ឋិកានិ បូតីនិ ចុណ្ណកជាតានិ ។ សោ ឥមមេវ កាយំ ឧបសំហរតិ អយម្បិ ខោ កាយោ ឯវំធម្មោ ឯវំភាវី ឯវំអនតីតោតិ ។ តស្ស ឯវំ អប្បមត្តស្ស ។ បេ ។ ឯវម្បិ ខោ ភិក្ខវេ ភិក្ខុ កាយគតំ សតឹ ភាវេតិ ។

១ ម. សង្ខវណ្ណូបនិភាគានិ ។ ២ ឱ. បុញ្ជកជាតានិ ។

មកប្រៀបផ្ទឹមនឹងកាយនេះឯងថា សូម្បីកាយនេះ ក៏គង់នឹងមានសភាពយ៉ាងនេះ គង់នឹងក្លាយទៅជាយ៉ាងនេះ កន្លងនូវភាវៈយ៉ាងនេះពុំបានឡើយ ។ កាលភិក្ខុនោះ មិនប្រមាទយ៉ាងនេះហើយ ។ បេ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុចម្រើនកាយគតាសតិ ដោយវិធីយ៉ាងនេះក៏បាន ។

(៣០២) ម្នាលភិក្ខុទាំងឡាយ មួយទៀត ភិក្ខុគប្បីឃើញនូវសរីរៈស្លាប់ ដែលគេចោលក្នុងព្រៃស្មសាន សល់នៅតែឆ្អឹងទទេ មានសម្បុរដូចជាសម្បុរនៃស័ង្ខ... សល់នៅតែឆ្អឹងទទេគរជាពំនូក កន្លងហួសមួយឆ្នាំហើយ... សល់នៅតែឆ្អឹងទទេ ពុកផុយខ្ទេចខ្ទី ជាលំអិតតូច លំអិតធំ ដូចម្ដេចមិញ ។ ភិក្ខុនោះ ( ក៏បង្អោនសរីរៈស្លាប់នោះ ) មកប្រៀបផ្ទឹមនឹងកាយនេះឯងថា សូម្បីកាយនេះសោតក៏គង់នឹងមានសភាពយ៉ាងនេះ គង់នឹងក្លាយទៅយ៉ាងនេះ មិនកន្លងនូវភាវៈយ៉ាងនេះពុំបានឡើយ ។ កាលភិក្ខុនោះ មិនប្រមាទយ៉ាងនេះ ។ បេ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុចម្រើនកាយគតាសតិ ដោយវិធីយ៉ាងនេះក៏បាន ។

(៣០៣) បុន ចបរំ ភិក្ខវេ ភិក្ខុ វិវិច្ចេវ កាមេហិ វិវិច្ច អកុសលេហិ ធម្មេហិ សវិតក្កំ សវិចារំ វិវេកជំ បីតិសុខំ បឋមំ ឈានំ ឧបសម្បជ្ជ វិហរតិ ។ សោ ឥមមេវ កាយំ វិវេកជេន បីតិសុខេន អភិសន្ទេតិ បរិសន្ទេតិ[១] បរិបូរេតិ បរិប្ផរតិ នាស្ស កិញ្ចិ សព្វាវតោ កាយស្ស វិវេកជេន បីតិសុខេន អប្ផុដំ ហោតិ ។ សេយ្យថាបិ ភិក្ខវេ ទក្ខោ ន្ហាបកោ វា ន្ហាបកន្តេវាសី វា កំសថាលេ ន្ហានីយចុណ្ណានិ អាកិរិត្វា ឧទកេន បរិប្ផោសកំ បរិប្ផោសកំ សន្នេយ្យ ។ សាស្ស ន្ហានីយបិណ្ឌិ ស្នេហានុគតា ស្នេហបរេតា[២] សន្តរពាហិរា ផុដា ស្នេហេន ន ច បគ្ឃរិនី[៣]

១ ឱ. អភិសន្ទេតិ បរិសន្ទេតិ ។ ២ ឱ. ស្នេហានុគ្គតា ស្នេហប្បរេតោ ។ ៣ ឱ. ផុដា ស្នេហេន ច បគ្ឃរិនី ។

សុត្តន្តបិដក មជ្ឈិមនិកាយ ឧបរិបណ្ណាសកៈ

(៣០៣) ម្នាលភិក្ខុទាំងឡាយ មួយទៀត ភិក្ខុស្ងប់ស្ងាត់ចាកកាមទាំងឡាយ ស្ងប់ស្ងាត់ចាកធម៌ទាំងឡាយជាអកុសល ហើយចូលដល់បឋមជ្ឈាន ដែលប្រកបដោយវិតក្កៈ និងវិចារៈ មានបីតិនិងសុខៈដែលកើតអំពីសេចក្ដីស្ងប់ស្ងាត់ជាអារម្មណ៍ ។ ភិក្ខុនោះ ញុំាងករជកាយនេះឯងឲ្យជោកជាំ ឲ្យស្កប់ស្កល់ ឲ្យពេញលេញ ឲ្យផ្សព្វផ្សាយដោយបីតិនិងសុខៈ ដែលកើតអំពីសេចក្ដីស្ងប់ស្ងាប់ ឯកទេសបន្តិចបន្តួចនៃករជកាយទាំងអស់របស់ភិក្ខុនោះ ដែលឈ្មោះថាមិនផ្សព្វផ្សាយដោយបីតិនិងសុខៈ ដែលកើតអំពីសេចក្ដីស្ងប់ស្ងាត់ មិនមានឡើយ ។ ម្នាលភិក្ខុទាំងឡាយ ដូចជាជាងកោរកាត់ ឬកូនសិស្សរបស់ជាងកោរកាត់ ដែលប៉ិនប្រសប់ គេយកនូវលំអិតសម្រាប់ងូតទៅក្នុងផ្តិលសំរិទ្ធ ហើយស្រោចស្រប់ ច្របល់ដោយទឹក ។ ឯដុំលំអិតសម្រាប់ងូតនោះ ក៏រលាយទៅដោយទឹក ជ្រួតជ្រាបទៅក្នុងទឹក ប្រឡូកប្រឡំដោយទឹក ទាំងខាងក្នុងទាំងខាងក្រៅ មិនបានខ្ចាត់ខ្ចាយចេញពីគ្នាឡើយ ដូចម្ដេចមិញ

ឯវមេវ ខោ ភិក្ខវេ ភិក្ខុ ឥមមេវ កាយំ វិវេកជេន បីតិសុខេន អភិសន្ទេតិ បរិសន្ទេតិ បរិបូរេតិ បរិប្ផរតិ នាស្ស កិញ្ចិ សព្វាវតោ កាយស្ស វិវេកជេន បីតិសុខេន អប្ផុដំ ហោតិ ។ តស្ស ឯវំ អប្បមត្តស្ស ។ បេ ។ ឯវម្បិ ភិក្ខវេ ភិក្ខុ កាយគតំ សតឹ ភាវេតិ ។

(៣០៨) បុន ចបរំ ភិក្ខវេ ភិក្ខុ វិតក្កវិចារានំ វូបសមា ។ បេ ។ [១] ទុតិយំ ឈានំ ឧបសម្បជ្ជ វិហរតិ ។ សោ ឥមមេវ កាយំ សមាធិជេន បីតិសុខេន អភិសន្ទេតិ បរិសន្ទេតិ បរិបូរេតិ បរិប្ផរតិ នាស្ស កិញ្ចិ សព្វាវតោ កាយស្ស សមាធិជេន បីតិសុខេន អប្ផុដំ ហោតិ ។ សេយ្យថាបិ ភិក្ខវេ ឧទករហទោ ឧព្ភិទោទកោ នេវស្ស [២] បុរត្ថិមាយ ទិសាយ ឧទកស្សាយមុខំ ន បច្ឆិមាយ ទិសាយ ឧទកស្សាយមុខំ ន ឧត្តរាយ ទិសាយ ឧទកស្សាយមុខំ ន ទក្ខិណាយ ទិសាយ ឧទកស្សាយមុខំ ។ ទេវោ ច កាលេន កាលំ សម្មាធារំ អនុប្បវេច្ឆេយ្យ ។

១ ឱ. បេយ្យាលោ ន ទិស្សតិ ។ ២ ឱ. តស្ស នេវស្ស ។

ម្នាលភិក្ខុទាំងឡាយ ភិក្ខុញ៉ាំងករជកាយនេះឯង ឲ្យជោកជាំ ឲ្យស្កប់ស្កល់ ឲ្យពេញលេញ ឲ្យផ្សព្វផ្សាយ ដោយបីតិនិងសុខៈ ដែលកើតអំពីសេចក្តីស្ងប់ស្ងាត់ ឯកទេសបន្តិចបន្តួច នៃករជកាយទាំងអស់របស់ភិក្ខុនោះ ដែលឈ្មោះថា មិនផ្សព្វផ្សាយដោយបីតិនិងសុខៈ ដែលកើតអំពីសេចក្តីស្ងប់ស្ងាត់ មិនមានឡើយ ក៏យ៉ាងនោះឯង ។ កាលភិក្ខុនោះ មិនប្រមាទយ៉ាងនេះហើយ ។ បេ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុចម្រើនកាយគតាសតិ ដោយវិធីយ៉ាងនេះក៏បាន ។

(៣០៤) ម្នាលភិក្ខុទាំងឡាយ មួយទៀត ភិក្ខុព្រោះរម្ងាប់វិតក្កៈ វិចារៈ ។ បេ ។ ក៏បានចូលទុតិយជ្ឈាន ។ ភិក្ខុនោះញ៉ាំងករជកាយនេះឯង ឲ្យជោកជាំ ឲ្យស្កប់ស្កល់ ឲ្យពេញលេញ ឲ្យផ្សព្វផ្សាយដោយបីតិនិងសុខៈ ដែលកើតអំពីសមាធិគឺបឋមជ្ឈាន ឯកទេសបន្តិចបន្តួចនៃករជកាយទាំងអស់របស់ភិក្ខុនោះ ដែលឈ្មោះថាមិនផ្សព្វផ្សាយដោយបីតិនិងសុខៈ ដែលកើតអំពីសមាធិ មិនមានឡើយ ។ ម្នាលភិក្ខុទាំងឡាយ ដូចជាអន្លង់ទឹកជ្រៅ មានទឹកជោរឡើង ប្រឡាយទឹកក្នុងទិសខាងកើតក៏មិនមាន ប្រឡាយទឹកក្នុងទិសខាងលិចក៏មិនមាន ប្រឡាយទឹកក្នុងទិសខាងជើងក៏មិនមាន ទាំងប្រឡាយទឹកក្នុងទិសខាងត្បូងក៏មិនមាន ។ មួយយ៉ាងទៀត ភ្លៀងបង្អុរនូវធារទឹក ស្រួលសព្វ ៗ កាលទៅ ។

អថខោ តម្ហា ច ឧទករហទា សីតា វារិធារា ឧព្ភិជ្ជិត្វា តមេវ ឧទករហទំ សីតេន វារិនា អភិសន្ទេយ្យ បរិសន្ទេយ្យ បរិបូរេយ្យ បរិប្ផរេយ្យ នាស្ស កិញ្ចិ សព្វាវតោ ឧទករហទស្ស សីតេន វារិនា អប្ផុដំ អស្ស ឯវមេវ ខោ ភិក្ខវេ ភិក្ខុ ឥមមេវ កាយំ សមាធិជេន បីតិសុខេន អភិសន្នេតិ បរិសន្នេតិ បរិបូរេតិ បរិប្ផរេតិ នាស្ស កិញ្ចិ សព្វាវតោ កាយស្ស សមាធិជេន បីតិសុខេន អប្ផុដំ ហោតិ ។ តស្ស ឯវំ អប្ប-មត្តស្ស ។ បេ ។ ឯវម្បិ ភិក្ខវេ ភិក្ខុ កាយគតំ សតឹ ភាវេតិ ។

(៣០៥) បុន ចបរំ ភិក្ខវេ ភិក្ខុ បីតិយា ច វិរាគា ។ បេ ។ តតិយំ ឈានំ ឧបសម្បជ្ជ វិហរតិ ។ សោ

១ ឱ. តម្ហា ម. តម្ហា ច ។

ក៏ស្រាប់តែទឹកត្រជាក់ផុសចេញ អំពីអន្លង់ទឹកនោះ ហើយញ៉ាំងអន្លង់ទឹកនោះឯង ឲ្យត្រជាក់ ឲ្យពោរពេញ ឲ្យបរិបូណ៌ ឲ្យហូរហៀរដោយទឹកត្រជាក់ (នោះ) ឯកទេសបន្តិចបន្តួចនៃអន្លង់ទឹកទាំងអស់នោះ ដែលឈ្មោះថាមិនផ្សព្វផ្សាយ ដោយទឹកត្រជាក់ មិនមានឡើយ ដូចម្តេចមិញ ម្នាលភិក្ខុទាំងឡាយ ភិក្ខុញ៉ាំងករជកាយនេះឯង ឲ្យជោកជាំ ឲ្យស្កប់ស្កល់ ឲ្យពេញលេញ ឲ្យផ្សព្វផ្សាយដោយបីតិនិងសុខៈ ដែលកើតអំពីសមាធិ ឯកទេសបន្តិចបន្តួចនៃករជកាយទាំងអស់របស់ភិក្ខុនោះ ដែលឈ្មោះថាមិនផ្សព្វផ្សាយ ដោយបីតិនិងសុខៈ ដែលកើតអំពីសមាធិ មិនមានឡើយ ក៏យ៉ាងដូច្នោះឯង ។ កាលភិក្ខុនោះ មិនប្រមាទយ៉ាងនេះហើយ ។ បេ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុចម្រើនកាយគតាសតិ ដោយអាការយ៉ាងនេះក៏បាន ។

[៣០៥] ម្នាលភិក្ខុទាំងឡាយ មួយទៀត ភិក្ខុព្រោះនឿយណាយចាកបីតិផង ។ បេ ។ ក៏បានដល់តតិយជ្ឈាន ។ ភិក្ខុនោះ

ឥមមេវ កាយំ និប្បីតិកេន សុខេន អភិសន្ទេតិ បរិ-
សន្ទេតិ បរិបូរេតិ បរិប្ផរតិ នាស្ស កិញ្ចិ សព្វាវតោ
កាយស្ស និប្បីតិកេន សុខេន អប្ផុដំ ហោតិ ។
សេយ្យថាបិ ភិក្ខវេ ឧប្បលិនិយំ វា បទុមិនិយំ វា
បុណ្ឌរីកិនិយំ វា អប្បេកច្ចានិ ឧប្បលានិ វា បទុមា-
និ វា បុណ្ឌរីកានិ វា ឧទកេ ជាតានិ ឧទកេ
សម្ពទ្ធានិ(១) ឧទកានុគ្គតានិ អន្តោនិមុគ្គបោសិតានិ(២)
យាវ ច អគ្គា(៣) យាវ ច មូលា សីតេន វារិនា អភិ-
សន្នានិ បរិសន្នានិ បរិបូរានិ បរិប្ផុដានិ នាស្ស កិញ្ចិ
សព្វាវតំ ឧប្បលានំ វា បទុមានំ វា បុណ្ឌរីកានំ វា
សីតេន វារិនា អប្ផុដំ អស្ស ឯវមេវ ខោ ភិក្ខវេ ភិក្ខុ
ឥមមេវ កាយំ និប្បីតិកេន សុខេន អភិសន្ទេតិ បរិ-
សន្ទេតិ បរិបូរេតិ បរិប្ផរតិ នាស្ស កិញ្ចិ សព្វាវតោ
កាយស្ស និប្បីតិកេន សុខេន អប្ផុដំ ហោតិ ។
តស្ស ឯវំ អប្បមត្តស្ស ។ បេ ។ ឯវម្បិ ភិក្ខវេ ភិក្ខុ
កាយគតំ សតឹ ភាវេតិ ។

---

១ ឱ. សម្ពុទ្ធានិ ។ ម. សំវុទ្ធានិ ។ ២ ឱ. ម. អន្តោនិមុគ្គបោសីនិ ពាទ័ ។ ៣ ឱ. បគ្គា ។

ញ៉ាំងករជកាយនេះឯង ឲ្យជោកជាំ ឲ្យស្កប់ស្កល់ ឲ្យពេញលេញ ឲ្យផ្សព្វផ្សាយដោយសុខៈ ដែលប្រាសចាកបីតិ ឯកទេសបន្តិចបន្តួចនៃករជកាយទាំងអស់របស់ភិក្ខុនោះ ដែលឈ្មោះថា មិនផ្សព្វផ្សាយដោយសុខៈ ដែលប្រាសចាកបីតិ មិនមានឡើយ ។ ម្នាលភិក្ខុទាំងឡាយ ដូចជាផ្កាផលជាតិពួកខ្លះ គឺផ្កាព្រលិតក្ដី ផ្កាឈូកក្រហមក្ដី ផ្កាឈូកសក្ដី ក្នុងគុម្ពនៃព្រលិតក្ដី ក្នុងគុម្ពនៃឈូកក្រហមក្ដី ក្នុងគុម្ពនៃឈូកសក្ដី តែងកើតឡើងក្នុងទឹក ចម្រើនឡើងក្នុងទឹក លូតលាស់ឡើងតាមទឹក លិចនៅក្នុងទឹក ជោកជាំ ឆ្អែតស្កប់ស្កល់ បរិបូណ៌ ផ្សព្វផ្សាយ ដោយទឹកត្រជាក់ តាំងអំពីចុងរហូតដល់គល់ ឯកទេសបន្តិចបន្តួចនៃផ្កាផលជាតិទាំងអស់នោះ គឺព្រលិតក្ដី ឈូកក្រហមក្ដី ឈូកសក្ដី ដែលឈ្មោះថាមិនផ្សព្វផ្សាយដោយទឹកត្រជាក់នោះ មិនមានឡើយ ដូចម្ដេចមិញ ម្នាលភិក្ខុទាំងឡាយ ភិក្ខុញ៉ាំងករជកាយនេះឯង ឲ្យជោកជាំ ឲ្យឆ្អែតស្កប់ស្កល់ ឲ្យពេញលេញ ឲ្យផ្សព្វផ្សាយ ដោយសុខៈដែលមិនមានបីតិ ឯកទេសបន្តិចបន្តួចនៃករជកាយទាំងអស់របស់ភិក្ខុនោះ ដែលឈ្មោះថាមិនផ្សព្វផ្សាយដោយសុខៈ ដែលមិនមានបីតិនោះមិនមានឡើយ ដូច្នោះឯង ។ កាលភិក្ខុនោះមិនប្រមាទយ៉ាងនេះហើយ ។ បេ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុចម្រើនកាយគតាសតិ ដោយវិធីយ៉ាងនេះក៏បាន ។

(៣០៦) បុន ចបរំ ភិក្ខវេ ភិក្ខុ សុខស្ស ច ប-ហានា ។ បេ ។ ចតុត្ថំ ឈានំ ឧបសម្បជ្ជ វិហរតិ ។ សោ ឥមមេវ កាយំ បរិសុទ្ធេន ចេតសា បរិយោទាតេន ផរិត្វា និសិន្នោ ហោតិ នាស្ស កិញ្ចិ សព្វាវតោ កាយស្ស បរិសុទ្ធេន ចេតសា បរិយោទាតេន អប្ផុដំ ហោតិ ។ សេយ្យថាបិ ភិក្ខវេ បុរិសោ ឱទាតេន វត្ថេន សសីសំ បារុបិត្វា និសិន្នោ អស្ស នាស្ស កិញ្ចិ សព្វាវតោ កាយស្ស ឱទាតេន វត្ថេន អប្ផុដំ អស្ស ឯវមេវ ខោ ភិក្ខវេ ភិក្ខុ ឥមមេវ កាយំ បរិសុទ្ធេន ចេតសា បរិយោទាតេន ផរិត្វា និសិន្នោ ហោតិ នាស្ស កិញ្ចិ សព្វាវតោ កាយស្ស បរិសុទ្ធេន ចេតសា បរិយោទាតេន អប្ផុដំ ហោតិ ។ តស្ស ឯវំ អប្បមត្តស្ស អាតាបិនោ បហិតត្តស្ស វិហរតោ យេ គេហសិតា សរសង្កប្បា តេ បហីយន្តិ ។ តេសំ បហានា អជ្ឈត្តមេវ ចិត្តំ

[៣០៦] ម្នាលភិក្ខុទាំងឡាយ មួយទៀត ភិក្ខុព្រោះលះបង់នូវសេចក្តីសុខផង ។ បេ ។ ក៏ចូលកាន់ចតុត្ថជ្ឈាន ។ ភិក្ខុនោះក៏ផ្សព្វផ្សាយនូវករជកាយនេះឯង ដោយចិត្តដ៏បរិសុទ្ធ ផូរផង់ អង្គុយនៅ ឯកទេសបន្តិចបន្តួចនៃករជកាយទាំងអស់របស់ភិក្ខុនោះ ដែលឈ្មោះថា មិនផ្សព្វផ្សាយ ដោយចិត្តដ៏បរិសុទ្ធ ផូរផង់នោះ មិនមានឡើយ ។ ម្នាលភិក្ខុទាំងឡាយ ដូចជាបុរសយកសំពត់សមកដណ្តប់កាយព្រមទាំងក្បាលអង្គុយនៅ ឯកទេសបន្តិចបន្តួចនៃករជកាយទាំងអស់ របស់បុរសនោះ ដែលឈ្មោះថាមិនផ្សព្វផ្សាយ ដោយសំពត់សនោះ មិនមានឡើយ ដូចម្តេចមិញ ម្នាលភិក្ខុទាំងឡាយ ភិក្ខុផ្សព្វផ្សាយនូវករជកាយនេះឯង ដោយចិត្តដ៏បរិសុទ្ធ ផូរផង់ អង្គុយនៅ ឯកទេសបន្តិចបន្តួចនៃករជកាយទាំងអស់របស់ភិក្ខុនោះ ដែលឈ្មោះថា មិនផ្សព្វផ្សាយដោយចិត្តដ៏បរិសុទ្ធ ផូរផង់នោះ មិនមានឡើយ ក៏ដូច្នោះឯង ។ កាលភិក្ខុនោះ មិនប្រមាទ មានព្យាយាមជាគ្រឿងដុតកំដៅកិលេស មានចិត្តបញ្ជូនទៅកាន់ព្រះនិព្វាន យ៉ាងនេះហើយ ក៏លះបង់នូវសេចក្តីត្រិះរិះដែលស្ទុះទៅ ដែលអាស្រ័យកាមគុណទាំង ៥ បាន ។ ព្រោះលះបង់នូវសេចក្តីត្រិះរិះដែលស្ទុះទៅទាំងអម្បាលនោះបានហើយ ចិត្តខាងក្នុង

សណ្ឋិដ្ឋតិ សន្និសីទតិ ឯកោទិ ហោតិ សមាធិយតិ ឯវម្បិ ភិក្ខវេ ភិក្ខុ កាយគតំ សតឹ ភាវេតិ ។

(៣០៧) យស្ស កស្សចិ ភិក្ខវេ កាយគតា សតិ ភាវិតា ពហុលីកតា អន្តោគធា តស្ស កុសលា ធម្មា យេ កេចិ វិជ្ជាភាគិយា ។ សេយ្យថាបិ ភិក្ខវេ យស្ស កស្សចិ មហាសមុទ្ទោ ចេតសា ផុដោ អន្តោគធា តស្ស កុន្នទិយោ យា កាចិ សមុទ្ទង្គមា ឯវមេវ ខោ ភិក្ខវេ យស្ស កស្សចិ កាយគតា សតិ ភាវិតា ពហុលិកតា អន្តោគធា តស្ស កុសលា ធម្មា យេ កេចិ វិជ្ជាភាគិយា ។

(៣០៨) យស្ស កស្សចិ ភិក្ខវេ កាយគតាសតិ អភាវិតា អពហុលីកតា លភតិ តស្ស មារោ ឱតារំ លភតិ តស្ស មារោ អារម្មណំ ។ សេយ្យថាបិ ភិក្ខវេ បុរិសោ គរុកំ សិលាគុឡំ អល្លមត្តិកាបុញ្ជេ បក្ខិ-បេយ្យ ។ តំ កឹ មញ្ញថ ភិក្ខវេ អបិ នុ តំ គរុកំ

ក៏តំកល់មាំ តំកល់ខ្ជាប់ ដល់នូវភាវៈខ្ពស់ឯក ឈ្មោះថាភិក្ខុតំកល់មាំ ម្នាលភិក្ខុទាំងឡាយ ភិក្ខុចំរើនកាយគតាសតិ ដោយវិធីយ៉ាងនេះក៏បាន ។

(៣០៧) ម្នាលភិក្ខុទាំងឡាយ កាយគតាសតិដែលភិក្ខុណាមួយ បានចំរើន បានធ្វើឲ្យច្រើនៗ ហើយ ភិក្ខុនោះ ឈ្មោះថាមានកុសលធម៌ណាមួយ ជាចំណែកនៃវិជ្ជា តាំងនៅក្នុងសន្តានបាន ។ ម្នាលភិក្ខុទាំងឡាយ ដូចមហាសមុទ្រ ដែលភិក្ខុណាមួយ បានផ្សាយចិត្តទៅហើយ ភិក្ខុនោះឈ្មោះថាមានស្ទឹងតូច ៗ ទាំងឡាយណាមួយ ដែលហូរមកកាន់សមុទ្រ ក៏តាំងនៅក្នុងសន្តានចិត្ត ដូចម្ដេចមិញ ម្នាលភិក្ខុទាំងឡាយ កាយគតាសតិដែលភិក្ខុណាមួយបានចំរើន បានធ្វើឲ្យច្រើន ៗ ហើយ ភិក្ខុនោះឈ្មោះថាមានកុសលធម៌ទាំងឡាយណាមួយ ដែលជាចំណែកនៃវិជ្ជា តាំងនៅក្នុងសន្តាន ដូច្នោះឯង ។

(៣០៨) ម្នាលភិក្ខុទាំងឡាយ កាយគតាសតិដែលភិក្ខុណាមួយ មិនបានចម្រើន មិនបានធ្វើឲ្យច្រើនៗ ហើយ មារក៏បានទៅចន្លោះ របស់ភិក្ខុនោះ មារក៏បាននូវអារម្មណ៍ របស់ភិក្ខុនោះ ។ ម្នាលភិក្ខុទាំងឡាយ ដូចជាបុរសបោលដុំថ្មដ៏ធ្ងន់ទៅលើគំនរដីជ្រាយ ។ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយសំគាល់សេចក្ដីនោះដូចម្ដេច ដុំថ្មដ៏ធ្ងន់នោះ

សិលាគុឡំ អល្លមត្តិកាបុញ្ជេ លភេថ ឱតារន្តិ ។ ឯវំ ភន្តេ ។ ឯវមេវ ខោ ភិក្ខវេ យស្ស កស្សចិ កាយគតា សតិ អភាវិតា អពហុលីកតា លភតិ តស្ស មារោ ឱតារំ លភតិ តស្ស មារោ អារម្មណំ ។

(៣០៩) សេយ្យថាបិ ភិក្ខវេ សុក្ខំ កដ្ឋំ កោឡាបំ ។ អថ បុរិសោ អាគច្ឆេយ្យ ឧត្តរារណឹ អាទាយ អគ្គឹ អភិនិព្វត្តេស្សាមិ តេជោ បាតុករិស្សាមីតិ ។ តំ កឹ មញ្ញថ ភិក្ខវេ អបិ នុ សោ អមុំ សុក្ខំ កដ្ឋំ កោឡាបំ ឧត្តរារណឹ អាទាយ អភិមត្ថេន្តោ អគ្គឹ អភិនិព្វត្តេយ្យ តេជោ បាតុករេយ្យាតិ ។ ឯវំ ភន្តេ ។ ឯវមេវ ខោ ភិក្ខវេ យស្ស កស្សចិ កាយគតា សតិ អភាវិតា អពហុលីកតា លភតិ តស្ស មារោ ឱតារំ លភតិ តស្ស មារោ អារម្មណំ ។

គួរនឹងបាននូវចន្លោះលើគំនរដីជ្រាយដែរឬ ។ ពួកភិក្ខុក្រាបបង្គំទូលថា ព្រះករុណា ព្រះអង្គ ។ ម្នាលភិក្ខុទាំងឡាយ កាយគតាសតិ ដែលភិក្ខុណាមួយ មិនបានចំរើន មិនបានធ្វើឲ្យរឿយ ៗ ហើយ មារតែងបាននូវចន្លោះរបស់ភិក្ខុនោះ មារតែងបានអារម្មណ៍របស់ភិក្ខុនោះ ដូច្នោះឯង ។

(៣០៩) ម្នាលភិក្ខុទាំងឡាយ ដូចជាឈើស្ងួតក្រៀម ។ វេលានោះ មានបុរសមកនាំយកឈើពិនួតខាងលើដោយគិតថា អាត្មាអញនឹងញ៉ាំងភ្លើងឲ្យកើតឡើង អាត្មាអញនឹងធ្វើតេជោធាតុ (ឲ្យកើតឡើង) ។ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយសំគាល់សេចក្តីនោះដូចម្តេច បុរសនោះនាំយកឈើពិនួតខាងលើ មកពួតនឹងឈើស្ងួតក្រៀមឯណោះ ឲ្យកើតជាភ្លើងឡើង ធ្វើឲ្យទៅជាតេជោធាតុ បានដែរឬ ។ ពួកភិក្ខុក្រាបបង្គំទូលថា ព្រះករុណា ព្រះអង្គ ធ្វើបាន ។ ម្នាលភិក្ខុទាំងឡាយ រឿងនេះមានឧបមេយ្យដូច កាយគតាសតិ ដែលភិក្ខុណាមួយ មិនបានចំរើន មិនបានធ្វើឲ្យរឿយ ៗ ហើយ មារតែងបាននូវចន្លោះ របស់ភិក្ខុនោះ មារតែងបាននូវអារម្មណ៍របស់ភិក្ខុនោះ ។

(៣១០) សេយ្យថាបិ ភិក្ខវេ ឧទកមណិកោ រិត្តោ តុច្ឆោ អាធារេ ឋបិតោ[១] ។ អថ បុរិសោ អាគច្ឆេយ្យ ឧទកភារំ អាទាយ ។ តំ កឹ មញ្ញថ ភិក្ខវេ អបិ នុ សោ បុរិសោ លភេថ ឧទកស្ស និក្ខេបនន្តិ ។ ឯវំ ភន្តេ ។ ឯវមេវ ខោ ភិក្ខវេ យស្ស កស្សចិ កាយគតា សតិ អភាវិតា អពហុលីកតា លភតិ តស្ស មារោ ឱតារំ លភតិ តស្ស មារោ អារម្មណំ ។

(៣១១) យស្ស កស្សចិ ភិក្ខវេ កាយគតា សតិ ភាវិតា ពហុលីកតា ន តស្ស លភតិ មារោ ឱតារំ ន តស្ស លភតិ មារោ អារម្មណំ ។ សេយ្យថាបិ ភិក្ខវេ បុរិសោ លហុកំ សុត្តគុឡំ សព្វសារមយេ អគ្គឡផលកេ បក្ខិបេយ្យ ។ តំ កឹ មញ្ញថ ភិក្ខវេ អបិ នុ តំ[២] លហុកំ សុត្តគុឡំ សព្វសារមយេ អគ្គឡផលកេ លភេថ ឱតារន្តិ ។ នោ ហេតំ ភន្តេ ។ ឯវមេវ ខោ ភិក្ខវេ យស្ស កស្សចិ កាយគតា សតិ

១ ឱ. បិតោ ។ ២ អបិ នុ សោ បុរិសោ តត្ថិប្បត្តំ ។

(៣១០) ម្នាលភិក្ខុទាំងឡាយ ដូចជាក្អមទឹកស្ងួតទទេ ដែលគេដាក់លើជើងសម្រាប់វា ។ វេលានោះមានបុរសទៅនាំយកទឹកមកចាក់ (ក្នុងក្អមនោះ) ។ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយសំគាល់សេចក្តីនោះដូចម្តេច បុរសនោះគួរនឹងចាក់ទឹក (ក្នុងក្អមនោះ) បានដែរឬ ។ ពួកភិក្ខុក្រាបបង្គំទូលថា ព្រះករុណា ព្រះអង្គ ។ ម្នាលភិក្ខុទាំងឡាយ កាយគតាសតិដែលភិក្ខុណាមួយ មិនបានចម្រើន មិនបានធ្វើឲ្យច្រើន ៗ ហើយ មារតែងបាននូវចន្លោះរបស់ភិក្ខុនោះ មារតែងបាននូវអារម្មណ៍របស់ភិក្ខុនោះ ក៏យ៉ាងដូច្នោះឯង ។

(៣១១) ម្នាលភិក្ខុទាំងឡាយ កាយគតាសតិដែលភិក្ខុណាមួយ បានចំរើន បានធ្វើឲ្យច្រើនៗ ហើយ មារមិនបាននូវចន្លោះរបស់ភិក្ខុនោះ មារមិនបាននូវអារម្មណ៍របស់ភិក្ខុនោះឡើយ ។ ម្នាលភិក្ខុទាំងឡាយ ដូចជាបុរសដាក់ដុំអម្បោះដ៏ស្រាលទៅលើសន្ទឹកទ្វារ ដែលធ្វើពីឈើខ្លឹមសុទ្ធ ។ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយសំគាល់សេចក្តីនោះដូចម្តេច ដុំអម្បោះដ៏ស្រាលនោះ គួរនឹងបាននូវចន្លោះលើសន្ទឹកទ្វារ ដែលធ្វើពីឈើខ្លឹមសុទ្ធដែរឬ ។ ភិក្ខុទាំងឡាយក្រាបបង្គំទូលថា មិនបានទេ ព្រះអង្គ ។ ម្នាលភិក្ខុទាំងឡាយ កាយគតាសតិដែលភិក្ខុណាមួយ

ភាវិតា ពហុលីកតា ន តស្ស លភតិ មារោ ឱតារំ ន តស្ស លភតិ មារោ អារម្មណំ ។

(៣១២) សេយ្យថាបិ ភិក្ខវេ អល្លំ កដ្ឋំ សសេ្នហំ(១) ។ អថ បុរិសោ អាគច្ឆេយ្យ ឧត្តរារណឹ អាទាយ អគ្គឹ អភិនិព្វត្តេស្សាមិ តេជោ បាតុករិស្សាមីតិ ។ តំ កឹ មញ្ញថ ភិក្ខវេ អបិ នុ សោ បុរិសោ អមុំ អល្លំ កដ្ឋំ សសេ្នហំ ឧត្តរារណឹ អាទាយ អភិមន្ថេន្តោ អគ្គឹ អភិនិព្វត្តេយ្យ តេជោ បាតុករេយ្យាតិ ។ នោ ហេតំ ភន្តេ ។ ឯវមេវ ខោ ភិក្ខវេ យស្ស កស្សចិ កាយគតា សតិ ភាវិតា ពហុលីកតា ន តស្ស លភតិ មារោ ឱតារំ ន តស្ស លភតិ មារោ អារម្មណំ ។

(៣១៣) សេយ្យថាបិ ភិក្ខវេ ឧទកមណិកោ បូរោ ឧទកស្ស សមតិត្តិកោ កាកបេយ្យោ អាធារេ ឋបិតោ ។ អថ បុរិសោ អាគច្ឆេយ្យ ឧទកការំ អាទាយ ។ តំ កឹ មញ្ញថ ភិក្ខវេ

១ ឱ. ម. សស្នេហំ ។

បានចម្រើន បានធ្វើឲ្យរឿយៗ ហើយ មារមិនបាននូវចន្លោះរបស់ភិក្ខុនោះ មារមិនបាននូវអារម្មណ៍របស់ភិក្ខុនោះ ក៏យ៉ាងនោះឯង ។

(៣១២) ម្នាលភិក្ខុទាំងឡាយ ដូចជាឈើស្រស់ដែលប្រកបដោយជ័រ ។ វេលានោះមានបុរសទៅយកឈើពិនួតភ្លើងខាងលើមកដោយគិតថា អាត្មាអញនឹងញុំាងភ្លើងឲ្យកើតឡើង អាត្មាអញនឹងធ្វើតេជោធាតុ (ឲ្យកើតឡើង) ។ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយ សំគាល់នូវហេតុនោះដូចម្តេច បុរសនោះនាំយកឈើពិនួតភ្លើងខាងលើមកពួតនឹងឈើស្រស់ ដែលប្រកបដោយជ័រឯណោះ គួរឲ្យកើតជាភ្លើង គួរឲ្យទៅជាតេជោធាតុបានដែរឬ ។ ភិក្ខុទាំងឡាយក្រាបបង្គំទូលថា មិនបានទេ ព្រះអង្គ ។ ម្នាលភិក្ខុទាំងឡាយ កាយគតាសតិដែលភិក្ខុណាមួយបានចំរើន បានធ្វើឲ្យរឿយៗ ហើយ មារមិនបាននូវចន្លោះរបស់ភិក្ខុនោះ មារមិនបាននូវអារម្មណ៍ របស់ភិក្ខុនោះឡើយ ក៏យ៉ាងដូច្នោះឯង ។

(៣១៣) ម្នាលភិក្ខុទាំងឡាយ ដូចជាក្អមទឹកដ៏ពេញដោយទឹកស្មើត្រឹមកណ្តាប់មាត់ ល្មមក្អែកផឹកបាន ដែលគេដាក់លើជើងសម្រាប់វង ។ ប្រសិនបើមានបុរសទៅដងទឹកយកមកចាក់ថែម (ក្នុងក្អមនោះទៀត) ។ ម្នាលភិក្ខុទាំងឡាយ តើអ្នកទាំងឡាយសំគាល់នូវហេតុនោះ

អបិ នុ សោ បុរិសោ លភេថ ឧទកស្ស និក្ខេបនន្តិ ។ នោ ហេតំ ភន្តេ ។ ឯវមេវ ខោ ភិក្ខវេ យស្ស កស្សចិ កាយគតា សតិ ភាវិតា ពហុលីកតា ន តស្ស លភតិ មារោ ឱតារំ ន តស្ស លភតិ មារោ អារម្មណំ ។

